# ប្រវត្តិសាស្ត្រសង្ខេប
# នៃប្រទេសកម្ពុជា

បោះពុម្ពជាថ្មីឡើងវិញ

## តាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់
## សម្តេចក្រឡាហោម ស ខេង

## ឆ្នាំ២០២៦


MONGKOL

**-សហការីពិនិត្យអក្ខរាវិរុទ្ធ ៖**

១. ឯកឧត្តម ឈឹម សេរីភ្ជួន

២. លោក រ៉ាំ សារឿន

**-ការីកុំព្យូទ័រ**

១. លោក រ៉ាំ សារឿន

២. លោក ឈឹម មករា

៣. លោក ប៉ោ កុសល



## សម្តេចក្រឡាហោម ស ខេង

[illegible]
[illegible]
[illegible]
[illegible] ។

ស ខេង
08.02.26

# មូលហេតុ និងគោលបំណង

**សម្តេចក្រឡាហោម ស ខេង** ជាមេដឹកនាំប្រកប ដោយគតិបណ្ឌិត និងមានមនសិកាប្រវត្តិសាស្ត្រជាតិដ៏ខ្ពង់ខ្ពស់ បានសង្កេតឃើញថា **សៀវភៅប្រវត្តិសាស្ត្រសង្ខេប នៃប្រទេសកម្ពុជា** ដែលនិពន្ធចងក្រងដោយអ្នកប្រវត្តិសាស្ត្រសូវៀត មួយក្រុម និងបានបកប្រែជាខេមរភាសា ដោយបណ្ឌិតអក្សរសាស្ត្រ **ឡុង សៀម** ហើយបានបោះពុម្ពផ្សាយតាំងពីឆ្នាំ ១៩៨៥ មកនោះ លុះមកដល់ពេលបច្ចុប្បន្ន មានការពុកផុយស្ទើរទាំងស្រុងទៅហើយ **សម្តេច** បានណែនាំមកឯកឧត្តមសន្តិបណ្ឌិត **ខៀវ សុភ័គ** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ ឱ្យចាត់ចែងបោះពុម្ពសៀវភៅនេះ ជាថ្មីឡើងវិញ ដោយរក្សាខ្លឹមសារដើមទាំងស្រុង ក្នុងគោលបំណងទុកជាប្រយោជន៍ដល់សិស្ស និស្សិត មន្ត្រីរាជការ និង សាធារណជនទូទៅ ធ្វើការសិក្សាស្រាវជ្រាវតាមការចាំបាច់។

សូមអរគុណ!

ថ្ងៃសុក្រ ១៣កើត ខែជេស្ឋ ឆ្នាំមមី អដ្ឋស័ក ព.ស. ២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែឧសភា ឆ្នាំ២០២៦

**ប្រធានក្រុមរៀបចំបោះពុម្ពសៀវភៅជាថ្មីឡើងវិញ**

**ឈឹម សេរីវុទ្ធន**

# ប្រវត្តិសាស្ត្រសង្ខេប
# នៃប្រទេសកម្ពុជា

អ្នកនិពន្ធនាយក យ.យ.មីហេយេវ

**អង្គការបោះពុម្ពផ្សាយ**
**" ប្រូហ្គ្រេស្ស "**
**មូស្គូ**

បណ្ឌិតសភាវិជ្ជាសាស្ត្រ ស.ស.ស.ស.
វិជ្ជាស្ថាននៃបុរាណសាស្ត្រ

ការបកប្រែ និងការចងក្រងកែតម្រូវអត្ថបទជាភាសាខ្មែរ
ដោយបណ្ឌិតអក្សរសាស្ត្រ ឡុង សៀម

Краткая история
Кампучии
*на кхмерском языке*

© ការិយាល័យនិពន្ធនាយកផ្នែកអក្សរសិល្ប៍បូព៌ា នៃអង្គការបោះពុម្ពផ្សាយ " ណាអ៊ូកា " ឆ្នាំ១៩៨១

© អារម្ភកថា យោបល់រួម ការបកប្រែភាសាខ្មែរ ដោយមានការកែប្រែខ្លះ របស់អង្គការបោះពុម្ពផ្សាយ " ប្រូហ្គ្រេស្ស " ឆ្នាំ១៩៨៥

$К\frac{0506000000-150}{014(01)-85}$ без объявл.

បោះពុម្ពនៅសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត

# អារម្ភកថា

ប្រទេសកម្ពុជា គឺជារដ្ឋមួយដ៏បូរាណជាងគេនៅអាស៊ីអាគ្នេយ៍។ ប៉ុន្តែ គួរឱ្យស្តាយ រហូតមកដល់ពេលបច្ចុប្បន្ន គេពុំឃើញមានស្នាដៃណាមួយដែលបានធ្វើអត្ថាធិប្បាយ ពេញលេញអំពីប្រវត្តិសាស្ត្រ នៃប្រទេសកម្ពុជា តាំងពីសម័យបូរមបូរាណរហូតដល់សម័យបច្ចុប្បន្ន។

សៀវភៅប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា ដែលយើងស្នើជូនដល់អ្នកអានទាំងឡាយ គឺជាស្នាដៃទីមួយបែបនេះ ដែលត្រូវបាននិពន្ធឡើងតាមទស្សនៈម៉ាក្ស - ឡេនីននិយម។

ដោយយោងទៅតាមការចាំបាច់ គឺមិនបោះបង់ចោលព្រឹត្តិការណ៍ប្រវត្តិសាស្ត្រណាមួយ ពីបណ្តាព្រឹត្តិការណ៍ទាំងឡាយ ហើយពិនិត្យពិចារណាព្រឹត្តិការណ៍ទាំងនេះ នៅក្នុងកន្សោមនៃទំនាក់ទំនងដ៏ជិតស្និទ្ធ ពីព្រឹត្តិការណ៍មួយទៅមួយទៀត អ្នកនិពន្ធសៀវភៅបានអធិប្បាយអំពីប្រវត្តិសាស្ត្រនៃការចាប់បដិសន្ធិ និងការវិវត្តនៃប្រទេសកម្ពុជា។

នៅក្នុងប្រព័ន្ធ នៃសភាពការណ៍ទូទៅដែលបានកើតមានឡើងនៅលើឧបទ្វីបឥណ្ឌូចិន និងនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាទូទៅ។

អារ្យធម៌ខ្មែរ ឯករាជ្យ និងប្រកបដោយលក្ខណៈដើមពិសេសផ្ទាល់របស់ខ្លួន ក៏ដូចជាបណ្តាអារ្យធម៌ដទៃ បានវិវត្តទៅដោយមានការទាក់ទងដ៏ជិតស្និទ្ធនឹងការរីកចម្រើន ខាងផលិតកម្ម និងវប្បធម៌នៅក្នុងបណ្តាប្រទេសជិតខាង ដែលផ្តល់ឥទ្ធិពល និងភាពចម្រុងចម្រើនដល់គ្នាទៅវិញទៅមក។

នៅក្នុងសៀវភៅ មានអធិប្បាយជាពិសេសអំពីដំណាក់

កាលនៃការរីកចម្រើននៅក្នុងសង្គមខ្មែរ នៃមធ្យោបាយផលិតកម្ម ដើម្បីបំពេញសេចក្តីត្រូវការផ្នែកសម្ភារៈ មានទាំងកម្លាំងផលិតកម្ម និងទំនាក់ទំនងផលិតកម្ម ព្រោះថា ដូច ក.ម៉ាក្ស និងហ្វ + អង់ហ្គែល្ស បានគូសបញ្ជាក់រួចមកហើយ ជីវភាពខាងសម្ភារៈរបស់មនុស្ស គឺជាកម្លាំងសំខាន់បំផុត ដែលបញ្ជាក់នូវការរីកចម្រើនខាងសង្គមកិច្ច។ នៅពេលជាមួយគ្នា មានការពិភាក្សានូវបណ្តា ទំនាក់ទំនងខាងនយោបាយ សាសនា វប្បធម៌ និងដទៃទៀត ដោយហេតុថា ទំនាក់ទំនងទាំងនេះ ទោះបីមានកម្រិតមិនអាចសម្រេចសភាពការណ៍តែឯកឯងក្តី ក៏បានផ្តល់ឥទ្ធិពលរបស់ខ្លួនទៅលើដំណើរ នៃការរីកចម្រើនខាងសង្គមផងដែរ។

អ្នកនិពន្ធទាំងអស់នៃសៀវភៅនេះ មានបំណងបង្ហាញថា គឺប្រជាជនខ្មែរ ដែលជាអ្នកកសាងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ហើយនៅទីបំផុត គឺពលកម្មរបស់ប្រជាជនខ្មែរនេះហើយ ដែលបានបង្កបង្កើតនូវមហិទ្ធិឫទ្ធិនៃប្រទេសរបស់ខ្លួន។

ជាឧទាហរណ៍ដ៏ត្រចេះត្រចង់នៃមហិទ្ធិឫទ្ធិនេះ គឺបូរាណប្រាសាទអង្គរដ៏ឧត្តុង្គឧត្តម។ នៅក្នុងសៀវភៅមានសេចក្តីអធិប្បាយយ៉ាងល្អិតល្អន់អំពីចលនាកុបកម្ម កូដកម្ម និងបះបោរនានានៃប្រជាជន មានការវែកញែករកប្រភពខាងសង្គម-សេដ្ឋកិច្ចផ្សេងៗនៃចលនា មានការធ្វើវិភាគអំពីដំណើរការណ៍ និងមូលហេតុ នៃបរាជ័យនៃចលនាប្រជាជនទាំងនេះ។

មិនតែប៉ុណ្ណោះ នៅក្នុងសៀវភៅមានការយកចិត្តទុកដាក់ដល់ការអធិប្បាយអំពីការកកើតនៃរាជវង្សានុវង្សនានា ព្រមទាំងអំពីសកម្មភាពរបស់បណ្តាមហាក្សត្រគ្រប់គ្រងប្រទេសកម្ពុជា។

អ្នកនិពន្ធសៀវភៅ បានពិនិត្យមើលឡើងវិញដោយវិវេចនកថា នូវឯកសារជាគ្រឿងសម្ភារៈ ដែលត្រូវបានប្រើប្រាស់ជាពិសេស នៅក្នុងសេចក្តីបរិយាយអំពីជីវភាព និង “ បុព្វកិច្ច ” របស់បណ្តាមហាក្សត្រ របស់បណ្តាអ្នកប្រឆាំងមហាក្សត្រ និងរបស់បណ្តាមុខមន្ត្រីនានាជាបរិវារមហាក្សត្រ។

អ្នកនិពន្ធយល់ថា ត្រូវតែប្រើប្រាស់នូវអត្ថាធិប្បាយខ្លះៗនៃឯកសារទាំងនេះ។ ហេតុដូច្នេះហើយ បានជានៅក្នុងឧទាហរណ៍ខ្លះ នៅក្នុងសៀវភៅ មានការអធិប្បាយអំពីសកម្មភាពតិច ឬច្រើនរបស់មហាក្សត្រ ឬអ្នកដឹកនាំប្រទេសមួយនីមួយៗ ដែលបានយកចិត្តទុកដាក់បម្រើផលប្រយោជន៍នៃសង្គមខ្មែរ។

សៀវភៅប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា នេះ ចែកចេញជាបួនចំពូក៖

**<u>វគ្គទីមួយ</u>** ៖ អធិប្បាយអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា ពីសម័យបុរមបូរាណ ដល់ភាគពាក់កណ្តាលនៃសតវត្សរ៍ទី១៩។ ចំពោះព្រឹត្តិការណ៍នានាដ៏សំខាន់បំផុត នៃប្រវត្តិសាស្ត្រប្រទេសកម្ពុជា នាសម័យកាលដ៏បុរមបូរាណ ជាចាំបាច់ត្រូវតែអធិប្បាយអំពីការបង្កបង្កើត មជ្ឈមណ្ឌលលោហកម្មលង្ហិនមួយក្នុងបណ្តាមជ្ឈមណ្ឌល ដ៏ល្បីល្បាញ និងបូរាណ នាសម័យកាលពាក់កណ្តាលនៃសតវត្សរ៍ទី៤ (ពី៤០០០ឆ្នាំ) មុនគ្រឹស្តសករាជ ដោយបុព្វបុរសជនជាតិមន - ខ្មែរ អំពីកំណកំណើតនៃសង្គមប្រកបដោយវណ្ណៈ នាសម័យកាលនៃសតវត្សរ៍ទី១-ទី២ គ្រឹស្តសករាជ អំពីការបង្កើតរដ្ឋបាភ្នំ នាសតវត្សរ៍ទី២-ទី៤ អំពីការចាប់ផ្តើមបដិសន្ធិនៃរដ្ឋកម្ពុជា (ចេនឡា) នាសម័យកាលភាគ

ពាក់កណ្តាលនៃសតវត្សរ៍ទី៤ អំពីកំណកំណើតទំនាក់ទំនង សក្តិភូមិនាសម័យកាលនៃសតវត្សរ៍ទី៧។

ព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដ៏សំខាន់ពិសេស គឺការស្ថាបនានូវចក្រភពកម្ពុជទេស និងអភិវឌ្ឍនកម្មដ៏រុងរឿងនៃចក្រភព នាសម័យកាលចាប់ពីដើមសតវត្សរ៍ទី១១-ដល់ដើមសតវត្សរ៍ទី១៣។ ជាទូទៅ គេតែងហៅសម័យកាលនេះថាជា៖ “ សម័យអង្គរដ៏រុងរឿង ” ជាកិត្តិយសដល់បណ្តាបូរាណប្រាសាទអង្គរ ( យសោធរៈបុរៈ ) ដែលបានស្ថិតនៅដល់សម័យបច្ចុប្បន្ន។

ការបង្រួបបង្រួមដែនដីខ្មែរទាំងឡាយ បញ្ចូលមកក្នុងចក្រភពកម្ពុជទេស ដ៏ធំធេង ត្រូវបានរៀបចំឡើងដោយសាមគ្គីភាព ក្នុងនយោបាយអភិវឌ្ឍនកម្មខាងសេដ្ឋកិច្ច នៃដែនដីខ្មែរទាំងអម្បាលមាណ។ ហើយនៅទីនេះ ត្រូវតែគូសបញ្ជាក់ថា នៅសម័យតមក នយោបាយនេះ បានផ្តល់លទ្ធភាពបង្កើតបានជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រសំខាន់ៗ ដូចជាការបង្រួបបង្រួមរដ្ឋល្វោជារដ្ឋនៃជនជាតិមន ដែលជាបងប្អូននឹងជនជាតិខ្មែរ ឱ្យចូលក្នុងសមាសភាពនៃចក្រភពកម្ពុជទេស នាសម័យកាលភាគខាងដើមនៃសតវត្សរ៍ទី១១។ នៅសម័យនោះ មានការឃោសនាដ៏ទូលំទូលាយនៃពុទ្ធសាសនាថេរវាទ និងមានដំណើរចម្លងឈានឡើងជាចក្រភពកម្ពុជទេស ឯកជាតិ នាសម័យកាលនៃសតវត្សរ៍ទី១៣។ ចាប់តាំងពីសម័យកាលនោះមក ចក្រភពកម្ពុជទេស ត្រូវបានគេចាប់ផ្តើមហៅថា ជាប្រទេសកម្ពុជា។

❖ សតវត្សរ៍ទី១៤-ទី១៦ គឺជាសម័យកាលនៃភាពចុះអន់ថយនៅតំបន់រដ្ឋធានីយសោធរៈបុរៈ និងការផ្លាស់រដ្ឋធានីមកតាំងនៅមជ្ឈមណ្ឌលសេដ្ឋកិច្ចថ្មី គឺតំបន់ដីត្រីកោណលង្វែក -

ឧដុង្គ - ភ្នំពេញ។ នៅឆ្នាំ១៤៣៤ រដ្ឋធានីត្រូវបានផ្លាស់ពីយសោធរៈបុរៈ (តាំងពីពេលនោះមក គេបានហៅថា ជារាជធានីអង្គរ មានន័យថា ទីក្រុងមហាក្សត្រ មកតាំងនៅ "ចតុមុខ" រដ្ឋធានីភ្នំពេញ សព្វថ្ងៃ)។ ព្រឹត្តិការណ៍សំខាន់ៗសម័យនោះ ដែលអ្នកនិពន្ធសៀវភៅបានពិនិត្យ និងអធិប្បាយវែកញែកដ៏ក្បោះក្បាយ គឺជាចលនាកុបកម្មកសិករក្រោមកិច្ចដឹកនាំរបស់នាយកន (គ.ស. ១៤៩៤ - គ.ស.១៥១៥) ដែលមានត្រកូលជាប់ជាអ្នកខ្ញុំបម្រើរាជការមួយរូប គឺជាចលនាប្រកបដោយលក្ខណៈប្រឆាំងរបបសក្តិភូមិ ហើយមានទិសដៅស្នេហាជាតិនិយម ព្រមទាំងចលនាបះបោរក្រោមកិច្ចដឹកនាំរបស់នាយ កែវ នៅគ.ស.១៦០០ ដែលបានតាំងខ្លួនថា ជា " អ្នកមានបុណ្យ "។

សតវត្សរ៍ទី១៧-ទី១៨ បានចូលសន្និតក្នុងទំព័រប្រវត្តិសាស្ត្រប្រទេសកម្ពុជា ដូចជា សម័យកាលដែលជាពិសេសប្រកបដោយចម្បាំងហែកហួរគ្នាផ្ទៃក្នុងរវាងពួកសមាជិករាជវង្ស និងពួកសក្តិភូមិ និងដោយការបែកបាក់សាមគ្គីភាព ដែលបានបណ្តាលឱ្យមានការបែងចែកទឹកដីនៃប្រទេស។ សភាពការណ៍ទាំងនេះ បានផ្តល់លទ្ធភាពដល់បណ្តាប្រទេសជិតខាង ដែលនៅពេលនោះបានធ្វើដំណើរទៅមុខលឿនលើសប្រទេសកម្ពុជា នៅក្នុងវិស័យនៃការរីកចម្រើនខាងសេដ្ឋកិច្ច ហើយតមក ក៏បានចាប់ផ្តើមធ្វើយុទ្ធនាការវាយលុកចូលប្រទេសកម្ពុជា។ នៅពេលខាងចុងនៃសម័យកាលនោះ ប្រព័ន្ធអាណាព្យាបាលទ្វេភាគីបានកើតមានឡើងចំពោះប្រទេសកម្ពុជា ក្នុងទំនាក់ទំនងរបស់ខ្លួនជាមួយប្រទេសសៀម និងប្រទេសដាយវៀត (វៀតណាម)។ នៅពេលខាងចុងរវាងឆ្នាំទី៥០ និងទី៧០ នៃសតវត្សរ៍ទី១៨ ចលនា

កុបកម្មបះបោរកសិករ បានផ្ទុះឡើងប្រឆាំងនឹងអំពើជិះជាន់របស់ពួកសក្តិភូមិ និងអំពើពុករលួយរបស់ពួកនាហ្មឺនមន្ត្រី។

នៅសម័យក្នុងភាគទីមួយនៃសតវត្សរ៍ទី១៩ នៅប្រទេសកម្ពុជា មានការរីកចម្រើននៃពាណិជ្ជកម្មក្នុងប្រទេស មានការសម្រិតសម្រាំងក្នុងការប្រើប្រាស់ប្រាក់កាស និងការប្រើគ្រឿងសង្ហារណៈខាងសំណង់ផ្លូវគមនាគមន៍។ នៅសម័យដើមសតវត្សរ៍នេះ មហាក្សត្រកម្ពុជា បានព្រមព្រៀងចំពោះប្រព័ន្ធរបបអាណាព្យាបាលទ្វេភាគីរបស់ប្រទេសសៀម និងប្រទេសវៀតណាម ហើយសភាពការណ៍បែបនេះបង្កើតឱ្យមានស្ថិរភាព ហើយបានបន្ថយឥទ្ធិពលប្រទេសជិតខាងពីរនៅក្នុងកិច្ចការផ្ទៃក្នុងប្រទេសកម្ពុជា ដែលអាចប្រើប្រាស់សេរីភាពរបស់ខ្លួនខ្លះនៅក្នុងកិច្ចការគ្រប់គ្រងរដ្ឋ។ នៅសម័យពាក់កណ្តាលនៃសតវត្សរ៍ទី១៩ ស្ថានភាពផ្ទៃក្នុងប្រទេសត្រូវបានពង្រឹង។

ក្នុងគោលបំណងរំដោះខ្លួន ពីទម្ងន់នៃអាណាព្យាបាលទ្វេភាគីរបស់ប្រទេសសៀម និងប្រទេសវៀតណាម របបគ្រប់គ្រងសក្តិភូមិកម្ពុជា ក្រោមអធិបតីភាពរបស់មហាក្សត្របានចាប់ផ្តើមស្វែងរកកម្លាំងក្រៅប្រទេសថ្មី ហើយក៏បានជួបប្រទះនឹងសម្ពន្ធមិត្តថ្មីបែបនេះ គឺប្រទេសបារាំង។

**<u>វគ្គទីពីរ</u>**៖ បានអធិប្បាយអំពីពួកអាណានិគមបារាំង ដែលបានជ្រួតជ្រាបចូលមកឥណ្ឌូចិន បន្តិចម្តងៗ ជាពិសេសចូលមកប្រទេសកម្ពុជា។ សន្ធិសញ្ញាបារាំង-កម្ពុជា ស្តីអំពីអាណាព្យាបាល ចុះហត្ថលេខានាថ្ងៃទី១១ សីហា ឆ្នាំ១៨៦៣ គឺជាដំណាក់កាល ដែលបានសម្រេចនូវសកម្មភាពជ្រាបចូលរបស់ពួកបារាំង។

នៅក្នុងចំពូកនេះ មានអធិប្បាយឱ្យឃើញថា តើពួកតំណាងបារាំង បានចាប់ផ្ដើមរៀបចំរបបអាណានិគម ដូចម្ដេច? តើពួកនេះបានប្រើវិធីបែបណាខ្លះខាងសេដ្ឋកិច្ច ខាងច្បាប់តុលាការ និងខាងរដ្ឋបាល ដើម្បីពង្រឹងអំណាចត្រួតត្រារបស់ខ្លួននៅប្រទេសកម្ពុជា?។ នៅពេលជាមួយគ្នា អ្នកនិពន្ធបានបើកមុខឱ្យឃើញថា តើពួកសក្តិភូមិមានមហាក្សត្រជាប្រមុខបានលក់ប្រទេសខ្លួនដល់ពួកអាណានិគមបារាំង យ៉ាងណាព្រោះតែពួកនេះមានគោលបំណង ដើម្បីរក្សាទុកនូវបុព្វសិទ្ធិនិងអត្ថប្រយោជន៍របស់ខ្លួន?។

សេចក្ដីអធិប្បាយ បានយកចិត្តទុកដាក់ជាពិសេសដល់បណ្ដាចលនាកុបកម្មបះបោររបស់ប្រជាជននៅប្រទេសកម្ពុជា។ គ្មានអ្វីគួរឱ្យ សង្ស័យទេ ប្រជាជនខ្មែរប្រហែលអាចការពារឯករាជភាពនៃប្រទេសខ្លួនបាន ហើយមិនតែប៉ុណ្ណោះ នៅក្នុងកាលៈទេសៈខ្លះ លទ្ធភាពបានកើតមានឡើងក្នុងការបំពេញសកម្មភាពរួមរវាងបណ្ដាកុបករខ្មែរ និងវៀតណាម ក្នុងការតស៊ូប្រឆាំងពួកអាណានិគមបារាំង ក៏ប៉ុន្តែសម្ពន្ធភាពរបស់មហាក្សត្រ និងពួកមន្ត្រីសក្តិភូមិជាន់ខ្ពស់នៅប្រទេសកម្ពុជា ដែលភ័យខ្លាចចំពោះសន្ទុះនៃចលនាប្រជាជន ជាមួយនឹងពួកឈ្លានពានបារាំងបានបង្កើត ជាឧបសគ្គធ្វើឱ្យចលនាកុបកម្មប្រជាជន ត្រូវទទួលបរាជ័យ។ ប្រវត្តិសាស្ត្រស្ដីអំពីអំពើជ្រួតជ្រាបរបស់ពួកអាណានិគមបារាំង ចូលមកក្នុងប្រទេសកម្ពុជា ក៏មិនមែនជាអ្វីក្រៅពីប្រវត្តិសាស្ត្រស្ដីអំពីអំពើក្បត់របស់មហាក្សត្រ និងពួករាជបរិពារឡើយ។ ហេតុនេះហើយ បានជាមិនមែនជាចៃដន្យទេ ដែល

អំណាចរាជាណាចក្របានធ្វើសហការជាមួយរដ្ឋការបារាំង ក្នុងការប្រយុទ្ធប្រឆាំងនឹងចលនាតស៊ូរបស់ប្រជាជន។

ចលនាតស៊ូដ៏គគ្រឹកគគ្រេងប្រឆាំងបារាំង បានកើតមានឡើងជាបន្តបន្ទាប់នាសម័យនោះ ក្រោមកិច្ចដឹកនាំរបស់អាចារ្យស្វា ពោធិ៍-កំបោរ ព្រមទាំងចលនាតស៊ូបីទៀត ដែលបានកើតមានឡើងក្រោមកិច្ចដឹកនាំរបស់ ស៊ី វត្ថា។ ជាការពិតចលនាតស៊ូទាំងអស់នេះមានលក្ខណៈ និងទិសដៅប្រឆាំងអាណានិគមបារាំង។ នៅពេលជាមួយគ្នានោះ ចលនាកម្មករក៏បានចាប់ផ្តើមប្រមែប្រមូលកម្លាំងរបស់ខ្លួន កាន់តែខ្លាំងឡើង។ ហើយកម្លាំងដ៏ធំធេងនៃចលនានេះ បានឡើងដល់កម្រិតខ្ពស់បំផុតនៅរវាងឆ្នាំ១៩២៩ -១៩៣០។

ព្រឹត្តិការណ៍ដ៏សំខាន់ជាងគេសម្រាប់ប្រទេសកម្ពុជា និងសម្រាប់ឧបទ្វីបឥណ្ឌូចិន ទាំងមូល គឺការបង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិន នៅឆ្នាំ១៩៣០ ហើយនៅក្នុងក្របខណ្ឌនៃបក្សនេះ សាខាកម្ពុជា របស់បក្ស ក៏ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៣៦។ ជនកុម្មុយនិស្តទាំងឡាយបានដឹកនាំចលនាតស៊ូដើម្បីសេរីភាព និងឯករាជភាពនៃមាតុប្រទេស ប្រឆាំងពួកអាណានិគមបារាំង ហើយតមក ប្រឆាំងពួកកាន់កាប់ទឹកដីជប៉ុន។

ប្រវត្តិសាស្ត្រនាសម័យកាលនោះ មានសារៈសំខាន់ម៉្យាងទៀត ដោយហេតុថា នៅពេលនោះ មិត្តភាព និងយុទ្ធសាមគ្គីភាពរវាងប្រជាជនខ្មែរ វៀតណាម និងឡាវ បានកើតមានហើយបានទៅជារឹងមាំខ្លាំងក្លា។ គេទាំងឡាយបានរួបរួមគ្នាមិនមែនតែដោយសារស្ថានភាពខាងភូមិសាស្ត្រ ជិតខាងគ្នាប៉ុណ្ណោះទេ ប៉ុន្តែដោយសារការរួមរស់នៅក្នុងរបបអាណានិគម

និយមបារាំង គឺក្នុងសហភាពឥណ្ឌូចិន ដែលត្រូវបានបង្កើតឡើងនាឆ្នាំ១៨៨៧ ក៏ប៉ុន្តែ ដោយសារគេមានសត្រូវរួមរបស់គេ គឺពួកអាណានិគមបារាំង តមក គឺពួកឈ្លានពានជប៉ុន។

ស្មាកៀកស្មាគ្នា គេទាំងឡាយបានប្រយុទ្ធប្រឆាំងពួកអ្នកជិះជាន់ផ្ទៃក្នុងក្នុងស្រុកគឺ ពួកបរិវារមហាក្សត្រ ពួកសក្តិភូមិ និងវណ្ណៈគហបតីក្នុងស្រុក ដែលបានកើតមានឡើង។ ទាល់តែចេះជួយគ្នាទៅវិញទៅមក ទើបគេអាចប្រើប្រាស់យ៉ាងពេញលេញនូវលទ្ធផល នៃការតស៊ូរួមគ្នាដ៏អង់អាច។

<u>**វគ្គទីបី**</u>៖ សៀវភៅបានបំភ្លឺនូវព្រឹត្តិការណ៍ផ្សេងៗ ដែលបានកើតមានឡើងរវាងឆ្នាំ១៩៤៥ - ឆ្នាំ១៩៧០។ អត្ថន័យជាប្រវត្តិសាស្ត្រដ៏សំខាន់សម្រាប់វាសនាអនាគតនៃឥណ្ឌូចិន បានមកដោយសារការរំលំរបបហ្វាស៊ីស្តអាល្លឺម៉ង់ និងរបបយោធានិយមជប៉ុន ដែលនៅក្នុងនេះ កងទ័ពនៃសហភាពសូវៀត និងបដិវត្តន៍ខែសីហា នៅវៀតណាម បានបំពេញតួនាទីដ៏ចម្បង។ សម្ពន្ធភាពរវាងប្រជាជននានានៃប្រទេសវៀតណាម ឡាវ និងកម្ពុជា ដែលបានចាក់គ្រឹះតាំងពីសម័យកាលមុនមក បានក្លាយទៅជាកត្តាមួយដ៏សំខាន់បំផុត ក្នុងការបង្រួបបង្រួមបណ្តាកម្លាំងចម្រើនជឿនលឿន និងស្នេហាមាតុភូមិនៅក្នុងការតស៊ូប្រឆាំងពួកអាណានិគម និងចក្រពត្តិ។ ជំហានដ៏ធំនៅក្នុងកិច្ចពង្រឹងសម្ពន្ធភាពនេះ គឺការបង្កើតសម្ពន្ធភាពរួមនៃចលនាតស៊ូរបស់ប្រជាជននានានៅឥណ្ឌូចិន នាខែមីនា ឆ្នាំ១៩៥១។

នៅថ្ងៃទី១៩ មេសា ឆ្នាំ១៩៥០ តាមសេចក្តីផ្តើមគំនិត និងក្រោមកិច្ចដឹកនាំរបស់ជនកុម្មុយនិស្តកម្ពុជា មានការបង្កើតអង្គការស្នេហាមាតុភូមិមួយដ៏ធំទូលាយ គឺរណសិរ្សឯកភាព

ជាតិខ្មែរឥស្សរៈ។ ព្រឹត្តិការណ៍ប្រកបដោយសារសំខាន់ដ៏ចម្បងសម្រាប់ប្រជាជនខ្មែរ គឺការបង្កើតបក្សប្រជាជនបដិវត្តន៍កម្ពុជានាថ្ងៃទី២៨ មិថុនា ឆ្នាំ១៩៥១ ស្របទៅតាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតទី២ នៃបក្សកុម្មុយនិស្តឥណ្ឌូចិន។

នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ អង្គភាពនៃកងទ័ពបារាំង ត្រូវបានដកចេញពីទីក្រុងភ្នំពេញ ហើយរដ្ឋបាលបារាំងបានបញ្ឈប់សកម្មភាពរបស់ខ្លួននៅប្រទេសកម្ពុជា។ ការនេះបានសម្រេចឡើងជាពិសេស ដោយសារជោគជ័យនានានៃចលនាតស៊ូរំដោះជាតិកម្ពុជា ក្រោមកិច្ចដឹកនាំនៃជនកុម្មុយនិស្ត និងដោយសារជំនួយនៃកងទ័ពស្ម័គ្រចិត្តប្រជាជនវៀតណាម។

ការទទួលស្គាល់អន្តរជាតិពិតប្រាកដ ដល់អធិបតេយ្យភាពឯករាជភាព ឯកភាព និងបូរណភាពទឹកដីប្រទេសកម្ពុជា ត្រូវបានសម្រេចឡើងនៅក្នុងសន្និសីទអន្តរជាតិ នៃទីក្រុងហ្សឺណែវស្តីអំពីឥណ្ឌូចិន នាឆ្នាំ១៩៥៤។

នៅប្រទេសកម្ពុជា នារដូវវស្សាឆ្នាំ១៩៥៤ មានការបង្កើតក្រុម “ ប្រជាជន ” ដែលជាអង្គការស្របច្បាប់របស់បក្សប្រជាជនបដិវត្តន៍។ ការតស៊ូប្រឆាំងគ្រប់ឧបាយកលរបស់បណ្តាប្រទេសចក្រពត្តិ ជាពិសេស សហរដ្ឋអាមេរិក ក្នុងគោលបំណងដ៏ខ្មៅងងឹតរបស់វា ដើម្បីទាក់ទាញប្រទេសកម្ពុជា ឱ្យចូលក្នុងបក្សយោធាឈ្លានពាន សេ.អា.តូ ជាការតស៊ូប្រកបដោយអត្ថន័យដ៏សំខាន់សម្រាប់ប្រជាជនកម្ពុជា។

ឱកាសដ៏ប្រពៃនៅក្នុងការតស៊ូ គឺសេចក្តីអនុម័តច្បាប់នាថ្ងៃទី៦ វិច្ឆិកា ឆ្នាំ១៩៥៧ ស្តីអំពីអព្យាក្រឹតភាពនៃប្រទេសកម្ពុជា។ សំណើពីសំណាក់ប្រជាជនខ្មែរ ដល់ប្រជាជនជាបងប្អូននៃប្រទេស

វៀតណាម និងឡាវ បានផ្តល់អត្ថន័យដ៏សំខាន់ចំពោះសហប្រតិបត្តិការ ក្នុងការតស៊ូប្រឆាំងគ្រប់ឧបាយកលរបស់ពួកចក្រពត្តិ និងពួកអាណានិគមថ្មី។ តួនាទីដ៏ធំធេងក្នុងកិច្ចការពង្រឹងសហប្រតិបត្តិការនេះ គឺការបើកសម័យប្រជុំសន្និសីទអន្តរជាតិនៃប្រជាជននានានៅឥណ្ឌូចិន នៅទីក្រុងភ្នំពេញ នាខែមីនា ឆ្នាំ ១៩៦៥។

<u>**វគ្គទីបួន**</u>៖ អធិប្បាយអំពីប្រវត្តិសាស្ត្រប្រទេសកម្ពុជា នាឆ្នាំ១៩៧០-១៩៨០។

នៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ នៅក្នុងប្រទេសមានរដ្ឋប្រហារមួយបានកើតឡើង ហើយរបបគ្រប់គ្រង លន់-ណុល ដែលប្រកាន់តាមអាមេរិកនិយម បានឡើងមកកាន់កាប់អំណាច។ មជ្ឈដ្ឋាននានានៃអ្នកស្នេហាជាតិខ្មែរ បានរួបរួមគ្នាយ៉ាងកុះករ ដើម្បីរៀបចំចលនានៃការតស៊ូប្រឆាំងរបបគ្រប់គ្រងនេះ និងចៅហ្វាយរបស់ខ្លួនឯនាយសមុទ្រ។

នៅថ្ងៃទី៤ ឧសភា ឆ្នាំ១៩៧០ មានការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ ដូចពេលមុន បណ្តាអ្នកស្ម័គ្រចិត្តវៀតណាម និងឡាវ បានចូលមកជួយឧបត្ថម្ភដល់ប្រជាជនកម្ពុជា។

នៅថ្ងៃទី២៤ - ទី២៥ មេសា ឆ្នាំ១៩៧០ មានបើកសន្និសីទទីពីរ នៃប្រជាជននានានៅឥណ្ឌូចិន។ សេចក្តីសម្រេចនានានៃសន្និសីទនេះ បានទៅជាមូលដ្ឋានដ៏រឹងមាំសម្រាប់សហប្រតិបត្តិការរវាងបណ្តាប្រជាជន នៃប្រទេសទាំងអស់នៅឥណ្ឌូចិន នៅក្នុងការតស៊ូដើម្បីសេរីភាព និងឯករាជភាព។ ដោយសារសេចក្តីក្លាហានអង់អាច និងវីរភាពរបស់ជនកុម្មុយនិស្ត

ទាំងឡាយ និងបណ្តាអ្នកស្នេហាជាតិដ៏ស្មោះត្រង់ដទៃទៀតនៃប្រទេសកម្ពុជា ដោយសារការគាំទ្រ និងជំនួយរបស់កងទ័ពស្ម័គ្រចិត្តវៀតណាម ប្រជាជនកម្ពុជា បានប្រយុទ្ធដណ្តើមយកជ័យជម្នះលើពួកចក្រពត្តិអាមេរិក និងបរិវាររបស់វានៅក្នុងស្រុក។ នៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ រដ្ឋធានីភ្នំពេញ ត្រូវបានរំដោះ ហើយតមក ទឹកដីនៃប្រទេសទាំងមូល ក៏ត្រូវបានរំដោះ របបគ្រប់គ្រងលន់-ណុល ត្រូវបានរំលំ និងបំបាត់ចោល។

នៅចំពោះមុខនៃប្រជាជនកម្ពុជា អនាគតដ៏ភ្លឺស្វាងហាក់លេចឡើងយ៉ាងទូលំទូលាយ។ ក៏ប៉ុន្តែ ព្រឹត្តិការណ៍ដ៏អាក្រក់ផ្ទុយស្រឡះពីសេចក្តីសង្ឃឹមរបស់ប្រជាជន បានកើតមានឡើង។ សម័យកាលមួយប្រកបដោយយប់ងងឹតសូន្យសុង ពុំដែលមាននៅក្នុងទំព័រប្រវត្តិសាស្ត្រប្រទេស បានគ្របដណ្តប់លើប្រទេស និងប្រជាជនកម្ពុជា គឺជាពេលវេលានៃរបបប្រល័យពូជសាសន៍របស់បក្សពួកប៉ុល ពត ដែលមានជីវិតរហូតដល់ខែមករា ឆ្នាំ១៩៧៩។ ពួកវាបានចាប់ផ្តើមជន្លៀសបណ្តាប្រជាជននៅទីក្រុងនានា ហើយបញ្ជាឱ្យទៅរស់នៅតាមជំរំការងារនៅស្រុកស្រែ និងស្រុកព្រៃ។ របបប៉ុល ពត បានចាប់ផ្តើមអនុវត្តនយោបាយប្រល័យពូជសាសន៍ចំពោះប្រជាជនកម្ពុជា។

នៅក្នុងស្ថានភាព ប្រកបដោយមហាសោកនាដកម្មដ៏ខ្លោចផ្សារបែបនេះ អាយុជីវិតប្រជាជនដ៏ស្លូតត្រង់ចំនួនបីលាននាក់ត្រូវបានទទួលការកាប់សម្លាប់យ៉ាងរង្គាលដោយពួកឃាតករប៉ុល ពត។

ដើម្បីប្រយុទ្ធប្រឆាំង នយោបាយភេរវកម្មកៀបសង្កត់ និងការកាប់សម្លាប់ដ៏ព្រៃផ្សៃយ៉ាងនេះ អ្នកស្នេហាមាតុភូមិដ៏

ស្មោះត្រង់ទាំងអស់គ្នាបានបង្រួបបង្រួមគ្នា បង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ឡើងនាថ្ងៃទី២ ធ្នូ ឆ្នាំ១៩៧៨។

ដោយសារជំនួយកងទ័ពស្ម័គ្រចិត្តវៀតណាម ជាបងប្អូនកងកម្លាំងប្រដាប់អាវុធប្រជាជនអ្នកស្នេហាមាតុភូមិ ក្រោមកិច្ចដឹកនាំរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានរំដោះភ្នំពេញ ពីក្រញ៉ាំនៃរបបប្រល័យពូជសាសន៍ នៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩។ នៅថ្ងៃទី១០ មករា នៃ ឆ្នាំដដែល ប្រទេសកម្ពុជាត្រូវបានប្រកាសជាផ្លូវការថាជា សាធារណរដ្ឋប្រជាមានិតកម្ពុជា។ ប្រជាជនខ្មែរបានទៅជាម្ចាស់ពិតប្រាកដ នៃប្រទេសរបស់ខ្លួន ហើយបានចាប់ផ្តើមកសាងប្រទេសកម្ពុជា ឯករាជ្យ ប្រជាធិតេយ្យ សន្តិភាព អព្យាក្រឹត មិនចូលបក្សសម្ពន្ធ ហើយឈានឡើងសង្គមនិយម។

ក្នុងកិច្ចការពារ និងធានានូវឯករាជភាពរបស់ខ្លួន ប្រជាជនកម្ពុជា បំពេញទៅបានតែដោយសារការទទួលកិច្ចគាំទ្រពីសំណាក់នៃសាធារណរដ្ឋសង្គមនិយមវៀតណាម សហភាពសូវៀត និងបណ្តាប្រទេសសង្គមនិយម ជាបងប្អូនដទៃទៀត។

សន្ធិសញ្ញាស្តីអំពីមិត្តភាព និងសហប្រតិបត្តិការរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម ចុះហត្ថលេខានាថ្ងៃទី១៨ កុម្ភៈ ឆ្នាំ១៩៧៩ នៅទីក្រុងភ្នំពេញ បានទៅជាព្រឹត្តិការណ៍មានអត្ថន័យជាប្រវត្តិសាស្ត្រក្នុងកិច្ចការពង្រឹងចំណងមិត្តភាពរវាងប្រជាជនកម្ពុជា និងវៀតណាម។ ដំណាក់កាលដ៏សំខាន់ៗនៅក្នុងជីវភាពនៃប្រទេសកម្ពុជាគឺការបើកសម័យប្រជុំទីមួយ (ពីថ្ងៃទី១៩-ដល់ទី៣០ កញ្ញា ឆ្នាំ១៩៧៩), ទីពីរ (នៅថ្ងៃទី២២ ធ្នូ ឆ្នាំ១៩៨១) នៃមហាសន្និបាត

របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា, ការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៃរដ្ឋសភា នាថ្ងៃទី១ ឧសភា ឆ្នាំ១៩៨១, ការបើកសម័យប្រជុំនៃរដ្ឋសភា ក្នុងនីតិកាលទី១ (ពីថ្ងៃទី២៥ - ដល់ទី២៩ មិថុនា ឆ្នាំ១៩៨១) ដែលនៅក្នុងនេះ មានសេចក្តីអនុម័តអំពីការប្រើប្រាស់រដ្ឋធម្មនុញ្ញ និងការបង្កើតរដ្ឋាភិបាលនៃសាធារណរដ្ឋ។

ព្រឹត្តិការណ៍ដ៏សំខាន់ជាចំបងនាសម័យនោះ គឺការបើកសម័យប្រជុំនៃមហាសន្និបាតទី៤ របស់បក្សប្រជាជនបដិវត្តន៍កម្ពុជា ដែលបានប្រព្រឹត្តទៅ ពីថ្ងៃទី២៦ ដល់ទី២៩ ឧសភា ឆ្នាំ ១៩៨១ ហើយដែលធ្វើសេចក្តីអនុម័តលើមាគ៌ានៃការកសាងប្រទេស ដើម្បីឈានឡើងសង្គមនិយម។

ព្រឹត្តិការណ៍ដ៏សំខាន់ៗ ដែលបានរៀបរាប់រួចមកហើយ នៅក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា ត្រូវបានវិភាគ និងអធិប្បាយនៅក្នុងសៀវភៅនេះ។

សៀវភៅ “ប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា” និពន្ធដោយអ្នកនិពន្ធសូវៀត មួយក្រុម ៖ អារម្ភកថា - បណ្ឌិតខាងនីតិសាស្ត្រ យ.យ.មីហេយេវ, វគ្គទី១ - បណ្ឌិតខាងប្រវត្តិវិទ្យា ដ.វ.ឌីយេអូពីក, វគ្គទី២ - បណ្ឌិតខាងប្រវត្តិវិទ្យា យ.ព.ដេមេនចេវ, វគ្គទី៣ -បណ្ឌិតខាងភូមិសាស្ត្រ គ.គ សូឆេវ.កូ, វគ្គទី៤ ចំពូកទី១ - យ.យ. មីហេយេវ, ចំពូកទី២ - យ.ព. ដេមេនចេវ និងបណ្ឌិតខាងប្រវត្តិវិទ្យា យ.វ.កូបេលេវ, ចំពូកទី៣ - យ.វ. កូបេលេវ, យោបល់រួម-យ.យ.មីហេយេវ។

# វគ្គទី១

# ប្រទេសកម្ពុជា ពីសម័យកាលដ៏បុរមបុរាណ ដល់សម័យកាលភាគទី១ នៃសតវត្សរ៍ទី១៩

## ចំពូកទី១

## ប្រទេសកម្ពុជា ពីសម័យកាលក្នុងពេលដ៏បុរម បុរាណព្រេងនាយរហូតដល់ភាគខាងដើមនៃ មជ្ឈមសម័យ

ទឹកដីប្រទេសកម្ពុជា ស្ថិតនៅក្នុងភូមិភាគ នៃដែនដីដែលបានបង្កបង្កើតមនុស្សជាតិនាសម័យបច្ចុប្បន្ន។

បុរេបុរាណវត្ថុវិទ្យានៅដែនដីម្លូព្រៃ និងនៅទីកន្លែងដទៃទៀតរកឃើញ និងសិក្សាដោយអ្នកប្រាជ្ញនានា ជាភស្តុតាងជាក់ស្តែងបញ្ជាក់ឱ្យឃើញនូវវប្បធម៌ នៃសម័យកាលបុរេសិលាភាគខាងចុង គឺពីដប់ពាន់ ដល់ប្រាំពាន់ឆ្នាំមុនគ្រឹស្តសករាជ ដែលបានកកើតមានឡើងនៅលើទឹកដីកម្ពុជា។ ប្រហាក់ប្រហែលនៅសម័យកាលពីមួយម៉ឺនបួនពាន់ឆ្នាំមុនគ្រឹស្តសករាជ បណ្តាជនប្រទេសកម្ពុជា បានរស់នៅក្នុងសម័យកាលមជ្ឈមសិលាភាគខាងដើមនៃវប្បធម៌បាន់ស័ន ដែលនៅសម័យកាលនោះ ជាលក្ខណៈពិសេសសម្រាប់បណ្តាជនជាតិនៅឧបទ្វីបឥណ្ឌូចិន ដែលបានរកស៊ីរស់នៅដោយសារការបេះផលដំណាំ ការបរបាញ់សត្វ និងការដាំដំណាំលើដីដោយគ្រឿងឧបករណ៍ដ៏បុរមបុរាណបំផុត។ ជាលើកទីមួយនៅសម័យនោះ នៅលើសកលលោក បណ្តាជនជាតិរស់នៅឧបទ្វីបឥណ្ឌូចិន បានឈានឡើង


ឈូងសមុទ្រសៀម



ទៅកាន់របររកស៊ីចិញ្ចឹមជីវិតដោយផលិតកម្ម។

សម័យកាលពីបួនពាន់ ដល់ប្រាំពាន់ឆ្នាំមុនគ្រឹស្តសករាជ គឺជាសម័យកាលនវសិលាភាគខាងចុង(ពីប្រាំបីពាន់ ដល់បីពាន់ឆ្នាំមុនគ្រឹស្តសករាជ) ប្រកបដោយលក្ខណៈដ៏ប្រសើរសម្រាប់ការប្រកបរបរកសិកម្មដ៏បូរមបូរាណ ក្នុងលក្ខខណ្ឌនៃតំបន់ក្តៅជាសម័យកាលដែលបណ្តាជនជាតិ ចាប់ផ្តើមប្រើប្រាស់ពូថៅធ្វើពីថ្មរំលីងក្នុងការប្រកបរបរកសិកម្ម។ នៅសម័យនោះ បណ្តាជនជាតិ មួយភាគបានចុះចាកពីលំនៅនៅតាមចង្កេះភ្នំ ដើម្បីធ្វើដំណើរចុះមករស់នៅតាមទីដីទំនាប និងដីសណ្តរនៅតាមដងទន្លេនានា។ គឺនៅពេលនោះហើយ ដែលភូមិឋានធំៗទាំងឡាយបានកកើតមានឡើងក្នុងពេលដ៏យូរអង្វែង គឺជាភូមិដ្ឋានប្រកបដោយរបរកសិកម្ម។ ការរីកចម្រើននៃផលិតកម្មបានជំរុញឱ្យមានការបែងចែកពពួកមនុស្ស ជាក្រុមមនុស្សត្រួតត្រានៅក្នុងកុលសម្ពន្ធនានា បណ្តាលឱ្យមានចម្បាំងប្រយុទ្ធរវាងកុលសម្ពន្ធ ហើយសភាពការណ៍បែបនេះ បានបន្ទាញឱ្យមានការពង្រឹងកិច្ចការពារភូមិដ្ឋាននានា។

បណ្តាជនជាតិអូស្ត្រូអាស៊ីយ៉ាទីក (នៅក្នុងនេះមានជនជាតិមន-ខ្មែរ) នៅឧបទ្វីបឥណ្ឌូចិន ក៏បានឈានឡើងមកដល់ស្ថានភាព នៃបណ្តាជនជាតិរីកចម្រើនទាំងឡាយនៅលើផែនដីចាស់បូរាណ។

តាមជាតិពន្ធុវិទ្យា ជនានុជននៃកុលសម្ពន្ធនៅភាគខាងចុងនៃសម័យនវសិលា (គឺពីប្រាំមួយពាន់ឆ្នាំ ដល់ពីរពាន់ប្រាំរយឆ្នាំមុនគ្រឹស្តសករាជ) ដែលរស់នៅប្រទេសកម្ពុជា ស្ថិតនៅក្នុងអម្បូរអូស្ត្រូអាស៊ីយ៉ាទីកហើយតាមនរវិទ្យារូបរាងនៃជនានុជន

ទាំងនេះ ដូចជាជនជាតិខ្មែរសព្វថ្ងៃជាដើម មានលក្ខណៈដូចគ្នានឹងក្រុមម៉ុងហ្គោលោអ៊ីដខាងត្បូង។ បណ្តាជនជាតិអូស្ត្រូអាស៊ីយ៉ាទិកមួយភាគ បានរស់នៅតទៅទៀតនៅតាមដងភ្នំទាំងឡាយ ហើយបានស្ថិតនៅក្នុងស្ថានភាពនៃការលូតលាស់ដ៏អន់ថយដដែល។

របររកស៊ីដ៏សំខាន់របស់បណ្តាជនជាតិ អូស្ត្រូអាស៊ីយ៉ាទិកនៅសម័យនោះ គឺរបរកសិកម្ម ដោយការដាំដំណាំលើដីចម្ការរៀបចំដោយការដុតព្រៃភ្នំ និងការដាំដំណាំនៅតាមដីទីវាលទំនាបដោយការបង្ហូរទឹក។ ដូចសម័យកាលមុន ការដើរបេះផលដំណាំ ការនេសាទត្រី ហើយតមកទៀត ការបរបាញ់សត្វទាំងអស់នេះបានបំពេញតួនាទី ដ៏សំខាន់នៅក្នុងរបររកស៊ីនៃបណ្តាជនជាតិសម័យនោះ។ ក្រៅអំពីដំណាំស្រូវ បណ្តាជនជាតិជាតិអូស្ត្រូអាស៊ីយ៉ាទិក បានដាំដំណាំសណ្តែក ដំណាំត្រឡាច ត្រសក់ ព្រមទាំងដំណាំយកមើម។

តាមកម្រិតលូតលាស់ខាងសង្គមកិច្ច គេអាចសន្មតបាននូវស្ថានភាពជីវភាពបណ្តាជនជាតិជំនាន់នោះ ថាជាជីវភាពជាកុលសម្ពន្ធនៃអ្នកធ្វើស្រែចម្ការ ដែលបានរស់នៅតាមការប្រមូលផ្តុំនៃក្រុមញាតិសាលោហិត ឬតាមសហគមន៍។

បុព្វបុរសជនជាតិមន-ខ្មែរ (ដែលជាអម្បូរជនជាតិដ៏សំខាន់ក្នុងបណ្តាអម្បូរជនជាតិដទៃ នៃមហាគ្រួសារជនជាតិអូស្ត្រូអាស៊ីយ៉ាទិក) បានកសាងមូលដ្ឋានវប្បធម៌លោហកម្មធ្វើស្ពាន់ដ៏បូរុមបូរាណបំផុត គឺជាមូលដ្ឋានមួយដ៏ល្បីល្បាញដែលគេបានស្គាល់ក្នុងសម័យបច្ចុប្បន្ន ក្នុងបណ្តាមជ្ឈមណ្ឌលលោហកម្មធ្វើស្ពាន់ទាំងបីនៅលើពិភពលោក (ទ្វីបអាស៊ីប៉ែកខាងបស្ចឹម

និងនៅទ្វីបអាមេរិក)។ គេបានដឹងថា វប្បធម៌លោហកម្មធ្វើស្ពាន់របស់ជនជាតិអូស្ត្រូអាស៊ីយ៉ាទីក នៅឥណ្ឌូចិន បានកើតមានឡើងតាំងពីបួនពាន់ឆ្នាំមុនគ្រិស្តសករាជ។ នៅសម័យកាលខាងចុងសម័យកាលបីពាន់ឆ្នាំមុនគ្រីស្តសករាជ វប្បធម៌ធ្វើស្ពាន់បានវិវត្តទៅដល់វប្បធម៌ធ្វើសំរិទ្ធ។ នៅខាងដើមសម័យកាលពីរពាន់ឆ្នាំមុនគ្រីស្តសករាជ នៅតាមតំបន់ផ្សេងៗនៃឧបទ្វីបឥណ្ឌូចិន មានកើតនូវវប្បធម៌ធ្វើសំរិទ្ធជាបងប្អូននៅពីរបីកន្លែង ដែលគេបានសន្មតថា ជាសម័យកាលនៃវប្បធម៌សំរិទ្ធ។

មជ្ឈមណ្ឌលនៃវប្បធម៌លោហកម្មនៅឥណ្ឌូចិន បានផ្តល់ឥទ្ធិពលដ៏ជ្រាលជ្រៅរបស់ខ្លួនទៅលើវប្បធម៌ នៃភូមិភាគខាងឧត្តរនានានៅអាស៊ីខាងបូព៌ា។ នៅពេលក្រោយមក វប្បធម៌នាសម័យកាលសំរិទ្ធ ដែលបានកើតមានមកជាបន្តបន្ទាប់នាសម័យពីពីរពាន់ឆ្នាំមុនគ្រីស្តសករាជ នៅទីវាលទំនាបនៃទន្លេហួនហែ បានទទួលឥទ្ធិពលវប្បធម៌នៅឥណ្ឌូចិន ក្នុងការផលិតគ្រឿងឧបករណ៍ធ្វើពីដែក ដែលមានការប្រើប្រាស់ទូទៅ និងក្នុងការប៉ិនប្រសប់ធ្វើគ្រឿងចានឆ្នាំងសេរ៉ាមិច។ ក៏ប៉ុន្តែ នៅសម័យកាលក្រោយៗមក គឺនៅពេលពាក់កណ្តាលនៃសម័យកាលពីពីរពាន់ឆ្នាំមុនគ្រីស្តសករាជ (គ.ស.) មជ្ឈមណ្ឌលវប្បធម៌ខាងទក្សិណ (នៅឥណ្ឌូចិន) បានចុះអន់ថយក្នុងការលូតលាស់របស់ខ្លួន ប្រហែលមកពីកម្រិតខាងសម្ភារៈនៃការរីកចម្រើនខាងសង្គម មិនបានពង្រីកលទ្ធភាពខាងបច្ចេកទេស សម្រាប់ការបង្ហូរទឹកស្រោចស្រពដែនដីដ៏ធំៗ (សម្រាប់ដំណាំស្រូវ ដែលតម្រូវឱ្យមានការកសាងប្រព័ន្ធបង្ហូរទឹក ដែលត្រូវបានកសាងឡើងនៅពេលក្រោយៗមកទៀត)។ សង្គមមនុស្សនាសម័យទាំងនោះ

មានលក្ខណៈពិសេស ប្រកបដោយភាពលូតលាស់ខាងផលិតកម្ម ដោយការរីកចម្រើនចំនួនបណ្តាជន ហើយផលវិបាកនៃសភាពការណ៍បែបនេះ បានជំរុញឱ្យមានការប្រមូលផ្តុំបន្ថែមនូវគ្រឿងផលិតកម្ម។ ការតស៊ូដោយការប្រយុទ្ធគ្នារវាងកុលសម្ពន្ធនានាក៏បានចាប់ផ្តើម មានឡើងក្នុងការចែករំលែកគ្រឿងផលិតកម្ម។ បណ្តាជនជាតិសេរីនៅទីវាលទំនាប ក៏បានចែកជាបណ្តាជនជាតិមួយភាគតូច ដែលរស់រានសម្បូរសប្បាយប្រកបដោយការមានអំណាច និងសមាជិកសាមញ្ញភាគច្រើនរស់នៅផ្តុំជាក្រុមក្រោមអំណាចនៃសហគមន៍។

ជាច្រើនសតវត្សរ៍នៅសម័យមុនគ្រឹស្តសករាជ បុព្វបុរសដើមនៃជនជាតិខ្មែរ ក៏ដូចជាបុព្វបុរសនៃជនជាតិមន វៀត និងចាម បានវិវត្តទៅដល់ការប្រើប្រាស់គ្រឿងឧបករណ៍ធ្វើពីដែក។ បច្ចេកទេសក្នុងការជីកយក និងលត់ដំដែកត្រូវបានទទួលឥទ្ធិពលពីភូមិភាគជិតខាង (ចំពោះរឿងនេះ ពុំទាន់មានឯកសារស្រាវជ្រាវច្បាស់លាស់) ពីប្រទេសឥណ្ឌាខាងត្បូង និងពីប្រទេសចិនខាងត្បូង។

ការលូតលាស់យ៉ាងរហ័សខាងវិស័យសេដ្ឋកិច្ច បន្ទាប់ពីការផ្សព្វផ្សាយការប្រើប្រាស់ឧបករណ៍ធ្វើពីដែក បានពន្លឿនការកកើតឡើងនូវសង្គមមនុស្សប្រកបដោយវណ្ណៈ ក្នុងពេលដ៏ឆាប់រហ័ស (ប្រហែលនៅជិតសម័យខាងដើមនៃគ.ស.)។ សង្គមបែបនេះ មានការទាក់ទងតាមពន្ធុវិទ្យា ទៅនឹងសង្គមមនុស្សនាសតវត្សរ៍ទី៦-៧ ដែលជាសង្គមប្រកបដោយការអនុវត្តនូវទាសភាព។ សង្គមបែបនេះ គេអាចសន្មតថាជាសង្គមប្រកបដោយវណ្ណៈពួកម្ចាស់ទាសាទាសី នៃសម័យកាលដំបូង។ ដូច

ជាបណ្ដាសង្គមមនុស្សប្រកបដោយវណ្ណៈនិយម ដែលបានកើតមាននៅជិតគ្នា និងមជ្ឈមណ្ឌលអារ្យធម៌ដែលបានវិវត្តទៅកាន់ស្ថានភាពជារដ្ឋប្រកបដោយវប្បធម៌ប្រកាន់វណ្ណៈនិយម រដ្ឋដែលកំពុងចាប់បដិសន្ធិឡើងបានទាក់ទាញឱ្យមានការជ្រួតជ្រាបទៅតាមការពិសោធខាងសង្គមកិច្ច ហើយបានជំរុញឱ្យមានលទ្ធភាពដល់ការបង្កបង្កើត និងការពង្រីកនូវស្ថាប័ននានានៃវណ្ណៈនិយម។ ដូចជាប្រជាជនមួយចំនួនធំនៅអាស៊ីអាគ្នេយ៍ ប្រជាជនខ្មែរបុរាណបានប្រើប្រាស់ការពិសោធរបស់រដ្ឋជ្រាវីឱយៀងទាំងឡាយ នៅប្រទេសឥណ្ឌាខាងទក្សិណ ដែលមានសភាពប្រហាក់ប្រហែលគ្នាក្នុងរបរប្រកបការងារខាងសេដ្ឋកិច្ចកសិកម្ម។

នៅតាមឆ្នេរទាំងឡាយនៃសមុទ្រខ្មែរ (ជាឈ្មោះហៅដោយអ្នកធ្វើដំណើរអារ៉ាប់ ចិនហៅថា សមុទ្រខាងត្បូង ហើយពួកអ្នកដំណើរអឺរ៉ុប ហៅថាសមុទ្រចិនខាងត្បូង) មានទូកសំពៅខ្មែរ និងឥណ្ឌា ដែលធ្វើចរាចរណ៍ទៅមកឥតឈប់ឈរ។ ទូកសំពៅចិនបានធ្វើដំណើរតាមសមុទ្រខ្មែរ ប្រហែលមួយពាន់ឆ្នាំក្រោយ។

ឯកសារជាលាយលក្ខណ៍អក្សរទាំងឡាយ (ជាភាសាខ្មែរ និងបរទេស) បានបញ្ជាក់ជាសក្ខីភាពជាក់ស្តែងថា នៅសតវត្សរ៍ទី២ នៃ គ.ស. នៅប្រទេសកម្ពុជា មានសង្គមមនុស្សប្រកបដោយវណ្ណៈនិយម ព្រមទាំងមានរដ្ឋដែលជារាជាណាចក្រទៀតផង។ ឈ្មោះប្រទេសកម្ពុជា នៅសម័យនោះ ត្រូវបានគេស្គាល់ដោយឯកសារជាអក្សរចិន ដែលតាមការអានសម័យបច្ចុប្បន្នថា ជាហ្វូណន។ ក៏ប៉ុន្តែតាមការស្រាវជ្រាវរបស់អ្នកឯកទេសខាងខេមរវិទ្យាមានសេចក្តីបញ្ជាក់ថា គឺជាអក្សរសរសេរពាក្យ “ បាភ្នំ ”

ដែលជាពាក្យមានន័យទាក់ទងនឹងគោរមងារដ៏បូរាណនៃមហាក្សត្រខ្មែរគឺ គុរុងបុំ (ក្រុងភ្នំ) មានន័យថាជាមហាក្សត្របព៌ត។

មជ្ឈមណ្ឌលរបស់ប្រទេសនេះ ស្ថិតនៅភូមិភាគប៉ែកខាងអាគ្នេយ៍នៃប្រទេសកម្ពុជា សព្វថ្ងៃ តាមមាត់ទន្លេមេកុង និងតាមដៃទន្លេនានាដែលហូរប្រសព្វទន្លេនេះ។ នៅសម័យនោះ រាជធានីនៃរដ្ឋបាភ្នំ មានឈ្មោះថា វ្យាធបូរៈ (មានន័យថា ទីក្រុងប្រមាញ់)។ នៅក្នុងដំណាក់កាលជាបឋម រដ្ឋបាភ្នំ មានទឹកដីលាតសន្ធឹងពីបឹងទន្លេសាប រហូតដល់ពាមទន្លេមេកុង ដែលជាប់ទៅនឹងសមុទ្រ។ បន្ទាប់មក ដោយជ័យជម្នះក្នុងការធ្វើចម្បាំងនានាក្រោមការដឹកនាំរបស់មហាក្សត្រខ្មែរបូរាណ រដ្ឋបាភ្នំ បានពង្រីកទំហំទឹកដីរបស់ខ្លួនទ្វេជាបួនដងទៅទិសខាងបស្ចិម និងខាងឧត្តរ។ មូលដ្ឋាននៃសេដ្ឋកិច្ចរដ្ឋ កើតមកពីរបរដាំដំណាំស្រូវតាមរបៀបបង្ហូរទឹកនៅទីដីទំនាបជុំវិញទន្លេសាប និងតាមតំបន់ដីទំនាបតាមមាត់ទន្លេមេកុង។ ក្នុងការភ្ជួររាស់ដាំដំណាំស្រូវ អ្នកស្រុកបានប្រើប្រាស់ជាទូទៅនូវសត្វពាហណៈ ដូចជា ក្របី និងគោ។ នៅសម័យនោះ ខ្មែរបូរាណសុទ្ធសឹងជាសិប្បករដ៏ប៉ិនប្រសប់។ ហេតុនេះហើយ បានជានៅទីក្រុងធំៗមានការប្រមូលផ្ដុំនូវផ្ទះជំនួញ (ដែលមានទាំងជំនួញក្រៅប្រទេស) ព្រមទាំងរបរ និងគ្រឿងសិប្បកម្មប្រកបដោយការលូតលាស់ដ៏ខ្ពង់ខ្ពស់។ ទីក្រុងនានាមិនមែនគ្រាន់តែជាទីក្រុងនៃសិប្បកម្ម និងពាណិជ្ជកម្មប៉ុណ្ណោះទេ ប៉ុន្តែជាមជ្ឈមណ្ឌលយោធាទៀតផង ហើយនៅជុំវិញទីក្រុងមានទីទួលជារបាំងការពារ។ វត្តអារាមនានាត្រូវបានកសាងឡើងសមស្របតាមប្រពៃណី នៃនិម្មាបនកម្មខ្មែរប្រកបដោយដំបូលលេចឡើងលើស្របតាមគម្រោងការ នៃសំណង់សង្កាត់

នានា។ ទីក្រុងទាំងឡាយតែងស្ថិតនៅចំទីកណ្តាលនៃទីវាលស្រែចម្ការ ដែលមានប្រព័ន្ធបង្ហូរទឹក និងព្រែកជីកសម្រាប់គមនាគមន៍។ តាមព្រែកជីកទាំងនេះ មានទាំងទូកសំពៅសមុទ្រដែលអាចបើកបរទៅមកបាន។

នៅរដ្ឋបាភ្នំ ក៏ដូចជានៅតាមភូមិភាគឆ្នេរសមុទ្រឥណ្ឌូនេស៊ីពាណិជ្ជកម្មក្នុងប្រទេស និងក្រៅប្រទេស បានដើរតួនាទីដ៏សំខាន់។ គេបានសន្និដ្ឋានថា ខ្មែរបូរាណជាអ្នកដំណើរតាមសមុទ្រដ៏ចំណាន។ មានគ្រឿងវត្ថុសម្រាប់ការប្រើប្រាស់ជាសាធារណៈ ការប្រើប្រាស់ប្រាក់របស់រដ្ឋបាភ្នំផ្ទាល់ ធ្វើពីមាស និងប្រាក់ ពីសំរឹទ្ធ និងសំណ ដែលមានសណ្ឋានដូចប្រាក់ទូទៅនៅលើពិភពលោក មានទាំងប្រាក់ ដែលមានសញ្ញាទាក់ទងនឹងប្រទេសឥណ្ឌា និងកត្តាដទៃទៀត។ ទាំងអស់នេះជាភស្តុតាងបញ្ជាក់ឱ្យឃើញថា រដ្ឋបាភ្នំសម័យនោះមានប្រព័ន្ធពាណិជ្ជកម្មខាងក្នុងប្រទេសដ៏រីកចម្រើន។ ប្រាក់កាសរបស់រដ្ឋបាភ្នំ ត្រូវបានគេរកឃើញរហូតដល់ភាគខាងបស្ចិមនៃឥណ្ឌូចិន។ ខុសគ្នាពីដែនដីវៀត (វៀតណាម) នៅដែនដីរដ្ឋបាភ្នំ គេពុំបានរកឃើញប្រាក់ចិន ឡើយ។ ការរកឃើញប្រាក់ធ្វើពីមាស និងប្រាក់ព្រមទាំងបន្ទោងក ពីចក្រភពរ៉ូម៉ាំង និងពីប្រទេសនានានៅមជ្ឈិមបូព៌ា បានបញ្ជាក់ឱ្យឃើញថា រដ្ឋបាភ្នំ មានការទាក់ទងខាងពាណិជ្ជកម្ម ជាមួយប្រទេសដ៏ឆ្ងាយៗ។

របស់នានាជាច្រើនទាក់ទងនឹងបូរាណវត្ថុវិទ្យា ជាភស្តុតាងបញ្ជាក់ថា នៅរដ្ឋបាភ្នំ មានសង្គមមនុស្សប្រកបដោយវណ្ណៈនិយមមានវប្បធម៌ទីក្រុងដ៏លូតលាស់ មានការបែកចែករបរសិប្បកម្មជាច្រើនសាខា។ មិនតែប៉ុណ្ណោះគេបានរកឃើញរបស់ផ្សេងៗ

ដូចជា បន្តោងមន្តគាថាតូចធំ កូនសោផ្សេងៗ រូបសំណាកអ្នកដឹកនាំ បណ្តាជនធម្មតា និងទាសាទាសី។

តាមការវិនិច្ឆ័យ ចំពោះរូបសំណាកបណ្តាជនធម្មតា ឃើញថា សំលៀកបំពាក់ខ្មែរបុរាណមានរបៀបដូចជាសំពត់នាសម័យបច្ចុប្បន្ន ការទុកសក់ខ្លី ដែលធ្វើឱ្យពួកអឺរ៉ុប ងឿងឆ្ងល់ គឺជាលំអធម្មតារបស់ស្ត្រីនៅសម័យនោះ។ មានគ្រឿងអលង្ការធ្វើពីលោហជាតិនានា ដែលនៅក្នុងនេះ មានទាំងក្រវិលត្រចៀកធ្វើពីប្រាក់ មានរូបរាងដូចនេះ (:) ផលិតនៅរដ្ឋបាភ្នំ ហើយការប្រើប្រាស់គ្រឿងអលង្ការទាំងនេះ ដែលបានរីកសាយទូទាំងភូមិភាគអាស៊ីអាគ្នេយ៍ បានបញ្ជាក់នូវវត្តមាននៃវប្បធម៌សម័យកាលសំរិទ្ធនៅរដ្ឋបាភ្នំ។

នៅក្នុងវិស័យវប្បធម៌ខាងសតិអារម្មណ៍ នាសម័យកាលនៃសតវត្សរ៍ខាងដើមនានានៃ គ.ស. នៅរដ្ឋបាភ្នំ មានការរក្សានូវប្រពៃណីមន-ខ្មែរ ដោយមានការផ្សំនឹងជាតុថ្មីនានានៃវប្បធម៌ប្រជាជនទាំងឡាយ នៅប្រទេសឥណ្ឌាខាងទក្សិណ (ជាពិសេសពុទ្ធសាសនា និងព្រហ្មញ្ញសាសនា)។ ក៏ប៉ុន្តែ តាំងពីដើមទីមកការផ្សាយសាសនាទាំងនេះមកលើមជ្ឈដ្ឋានវប្បធម៌ខ្មែរ បានបង្កើតឱ្យមានសភាពថ្មី ក្នុងការមិនព្រមទទួលនូវលក្ខណៈតឹងតែងគ្រោតគ្រាតរបស់អាទិទេពទាំងឡាយ ហើយមាននិន្នាការឆ្ពោះទៅកាន់សំយោគវិធីរវាងជំនឿខាងព្រហ្មនិយម និងពុទ្ធនិយម។

រូបភាពបង្ហាញអាទិទេពខាងព្រហ្មញ្ញសាសនា មានចំនួនពុំសូវច្រើន។ ខុសគ្នាពីសម័យកាលក្រោយមក ការកសាងរូបព្រះពុទ្ធ តាមរូបបដិមាសិល្បៈដ៏ធំគគ្រឹកគគ្រេង មានប្រៀបលើការកសាងរូបភាពអាទិទេព ក្នុងព្រហ្មញ្ញសាសនាទាំងឡាយ

ហើយមិនតែប៉ុណ្ណោះ រូបភាពអាទិទេពព្រហ្មញ្ញសាសនាទាំងនេះបានទៅជារូបភាពបន្ទាប់បន្សំទៅវិញ។ មែនពិត មានទាំងរូបបដិមាធំៗ របស់ព្រះឥសូរ និងរបស់ព្រះវិស្ណុ។ ជាទូទៅ រូបបដិមាទាំងនេះជាច្រើន ជាពិសេសរូបភាពតូចតាចរបៀបឈរឬអង្គុយ ព្រមទាំងសំលៀកបំពាក់ជាដើម មានលក្ខណៈខុសគ្នាច្រើនពីរូបបដិមា និងក្បួនតម្រាសិល្បៈឥណ្ឌា ហើយបានបង្ហាញឱ្យឃើញនូវទម្រង់នៃក្បាច់រចនាខ្លះ ដែលបានលេចឡើងមុនសម័យកាលនៃការលូតលាស់របស់សិល្បៈចម្លាក់ខ្មែរ នាមធ្យមសម័យ។ គួរកត់សម្គាល់ថា ចម្លាក់រូបមនុស្សប្រកបដោយភាពជាក់ស្តែងបានកើតមានឡើងនៅរដ្ឋបាភ្នំ នាសម័យកាលប្រហែលគ្នានៅប្រទេសឥណ្ឌា។ ប្រហែលជាភូមិភាគអាស៊ីអាគ្នេយ៍ ក៏ដូចជាប្រទេសឥណ្ឌា បានទទួលឥទ្ធិពលសិល្បៈពីប្រទេសនានានៅតាមមាត់សមុទ្រមេឌីទែរ៉ាណេ និងប្រទេសអៀរ៉ង់ នៅពេលប្រហាក់ប្រហែលគ្នា។

ភាពដូចគ្នាក្នុងប្រពៃណីខាងសង្គមកិច្ច និងសេដ្ឋកិច្ច និងការទាក់ទងដ៏ធំទូលាយជាមួយភូមិភាគខាងទក្សិណ នៃប្រទេសឥណ្ឌា បានផ្តល់លទ្ធភាពដ៏ប្រសើរដល់ប្រជាជនខ្មែរក្នុងការក្រេបជញ្ជក់យកការពិសោធរបស់រដ្ឋជ្រាវីឌីយៀង ប្រកាន់ព្រហ្មនិយម ដែលស្ថិតនៅតាមត្រើយសមុទ្រក្បូរម៉ានដែលស្ដី។

តាមពិត ខ្មែរបុរាណផ្តើមគំនិតធ្វើពាណិជ្ជកម្ម និងបង្កបង្កើតទម្រង់នានា ដែលទ្រទ្រង់នូវប្រពៃណីខាងសង្គមសេដ្ឋកិច្ចដោយខ្លួនឯង ព្រោះថានៅរដ្ឋបាភ្នំ ក៏ដូចនៅភូមិភាគអាស៊ីអាគ្នេយ៍ទាំងមូលដែរ សម័យនោះ គេពុំបានរកឃើញនូវស្នាមភូមិដ្ឋានជនជាតិឥណ្ឌា ទេ។ ខ្មែរបុរាណបានក្រេបយកពាក្យបច្ចេកទេស

ខាងសង្គមកិច្ច ខាងសាសនាមួយចំនួនពីភាសាសំស្ក្រឹត ដើម្បីបំពេញបំប៉នសេចក្តីត្រូវការ ក្នុងការពង្រីកវប្បធម៌របស់ខ្លួន ហើយក្រេបយកក្បួនខ្នាតខាងរដ្ឋបាល និងខាងនីតិសាស្ត្រដែរ។

នៅសម័យនៃរដ្ឋបាភ្នំ ក្រសួងតុលាការ រដ្ឋបានធ្វើការ ក៏ប៉ុន្តែនៅក្នុងកិច្ចការតុលាការទាំងនេះ ជាមួយនឹងការប្រើប្រាស់ច្បាប់ឥណ្ឌា តាមនីតិសាស្ត្រជាភាសាសំស្ក្រឹត មានទាំងការប្រើប្រាស់ " តុលាការអាទិទេព " ដែលជារបៀបវិនិច្ឆ័យទោសតាមបែបបទប្រពៃណីប្រជាប្រិយ។ នៅក្នុងសង្គមខ្មែរនាសម័យរដ្ឋបាភ្នំ ដោយសារការរីកចម្រើនខាងសង្គមកិច្ច និងខាងសេដ្ឋកិច្ច ខ្មែរបូរាណបានប្រើអក្សរ ដែលមានមូលដ្ឋានដើមពីអក្សរនៅក្នុងអក្ខរវិធីភាសាសំស្ក្រឹត។ ភាសាសំស្ក្រឹតត្រូវបានប្រើប្រាស់មួយភាគធំក្នុងការនិពន្ធអត្ថបទសិលាចារិកស្តីអំពីកិច្ចការរដ្ឋ និងអំពីបុណ្យកិច្ចរបស់ព្រះមហាក្សត្រទាំងឡាយ។ ខ្មែរបូរាណបានប្រើប្រក្រតីទិនឥណ្ឌា (គឺមហាសករាជ) ហើយរឿងទេវកថាខ្មែរបានទទួលឥទ្ធិពលរឿងទេវកថា ដែលទាក់ទងនឹងព្រហ្មញ្ញសាសនា (ដូចជារឿងរាមកេរ្តិ៍ និងមហាភរទៈ) ប៉ុន្តែ បានរក្សានូវលក្ខណៈប្រពៃណីជាតិជាប់មកដល់សព្វថ្ងៃ។ សិល្បៈឥណ្ឌាក៏បានផ្តល់ឥទ្ធិពលរបស់ខ្លួនជាច្រើនមកលើសិល្បៈចម្លាក់ខ្មែរ។

នៅសម័យនោះ សង្គមខ្មែរបានកសាងឡើងតាមរបៀបនៃជីវភាពជាសហគមន៍ ដោយរក្សានូវប្រពៃណីមន-ខ្មែរបូរាណ ហើយមិនបានយករបៀបចាត់តាំងខាងសង្គម-វប្បធម៌ប្រជាជនប្រទេសឥណ្ឌា ដូចជាការបែងចែកសង្គមជាជាន់ថ្នាក់ ជាវណ្ណៈ (ជាកាស្ត)។ សហគមន៍នៅរដ្ឋបាភ្នំ មិនធំ ហើយខុសគ្នាពីសហគមន៍ដ៏ធំនៅប្រទេសឥណ្ឌាខាងទក្សិណ ដោយមានការ

បែងចែកមនុស្សជាម្ចាស់ដី និងអ្នកធ្វើស្រែចម្ការ។ ដោយគ្មានមូលដ្ឋានខាងសង្គមកិច្ចច្បាស់លាស់ សង្គមខ្មែរបានផ្លាស់ប្តូរទម្រង់របស់ខ្លួនទៅតាមប្រពៃណីឥណ្ឌា បន្តិចម្តងៗ។ នៅក្នុងវិស័យសាសនា មានសភាពខុសគ្នាមិនសូវខ្លាំង នៅក្នុងរបបគ្រប់គ្រងរដ្ឋ មានការទទួលឥទ្ធិពលចំពោះអំណាចផ្តាច់ការមហាក្សត្រ ហើយគ្មានការកម្រិតដល់បុព្វសិទ្ធិដល់វណ្ណៈជាន់ខ្ពស់នានា។ ប្រព័ន្ធរឿងទេវកថាខ្មែរ បានជ្រួតជ្រាបចូលក្នុងរឿងទេវកថារាជវង្សានុវង្ស និងក្នុងមនោគមវិជ្ជាជាផ្លូវការនៃសង្គម ហើយបានបន្តផ្តល់ឥទ្ធិពលរបស់ខ្លួន ទៅក្នុងជីវភាពរស់នៅខាងសតិអារម្មណ៍នៃជនានុជនក្នុងស្រទាប់ជាន់លើ និងជាន់ក្រោមនៃសង្គម។

ដំណាក់កាលក្នុងបឋមសម័យនានា នៃប្រវត្តិសាស្ត្ររដ្ឋបាភ្នំ បានជ្រួតជ្រាបមកដល់យើងក្នុងបច្ចុប្បន្នសម័យ តាមរយៈនៃពង្សាវតារ កត់ត្រាដោយឯកសារស្ថានទូតរាជវង្សានុវង្សចិនខាងទក្សិណ។

ស្របតាមអត្ថន័យនៃពង្សាវតារនេះ ស្ថាបនកររដ្ឋនគរភ្នំគឺព្រះបាទកោណ្ឌញ្ញវ្ម័ន ដែលបានធ្វើដំណើរមកពីទិសខាងទក្សិណ (យើងសូមរំលឹកថា នៅក្នុងសង្គមវណ្ណៈនិយម ដែលកំពុងកកើតឡើងតែងមានផ្សាយរឿងព្រេងស្តីអំពី ការមកដល់នូវមហាបុរស ដែលបាននាំមកនូវគំនិតថ្មី ស្តីអំពីការកសាងរដ្ឋពីប្រទេសមួយផ្សេងទៀត)។ តាមសេចក្តីនៃរឿងព្រេង គឺថា តាមការយល់សប្តិ ដួងព្រលឹងមេបា បានមកដល់ទីភូមិ បានជូនធ្នូដល់ព្រះបាទកោណ្ឌញ្ញវ្ម័ន បានទូន្មានឱ្យជិះសំពៅជំនួញតាមសមុទ្រទៅកាន់ដែនដីសុវណ្ណភូមិ។ សំពៅបានមកដល់ដែនដីបាភ្នំ ហើយតាមអត្ថន័យនៃរឿងព្រេងចិន នៅរដ្ឋបាភ្នំ មានសំពៅ

ជំនួញធំៗបានបើកបរចូលមក។ រឿងព្រេងស្ដីអំពីដួងព្រលឹងមេបា ដែលជារឿងតម្រែតម្រូវតាមអ្នកបង្កបង្កើតរាជវង្សានុវង្ស ព្រមទាំងរឿងទាក់ទងនឹងកៅទណ្ឌ(ធ្នូ)ទិព្វ ជារឿងព្រេងដែលមានមិនមែនចំពោះតែជនជាតិខ្មែរបូរាណទេ តែមានចំពោះជនជាតិឡាក វៀតជាជនជាតិអូស្រ្តូអាស៊ីយ៉ាទីក ដទៃមួយទៀត ដែលរស់នៅប៉ែកខាងល្ងិសាននៃឧបទ្វីបឥណ្ឌូចិន។

បន្ទាប់ពីបានធ្វើចម្បាំងឈ្នះមហាក្សត្រិយានី ព្រះនាងលីវ-យី ដែលបានគ្រប់គ្រងរដ្ឋបាភ្នំ មក ព្រះបាទកោណ្ឌញ្ញវរ្ម័ន បានលើកព្រះនាងលីវ-យី ធ្វើជាអគ្គមហេសីរបស់ព្រះអង្គ។ បន្ទាប់ពីមានព្រះរាជអាពាហ៍ពិពាហ៍នេះហើយ ដែលមានទស្សនៈចំពោះការបន្តព្រះរាជវង្សានុវង្ស នៃរបាក្សត្រខ្មែរជាបន្តបន្ទាប់មកនៅរដ្ឋបាភ្នំ ហើយអ្នកបង្កើតរាជវង្សានុវង្សនេះ គឺជាមហាបុរសប្រកបដោយទេវមហិទ្ធិឫទ្ធិខ្លាំងក្លា ដែលទើបយាងមកពីឆ្ងាយ។ ជាច្រើនសតវត្សរ៍នាសម័យក្រោយៗមកទៀត មហាក្សត្រនៃសម័យចក្រភពខ្មែរសម័យអង្គរ តែងបានប្រកាសខ្លួនថាជាអ្នកបន្តរាជវង្សានុវង្សនេះ។ រឿងព្រេងបញ្ជាក់អំពីរាជវង្សានុវង្សខ្មែរ បានទទួលឥទ្ធិពលតាមព្រហ្មញ្ញសាសនា ដោយមានការនិទានដូចតទៅ៖

ព្រះបាទកោណ្ឌញ្ញវរ្ម័ន គឺជាមហាឥសី ដែលមានលំពែងជាអាវុធ ហើយបានបោះលំពែងនេះដើម្បីកំណត់ទីកន្លែងអនាគតរដ្ឋធានី។ មហាក្សត្រិយានីនៃដែនដីបាភ្នំសម័យនោះ មាននាមឈ្មោះជាភាសាសំស្រ្កឹតថា នាងសោមា ព្រះនាងជារាជិនី នៃភុជង្គនាគ។ល។

ព្រះបាទកោណ្ឌញ្ញវរ្ម័ន ជាអ្នកបង្កបង្កើតរាជវង្សានុវង្សខាងព្រះចន្ទ្រ ហើយការបន្តរាជសម្បត្តិបានប្រព្រឹត្តទៅតាមខ្សែស្រឡាយ

វង្សត្រកូលខាងបិតា។ ចំណែកឯព្រះនាងសោមា ជាអ្នកបន្តរាជវង្សានុវង្សខាងព្រះសុរិយា ហើយការបន្តរាជសម្បត្តិបានប្រព្រឹត្តទៅតាមខ្សែស្រឡាយវង្សត្រកូលខាងមាតា។ ព័ត៌មានខ្លះៗដែលគេបានដឹងអំពីសម័យកាល ក្នុងការគ្រប់គ្រងរាជរបស់ព្រះបាទកោណ្ឌញ្ញវរ្ម័ន និងមហាក្សត្របន្តរាជវង្សានុវង្ស តមកទៀត បានធ្វើឱ្យគេអាចសន្និដ្ឋានបានថា របបគ្រប់គ្រងរដ្ឋបាភ្នំ នាសម័យនោះមានលក្ខណៈបូរាណ។ រាជបុត្រនានារបស់ព្រះមហាក្សត្របានគ្រប់គ្រងទីក្រុងប្រាំពីរកន្លែង។ មន្ត្រីជាន់ខ្ពស់នានាបានគ្រប់គ្រងភូមិភាគដទៃទៀត គេអាចហៅមន្ត្រីទាំងនេះថា ជាស្ដេចត្រាញ់។ ទឹកដីប្រទេសខ្មែរនៅសម័យនោះ លាតសន្ធឹងពីទីវាលទំនាបទន្លេមេកុង ដល់ភូមិភាគភ្នំពេញ។

ដំណាក់កាលក្រោយមកទៀត នៃប្រវត្តិសាស្ត្ររបស់រដ្ឋបាភ្នំ នៅមិនទាន់ច្បាស់លាស់។ ក្នុងបណ្ដាមហាក្សត្រ ដែលបានសោយរាជ្យបន្តរាជវង្សានុវង្សព្រះបាទកោណ្ឌញ្ញវរ្ម័ន គេបានស្គាល់មហាក្សត្រមួយអង្គព្រះនាមហ៊ុន ប៉ាញ់ហួន (តាមឯកសារនិងតាមការអានជាភាសាចិន) ដែលបានសោយរាជសម្បត្តិនៅរដ្ឋបាភ្នំ នាសម័យកាលភាគទីពីរនៃសតវត្សរ៍ទី២ និងភាគខាងដើមនៃសតវត្សរ៍ទី៣ នៃ គ.ស.។ នៅសម័យនោះ កុបកម្មបះបោរនានា បានកើតមានឡើង ដោយអ្នកគ្រប់គ្រងតំបន់ផ្សេងៗ (ប្រហែល ពីសំណាក់មេកន្ទ្រាញកុលសម្ពន្ធ ទាំងឡាយ) ប្រឆាំងនឹងរដ្ឋអំណាចកណ្ដាល។ បន្ទាប់ពីបានបង្ក្រាបកុបកម្មបះបោរទាំងនេះហើយ ព្រះបាទហ៊ុន ប៉ាញ់ហួន បានតែងតាំងរាជបុត្រ និងចៅរបស់ព្រះអង្គឱ្យសោយរាជ្យ ដូចជា “ ស្ដេចសមន្តរាជ ” នានានៅតំបន់ផ្សេងៗនៃព្រះរាជាណាចក្រ។

ព្រឹត្តិការណ៍បែបនេះអាចបញ្ជាក់បានជាសក្ខីភាព ដោយវត្តមាននៃទំនាក់ទំនងរវាងស្តេចសមន្តរាជនានា និងមហាក្សត្រនៃរដ្ឋបាភ្នំ។ តមក ព្រះបាទហ៊ុន ប៉ាញ់ហួន បានប្រគល់រាជសម្បត្តិដល់រាជបុត្រព្រះនាម ប៉ាន់-ប៉ាន់ ក៏ប៉ុន្តែ ព្រះអង្គបានប្រគល់កិច្ចការរដ្ឋទាំងអស់ដល់អគ្គមេបញ្ជាការកងទ័ពមួយរូប នាមហ្វាន់-ម៉ាន់ (ឬ ហ្វាន់-ស៊ីម៉ាន់)។ ពាក្យ " ហ្វាន់ " បើពិនិត្យតាមឯកសារក្រោយៗមកទៀត ទាក់ទងនឹងពាក្យ " វរ្ម័ន " ដែលជាគោរមនាមទូទៅរបស់មហាក្សត្រប្រទេសកម្ពុជា និងប្រទេសឥណ្ឌាខាងត្បូង។

បីឆ្នាំបានកន្លងផុតមក ព្រះបាទប៉ាន់-ប៉ាន់ បានសោយទិវង្គត ហើយ " ប្រជារាស្ត្រនៃព្រះរាជាណាចក្រ " បានជ្រើសរើសហ្វាន់-ស៊ីម៉ាន់ ឱ្យឡើងសោយរាជ្យជាព្រះមហាក្សត្រ។

បន្ទាប់ពីការទទួលជ័យជម្នះក្នុងចម្បាំងផ្សេងៗ មានរដ្ឋជិតខាងមួយចំនួនធំ បានទទួលស្គាល់នូវអនិស្សរភាពរបស់ខ្លួនចំពោះរដ្ឋបាភ្នំ ហើយនៅសម័យនោះ រដ្ឋបាភ្នំ បានប្រែក្លាយទៅជារដ្ឋចក្រភពមួយ។ ព្រះបាទហ្វាន់-ស៊ីម៉ាន់ បានទទួលគោរមនាមជាមហាអធិរាជនៃចក្រភពបាភ្នំ។ កងកម្លាំងនាវាចរណ៍ដ៏ខ្លាំងក្លាមួយត្រូវបានស្ថាបនាឡើង ហើយកងនាវាចរណ៍នេះបានចាប់ផ្តើមធ្វើយុទ្ធនាការផ្សេងៗ ដែលនៅពេលនោះ កងទ័ពខ្មែរបានធ្វើដំណើរឆ្លងកាត់តាម " មហាសមុទ្រ " ហើយបានធ្វើការវាយប្រហារលើប្រទេសជារាជាណាចក្រ ចំនួនដប់។ ក្នុងបណ្តាប្រទេសទាំងនោះ តាមឯកសារនៃអ្នកប្រវត្តិសាស្ត្រខ្លះ មានប្រទេសដែលមានឈ្មោះដូចតទៅ៖ ស៊ូ-ឌូ-ស៊ូយ៉ាញ់, ទួន-សូន, ស៊ូ-ឈេ, ចាញ់-ស៊ុន, ឈីន-លីន ( សុវណ្ណភូមិ ) និងប្រទេសដទៃទៀត។ បើយោងទៅតាមឯកសារនៃស្ថានទូតរាជវង្សានុវង្ស

ចិនខាងត្បូង ដែលមាន ជោគជ័យនៃយុទ្ធនាការទាំងនេះ បានផ្ដល់លទ្ធភាពឱ្យមានការពង្រីកទឹកដីចក្រភពបាភ្នំ ប្រវែងដល់ពីរពាន់គីឡូម៉ែត្រ។ ក៏ប៉ុន្តែ បើតាមការសន្និដ្ឋានដ៏សមរម្យវិញ ឃើញថា ដែនដីមួយភាគនៃប្រទេសមន និងប្រទេសម៉ាឡាយូបានធ្លាក់មកក្នុងស្ថានភាពអនិស្សរភាពនៃចក្រភពបាភ្នំ។

នៅពេលនោះទឹកដីនៃចក្រភពបាភ្នំ បានគ្របដណ្ដប់លើភូមិភាគខាងក្រោមទន្លេមេកុង ភូមិភាគខាងកើតនៃតំបន់បឹងទន្លេសាប តំបន់ខាងកើតចាប់តាំងដែទន្លេមេកុង តំបន់ខាងដើមនៃទន្លេចៅ-ប្រែន ដែនដីតំបន់ជ្រោយសមុទ្រក្រា រហូតដល់ឈូងសមុទ្របន់ដុន។

នៅសម័យពាក់កណ្ដាលទសវត្សរ៍ទី២ នៃសតវត្សរ៍ទី៣ នៅពេលដែលព្រះបាទហ្វាន់-ស៊ីម៉ាន់ សោយទិវង្គត រជ្ជអំណាចបានធ្លាក់មកក្នុងកណ្ដាប់ដៃរបស់រាជបុត្រព្រះអង្គ នាមព្រះបាទហ្វាន់-ឈិន-មេន។ ដោយពឹងផ្អែកលើកម្លាំងកងទ័ពរបស់ខ្លួន មេទ័ពហ្វាន់-ចាន់ ជាក្មួយរបស់ព្រះបាទហ្វាន់-ស៊ីម៉ាន់ និងជាស្ដេចត្រាញ់នៃភូមិភាគមួយនៃចក្រភពបាភ្នំ បានបះបោរ ហើយធ្វើឃាតព្រះបាទហ្វាន់-ឈិន-មេន។ រាជវង្សានុវង្សភេទប្រុសរបស់ព្រះអង្គមួយចំនួន មិនត្រូវបានកាត់ទោសប្រហារជីវិតទេ ប៉ុន្តែត្រូវបានដកចេញពីតំណែងរជ្ជ ហើយអនុញ្ញាតឱ្យទៅរស់នៅក្នុងបណ្ដាអ្នកស្រុក។

នៅពេលរវាងទសវត្សរ៍ទី២-៣ នៃសតវត្សរ៍ទី៣ ព្រឹត្តិការណ៍សំខាន់ៗ បានកើតមានឡើងនៅក្នុងវិស័យសេដ្ឋកិច្ច និងវប្បធម៌នៃប្រវត្តិសាស្ត្ររបស់ប្រទេស។ ចក្រភពខ្មែរប្រកបដោយកម្លាំងយោធាដ៏រឹងមាំ និងដោយស្ថានភាពភូមិសាស្ត្រ ដែលមានផ្លូវ

ពាណិជ្ជកម្មដ៏សំខាន់ៗ បានពង្រឹងទំនាក់ទំនងអន្តរជាតិរបស់ខ្លួននៅលើកម្រិតនៃទំនាក់ទំនងទូត។ អគ្គរដ្ឋទូតចក្រភពបាភ្នំបានធ្វើដំណើរទស្សនកិច្ចនៅរដ្ឋឥណ្ឌាមួយ ដែលមានព្រះរាជវង្សរាន្ទុវង្សមុរុនដា សោយរាជ្យ។ អគ្គរដ្ឋទូតត្រូវបានគេធ្វើគារវកិច្ចទទួលយ៉ាងគគ្រឹកគគ្រេង។ នៅឱកាសនៃទស្សនកិច្ចតបវិញ ពីសំណាក់អគ្គរដ្ឋទូតរបស់មហាក្សត្រមុរុនដា មានការផ្តល់ជំនូនដល់ជនជាតិខ្មែរ នូវពូជសេះអាជនេយ្យ គឺជាពូជសេះឥណ្ឌាសកៈ ដែលមានតម្លៃបំផុតនៅប្រទេសឥណ្ឌាខាងត្បូង និងនៅអាស៊ីអាគ្នេយ៍។

នៅសម័យក្រោយមក ស្ថានភាពប្រទេសបានទៅជាស្មុគស្មាញ ដោយមានយុទ្ធនាការរវាងរាជបុត្ររបស់ព្រះបាទហ្វាន់-ស៊ីម៉ាន់។ មហារាជហ្វាន់-ចាន់ ត្រូវបានគេធ្វើគត ដោយរាជបុត្រពៅរបស់ព្រះបាទហ្វាន់-ស៊ីម៉ាន់ ដែលបានរស់នៅក្នុងបណ្តាអ្នកស្រុក ហើយទទួលការអប់រំក្នុងបណ្តាអ្នកស្រុក។ ជីវភាពរស់នៅរបស់សមាជិកនៃរាជវង្សរាន្ទុវង្ស ក្នុងបណ្តាអ្នកស្រុកធម្មតាបែបនេះមិនមែនជាព្រឹត្តិការណ៍ចម្លែកទេ គឺជាព្រឹត្តិការណ៍ដែលតែងមានហើយនឹងមានតមកទៀត។ ស្ថានភាពនេះកើតមកអំពីអំណាចដ៏ខ្លាំងក្លារបស់មហារាជ ដែលតែងមានមកចំពោះបណ្តារាស្ត្រទាំងអស់របស់ប្រទេស។

នៅពេលក្រោមមក រាជបុត្ររបស់ព្រះបាទហ្វាន់-ស៊ីម៉ាន់ក៏ត្រូវបានមេទ័ពនាមហ្វាន់-ស៊ុន ធ្វើឃាតទៀត។ ហើយនៅសម័យដើមទសវត្សរ៍ទី៤ នៃសតវត្សរ៍ទី៣ មេទ័ពហ្វាន់-ស៊ុន ក៏បានប្រកាសខ្លួនជាអធិរាជនៃចក្រភពបាភ្នំ។

នៅក្នុងសម័យកាលនៃការគ្រងរាជ្យរបស់ព្រះបាទហ្វាន់-ស៊ុន មានការចាប់ផ្តើមស្ថាបនកម្មបរមរាជវាំង ដែលមានលក្ខណៈពិសេសសម្រាប់ប្រជាជនខ្មែរនាសម័យក្រោយៗ។ ព្រះរាជពិធីដ៏ឱឡារិកគគ្រឹកគគ្រេង និងស្មុគស្មាញផ្សេងៗក៏បានចាប់ផ្តើមមានឡើង។

នៅសម័យនោះ ប្រទេសជិតខាងដែលខ្លាំងក្លា ហើយអាចបណ្តាលឱ្យមានគ្រោះថ្នាក់ដល់ចក្រភពបាភ្នំ គឺប្រទេសចម្ប៉ា។ ក៏ប៉ុន្តែ នៅឆ្នាំ២៧០ គ.ស. ចក្រភពបាភ្នំ បានចងសម្ពន្ធភាពជាមួយប្រទេសចម្ប៉ា ក្នុងគោលបំណងធ្វើការវាយបំបាត់បន្ទាយកងទ័ពរបស់រាជាណាចក្រចិន ព្រះនាម “ អ៊ូ ” នៅតំបន់សៅ ឈី (ជាភាសានៅប្រទេសវៀតណាម សៅ ទី) នៅប្រទេសវៀតណាមខាងជើង។ ការធ្វើសង្គ្រាមបានបន្តរហូតដល់ដប់ឆ្នាំ ហើយមិនបានបណ្តាលឱ្យមានការផ្លាស់ប្តូរព្រំប្រទល់ឡើយ ប៉ុន្តែបានធ្វើឱ្យកងកម្លាំងរបស់ស្តេចចិន ទន់ខ្សោយប៉ុណ្ណោះ។

ព្រះបាទហ្វាន់-ស៊ុន បានសោយទិវង្គតនៅសម័យខាងចុងនៃទសវត្សរ៍ទី៨។ រាជវង្សានុវង្សរបស់ព្រះអង្គបានសោយរាជ្យជាបន្តបន្ទាប់មក អស់រយៈពេលជិត៧០ឆ្នាំ រហូតដល់សម័យកាលដ៏អាប់អួរនៃពេលពាក់កណ្តាលសតវត្សរ៍ទី៥។

នៅសម័យកាលនៃសតវត្សរ៍ទី៣ - ទី៤ នៃ គ.ស. ដូចសម័យមុន ជីវភាពខាងសតិអារម្មណ៍របស់ប្រទេសបានទទួលឥទ្ធិពលដ៏ខ្លាំងនៃពុទ្ធសាសនាមហាយាន (អំពីឥទ្ធិពលនេះមានភស្តុតាងដោយរូបចម្លាក់សិលាចារឹក និងរឿងនិទាននានា)។ ក៏ប៉ុន្តែ ឯកសារនានាបញ្ជាក់អំពីប្រវត្តិសាស្ត្រប្រទេសនាសម័យសតវត្សរ៍ទី៤ មានតិចតួច ដោយហេតុថា ឬមួយមានការចុះអន់

ថយក្នុងការធ្វើពាណិជ្ជកម្មតាមសមុទ្ររបស់រាជវង្សានុវង្សស្តេចប្រទេសចិន ព្រះនាម ហាង់ បន្ទាប់ពីការផុតរលត់របស់រាជវង្សានុវង្សស្តេចប្រទេសចិន ព្រះនាម អ៊ូ ឬម៉្យាងទៀត មានកើតវិបត្តិផ្ទាល់នៅចក្រភពបាភ្នំ។

នៅសម័យពាក់កណ្តាលនៃសតវត្សរ៍ទី៤ មានមហាក្សត្រមួយអង្គជាតំណាងរាជវង្សានុវង្សថ្មី ព្រះនាមចន្ទនៈ ព្រះអង្គបានឡើងសោយរាជ្យនៅចក្រភពបាភ្នំ។ នៅឆ្នាំ៣៥៧ គ.ស. មានការបញ្ជូនបេសកកម្មខាងពាណិជ្ជកម្មមួយទៅប្រទេសខាងជើង ដែលនៅក្នុងនេះ មានទាំងការនាំចេញនូវដំរីស្រុក ដែលជាសត្វពាហនៈដ៏សំខាន់ សម្រាប់ការនាំចេញរបស់ប្រទេសខ្មែរ។

នៅសម័យខាងដើមនៃសតវត្សរ៍ទី៥ នៅពេលដែលព្រះបាទកោណ្ឌញ្ញវរ្ម័នទីពីរ បានឡើងសោយរាជ្យនៅក្នុងប្រទេស មានការបង្កើតឥទ្ធិពលនៃព្រហ្មញ្ញសាសនា ដែលមានជាអាទិ គឺសាសនាព្រះវិស្ណុ ដែលទូន្មានសេចក្តីអត់ឱនខ្លះៗដល់សាសនាដទៃទៀត។ មហាក្សត្រ ដែលមានឋានៈជាលោកសង្ឃព្រាហ្មណ៍ បានមកជំនួសវេនមហាក្សត្រ ដែលបានបំពេញតួនាទីជាយុទ្ធជនផង។

ក៏ប៉ុន្តែ ពុទ្ធនិយម (មានពុទ្ធសាសនាហីនយាន និងពុទ្ធសាសនាមហាយាន ដែលកាន់តែលូតលាស់ខ្លាំង) បានរក្សានូវស្ថានភាពរបស់ខ្លួននៅក្នុងសង្គម។ អស់រយៈពេលសតវត្សរ៍ទី៥ មានការលូតលាស់ខាងសំណង់វត្តអារាម មានការបង្កើតឥទ្ធិពលរបស់គណៈសង្ឃ ហើយជាផលវិបាក គឺមានការយកចិត្តទុកដាក់យ៉ាងខ្លាំងជាថ្មីដល់ការពិសោធនៃប្រទេសឥណ្ឌា។ ជាពិសេស មានការបង្កើនទំនាក់ទំនង ជាមួយនឹងប្រទេសឥណ្ឌាខាងត្បូង ក្នុងរជ្ជកាលនៃព្រះរាជវង្សានុវង្សបល្លវៈ។

មហាក្សត្របន្តរាជសម្បត្តិពីព្រះបាទកោណ្ឌញ្ញវរ្ម័នទី២ គឺព្រះបាទស្រីឥន្ទ្រវរ្ម័ន (មុន គ.ស. ៤៣៤ - និងបន្ទាប់ពី គ.ស. ៤៣៨)។ នៅសម័យនោះចក្រភពបាភ្នំ បានបដិសេធចោលនូវសម្ពន្ធភាពជាមួយប្រទេសចម្ប៉ា ហើយឈប់ចូលរួមក្នុងចម្បាំងនៃប្រទេសនេះប្រឆាំងប្រទេសចិន ក្នុងសម័យរាជវង្សានុវង្សស៊ុន។ ការបដិសេធសម្ពន្ធភាពបែបនេះ ប្រហែលបានកើតមកពីមានការទាក់ទងជាអចិន្ត្រៃយ៍ ខាងពាណិជ្ជកម្មរវាងចក្រភពបាភ្នំ និងកំពង់ផែនានានៅសៅទី និងនៅប៉ាញូ (សព្វថ្ងៃគឺ កង់តុង)។ ចក្រភពបាភ្នំ បានធ្វើជំនួញ ជាមួយប្រទេសចិន ដោយនាំចេញនូវភ្លុកដំរី មាស ចានកែវ គ្រឿងអលង្ការ និងគ្រឿងសិប្បកម្មផ្សេងៗ ហើយនាំចេញនូវសំពត់សូត្រ។

រាជបុត្របន្តរាជវង្សានុវង្ស ព្រះបាទកោណ្ឌញ្ញវរ្ម័នទី២ បានសោយរាជសម្បត្តិនៅចក្រភពបាភ្នំ នៅសម័យខាងចុងសតវត្សរ៍ទី៥ និងសម័យខាងដើមសតវត្សរ៍ទី៦។ អំណាចរបស់មហារាជមានសភាពរឹងមាំ ហើយមហិទ្ធិឫទ្ធិរបស់ចក្រភពបានគ្របសង្កត់ទៅលើកិច្ចត្រួតត្រាលើទឹកដីទាំងអស់ ដែលដណ្តើមយកបាននៅសម័យរជ្ជកាលព្រះបាទហ្វាន់-ស៊ីម៉ាន់។

នៅសម័យកាលក្នុងភាគទីពីរ នៃសតវត្សរ៍ទី៥ មានឯកសារជាសិលាចរឹកដែលរៀបរាប់អំពីកិច្ចការដីស្រែចម្ការ ភូមិដ្ឋាននៅចក្រភពបាភ្នំ។ មហារាជគឺជាគ្រូរុងបាភ្នំ មានអំណាចធ្វើអំណោយដីភូមិដ្ឋាន ដោយហេតុថា នៅពេលនោះទឹកដីទាំងអស់នៃប្រទេសគឺជាកម្មសិទ្ធិជាន់ខ្ពស់ផ្ទាល់របស់អំណាចរបស់រដ្ឋ។ មហារាជបានធ្វើអំណោយដីដល់វត្តអារាម ដល់និវេសនដ្ឋានតាបសឥសី។ ដូចជានៅប្រទេសដទៃនៃអាស៊ីអាគ្នេយ៍ និងប្រទេសលង្កា សីឡង់

នៅសម័យនោះ រាជអំណោចដីសំខាន់ៗ មានទាំងសំណង់ទំនប់ទឹក និងប្រព័ន្ធបង្ហូរទឹកត្រូវបានកសាងឡើងក្រោមកិច្ចដឹកនាំរបស់អង្គការរាជការជាន់ខ្ពស់។ នៅសម័យនៃសតវត្សរ៍ទាំងនោះ កម្មសិទ្ធិដីស្រែចម្ការធំៗ បានកកើតមានឡើង ដោយសារការត្រួសត្រាយដីថ្លុកត្រពាំង ដែលស្ថិតនៅជិតទីវាលទំនាបទន្លេមេកុង បានសេចក្ដីថា ជាទឹកដីនៅក្នុងភូមិភាគកណ្ដាលនៃចក្រភពបាភ្នំ។ នៅក្នុងការងារត្រួសត្រាយដីទាំងនេះ ពួកមុខមន្ត្រីនិងបណ្ដារាជវង្សរបស់មហារាជ បើតាមឯកសារជាសិលាចារឹកនាសតវត្សរ៍ទី៦ អ្នកទាំងនេះបានប្រើវិធីបង្ខិតបង្ខំកម្លាំងពលករដែលជាកសិករ អ្នកស្រុកស្រែ និងជាពួកទាសាទាសី (ពួកក្ញុំ)* ក្នុងកិច្ចការធ្វើស្រែចម្ការ។ គួរកត់សម្គាល់ថា តាំងពីសម័យនោះមកម្ល៉េះ នៅប្រទេសកម្ពុជា សក្តិភូមិមានការបង្កើតឱ្យមានលទ្ធភាពក្នុងការបន្តកេរមរតកដីភូមិ តាមមធ្យោបាយធ្វើពិធីអភិសេកដីភូមិឱ្យទៅជាដីភូមិរបស់វង្សត្រកូលដ៏ស្ដុកស្ដម្ភរបស់បុគ្គលដែលជាអ្នកទទួលមរតក ហើយដែលមានជំនឿលើសាសនា។ ជួនកាលនៅលើដីត្រួសត្រាយថ្មី អំណាចត្រួតត្រាកាន់កាប់ដីមានដល់ម្ចាស់ដី។ ម្ចាស់ដីគឺជានាយកផ្ដាច់មុខលើដីរបស់ខ្លួនទាំងអស់។

បន្ទាប់ពីមរណភាពរបស់ព្រះបាទជ័យវរ្ម័ន ពី គ.ស. ៤៨០-៥១៤ អំណាចរដ្ឋបានធ្លាក់មកក្នុងកណ្ដាប់ដៃរបស់ព្រះរាជបុត្រច្បងរបស់ព្រះអង្គ គឺព្រះបាទរុទ្រវរ្ម័ន គ.ស. ៥១៤ - ៥៥០ ។

ក្នុងសតវត្សរ៍ទី៦ និងជាពិសេសសតវត្សរ៍ទី៧ គឺជាសម័យកាលនៃវឌ្ឍនាការខាងសង្គម និងសេដ្ឋកិច្ចដ៏សំខាន់នៅ

---

(ពួកក្ញុំ)* : ក្ញុំ គឺជាអក្ខរាវិរុទ្ធបុរាណនៃពាក្យខ្ញុំ

ក្នុងសង្គមខ្មែរ ហើយការរីកចម្រើនដែលបានបណ្តាលឱ្យមានសភាពផ្លាស់ប្តូរនៅក្នុងវិស័យនយោបាយ។ ការសិក្សាឯកសារសិលាចារឹកនាសម័យនោះ បានបង្ហាញឱ្យឃើញថា ស្ថានភាពសេដ្ឋកិច្ចនៃចក្រភពបាភ្នំ នាសតវត្សរ៍ទី៧ មានលក្ខណៈពិសេសដែលត្រូវបានសម្រេចនៅភូមិភាគខាងជើងនៃប្រទេស ជាពិសេសនៅភូមិភាគកម្ពុជទេស តាមឯកសារចិន គឺជាចេនឡា ដីទំនាបនៃទន្លេមូន។ ការបង្រួបបង្រួមនៃទឹកដីចេនឡា និងបាភ្នំ នៅសតវត្សរ៍ទី៧ បានសម្រេចឡើងដោយសារផលវិបាកនៃកត្តាថ្មីៗនៅក្នុងសេដ្ឋកិច្ចប្រទេស ដែលមានលក្ខណៈពិសេសសម្រាប់សតវត្សរ៍ទី៧។ ហេតុនេះហើយ បានជាគេត្រូវពិនិត្យជាមួយគ្នានូវវឌ្ឍនាការខាងសេដ្ឋកិច្ចនៅសតវត្សរ៍ទី៦ ជាមួយគ្នានឹងការលូតលាស់នៃជនជាតិខ្មែរ ដែលរស់នៅលើដែនដីទាំងនោះ។

ឯកសារតាមសិលាចារឹកនាសតវត្សរ៍ទី៦ គឺជាប្រភពប្រកបដោយសក្ខីភាពដ៏ជាទីសង្ឃឹម ក្នុងការសិក្សាចងក្រងទម្រង់ជាមូលដ្ឋាននៃសេដ្ឋកិច្ចប្រទេសកម្ពុជាសម័យនោះ ជាពិសេសគឺទម្រង់នៃសង្គមមនុស្ស។

សភាពការណ៍ពិសេសនៃសម័យនោះ គឺការស្ថាបនាប្រព័ន្ធប្រឡាយបង្ហូរទឹកដ៏ធំៗដែលបានប្រព្រឹត្តទៅច្រើនជាងការស្ថាបនាបរវេសនដ្ឋាននានា។ នៅពេលនោះ ការស្ថាបនាប្រាសាទ និងវត្តអារាមពុំទាន់មានទំហំធំសម្បើម ដូចជានៅសម័យក្រោយៗមកទៀត។ ជាពិសេស ជាសម័យកាលដែលមានការធ្វើអំណោយទូទៅនៃទាសាទាសីក្ញុំ ដោយមិនធ្វើអំណោយឱ្យពួកក្ញុំទាំងគ្រួសារ ដោយមិនធ្វើអំណោយទាំងដីធ្លី ដល់អាទិទេព ឬដល់វត្តអារាមថ្មីៗ។ មហារាជនានា គឺជាបុគ្គលដែលជាអ្នកបានធ្វើអំណោយ

ដ៏សំខាន់សម្បើមជាងគេនៅទឹកដីរដ្ឋចេនឡា។ នៅលើទឹកដីរដ្ឋបាភ្នំ បើពិនិត្យតាមអត្ថបទសិលាចារឹកផ្សេងៗ ឃើញថា អំណោយនានាត្រូវបានបំពេញដោយពួកអភិជនម្រតាង ដែលជាក្ពុម្ភ (ជាម្ចាស់ដីធំៗ) និងប៉ោញ ដែលជាម្ចាស់ដីមធ្យម។ ការទាក់ទងនឹងអំណាចរបស់ពួកអភិជនទាំងពីរប្រភេទនេះ នៅតំបន់ស្រុកស្រែចម្ការ ពុំទាន់មានការសិក្សាស្រាវជ្រាវច្បាស់លាស់។

ការធ្វើអំណោយដី (ស្រែចម្ការ ភូមិដ្ឋាន) បានប្រព្រឹត្តទៅនៅលើដីចេនឡា (កម្ពុជា) ដោយហេតុថា នៅទីនោះ មានការបង្កើនសង្វាក់ស្ថាបនកម្ម បូជនីយដ្ឋាន វត្តអារាម និងការចាប់ផ្តើមកសាងភូមិដ្ឋានរបស់បណ្តាវង្សត្រកូលពួកក្ពុម្ភ។ នៅលើទឹកដីបាភ្នំ សង្វាក់ស្ថាបនកម្មបែបនេះ មានចលនាទៅមុខមិនសូវលឿនប៉ុន្មាន ទោះបីនៅទីនេះមានដែនដីប្រកបដោយស្រែចម្ការធំៗ នៅសតវត្សរ៍ទី៦ -៧ ក៏ដោយ។ ជាពិសេស សិលាចារឹកនាសម័យនោះ ត្រូវបានចារឹកទុកនៅបូជនីយដ្ឋាននៅជិតទន្លេសាប នៅតាមមាត់ទន្លេមេកុង និងនៅតាមទីវាលទំនាបទន្លេមូន (នៅប្រទេសថៃឡង់ដ៍)។ នៅតាមទីវាលទំនាបនៃទន្លេមេកុង ដែលមានថ្លុកត្រពាំង ដីសម្រាប់ដំណាំស្រូវប្រហែលជាពុំទាន់មានទំហំធំទូលាយនៅឡើយ។

លក្ខណៈពិសេស នៃស្ថានភាពសេដ្ឋកិច្ចប្រទេសនាសម័យនោះ បានបញ្ជាក់ឱ្យឃើញនូវការវិវត្តខាងនយោបាយនៃប្រទេសខ្មែរ។ នៅសម័យកាលនាទសវត្សរ៍ខាងចុង នៅចក្រភពបាភ្នំ មានទំនាស់ទាស់ទែងផ្ទៃក្នុងយ៉ាងខ្លាំងក្លា រវាងមជ្ឈដ្ឋាននយោបាយបីក្រុមដ៏សំខាន់ ហើយក្រុមនីមួយៗបានពឹងផ្អែកទៅលើដែនដីដែលប្រកបដោយដីស្រែចម្ការ។ នៅដែនដីខាងឧត្តរ គឺនៅតាម

ភាគខាងក្រោមនៃទន្លេរមូន រាជវង្សរបស់ កម្ពុ-ស្វ័យយម្ភូ ដែលកាលពីមុន បានស្ថិតនៅក្រោមឥទ្ធិពលរបស់រាជវង្សរាន្ទុវង្ស ចក្រភពបាភ្នំ លែងស្ថិតនៅក្រោមឥទ្ធិពលចក្រភពបាភ្នំ។ នៅដែនដីក្នុងភូមិភាគកណ្តាលនៃប្រទេស ព្រះបាទរុទ្រវរ្ម័ន ដែលជាមហារាជស្របច្បាប់ នៅសោយរាជសម្បត្តិ។ នៅដែនដីខាងទក្សិណ មានក្រុមរបស់រាជវង្សរបស់ព្រះអម្ចាស់គុណវរ្ម័ន ជាប្អូនប្រុស (បិតាជាមួយគ្នា) របស់ព្រះបាទរុទ្រវរ្ម័ន ដែលត្រូវគេធ្វើឃាត ហើយក្រុមនេះបានកាន់កាប់ស្ថានភាពរបស់ខ្លួននៅដែនដីនោះ។ ការបាក់បែកផ្ទៃក្នុងរបស់ចក្រភពបាភ្នំ បានកើតមានឡើងដោយសារផលវិបាកនៃស្ថានភាពពុំទាន់រឹងមាំនៃដែនដីដ៏ធំធេង ដណ្តើមបានមកដោយសារការធ្វើចម្បាំងរបស់ព្រះបាទហ្វាន់-ស៊ីម៉ាន់។ ដែនដីទាំងឡាយ ដែលត្រូវដណ្តើមបានមកស្ថិតនៅភូមិភាគខាងបស្ចិម និងខាងពាយ័ព្យនៃចក្រភព ហើយអ្នកគ្រប់គ្រងខ្មែរយើង បានជួបប្រទះការលំបាកក្នុងកិច្ចការកាន់កាប់ដែនដីទាំងនេះ ដោយហេតុថា ប្រាក់ចំណូលអំពីរបរអាជីវកម្មមិនអាចគ្របដណ្តប់លើការចំណាយកិច្ចការរក្សាដែនដីទាំងនេះបាន។ មិនតែប៉ុណ្ណោះ ការវិវត្តនៃការលូតលាស់ពូជពង្សជនជាតិខ្មែរបូរាណនៅទីនោះ  ពុំទាន់បានរឹងមាំធំធាត់នៅឡើយ។ ប៉ុន្តែ ដល់សម័យក្រោយមកទៀត ការលូតលាស់នៃជនជាតិខ្មែរបានរឹងមាំ ហើយនយោបាយនាសម័យចក្រភពអង្គរ ក៏បានពឹងផ្អែកពេញជំហរលើស្ថានភាពថ្មីបែបនេះ។

នាទសវត្សរ៍ទី៤-៥ នៃសតវត្សរ៍ទី៦ ការបែកបាក់ផ្ទៃក្នុងប្រទេស បានកើតមានឡើងកាន់តែខ្លាំង។ រាជវង្សរបស់កម្ពុ-

ស្វ័យយម្ភូ បានឡើងទៅជាព្រះញាតិវង្សានុវង្សនឹង “មហារាជភ្នំ” នៃចក្រភពបាភ្នំហើយបានផ្តល់ការគាំទ្រដល់ ព្រះបាទរូទ្រវរ្ម័ន ។

ព្រះថៅមួយអង្គរបស់ព្រះបាទរូទ្រវរ្ម័ន ដែលជាតំណាងរាជវង្សានុវង្ស នាមភវវរ្ម័ន បានរៀបអាពាហ៍ពិពាហ៍នឹងព្រះអង្គម្ចាស់ក្សត្រីមួយអង្គនៃរាជវង្សានុវង្សកម្ពុ-ស្វ័យយម្ភូ។

រឿងទេវកថាទាក់ទងនឹងដើមកំណើត នៃរាជវង្សានុវង្សបែបនេះ ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងរាជវង្សានុវង្សបាភ្នំ បានភ្ជាប់ញាតិវង្សរបស់ខ្លួនទៅនឹងកម្ពុ-ស្វ័យយម្ភូ ដែលជាតាបសឥសីមួយរូប ។ តាបសឥសី កម្ពុ - ស្វ័យយម្ភូ បានរៀបអាពាហ៍ពិពាហ៍នឹងព្រះនាងទេវីមេរៈ ជាប់រាជវង្សនឹងសូរ្យវង្ស ហើយបានផ្តើតជារាជវង្សានុវង្សនៃសូរ្យវង្ស ។ (យើងសូមបញ្ជាក់ថា សាជាថ្មី តាមការនិទាននៃរឿងទេវកថា ស្ថាបនករនៃរាជវង្សានុវង្សរបស់រដ្ឋខ្មែរ គឺបុគ្គលដែលជាបុព្វជិត ។ បន្ទាប់ពីមរណភាពរបស់រាជបុត្រច្បងនៃរាជវង្សានុវង្សសូរ្យវង្ស មក ព្រះបាទ ភវវរ្ម័ន បានក្លាយទៅជាមហាក្សត្រនៃប្រទេសកម្ពុជា (ចេនឡា)។

នៅសម័យកាលភាគពាក់កណ្តាលសតវត្សរ៍ទី៦ មហាក្សត្ររូទ្រវរ្ម័ន បានសោយទិវង្គត ។ តមក ព្រះបាទភវវរ្ម័ន និងរៀមច្បងនាម ចិត្រាសេនា ដែលធ្វើជាអគ្គសេនាកងទ័ព បានឡោមព័ទ្ធវាយយករាជធានី នៃចក្រភពបាភ្នំ ។ ក៏ប៉ុន្តែ ក្នុងចម្បាំងនេះ បក្សពួកខាងរាជវង្សានុវង្សចន្ទ្រាវង្ស មិនបានទទួលបរាជ័យទាំងស្រុងឡើយ ។ ម្លោះហើយរាជវង្សខាងចន្ទ្រាវង្ស បានទៅតាំងរដ្ឋធានីនៅក្នុងតំបន់អង្គរបូរី ហើយបានបន្តការគ្រប់គ្រងរដ្ឋពីទិសខាងត្បូង ។ ចំណែកព្រះបាទភវវរ្ម័ន រាជអំណាចរបស់ព្រះអង្គបានគ្របដណ្តប់លើដែនដីស្រែចម្ការពីកាលមុន ហើយ

ដែលស្ថិតនៅតាមមាត់ទន្លេមេកុង និងតាមទីវាលទំនាបនៃទន្លេមូន។ ចាប់តាំងពីពេលនោះមក ព្រះនាមព្រះអង្គត្រូវបានគេស្គាល់ក្នុងប្រវត្តិសាស្ត្រថា ជាព្រះបាទភវវរ្ម័នទី១ (ជិត គ.ស. ៥៥០ ដល់ជិត គ.ស. ៦០០)។ នៅពេលនោះ ចក្រភពខ្មែរក៏បានទទួលការបែងចែកជាតថភាព។

សម័យកាលនោះ ផ្ទៃក្នុងនៃសង្គមខ្មែរបានវិវត្តទៅមុខយ៉ាងខ្លាំង ហើយបានឈានឡើងទៅកាន់សម័យសក្តិភូមិ។ អង្គការចាត់តាំងថ្មីខាងសង្គមកិច្ចនៃសង្គមខ្មែរ ក៏បានកកើតឡើង ហើយបានរីកចម្រើន ដោយធ្វើដំណើរចម្លងពីសង្គមនៃសម័យចក្រភពបាភ្នំ ឆ្ពោះទៅកាន់សង្គម ដែលជាមូលដ្ឋាននៃអនាគតចក្រភពកម្ពុជទេស (គឺចក្រភពអង្គរ)។

នៅជិតសម័យកាលនៃ គ.ស. ៦០០ រដ្ឋអំណាចទាំងមូលនៃដែនដីចេនឡា និងបាភ្នំ បានធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់អគ្គមេបញ្ជាការសឹក ចិត្រាសេនា ដែលបានឡើងសោយរាជសម្បត្តិក្នុងគោរមនាមថា ព្រះបាទមហេន្ទ្រវរ្ម័ន (ជិត គ.ស. ៦០០ ដល់ជិត គ.ស. ៦១៥ )។

ឯកសារប្រវត្តិសាស្ត្រមួយចំនួននៃសតវត្សរ៍ទី៧ និងសតវត្សរ៍ទី៨ បានបង្ហាញឱ្យឃើញនូវទិដ្ឋភាព នៃទម្រង់ខាងសង្គមកិច្ច និងសេដ្ឋកិច្ចនៃសង្គមខ្មែរសម័យនោះ។ នៅក្នុងទម្រង់នេះ មានរបបទាសភាព និងសក្តិភូមិ។ បណ្តាជនានុជនដែលមានការទទួលស្គាល់តាមផ្លូវច្បាប់ថាជា “ អ្នកជា ” គឺជាអ្នកស្រុកស្រែចម្ការ ដែលជាអ្នកទទួលបន្ទុកបង់ពន្ធដារជូនឃ្លាំងព្រះរាជទ្រព្យ។ ក្នុងបណ្តាអ្នកទាំងនេះ មានស្រទាប់មនុស្សដែលមានទ្រព្យសម្បត្តិ ហើយមានឋានន្តរនាមថា ជា “ តាង ”។

នៅស្រុកស្រែចម្ការទាំងឡាយ មានស្រទាប់អភិជនដែលជាគ្រហស្ថ ឬជាបព្វជិត។ អ្នកទាំងនោះគឺជាក្តុម្ពី ឬជាម្ចាស់ដីមធ្យម ដែលបានប្រើកម្លាំងរបស់ពួកទាសាទាសីក្ញុំ។ ពួកទាសាទាសីក្ញុំ ជាវណ្ណៈមនុស្សដែលគ្មានទ្រព្យសម្បត្តិ ត្រូវគេបង្ខំឱ្យធ្វើការនៅតាមកសិដ្ឋាន ហើយជាជនដែលគេអាចឱ្យជាអំណោយ។ ប៉ុន្តែ ពួកគេមិនអាចធ្វើអំណោយអ្នកទាំងនេះទាំងគ្រួសារបានឡើយ ខុសពីពួកទាសាទាសីក្នុងរបបសក្តិភូមិកម្ពុជា នាសម័យចក្រភពអង្គរ។

ម្ចាស់លើទឹកដីទាំងអស់ គឺមហារាជ។ ក្រៅពីនេះ មានអ្នកម្ចាស់ដី ដែលជាឯកជន ឬជាសមូហភាព ដូចជាវត្តអារាម។ មានពួកម្ចាស់ដីតូចៗ គេឱ្យឈ្មោះ ប៉ោញ ដែលមិនចូលជាមនុស្សក្នុងសហគមន៍ទេ តែមានសិទ្ធិប្រើកម្លាំងពួកទាសាទាសីក្ញុំ។ ស្រទាប់អភិជនមួយប្រភេទ គឺពួកអភិជនម្រតាង ដែលជាក្តុម្ពី គឺជាម្ចាស់ដីធំៗ ដែលប្រើកម្លាំងពួកទាសាទាសីក្ញុំ។ ពួកទាសាទាសីក្ញុំធ្វើការជាប្រយោជន៍ដល់វត្តអារាម ក្រោមការត្រួតត្រារបស់ព្រះគម្តែង ឬម្រតាញជាចៅអធិការវត្ត។ នៅពេលនោះ ចៅអធិការវត្តភាគច្រើន គឺជាព្រហ្មចារ្យដែលបានបំពេញមុខងារជាមុខមន្ត្រីរបស់រាជការទៀតផង។ មានស្រទាប់អភិជនមួយប្រភេទទៀតដែលមានឋានន្តរនាមជា “ ព្រះម្រតាង ” គឺជាព្រាហ្មចារ្យផងជាក្តុម្ពីផង ហើយអភិជនទាំងនេះ បានទទួលដីជារង្វាន់ដល់សកម្មភាពរបស់ខ្លួន។ មិនតែប៉ុណ្ណោះ “ ព្រះម្រតាង ” អាចទាំងធ្វើអំណោយដីដល់វត្តអារាមទៀតផង។ ស្រទាប់បណ្តាជនមួយភាគធំនៅស្រុកស្រែចម្ការ គឺ “ អ្នកស្រែ ” ( តាមសិលាចារឹក ) គឺអ្នកទាំងនេះហើយ ដែលជាអ្នកបង់ពន្ធដារជូនឃ្លាំងព្រះរាជទ្រព្យ

គឺជាអ្នកដែលគេបង្ខំ ឱ្យបំពេញការងារ ជាប្រយោជន៍របស់រាជការ គឺជាអ្នកដែលគេធ្វើកំណែនឱ្យចូលបម្រើកងទ័ព។ សភាពចុះឱនថយនៃស្រទាប់ជនានុជនប្រភេទនេះ នៅសម័យកាលខាងចុងនៃសម័យកាលចក្រភពបាភ្នំ បានបណ្តាលឱ្យមានការថយកម្លាំងដល់មហិទ្ធិឫទ្ធិរបស់កម្ពុជទេស។

នៅសម័យនោះ ប្រពៃណីសហគមន៍មានឥទ្ធិពលរបស់ខ្លួនខ្លាំង ភូមិសហគមន៍អាចដឹកនាំរឿងក្តីក្តាំនៅតុលាការ ជាមួយពួកអភិជនដូចជាពួកម្រតាង ឬចៅអធិការវត្តអារាម ហើយការប្រគល់សិទ្ធិកាន់កាប់ដីដល់បុគ្គលណាមួយ “ ប៉ោញ ” នឹងប្រព្រឹត្តទៅបាន លុះត្រាកាលណាមានសេក្តីយល់ព្រមពីសហគមន៍ភូមិជិតខាងនានា។ នៅសម័យនោះ ការបង្ខិតបង្ខំឱ្យបំពេញការងារលើដីធ្លីរបស់ពួកអភិជន និងព្រាហ្មាចារ្យ មានលក្ខណៈមិនស្របតាមសេដ្ឋកិច្ច ដោយហេតុថា ការជម្រះសម្អាតដីស្រែចម្ការ និងការស្ថាបនាប្រព័ន្ធបង្ហូរទឹកត្រូវបានបំពេញដោយសារហត្ថារបស់បណ្តាអ្នកស្រុកស្រែ។ ដីស្រែចម្ការកាប់គាស់ប្រកបដោយប្រឡាយបង្ហូរទឹក ត្រូវបានប្រគល់ដល់ពួកតំណាងវណ្ណៈសក្តិភូមិធំៗ និងដល់វត្តអារាមនានា ហើយការធ្វើស្រែចម្ការជាប្រយោជន៍អ្នកទាំងនេះ បានប្រព្រឹត្តទៅដោយពួកទាសាទាសីក្ញុំ។

ទាសាទាសីក្ញុំទាំងឡាយ នៅពេលក្រោយមក បានប្រែក្លាយខ្លួនបន្តិចម្តងៗ ទៅជាកសិករក្នុងរបបសក្តិភូមិ។ ប្រសិនបើនៅសតវត្សរ៍ទី៦ គ្មានការទទួលស្គាល់ដល់សិទ្ធិគ្រួសាររបស់ទាសាទាសីក្ញុំទេ ទោះបីជួនកាលមានការធ្វើអំណោយពួកទាសាទាសីក្ញុំទាំងម្តាយទាំងកូនក្តី នោះនៅសតវត្សរ៍ទី៧ - ទី៨ ក៏គ្មានការធ្វើអំណោយ ឬការលក់ទាសាទាសីក្ញុំទាំងគ្រួសារដែរ។ ការងារ

របស់ពួកទាសាទាសីក្តី នៅសម័យនោះ គ្មានការកំណត់ច្បាស់លាស់ (ជាពិសេស គឺគ្មានកម្រិតជាច្បាប់ច្បាស់លាស់)។

គួរកត់សម្គាល់ថា នៅក្នុងសង្គមខ្មែរ ស្រ្តីភេទបានកាន់កាប់តំណែង និងស្ថានភាពខ្ពង់ខ្ពស់ (ស្ថានភាពបែបនេះរបស់ស្រ្តីមានលក្ខណៈប្រហាក់ប្រហែលនឹងស្ថានភាពស្រ្តីមន ឬស្រ្តីកូមាដែរ)។ ហេតុនេះហើយ បានជាមានបណ្តាស្រ្តីនៃវណ្ណៈអភិជនម្ចាស់ដីដែលបានធ្វើជាម្ចាស់ដីធ្លី និងភូមិដ្ឋានរបស់ខ្លួន ហើយជួនកាល ស្រ្តីភេទបានកាន់កាប់តំណែងខ្ពង់ខ្ពស់នៅក្នុងកិច្ចការរដ្ឋទៀតផង។

តាមធម្មតា ប្រធានភូមិសហគមន៍នៅស្រុកស្រែ ឬនៅក្របខណ្ឌរាជការថ្នាក់មធ្យម មានឋានន្តរនាមជា " តាង "។ ក្របខណ្ឌរាជការមានថ្នាក់ខ្ពស់បន្តិចទៀត មានឋានន្តរនាមជា " ប៉ោញ "។ រីឯ អស់មុខមន្ត្រីដែលកាន់កាប់មុខតំណែងជាន់ខ្ពស់បំផុត មានឋានន្តរនាមជា " ម្រតាង " ជា " គុរុងម្រតាង " ( ម្រតាងជាប់សាច់ញាតិនឹងរាជវង្ស )។

គឺបណ្តាក្របខណ្ឌរាជការ " ប៉ោញ " និងបណ្តាមន្ត្រី " ម្រតាង " ទាំងនេះហើយ ដែលបានបំពេញមុខងារជាមន្ត្រី " ក្លោញ " ( គឺមេក្លោង, ប្រធាន )។ មន្ត្រី " ក្លោញ " ធ្វើជាចៅហ្វាយស្រុក ចៅហ្វាយខេត្ត។ ក្នុងប្រភេទមុខមន្ត្រី មានបណ្តាព្រាហ្មចារ្យ ដែលបំពេញមុខងារជាមន្ត្រីទទួលបន្ទុកខាងវប្បធម៌ ខាងកិច្ចការរក្សាគ្រឿងកេតណាភណ្ឌ ដែលនៅក្នុងនេះ មានវត្តអារាម និងដីស្រែចម្ការច្បារដំណាំ។

បណ្តាថ្នាក់ដឹកនាំរដ្ឋជាន់ខ្ពស់ មានអ្នកដឹកនាំជាមន្ត្រីជាន់ខ្ពស់ដែលជាគ្រហស្ថ និងព្រាហ្មចារ្យ ហើយដែលមានឋានន្តរនាម

ជា “ វ្រះកម្រតាងអញ ” ( ព្រះគម្តែងអញ ) ។ មន្ត្រីជាន់ខ្ពស់បែបនេះ មានចំនួនពីពីររយដល់បីរយរូប ។ ពាក្យថា ព្រះគម្តែងអញមានន័យថា “ បុគ្គលនៃព្រះអំណាចរដ្ឋ ”។ យើងសូមបញ្ជាក់ថាពាក្យ “ វ្រះកម្រតាងអញ ” មិនមែនមានន័យសម្រាប់តែសម្គាល់បណ្តាមន្ត្រីជាន់ខ្ពស់របស់រដ្ឋប៉ុណ្ណោះទេ គឺមានន័យសម្រាប់សម្គាល់វត្តអារាម និងបណ្តាអាទិទេពបន្ទាប់បន្សំទៀតផង ។ ន័យពីរបែបរបស់ពាក្យនេះ ដែលភ្ជាប់កិច្ចការរដ្ឋទៅនឹងអាទិទេពបានចាប់ផ្តើមមានមកតាំងសតវត្សរ៍ទី៧ ហើយនៅពេលក្រោយមកបានបង្កើតជាមូលដ្ឋាន នៃមនោគមន៍ ក្នុងពិធីធ្វើសក្ការៈបូជាទេវ-រាជា ដែលជាសំយោគរវាងសាសនា និងអំណាចអាណាចក្រ។ គឺជាមនោគមន៍ពុំធ្លាប់មានពីសម័យមុនៗឡើយ ។

ក្រៅអំពីដីស្រែចម្ការ ដែលជាសម្បត្តិទ្រព្យរបស់ពួកអភិជនប៉ោញ និងម្រតាង មានទាំងដីស្រែចម្ការ ដែលជាសម្បត្តិទ្រព្យរបស់អាស្រមខាងព្រហ្មញ្ញសាសនា និងរបស់វត្តខាងពុទ្ធសាសនា ។ នៅជិតដីស្រែចម្ការរបស់គណៈសង្ឃ រមែងមានដីស្រែចម្ការរបស់ពួកសក្តិភូមិ ដែលជាគ្រហស្ថ ។ ជាញឹកញាប់ ពួកអភិជនសក្តិភូមិបានធ្វើការបរិច្ចាគដីមួយភាគរបស់ខ្លួន ដើម្បីសង់ព្រះវិហារ ហើយតាមរបៀបនេះ ពួកសក្តិភូមិបានទទួល “ សិទ្ធិ ” ក្នុងការប្រើប្រាស់ដីដទៃ ដែលនៅសល់ ឬប្រើប្រាស់ចំណូលដែលបានពីផលដីនៃព្រះវិហារ ។ គេអាចយល់ថា ពួកអភិជនសក្តិភូមិធំៗមិនបានធ្វើបរកសិកម្មខ្លួនឯងទេ ហើយបណ្តាទាសាទាសីក្ញុំ បានទៅជាអ្នកជាប់ពន្ធអាករ និងទទួលបន្ទុកក្នុងការបំពេញពលកម្មលើដី ។

កិច្ចការទាំងអស់ទាក់ទងនឹងដីធ្លី ព្រមទាំងការទទួលសិទ្ធិជាម្ចាស់ដីរបស់ពួកសក្តិភូមិ បើនិយាយឱ្យចំ គឺសិទ្ធមិនបង់ពន្ធដារ ត្រូវបានអនុម័តដោយមហារាជ ហើយកិច្ចការផ្ទេរមរកតដី និងការចាត់តាំងបុគ្គល ឱ្យទទួលខុសត្រូវចំពោះ របរកសិកម្មលើដីត្រូវបានអនុវត្តដោយអង្គការរដ្ឋ។

ស្ថានភាពខាងការងារកសិកម្ម នៅសម័យខាងដើមសតវត្សរ៍ទី៧ មានលក្ខណៈស្មុគស្មាញ ដោយហេតុថា ដូចពេលមុនមានការអនុវត្តភាពខុសគ្នាក្នុងការពង្រីករបរកសិកម្មនៅលើដែនដីចាស់ទាំងឡាយ និងនៅទីវាលទំនាបនៃទន្លេមូន។ ជាមួយនឹងការធ្វើអំណោយដី មានការកាប់គាស់ដីថ្មី ជាពិសេសនៅប៉ែកខាងឧត្តរ ហើយដីទាំងនេះ ដូចជាដីស្រែ និងសួនច្បារ គឺគេអាចទទួលបានដោយការទិញ ហើយក្នុងការលក់ដូរបែបនេះ ជាញឹកញយមានការប្រើប្រាស់ពួកទាសាទាសីកុំ។ នៅលើដែនដីចាស់ក្នុងភូមិភាគកណ្តាល និងខាងត្បូង គឺចៅហ្វាយក្រុងនានាពួកក្តុម្ពីធំៗ ដែលទាក់ទងនឹងការកាន់កាប់អំណាចបានទៅជាអ្នកធ្វើអំណោយ ឬជាអ្នកដែលបំពេញកិច្ចការលក់ដូរដីទាំងនេះ។ ការលក់ទិញដី បានប្រព្រឹត្តទៅក្រោមការទទួលខុសត្រូវរបស់រដ្ឋបាល។ ការធ្វើអំណោយដីមានលក្ខណៈពីរយ៉ាង ម៉្យាងគឺអំណោយរបស់អ្នកម្ចាស់ដី ដែលជាគណៈសង្ឃដល់ពួកអភិជនគ្រហស្ថ សក្តិភូមិ ហើយម៉្យាងទៀត គឺអំណោយរបស់ព្រះមហារាជ ឬរបស់អភិជនសក្តិភូមិដល់គណៈសង្ឃ។ នៅក្នុងការធ្វើអំណោយរបស់បណ្តាអភិជនសក្តិភូមិ ចំណូលមួយភាគត្រូវបានដល់រដ្ឋ។

នៅសម័យនោះ មានប្រភេទដីភូមិដ្ឋានដែលប្រកបដោយកម្មសិទ្ធិ និងឯកសិទ្ធិ ដែលម្ចាស់ដីអាចប្រគល់ជាកេរមរតកដល់

កូនចៅ។ កម្មសិទ្ធិដីបែបនេះ គឺជាកម្មសិទ្ធិលើដីរបស់រាជវង្សក្សត្រ។ ចំណែកឯដីរបស់ពួកអភិជនសក្តិភូមិ ពួកនេះត្រូវបង់ពន្ធដារមួយភាគដល់រដ្ឋ ហើយមិនអាចប្រគល់ដីជាកេរមរតកដល់កូនចៅបានឡើយ។ នៅលើដីស្រែចម្ការទាំងនេះ អ្នកបង្កើតផលដំណាំ គឺពួកទាសាទាសីក្ញុំ ហើយការងារ និងស្ថានភាពរបស់ពួកអ្នកទាំងនេះ នៅសម័យនោះពុំមានការបញ្ជាក់ច្បាស់លាស់តាមសិលាចារឹក។ ចំពោះ " អ្នកស្រុកស្រែ " ដែលធ្វើរបរដំណាំលើដីរបស់ខ្លួន ពន្ធដារត្រូវបានកំណត់មិនមែនតាមចំនួននៃផលដំណាំទេ ក៏ប៉ុន្តែ តាមទំហំដី ព្រោះអ្នកស្រែត្រូវបង់ពន្ធដារជាអង្ករដល់វត្តអារាម។

ឥស្សរជនទាំងឡាយប្រកបដោយគោរមងារ " ប៉ោញ " គេអាចប្រៀបធៀបពាក្យទាំងនេះទៅនឹងពាក្យ " ពញា " នាមធ្យមសម័យ មានសិទ្ធិធ្វើជាម្ចាស់ដី។ ក៏ប៉ុន្តែ ខុសពីបណ្តាពួកក្សត្រដែលជាសមាជិកនៃរាជវង្សានុវង្ស ឥស្សរជន " ប៉ោញ " អាចធ្វើអំណោយកម្មសិទ្ធិដី របស់ខ្លួនជាកេរមរតកដល់កូនចៅ។ ពួកឥស្សរជន " ប៉ោញ " ត្រូវបង់ពន្ធអាកររបស់ខ្លួនមួយភាគដល់វត្តអារាម មួយភាគទៀតដល់ព្រះមហារាជ ដែលជាអ្នកធ្វើអំណោយដី។ នៅក្នុងកាលៈទេសៈខ្លះ អ្នកធ្វើអំណោយដី គឺជាគ្រហស្ថដែលជាជនសក្តិភូមិ ក៏ប៉ុន្តែ ត្រូវតែបង់ពន្ធអាករដល់វត្តអារាម និងរតនាគាររបស់ព្រះមហារាជ។ បានសេចក្តីថា នៅពេលនោះ ផលភូមិករដីត្រូវបានបែងចែកជាបីភាគ គឺភាគរបស់វត្តអារាម ភាគរបស់ព្រះមហារាជ និងភាគរបស់ជនសក្តិភូមិជាគ្រហស្ថ។

បើតាមការសន្និដ្ឋាន ដីស្រែចម្ការរបស់វត្តអារាម និងរបស់វណ្ណៈអភិជនមានទំហំដល់មួយភាគបីនៃទំហំដីទូទៅ។

សភាពនៃរបបសក្តិភូមិ បានលេចរូបរាងឡើង នៅក្នុងវិស័យកសិកម្ម មិនមែនតែក្នុងការកកើតវណ្ណៈនៃ “ ព្រះអ្នកស្រែ ” ដែលបង់ពន្ធដារជាអង្ករដល់ព្រាហ្មស្រម និងវត្តអារាមប៉ុណ្ណោះទេ ក៏ប៉ុន្តែ បានលេចរូបរាងឡើងក្នុងរបបផ្ទេរដីភូមិដ្ឋានពីបុគ្គលមួយទៅបុគ្គលមួយទៀត ដោយមានទាំងពួកទាសាទាសីក្ញុំផង។ ជាញឹកញាប់ ការផ្ទេរក្រុមពួកក្ញុំ បានប្រព្រឹត្តទៅដោយមានការផ្ទេរពួកនាយកក្ញុំ ថែមទៀត។

កម្មសិទ្ធិដីជាមូលដ្ឋានមិនមែនជាដីភូមិទេ គឺដីសម្រាប់ដំណាំស្រូវ។ ពួកសក្តិភូមិអាចមានដីស្រែចម្ការនៅទីកន្លែងផ្សេងៗ។ នៅតាមសិលាចារឹក ច្រើនមានការបញ្ជាក់អំពីព្រំប្រទល់ដីស្រែ ប៉ុន្តែ មិនបានបញ្ជាក់អំពីតម្លៃស្រែទេ។ កម្មសិទ្ធិដីមានទាំងច្បារដំណាំ សួនច្បារ ដីព្រៃ និងត្រពាំងទឹក។

មូលដ្ឋានខាងសង្គមកិច្ច និងសេដ្ឋកិច្ច គឺមានទិដ្ឋភាពដូចការពណ៌នាខាងលើ នៅប្រទេសកម្ពុជា ជំនាន់ចេនឡា។ ទាំងអស់នេះ គឺជាកត្តាសំខាន់ ដើម្បីបំភ្លឺអំពីប្រវត្តិសាស្ត្រនយោបាយនៃប្រទេសសម័យនោះ និងអំពីរបៀបនៃការចាប់បដិសន្ធិកកើតចក្រភពកម្ពុជទេសដ៏ធំធេង ដែលអ្នកប្រវត្តិសាស្ត្រខ្លះយល់ថាជាបាតុភូតមិនអាចពន្យល់បាន ហើយដែលបានចាប់បដិសន្ធិកើតឡើង ហើយរលើងរលំបាត់ទៅវិញ ដោយពុំដឹងមូលហេតុអ្វីមួយខាងនយោបាយ។ តាមការពិត ការកកើតនៃចក្រភពខ្មែរមានមកនៅពេលក្រោយការកកើតរបបសក្តិភូមិ នៅក្នុងសង្គមខ្មែរ។ ហេតុនេះហើយ បានជារបបនេះបានលូតលាស់ពេញបន្ទុកនៅសម័យកាលនៃចក្រភព ហើយវិបត្តិនៃចក្រភព ដែលបានកើតមាននៅពេលក្រោយមក ក៏មានប្រភពពីរបបសក្តិភូមិដែរ។

ការបង្រួបបង្រួមដែនដីខ្មែរទាំងឡាយ និងការទទួលកម្មសិទ្ធិលើដែនដីទាំងនេះ ដោយមហារាជនានានៃចក្រភពបាភ្នំនៅទិសទក្សិណ បានប្រព្រឹត្តទៅនៅក្នុងរជ្ជកាលនៃព្រះរាជបុត្ររបស់ព្រះបាទមហិន្ទ្រវរ្ម័ន គឺជាព្រះបាទឦសានវរ្ម័នទី១ (ជិត គ.ស. ៦១៥ - ៦៣៥)។ នៅឆ្នាំ៦៣០ រដ្ឋធានីរបស់ចក្រភពបាភ្នំ ត្រូវបានទ្បោមព័ទ្ធ ហើយដែនដីទាំងអស់បានចូលមកក្នុងសមាសភាពនៃប្រទេសកម្ពុជាចេនឡា ដែលនៅសម័យនោះ មានទាំងដែនដីតាមទីវាលទំនាបនៃទន្លេមេកុង និងដែនដីខាងទិសពាយព្យ ដែលស្ថិតនៅតាមឆ្នេរសមុទ្រខ្មែរ សព្វថ្ងៃហៅ ឈូងសមុទ្រសៀម។ ការបើកទ្វារប្រទេសទៅកាន់សមុទ្រ បានធ្វើឱ្យប្រទេសកម្ពុជាចេនឡា ក្លាយទៅជាមហាអំណាចសមុទ្រ ដោយហេតុថាបេសកកម្មខាងពាណិជ្ជកម្ម និងខាងកិច្ចការទូតខ្មែរ បានតាំងនៅរហូតដល់កំពង់ផែខាងត្បូងនានា នៃប្រទេសចិន ជំនាន់អធិរាជស៊ូយ។

ការបង្រួបបង្រួមដែនដីខ្មែរបានប្រព្រឹត្តិទៅ មិនមែនដោយផលវិបាកនៃជោគជ័យយោធា ឬដោយការប្រឹងប្រែងខាងនយោបាយទេ គឺកើតឡើងដោយសារឯកភាពនៃការរីកចម្រើនខាងសេដ្ឋកិច្ចនៃដែនដីទាំងនេះ ហើយការរីកចម្រើននេះ បានផ្តល់លទ្ធភាពក្នុងការបង្រួបបង្រួមដែនដីចក្រភពទូទៅ។ ព្រះបាទឦសានវរ្ម័នទី១ មិនបានតាំងខ្លួនព្រះអង្គជាតំណាងរាជវង្សនៅលើដែនដីទីវាលទំនាបនៃទន្លេមូន ឬជាតំណាងរាជវង្សនៅវ្យាធបូរៈ ស្រុកបាភ្នំ សព្វថ្ងៃទេ រាជធានីថ្មីរបស់ព្រះអង្គ ឈ្មោះឥសាណបូរៈ បានស្ថិតនៅត្រង់កន្លែងជួបគ្នានៃដែនដីរដ្ឋបាភ្នំ និងដែនដីកម្ពុជាបូរាណ នៅតំបន់ស្រុកសម្បូរព្រៃគុក តាមទន្លេ

មេកុង ។ រដ្ឋធានី បានលូតលាស់រហ័សដូចជារដ្ឋធានីរបស់អាស៊ីដទៃនៅមធ្យមសម័យដែរ ហើយរាជអំណាចមហាក្សត្របានគ្របដណ្តប់លើបណ្តាជន បន្ទាក់បន្ទាញឱ្យបណ្តាជន ចូលបំពេញមុខងារក្នុងកិច្ចការរាជការ ក្នុងកិច្ចការយោធា ព្រមទាំងបម្រើរាជវាំង និងកងទ័ពរបស់ប្រទេស ។ នៅពេលក្រោយមក បណ្តាជននៅរដ្ឋធានីបានកើនដល់ ២០ពាន់នាក់ ហើយចំនួននេះ ក៏កាន់តែកើនជាលំដាប់ ។

ការរីកចម្រើនដ៏ឆាប់រហ័សខាងសង្គមកិច្ច និងសេដ្ឋកិច្ចនៅលើដែនដីខ្មែរ បានផ្តល់លទ្ធភាពដល់ការលូតលាស់ខាងវប្បធម៌តាមបែបបទថ្មីៗនាសតវត្សរ៍ទី៧ - ទី៨ ។ សម័យកាលនេះតាមសារៈសំខាន់របស់ខ្លួន អាចប្រៀបបានទៅនឹងសម័យកាលនៃចក្រភពបាភ្នំ និងសម័យកាលចក្រភពអង្គរ សតវត្សរ៍ទី៩ -ទី១៣ ព្រមទាំងនឹងសម័យកាល ប្រទេសកម្ពុជាសក្តិភូមិ ប្រកបដោយប្រជាជនខ្មែរ ក្នុងសតវត្សរ៍ទី១៤ - ទី១៨ ។ លក្ខណៈពិសេសនានានៃវប្បធម៌នេះ បានលេចជារូបរាងឡើង ក្នុងវិស័យស្ថាបត្យកម្មដែលមានស្ថាបនកម្មប្រាសាទធំៗ ប្រកបដោយរូបរាងជាមហាចេតិយ សង់អំពីឥដ្ឋ ក្នុងវិស័យការផ្សព្វផ្សាយភាសាខ្មែរតាមសិលាចារឹក ក្នុងវិស័យសាសនាដោយការគោរពព្រះឥសូរ រួមគ្នានឹងព្រះវិស្ណុ បង្កើតបានជាសំយោគក្នុងរូបភាពនៃព្រះហរិហរៈ ហើយដែលជានិន្នាការនៃសាសនានៅសម័យបាភ្នំ ។ ការលូតលាស់ថ្មីនៃរបបគ្រប់គ្រងរដ្ឋខ្មែរ បានផ្តល់លទ្ធភាព ឱ្យមានការបង្កើតប្រព័ន្ធអង្គការរដ្ឋដ៏ស្មុគស្មាញច្រើនបែបយ៉ាង ប្រកបដោយការបង្កើនទំហំនៃរាជពិធីដ៏ស្មុគស្មាញនៅក្នុងព្រះបរមរាជវាំង ។ ការរៀបចំរាជពិធីដ៏ស្មុគស្មាញនៅព្រះបរមរាជវាំង ដែលមានលក្ខណៈពាក់

កណ្តាលជាពិធីសាសនា ពាក់កណ្តាលជាពិធីតាមប្រពៃណីខ្មែរ ព្រមទាំងរាជពិធីគាល់មហារាជ។ ទាំងអស់នេះ បានកើតមាន នាសម័យរជ្ជកាលព្រះបាទឦសានវរ្ម័នទី១ ហើយបានបន្តមក ទៀតយ៉ាងគគ្រឹកគគ្រេង រហូតដល់សម័យកាលចក្រភពអង្គរ។

នៅក្រោមរជ្ជកាលព្រះបាទឦសានវរ្ម័ន មានការខិតខំពង្រឹង រដ្ឋអំណាចមជ្ឈិមរបស់ប្រទេស។ នៅកំពូលរដ្ឋាភិបាលប្រទេស មានរដ្ឋមន្រ្តីប្រាំរូប។ ប្រទេសត្រូវបានបែងចែកជាភូមិភាគរដ្ឋការ ចំនួន៣០ ហើយភូមិភាគនីមួយៗមានប្រមុខភូមិភាគឬស្តេចត្រាញ់ ជាអ្នកគ្រប់គ្រង។ នៅសម័យនោះ វង្សត្រកូលធំៗខ្លះបានរក្សា តំណែងជាប្រមុខភូមិភាគធំៗ។

ការពង្រឹងរដ្ឋអំណាចកំពូលរបស់ប្រទេស បានប្រព្រឹត្តទៅ ដោយមានការផ្លាស់ប្តូរ នៅក្នុងជីវភាពខាងសតិអារម្មណ៍ របស់ សង្គមខ្មែរ។ នៅសម័យកាលខាងដើមនៃចក្រភពបាភ្នំ សង្គមខ្មែរ កាន់ពុទ្ធសាសនាផង ព្រហ្មញ្ញសាសនាផង។ តមក បានកាន់ សាសនាព្រះវិស្ណុ ហើយបានគោរពដល់ព្រះហរិហរៈ នៅសម័យ ខាងដើមនៃចក្រភពកម្ពុជាចេនឡា ដែលនៅពេលនោះ មានការ ពង្រឹងរដ្ឋអំណាចរបស់មហារាជ និងរដ្ឋមន្រ្តី ព្រមទាំងអស់មុខ មន្រ្តីនាហ្មឺនទាំងឡាយ ដោយការគោរពសាសនាព្រះឥស្វរ ហើយ ការពង្រឹងរដ្ឋអំណាចបែបនេះ បានបង្កើតឱ្យមានមហិទ្ធិឫទ្ធិដល់ ប្រទេស ដែលចេះតែមានបន្តមក ពេញសម័យកាលដ៏ត្រចះត្រចង់ នៃចក្រភពអង្គរ។ ការផ្លាស់ប្តូរជំនឿឆ្ពោះមកការគោរពសាសនា ព្រះឥស្វរ បានសម្រេចឡើងនៅក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី២ (គ.ស.៦៣៥ - ៦៥៥) ហើយពីសម័យកាលនោះមក មាននៅ សល់សិលាចារឹក និងដំណែលប្រាសាទបាយាង និងប្រាសាទ

ដទៃទៀត ក៏ប៉ុន្តែ ព្រឹត្តិការណ៍ទាំងអស់នេះ មិនមែនជាភស្តុតាងបញ្ជាក់ថា មានការឈប់គោរពព្រះហរិហរៈ ទេ។ នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី១ (គ.ស.៦៥៥ - ៦៨១) មានការពង្រីកដែនដីនៃប្រទេសកម្ពុជា សម័យចេនឡា តទៅទៀត។ កងទ័ពប្រទេសដែលមានការរៀបចំពង្រឹងជាថ្មី ដោយការបង្កើតបន្ថែមកងទ័ពសេះ បានចាប់ផ្តើមធ្វើយុទ្ធនាការទៅលើដែនដីភាគខាងលើនៃទន្លេមេកុង រហូតដល់តំបន់វៀងចន្ទ និងហ្លួងព្រះបាង សព្វថ្ងៃ ហើយដែលនៅទីនោះ មានជនជាតិនានាជាជនជាតិបងប្អូននឹងជនជាតិខ្មែររស់នៅ គឺជនជាតិមន - ខ្មែរ។

នៅសម័យកាលនៃទសវត្សរ៍ទី៨ នាសតវត្សរ៍ទី៧ វិបត្តិបង្កើតបានជាការតស៊ូប្រយុទ្ធគ្នា រវាងមជ្ឈមណ្ឌលពីរដ៏សំខាន់ជាងគេនៃប្រទេសខ្មែរនៅសម័យនោះ គឺមជ្ឈមណ្ឌលក្នុងភាគកណ្តាលប្រទេស និងមជ្ឈមណ្ឌលខាងទក្សិណ និងខាងមាត់សមុទ្រនៃប្រទេស។ នៅក្នុងសម័យនៃការគ្រប់គ្រងរបស់មហាក្សត្រយានី ជ័យ ទេវី ដែលជាអតីតរាជិនីរបស់ព្រះបាទជ័យវរ្ម័នទី១ (គ.ស. ៦៨១ រហូតដល់ពេលក្រោយ គ.ស. ៧១៣) មជ្ឈមណ្ឌលក្នុងភាគកណ្តាលប្រទេសបានចុះទន់ខ្សោយ ហើយនៅសម័យខាងដើមសតវត្សរ៍ទី៧ ការតស៊ូប្រយុទ្ធគ្នារវាងស្តេចត្រាញ់ជាប្រមុខភូមិភាគនានានៃប្រទេស ក៏បានចាប់ផ្តើមមានឡើង។ ការតស៊ូប្រយុទ្ធរវាងគ្នាឯងបែបនេះ បានបង្កើតបានជាបុព្វហេតុឱ្យប្រទេសចុះអន់ថយ ហើយធ្វើឱ្យដែនដីប្រទេសប្រេះឆា ជាដែនដីសាមន្តរាជពីរបី។ នៅពេលបន្តមក ដែនដីទាំងនេះ បានរួបរួមចូលគ្នានៅក្នុងសហព័ន្ធមួយបែប មានរដ្ឋពីរ ដែលគេឱ្យឈ្មោះថា ប្រទេសកម្ពុជា សម័យចេនឡាដីគោក និងប្រទេសកម្ពុជាសម័យចេនឡា

ដីទឹក។ នៅសម័យនោះ គឺនៅសម័យខាងដើមសតវត្សរ៍ទី៧ ដែនដីទាំងពីរនៃប្រទេសកម្ពុជា បានលាតសន្ធឹងលើតំបន់ពីរដ៏សំខាន់ គឺមានតំបន់ដីទីវាលទំនាបនៃទន្លេមូន និងដីទីវាលទំនាបនៅភាគមធ្យមនៃទន្លេមេកុង និងតំបន់ខាងទក្សិណចាប់តាំងពីតំបន់ទន្លេសាប ដល់ដែនដីទីវាលទំនាបនៃទន្លេមេកុង។ នៅសតវត្សរ៍ទី៨ គេបានត្រួសត្រាយដីតំបន់ខាងត្បូង ខាងលិច និងខាងជើងនៃបឹងទន្លេសាប។ គឺនៅតាមតំបន់ដីថ្មីទាំងនេះហើយ ដែលមានកម្មសិទ្ធិជាច្រើន របស់វណ្ណៈអភិជនដែលជាបព្វជិត និងជាគ្រហស្ថ។ បណ្ដាក្សត្រនានាជាអ្នកគ្រប់គ្រងរដ្ឋនៅតំបន់នេះ ដែលនៅសតវត្សរ៍ក្រោយមក បានទៅជាមូលដ្ឋាននៃរដ្ឋខ្មែរ នៅសម័យខាងដើមនៃសតវត្សរ៍ទី៨ អ្នកដឹកនាំទាំងនោះស្ថិតនៅក្នុងស្ថានភាពទន់ខ្សោយនៅឡើយ ហើយបានរួបរួមកម្លាំងជាមួយនឹងមហាក្សត្រទាំងឡាយជាអ្នកគ្រប់គ្រងរដ្ឋនៅភូមិភាគខាងត្បូង ដោយមានការបង្រួបបង្រួមគ្នាជាមួយដែនដីកម្ពុជា (សម័យចេនឡា)ដីទឹក។ ជាទូទៅ ការចុះអន់ថយបាក់បែកគ្នានៃប្រទេសនៅសតវត្សរ៍ទី៨ បានបង្ហាញឱ្យដឹងថា ដែនដីភាគខាងជើងគ្រប់គ្រងដោយរាជវង្សសុរិយវង្ស របស់តាបសឥសីកម្ពុ នៅសម័យនោះ មិនទាន់បានចូលរួមក្នុងដែនដីទូទៅរបស់ប្រទេស ដូចជានៅសម័យមួយសតវត្សរ៍ក្រោយមកនៃប្រទេសកម្ពុជា។

ការតស៊ូខាងនយោបាយនៅក្នុងសម័យកាលនៃការបែកបាក់គ្នា បានប្រព្រឹត្តទៅនៅលើការវិវត្តថ្មីៗខាងសង្គមកិច្ច និងសេដ្ឋកិច្ច ហើយទាក់ទង នឹងការលូតលាស់នៃសង្គមសក្តិភូមិ។ យើងសូមបញ្ជាក់ថា ការវិវត្តសង្គមនាសម័យនោះ មិនសូវ

សំខាន់ដូចជាការវិវត្តសង្គមនាសម័យសតវត្សរ៍ទី៧ ដោយហេតុថា គេពុំប្រទះឃើញធាតុអ្វីថ្មីៗនៅក្នុងការវិវត្តបែបនេះ។

ព្រឹត្តិការណ៍ដ៏សំខាន់បំផុតនាសម័យនោះ គឺការត្រួសត្រាយដែនដីដែលជា “ ជង្រុកស្រូវនៃភូមិភាគខាងលិច ” គឺមានដែនដីខាងលិច និងខាងពាយព្យនៃបឹងទន្លេសាប គឺជាតំបន់ដ៏សំខាន់នៃអនាគតរាជធានីរបស់ចក្រភពអង្គរ ដែលស្ថិតនៅតាមមាត់ទន្លេសៀមរាប ខេត្តសៀមរាប សព្វថ្ងៃ។ ដូចជារដ្ឋធានីដទៃខ្មែរ ដែលមានអាយុយឺនយូរ រដ្ឋធានីនេះស្ថិតនៅចំទីកណ្ដាលនៃតំបន់ស្រែចម្ការ ហើយការត្រួសត្រាយបានប្រព្រឹត្តទៅអស់រយៈពេលមួយសតវត្សរ៍ មុនពេលស្ថាបនារដ្ឋធានីអង្គរ នៅតំបន់នេះ។

ចំណែកឯមជ្ឈមណ្ឌលចាស់នៃចក្រភពបាភ្នំ វិញនោះនៅសតវត្សរ៍ទី៧ លែងមានការចែកចាយអំណោយដីនៅទីនោះទៀតហើយ ដោយហេតុថា ការដកយកដីពីពួកអ្នកស្រុក ហើយនិងការដាក់អ្នកស្រុកទាំងនេះ ឱ្យនៅក្នុងស្ថានភាពជាអ្នកងារ បានប្រព្រឹត្តទៅនៅពេលមួយសតវត្សរ៍ក្រោយមក ហើយដីសម្រាប់ដាំដំណាំបានទៅជាខ្សត់ខ្សោយ។ តំបន់នានាដែលមានអ្នកស្រុកស្រែចម្ការរស់នៅច្រើន បានក្លាយទៅជាប្រភពដ៏សំខាន់ខាងបណ្ដាជន និងខាងសេដ្ឋកិច្ច ព្រមទាំងសំខាន់ក្នុងកិច្ចការត្រួសត្រាយតំបន់ថ្មីនៃរដ្ឋធានី អនាគតឈ្មោះ យសោធរបុរៈអង្គរសព្វថ្ងៃ។ នៅទីនេះហើយ ដែលមានកម្មសិទ្ធិដីធំៗរបស់ពួកអភិជន និងរបស់វត្តអារាម ដែលបានមកពីការត្រួសត្រាយកាប់គាស់ដីព្រៃ និងការស្ថាបនាទំនប់ និងប្រឡាយទឹកធំៗ។ គួរកត់សម្គាល់ថា ការត្រួសត្រាយដីថ្មីៗ បានប្រព្រឹត្តទៅជាពិសេសនៅតំបន់ជាយៗនៃអនាគតរដ្ឋធានី ហើយបានចាប់ផ្ដើម

អនុវត្តឡើងជាពិសេសនៅដើមសតវត្សរ៍ទី៨ នៅពេលដែលប្រទេសកម្ពុជា សម័យចេនឡា បានរក្សានូវឯកភាពរបស់ខ្លួន។

ការដោះស្រាយនូវភារកិច្ចអនាគតជាប្រវត្តិសាស្ត្រ របស់ប្រទេស គឺជាកិច្ចការត្រួសត្រាយដែនដីស្រែចម្ការដែលមានទំហំធំធេង (ដែនដីតាមទន្លេសាប) បានប្រព្រឹត្តទៅនៅក្នុងស្ថានភាពនានា ដែលលទ្ធភាពខាងសេដ្ឋកិច្ចរបស់មជ្ឈមណ្ឌលចាស់ នៃចក្រភពបាភ្នំ ដែលជាមូលដ្ឋាននៃការលូតលាស់អនាគតរបស់កសិកម្មតាមបែបសក្តិភូមិ បានចុះទន់ខ្សោយ និងនៅក្នុងស្ថានភាពដែលមជ្ឈមណ្ឌលនយោបាយនានា ដែលមានវិបត្តិបែកបាក់គ្នា ពុំទាន់មានលទ្ធភាពបង្រួបបង្រួមប្រទេសទាំងមូលនៅឡើយ ហើយវិបត្តិបែកបាក់គ្នានេះក៏បានកើតមានឡើងរវាងដែនដីសាមន្តរាជ ចំនួនពីរបី។ ដែនដីនៃប្រទេសកម្ពុជា (សម័យចេនឡា)ជីគោក មានទំហំធំធេង ក៏ប៉ុន្តែជាតំបន់ដែលមានស្ថានភាពខាងសេដ្ឋកិច្ចទន់ខ្សោយជាងគេ ដោយហេតុថានៅទីនោះ ពុំមានលទ្ធភាពសម្រាប់ការកសាងប្រព័ន្ធបង្ហូរទឹកដ៏សំខាន់ៗសម្រាប់កសិកម្ម។ គោលបំណងខាងនយោបាយរបស់មហាក្សត្រជាអ្នកគ្រប់គ្រងរដ្ឋនេះ កម្ពុជាចេនឡាជីគោក គឺការបង្រួបបង្រួមគ្នា និងដែនដីខ្មែរនៅភាគខាងត្បូង។ ហើយប្រទេសកម្ពុជា ( ចេនឡា )ជីទឹក តាំងពីដើមទីមក ពុំមានឯកភាពជារដ្ឋមួយឱ្យបានពិតប្រាកដទេ។

# ចំពូកទី ២

## ចក្រភពកម្ពុជទេស (ចក្រភពអង្គរ)

ការវិវត្តផ្លាស់ប្តូរខាងសង្គម និងខាងសេដ្ឋកិច្ចរបស់ប្រទេសនៅសតវត្សរ៍ទី៧ - ៨ បានរៀបចំដំណើរទៅកាន់ដំណាក់កាលថ្មីនៃការប្រមូលផ្តុំរដ្ឋអំណាច។ ការពង្រឹងកម្មសិទ្ធិដែនដីខ្មែរបានសម្រេចសព្វគ្រប់នៅសតវត្សរ៍ទី៩ ហើយបានកំណត់នូវការផ្លាស់ប្តូរទម្រង់នៃរដ្ឋខ្មែរ ឱ្យទៅជាចក្រភពកម្ពុជទេសពហុជាតិ គឺជាចក្រភពមួយក្នុងបណ្តារដ្ឋសក្តិភូមិដ៏ធំជាងគេនៅទ្វីបអាស៊ី។

ការតស៊ូដើម្បីរៀបចំឯកភាពប្រទេស បានចាប់ផ្តើមឡើងដោយរាជវង្សានុវង្សបុស្ការក្ស ដែលបានគ្រប់គ្រងប្រទេសកម្ពុជា (ចេនឡា)ដីទឹក ដោយមានការបញ្ចូលនូវភូមិភាគប្រកបដោយដីស្រែចម្ការដ៏ល្អៗ មកក្នុងសមាសភាពនៃប្រទេសខ្មែរ។ តាំងពីសម័យកាលខាងចុងសតវត្សរ៍ទី៨ ព្រះបាទជ័យវរ្ម័ន ជាចៅ - ក្មួយរបស់ព្រះបាទបុស្ការក្ស បានដឹកនាំយុទ្ធនាការ បានបង្រួបបង្រួមនិងបញ្ចូលនូវដីសម្ពន្ធរាជ្យនានា ដែលបានបែកបាក់មកក្នុងមាតុភូមិកម្ពុជា ដោយការប្រើយុទ្ធវិធី និងនយោបាយតាមផ្លូវទូតផ្សេងៗ។

ការសិក្សាទម្រង់សង្គម-សេដ្ឋកិច្ច របស់ចក្រភពកម្ពុជទេសអាចឱ្យយើងចែកការវិវត្ត នៃចក្រភពជាបីដំណាក់កាលសំខាន់ៗ៖ ដំណាក់កាលខាងដើម ចាប់ពីចុងសតវត្សរ៍ទី៨ - ដល់សតវត្សរ៍ទី១០, ដំណាក់កាលដ៏រុងរឿង ចាប់ពីពេលខាងដើមសតវត្សរ៍

ទី១១- ដល់ដើមសតវត្សរ៍ទី១៣, ដំណាក់កាលខាងចុង ចាប់ពីសតវត្សរ៍ទី១៣ ដល់ភាគពាក់កណ្តាលនៃសតវត្សរ៍ទី១៤។

សម័យខាងចុងនៃសតវត្សរ៍ទី៨ និងសម័យខាងដើមនៃសតវត្សរ៍ទី៩ បានកន្លងទៅដោយមានការបង្រួបបង្រួមជាបន្តបន្ទាប់នូវដែនដីសាមន្តរាជ ដែលបាក់បែកគ្នាមកក្នុងសមាសភាពប្រទេសកម្ពុជា ( ចេនឡា ) ដីទឹក។ ដោយមូលហេតុនេះហើយបានជាព្រះបាទជ័យវរ្ម័នទី២ បានផ្លាស់ប្តូររដ្ឋធានី ពីតំបន់បង្រួបបង្រួមមួយទៅកាន់តំបន់បង្រួបបង្រួមមួយទៀត។

បន្ទាប់ពីបានពង្រឹងស្ថានភាពនៅតំបន់ទាំងមូល នៃខេត្តកំពង់ចាម សព្វថ្ងៃនេះ ព្រះអង្គបានបង្រួបបង្រួមខេត្តសៀមរាប ហើយនៅទីនេះ ព្រះអង្គបានកសាងទីក្រុងមួយ ដែលស្ថិតនៅជិតអនាគតរដ្ឋធានីយសោធរបុរៈ (អង្គរធំ)។ តមកទៀត ព្រះអង្គបានកសាងរាជវាំងនៅហរិហរល័យ (ហៅថាទីក្រុងរលួស សព្វថ្ងៃ)។ គឺនៅទីនេះ ដែលព្រះអង្គត្រូវបានប្រកាសជាព្រះមហារាជ-ចក្រវាទិន នៅ គ.ស. ៨០២។ ព្រះបាទជ័យវរ្ម័នទី២ បានគ្រប់គ្រងប្រទេសរហូតដល់ គ.ស.៨៥៤។ បន្ទាប់ពីត្រូវបានប្រកាសជាព្រះមហារាជ-ចក្រវាទិន ព្រះអង្គបានយាងមកតាំងនៅទីក្រុងអមរេន្ទ្របូរៈ ហើយនៅពេលក្រោយមកទៀត ព្រះអង្គបានយាងមកគង់នៅតំបន់យសោធរបូរៈ។ នៅក្នុងរជ្ជកាលខាងចុង ព្រះអង្គបានយាងទៅតាំងរដ្ឋធានី ឈ្មោះ មហិន្ទ្របព៌តដែលស្ថិតនៅលើភ្នំគូលែន។ គួរកត់សម្គាល់ថា ការត្រួសត្រាយដីថ្មីៗ បានចាប់ផ្តើមឡើងនៅតំបន់នានានៅភាគខាងជើងបឹងទន្លេសាប ដែលនៅទីនេះ នៅពេលមុន ក្រៅពីតំបន់អនិន្ទិតបូរៈ ពុំទាន់មានមជ្ឈមណ្ឌលធំៗរបស់រដ្ឋនៅឡើយ។

សកម្មភាពខាងយោធា និងនយោបាយនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី២ និងរបស់ព្រះមហារាជនានា ដែលបានគ្រប់គ្រងរដ្ឋជាបន្តមកនៅសតវត្សរ៍ទី៩ បានអភិវឌ្ឍទៅនៅក្នុងស្ថានភាពសង្គម-សេដ្ឋកិច្ចថ្មី។ ព្រឹត្តិការណ៍នៅសតវត្សរ៍ទី៨ បានបង្កបង្កើតជាមូលដ្ឋាននៃការផ្លាស់ប្តូរដ៏ជ្រាលជ្រៅនៅក្នុងសង្គម ហើយព្រឹត្តិការណ៍ទាំងនេះ ត្រូវបានចារឹកជាភស្តុតាងនៅតាមសិលាចារឹកនាសតវត្សរ៍ទី៩ និងនាសតវត្សរ៍ក្រោយៗមកទៀត។ ស្រទាប់វណ្ណៈនានា នៃប្រជាជនបានផ្លាស់ប្តូររូបរាង ដោយសារការកកើតនូវស្រទាប់នៃវណ្ណៈថ្មីៗ។ នៅស្រុកស្រែទាំងឡាយ ជំនួសវណ្ណៈនៃបុគ្គលដែលមានឋានន្តរនាមជា “ តាង ” មានកើតឡើងវណ្ណៈនៃបុគ្គលដែលមានឋានន្តរនាមជា “ វាប ”។

បុគ្គលប្រកបដោយឋានន្តរនាមជា “ វាប ” ច្រើនធ្វើជានាម៉ឺន ឬភ្នាក់ងារថ្នាក់មធ្យមនៅក្នុងរាជការនៅទូទាំងប្រទេស ឬធ្វើជាអ្នកមុខអ្នកការនៅតាមស្រុកស្រែនានា។ គឺអ្នកទាំងនេះហើយ ដែលបានទៅជាម្ចាស់ដីតូចៗ ហើយដែលតែងតែមានការទាក់ទងនឹងការលក់ទិញ ឬការក្តីក្តាំអំពីរឿងដីធ្លី។ ខ្ពស់ជាងនេះបន្តិច មានស្រទាប់បុគ្គល ឬភ្នាក់ងាររាជការថ្មី ដែលមានឋានន្តរនាមជា “ លោញ ” ជំនួសស្រទាប់បុគ្គលដែលមានឋានន្តរនាមជា “ ប៉ោញ ”។ ស្រទាប់វណ្ណៈបែបនេះ ច្រើនជានាម៉ឺន ឬភ្នាក់ងារបម្រើរាជការនៅក្នុងកងទ័ព នៅក្នុងស្ថាបនកម្ម ឬជាអ្នកមុខអ្នកការនៅតាមជនបទនានា។ ស្រទាប់ម្ចាស់ដីថ្មី គឺម្ចាស់ដីមធ្យម ព្រមទាំងម្ចាស់ដីតូចតាច ដែលមានឋានន្តរនាមជា “ តេង ” ក៏បានកើតមានឡើង។

ចំណែកម្ចាស់ដីធំៗដែលគេហៅថា ក្ពុំ្ម គឺបុគ្គលដែលមានឋានន្តរនាម " ម្រតាង " ដែលបានបំពេញមុខងារជាមន្ត្រីធំៗ។ ស្រទាប់នៃវណ្ណៈសក្តិភូមិជាន់ខ្ពស់នេះ កាន់តែលូតលាស់ឡើង ដោយហេតុថា វណ្ណៈនេះមានការទាក់ទងនឹងការកាន់តំណែងក្នុងអង្គការរាជការផង ក្នុងកិច្ចការគណៈព្រាហ្មាចារ្យដែលបម្រើព្រះមហារាជ និងទេវស្ថានផ្សេងៗ។ ស្រទាប់នៃមន្ត្រីប្រកបដោយឋានន្តរសក្តិជា " ភ្លោញ " មេក្លោង, នាយក ក៏កាន់តែមានចំនួនច្រើនឡើង ស្ថានភាពរបស់ទាសាទាសីក្ញុំ ក៏បានផ្លាស់ប្តូរ។ បណ្តាក្ញុំ សម្គាល់ដោយពាក្យថា " វា " (សម្រាប់ក្ញុំប្រុស) និង " កូ " (សម្រាប់ក្ញុំស្រី) ដែលមាននៅក្នុងសង្គមរហូតដល់សតវត្សរ៍ទី៨ ក៏ត្រូវបានផ្លាស់ប្តូរដោយស្រទាប់ទាសាទាសីថ្មីៗ សម្គាល់ដោយពាក្យ " ស៊ី " (ក្ញុំប្រុស) និង " តៃ " (ក្ញុំស្រី)។

នៅក្នុងដំណាក់កាលទីមួយ ជាមួយនឹងការរក្សាទុកនូវប្រពៃណីជាច្រើននៃសតវត្សរ៍ទី៧ - ទី៨ ដូចជាការធ្វើអំណោយពួកក្ញុំ ដាច់ដោយពីការធ្វើអំណោយដី មានកើតសភាពការណ៍ដែលមានលក្ខណៈពិសេស សម្រាប់សម័យកាលនៃចក្រភពកម្ពុជទេស ដែលរីកសាយជាខ្លាំងនៅសម័យចុងសតវត្សរ៍ទី៨ - ដល់សម័យដើមសតវត្សរ៍ទី១០ ហើយមានលក្ខណៈពិសេសនៅសម័យចុងសតវត្សរ៍ទី៨ ពី គ.ស. ៨៧៧។ គឺជាសភាពការណ៍ដែលទាក់ទងនឹងវិធានការកាប់ឆ្ការដីព្រៃ ព្រមទាំងការធ្វើអំណោយរបស់ព្រះមហារាជនូវដីស្រែ និងដីភូមិស្រុកទាំងមូលៗដល់បណ្តាវណ្ណៈអភិជនសក្តិភូមិ ដែលជាគ្រហស្ថ ឬជាបព្វជិតក្តី។ តាមធម្មតា សហគមន៍ស្រុកមានភូមិចាប់ពីចំនួនពីរបី ដល់ចំនួនច្រើន។ នៅពេលនោះ សភាពការណ៍ពិសេសសម្រាប់សតវត្សរ៍ទី៩ - ទី១១

គឺការធ្វើអំណោយដីនានា បូករួមទាំងដីស្រែចម្ការរបស់ម្ចាស់ដីមួយទៅនឹងដីទទេនៅក្នុងស្រុក ដល់បណ្ដាចៅអធិការវត្ត ឬអាស្រម ដោយមានការចាប់ផ្ដើមការកាប់គាស់ដីថ្មីៗតាមការផ្ដើមគំនិតរបស់ពួកអភិជនសក្ដិភូមិ។ ហេតុនេះហើយ បានជាកម្មសិទ្ធិលើដីភូមិធំៗ របស់ពួកអភិជនសក្ដិភូមិជាបុព្វជិត និងគ្រហស្ថកាន់តែរីកចម្រើនខ្លាំងឡើង។ព្រះបាទជ័យវរ្ម័នទី៣ ដែលគេបានស្គាល់ថាជា " មហាក្សត្រប្រមាញ់សត្វដំរី " ក៏បានជួយជ្រោមជ្រែងនិន្នាការបែបនេះដែរ។ ការនេះ មានន័យទាក់ទងនឹងការស្វែងរកទឹកដីថ្មីៗ សម្រាប់ធ្វើស្រែចម្ការជាមួយនឹងការស្វះស្វែងដេញតាមដំរីព្រៃ ហើយកាលណាដំរីឈប់នៅទីណា នៅទីនោះរមែងមានការតាំងមជ្ឈមណ្ឌលថ្មី និងការកំណត់កម្មសិទ្ធិលើដីនោះ។

នៅសម័យនោះ ការលូតលាស់នៃកម្មសិទ្ធិលើដីធំៗ ពុំទាន់មានការទាក់ទងនឹងស្ថានភាពចុះអន់ថយ របស់ពួកម្ចាស់ដីមធ្យម និងតូចតាចធម្មតានៅឡើយ។ បណ្ដាបុគ្គលប្រកបដោយឋានន្តរនាម " វាប ", " លោញ " និង " តេង " ព្រមទាំងបណ្ដាអ្នកមុខអ្នកការភូមិសហគមន៍ ត្រូវបានរំលឹកជានិច្ចកាលតាមសិលាចារឹក ក៏ប៉ុន្តែ អ្នកទាំងនេះ ពុំទាន់មានលទ្ធភាពចាប់ផ្ដើមធ្វើអំណោយដល់វត្តអារាម ឬលក់ដូរជាទូទៅនូវដីស្រែចម្ការ ភូមិឋានទេ។ នៅសម័យនោះ ដែលជាសម័យកាលដូចគ្នានឹងចក្រភពប៉ាហ្គ័ន ប្រទេសភូមា គឺអស់រយៈពេលចំនួនពីរសតវត្សរ៍ គឺច្រើនមានតែព្រះមហារាជ ដែលបានធ្វើអំណោយដី។ ចាប់ពីសតវត្សរ៍ទី៩ ដល់ទី១១ បណ្ដាអ្នកមុខអ្នកការស្រុកស្រែតែងបានចូលរួមជាចាំបាច់ក្នុងការចែករំលែកដី គឺដូចគ្នានឹងប្រទេសជ្វា។ នៅពេល

នោះ សិលាចារឹកពុំទាន់បានរំលឹកអំពីការបែករំលែកដីជាទូទៅ ហើយនៅសតវត្សរ៍ទី៩ ការរំលឹកអំពីការប្ដូរផ្ដោះ លក់-ទិញដី មានតិចបំផុត។ បើប្រៀបធៀបទៅនឹងសម័យកាលមុន និង សម័យកាលក្រោយមកទៀត សិលាចារឹកពុំសូវបានរំលឹកអំពី ការបែករំលែកដីតូចតាចដូចជាដីស្រែចម្ការ ហើយច្រើនតែ រំលឹកអំពីដីស្រុក និងដីភូមិ។

មធ្យោបាយនានា ក្នុងការកាន់កាប់សិទ្ធិលើដីនៅសម័យ កាលនៃការដណ្ដើមបានដែនដីថ្មីៗ ដែលជាលទ្ធភាពផ្ដល់ដល់ អ្នកទទួលជ័យជម្នះ ក្នុងចម្បាំងនូវមូលនិធិដីថ្មីៗ ច្បាស់លាស់ ព្រមទាំងកិច្ចការត្រួសត្រាយដីព្រៃ នៅតំបន់ភាគខាងជើងបឹង ទន្លេសាប សភាពការណ៍ទាំងអស់នេះមានលក្ខណៈខុសៗគ្នា។

យើងសូមបញ្ជាក់ថា មានការស្វែងរកដីទំនេរថ្មីៗដោយវិធី ដេញតាមដំរីព្រៃ និងការធ្វើអំណោយដីទាំងនេះជាសម្បត្តិទ្រព្យ របស់វត្ត និងអាស្រមទាំងឡាយ។ ការត្រួសត្រាយដីស្រែថ្មីៗ ការកសាងព្រែកជីក ប្រឡាយបង្ហូរទឹក និងត្រពាំង បានប្រព្រឹត្ត ទៅក្រោមការទទួលខុសត្រូវរបស់រាជការមហារាជ ហើយត្រូវ បានប្រគល់ទៅដល់ពួកអភិជនសក្ដិភូមិបម្រើរាជការ ដើម្បីជា សម្បត្តិទ្រព្យរបស់ស្រុក។ ការប្រគល់អំណោយបែបនេះ ទាក់ទង នឹងកាតព្វកិច្ចកសាងវត្តអារាមនៅលើដីនោះ ព្រមទាំងទទួលបន្ទុក ទ្រទ្រង់ជីវភាពនៅវត្តនោះ ដោយសារភោគផលបានមកពីរបរ លើដីទាំងនោះ។ ការធ្វើអំណោយដីភូមិបែបនេះ មានឈ្មោះនៅ សម័យនោះថា ការធ្វើអំណោយ “ បុណ្យ ”។ នៅក្នុងរឿងកែឆ្នៃ ដីទាំងនេះ ឃើញថា គេបានប្រើប្រាស់ពលកម្មបណ្ដាអ្នកស្រែ ដើម្បីត្រួសត្រាយកាប់គាស់ដីព្រៃ ហើយគេបានប្រើប្រាស់ពល

កម្មពួកក្ញុំ ដើម្បីប្រកបរបរអាជីវកម្មលើដីទាំងនោះ។ ពួកក្ញុំ គឺជាពួកផលិតករដ៏សំខាន់នៅលើដីស្រែចម្ការ។ ហេតុនេះហើយ បានជាតាមរយៈសិលាចារឹក គេតែងប្រទះឃើញមានទំនាស់ក្ដីក្ដាំអំពីកម្មសិទ្ធិលើការងាររបស់ពួកក្ញុំទាំងនេះមិនចេះចប់ នៅក្នុងសម័យកាលនៃចក្រភព គឺជាទំនាស់រវាងវត្តអារាម និងពួកនាម៉ឺននៅតាមស្រុកអាយ។ ក៏ប៉ុន្តែ រឿងក្ដីក្ដាំអំពីដីទាំងនេះ តែងកើតមានឡើងក្រោមសេចក្ដីសម្រេចជាចុងក្រោយរបស់ព្រះមហារាជ។

របបគ្រប់គ្រងរបស់ព្រះបាទជ័យវរ្ម័នទី២ មិនគ្រាន់តែបានផ្ដល់លទ្ធភាពដល់ការបង្រួបបង្រួមទឹកដីរដ្ឋ និងបានសម្រេចនូវនិន្នាការចម្រើននិយមនៅក្នុងការពង្រីកវិស័យសេដ្ឋកិច្ច មិនគ្រាន់តែបានបង្កើតនូវមជ្ឈដ្ឋានថ្មីៗនៃប្រទេស មិនមែនទីក្រុងទេ តែជាមូលដ្ឋានរដ្ឋ ក៏ប៉ុន្តែ ថែមទាំងមានការកំណត់នូវគុណ្យការនៃការរីកចម្រើនរបស់ប្រទេសខ្មែរ ដោយមានការពង្រឹង និងប្រមូលផ្ដុំនូវអំណាចរបស់វណ្ណៈអភិជន បព្វជិត និងគ្រហស្ថ។ នៅសម័យនោះ មានពិធីប្រារព្ធការគោរពសក្ការៈបូជា “ ទេវ-រាជា ” ឬការគោរពព្រះមហារាជ ដូចជាអាទិទេព ដោយបានបង្កើតនូវមនោគមន៍នៃរដ្ឋអំណាចមួយបែប ដែលឃោងទៅលើរាជអំណាចដ៏មហិមា ឥតព្រំដែនរបស់ព្រះមហារាជ។ ព្រះមហារាជដ៏មានឫទ្ធានុភាពមិនមែនជាតំណាងរបស់អាទិទេពទេ ក៏ប៉ុន្តែ ជាទេវតាមួយរូបនៅលើផែនដីនៃនគរ។

មានការសម្រេច នូវការបង្រួបបង្រួមរវាងវណ្ណៈអភិជនសក្តិភូមិដែលជាមន្ត្រីរាជការ និងជាត្រកូលខ្ពង់ខ្ពស់ទៅនឹងវណ្ណៈអភិជនជាបព្វជិតឱ្យទៅជាវណ្ណៈអភិជនសក្តិភូមិជាបព្វជិត និងគ្រហស្ថតែមួយរបស់រដ្ឋ ដោយការអនុវត្តការបង្រួបបង្រួមកម្ម

សិទ្ធិដីរបស់អ្នកស្រុកស្រែ ទៅនឹងកម្មសិទ្ធដីរបស់ពួកសក្តិភូមិជាមួយនឹងវត្តអារាម ដែលមានកម្មសិទ្ធលើដី។ បាតុភូតជាប្រវត្តិសាស្ត្រដែលកើតមានឡើងក្នុងមនោគមន៍ នៃការគោរព " ទេវ-រាជា " ដែលបានបង្រួបបង្រួមគណៈសង្ឃ និងបណ្តាមន្ត្រីនាម៉ឺន ហើយដែលបានបង្កលក្ខណៈល្អ ឱ្យបង្កើតបាននូវរដ្ឋសក្តិភូមិមួយ គឺជាកម្លាំងដ៏រឹងមាំមួយដ៏កម្រ។ រដ្ឋអំណាចបែបនេះបានបង្កលក្ខណៈឱ្យបង្កើតបានជាចក្រភព ដែលមានទំហំធំ និងមានអាយុយឺនយូរ ស្មើនឹងបណ្តាប្រទេសជាចក្រភពដ៏ធំៗជាងគេនៅទ្វីបអាស៊ី នាមជ្ឈមសម័យ។

នៅក្នុងមនោគមន៍នៃសក្ការៈបូជា " ទេវ - រាជា " មានវិធីផ្សំបញ្ចូលជំនឿអូស្ត្រូអាស៊ីយ៉ាទិក មន - ខ្មែរ ក្នុងជំនឿនៃការគោរពមេបា មានជាពិសេស បុព្វបុរសជាព្រះរាជា ទៅនឹងជំនឿលើអ្នកតារក្សាទឹកដី ជាមួយនឹងជំនឿមិនសូវផ្សព្វផ្សាយនៅប្រទេសឥណ្ឌា គឺលទ្ធិតង់ទ្រិក ដែលជាសំយោគរវាងកម្លាំងអាទិទេព និងមហិទ្ធិឫទ្ធិរបស់ព្រះរាជា ភ្ជាប់នឹងលក្ខណៈពិសេសនៃជំនឿលើសាសនាព្រះឥសូរ ព្រះសីវៈ។ ពិធីដ៏ឱឡារិកនៃការគោរពបូជា "ទេវ-រាជា" ត្រូវបានធ្វើឡើងដោយព្រាហ្មណ៍បរោហិតពិសេសដែលបំពេញពិធីនេះជាតំណ តវង្សត្រកូលក្នុងបរមោរាជវាំង ហើយបានប្រកាសនូវអំណាចរួមរបស់អាទិទេព នៅលើក្រឡាផ្ទៃក្រោមផែនដី ឧទ្ទិសដល់ព្រះមហារាជណាមួយដែលគ្រងរាជសម្បត្តិ។ អាទិទេពសំខាន់ គឺព្រះឥសូរ ហើយនិមិត្តរូបនៃមហិទ្ធិឫទ្ធិរបស់ព្រះឥសូរ គឺរូបរាជលិង្គ។ រាជលិង្គនេះ បានទៅជានិមិត្តរូបនៃរាជអំណាចរបស់ព្រះមហារាជ ដែលគ្រប់គ្រងរៀបចំសង្គមខាងសតិអារម្មណ៍ ស្មារតី និងខាងសម្ភារៈ។ ជំនឿបែបនេះ

មានលក្ខណៈជាមនោគមវិជ្ជា ដែលមនុស្សភាគតិចអាចយល់បាន ក៏ប៉ុន្តែ តាមសភាពច្បាស់លាស់ខាងក្រៅ របស់ពិធីធ្វើសក្ការៈបូជាបែបនេះ អាចមានការទាក់ទាញអារម្មណ៍ដល់អ្នកស្រុកទូទៅនៅក្នុងប្រទេស។ មិនមែនការឃោសនា អំពីមនោគមន៍បែបនេះទេ ដែលបានផ្តល់ប្រសិទ្ធភាព ប៉ុន្តែប្រសិទ្ធភាពនៃការសំដែងកម្លាំងនៃអច្ឆិរយភាពនេះបានស្ថិតនៅលើមូលដ្ឋាន នៃមុខងារខាងសង្គមរបស់ការគោរពបូជាមនោគមន៍បែបនេះ។ ការគោរពបូជាមនោគមន៍ " ទេវ - រាជា " មិនបានរំខាន ហើយគ្មានបំណងនឹងរំខានដល់ការគោរពសាសនាដទៃទៀតឡើយ ហើយបានប្រព្រឹត្តទៅជាពិសេសលើគោលការណ៍នៃទំនាក់ទំនង " បុគ្គល - សង្គមមនុស្ស - អាទិទេព " ដោយយោងទៅតាមសច្ចភាពនៅក្នុងវិស័យនៃទំនាក់ទំនងខាងសង្គមកិច្ច។ វិស័យទំនាក់ទំនងរវាង " បុគ្គល និងអាទិទេព " បានស្ថិតនៅលើជំនឿដទៃនៅក្នុងស្រុក ដូចជាព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនា។ ព្រាហ្មាចារ្យ ដែលធ្វើពិធីបូជាទេវ - រាជា គឺជាព្រាហ្មណ៍បរោហិតផង (ដែលមិនមែនស្ថិតនៅក្នុងវណ្ណៈដាច់ដោយឡែកដូចក្នុងសង្គមឥណ្ឌា ទេ ក៏ប៉ុន្តែជាព្រាហ្មាចារ្យ ដែលបម្រើកិច្ចការរាជការ) ជាអ្នកបម្រើរដ្ឋការផង ឬជាសមាជិករបស់ស្ថាប័នរដ្ឋខាងក្រសួងធម្មការ។

រជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៣ (គ.ស.៨៥៤ - គ.ស. ៨៧៧) បានទាក់ទងនឹងការពង្រីកមជ្ឈមណ្ឌលខាងសង្គម-សេដ្ឋកិច្ចនៃចក្រភពកម្ពុជទេស (ដោយមានស្ថាបនកម្មដ៏សកម្មនូវវត្តអារាមនៅតាមភូមិភាគកណ្តាលនៃប្រទេស និងនៅទីដទៃទៀត)។ រជ្ជកាលនេះ បានរៀបចំជាជំហានថ្មីនៃការបង្រួបបង្រួមដែនដី បានមកដោយជោគជ័យក្នុងចម្បាំង ដើម្បីឆ្លងទៅកាន់

ដំណាក់កាលតទៅមុខទៀត នៃសម័យកាលខាងដើមរបស់ចក្រភពកម្ពុជទេស។ រដ្ឋធានីកម្ពុជា នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៣ គឺហរិហរាល័យ ទីក្រុងរលួស សព្វថ្ងៃ។ក៏ប៉ុន្តែ នៅពេលជាមួយគ្នា ព្រះអង្គបានកសាងទីក្រុងនៅដែនដីអមរេន្ទ្របូរៈ។

ដំណាក់កាលតមកទៀត នៃការពង្រឹងចក្រភពកម្ពុជទេស បានប្រព្រឹត្តទៅនៅក្នុងរជ្ជកាលរបស់ព្រះបាទឥន្ទ្រវរ្ម័នទី១ (គ.ស. ៨៧៧-៨៨៩) របស់ព្រះបាទយសោវរ្ម័នទី១ (ពីគ.ស.៨៨៩ រហូតដល់ គ.ស.៩០០ និង គ.ស.៩១២) របស់ព្រះបាទហស៌វរ្ម័នទី១ (គ.ស. ៩១២ - ៩២២) និងរបស់ព្រះបាទឦសានវរ្ម័នទី២ (គ.ស.៩២២ - ៩២៥)។ នៅសម័យកាលទាំងនេះ មានការផ្លាស់ប្តូរដ៏សំខាន់ដ៏ចម្លែកៗ នៅក្នុងជីវភាពខាងសង្គម - សេដ្ឋកិច្ចរបស់ប្រទេស ដោយមានការចាប់ផ្តើមអនុវត្តការបែកវំលែកដីដល់ដល់ពួកក្ញុំ និងមានការវិវត្តរបស់ពួកក្ញុំ ទៅជាស្រទាប់នៃវណ្ណៈអ្នកងារ ដែលជាកសិករ ព្រមទាំងមានការផ្តល់ដីមួយចំនួនរបស់អ្នកស្រុកស្រែដល់វត្តអារាមនានា។ ក៏ប៉ុន្តែ ស្ថានភាពបែបនេះពុំទាន់បណ្តាលឱ្យមានភាពអន់ថយទូទៅ ដល់ស្រទាប់នៃវណ្ណៈនេះទេ ហើយរៀបចំការត្រៀមលក្ខណៈបែបនេះសម្រាប់ចម្លងទៅកាន់ស្ថានភាពអនិស្សរភាពរបស់វណ្ណៈកសិករ។ ជាពិសេសនៅសតវត្សរ៍ទី១០ ការធ្វើអំណោយបណ្តាពួកក្ញុំ និងដីបានរីកសាយទូទៅកាន់តែខ្លាំង បើប្រៀបធៀបទៅនឹងសតវត្សរ៍មុនៗ។ នៅក្នុងសតវត្សរ៍នេះ អ្នកធ្វើអំណោយដី ជាពិសេសដីស្រែចម្ការច្រើនតែបុគ្គលដែលមានឋានន្តរនាម “វាប”, “លោញ”, “តាង” និង “តេង” ហើយដែលច្រើនជាអ្នកម្ចាស់ដីមធ្យម និងតូចតាច។ នៅពេលជាមួយគ្នា មានការចុះអន់ថយនូវអំណោយពួកក្ញុំ ដោយ

គ្មានការធ្វើអំណោយទាំងដី។ ការលក់ទិញដីក៏បានកើតមានឡើងយ៉ាងឆាប់រហ័ស ហើយសភាពការណ៍នេះជាមធ្យោបាយមួយដើម្បីប្រមែប្រមូលដីមកក្នុងកណ្ដាប់ដៃរបស់ពួកសក្ដិភូមិ។ ច្បាប់ទម្លាប់ទាក់ទងនឹងកម្មសិទ្ធិដី ក៏ត្រូវបានបញ្ជាក់ច្បាស់លាស់ដោយមានទាំងការកំណត់អំពីព្រំប្រទល់ដី អំពីទំហំដី អំពីទំហំនៃផលដី។ ទាំងអស់នេះបានបញ្ជាក់ឱ្យដឹងនូវអំពីទំនាក់ទំនងខាងប្រព័ន្ធពន្ធដារ។ របៀបទារពន្ធដារលើដី ការទិញដូរដី និងផលចំណូលបានមកពីដី បានទៅជាកិច្ចការដ៏ស្មុគស្មាញ។

នៅក្នុងប្រវត្តិសាស្ត្រនយោបាយ នាសម័យកាលនោះ មានការអនុវត្តតទៅទៀតនូវការបង្រួបបង្រួមទឹកដីខ្មែរ ព្រមទាំងមានការបង្កើត និងពង្រឹងចក្រភពកម្ពុជទេស។ នៅក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី១ របៀបរៀបអាពាហ៍ពិពាហ៍រវាងរាជវង្សានុវង្សនានាបានពង្រឹងការបង្រួបបង្រួមជាកម្មសិទ្ធិដោយកេរមរតកនូវទឹកដីបូរាណទាំងឡាយនៃចក្រភពបាភ្នំ នូវដែនដីតាមទន្លេមេកុង (ដែលលាតសន្ធឹងយ៉ាងមធ្យមរហូតដល់តំបន់នានា នៅប្រទេសឡាវប៉ែកខាងត្បូង) និងដែនដីទីវាលទំនាបនៃទន្លេមូន ដែលលាតសន្ធឹងរហូតដល់ទីក្រុងអ៊ូប៊ុន (សព្វថ្ងៃ ប្រទេសសៀម)។ ការបង្រួបបង្រួមទឹកដីនៃអតីតប្រទេសចេនឡា ត្រូវបានសម្រេចពេញលេញ។ ក៏ប៉ុន្តែ ការនេះបានប្រព្រឹត្តទៅនៅលើមូលដ្ឋាននៃការពង្រឹងកាន់តែខ្លាំងនូវប្រព័ន្ធកៀបសង្កត់សក្តិភូមិ ដែលបានកកើតឡើងក្នុងក្របខ័ណ្ឌនៃរដ្ឋអំណាចមជ្ឈិមដ៏រឹងមាំ។ រដ្ឋអំណាចមជ្ឈិមដ៏រឹងមាំ វត្តមាននៃវណ្ណៈដ៏សំខាន់នៃបណ្ដាអ្នកម្ចាស់ដីធំ និងម្ចាស់ដីឯកជន ឯកភាពខាងនយោបាយ និងសាសនាទាំងអស់ គឺជាមូលដ្ឋាននៃការពង្រឹងរដ្ឋអំណាចនា

សម័យនោះ ដែលមិនទាន់បានចូលដល់ដំណាក់កាលនៃចក្រភពកម្ពុជទេស ផង។ ហើយគោលបំណងឆ្ពោះទៅកាន់ការស្ថាបនាចក្រភពបែបនេះ បានលេចជារូបរាងច្បាស់លាស់រួចមកហើយ។ ប្រសិនបើព្រះបាទជ័យវរ្ម័នទី២ បានប្រកាសនូវឯករាជ្យពេញទីនៃប្រទេសកម្ពុជា នោះ ព្រះបាទឥន្ទ្រវរ្ម័នទី១ បានប្រកាសថា ព្រះអង្គមិនគ្រាន់តែជាមហារាជ ដែលត្រួតត្រាប្រទេសជ្វា*ប៉ុណ្ណោះទេ ក៏ប៉ុន្តែជាមហារាជដែលត្រួតប្រទេសចម្ប៉ា និងប្រទេសចិន សម័យអធិរាជតាន់ ទៀតផង។

គោលបំណងខាងនយោបាយក្រៅប្រទេស របស់ព្រះបាទឥន្ទ្រវរ្ម័នទី១ បានពឹងផ្អែកទៅលើស្ថានភាពដ៏រឹងមាំនៃរាជអំណាចរបស់ព្រះអង្គនៅក្នុងប្រទេស។ ដោយពឹងផ្អែកទៅលើមូលនិធិនៃដែនដីនៅទំនេរ ដែលស្ថិតនៅពីទិសខាងជើងបឹងទន្លេសាបរហូតដល់ជើងភ្នំដងរែក ហើយដែលនៅទីនោះ មានការអនុវត្តស្ថាបនកម្មធំៗនៃប្រព័ន្ធបង្ហូរទឹកដោយសារពលកម្មកសិករ និងដោយសារមានការអនុវត្តនយោបាយចែកចាយ ដីត្រួសត្រាយព្រះអង្គបានកសាងមូលដ្ឋាន ខាងសេដ្ឋកិច្ចដ៏រឹងមាំសម្រាប់វណ្ណៈអភិជនសក្តិភូមិ និងមន្ត្រីរាជការ ដោយនៅពេលនោះពុំមានធ្វើឱ្យខូចប្រយោជន៍ដល់កម្មសិទ្ធិ របស់បណ្តាកសិករលើដីស្រែចម្ការនៅលើទឹកដីចាស់តាមមាត់ទន្លេមេកុង។

គឺនៅសម័យនោះហើយ ដែលមានការលើកតម្កើងនូវពិធីសក្ការៈបូជាព្រះអាទិទេព និងព្រះមហារាជ តាមមធ្យោបាយនៃសិល្បៈស្ថាបត្យកម្ម និងសិល្បៈចម្លាក់ (ប្រាសាទព្រះគោ)។

---

* រាជាណាចក្រម៉ាឡាយូឈ្មោះ ស្រីវិជ័យ

នៅពេលនោះ ជាលើកទីមួយ គេបានស្ថាបនាប្រាសាទទី១ ដែលមានតម្កល់រូបរាជលិង្គតំណាងទេវ - រាជា នៅលើកំពូលប្រាសាទបាគង។ នៅក្នុងវិស័យវប្បធម៌នៅពេលនោះ រចនាបទនៃក្បាច់រចនាខ្មែរបាននិម្មាន និងវិវត្តឡើងដ៏ខ្ពង់ខ្ពស់បំផុត ហើយដែលបានទុកជាគំរូដល់ព្រៃពៃណើសិល្បៈក្នុងវិស័យនិម្មាបនកម្ម និងក្បាច់ចម្លាក់ ដែលបានបញ្ជាក់នូវឥទ្ធិពលនៃមនោគមន៍ ទេវ-រាជា។

ការបង្រួបបង្រួមប្រទេសជាមួយនឹងទឹកដីចាស់ នៃអតីតចក្រភពបាភ្នំ បានផ្តល់លទ្ធភាពជាថ្មីដល់រាជវង្សានុវង្សខាងចន្ទ្រវង្ស ឱ្យគ្រប់គ្រងរាជសម្បត្តិ។ សមាជិកមួយអង្គនៃរាជវង្សានុវង្សនេះ គឺព្រះបាទយសោវរ្ម័នទី១ ដែលជារាជបុត្ររបស់ព្រះបាទឥន្ទ្រវរ្ម័នទី១ បានឡើងគ្រប់គ្រងរដ្ឋដោយប្រកាន់នយោបាយនៃការ “ រក្សាពង្រឹងសមិទ្ធផលដែលបានមក ”។ នៅក្នុងរជ្ជកាលព្រះអង្គ មានការអនុវត្តនយោបាយពង្រឹងលទ្ធផលនៃការវិវត្តខាងសង្គម-សេដ្ឋកិច្ច ដែលត្រូវបានបំពេញជាបន្តបន្ទាប់មកតាំងពីសតវត្សរ៍ទី៩។ ព្រះអង្គបានកសាងរដ្ឋធានីថ្មី ហៅថា យសោធរបុរៈ (អង្គរធំ) នៅក្នុងតំបន់អមរេន្ទ្របូរៈ ហើយនៅពេលជាមួយគ្នា មានការបន្តនយោបាយពង្រីកមូលនិធិដីកាប់គាស់ថ្មីៗតាមមធ្យោបាយនៃការកសាងប្រព័ន្ធបង្ហូរទឹក។ រដ្ឋធានីថ្មីបានទៅជាមជ្ឈមណ្ឌលនៃតំបន់ស្រែចម្ការភាគខាងបស្ចិម រហូតដល់ព្រំប្រទល់នៃទឹកដីខ្មែរចាស់ៗ ហើយបានទៅជាតំបន់ស្រែចម្ការប្រកួតប្រជែងនឹងមជ្ឈមណ្ឌលចាស់នៃអតីតចក្រភពបាភ្នំ។ វណ្ណៈអភិជនសក្តិភូមិ ដែលរស់នៅតាមទីវាលទំនាបនៃទន្លេមូន ដែលគ្មានមធ្យោបាយកាប់គាស់ដីបែបនេះ ពុំបានទៅជាវណ្ណៈអភិជនដឹកនាំនៃចក្រភពថ្មីឡើយ។

នៅក្នុងរជ្ជកាលព្រះបាទយសោវរ្ម័នទី១ នយោបាយត្រួសត្រាយដែនដីថ្មីនៅភាគខាងពាយ័ព្យ ត្រូវបានបន្តយ៉ាងសកម្ម។ កិច្ចការដ៏ធំធេងនេះ បានប្រព្រឹត្តទៅដោយសារហេត្ថារបស់បណ្តាកសិករ ដែលបានត្រួសត្រាយធ្វើរបរលើដី និងបានកសាងប្រព័ន្ធបង្ហូរទឹកទាំងឡាយ។ វណ្ណៈកសិករនៅពេលនោះ គឺជាពលកម្មផលិតករជាមូលដ្ឋាន។

រដ្ឋបានដឹកនាំការស្ថាបនាប្រព័ន្ធបង្ហូរទឹកដ៏ធំៗបំផុតហើយប្រព័ន្ធបង្ហូរទឹកតូចៗ ត្រូវបានកសាងឡើងដោយបណ្តាវណ្ណៈសក្តិភូមិជាបព្វជិត និងគ្រហស្ថ ព្រមទាំងដោយភូមិសហគមន៍។ ក្រោមការត្រួតត្រារបស់រដ្ឋ គណៈសង្ឃគ្រប់សាសនាទាំងអស់បានទទួលដីព្រៃនៅទីដាច់ស្រយាលនៃប្រទេស ហើយបានដឹកនាំការត្រួសត្រាយដីទាំងនេះ ដោយពលកម្មរបស់បណ្តាអ្នកស្រែ និងពួកក្ញុំ។ នៅពេលនោះ គេអាចសន្មតបានថា វត្តអារាម គឺជា “ ស្ថាប័នជួរមុខ ” នៅក្នុងការត្រួសត្រាយ និងការកាន់កាប់សិទ្ធិលើដីថ្មីៗ។ មុខងារបែបនេះរបស់វត្តអារាម គេតែងប្រទះឃើញនៅក្នុងប្រទេសសក្តិភូមិដទៃ។ នៅពេលជាមួយគ្នា កម្មសិទ្ធិជាម្ចាស់ដីរបស់ពួកសក្តិភូមិជាគ្រហស្ថ ក៏កាន់តែលូតលាស់ច្រើនដោយសារសេចក្តីអនុញ្ញាត ជាចាំបាច់ពីសំណាក់គណៈសង្ឃលើការបន្តកេរមរតក ដោយហេតុថា កម្មសិទ្ធិលើដីរបស់គ្រហស្ថសុទ្ធសាធ ពុំដែលមានទេ ហើយបើតាមការសន្និដ្ឋាន ដីភូមិជាកម្មសិទ្ធិទាំងនេះ កាន់តែមានច្រើនឡើងៗនៅជិតរដ្ឋធានី។

នៅទីបំផុត រដ្ឋធានីយសោធរបុរៈ បានប្រែទៅជាមជ្ឈមណ្ឌលនៃតំបន់កសិកម្មដ៏សំខាន់មួយ ប្រកបដោយបណ្តាជនកុះករ ហើយបានប្រែទៅជាប្រភពនៃការចែករំលែកទឹកសម្រាប់

តំបន់កសិកម្មដ៏ធំធេង។ កិច្ចការនេះបានសម្រេចឡើងដោយការកសាងបឹងទន្លេសិប្បនិម្មិតដ៏ធំៗមហិមា ដូចជា បឹងយសោធរៈតដាកៈ បារាយណ៍ទឹកថ្លា ព្រមទាំងបឹង និងត្រពាំងដ៏ទៃទៀតចំនួន ៨០០កន្លែង ព្រមទាំងព្រែកជីក និងប្រឡាយបង្ហូរទឹកមួយចំនួនធំ។ រដ្ឋធានីបានរីកធំសម្បើម គឺជាទីក្រុង ដែលបានកសាងឡើងដោយគម្រោងការដ៏ធើតធាយ។ តំបន់ជាយក្រុងប្រកបដោយដំណាំ បានកកើតមានឡើងពីដីភូមិរបស់វត្តអារាម និងរបស់វណ្ណៈអភិជន និងពីភូមិដ្ឋានរបស់អ្នកស្រុក។ គឺតំបន់ទាំងនេះហើយ ដែលបានទៅជាមូលដ្ឋានដ៏រឹងមាំខាងសេដ្ឋកិច្ច និងខាងបណ្ដាជន ហើយដែលព្រះមហារាជគ្រងរាជ្យតមក បន្ទាប់ពីព្រះបាទយសោវរ្ម័ន បានពឹងផ្អែក ដើម្បីស្ថាបនាចក្រភពកម្ពុជទេស។

ការបង្កើតស្ថានភាពខាងសេដ្ឋកិច្ច របស់វណ្ណៈអភិជនសក្តិភូមិជាបព្វជិត និងគ្រហស្ថ បានប្រព្រឹត្តទៅនៅពេលជាមួយគ្នានឹងការពង្រឹងរដ្ឋអំណាចមជ្ឈិម ដែលជាអំណាចតែមួយក្នុងការចែករំលែកដីភូមិ។ នៅក្នុងរដ្ឋកាលរបស់ព្រះបាទយសោវរ្ម័នទី១ ការធ្វើសក្ការៈបូជា ទេវ-រាជា នៅប្រាសាទបាគងមានកម្រិតកាន់តែខ្លាំង។ ការត្រួសត្រាយដីនៅភូមិភាគខាងបស្ចិមដើម្បីឱ្យទៅជាមូលដ្ឋានខាងសេដ្ឋកិច្ច និងសង្គមកិច្ច ក៏បានសម្រេចផល។ នៅសម័យនោះ នៅដែនដីដាច់ស្រយាលនៃប្រទេស មានការស្ថាបនាទីក្រុងប្រកបដោយវត្តអារាម ដែលបានទៅជាមជ្ឈមណ្ឌលនៃជីវភាពខាងសេដ្ឋកិច្ច និងនយោបាយរបស់ចក្រភពកម្ពុជទេស។ ជាការពិត ការពង្រីករដ្ឋសក្តិភូមិបានទាក់ទងនឹងគោលបំណងនៃការពង្រីកទឹកដីរបស់ប្រទេស។

ព្រះបាទយសោវរ្ម័នទី១ បានចាប់ផ្តើមធ្វើយុទ្ធនាការទៅប៉ែកខាងត្បូងប្រទេសឡាវ ចូលទៅតាមទឹកដីនៅឈូងសមុទ្រសៀម នៅតំបន់ចន្ទបូរី ហើយទៅតំបន់ពាម (សព្វថ្ងៃ ហាទៀន)។

ប៉ុន្តែ មុននឹងចាប់ផ្តើមធ្វើយុទ្ធនាការទាំងនេះ ប្រទេសបានជួបប្រទះនឹងវិបត្តិផ្ទៃក្នុងចុងក្រោយ កើតមកពីការតស៊ូដណ្តើមអំណាចរដ្ឋ ដោយហេតុថា ភូមិភាគគោកគគីរ (កោះកេរ) ដែលស្ថិតនៅប៉ែកខាងកើតនៃបឹងទន្លេសាប បានដើរតួប្រឆាំងនឹងរដ្ឋធានីយសោធរបុរៈ។ ដំណាក់កាលសម័យខាងដើមនៃចក្រភពកម្ពុជទេស ដែលបានចាប់ផ្តើមឡើងជាដំណាក់កាល សម្បូរទៅដោយព្រឹត្តិការណ៍នានាខាងសង្គម-សេដ្ឋកិច្ច និងខាងនយោបាយ។ ដោយសារការបង្រួបបង្រួមសម្បត្តិដីទាំងឡាយរបស់វត្តអារាម កម្មសិទ្ធិជាម្ចាស់ដីរបស់វត្តអារាម ក៏បានរីកចម្រើនយ៉ាងខ្លាំង។ វត្តអារាមក៏បានក្លាយជាមជ្ឈដ្ឋាននៃវណ្ណៈសក្តិភូមិដ៏ខ្លាំងក្លា។ ដូច្នេះហើយ បានជារដ្ឋអំណាចមជ្ឈិមបានខំសាកល្បងកម្រិតឥទ្ធិពលដ៏ខ្លាំងក្លា ខាងសេដ្ឋកិច្ចរបស់វត្តអារាមទាំងនេះ។ ព្រះមហារាជបានកម្រិតនូវអំណោយជាដីភូមិដល់វត្តអារាមទាំងឡាយ ហើយសម្បត្តិដីរបស់វត្តអារាមទាំងឡាយបានរីកចម្រើន ដោយសារការប្រមូលផ្តុំបណ្តាម្ចាស់ដីតូចតាច (ជាពិសេស ដោយសារការទិញដោយបំណុល ។ល។)។ នៅពេលនោះ ព្រះមហារាជបានរៀបចំឱ្យមានការត្រួតត្រាដ៏តឹងរឹងទៅលើដីធ្លីជាអំណោយទាំងអស់។ នៅសម័យនោះ ការធ្វើអំណោយដីឈ្មោះ "រាជ្យបុណ្យ"។ ជួសកាលធ្វើអំណោយដី ឈ្មោះ "បុណ្យ" ដោយហេតុថា រដ្ឋក៏បានទទួលផលមួយភាគពីដីធ្លីជាអំណោយនេះ។

ព្រឹត្តិការណ៍ថ្មីៗ បានបង្កើតឱ្យមានផលវិបាក ពិសេសនៅលើដែនដីចាស់ៗ ដែលមានកម្មសិទ្ធិ នៅលើដីកាន់តែច្រើន (ដីទំនេរមានតិច)។ គឺនៅទីនោះហើយ ដែលមានការត្រួតត្រាខាងភូមិបាលដ៏មធ្យ័ត ដោយហេតុថា ដីទាំងនេះលែងនៅជាកម្មសិទ្ធិរបស់អ្នកស្រុកស្រែ និងរបស់ពួកសក្តិភូមិតូចតាចទៀតហើយ។ ដីធ្លីទាំងអស់ត្រូវបានចុះបញ្ជីកំណត់តាមផ្លូវច្បាប់ រដ្ឋការនៅទីអាយទទួលបន្ទុក តាមពិនិត្យដល់របស់របរកសិកម្មលើដីវត្តអារាម។ ហេតុនេះ បានជាមិនមែនជាចៃដន្យទេ ដែលតែងមានបណ្តឹងជាញឹកញាប់របស់អ្នកតំណាងវត្តអារាម ស្តីអំពីការទារពន្ធដារមិនត្រឹមត្រូវរបស់បណ្តាមន្ត្រី “ខ្លោញ”។ ក៏ប៉ុន្តែ បណ្តឹងទាំងនេះប្រហែលលេចចេញមកពីមជ្ឈដ្ឋានខ្លះ នៃរាជវាំង។ យើងសូមរំលឹកថា ដូចជានៅប្រទេសដ៏ទៃជាច្រើននៅអាស៊ីអាគ្នេយ៍ រដ្ឋសក្តិភូមិ តែងមានបំណងរក្សាទុកនូវក្រុបខ័ណ្ឌកសិករសេរី ដែលជាអ្នកបង់ពន្ធដារ និងជាទាហាន។ នៅក្នុងវិបត្តិនេះ ពួកអភិជនសក្តិភូមិជាមន្ត្រីនាហ្មឺន ដែលបានទៅជាអ្នកមានទ្រព្យសម្បត្តិ ក៏ដោយសារស្ថានភាពរបស់ឃ្លាំងព្រះរាជទ្រព្យរបស់ពួកអភិជនទាំងនេះ តែងបានថ្លែងប្រឆាំងនឹងពួកអភិជនសក្តិភូមិជាបព្វជិត ដោយហេតុថា ពួកជនខាងក្រោយទាំងនេះ បានធ្វើឱ្យបណ្តាអ្នកស្រុកស្រែចុះអន់ថយ ដោយសារការលក់ដី។

ព្រះបាទជ័យវរ្ម័នទី៤ (គ.ស.៩២១ គ.ស.៩២៧ - គ.ស.៩៤៨) ប្រហែលបានខិតខំសាកល្បងបង្ក្រាបការតស៊ូប្រឆាំងរបស់ពួកមន្ត្រីធំៗ ដែលបម្រើរាជការ និងរបស់គណៈសង្ឃជាន់ខ្ពស់ ដោយការពង្រឹងរដ្ឋអំណាចមជ្ឈិម។ នៅពេលក្រោយមក សកម្មភាពបែបនេះរបស់ព្រះអង្គមានវិបត្តិនឹងព្រះបាទហស៌វរ្ម័នទី១ និង

ព្រះបាទឦសានវរ្ម័នទី២ ដែលជាក្មួយរបស់ព្រះអង្គ។ វិបត្តិនេះបានវិវត្តឡើងលើមូលដ្ឋាននយោបាយជាងលើមូលដ្ឋានយោធា ហើយដែលបង្កើតបានជាព្រឹត្តិការណ៍ដូចតទៅ។ ព្រះបាទហស៌វរ្ម័នទី១ (គ.ស. ៩០០ ឬ គ.ស.៩១២ -៩២២) ប្រហែលដល់ គ.ស. ៩២៥ បានបន្តនយោបាយព្រះបាទយសោវរ្ម័ន ជារាជបិតាព្រះអង្គ។ ក៏ប៉ុន្តែ នៅក្នុងរជ្ជកាលព្រះអង្គ វិបត្តិដូចយើងបានអធិប្បាយ បានកើតមានឡើងខ្លះៗមកហើយ ហើយវិបត្តិនេះបានទាក់ទងនឹងឥរិយាបទខាងជំនឿ របស់ព្រះបាទហស៌វរ្ម័ន ដែលបានដកខ្លួនថយពីពួកអភិជនកាន់សាសនា ព្រះឥសូរ ហើយបានគាំទ្រពង្រឹងជំហររបស់ពួកអភិជន កាន់សាសនាព្រះវិស្ណុវិញ។ នៅ គ.ស. ៩២១ ព្រះបាទជ័យវរ័ន្មទី៤ ដែលជាឪពុកមាព្រះបាទហស៌វរ្ម័ន ប្រកាន់ឥរិយាបទប្រឆាំងនឹងក្មួយ ហើយបានចេញទៅតាំងរដ្ឋធានីនៅគោកគគីរ (កោះកេរ) ដែលស្ថិតនៅក្រៅពីតំបន់ស្រែចម្ការ។ ព្រះបាទជ័យវរ្ម័នទី៤ បានអនុវត្តនយោបាយផ្ទៃក្នុង ដោយការពង្រឹងរដ្ឋអំណាចមជ្ឈិម។ ហេតុនេះហើយ បានជាព្រះអង្គបានចាប់ផ្ដើមធ្វើការកសាងប្រាសាទធំៗមហិមា ដូចជាប្រាសាទកោះកេរ។ ផ្ទុយទៅវិញ ដោយមានការឱ្យតម្លៃដល់ប្រព័ន្ធទំនាក់ទំនងខាងសង្គមកិច្ច ព្រះបាទហស៌វរ្ម័ន បានកសាងប្រាសាទដ៏តូចសម្រាប់តម្កល់ព្រះរាជលិង្គទេវរាជា។ ព្រះអង្គពុំបានកសាងសំណង់អ្វីដ៏អស្ចារ្យ ដើម្បីសំដែងនូវមហិទ្ធិឫទ្ធិរបស់ព្រះមហារាជឡើយ។

រវាង គ.ស. ៩២២ និង គ.ស. ៩២៥ ព្រះបាទឦសានវរ្ម័នទី២ ជាប្អូនពៅព្រះបាទហស៌វរ្ម័ន បានឡើងសោយរាជ្យជំនួស។ មហាក្សត្រអង្គនេះ បានគ្រប់គ្រងប្រទេសក្នុងរយៈពេលដ៏ខ្លីនៅ

លើដែនដីមួយភាគនៃកម្ពុជទេស។ របបគ្រប់គ្រងប្រទេសរបស់ព្រះអង្គមានលក្ខណៈខុសគ្នាពីរបបគ្រប់គ្រង របស់ឪពុកមាព្រះបាទជ័យវរ្ម័នទី៤ ដែលបានបញ្ជាក់ថា រាជលិង្គទេវ-រាជាបានចេញទៅគង់នៅគោកគគីរ។ មហាក្សត្រនីមួយៗមានរាជលិង្គទេវ-រាជា ផ្ទាល់ ដែលជាហេតុអាចបង្កើតឱ្យមានសភាពការណ៍ខាងមនោគមវិជ្ជាខុសធម្មតា។ នៅ គ.ស. ៩២៧ ឬ គ.ស. ៩២៨ ព្រះបាទឦសានវរ្ម័នទី២ បានសោយទិវង្គត។ គឺចាប់តាំងពីពេលនោះហើយ ដែលព្រះបាទជ័យវរ័ន្មទី៤ បានក្លាយទៅជាព្រះមហារាជតែមួយអង្គ នៃចក្រភពកម្ពុជទេស។

ព្រះបាទជ័យវរ្ម័នទី៤ បរមស្វរបទ បានអនុវត្តជាពិសេសនូវកម្មវិធីនយោបាយថ្មីរបស់ព្រះអង្គ។ គោកគគីរ (កោះកេរ) បានទៅជារដ្ឋធានីថ្មីនៃចក្រភព។ ការបង្កើតរដ្ឋធានីបានបញ្ជាក់នូវការឈប់ប្រកាន់តាមនយោបាយនៃព្រះមហារាជ ដែលបានគ្រងរាជសម្បត្តិនៅពេលមុន។ ព្រះអង្គបានបន្តការស្ថាបនាសំណង់ប្រាសាទធំៗ ហើយប្រាសាទជាគំរូច្បាស់ជាងគេ គឺប្រាសាទដែលមានតម្កល់រាជលិង្គត្រីភូវនេស្វរៈ។ ប្រាសាទនេះមានសណ្ឋាន ជាមហាចេតិយប្រកបដោយថ្នាក់ ប្រាំពីរជាន់កម្ពស់៣៥ម៉ែត្រ ហើយមានទ្រង់ទ្រាយដ៏ធំសម្បើមសម្រាប់អ្នកស្រុកសម័យនោះ។នៅលើកំពូលមានតម្កល់រាជលិង្គត្រីភូវនេស្វរៈ ដែលសិលាចារឹកជាភាសាខ្មែរហៅថា “ កម្រតែងជ៏រាជា ” ដែលបញ្ជាក់នូវគោលការណ៍នៃពិធីសក្ការៈបូជាទេវ - រាជា។

បន្ទាប់ពីពេលមានជ័យជម្នះសព្វគ្រប់លើមហាក្សត្រទាំងពីរជាក្មួយព្រះអង្គ ព្រះបាទជ័យវរ្ម័នទី៤ បានប្រមែប្រមូលកម្លាំងទាំងអស់ដើម្បីពង្រឹងរដ្ឋអំណាចមជ្ឈិម។ រដ្ឋអំណាចបែបនេះ

បានផ្តល់លទ្ធភាពដល់ការស្ថាបនាសំណង់ធំៗ ដល់ការចែករំលែកដីទាំងឡាយនៅជុំវិញរដ្ឋធានីថ្មីនៃចក្រភព ផ្តល់លទ្ធភាពដល់ការពង្រឹងរដ្ឋអំណាចមជ្ឈិម។ មូលដ្ឋានជាបង្គោលរបស់ព្រះបាទជ័យវរ្ម័នទី៤ នៅក្នុងរជ្ជកាលរបស់ព្រះអង្គនាសម័យនោះ គឺតំបន់ទាំងឡាយនៅខាងពាយព្យនៃប្រទេស។

បន្ទាប់ពីមរណភាពរបស់ព្រះបាទជ័យវរ្ម័នទី៤ រដ្ឋអំណាចបានធ្លាក់ក្នុងកណ្តាប់ដៃនៃមន្ត្រីនានា ដែលទទួលបន្ទុកឧបត្ថម្ភព្រះបាទហស៌វរ្ម័នទី២ ដែលជារាជបុត្រដ៏ក្មេងរបស់ព្រះអង្គ (គ.ស. ៩៤១ គ.ស.៩៤២ - គ.ស.៩៤៤)។ ក៏ប៉ុន្តែ នៅពេលនោះ ពួកអភិជនសក្តិភូមិនៅរដ្ឋធានីយសោធរបុរៈ បានគាំទ្របេក្ខជនភាពព្រះបាទរាជេន្ទ្រវរ្ម័នទី២ ដែលមានវ័យក្មេង (គ.ស. ៩៤៤ - គ.ស. ៩៦៨) ជាបងប្អូនជីដូនមួយនឹងព្រះបាទហស៌វរ្ម័នទី២ (ស្ថានភាពជាបងប្អូនបែបនេះ នៅមិនទាន់ជាជាក់ច្បាស់)។

នៅ គ.ស. ៩៤៤ បក្សពួកខាងព្រះបាទរាជេន្ទ្រវរ្ម័នទី២ បានទទួលជ័យជម្នះ។ តាមសិលាចារឹកក្នុងរជ្ជកាលព្រះអង្គ ដែនដីខ្មែរជាចុងក្រោយ (នៅខាងទិសឦសាននៃប្រទេស ដែលបានទាមទារស្វ័យភាព) ត្រូវបានបង្រួបបង្រួមមកក្នុងចក្រភពកម្ពុជទេស។ យសោធរបុរៈ (អង្គរធំ) ក៏បានប្រែត្រឡប់ជារដ្ឋធានីនៃប្រទេស ដូចពេលមុនវិញ។

សម័យកាល នៃរជ្ជកាលរបស់ព្រះបាទរាជេន្ទ្រវរ្ម័នទី២ និងរបស់ព្រះបាទជ័យវរ្ម័នទី៥ ជារាជបុត្រព្រះអង្គ (គ.ស. ៩៦៨ - គ.ស. ១០០១) គឺជាដំណាក់កាលនៃការចាប់ផ្តើមសម័យរុងរឿងនៃចក្រភពកម្ពុជទេស។ មូលដ្ឋានខាងសង្គមកិច្ចរបស់ចក្រភពក៏បានលូតលាស់ ដោយការកម្រិតយ៉ាងខ្លាំងដល់ការប្រើប្រាស់

កម្លាំងពលករក្នុំនៅក្នុងរបរកសិកម្មធំៗ ហើយចំពោះពលករក្នុំ តែងមានការចែករំលែកដីធ្លី។ ពលករក្នុំទាំងឡាយក៏បានប្រែ ក្លាយទៅជាអ្នកស្រែដោយមានការទាក់ទងទៅនឹងពន្ធដារ។

នៅពេលជាមួយគ្នា មានការកំណត់កម្រិតនៃពន្ធដារ ប៉ុន្តែ គ្មានការបញ្ជាក់អំពីទំហំដី ចំនួន និងឈ្មោះកសិករ ដែលដាំ ដំណាំលើដី។ រដ្ឋអំណាចមជ្ឈិមបានសម្រេចកិច្ចត្រួតត្រារបស់ ខ្លួនលើម្ចាស់ដីធំៗដែលជាបព្វជិត បានតម្រែតម្រង់ការលួតលាស់ របរលើដីរបស់ពួកនេះ ទៅតាមច្បាប់ទម្លាប់ដីរដ្ឋ ដែលប្រគល់ ដល់វត្តអារាម។ ការត្រួតត្រារបស់រាជការលើសកម្មភាពខាង សេដ្ឋកិច្ចរបស់ពួកសក្តិភូមិត្រូវបានបង្កើន។

នៅសម័យនោះ ស្រទាប់បុគ្គលប្រកបដោយឋានន្តរនាម “ វាប ” បានចាប់ផ្តើមចុះអន់ថយ។ តាមធម្មតា ពួកអ្នកម្ចាស់ដី តូចតាចទាំងនេះ នៅស្រុកស្រែដែលតែងផ្តល់កូនថៅដល់កង កម្លាំងទ័ពរបស់ប្រទេស បានបង្កើនស្ថានភាពតាមផ្លូវច្បាប់របស់ ខ្លួន ដោយបានចូលរួមកាន់តែច្រើនក្នុងតំណែងបន្ទាប់បន្សំនៃ អង្គការរាជការ។ នៅពេលជាមួយគ្នា មូលនិធិដីរបស់ពួក “ វាប ” ក៏កាន់តែចុះអន់ថយ ហើយដីមួយភាគរបស់ពួកជនទាំងនោះ បានចូលទៅជាសម្បត្តិទ្រព្យរបស់គណៈសង្ឃ។ នៅពេលជាមួយ គ្នា អំណោយដីដោយព្រះមហារាជក៏កាន់តែមានតិច។ សភាព ការណ៍នេះ បញ្ជាក់ឱ្យដឹងថា សម្បត្តិបម្រុងខាងដីកាប់គាស់ថ្មី បានទៅជាស្តួចស្តើង ហើយបញ្ជាក់ឱ្យដឹងម៉្យាងទៀតនូវការចុះ អន់ថយល្បឿននៃរបរលើដីកាប់គាស់ថ្មី។ នៅលើដីចាស់ៗ ការងារ របស់ពលករក្នុំត្រូវបានបន្ថយជាខ្លាំង ដោយសារការបង្កើនរបៀប គ្រប់គ្រងកសិដ្ឋានរបស់វត្តអារាម ហើយមានតែភូមិសហគមន៍

នៅស្រុកស្រែទាំងឡាយ។ សភាពការណ៍ទាំងអស់បានចោទជាបញ្ហាចាំបាច់ស្តីអំពី ការពង្រីកទឹកដីតទៅទៀតនាសម័យកាលខាងដើមនៃចក្រភពកម្ពុជទេស ប៉ុន្តែ ទិសដៅបែបនេះ ត្រូវបានបំពេញជាជំហានទីមួយរួចមកហើយ នៅក្នុងរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័ន។

ការអនុវត្តការបែកវំលែកដីសាជាថ្មី បានប្រព្រឹត្តទៅយ៉ាងសកម្មនៅសម័យកាលនៃរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័នទី៥។ ឯកសារតាមសិលាចារឹកជាច្រើន បានបញ្ជាក់អំពីសភាពការណ៍ទាំងនេះ។

នៅរដ្ឋជានីយសោធរបូរៈ ការកសាងស្ថាបនកម្មនានាបានចាប់ផ្តើមសាជាថ្មី ហើយមានចលនាឃឹតយ៉ាវបន្តិចនាទសវត្សរ៍ទី២-៣។ នយោបាយក្រៅប្រទេស ត្រូវបានអនុវត្តជាបន្តដោយការបង្រួបបង្រួមដែនដីចុងក្រោយនៃភូមិភាគគវបូរៈ ហើយយុទ្ធនាការនៃសង្គ្រាមរបស់ចក្រភព ក៏បានចាប់ផ្តើមធ្វើដំណើរទៅមុខ។ ក្នុងការតបតនឹងចម្បាំងវាយលុករបស់ប្រទេសចម្ប៉ានៅចុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៤ បណ្តាមន្ត្រីជាអ្នកឧបត្ថម្ភយុវព្រះបាទរាជេន្ទ្រវរ្ម័នទី២ បានផ្តើមធ្វើការវាយលុកប្រកបដោយជោគជ័យលើប្រទេសចម្ប៉ា ហើយបានកាន់កាប់រដ្ឋធានីប្រទេសនេះ។ នៅពេលនោះ ចក្រភពកម្ពុជទេស បានទៅជាប្រទេសអាណាព្យាបាលប្រទេសចម្ប៉ា។

នយោបាយផ្ទៃក្នុងត្រូវបានបន្តទៅទៀត ដោយការពង្រឹងនៃរដ្ឋអំណាចមជ្ឈិម តាមមធ្យោបាយពង្រឹងសាមគ្គីភាពវវាងវណ្ណៈអភិជនបម្រើរាជការ និងគណៈសង្ឃខាងព្រហ្មញ្ញសាសនា និងពុទ្ធសាសនា។ ព្រាហ្មណ៍បរោហិតដែលជាព្រះរាជគ្រូផ្ទាល់

របស់មហាក្សត្រ គឺមានបណ្ដារាជកូលមហាមន្ត្រីជាដើម បានដើរតួនាទីសំខាន់ក្នុងកិច្ចការប្រទេស។ ក៏ប៉ុន្តែ នៅពេលនោះ ព្រហ្មញ្ញសាសនាមិនមែនជាសាសនាតែមួយ នៅក្នុងប្រទេសទេ។ បរិស័ទកាន់ពុទ្ធសាសនា បានកាន់កាប់យ៉ាងរឹងប៉ឹងនូវតំណែងនានារបស់ខ្លួន ដូចជាតំណែងជាមហាមន្ត្រីព្រះមហារាជ។ មនោគមន៍នៃពិធីសក្ការៈបូជាទេវរាជា ក៏កាន់តែមានឥទ្ធិពល ប្រាង្គប្រាសាទដែលបានកសាងឡើងថ្មីៗ ក៏មានទំហំធំសម្បើម ដូចជា ប្រាសាទប្រែរូប។ ស្ថាបនកម្ម នៃប្រាសាទ-វិហារ ឈ្មោះភិមានអាកាសក៏បានសម្រេចសព្វគ្រប់។ សម្បត្តិដីធំៗរបស់ពួកអភិជនសក្តិភូមិត្រូវបានបន្ថយ ក៏ប៉ុន្តែ បណ្ដាម្ចាស់ដីធំៗ គឺជាមន្ត្រីបម្រើរាជការនៅបរមរាជវាំង ហើយទោះបីនៅលើសម្បត្តិដី ដែលមានបុគ្គលជាម្ចាស់កម្មសិទ្ធិផ្ទាល់ក៏ដោយក៏ព្រះវិហារ ដែលត្រូវកសាងឡើងលើដីនោះ ត្រូវតែមានទិសដៅឧទ្ទិសដល់មហិទ្ធិឫទ្ធិលើផែនដីរបស់ព្រះមហារាជ ដែរ។ ព្រះវិហារបែបនេះមួយដ៏ល្បីល្បាញបំផុតដែល ជាសមិទ្ធិផលដ៏ខ្ពង់ខ្ពស់ ខាងក្បូរក្បាច់រចនាដ៏ឆើតឆាយ គឺប្រាសាទបន្ទាយស្រី។

គួរកត់សម្គាល់ថា នៅពេលនោះ ពុំមានស្ថាបនកម្មនៃប្រព័ន្ធបង្ហូរទឹកធំៗទេ ហើយដើម្បីបំពេញស្ថាបនកម្មបែបនេះ ត្រូវមានមធ្យោបាយខាងសម្ភារៈ ដែលកើតមានមកដោយសារការដណ្ដើមយក និងត្រួសត្រាយនូវដែនដីថ្មីៗ។ ទោះដូច្នេះក្ដី ក៏នៅពេលខាងចុងនៃរជ្ជកាលព្រះបាទរាជេន្ទ្រវរ្ម័នទី២ មានការធ្វើអំណោយដីជាច្រើន ហើយការធ្វើអំណោយបែបនេះ ត្រូវបានកម្រិតនៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៥។ ស្ថាបនកម្មទូទៅត្រូវបានកម្រិត ហើយមានទាំងការខ្វះមធ្យោបាយសម្រាប់កសាង

ប្រាសាទនានាទៀតផង។ ចំពោះសភាពការណ៍នេះ ក្នុងពេលនោះ គេមិនអាចនិយាយអំពីការថយចំនួននៃមូលនិធិដីទេ ហើយច្បាប់ផ្តល់សិទ្ធិកាន់កាប់ដីធំៗក៏កាន់តែមានច្រើន ក៏ប៉ុន្តែ ឯកសារជាសិលាចារឹកបានបញ្ជាក់ថា សម្បត្តិដីបម្រុងសម្រាប់បរកសិកម្មត្រូវបានចែកចាយសឹងទាំងអស់។ នៅពេលនោះ សម្បត្តិដីសក្តិភូមិបានកើតមានឡើង មិនមែនតែដោយសារការត្រួសត្រាយដីថ្មីៗទេ ក៏ប៉ុន្តែ ដោយមធ្យោបាយទាសកម្ម និងដោយសារខូចខាតដល់ម្ចាស់ដីតូចតាច។ ការចុះអន់ថយនៃស្ថានភាពរបស់ពួក " វាប " ដូចមានអធិប្បាយរួចមកហើយ បានទៅជាសភាពពិតនៅសម័យចុងសតវត្សរ៍។ នៅក្នុងលក្ខខណ្ឌបែបនេះ ការកម្រិតស្ថាបនកម្មសំណង់នានា មិនអាចដោះស្រាយបញ្ហារបស់រដ្ឋដ៏ខ្លាំងក្លា ដែលមានសមត្ថភាពសម្រាប់កិច្ចការចម្បាំងរបស់ប្រទេសបានឡើយ។

ការសាកល្បងត្រួសត្រាយជាថ្មី នូវដែនដីស្រែចម្ការដ៏ធំបានទៅការចាំបាច់ជាបន្ទាន់។ ក៏ប៉ុន្តែ ដែនដីត្រួសត្រាយថ្មីនោះស្ថិតនៅភាគខាងក្រោមនៃទន្លេរថៅ - ប្រែ គឺទន្លេមេ - ណាម ( ប្រទេសសៀម សព្វថ្ងៃ ) ហើយខុសពីតំបន់ជង្រុកស្រូវនៅប៉ែកខាងបស្ចិមផ្ទាល់នៃប្រទេសកម្ពុជា នៅលើដែនដីថ្មីនោះ មានជនជាតិជាបងប្អូនដទៃរស់នៅ គឺជាពិសេសប្រជាជនមន។ ហេតុនេះហើយ បានជាការប្រឹងប្រែងតទៅមុខរបស់រដ្ឋខ្មែរ បានសម្រេចតែតាមមាគ៌ានៃការកសាងចក្រភពពហុជាតិ ដ៏ធំមួយ ហើយការកសាង និងការសម្រេចនូវគោលដៅដ៏វែងឆ្ងាយបែបនេះ បានទៅជាភារកិច្ចជាមូលដ្ឋាននៅក្នុងប្រវត្តិសាស្រ្ត នៃ

សម័យកាលដ៏រុងរឿងនៃចក្រភពអង្គរ នៅសម័យដើមសតវត្សរ៍ទី ១១ - ដល់សម័យដើមសតវត្សរ៍ទី១៣។

សម័យកាលនោះ គឺជាសម័យកាលនៃការវិវត្តដ៏ធំៗ ខាងសង្គម-សេដ្ឋកិច្ចនៅក្នុងសង្គមខ្មែរ ដោយវណ្ណៈអភិជនសក្តិភូមិ ជាម្ចាស់ដីដ៏ធំៗ បានចុះក្រីក្រឱនថយជាបន្តបន្ទាប់ ទោះបីមានការដោះស្រាយនូវបញ្ហាសេដ្ឋកិច្ចខ្លះៗ ដោយមធ្យោបាយយកបានដែនដីក្រៅប្រទេសថ្មីៗ ក៏ដោយ។ សតវត្សរ៍ទី១១ គឺជាសម័យកាលនៃការផ្លាស់ប្តូរសមាសភាពខាងសង្គម របស់ប្រជាពលករ។ ស្ថានភាពប្រជាករក្ញុំ មានលក្ខណៈប្រហាក់ប្រហែលនឹងស្ថានភាពអ្នកស្រុកស្រែ (មានអ្នកងារ ជាដើម) ហើយស្ថានភាពនៃប្រជាករទាំងពីរប្រភេទនេះ បានឈានជំហានមកជិតគ្នានឹងស្ថានការណ៍ដែលនឹងកើតមានឡើង នាសតវត្សរ៍ក្រោយ។ នៅសតវត្សរ៍នោះ ជាមួយនឹងការធ្វើអំណោយដីព្រមទាំងក្ញុំមានការចាប់ផ្តើមធ្វើអំណោយដីភូមិទាំងមូល ព្រមទាំងពួកក្ញុំ ដែលរស់នៅទីនោះទៀតផង។ អំណោយទាំងពីរបែបនេះ ត្រូវបានអនុវត្តកាន់តែញឹកញាប់ ហើយអំណោយក្ញុំដោយគ្មានអំណោយដីមានកាន់តែតិចទៅបន្តិចម្តងៗ។

មានការផ្លាស់ប្តូរជាខ្លាំង នៅក្នុងកិច្ចការបន្តមរតករបស់កសិករសេរី និងម្ចាស់ដីតូចតាច។ អំណោយរបស់ពួកទាំងនេះដល់វត្តអារាមបានចុះថយ ហើយតាមចំនួនសិលាចារឹក និងតាមចំនួនអ្នកធ្វើអំណោយ ឃើញថា ស្រទាប់នៃវណ្ណៈទាំងពីរនេះកាន់តែចុះក្រីក្រ។ ស្រទាប់ជនប្រកបដោយឋានន្តរនាម “ លោញ ” បានក្លាយទៅជាអ្នកម្ចាស់ដីមធ្យម ដែលមានស្ថានភាពកាន់តែល្អ ដោយហេតុនៅសតវត្សរ៍ទី១១ ស្រទាប់ជនទាំងនេះ ភាគច្រើន

បានចូលបម្រើកិច្ចការរាជការ ក្នុងឋានៈជាមន្ត្រីដែលកាន់តំណែងផ្សេងៗ។ គឺតាមបែបនេះហើយ ដែលមានការបែងចែកនូវវណ្ណៈអ្នកម្ចាស់ដីតូចតាច។ ជាទូទៅ តួនាទីរបស់នាម៉ឺនទាំងឡាយកាន់តែលូតលាស់ក្នុងបណ្ដាអ្នកស្រុកស្រែ (កសិករសេរី)។ សម្បត្តិដី ប្រកបដោយលក្ខខណ្ឌរដ្ឋរបស់បណ្ដាអ្នកបម្រើរាជការបានទៅជាសម្បត្តិ ដែលអ្នកបម្រើរាជការទាំងនេះអាចផ្ដល់ជាកេរមរតកដល់កូនចៅ (ជាមួយនឹងតំណែងរបស់ខ្លួន) ក៏ប៉ុន្តែ នៅក្នុងកិច្ចការគ្រប់យ៉ាង សិទ្ធិលើការផ្ដល់ និងការបន្តមរតកត្រូវទទួលសេចក្ដីអនុញ្ញាតពីមហារាជ។

ការធ្វើវិភាគទំនាក់ទំនងខាងកសិកម្ម តាមឯកសារនៃសិលាចារឹក បញ្ជាក់ឱ្យដឹងនូវការចុះក្រីក្រនៃបណ្ដាអ្នកម្ចាស់ដីតូចតាចនៅសតវត្សរ៍ទី១១។ នៅសតវត្សរ៍ទី១១ ការលក់ទិញដីបានប្រព្រឹត្តទៅដោយសង្វាក់យ៉ាងលឿនបំផុតដូចនៅសតវត្សរ៍ទី១០ ក៏ប៉ុន្តែ នៅសតវត្សរ៍ទី១២ កាលណាស្រទាប់អ្នកម្ចាស់ដីតូចតាចមានចំនួនកាន់តែតិច ឃើញថា ការលក់ដីមានសង្វាក់កាន់តែអន់ថយ។ នៅសតវត្សរ៍ទី១១ អំណោយដីដល់វត្តអារាមមានចំនួនតិចបំផុត ហើយចំនួនអំណោយនៅសតវត្សរ៍ទី១២មានប្រហាក់ប្រហែលនឹងនៅសតវត្សរ៍ទី១១។ សភាពការណ៍បែបនេះ បញ្ជាក់ឱ្យឃើញថា នៅសម័យនោះ ការទិញដីបានទៅជាមធ្យោបាយមួយជាមូលដ្ឋាន ដើម្បីបង្កើនសម្បត្តិដីដ៏ធំៗរបស់វណ្ណៈអភិជនសក្តិភូមិ ដែលជាបុព្វជិត។

កម្មសិទ្ធិកាន់កាប់ដីក៏មានការផ្លាស់ប្ដូរជាច្រើន។ គេបានចាប់ផ្ដើមឱ្យតម្លៃដល់ឡូត៍ដីទៅតាមផលដំណាំនៃដីនោះ ហើយរបៀបឱ្យតម្លៃដីបែបនេះ ត្រូវបានគេអនុវត្តពេញលេញនៅសត

វត្សរ៍ទី១២។ ការនេះបញ្ជាក់ឱ្យឃើញនូវការផ្សព្វផ្សាយទូទៅនូវវិធីយកពន្ធដារលើដីប្រកបដោយរបរកសិកម្ម។ ហេតុនេះហើយបានជាការបង់ពន្ធដារ មិនមែនមានដល់តែចំពោះបុគ្គលដែលរស់នៅ ហើយធ្វើរបរលើដីដូចពេលមុនប៉ុណ្ណោះទេ ប៉ុន្តែ មានដល់ភូមិដ្ឋានទាំងឡាយរបស់ពលករក្ញុំ និងភូមិដ្ឋានរបស់អ្នកស្រុកស្រែទៀតផង។

ការវិវត្តសង្គម - សេដ្ឋកិច្ចនៅក្នុងប្រទេស បានប្រព្រឹត្តទៅនៅសម័យខាងដើមនៃសតវត្សរ៍ទី១១ ដោយមានការតស៊ូប្រយុទ្ធផ្ទៃក្នុងដ៏តឹងតែងខាងមនោគមវិជ្ជា និងខាងនយោបាយ។ តាំងពីពេលឡើងសោយរាជសម្បត្តិ ព្រះបាទជ័យវិរវរ្ម័នទី១ (គ.ស. ១០០២ - គ.ស.១០១១) និងរបបគ្រប់គ្រងសិវៈនិយមរបស់ព្រះអង្គត្រូវបានបង្ខំចិត្ត ធ្វើការតស៊ូប្រឆាំងនឹងព្រះបាទសុរ្យវរ្ម័នទី១ ដែលជាព្រះមហាក្សត្រកាន់ពុទ្ធសាសនា។ នៅឆ្នាំ១០០៦ កងទ័ពរបស់ព្រះបាទសុរ្យវរ្ម័នទី១ បានទទួលជ័យជម្នះដ៏ត្រចេះត្រចង់ ហើយវាយដណ្តើមយកបានរដ្ឋធានីយសោធរបុរៈ។ ចម្បាំងរវាងមហាក្សត្រទាំងពីរ បានប្រព្រឹត្តទៅយ៉ាងស្វិតស្វាញ អស់ពេលយ៉ាងយូរ ដោយហេតុថា កងទ័ពរបស់ព្រះបាទជ័យវិរវ័ន្មទី១ បានបន្តយុទ្ធនាការនៅភាគខាងត្បូងប្រទេស រហូតដល់ គ.ស. ១០១១។ ទឹកដីប្រទេសត្រូវបានបង្រួបបង្រួមជាថ្មី នៅក្នុងអំឡុងមួយឆ្នាំក្រោយមក។ នៅលើមូលដ្ឋាននៃទស្សនៈខាងសាសនាខុសគ្នារបស់អតីតមហាក្សត្រ និងមហាក្សត្រថ្មី។ ការអនុវត្តនយោបាយពង្រីកចក្រភពកម្ពុជទេស ប្រកាន់ដោយព្រះបាទសុរ្យវរ្ម័នទី១ ជាពិសេសទាក់ទងនឹងប្រទេសមន ជាប្រទេសកាន់ពុទ្ធសាសនា ដែលស្ថិតនៅតាមទីវាលទំនាបនៃទន្លេចៅ - ប្រែន

ប្រទេសថៃឡង់ដ៍ បានតម្រូវឱ្យមានការបន្ធូរបន្ថយសេរីភាពក្នុងនយោបាយសាសនាជាងពេលមុន។ ព្រះបាទសុរ្យវរ្ម័នទី១ បានបង្រួបបង្រួមជុំវិញរាជបល្ល័ង្ក នូវបណ្តាអភិជនសក្តិភូមិជាបព្វជិត និងគ្រហស្ថ មានទាំងបណ្តាអភិជន ដែលបានថ្លែងប្រឆាំងព្រះអង្គពេលមុន ដើម្បីបង្កើតជាខឿននយោបាយដ៏ធំទូលាយសម្រាប់បម្រើនូវបំណងរបស់ព្រះអង្គក្នុងការពង្រីកទឹកដីចក្រភព។ ព្រះអង្គជាពុទ្ធបរិស័ទមួយរូប ក៏ប៉ុន្តែ រក្សានៅការគោរពបូជាទេវ - រាជា និងបុព្វសិទ្ធិគ្រប់បែបយ៉ាងខាងសាសនាព្រះឥសូរ។ នៅពេលជាមួយគ្នា ឥទ្ធិពលនៃសាសនាព្រះវិស្ណុ ក៏មានកាន់តែខ្លាំង ហើយមាននិន្នាការរួមរស់ជាមួយពុទ្ធសាសនា ជាងសាសនាព្រះឥសូរ។

ការឡើងកាន់កាប់អំណាច របស់ព្រះបាទសុរ្យវរ្ម័នទី១ បានប្រព្រឹត្តទៅដោយសារលទ្ធផលនៃការប្រយុទ្ធដោយអាវុធដ៏តឹងតែងបំផុត ហើយនៅពេលនោះ មានទាំងការផ្តន្ទាទោសប្រហារជីវិតផ្សេងៗ។ ព្រះមហារាជថ្មីត្រូវតែរក្សានូវឯកភាពផ្ទៃក្នុង ដើម្បីអនុវត្តនយោបាយពង្រីកចក្រភព។ សមាជិករាជវង្សានុវង្សទាំងអស់បានស្ថិតនៅក្រោមការត្រួតត្រា របស់បរមរាជវាំង ហើយនៅពេលជាមួយគ្នា មានការពង្រឹងតទៅទៀតនូវឯកភាពរដ្ឋខាងនយោបាយ និងសាសនា។ ប្រសិនបើមនោគមន៍នៃពិធីសក្ការៈបូជាទេវ-រាជា បានបង្រួបបង្រួមមជ្ឈដ្ឋានដ៏តូចនៃមុខមន្ត្រីជាន់ខ្ពស់ឱ្យនៅជុំវិញព្រះមហារាជនោះ នៅពេលនេះ នៅលើមូលដ្ឋាននៃសាសានាមជ្ឈដ្ឋាន ដ៏ធំទូលាយ នៃវណ្ណៈអភិជនសក្តិភូមិការិយាល័យនិយមនៅរដ្ឋធានី និងនៅជនបទ ត្រូវបានបង្រួបបង្រួមយ៉ាងជិតស្និទ្ធឱ្យនៅជុំវិញព្រះបាទសុរ្យវរ្ម័នទី១។ បណ្តា

មន្ត្រីទាំងអស់ ទាំងមន្ត្រីនាម៉ឺនថ្នាក់មធ្យម ក៏ត្រូវតែធ្វើសច្ចាប្រណិធាន (ផឹកទឹកសម្បថ) សំដែងស្វាមីភក្តិដល់ព្រះមហារាជ។

ដូចមានសេចក្តីអធិប្បាយខ្លះរួចមកហើយ ប្រទេសមន ដែលស្ថិតនៅតាមទីវាលទំនាបនៃទន្លេ ចៅ-ប្រែន ជាតំបន់សំខាន់ ដែលស្ថិតនៅជិតតំបន់ដីស្រែចម្ការធំៗ ហើយគោលបំណងរបស់អ្នកនយោបាយខ្មែរបានបាញ់ឆ្ពោះទៅទីនោះ។ ដោយមានជាប់សាច់ញាតិខាងរាជវង្សានុវង្ស និងពិភពអ្នកកាន់ពុទ្ធសាសនានៅប្រទេសម៉ាឡាយូ ជាប្រទេសដែលព្រះអង្គបានស្គាល់ច្បាស់ បន្ទាប់ពីបានបញ្ចប់ចម្បាំងផ្ទៃក្នុង ព្រះបាទសុរ្យវរ្ម័នទី១ បានរៀបចំដំណើរយុទ្ធនាការទៅទិសខាងបស្ចិម។ សង្គ្រាមនេះ ត្រូវបានបញ្ចប់សព្វគ្រប់ដោយជោគជ័យ ហើយប្រទេសមានឈ្មោះលុវបូរៈ (ប្រទេសល្វោ) ត្រូវបានចុះចាញ់។

ព្រឹត្តិការណ៍បែបនេះ បានផ្តល់អត្ថន័យដ៏សំខាន់បំផុតចំពោះជោគវាសនាអនាគតរបស់ចក្រភពកម្ពុជទេស ដោយហេតុថា សម្រាប់អំឡុងពេលដ៏យូរអង្វែង តំបន់ដ៏សម្បូរសម្បត្តិធញ្ញជាតិមិនអន់ជាងដែនដីខ្មែរប្រកបដោយស្រែចម្ការដទៃ បានមកស្ថិតនៅក្រោមរបបគ្រប់គ្រងរបស់ចក្រភពកម្ពុជទេស។ ប្រជាជនមនជាបងប្អូន និងប្រជាជនខ្មែរ បានចាប់ផ្តើមក្រេបជញ្ជក់នូវវប្បធម៌ព្រមទាំងច្បាប់ទម្លាប់របស់រដ្ឋ។ នៅសម័យនោះ គេមានមូលហេតុនិងសន្និដ្ឋានបានថា ប្រជាជនមន មួយភាគធំ បានធុញទ្រាំនឹងប្រជាជនខ្មែរ ជាអ្នកឧបត្ថម្ភ។ ពុទ្ធសាសនាជាសាសនាសំខាន់ប្រកាន់ដោយប្រជាជនមន បានស្ថិតនៅដដែល ទោះបីព្រះវិហារខាងព្រហ្មញ្ញសាសនាបានកើតមានឡើងក្តី។

ប្រជាជនខ្មែរបានធ្វើការសាកល្បងបង្រួបបង្រួម ប្រជាជនមន ជាអ្នកស្រុកភ្នំខាងឧត្តរ នៅក្នុងប្រទេសមន មួយទៀតឈ្មោះហរិបុណ្ណជ័យ ដែលជារដ្ឋមិនសូវសម្បូរភោគផលខាងសេដ្ឋកិច្ចដូចជាប្រទេសល្វោ។ ក៏ប៉ុន្តែ កងទ័ពខ្មែរបានធ្វើយុទ្ធនាការដណ្ដើមយកហរិបុណ្ណជ័យនេះ ដែលស្ថិតនៅតាមមាត់ទន្លេចៅផ្រះយ៉ាខាងលើ មិនបានសម្រេចជោគជ័យ។

ការដណ្ដើមយកបានដែនដីថ្មីៗ បានតម្រូវឱ្យមានការកសាងមូលដ្ឋានសង្គម-សេដ្ឋកិច្ចជាបន្ទាន់។ ប្រសិនបើនៅពេលនោះ ជាមួយប្រទេសចម្ប៉ា មានការរៀបចំអាណាព្យាបាលខ្មែរ នោះនៅលើទឹកដីមន ទាំងឡាយ មានការបង្រួបបង្រួមរដ្ឋជាចក្រភព។ ម្លោះហើយ នៅទីនោះមានតែងតាំងរដ្ឋការរបស់មន្ត្រីខ្មែរ មានការកសាងបន្ទាយ និងវត្តអារាម (បានសេចក្ដីថាមានតាំងរបបកាន់កាប់ដីសក្តិភូមិជាមួយនឹងចក្រភព)។ គោលបំណងគាំទ្រដែនដីទាំងនេះ ឱ្យស្ថិតនៅក្នុងសមាសភាពនៃចក្រភព បានតម្រូវឱ្យមានការបន្ធូរបន្ថយដ៏ទូលំទូលាយ នូវអនាគតដល់ជំនឿខាងសាសនា។ ជាមួយនឹងសាសនា (ជាពិសេសព្រហ្មញ្ញសាសនា) ជឿដោយអ្នកស្រុកនៃចក្រភពកម្ពុជទេសមានជំនឿខាងពុទ្ធសាសនាហីនយាន ជឿដោយប្រជាជនមន (ជាពុទ្ធសាសនាមានលក្ខណៈខុសគ្នា ពីពុទ្ធសាសនាមហាយានជឿដោយជនជាតិខ្មែរ នាសម័យនោះ)។ អក្សរ អក្សរសាស្ត្រសិល្បៈសំណង់ សិល្បៈចម្លាក់រចនាខ្មែរ បានផ្ដល់ឥទ្ធិពលហើយផ្សព្វផ្សាយដល់ប្រជាជនមន។ នៅសម័យដំបូង ការបង្រួបបង្រួមយកបានភូមិភាគនានា ប្រកបដោយដែនដីសម្បូរដីស្រែចម្ការ បានចម្រុងចម្រើនដល់ស្ថានភាពខាងសេដ្ឋកិច្ចនៃចក្រភព។

នៅលើដែនដីទាំងនេះ មានតែងតាំងប្រព័ន្ធពន្ធដារ ហើយមិនតែប៉ុណ្ណោះ មធ្យោបាយខាងសម្ភារៈទាំងនេះត្រូវបានប្រើប្រាស់សម្រាប់ការកសាងប្រព័ន្ធបង្ហូរទឹកថ្មីៗនៅលើទឹកដីខ្មែរ។ នៅពេលតមក ការរីកចម្រើនខាងសេដ្ឋកិច្ចនៅលើដែនដីមន ប្រហែលជាបានចុះអន់ថយ។ នេះជាសភាពការណ៍ ដែលមានដំណើរការធម្មតា ដោយហេតុថា ចំណូលនៃភោគផលមួយភាគបានចូលមកចម្រុងចម្រើនស្ថានភាពសេដ្ឋកិច្ចប្រទេស ដោយគ្មានការវិលត្រឡប់ទៅវិញ។

នៅសតវត្សរ៍ក្រោយមក ការចំណាយទាំងឡាយសម្រាប់ការទ្រទ្រង់ដែនដីក្រៅឱ្យស្ថិតនៅដដែល ឃើញថា គ្មានការទូទាត់ដោយចំណូលត្រឡប់មកវិញ។ បូកបញ្ចូលទាំងមូលហេតុផ្ទៃក្នុងនានា ដែលបានទាមទារឱ្យមានការកៀបសង្កត់ដែនដីក្រៅ សភាពការណ៍ទាំងអស់នេះ បានបណ្ដាលឱ្យកើតមានវិបត្តិនៅក្នុងចក្រភព។ ក៏ប៉ុន្តែនៅសតវត្សរ៍ទី១១ ការពង្រីកដែនដីចក្រភពបានជម្រុញឱ្យមានសន្ទុះខាងសេដ្ឋកិច្ច ហើយនៅក្នុងរជ្ជកាលរបស់ព្រះបាទសុរ្យវរ្ម័នទី១ មានការបញ្ជាក់ឱ្យឃើញច្បាស់នូវការប្រើប្រាស់មធ្យោបាយខាងសម្ភារៈ ដើម្បីត្រួសត្រាយតំបន់ខាងបស្ចិមនៃចក្រភព ដែលនឹងមានអនាគត ព្រមទាំងភូមិភាគដាច់ស្រយាលនៃចក្រភព។ ការងារខាងស្ថាបនកម្មទីក្រុងប្រកបដោយវត្តអារាមនានា នៅតាមទីវាលទំនាបនៃទន្លេមូន និងនៅតាមតំបន់នានាដែលស្ថិតនៅជិតទន្លេនេះ ត្រូវបានបំពេញជាលំដាប់លំដោយ។ ជាពិសេស គឺតាមរយៈបណ្ដាជនខ្មែរ ដែលរស់នៅក្នុងតំបន់កសិកម្មនៃទន្លេនេះ ដែលរដ្ឋាភិបាលចក្រភពកម្ពុជទេស បានរៀបចំទំនាក់ទំនងរបស់ខ្លួននឹងដែនដីមន។ ដងភ្នំកូរ៉ាត ទីវាល

ទំនាបនៃទន្លេមូន ត្រូវបានប្រើប្រាស់ជាមូលដ្ឋានសម្រាប់រៀបចំការទាក់ទងនឹងតំបន់ទាំងនេះ ដោយព្រះបាទសុរ្យវរ្ម័ន នៅសម័យសង្គ្រាម និងវដ្ដមន នានា ហើយទឹកដីទាំងនេះត្រូវបានរក្សាទុកនៅរហូតពេលអនាគត។ គឺពីទីកន្លែងទាំងនេះហើយ ដែលកងទ័ពព្រះបាទសុរ្យវរ្ម័ន បានធ្វើចលនាឡើងតាមដងទន្លេមេកុង រហូតដល់ទីវាលទំនាបនៃទន្លេអ៊ូ (នៅក្នុងតំបន់ហ្លួងប្របាងសព្វថ្ងៃ)។

នៅសម័យនោះ មានការកសាងប្រាសាទវត្ត-ភូ ប្រាសាទព្រះវិហារ ដែលស្ថិតនៅតាមព្រំប្រទល់ខាងបស្ចិមនៃទឹកដីខ្មែរ។ ក៏ប៉ុន្តែមធ្យោបាយខាងសម្ភារៈដ៏សំខាន់ៗ ត្រូវបានប្រើប្រាស់ដើម្បីពង្រីកសេដ្ឋកិច្ចនៃភូមិភាគកណ្ដាល ដែលនៅទីនេះមានរដ្ឋធានី។ គេបានកសាងល្អាងទឹកបម្រុងដ៏ធំមហិមាទីពីរ (គឺបារាយណ៍ខាងលិច) ប្រព័ន្ធត្រពាំង និងស្រះ សម្រាប់រក្សាទឹកប្រឡាយទឹក និងព្រែកជីកនានានៅជុំវិញរដ្ឋធានី - មែនពិត គឺជាប្រព័ន្ធបង្ហូរទឹកដ៏ស្មុគស្មាញបំផុតមួយ នៅក្នុងពិភពលោក។ ប្រព័ន្ធបង្ហូរទឹកដ៏ធំសម្បើមៗបែបនេះ បានបង្កើនប្រសិទ្ធភាពដ៏ស័ក្តិសិទ្ធដល់របរកសិកម្ម ទោះបីកិច្ចការសំណង់តម្រូវឱ្យមានការប្រើប្រាស់មធ្យោបាយខាងសម្ភារៈយ៉ាងសម្បើម ក៏ដោយ។ បញ្ហាទឹកសម្រាប់របរកសិកម្មលើដីស្រែចម្ការ ត្រូវបានដោះស្រាយសម្រាប់ពេលវេលាដ៏យូរយារ ហើយរហូតមកដល់សតវត្សរ៍ទី១៧ ប្រព័ន្ធបង្ហូរទឹកនៅទីក្រុង បានបន្តបំពេញសកម្មភាពរបស់ខ្លួន។ ទំហំនៃស្ថាបនកម្មបានបង្ហាញឱ្យឃើញនូវទំហំ នៃការចំណាយខាងសម្ភារៈ ដែលត្រូវបានប្រមែប្រមូលមកពីតំបន់នានានៃចក្រភព។

ការឃោសនាដើម្បីមនោគមវិជ្ជា នៃពិធីសក្ការៈបូជា ក៏ទាមទារឱ្យមានការចំណាយសម្ភារៈយ៉ាងសំខាន់ដែរ។ ការ

ចំណាយត្រូវបានបង្កើនដើម្បីសង់រាជដំណាក់នានា និងកសាងស្ថាបនកម្មផ្សេងៗ (មានទីលានធំៗនៅមុខប្រាសាទ កំពែងនានា) ព្រមទាំងមានការកសាងទីក្រុងឡើងវិញ។ នៅក្នុងវិស័យស្ថាបនកម្មសម្រាប់ការផ្សាយសាសនា ព្រះបាទសុរ្យវរ្ម័នទី១ បានកម្រិតការកសាងបង្កើយប្រាសាទផ្សេងៗ មានប្រាសាទតាកែវ និងប្រាសាទភិមានអាកាស ជាដើម។ រជ្ជកាលព្រះបាទសុរ្យវរ្ម័នទី១ គឺជាសម័យកាលនៃដំណើរឈានឡើងទៅកាន់សម័យកាលដ៏រុងរឿងខាងនយោបាយនៃចក្រភពកម្ពុជទេស។

រជ្ជកាលនៃរាជវង្សានុវង្ស ដែលបានសោយរាជសម្បត្តិបន្តមក បានប្រព្រឹត្តនៅក្នុងការពង្រឹងនៃសមិទ្ធិជ័យដែលទទួលបានមកពីពេលមុន។ ព្រះរាជបុត្ររបស់ព្រះបាទសុរ្យវរ្ម័នទី១ នាមព្រះបាទឧទ័យទិត្យាវរ្ម័នទី២ (គ.ស. ១០៥០-គ.ស. ១០៦៧) ខុសពីព្រះវររាជបិតា បានពឹងផ្អែកលើវណ្ណៈអភិជន ដែលកាន់សាសនាព្រះឥសូរ។ ព្រះអង្គបានប្រើប្រាស់មធ្យោបាយខាងសម្ភារៈដ៏សំខាន់ដើម្បីកសាងមហាប្រាសាទមួយ ឈ្មោះប្រាសាទបាពួន ដែលជាប្រាសាទដ៏ល្បីល្បាញធើតឆាយមួយនៅក្នុងស្នាដៃខាងសិល្បៈចម្លាក់រចនាខ្មែរ។ គឺជាប្រាសាទកសាងឡើងដើម្បីឧទ្ទិសដល់សាសនាព្រះឥសូរ។ នយោបាយនេះបានបណ្ដាលឱ្យមានចលនាកុបកម្មដោយអាវុធប្រឆាំងនឹងរដ្ឋអំណាច នៃព្រះអង្គ។ នៅភូមិភាគខាងត្បូងនៃប្រទេស កុបកម្មបែបនេះបានកើតមានឡើងក្រោមកិច្ចដឹកនាំរបស់មគ្គុទេសក៍មួយរូប នាមអរវិន្ទ្រធរជៈ (ប្រហែលជាអ្នកកាន់ពុទ្ធសាសនាមួយរូប)។ បន្ទាប់ពីចលនាកុបកម្មបានទទួលបរាជ័យ អរវិន្ទ្រធរជៈ បានភៀសខ្លួនទៅរស់នៅប្រទេសចម្ប៉ា ដែលនៅពេលនោះមានទំនាក់ទំនងដ៏តានតឹង

នឹងចក្រភពកម្ពុជទេស។ នយោបាយក្រៅប្រទេសដឹកនាំដោយព្រះបាទឧទ័យទិត្យាវរ្ម័ន ក៏មានសភាពការណ៍មិនដូចគ្នានឹងនយោបាយរបស់ព្រះបាទសុរ្យវរ្ម័នទី១។ ក្នុងរជ្ជកាលព្រះបាទឧទ័យទិត្យាវរ្ម័ន ចម្បាំងបានកើតមានឡើងរវាងចក្រភពកម្ពុជទេសនឹងរដ្ឋមននានានៅទិសខាងលិច ដូចជា រដ្ឋហង្សវតី និងរដ្ឋថតៈណូម ហើយភាពទន់ខ្សោយបណ្តាលមកពីចម្បាំងទាំងនេះមិនបានបម្រើដល់ផលប្រយោជន៍ របស់ព្រះមហារាជខ្មែរទេ ប៉ុន្តែបែរជាបម្រើផលប្រយោជន៍របស់ព្រះមហារាជប្រទេសភូមាទៅវិញ។

ការធ្វើអំណោយដីដល់វណ្ណៈអភិជន ប្រកាន់តាមសីវៈនិយម សាសនាព្រះឥសូរ ដែលបានចាប់ផ្តើមមានឡើងកាន់តែសកម្ម ការពង្រឹងស្ថានភាពរបស់វណ្ណៈនេះក្នុងឋានៈជាមន្ត្រីព្រាហ្មណ៍បរោហិតនៅបរមរាជវាំង ទាំងអស់នេះ ប្រហែលជាបានបង្កើតជាមូលហេតុនៃវិបត្តិរវាងមហារាជ និងបណ្តាមេបញ្ជាការកងទ័ពធំៗ ដែលបានចូលរួមក្នុងចម្បាំងនានានៅអតីតកាលដឹកនាំដោយព្រះបាទសុរ្យវរ្ម័នទី១។ នៅភាគកណ្តាលនៃចក្រភព ចលនាកុបកម្មធំមួយបានផ្ទុះឡើងក្រោមកិច្ចដឹកនាំរបស់មេបញ្ជាការកងទ័ពដ៏សំខាន់មួយរូប នាមមេបញ្ជាការ កំវៅ (គ.ស.១០៦៥)។បន្ទាប់ពីបានបង្ក្រាបចលនាកុបកម្មនេះ ចលនាកុបកម្មមួយទៀតបានកើតមានឡើង នៅភូមិភាគខាងកើត ក្រោមកិច្ចដឹកនាំរបស់មេបញ្ជាការកងទ័ពដ៏សំខាន់មួយរូបទៀត នាមមេបញ្ជាការ ស្លូត។នៅពេលជាមួយគ្នានោះ ចលនាកុបកម្មកសិករក៏បានកើតមានឡើង ហើយបានបង្កើតឱ្យមានការគំរាមកំហែងដល់ទ្រព្យសម្បត្តិដីធ្លីរបស់ពួកក្តុម្ពី និងវត្តអារាមទាំងឡាយ។ អគ្គមេបញ្ជាការកងទ័ពព្រះមហារាជ នាម សង្គ្រាមកំណត់ខ្មៅ

បានដើរបង្ក្រាបចលនាកុបកម្មទាំងនេះ។ ក៏ប៉ុន្តែ សភាពការណ៍ទាំងអស់នេះ មិនមែនជាការចៃដន្យទេ ដោយហេតុថា នៅ គ.ស. ១០៦៧ រដ្ឋអំណាចនៃចក្រភពកម្ពុជទេស ត្រូវបានធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់ព្រះមហារាជមួយរូបទៀត គឺព្រះបាទហស៍វរ្ម័នទី៣ (គ.ស.១០៦៧ - គ.ស.១០៨០) ប្អូនរបស់ព្រះបាទឧទ័យ-ទិត្យាវរ្ម័នទី២។ ព្រះមហារាជថ្មីបានបញ្ឈប់យុទ្ធនាការតទៅទៀតទៅទិសខាងលិច ក៏ប៉ុន្តែ បានបន្តការពង្រឹងស្ថានភាពរបស់វណ្ណៈអភិជនសិវៈនិយមតទៅមុខទៀត។ នៅក្នុងរជ្ជកាលព្រះបាទហស៍វរ្ម័នទី៣ សង្គ្រាមបានកើតមានឡើងនៅទិសខាងកើតនៃចក្រភព។ ទំនាក់ទំនងដ៏តានតឹងជាមួយប្រទេសចម្ប៉ា បានបន្ទាញឱ្យមានការប្រយុទ្ធគ្នាយ៉ាងចំហនៅសម័យទសវត្សរ៍ទី៧។ តាមឯកសារចាម ការវាយលុករបស់ទ័ពខ្មែរត្រូវបានបញ្ឈប់ ហើយបានទទួលការខូចខាតជាច្រើន។ នៅឆ្នាំ១០៧៤ កងទ័ពចាមបានវាយលុកចូលដល់មាត់ទន្លេមេកុង បានវាយចូល ហើយបានបំផ្លិចបំផ្លាញទីក្រុងសម្ពបូរៈ (សម្បូរ សព្វថ្ងៃ) ហើយបានចាប់ជនជាតិខ្មែរយកទៅជាឈ្លើយយ៉ាងច្រើន។ នៅឆ្នាំ១០៨០ សង្គ្រាមថ្មីបានផ្ទុះឡើងរវាងប្រទេសចម្ប៉ា ហើយនៅក្នុងការប្រយុទ្ធដ៏ធំនៅជិតទីក្រុងសុមេស្វរៈ កងទ័ពខ្មែរត្រូវបានទទួលការខូចខាត ហើយមេបញ្ជាការត្រូវបានចាប់ជាឈ្លើយសង្គ្រាម។

បរាជ័យរបស់កងទ័ពនៅក្នុងសមរភូមិនេះ បានបណ្ដាលឱ្យមានវិបត្តិ និងប្រតិកម្មនានានៅភូមិភាគកណ្ដាល និងភូមិភាគដាច់ស្រយាលនៃចក្រភព ហើយវិបត្តិកាន់តែមានសភាពតានតឹងនៅពេលបន្ទាប់ពីការសោយទិវង្គតរបស់ព្រះបាទសុរ្យវរ្ម័នទី១។ បន្ទាប់ពីបរាជ័យកងទ័ពខ្មែរនៅជិតទីក្រុងសុមេស្វរៈ បណ្ដាក្សត្រ

គ្រប់គ្រងរដ្ឋនានានៅតាមទីវាលទំនាបនៃទន្លេមូន បានប្រកាសឯករាជភាពរបស់ខ្លួន ពីព្រះបាទហស៍វរ្ម័នទី៣។ ក្សត្រទាំងនេះបានចាប់ផ្តើមបង្កើតរាជវង្សានុវង្សថ្មីរបស់ខ្លួននៅរដ្ឋធានីមហិធរបុរៈដែលស្ថិតនៅភូមិភាគខាងលើនៃទន្លេមូន គឺនៅជិតភូមិភាគមនទាំងឡាយ ដែលត្រូវដណ្តើមបានថ្មីៗ ហើយដែលបានសំដែងការគាំទ្រដល់ក្សត្រទាំងនោះ។ ក្សត្រទាំងនោះមិនបានទាំងសាកល្បងប្រកាសខ្លួនថា ជាអ្នកបន្តរាជវង្សានុវង្សចាស់ទេ ហើយគ្រាន់តែបានជ្រើសរើស ហើយប្រកាសនូវព្រះមហារាជរបស់ខ្លួន គឺព្រះបាទជ័យវរ្ម័នទី៦ (គ.ស.១០៨២ -១១០៧)។ នៅពេលជាមួយគ្នា នៅភូមិភាគកណ្តាលនៃចក្រភព ព្រះបាទហស៍វរ្ម័នទី៣ បាននៅគ្រងរាជសម្បត្តិបន្តរហូតដល់ គ.ស.១០៨៩។ រួចបន្ទាប់ពីព្រះអង្គ គឺព្រះបាទនរបតិន្ទ្រវរ្ម័នទី១ (បន្ទាប់ពី គ.ស. ១០៨៩-គ.ស. ១១១២)។

រាជវង្សានុវង្សនៃមហិធរបុរៈ បានអនុវត្តតាមមនោគមន៍នៃពិធីសក្ការៈបូជាទេវ-រាជា។ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៦ អ្នកប្រារព្ធពិធីនេះ គឺព្រះរាជគ្រូជាព្រាហ្មណ៍បរោហិតទិវាករៈបណ្ឌិត ដែលបានបង្កើតទ្រឹស្តីខាងមនោគមន៍របស់ខ្លួនដោយយោងទៅតាមជំនឿខាងសាសនា របស់ព្រះបាទសុរ្យវរ្ម័នទី១ ហើយដែលត្រូវបានអនុវត្តនៅសតវត្សរ៍ទី១២។ ទ្រឹស្តីនេះបានប៉ុនប៉ងសម្រេចនូវសំយោគនិយម ខាងសាសនាដោយការគោរពស្មើគ្នាដល់ព្រះឥសូរ និងព្រះពុទ្ធ។ ទ្រឹស្តីនេះត្រូវបានបង្កើតឡើងនៅលើមូលដ្ឋាន នៃនិន្នាការទូទៅខាងសង្គមកិច្ចនៅក្នុងសង្គមខ្មែរ ដោយហេតុថា មជ្ឈដ្ឋាននានា ដែលបានផ្តល់កិច្ច

គាំទ្រដល់រាជវង្សានុវង្សថ្មី គឺតំបន់ទាំងឡាយដែលមានប្រជាជនមន ជាអ្នកកាន់ពុទ្ធសាសនារស់នៅ។

វិបត្តិផ្ទៃក្នុង ប្រកបដោយយុទ្ធនាការដើម្បីដណ្តើមរដ្ឋអំណាចបានប្រព្រឹត្តទៅអស់ពេលដ៏យូរ រវាងភូមិភាគកណ្តាលនៃចក្រភព ដែលមានកម្លាំងមជ្ឈដ្ឋានដឹកនាំប្រពៃណី និងភូមិភាគដាច់ស្រយាល ដែលបានគាំទ្រដល់និន្នាការថ្មីៗ។ភូមិភាគកណ្តាលមិនអាចធ្វើចម្បាំងឈ្នះព្រះបាទជ័យវរ្ម័នទី៦ បាន ដោយហេតុថាព្រះអង្គបានទទួលការគាំទ្រដ៏សំខាន់ពីសំណាក់ប្រជារាស្ត្រមួយភាគធំនៃចក្រភព។ ចម្បាំងក្នុងស្រុកបានប្រព្រឹត្តទៅរហូតដល់ គ.ស. ១១០៧។ នៅក្នុងចម្បាំងនេះ បណ្តារាស្ត្រនៅតំបន់ខាងជើង និងខាងកើតទាំងឡាយបានគាំទ្រដល់ព្រះបាទជ័យវរ្ម័នទី៦ និងព្រះមហាក្សត្របន្តរាជវង្សានុវង្សរបស់ព្រះអង្គ ក៏ប៉ុន្តែ បណ្តារាស្ត្រនៅតំបន់ជិតរដ្ឋធានីយសោធរបុរៈ និងនៅជិតដែនដីភាគខាងត្បូង និងខាងលិចបឹងទន្លេសាប បានស្ថិតនៅស្មោះស្ម័គ្រនឹងព្រះរាជវង្សានុវង្សចាស់។

មហាក្សត្របន្តរាជសម្បត្តិពីព្រះបាទជ័យវរ្ម័នទី៦ គឺព្រះបាទធរណិន្ទ្រាវរ្ម័នទី១ (គ.ស.១១០៧-គ.ស.១១១២) ដែលជាមហាក្សត្រកាន់ពុទ្ធសាសនាមួយរូប។ នៅក្នុងរជ្ជកាលរបស់ព្រះអង្គ ទឹកដីរបស់រាជវង្សានុវង្សនៃមហិធរបុរៈ ត្រូវបានពង្រីកមកទិសបូព៌ានៃរដ្ឋធានីរបស់ចក្រភព។ ព្រះអង្គបានបង្គាប់ឱ្យកសាងប្រសាទមួយ ឈ្មោះប្រាសាទបឹងមាលា ដើម្បីឧទ្ទិសដល់សាសនាព្រះវិស្ណុ។ព្រះអង្គមានទំនាស់នឹងព្រាហ្មណ៍បរោហិតទិវាករៈបណ្ឌិត ហើយដោយសារល្បិចកលអាក្រក់របស់ទិវាករៈ

បណ្ឌិត ការប្រយុទ្ធមួយបានកើតមានឡើង ដែលជាហេតុបណ្តាល ឱ្យព្រះបាទធរណិន្ទ្រាវរ្ម័នទី១ ទទួលទិវង្គតក្នុងសមរភូមិ។

នៅសតវត្សរ៍ទី១២ ចក្រភពកម្ពុជទេស បានស្ថិតនៅក្នុង សម័យកាលមួយ ប្រកបដោយសភាពការណ៍បត់បែនបំផុតនៅ ក្នុងទំនាក់ទំនងខាងសង្គម-សេដ្ឋកិច្ច។ ឯកសារផ្សេងៗនាសម័យ នោះ បានបរិយាយអំពីការផ្លាស់ប្តូរជាមូលដ្ឋាននៅក្នុងវិស័យ កសិកម្ម នៅក្នុងទម្រង់នៃសង្គម និងនៅក្នុងនយោបាយខាង សង្គមកិច្ចរបស់របបគ្រប់គ្រងសក្តិភូមិ។

វណ្ណៈទាសាទាសីក្ញុំ ដែលប្រកបរបរកសិកម្មលើដីស្រែ ចម្ការបានវិវត្តទៅជាវណ្ណៈ " អ្នកងារ "។ ការធ្វើអំណោយ អ្នកងារដោយគ្មានធ្វើអំណោយ ទាំងដីដែលពួកនេះរស់នៅត្រូវ បានបញ្ឈប់។ ការធ្វើអំណោយដីបានទៅជាសភាពការណ៍ដ៏កម្រ ក៏ប៉ុន្តែ ការធ្វើអំណោយបានប្រព្រឹត្តទៅទាំងអំណោយដីភូមិ ព្រម ទាំងពួកក្ញុំ ដោយមានកំណត់ទាំងទំហំនៃផលដីទៀតផង។ នៅ សតវត្សរ៍ទី១២ នៅចក្រភពកម្ពុជទេស ក៏ដូចជានៅប្រទេសជិត ខាងផ្សេងៗ មានការបង្កើតប្រព័ន្ធយកពន្ធដារ ដែលយោងទៅ តាមចំនួនមនុស្សនៅលើដី ក៏ប៉ុន្តែ មិនមែនតាមទំហំដីទេ។ នៅ សតវត្សរ៍ក្រោយមក ដោយសារការអនុវត្តនូវប្រព័ន្ធយកពន្ធដារ បែបនេះ បណ្តាកសិករអាចមានសិទ្ធិចាកចេញពីទីដីមួយទៅកាន់ ដីថ្មីៗដទៃទៀត។ តាមការសន្និដ្ឋាន ស្ថានភាពបែបនេះបាន កើតមានឡើងច្បាស់លាស់នៅសតវត្សរ៍ទី១២ បន្ទាប់ពីសម័យ កាលនៃការត្រួសត្រាយដែនដីធំៗជាមូលដ្ឋាននៅលើទឹកដីខ្មែរ សុទ្ធសាធ។

ការរំសាយរបបគ្រប់គ្រងរបស់ភូមិសហគមន៍ នៃបណ្ដាអ្នកស្រុកស្រែបានបន្ទាញ ឱ្យមានការបង្កើតនូវប្រព័ន្ធរដ្ឋនៅក្នុងរបៀបកៀបសង្កត់ដល់វណ្ណៈកសិករ ដោយមិនបានទាមទារឱ្យមានការទាក់ទងជាអចិន្ត្រៃយ៍ ជាមួយពួកអភិជនសក្តិភូមិច្បាស់លាស់ណាមួយ ឬជាមួយអ្នកម្ចាស់ដីណាមួយច្បាស់លាស់។ នៅពេលជាមួយគ្នានោះ តាមឯកសារសិលាចារឹកខ្លះ បណ្ដាពួកជនប្រកបដោយឋានន្តរនាម " វាប " " តេង " និង " លោញ " បានផ្លាស់ប្ដូរនូវស្ថានភាពសង្គមរបស់ខ្លួន ហើយបានធ្លាក់មកជិតស្ថានភាពនៃពួកជនដែលប្រកបដោយអនិស្សរភាព ដូចបណ្ដាស្រទាប់វណ្ណៈតូចទាបដទៃទៀត (ពួកក្ញុំជាដើម) ដោយហេតុថានៅក្នុងកាលៈទេសៈដ៏កម្រខ្លះ ពួកជនទាំងនេះបានទៅជាកម្មវត្ថុនៃការធ្វើអំណោយជាមួយនឹងអំណោយដី (របៀបដូចគ្នានឹងការធ្វើអំណោយបណ្ដាពួកក្ញុំនៅសតវត្សរ៍ទី១២)។ហេតុដូច្នេះហើយ បានជាស្រទាប់វណ្ណៈតែមួយថ្មីនៅក្នុងរដ្ឋបានកកើតឡើង គឺវណ្ណៈកសិករ ជាពិសេសមានវណ្ណៈកសិករជាអ្នកងារ។

គោរមនាម និងឋានន្តរនាមនានា ដែលជាសញ្ញាបញ្ជាក់នូវដំហាររបស់បុគ្គលមួយរូបៗ នៅក្នុងស្រទាប់នីមួយៗ នៅក្នុងសង្គមបានចុះអន់ថយ ហើយបុគ្គលបានប្រែទៅជាកម្មវត្ថុទាក់ទងនឹងការចែករំលែកដីឱ្យតាមតំណែងនៃការបម្រើរាជការ។ គឺតំណែងនេះហើយ ដែលជាលក្ខខណ្ឌដ៏សំខាន់ក្នុងការទទួលកម្មសិទ្ធិជាម្ចាស់ដី។ តាមបែបនេះ វណ្ណៈនៃពួកសក្តិភូមិមួយចំនួនធំបានប្រែត្រឡប់ទៅជាអ្នកកាន់តំណែងរាជការ ដូចជាមន្ត្រី និងនាហ្មឺន។

នយោបាយពង្រឹងទំនាក់ទំនងខាងសង្គមកិច្ច អនុវត្តដោយរដ្ឋអំណាចបានបង្កើតជាផលវិបាក ដែលបានលេចជារូបរាងនៅ

ក្នុងការពន្យឺតសង្វាក់នៃការផ្ដល់សិទ្ធិកាន់កាប់ដីដល់វត្តអារាម។ អំណោយដីដោយគ្មានអំណោយទាសាទាសី មានស្ថានភាពស្ថិតនៅដូចជាកម្រិតនៃអំណោយនៅសតវត្សរ៍ទី១១ ចំនួនដីដែលជាកម្មវត្ថុនៃការលក់ដូរបានចុះថយជាខ្លាំង។  នៅពេលជាមួយគ្នាតម្លៃដីលក់ត្រូវបានកំណត់ មិនមែនតាមទំហំទេ ប៉ុន្តែតាមផលដំណាំដី បានសេចក្ដីថា តាមចំនួនស្រូវដែលកសិករធ្វើបរលើដីនោះ ត្រូវបង់ឱ្យក្ដុម្ពីជាម្ចាស់ដី។ បើនិយាយម្យ៉ាងទៀត គឺថា ចាប់តាំងពីសតវត្សរ៍ទី១២ទៅ វណ្ណៈកសិករ និងដីស្រែចម្ការបានទៅជាសត្យានុភាពជាក់ស្ដែងនៅក្នុងរបរកសិកម្មនៃចក្រភព។ អំពើជ្រៀតជ្រែកទាំងឡាយនៅក្នុងកិច្ចការរបស់កសិករ ត្រូវបានបន្ធូរបន្ថយ ហើយពួកអ្នកកៀបសង្កត់យកចិត្តទុកដាក់តែទៅលើទំហំនៃពន្ធដារ និងចំណូល ដែលត្រូវទាមទារយក។

សង្គមខ្មែរ បានឈានឡើងទៅកាន់សម័យកាល នៃការលូតលាស់ទំនាក់ទំនងខាងសក្តិភូមិ ដែលបានប្រព្រឹត្តទៅអស់អំឡុងពេលពីរបីសតវត្សរ៍។ ដំណើរចម្លងទៅកាន់ដំណាក់កាលនៃទំនាក់ទំនងថ្មី ដែលបានផ្ដល់ឥទ្ធិពលដ៏ខ្លាំងក្លាទៅលើវិស័យនានានៃជីវភាពសង្គម មិនបានបន្ទាញឱ្យចក្រភពចុះអន់ថយទេ។ សតវត្សរ៍ទី១២ គឺជាសតវត្សរ៍នៃសម័យដ៏រុងរឿងជាបន្តបន្ទាប់របស់ចក្រភពកម្ពុជទេស។ ក៏ប៉ុន្តែ ជាការចាំបាច់ ត្រូវតែបញ្ជាក់បន្ថែមថា សតវត្សរ៍ទី១២ បានវិវត្តទៅនៅក្នុងវិស័យនៃស្ថានភាពដ៏ចម្រុងចម្រើនរបស់វណ្ណៈអភិជនសក្តិភូមិខ្លះៗ ដែលបានទទួលមរតកជាម្ចាស់ដីធំៗ ហើយដែលគេអាចហៅបានថាជា “ ត្រកូលសេដ្ឋីប្រកបដោយដី-ភូមិករ ”។ នៅក្នុងដីភូមិកររបស់អ្នកទាំងនេះមានសំណង់កំពែងការពារ ដែលមានទាំងសំណង់ប៉មខ្ពស់ៗ និង

ប្រទ្បាយទឹកធំៗនៅជុំវិញ។ ចំណែកឯភូមិសហគមន៍វិញ គឺជាបណ្តាអ្នកតំណាងភូមិទាំងនេះ មានជាអាទិ “បុរសប្រធាន” ភូមិ និងបណ្តាមនុស្សចាស់ទុំជា “គ្រាមព្រឹទ្ធាចារ្យ” ដែលគេតែងបានរំលឹកតាមសិលាចារឹកនៅក្នុងរឿងក្តីក្តាំ និងក្នុងអំណោយដីនាសតវត្សរ៍មុន នៅសតវត្សរ៍ទី១ គេលែងរំលឹកអំពីអ្នកទាំងនេះទៀត។ នៅសម័យនោះ នៅក្នុងរឿងក្តីក្តាំ និងចែករំលែកដី គេបានរំលឹកតែភ្នាក់ងាររាជការ “រង់វាង” ដែលកាន់កាប់កិច្ចការភូមិបាល។ នៅក្នុងលក្ខខណ្ឌនៃស្ថានភាពអន់ថយរបស់ភូមិសហគមន៍ និងដោយមានការយកចិត្តទុកដាក់តែដល់ទំហំ នៃចំណូលផលដីប៉ុណ្ណោះ ដោយមិនរវល់ដល់កិច្ចការកសិកម្មនៅលើដីកម្មសិទ្ធិលើដីធំៗរបស់វណ្ណៈអភិជនសក្តិភូមិ បានសម្រេចជារូបរាងឡើងដោយសារការឧបត្ថម្ភរបស់រដ្ឋ។

ស្ថានភាពសម្បត្តិដីរបស់វត្តអារាមបានផ្លាស់ប្តូរ ហើយទោះបីកម្រមានអំណោយដីដល់វត្តអារាមក្តី ក៏សម្បត្តិដីជាកេតនៈភ័ណ្ឌនៅតែមានទំហំធំធេងដដែល។ នៅសតវត្សរ៍ទី១២ មាននិន្នាការចំពោះការប្រមូលផ្តុំដីមកក្នុងកណ្តាប់ដៃ នៃអ្នកតំណាងជាអ្នកគ្រប់គ្រងវត្តអារាមធំៗ។ និន្នាការបែបនេះ បើតាមការសន្និដ្ឋានបានបង្កើតឱ្យមានទំនាក់ទំនងនឹងឃោបាយកសិកម្មរដ្ឋ ដែលបានផ្តល់ឥទ្ធិពលរបស់ខ្លួន ក្នុងកិច្ចការពង្រឹងមហិទ្ធិឫទ្ធិខាងសេដ្ឋកិច្ចរបស់ចក្រភព មិនតិចជាងការពង្រឹងសម្បត្តិដីរបស់ពួកអភិជនសក្តិភូមិជាអ្នកគ្រប់គ្រងវត្តអារាមទាំងឡាយ។

សភាពការណ៍ទាំងអស់នេះ បានទាមទារឱ្យមានការផ្លាស់ប្តូរវិធីនៃរបបជិះជាន់ទាក់ទងនឹងការវិវត្តនយោបាយ របស់ប្រទេស ឬក៏ទាមទារឱ្យមានការបង្កើនប្រសិទ្ធភាព នៃវិធីចាស់បុរាណទាំង

ឡាយ។ រជ្ជកាលរបស់ព្រះបាទសុរ្យវរ្ម័នទី១ (គ.ស.១១១៣ - គ.ស. ១១៥០) បានបញ្ជាក់ឱ្យឃើញនូវការបំពេញសកម្មភាពដ៏មធ្យ័ត ចំពោះទិសដៅពីរយ៉ាង។ សកម្មភាពនេះបានផ្តល់ប្រសិទ្ធភាព ឥតជជែកបាន នៅក្នុងអំឡុងតែពីរបីទសវត្សរ៍ប៉ុណ្ណោះ ដោយ ហេតុថា ស្ថានភាពនយោបាយផ្ទៃក្នុងប្រទេស ត្រូវបានពង្រឹង យ៉ាងរឹងមាំ។ នៅក្នុងរជ្ជកាលនោះ ប្រតិបត្តិការសឹកបានប្រព្រឹត្ត ទៅដើម្បីដណ្តើមរជ្ជធានីយសោធរបូរៈ ដែនដីដាច់ដោច និងចុះ អន់ថយរបស់ក្សត្រានានានៃរាជវង្ស " ព្រះមហាក្សត្រភ្នំ " ត្រូវ បានបង្រួបបង្រួមចូលក្នុងចក្រភពយ៉ាងឆាប់រហ័ស ហើយនៅ គ.ស.១១១៣ ព្រាហ្មណ៍បរោហិតទិវាការៈបណ្ឌិត បានរៀបចំពិធី រាជាភិសេកព្រះបាទសុរ្យវរ្ម័នទី២ ជាព្រះមហារាជនៃចក្រភព កម្ពុជទេស ទាំងមូល។

ទឹកដីចក្រភពកម្ពុជទេសនៅសតវត្សរ៍ទី១២ មានជំជេង ដោយការបង្រួបបង្រួមបណ្តារដ្ឋសាមន្តរាជតូចតាច និងមធ្យម នានានៃឧបទ្វីបឥណ្ឌូចិន ហើយព្រំប្រទល់ចក្រភពបានលាតសន្ធឹង ដល់ប្រទេសជិតខាងដ៏ខ្លាំងៗ ដូចជាចក្រភពប៉ាហ្គន (ភូមា) នៅ ទិសខាងលិចនឹងប្រទេសដាយវៀត (វៀតណាម) នៅទិសខាង ឦសាន។ ប្រទេសទាំងនេះ ទើបបានឈានឡើងសម័យកាល នៃភាពរីកចម្រើនខាងសេដ្ឋកិច្ច និងការបង្កើនសកម្មភាពក្នុង នយោបាយអន្តរជាតិរបស់ខ្លួន។ នយោបាយរបស់ចក្រភពកម្ពុជ ទេស ទាក់ទងនឹងការបង្រួបបង្រួមទឹកដីថ្មីៗទៀតពុំសូវបានសម្រេច ផល។ ស្ថានភាពដូចគ្នាក៏បានកើតមានឡើងចំពោះទំនាក់ទំនង នឹងបណ្តាជនទាំងឡាយ ដែលរស់នៅតាមតំបន់ភ្នំនានា រវាងទីវាល

ទំនាបនៃទន្លេសាលូអង់ និងទន្លេចៅ-ប្រែន (ទន្លេមេណាម) ព្រម ទាំងនៅទីវាលទំនាបប៉ែកខាងជើងនៃទន្លេចៅ-ប្រែន ទៀតផង។

នៅដែនដីទាំងនេះ ទំនាក់ទំនងខាងវណ្ណៈសង្គមពុំទាន់ទាំង កើតមានផង ហើយការប្រមូលយកពន្ធអាករដ៏សំខាន់ៗ ក៏មិន អាចប្រព្រឹត្តទៅបាន។ នៅសម័យនោះ ព្រះមហារាជខ្មែរពុំដែល បានចាត់វិធានការអ្វី ដើម្បីធ្វើការវាយលុកចូលទៅក្នុងបណ្តារដ្ឋ ម៉ាឡាយូ នៅឧបទ្វីបម៉ាឡាកា និងនៅល័នកាស៊ូគូ ឡើយ។

នៅក្នុងរជ្ជកាលព្រះបាទសុរ្យវរ្ម័នទី២ មានការអនុវត្ត នយោបាយយុទ្ធនាការពង្រីកទឹកដី ក៏ប៉ុន្តែ ចក្រភពពុំបានកាន់កាប់ ដែនដីដែលមានសារៈសំខាន់ខាងសេដ្ឋកិច្ចឱ្យខ្ជាប់បានឡើយ។ ដោយពឹងផ្អែកលើភោគសម្បត្តិដ៏សម្បូររបស់ប្រទេស ព្រះបាទ សុរ្យវរ្ម័នទី២ បានចាប់ផ្តើមធ្វើចម្បាំងនានា ជាពិសេសនៅលើ ដែនដីដែលស្ថិតនៅទិសបូព៌ា។ កងទ័ពរបស់ព្រះអង្គបានធ្វើការ វាយលុកចូលប្រទេសចម្ប៉ា ដោយជោគជ័យ ក៏ប៉ុន្តែ ចម្បាំងនេះ មានលក្ខណៈស្វិតស្វាញ ហើយមានការបង់ខាតខាងសម្ភារៈជា ច្រើន រួចមិនតែប៉ុណ្ណោះ ការគ្រប់គ្រងប្រទេសចម្ប៉ា ឱ្យស្ថិតនៅ ក្រោមអាណាព្យាបាលនៃចក្រភពកម្ពុជទេស ក៏បានចោទជាបញ្ហា ដ៏លំបាក។ ចម្បាំងជាមួយប្រទេសដាយវៀត ក៏បានប្រព្រឹត្តទៅ ដោយមានជោគជ័យខ្លះៗ ក៏ប៉ុន្តែ ឥតបានទទួលជ័យជម្នះដ៏ធំ ណាមួយ ឬក៏ទទួលការកាន់កាប់ដែនដីថ្មីណាមួយឡើយ។

ចម្បាំងជាមួយរដ្ឋមន ហរិបុញ្ញជ័យ និងរដ្ឋសៀម តូចៗនានា ដែលទើបនឹងបានកកើតមានឡើង នៅតាមភូមិភាគខាងលើនៃ ទន្លេចៅ-ប្រែន បានប្រកបដោយជ័យជម្នះ។ រដ្ឋតូចៗទាំងនេះ បានទទួលការចុះចាញ់ ក៏ប៉ុន្តែ ក្នុងការកាន់កាប់ដែនដីទាំងនេះ

ចក្រភពពុំបានចំណោញអ្វីខាងសម្ភារៈ ដូចកាលព្រះបាទសុរ្យវរ្ម័នទី១ វាយលុកយកបានដែនដីល្វោ ឡើយ ដោយហេតុថា ដែនដីដណ្តើមយកបានថ្មីៗនេះ ជាដែនដីក្រខ្សត់។ ភោគផលដ៏សំខាន់ៗ ក៏បានស្រូបទាញមកពីដែនដីមន ថ្មីៗ ក៏ប៉ុន្តែ នយោបាយស្រូបទាញភោគផលទាំងនេះ ត្រូវបានបញ្ឈប់ទៅវិញយ៉ាងឆាប់រហ័ស។ រីឯនយោបាយទាក់ទងនឹងជនជាតិសៀម វិញនោះ មានការកៀបសង្កត់តាមមធ្យោបាយពិសេស គឺកងកម្លាំងទ័ពសៀមទាំងឡាយ ត្រូវបានបញ្ចូលមកក្នុងអង្គភាពនៃកងទ័ពខ្មែរ។

នៅក្នុងរជ្ជកាលរបស់ព្រះបាទសុរ្យវរ្ម័នទី២ ដែនដីចក្រភពកម្ពុជទេសបានរីកធំសម្បើម ហើយគេអាចប្រៀបសភាពការណ៍បែបនេះនឹងចក្រភពចិន ក្រោមរាជវង្សានុវង្សស្តេច ស៊ុន។ គឺជាប្រទេសដែលចក្រភពកម្ពុជទេស មានទំនាក់ទំនងដ៏ល្អខាងមិត្តភាពនៅដើមសតវត្សរ៍ទី១២។ នៅសម័យនេះ ចក្រភពកម្ពុជទេស មានព្រំប្រទល់ខាងត្បូងរហូតដល់ជ្រោយសមុទ្រក្រា (នៅម៉ាឡាកា) ពីទិសខាងលិច ទៅទិសខាងកើត ព្រំប្រទល់ចក្រភពលាតសន្ធឹងចាប់ពីព្រំប្រទល់ប្រទេសប៉ាហ្គ័ន (ភូមា) រហូតដល់មាត់សមុទ្រដែនដីកូសាំងស៊ីន (គឺវៀតណាមខាងត្បូង សព្វថ្ងៃ)។ នៅក្នុងដែនដីនានាចក្រភពកម្ពុជទេស ក្រៅពីប្រជាជនខ្មែរ មានជនជាតិមន ចាម សៀម ម៉ាឡាយូ និងជនជាតិភាគតិចមួយចំនួនធំដែលរស់នៅតាមតំបន់ភ្នំ។ ដើម្បីពង្រឹងការត្រួតត្រាលើដែនដីទាំងនេះ ដែលមានការទាក់ទងមិនសូវរឹងមាំខាងវិស័យសេដ្ឋកិច្ច និងវប្បធម៌ មានការតម្រូវឱ្យមានការប្រើប្រាស់មធ្យោបាយខាងសម្ភារៈដ៏ច្រើនមហិមា។ ក៏ប៉ុន្តែ នៅសម័យនោះ តំបន់ដ៏រឹងមាំខាងសេដ្ឋកិច្ចនៃរដ្ឋធានីយសោធរបុរៈ (តំបន់អង្គរ សព្វថ្ងៃ) បាន

ផ្តល់ក្របខ័ណ្ឌអ្នកគ្រប់គ្រងដល់ដែនដីទាំងនោះ ចក្រភពកម្ពុជទេស បានទៅជាប្រទេសប្រកបដោយមហិទ្ធិឫទ្ធិ គ្មានប្រទេសណាច្បាំងឈ្នះ។ ចក្រភពកម្ពុជទេស ដ៏រឹងមាំខ្លាំងក្លា ស្ថាបនាឡើងដោយសារព្រះបាទសុរ្យវរ្ម័នទី២ បានស្ថិតនៅអស់អំឡុងមួយសតវត្សរ៍កន្លះ។ នយោបាយខាងសាសនារបស់ព្រះបាទសុរ្យវរ្ម័នទី២ ដែលបានយោងទៅតាមមនោគមន៍នៃពិធីសក្ការៈបូជាទេវ-រាជា បានអនុវត្តទៅលើមូលដ្ឋាននៃសហវិជ្ជមាននៃសាសនានានា គឺជានយោបាយដូចគ្នានឹងនយោបាយរបស់ព្រះបាទសុរ្យវរ្ម័នទី១។ ព្រះបាទសុរ្យវរ្ម័នទី២ ជាព្រះមហារាជកាន់សាសនាព្រះវិស្ណុ។ ស្ថានភាពបែបនេះបានសម្រួលដល់សំយោគបញ្ចូលគ្នារវាងប្រព័ន្ធសាសនានានា។ នៅក្នុងរជ្ជកាលព្រះបាទសុរ្យវរ្ម័នទី២ មានការសាកល្បងផ្សព្វផ្សាយមនោគមន៍ នៃពិធីសក្ការៈបូជាទេវ-រាជានៃវណ្ណៈអភិជន តាមមធ្យោបាយនៃការពង្រីកទំហំនៃស្ថាបនកម្មព្រះវិហារខាងសាសនា បានសេចក្តីថា មានការដោះស្រាយភារកិច្ចខាងសង្គមកិច្ចថ្មីៗដ៏ស្មុគស្មាញ តាមមធ្យោបាយចាស់ៗពីមុនមក។ ស្ថាបនកម្មព្រះវិហារខាងសាសនាតម្រូវតាមមនោគមន៍នៃព្រះពិធីសក្ការៈបូជាទេវ - រាជា មានលក្ខណៈគគ្រឹកគ្រេងឆើតឆាយ ហើយបណ្តាលឱ្យមានការចំណាយខាងសម្ភារៈដ៏ច្រើនសម្បើម។ កិច្ចពង្រឹងមនោគមន៍រដ្ឋអំណាចនៃព្រះមហារាជ បានតម្រូវឱ្យមានការធ្វើអំណោយដីភូមិថ្មីៗដល់គណៈសង្ឃតាមទំហំមិនសូវធំដុំ ក៏ប៉ុន្តែ បានបង្កើតស្ថានភាពថ្មីៗដ៏លំបាកធ្ងន់ធ្ងរនៅក្នុងបន្ទុករបស់ចក្រភព។ នៅសម័យនោះមធ្យោបាយដ៏សំខាន់ៗមិនត្រូវបានប្រើប្រាស់ដើម្បីពង្រឹងកម្មសិទ្ធិលើដីរបស់វណ្ណៈអភិជនសក្តិភូមិបព្វជិតទេ ក៏ប៉ុន្តែ ត្រូវបានប្រើ

ប្រាស់ក្នុងស្ថាបនកម្មព្រះវិហារ "របស់រដ្ឋ" មួយចំនួនតិច។ របស់ជានិមិត្តរូបច្បាស់លាស់នៃនយោបាយថ្មីនេះ គឺការប្រតិដ្ឋាននូវព្រះវិហារមួយដ៏ធំសម្បើម ដែលសព្វថ្ងៃគេបានស្គាល់ថាជាប្រាសាទអង្គរវត្ត។ នៅពេលជាមួយគ្នា មានការស្ថាបនាព្រះវិហារធំៗចំនួនពីរបីទៀត ក៏ប៉ុន្តែ ប្រាសាទអង្គរវត្ត គឺជាបុរាណប្រាសាទដ៏ល្បីល្បាញរុងរឿងជាងគេមួយ នៅក្នុងសិល្បៈស្ថាបនកម្មពិភពលោក។

មូលដ្ឋានជាទីពំនឹងរបស់ព្រះបាទសុរ្យវរ្ម័នទី២ គឺតំបន់ស្រែចម្ការនៅទិសខាងជើង គឺជាទីដីទំនាបតាមទន្លេមូន។ គឺជាតំបន់ដែលបានពឹងផ្អែកលើប្រព័ន្ធទឹកធំៗ ហើយដែលនៅទីនេះដីស្រែចម្ការ មិនទាន់បានចាប់ផ្តើមអស់ជីជាតិបន្តិចម្តងៗនៅឡើយ ហើយនៅពេលក្រោយៗមកភាពអស់ជីជាតិដីស្រែចម្ការ ជាហេតុបណ្តាលឱ្យសេដ្ឋកិច្ចតំបន់រដ្ឋធានីបានចុះឱនថយ។ ក៏ប៉ុន្តែ នៅសម័យកាលក្រោយៗមកទៀត និន្នាការថ្មីៗនៃការដាំដំណាំកសិកម្មបានពង្រឹងនូវស្ថិរភាពនៃតំបន់ទាំងនេះវិញ។

នៅគ.ស. ១១២៨, គ.ស. ១១២៩ , គ.ស. ១១៣២ (ជាមួយប្រទេសចម្ប៉ា) និងនៅ គ.ស. ១១៣៦ កងទ័ពរបស់ចក្រភពកម្ពុជទេស បានធ្វើការវាយលុកចូលទៅក្នុងបណ្តាខេត្តខាងត្បូងនៃប្រទេសដាយវៀត។ ក៏ប៉ុន្តែ ជារៀងរាល់ដង កងទ័ពខ្មែរត្រូវបានថយក្រោយវិញ ទោះបីកងទ័ពនេះបានទទួលជោគជ័យខ្លះៗក្តី។ នៅពេលនោះ ប្រទេសដាយវៀត បានទៅជាប្រទេសមួយខ្លាំងរួចមកហើយ។ នៅ គ.ស.១១៤៥ ព្រះបាទសុរ្យវរ្ម័នទី២ ធ្វើការវាយដណ្តើមយកបានភូមិភាគខាងជើង និងកណ្តាលនៃប្រទេសចម្ប៉ា ក៏ប៉ុន្តែ នៅភូមិភាគខាងត្បូង មហាក្សត្រចម្ប៉ា

ព្រះនាមជ័យហរិវ៉្ម័នទី១ បាននៅសោយរាជសម្បត្តិនៅទីនោះ។ ក្នុងការវាយលុកចូលប្រទេសចម្ប៉ា នាឆ្នាំ១១៤៧ កងទ័ពខ្មែរបាន ទទួលបរាជ័យនៅជិតទីក្រុងប៉ន័ឌូរ៉ាន់ហ្គា ហើយបរាជ័យដ៏ធ្ងន់ធ្ងរ មួយទៀត បានកើតមានឡើងនៅទីក្រុងវិរបូរៈ នៅគ.ស. ១១៤៨។ នៅឆ្នាំ១១៤៩ ស្តេចចាម ដែលបានឡើងសោយរាជ្យនៅភូមិ ភាគខាងជើង ដោយសារការឧបត្ថម្ភរបស់ព្រះមហារាជខ្មែរ ត្រូវ បានទទួលឃាតកម្មដោយមហាក្សត្រជ័យវ៉្ម័នទី១ ដែលវាយ ដណ្តើមយកបានរដ្ឋធានីចម្ប៉ា ឈ្មោះ វិជ័យ ។ នៅឆ្នាំ១១៥០ កងទ័ពខ្មែរ បានធ្វើយុទ្ធនាការចូលប្រទេសដាយវៀត ម្តងទៀត ក៏ប៉ុន្តែ មិនបានទទួលជ័យជម្នះអ្វីឡើយ។

ក៏ប៉ុន្តែ នៅក្នុងចម្បាំងវាយលុកទាំងនេះ ចក្រភពពុំបាន ប្រើប្រាស់កងកម្លាំងទ័ពរបស់ខ្លួនទាំងអស់ទេ។ ចម្បាំងទាំង នេះត្រូវបានធ្វើឡើង ដោយកងកម្លាំងទ័ពដាច់ដោយឡែកពីរបី ហើយយុទ្ធនាការទាំងឡាយមិនដែលប្រព្រឹត្តទៅ នៅលើទឹកដី ចក្រភពម្តងណាឡើយ។ នៅទសវត្សរ៍ទី៤ កងទ័ពខ្មែរនានា បានធ្វើចម្បាំងវាយលុកលើរដ្ឋមន ឈ្មោះហរិបុញ្ញជ័យ ហើយ បានឡោមព័ទ្ធរដ្ឋធានី ដែលនៅទីនោះមហាក្សត្រមន ព្រះនាម អាទិត្យរាជ្យ សោយរាជសម្បត្តិ។ ដែនដីនៃរដ្ឋនេះមួយភាគត្រូវ បានបង្រួបបង្រួមចូលមកក្នុងចក្រភពកម្ពុជទេស។ គឺនៅក្នុង ចម្បាំងទាំងនេះហើយ ដែលឥទ្ធិពលរបស់ចក្រភពត្រូវបាន ផ្សព្វផ្សាយ ហើយពង្រឹងទៅលើបណ្តារដ្ឋសៀមនានា ដែលស្ថិត នៅតំបន់ភ្នំ។

ព្រះបាទធរនិន្ទ្រវ៉្ម័នទី២ (ឆ្នាំ១១៥០-១១៦០) ជាពុទ្ធ បរិស័ទ បានឡើងសោយរាជសម្បត្តិបន្តពីព្រះបាទសុរ្យវ៉្ម័នទី២។

នៅក្នុងរជ្ជកាលរបស់ព្រះបាទធរនិន្ទ្រវរ្ម័នទី២ ពុទ្ធសាសនាបានបំពេញតួនាទីយ៉ាងសំខាន់ នៅក្នុងជីវភាពខាងសតិអារម្មណ៍របស់ប្រទេស ហើយចម្បាំងក៏ត្រូវបានធ្វើបន្តទៅទៀត ប្រឆាំងប្រទេសចម្ប៉ា។ ទោះបីម្តងនេះ ចម្បាំងមានសភាពស្វិតស្វាញលំបាកក្តី ក៏ការវាយលុកបានប្រកបដោយជោគជ័យ ហើយរដ្ឋធានីវិជ័យ (នៃប្រទេសចម្ប៉ា) ត្រូវបានឡោមព័ទ្ធដោយកងទ័ពខ្មែរ។ ខុសពីព្រះបាទសុរ្យវរ្ម័នទី១ ព្រះបាទធរនិន្ទ្រវរ្ម័នទី២ ដែលជាពុទ្ធបរិស័ទ ពុំបានស្ថាបនាព្រះវិហារនានាខាងព្រហ្មញ្ញសាសនាទៀតឡើយ ហើយមិនតែប៉ុណ្ណោះ ព្រះអង្គពុំបានធ្វើអំណោយដីដូចព្រះមហាពជមុនៗទៀត។ ព្រះបាទយសោវរ្ម័នទី២ (គ.ស. ១១៦០, គ.ស.១១៦៥) បានឡើងសោយរាជសម្បត្តិ បន្តពីព្រះអង្គ។

នៅភាគកណ្តាលនៃសតវត្សរ៍ទី១២ នៅក្នុងប្រទេស ចលនាកុបកម្មបះបោរប្រជាករបានកើតមានឡើងទូទៅ គឺជាផលវិបាកដែលបានកើតមានមកដោយស្ថានភាពក្រីក្រតោកយ៉ាក របស់ប្រជាកសិករជាម្ចាស់ដីមធ្យមមួយចំនួនធំ។ អ្នកទាំងនេះបានធ្លាក់ខ្លួនបន្តិចម្តងៗ ទៅជាអ្នកងារ។ ចលនាកុបកម្មនេះ បានចូលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រប្រទេស ដោយមានឈ្មោះថាជា " ចលនាកុបកម្ម ក្រោមកិច្ចដឹកនាំរបស់ រាហុ " (នៅក្នុងព្រហ្មញ្ញសាសនា រាហុ ជាអាទិទេពតំណាងសភាវៈអាក្រក់) គឺជាឈ្មោះហៅដោយពួកជននៅក្នុងវណ្ណៈសក្តិភូមិ។ ចលនាកុបកម្មត្រូវបានបង្ក្រាប ព្រះបាទយសោវរ្ម័ន ត្រូវបានរួចព្រះជន្មាយុ ដោយសារសេចក្តីអង់អាចរបស់មេទ័ពមួយរូប។ ក៏ប៉ុន្តែ នៅពេលក្រោយមកសកម្មភាពក្បត់នៅក្នុងព្រះបរមរាជវាំង បានកើតមានឡើងដែល

ជាហេតុបណ្ដាលឱ្យព្រះបាទយសោវរ្ម័នទី២ អស់ព្រះជន្មាយុនៅពេលនោះ។

អ្នកដឹកនាំសកម្មភាពក្បត់ គឺជាមន្រ្តីធំមួយរូបនៅព្រះបរមរាជវាំង ហើយមន្រ្តីនេះបានឡើងសោយរាជ្យ ដោយបានទទួលគោរមនាមថាជា ព្រះបាទត្រីភូវនទិត្យវរ្ម័ន (គ.ស. ១១៦៥ - គ.ស.១១៧៧)។ នៅសម័យនោះ វិបត្តិខាងសង្គមកិច្ចនៅលើទឹកដីខ្មែរផ្ទាល់ ដែលបានកើតឡើងដោយសារ “ចលនាកុបកម្មរាហូ ” បានបង្កើតឱ្យមានស្ថានភាពរំជើបរំជួលកាន់តែខ្លាំងនៅក្នុងចក្រភព។ ស្ថានភាពបានទៅជាធ្ងន់ធ្ងរ ដោយហេតុថា ព្រះមហារាជថ្មីពុំមានបំណងនឹងអនុវត្តការកែប្រែថ្មីៗ ខាងនយោបាយផ្ទៃក្នុង ហើយដោយហេតុថា ចម្បាំងជាមួយប្រទេសចម្ប៉ា ក៏មិនបានសម្រេចដោយជោគជ័យ។ ចម្បាំងបានប្រព្រឹត្តទៅដោយមានជ័យជម្នះ និងបរាជ័យ ក៏ប៉ុន្តែ ខុសពីជ័យជម្នះទទួលបានពីពេលដប់ឆ្នាំមុន កងទ័ពខ្មែរបានជួបប្រទះនឹងកងទ័ពចាម ដែលមិនសូវធំ ប៉ុន្តែ កាន់តែប៉ិនប្រសប់ច្បាំង កាន់តែមានកម្លាំងខ្លាំងឡើង។ មហាក្សត្រចាម ចាប់ផ្ដើមប្រើប្រាស់កងនាវាចរណ៍ដ៏ខ្លាំងក្លា ដែលប្រទេសចាម បានកសាងឡើងសម្រាប់វិស័យពាណិជ្ជកម្មនៃប្រទេស។ នៅឆ្នាំ១១៧៧ កងកម្លាំងនាវាចរណ៍ចម្ប៉ា បានមកដល់ភូមិភាគខាងកើតនៃចក្រភពនៅជិតទីសមរភូមិដ៏សំខាន់ ហើយកងនាវាចរនេះ ស្រាប់តែធ្វើដំណើរឡើងមកតាមទន្លេមេកុង ចូលក្នុងទន្លេសាប មកដល់ស្ទឹងសៀមរាប ហើយក៏បានឡើងមកធ្វើការឡោមព័ទ្ធរដ្ឋធានីយសោធរបុរៈ (អង្គរធំ)។ នៅពេលដែលកងកម្លាំងទ័ពខ្មែរ កំពុងធ្វើដំណើរមួយជួយរដ្ឋធានីកងទ័ពចាម បានចាប់ផ្ដើមវាយសម្រុកចូលក្នុងរដ្ឋធានី។ព្រះបាទ

ត្រីភូវនទិត្យវ្ម័ន បានបាត់បង់ជីវិតនៅក្នុងការប្រយុទ្ធនៅសមរភូមិ។ បន្ទាប់ពីការវាយលុកចូលរដ្ឋធានីយ៉ាងរហ័សបែបនេះ កងនាវាចរណ៍ចាម បានចាកចេញពីទឹកដីខ្មែរជាបន្ទាន់។

រាជសម្បត្តិក៏បានធ្លាក់មកក្នុងកណ្តាប់ដៃ នៃរាជបុត្ររបស់ព្រះបាទធរនិន្ទ្រវ្ម័នទី២ គឺព្រះបាទជ័យវ្ម័នទី៧ (គ.ស.១១៧៧-១១៨១- ជិត គ.ស. ១២២០)។ ព្រះបាទជ័យវ្ម័នទី៧ បានចាប់ផ្តើមពង្រឹង និងពង្រីកកងកម្លាំងនាវាចរណ៍របស់ចក្រភព។ ចម្បាំងជាមួយប្រទេសចម្ប៉ា បានប្រព្រឹត្តទៅអស់រយៈពេលបួនឆ្នាំមកហើយ។ នៅឆ្នាំ១១៨១ ការប្រយុទ្ធគ្នានៅតាមសមុទ្រ បានសម្រេចនូវជោគវាសនានៃចម្បាំងនេះ។ កងកម្លាំងនាវាចរណ៍ចាម បានទទួលបរាជ័យយ៉ាងទម្ងន់ ហើយមហាក្សត្រចាម បានក្សិណក្ស័យជន្មាយុនៅក្នុងសមរភូមិ។ នៅឆ្នាំដដែលនោះ ព្រះបាទជ័យវ្ម័នទី៧ បានទទួលរាជាភិសេកជាព្រះមហារាជនៃចក្រភពកម្ពុជទេស។ បន្ទាប់ពីបានបង្ក្រាបចលនាប្រឆាំង របស់ពួកសត្រូវផ្ទៃក្នុងប្រទេស នៅឆ្នាំ១១៨២ ព្រះអង្គស្ថិតនៅជាអធិរាជនៃចក្រភពដ៏ធំធេង អស់ពេលដ៏យូរ។

ព្រឹត្តិការណ៍នានា ដែលបានកើតមានឡើងនៅសម័យចុងសតវត្សរ៍ទី៧ បានបញ្ជាក់ឱ្យឃើញថា ដើម្បីរក្សាផ្គត់ផ្គង់ចក្រភព គឺត្រូវតែមានការកែប្រែទម្រង់នៃសង្គមជាដាច់ខាត។ ការផ្លាស់ប្តូរនៅក្នុងសេដ្ឋកិច្ចនៃដែនដីខ្មែរដ៏សំខាន់ៗ បានត្រួសត្រាយផ្លូវដើម្បីការកសាងឡើងវិញនូវទម្រង់នានាខាងសេដ្ឋកិច្ច។

នៅក្នុងវិស័យទំនាក់ទំនងខាងសេដ្ឋកិច្ច ការផ្លាស់ប្តូរទាំងនេះបានបន្ទាញឱ្យមានភាពចុះឱនថយ នៃការបន្តមរតកដីធំៗ របស់វណ្ណៈអភិជនបព្វជិត (ស្ថានភាពបែបនេះបានកើតមានឡើង

នៅប្រទេសទាំងអស់នៅអាស៊ីអាគ្នេយ៍ នាសតវត្សរ៍ទី១៣-១៥) និងការពង្រីកចំនួនពួកអភិជនសក្តិភូមិ ដែលស្ថិតនៅក្នុងអនិស្សរភាព ក៏ប៉ុន្តែ ពួកជនទាំងនេះមានសិទ្ធិក្នុងការដឹកនាំគ្រប់គ្រងរបរកសិកម្មរបស់ខ្លួន ដោយសារពលកម្មកសិករជាវណ្ណៈដែលបានលេចឡើង ដោយការបង្រួបបង្រួមបណ្តាទាសាទាសីក្ដី និងអ្នកស្រុកស្រែ គឺអនាគត "អ្នកជា"។ វណ្ណៈកសិករខ្មែរ បានបាត់បង់នូវរបៀបរៀបចំរបស់ខ្លួនជាសហគមន៍ ហើយបានស្ថិតនៅក្រោមកិច្ចត្រួតត្រារបស់រដ្ឋ និងក្រោមការកៀបសង្កត់ផ្ទាល់របស់អ្នកកាន់កាប់ដី - គឺពួកមន្ត្រីនាហ្មឺនសក្តិភូមិ។

ចម្បាំងជាមួយប្រទេសចម្ប៉ា នាឆ្នាំ១១៧៧-១១៨២ មិនបានទុកស្លាកស្នាមអ្វីធំដុំ នៅក្នុងជីវភាពរបស់ចក្រភពទេ។ចម្បាំងនេះមិនបានទាក់ទាញ ឱ្យមានការប្រើប្រាស់កម្លាំងទាំងអស់របស់ចក្រភពទេ ហើយការវាយលុករបស់កងទ័ពចាម ចូលមកក្នុងរដ្ឋធានីនៅពេលមុន គឺគ្រាន់តែជាព្រឹត្តិការណ៍ជាចៃដន្យមួយប៉ុណ្ណោះ។ រហូតដល់ឆ្នាំ១១៨៦ ទឹកដីរបស់ចក្រភពបានរីកធំទូលាយដល់តំបន់វៀងចន្ទ សព្វថ្ងៃ ក្នុងប្រទេសឡាវ។ អំឡុងពេលទាំងមូលនៃរជ្ជកាលរបស់ព្រះបាទជ័យវរ្ម័នទី៧ រហូតដល់ឆ្នាំ១២២០ គឺជាសម័យកាលនៃជ័យជម្នះនៅក្នុងសង្គ្រាម និងការដណ្តើមយកទឹកដីថ្មីៗ ដោយយុទ្ធនាការ។

ស្ថានភាពខាងសេដ្ឋកិច្ចរបស់ចក្រភពកម្ពុជទេស នៅសម័យខាងចុងនៃទសវត្សរ៍ទី៧ មិនទាន់មានការផ្លាស់ប្តូរធំៗជាមូលដ្ឋាននៅឡើយ។ នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ ស្ថាបនកម្មបានប្រព្រឹត្តទៅតាមទំហំដ៏ធំធេង ហើយមិនបាន

បង្កើតឱ្យមានសេចក្តីលំបាកខាងនយោបាយផ្ទៃក្នុងប្រទេសអ្វីច្បាស់លាស់។

កម្មវិធីនយោបាយរបស់ព្រះបាទជ័យវរ្ម័នទី៧ បានទាក់ទងម៉្យាងទៅនឹងការបង្រួបបង្រួមទឹកដីដ៏ធំធេងរបស់ចក្រភព ម៉្យាងទៀត ទៅនឹងកិច្ចការរៀបចំស្រុកទេស ដែលតម្រូវឱ្យមានការផ្លាស់ប្តូរខាងសង្គម-សេដ្ឋកិច្ច នៅលើដែនដីកណ្តាលនានានៃចក្រភព។ ដោយបានបង្រួបបង្រួមរាជវង្សខាងចន្ទ្រវង្ស (ដែលមានព្រះអង្គជាសមាជិក ហើយដែលនៅពេលនោះ បានបង្រួមញាតិសារលោហិត និងរាជវង្សខាងសូរ្យវង្ស) ជាមួយនឹងរាជវង្សមហិធរៈបូរៈ ព្រះបាទជ័យវរ្ម័នទី៧ បានបំបាត់នូវបដិបក្ខភាពរវាងរាជវង្សានុវង្សខ្មែរដ៏សំខាន់ទាំងពីរ។ នៅតាមដែនដីសាមន្តរាជពីពេលមុន មានបង្កើតប្រព័ន្ធរបបត្រួតត្រាផ្ទាល់របស់រដ្ឋអំណាចមជ្ឈិម តាមរយៈនៃរបៀបចាត់តាំងបណ្តាមន្ត្រីសក្តិភូមិ និងគណៈសង្ឃឱ្យទៅសន្និតនៅត្រួតត្រាតាមទឹកដីចុងកាត់ដាច់ស្រយាលទាំងឡាយ។

វិធានការដ៏សំខាន់បំផុត ដែលបានបង្កលក្ខណៈដល់ការបង្រួបបង្រួមចក្រភព និងដល់ការអភិវឌ្ឍខាងសង្គម-សេដ្ឋកិច្ច គឺវិធានការកែប្រែខាងសាសនា។ អស់រយៈពេលមួយសតវត្សរ៍មកហើយ ដោយចាប់អារម្មណ៍ចំពោះភាពខ្វះខាតនៃជំនឿចាស់របស់វណ្ណៈអភិជន និងជំនឿប្រជាករដ៏ធម្មតាបំផុតចំពោះភាពជាក់ស្តែងសម្រាប់ការរៀបចំរបបសង្គមសក្តិភូមិ គេបានចាប់អារម្មណ៍ចំពោះសេចក្តីត្រូវការ នៃសាសនាប្រជាប្រិយមួយប្រកបដោយទស្សនវិជ្ជា “ ប្រជាធិបតេយ្យ ” គ្រាន់បើជាងមុន ដែលបានតម្រូវតាមគោលបំណង ដើម្បីធ្វើយ៉ាងណាឱ្យបណ្តាជន

ស្ថិតនៅក្រោមរបបសក្តិភូមិតទៅទៀត។ នៅសម័យកាលដ៏រុងរឿងនៃចក្រភព សាសនាស្របតាមគោលបំណងថ្មីបែបនេះ គឺពុទ្ធសាសនាមហាយាន ហើយនៅពេលតមក គឺពុទ្ធសាសនាថេរវាទ។ ជំនឿបែបនេះ គឺជាដំណើរចម្លងពីជំនឿខាងព្រហ្មញ្ញសាសនារបស់វណ្ណៈ “ ថ្នាក់លើ ” និងភាពជាក់ស្តែងខាងក្រៅ (មានព្រះវិហារ ពិធីសក្ការៈបូជានានា និងដទៃទៀត) ដែលសម្របសម្រួលតាមជំនឿនានានៃប្រជាជន “ ថ្នាក់ក្រោម ” មកកាន់ប្រព័ន្ធសាសនាដ៏ធំមួយ ដែលបានទៅជាទស្សនវិជ្ជាសម្រាប់ប្រជាករទូទៅ ហើយដែលអាចបម្រើផលប្រយោជន៍ដល់សង្គមសក្តិភូមិ តាមទម្រង់ថ្មីរបស់ខ្លួន គឺជាសាសនា ដែលបានទៅជាសាសនាជាមូលដ្ឋាននៅសតវត្សរ៍នោះ និងនៅពេលដ៏យូរកាលតមកទៀតនៅប្រទេសកម្ពុជា។

ដំណាក់កាលដ៏សំខាន់នៅក្នុងជំនឿថ្មីនេះ គឺសក្ការៈបូជាដែលគេអាចហៅថា ជាសក្ការៈបូជាព្រះពោធិសត្វ គឺជាសក្ការៈបូជាដែលបានលូតលាស់ឡើងដោយសារសក្ការៈបូជាព្រះវិស្ណុ នាភាគខាងដើមនៃសតវត្សរ៍ទី១២។ ពុទ្ធសាសនាមហាយាន ព្រមទាំងសក្ការៈបូជាព្រះពោធិសត្វ គឺ ជ្រុះកម្រតែងជគត មានន័យថា “ អាទិទេព-មនុស្សលោក ” មានលក្ខណៈប្រហាក់ប្រហែល ហើយសម្របសម្រួលទៅនឹងមនោគមន៍ នៃពិធីសក្ការៈបូជាទេវ-រាជា ដែលត្រូវបានអនុវត្តទៅ នៅសម័យដ៏រុងរឿងនៃចក្រភព។ សក្ការៈបូជាព្រះពោធិសត្វអវលោកិតេស្វរៈ នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ បានចូលមកជំនួសពិធីសក្ការៈបូជាព្រះវិស្ណុ ។ តាមវិធីបំពេញតួនាទីរបស់ខ្លួនខាងសង្គមកិច្ច គឺជាការគោរពបូជាមិនខុសគ្នាពីពិធីសក្ការៈបូជាទេវ-រាជា ហើយមិនតែប៉ុណ្ណោះ

មានលក្ខណៈខ្ពង់ខ្ពស់ទៅទៀត ដោយហេតុថា នៅពេលនេះរូបបដិមា របស់ព្រះពោធិសត្វអវលោគិតេស្វរៈ គឺជារូបតំណាងរូបភាព និងទ្រង់ទ្រាយរបស់ព្រះបាទជ័យវរ្ម័នទី៧។

ការផ្សព្វផ្សាយដ៏ទូលំទូលាយនៃពុទ្ធសាសនា និងការឃោសនាដោយមធ្យ័តនូវទស្សនៈវិជ្ជាដ៏ទន់ភ្លន់ ស្រណុកយល់នៃពុទ្ធសាសនានៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ គឺជាដំណាក់កាលជាមូលដ្ឋានមួយនៅក្នុងប្រវត្តិសាស្ត្រ។ ភាពចាំបាច់ក្នុងការពង្រឹងជំហរនៃសាសនាថ្មីរបស់រដ្ឋនេះម្យ៉ាង ហើយម្យ៉ាងទៀតវត្តមាននៃព្រះវិហារច្រើនឥតគណនា ខាងព្រហ្មញ្ញសាសនា តម្រូវឱ្យមានការចំណាយខាងស្ថាបនកម្មដ៏សម្បើម។ ភារកិច្ចចំពោះមុខរបស់ស្ថាបនករ និងនិម្មាបនករ បានចោទឡើងជាបន្ទាន់ គឺថាត្រូវតែស្ថាបនាវត្ត ខាងពុទ្ធសាសនាច្រើនជាងព្រះវិហារខាងព្រហ្មញ្ញសាសនា។ ក៏ប៉ុន្តែ ព្រះវិហារចាស់ៗមិនត្រូវបានបំបាត់ ហើយមិនត្រូវបានកសាងឡើងវិញ តាមរចនាបទខាងពុទ្ធសាសនាទេ។ នៅពេលជាមួយគ្នា ក្រៅពីស្ថាបនកម្មប្រាសាទព្រហ្មបាយ័ន គេបានស្ថាបនាព្រះវិហារធំៗដទៃទៀតដូចជា ប្រាសាទព្រះខ័ន ប្រាសាទបន្ទាយក្ដី ប្រាសាទតាព្រហ្ម (នៅក្នុងស្រុកបាទី សព្វថ្ងៃ)។ ស្ថាបនកម្មដ៏សំខាន់ជាងគេ ត្រូវបានធ្វើឡើងនៅក្នុងរដ្ឋធានី ព្រោះថា គឺនៅទីនេះ ដែលមានការផ្សព្វផ្សាយចេញនូវសក្ការៈបូជាថ្មី។ នៅសម័យនៃទសវត្សរ៍ទាំងនោះ រដ្ឋធានីយសោធរបុរៈបានប្រែទៅជាទីក្រុងដ៏ធំមហិមាជាងគេនៅក្នុងពិភពលោក។

សង្គមខ្មែរបានចាប់ផ្ដើមវិវត្តទៅតាមប្រព័ន្ធ នៃមនោគមវិជ្ជាថ្មីនៅចុងសតវត្សរ៍ទី១២ និងនៅដើមសតវត្សរ៍ទី១៣។ ការវិវត្តបែបនេះ មានមូលហេតុខាងសង្គមកិច្ច ដោយហេតុថា ការវិវត្ត

ខាងសង្គមកិច្ច-សេដ្ឋកិច្ចមួយចំនួនធំ បានធ្វើឱ្យវណ្ណៈកសិករស្ថិតនៅកណ្ដាលក្នុងប្រព័ន្ធ នៃទំនាក់ទំនងដ៏ស្មុគស្មាញថ្មីផ្សេងៗ។ ជំនឿចាស់ៗពីមុនមក មិនបានសមស្របទៅតាមសេចក្ដីត្រូវការថ្មី គឺជាជំនឿដែលបានកសាងឡើង ដើម្បីពន្យល់នូវលក្ខខណ្ឌនៃជីវភាពពីពេលមុន ដោយមនោគមន៍នៃជំនឿទាំងនេះពុំបានយកចិត្តទុកដាក់ដល់វណ្ណៈតូចទាបទាំងឡាយ។ផ្ទុយទៅវិញ ពុទ្ធនិយមដែលបានប្រកាសនូវសមភាពសម្រាប់មនុស្សទាំងអស់ ដោយមិនយោងទៅតាមលក្ខខណ្ឌនានានៃឋានន្តរសក្ដិ បានទទួលនូវប្រជាប្រិយភាពដ៏ទូលំទូលាយ។ សម្រាប់ជនានុជន ដែលចង់ក្រេបរសជាតិនៃលទ្ធិថ្មី អ្នកឃោសនាពុទ្ធសាសនាបានបង្កើតសាលាថ្នាក់មធ្យម និងថ្នាក់ជាន់ខ្ពស់ទាំងឡាយ ដែលនៅទីនេះមានការបង្ហាត់បង្រៀនគ្រប់ខណ្ឌ ជាព្រះសង្ឃប្រកបដោយចំណេះវិជ្ជា ហើយដែលត្រូវបានចាត់ឱ្យចេញទៅផ្សាយសាសនាថ្មីដល់ប្រជារាស្ត្រទូទៅ។ សិល្បៈសំណង់ និងចម្លាក់បានកកើតឡើងជាថ្មី តាមរូបភាពតាមរចនាបថ និងតាមគំនិតប្រឌិតខាងនិម្មាបនកម្មថ្មីៗ។ វិវត្តនាការចម្រុះ ហើយស្មុគស្មាញនានាបែបនេះបានប្រព្រឹត្តទៅក្នុងភាគទីពីរ នៃរជ្ជកាលដ៏យូររបស់ព្រះបាទជ័យវរ្ម័នទី៧។ ក៏ប៉ុន្តែ ការវិវត្តទាំងអស់នេះ បានដក់ដោយគំនិតច្នៃប្រឌិត ដោយហេតុថា គឺការតស៊ូខាងមនោគមវិជ្ជានាសតវត្សរ៍ទី១២-ទី១៣ នេះហើយ ដែលបានរៀបចំលក្ខណៈសម្បត្តិចំពោះភាពរីកចម្រើនតទៅអនាគត នៃជីវភាពខាងមនោគមវិជ្ជា និងវប្បធម៌របស់សង្គមខ្មែរនៅមធ្យមសម័យ។

ទស្សនៈចំពោះនិមិត្តរូបនៃពិភពលោកនៅក្នុង “នវៈសម័យ” បានចាប់អារម្មណ៍ជាពិសេស នៅលើការកសាងនៃមជ្ឈមណ្ឌល

កណ្តាលរបស់រដ្ឋធានី ដែលនៅពេលនោះ គេបានទម្លាក់កំហុសទៅលើបណ្ឌាបុព្វបុរស ដែលមិនជ្រើសរើសឱ្យត្រឹមត្រូវនូវមជ្ឈមណ្ឌលកណ្តាលនៃរដ្ឋធានីរបស់ចក្រភព។ ដូច្នេះ គម្រោងការថ្មីនៃស្ថាបនកម្មរដ្ឋធានីថ្មី មិនបានយោងទៅតាមទស្សនៈខាងព្រហ្មញ្ញសាសនាទេ ប៉ុន្តែយោងទៅតាមទស្សនៈខាងពុទ្ធសាសនាវិញ។

នយោបាយខាងសាសនាបានផ្លាស់ប្តូរជាខ្លាំង ក្នុងទំនាក់ទំនងនឹងព្រហ្មញ្ញសាសនា ដែលគេបានចាត់ទុកថាជាសាសនារបស់រដ្ឋ។ ប្រសិនបើនៅសម័យមុន ព្រះមហារាជជាពុទ្ធបរិស័ទបានរក្សាទុកនូវពិធីសក្ការៈបូជាលិង្គទេវ-រាជា នោះ នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៧ រូបភាពជានិមិត្តនៃមហិទ្ធិឫទ្ធិរបស់ព្រះមហារាជមិនមែនជាលិង្គទេ ក៏ប៉ុន្តែ ជារូបបដិមារបស់ព្រះពោធិសត្វអវលោកិតេស្វរៈ ទៅវិញ គឺជាព្រះពោធិសត្វ ដែលគេគោរពទូទៅនៅអាស៊ីអាគ្នេយ៍នាសម័យនោះ។

ប្រាសាទព្រហ្មបាយ័ន ដែលស្ថិតនៅចំមជ្ឈមណ្ឌលកណ្តាលនៃរដ្ឋធានី គឺជាព្រះវិហារឧទ្ទិសដល់ព្រះពោធិសត្វអវលោកិ-តេស្វរៈ។ មនោគមន៍នៃពិធីសក្ការៈបូជាព្រះពុទ្ធ-ព្រះមហារាជក៏បានលេចជារូបរាងច្បាស់លាស់នៅចក្រភពកម្ពុជទេស។ គឺជាមនោគមដែលត្រូវបានផ្សព្វផ្សាយនៅពេលក្រោយ នៅប្រទេសថៃ។

នៅក្នុងសម័យកាល នៃរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី២ (បន្ទាប់ គ.ស.១២២០ - គ.ស.១២៤៣) ជាព្រះរាជបុត្ររបស់ព្រះបាទជ័យវរ្ម័នទី៧ ជីវភាពរុងរឿងរបស់ចក្រភពបានបន្តដំណើរទៅមុខទៀត។ នៅឆ្នាំ១២២៣ ដោយមានសេចក្តីព្រមព្រៀងរបស់ចក្រភពកម្ពុជទេស ព្រះរាជបុត្រចាម មួយព្រះអង្គបាន

ឡើងសោយរាជសម្បត្តិទៅលើព្រះរាជបល្ល័ង្ក នៃប្រទេសចម្ប៉ា ដែលរហូតមកដល់ពេលនោះ ព្រះអង្គបានធ្វើជាទេសាភិបាលខ្មែរនៅប្រទេសចម្ប៉ា។ អស់ពេលដ៏យូរនៅក្នុងរជ្ជកាលរបស់ព្រះបាទឥន្ទ្រវរ្ម័នទី២ ពុំមានវិបត្តិអ្វីមួយដែលបានកើតឡើងជាមួយប្រទេសចម្ប៉ា ទេ ហើយព្រះអង្គបានរក្សានូវកិច្ចត្រួតត្រាលើប្រទេសចម្ប៉ា នៅពេលតទៅមុខទៀត។ តាមឯកសារផ្សេងៗ ដែនដីដែលស្ថិតនៅជាសមាសភាព នៃទឹកដីចក្រភពនាឆ្នាំ ១២២៥ គឺមានដែនដីទាំងអស់របស់ព្រះបាទជ័យវរ្ម័នទី៧។ នៅលើដែនដីទាំងនេះ ដែនដីខ្លះបានស្ថិតនៅក្រោមរបបគ្រប់គ្រងផ្ទាល់របស់រដ្ឋអំណាចមជ្ឈិម ដែនដីខ្លះទៀតបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់ស្ដេចសាមន្តរាជ ដែលជួនកាលមានជាប់ញាតិសារលោហិត និងព្រះរាជវង្សានុវង្សខ្មែរ ដូចជាស្ដេចសៀម នាម ផា-មឿង ជាដើម។

នៅសម័យពាក់កណ្ដាលសតវត្សរ៍ទី១៣ ជាមួយនឹងវិវត្តនាការខាងសង្គម បាតុភូតនៃវិបត្តិខ្លះៗបានកើតមានឡើងទាក់ទងនឹងភាពអស់ជីជាតិដីស្រែចម្ការ និងភាពខ្វះខាតទឹកនៅក្នុងភូមិភាគនៃរដ្ឋធានី។ ការបង្ហូរទឹកតាមកម្រិតខ្លាំង ភាពកខ្វក់ទឹកនៅតាមព្រែកជីក ដែលបណ្ដាលឱ្យស្ទះប្រឡាយទឹកនានា ព្រមទាំងការភ្ជួររាស់ដីដដែលទាំងអស់នេះ បានធ្វើឱ្យដីដំណាំអស់ជីជាតិបន្តិចម្ដងៗ ហើយផលដំណាំក៏បានចុះថយជាលំដាប់ (ជាពិសេសនៅតំបន់ខាងកើតទាំងឡាយ ដែលទឹកហូរបាននាំមកនូវដីល្បប់ និងជីជាតិផលដំណាំមិនបានចុះថយទេ)។មិនតែប៉ុណ្ណោះ កម្ពស់ទឹកនៅតាមស្ទឹងដ៏សំខាន់ គឺស្ទឹងសៀមរាប ក៏បានចុះថយ។ ដីហិលអស់ជីជាតិបណ្ដាលឱ្យផលដំណាំ ខាងកសិកម្មចុះឱនថយ។

ម្ល៉ោះហើយ បណ្តាកសិករក៏ចាប់ផ្តើមចាកចេញពីតំបន់រដ្ឋធានី។ ប្រភពដើមដ៏សំខាន់បំផុតខាងភោគផល និងខាងប្រជាករ ដែលស្ថិតនៅក្នុងតំបន់កណ្តាលនៃចក្រភព ក៏បានចុះឱនថយដែរ។ គឺប្រភពដើមខាងភោគផល និងខាងប្រជាករនេះហើយ ដែលបានជួយស្តារស្ថានភាពចក្រភពនៅក្នុងគ្រាលំបាក ដែលបានកើតមានឡើងដោយសារចម្បាំង ឬវិបត្តិសេដ្ឋកិច្ច ហើយឥឡូវនេះស្ថានភាពបានចាប់ផ្តើមផ្លាស់ប្តូរ។

សភាពការណ៍បែបនេះ បានជំរុញឱ្យស្ថានភាពខាងនយោបាយទៅជាស្មុគស្មាញ រួចមិនតែប៉ុណ្ណោះ ការផ្លាស់ប្តូរខាងជំនឿ និងសតិអារម្មណ៍ ក៏បានបន្តដំណើរតទៅមុខ។

គឺព្រឹត្តិការណ៍ទាំងនេះហើយ ដែលបង្កើតឱ្យមានវិបត្តិនានា។ នៅក្នុងជីវភាពនៃបណ្តាជនដែលបានចាប់ផ្តើមជឿលើពុទ្ធសាសនានាសម័យពាក់កណ្តាលនៃសតវត្សរ៍ទី១៣ ពុទ្ធសាសនាថេរវាទ បានផ្តល់ឥទ្ធិពលរបស់ខ្លួន នៅក្នុងការអនុវត្ត និងនៅក្នុងជីវភាពរស់នៅ។

សិលាចារឹកបានផ្តល់ព័ត៌មានដ៏មានតម្លៃ ស្តីអំពីការវិវត្តខាងសង្គម-សេដ្ឋកិច្ចនៅសម័យនោះ។ ពន្ធដារ ដែលរដ្ឋទារបានពីបណ្តាកសិករ គឺជាចំណូលដ៏សំខាន់ខាងសេដ្ឋកិច្ច។

ភាពផ្លាស់ប្តូរដ៏សំខាន់ៗ បានកើតមានឡើងនៅក្នុងវិស័យសង្គមកិច្ច។ នៅក្នុងឯកសារតាមសិលាចារឹក ការរៀបរាប់គោរមងារ និងឋានន្តរសក្តិរបស់មនុស្សនៅក្នុងវណ្ណៈអភិជនមិនសូវមាន លើកលែងតែគោរមងាររបស់ព្រះមហារាជ “ ប្រ៉ះកម្រតែងអញ ”។ មែនពិត ប្រព័ន្ធនៃគោរមងារ និងឋានន្តរសក្តិក៏បានផ្លាស់ប្តូរ។ គេអាចសន្និដ្ឋានបានថា គោរមងារទាំងនេះជា

ច្រើនមិនបានបាត់បង់ពីការប្រើប្រាស់ទេ ព្រោះថា នៅសម័យកាលក្រោយមក គោរមងារត្រូវបានប្រើប្រាស់ឡើងវិញ។ ក៏ប៉ុន្តែ ខុសពីសម័យកាលដ៏រុងរឿងនៃពិធីសក្ការៈបូជាទេវ-រាជា នៅក្នុងសម័យកាលនៃពុទ្ធសាសនា គោរមងារ និងឋានន្តរសក្តិមិនសូវមានការរំលឹកតាមសិលាចារឹក ហើយបានទៅជារបស់មិនសូវសំខាន់ក្នុងការគោរពដល់ព្រះ។ ពុទ្ធសាសនាថេរវាទ មិនបានឱ្យតម្លៃដល់ឋានន្តរសក្តិ របស់មនុស្សនៅលើផែនដីក្នុងពិធីគោរពព្រះឡើយ។ គឺមកពីមូលហេតុនេះហើយ បានជាគេពុំឃើញមានសេចក្តីរំលឹកដល់អតីតកាល ឬដល់ប្រវត្តិរូបរបស់អ្នកធ្វើអំណោយ។ ពុទ្ធសាសនាថេរវាទបានឱ្យតម្លៃតែលើលក្ខណៈសម្បត្តិរបស់បុគ្គលប៉ុណ្ណោះ។ ទស្សនៈខាងពុទ្ធសាសនាបែបនេះមានលក្ខណៈដូចគ្នានឹងទស្សនៈ ខាងពុទ្ធសាសនារបស់ជនជាតិមន ដែលបានរស់នៅភូមិភាគខាងលិចនៃឧបទ្វីបឥណ្ឌូចិន។ គួរកត់សម្គាល់ម្យ៉ាងទៀតថា នៅសតវត្សរ៍ទី១៣ ឈ្មោះរបស់ព្រះពោធិសត្វនានា នៅក្នុងពុទ្ធសាសនាបានលាយចូលគ្នានឹងនាមឈ្មោះរបស់មហាក្សត្រ។ ក៏ប៉ុន្តែ នៅសតវត្សរ៍ទី១៤ គេពុំប្រទះឃើញនូវសំណល់ នៃការគោរពអាទិទេព-ព្រះមហាក្សត្របែបនេះទៀតឡើយ។

នៅភាគពាក់កណ្តាលនៃសតវត្សរ៍ទី១៣ ដូចតែងមានមកហើយ ពួកអភិរក្សនិយមនៃ “សង្គមចាស់” បានចូលមកកាន់កាប់កិច្ចការរដ្ឋជំនួសអ្នកនយោបាយ ដែលប្រាថ្នារក្សាចក្រភពតាមការអនុវត្តនូវមនោគមវិជ្ជាទំនើប។ នៅក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៨ (គ.ស.១២៤៣ - គ.ស.១២៩៥) មានការបង្កើតឥទ្ធិពលពួកបរិស័ទប្រកាន់សាសនាព្រះឥសូរ និងការរៀបចំ

ឡើងវិញនូវពិធីសក្ការៈបូជាលិង្គទេវ-រាជា។ ពុទ្ធសាសនាក៏បានត្រឡប់ទៅជាសាសនាបន្ទាប់បន្សំ ទោះបីឯកសារជាភស្តុតាងនៅចុងសតវត្សរ៍បានបញ្ជាក់ថា ពុទ្ធសាសនាត្រូវបានផ្សព្វផ្សាយតទៅទៀតនៅរដ្ឋធានី ក៏ដូចជានៅទីខេត្តផ្សេងៗ។ ការប្រែត្រឡប់មកគោរពតាមពិធីសក្ការៈបូជាលិង្គទេវ-រាជា ដោយព្រះបាទជ័យវរ្ម័នទី៨ មិនបានបង្កើតបរិយាកាសតឹងតែងដែលបណ្តាលឱ្យមានការបំផ្លិចបំផ្លាញ និងបិទទ្វារព្រះវិហារធំៗខាងពុទ្ធសាសនាឡើយ។ មិនតែប៉ុណ្ណោះសោត គឺនៅសម័យនោះហើយ ដែលពុទ្ធសាសនាថេរវាទ បានផ្សព្វផ្សាយយ៉ាងសកម្មនូវឥទ្ធិពលរបស់ខ្លួន។ នៅពេលជាមួយគ្នា ពុទ្ធសាសនាមហាយានក៏ត្រូវបានរក្សាទុក ក៏ប៉ុន្តែ ការរៀបចំឡើងវិញនូវពិធីសក្ការៈបូជាលិង្គទេវ-រាជា ធ្វើឱ្យខូចខាតដល់ឥទ្ធិពលដល់ពិធីសក្ការៈបូជារូបព្រះពោធិសត្វ-ព្រះមហាក្សត្រ។ ហើយការធ្វើអំណោយដល់ព្រះវិហារខាងពុទ្ធសាសនា ក៏ត្រូវបានបន្តទៅទៀត។ មានសភាពការណ៍មួយទាក់ទងនឹងបំណងធ្វើឱ្យជីវភាពខាងវប្បធម៌មានលក្ខណៈប្រជាធិបតេយ្យ គឺការសរសេរនាមឈ្មោះរបស់សិល្បករចម្លាក់នៅលើរូបបដិមានានា។

ម្យ៉ាងវិញទៀត ការតស៊ូដើម្បីផ្សព្វផ្សាយសាសនាថ្មី និងនយោបាយរបស់បរមរាជវាំងប្រឆាំងនឹងប្រពៃណី នៃប្រជាជនទូទៅ បណ្តាលឱ្យមានការបែកបាក់គ្នា និងភាពទន់ខ្សោយនៃចក្រភព ហើយផលវិបាកបែបនេះបណ្តាលឱ្យមានភាពទន់ខ្សោយដល់មហិទ្ធិឫទ្ធិយោធា។ វង្សត្រកូលនៃពួកអភិជនសក្តិភូមិថ្មីៗ បានឡើងមកកាន់កាប់តំណែងនៅក្នុងរដ្ឋបាល ហើយចាប់ផ្តើមកងសាងព្រះវិហារខាងសាសនាព្រះឥសូរ សាជាថ្មី។ ព្រះ

វិហារបែបនេះ គេឈប់កសាងពីយូរមកហើយ។ ការធ្វើអំណោយត្រូវចាប់ផ្ដើមឡើង មានទាំងការធ្វើអំណោយដល់ព្រះវិហារខាងពុទ្ធសាសនាផងដែរ។ បើតាមការសន្និដ្ឋាន ព្រះបាទជ័យវរ្ម័នទី៨ បានឡើងសោយរាជ្យ ហើយត្រូវបានបាត់បង់រាជសម្បត្តិវិញ ក៏ដោយសារមានរដ្ឋប្រហារ។ ព្រះអង្គគ្មានទំនាក់ទំនងអ្វីនឹងខ្សែព្រះរាជវង្សានុវង្ស ហើយនៅក្នុងរជ្ជកាលរបស់ព្រះអង្គ ចលនាប្រឆាំងនានាបានកើតមានឡើង។ មហារាជថ្មីបានហៅរកមនុស្សថ្មីៗពីសំណាក់វណ្ណៈអភិជន ដែលប្រកាន់តាមសិវៈនិយម ឱ្យចូលបម្រើរាជការជុំវិញព្រះអង្គ។ ប្រទេសពោរពេញទៅដោយការតស៊ូខាងសាសនារៀងៗខ្លួន ក៏ប៉ុន្តែ ក្នុងការតស៊ូទាំងនេះពុំដែលមានការប្រើប្រាស់ហិង្សាភាពទេ។ ព្រឹត្តិការណ៍ទាំងនេះពុំបានផ្ដល់ឥទ្ធិពលអាក្រក់ ដល់ជីវភាព ខាងសង្គម-សេដ្ឋកិច្ចនៅលើដែនដីខ្មែរឡើយ។ កម្ពុជទេស នៅសម័យនោះ ស្ថិតនៅជាប្រទេស “ សម្បូររុងរឿងខ្ពង់ខ្ពស់ ” ក៏ប៉ុន្តែ សម្រាប់ដោគវាសនានៃដែនដីដាច់ស្រយាល វិបត្តិនៃការតស៊ូខាងនយោបាយនៅរដ្ឋធានីយសោធរៈបុរៈ ដើរតួនាទីដ៏សំខាន់សម្រាប់ដែនដីទាំងនេះ។ ការបញ្ជូនកងកម្លាំងយោធាដោយចក្រភពកម្ពុជទេស ទៅភូមិភាគខាងកើត ដើម្បីធ្វើការប្រយុទ្ធប្រឆាំងអំពើវាយលុក របស់កងទ័ពម៉ុងហ្គោល ក៏បានបង្កើតជាផលវិបាកមួយ ដោយហេតុថាភូមិភាគខាងលិចនៃចក្រភពបានទៅជាទន់ខ្សោយ។

វិបត្តិ និងការតស៊ូគ្នាខាងនយោបាយផ្ទៃក្នុង ដែលកាន់តែមានកម្រិតខ្លាំងក្លា វិបត្តិសេដ្ឋកិច្ចដែលកើតមាននៅក្នុងតំបន់កណ្ដាលនៃចក្រភព ការបញ្ជូនកងកម្លាំងយោធាទៅភូមិភាគខាងកើត ទាំងអស់នេះបានបង្កើតឱ្យមាននិន្នាការបែកខ្ញែកនៅ

ក្នុងដែនដីដាច់ស្រយាលទាំងឡាយ ដែលមានជនជាតិជទៃរស់នៅ។ និន្នាការបែបនេះបានលេចចេញឡើងនៅក្នុងបណ្តារដ្ឋសាមន្តរាជសៀម តូចៗ ដែលស្ថិតនៅភាគខាងលើនៃទន្លេចៅ-ប្រែន។ នៅក្នុងរដ្ឋសាមន្តរាជទាំងនេះ នាសម័យនៃទសវត្សរ៍ទី៥ តុល្យភាពនៃជីវភាពផ្ទៃក្នុង ត្រូវបានខូចខាតដោយការមកដល់របស់កងកម្លាំងនៃពួកសក្តិភូមិ និងការមកដល់នៃក្រុមបណ្តាជនទាំងឡាយ ដែលបានភៀសខ្លួនមកពីតំបន់ខាងជើងនៃចក្រភព គឺតំបន់ដាលី បន្ទាប់ពីពេលដែលកងទ័ពម៉ុងហ្គោល បានវាយលុកចូលតំបន់នេះ នាឆ្នាំ១២៥៣។ បន្ទាប់ពីបានកាន់កាប់ដីមួយផ្នែកនៃរដ្ឋមន ឈ្មោះហរិបុញ្ញជ័យ នៅសម័យនៃទសវត្សរ៍ទី៥ ជនជាតិនៃសាមន្តរាជសៀម បានចាប់ផ្តើមធ្វើយុទ្ធនាការបញ្ចេញកងកម្លាំងខ្មែរចេញពីទីក្រុងនានា នៅតាមទីមធ្យមនៃទន្លេចៅ-ប្រែន គឺនៅទីនេះហើយ ដែលរដ្ឋសុខោទ័យសៀម បានចាប់បដិសន្ធិឡើង។ ព្រឹត្តិការណ៍នេះ បានបញ្ជាក់ឱ្យឃើញនូវការចាប់ផ្តើមរង្គោះរង្គើរនៃចក្រភព។ បន្ទាប់ពីចម្បាំងនាឆ្នាំ១២៨៣-១២៨៧ រដ្ឋមន ឈ្មោះលវបូរៈ(ល្វោ) បានប្រកាសនូវឯករាជភាពរបស់ខ្លួន ចក្រភពក៏បានចាប់ផ្តើមរង្គើរយ៉ាងពិតប្រាកដ។

នៅពេលខាងចុងនៃរជ្ជកាលព្រះបាទជ័យវរ្ម័នទី៨ មានការប៉ះទង្គិចគ្នារវាងកងទ័ពខ្មែរ និងកងទ័ពរួបរួមនៃជនជាតិនានា។ ទោះបីក្នុងការប្រយុទ្ធនេះ ពួកសៀម មិនបានជោគជ័យក្តី ក៏ចម្បាំងនេះបានទាមទារឱ្យចក្រភពធ្វើការប្រឹងប្រែងជាខ្លាំង។ ប៉ុន្តែ ទោះបីដូចម្តេចក្តី ក៏មហិទ្ធិឫទ្ធិ និងភាពរុងរឿងរបស់ចក្រភព បានធ្វើឱ្យមនុស្សសម័យនោះកោតស្ញប់ស្ញែងនៅឡើយ ពេលដែលចម្បាំងនេះបានកន្លងផុតមួយឆ្នាំ។

សង្គមខ្មែរនាសម័យខាងចុងនៃសតវត្សរ៍ទី១៣ បានសម្រេចនូវការប្រតិដ្ឋាននៃមនោគមវិជ្ជារបស់ខ្លួន។ ពុទ្ធសាសនាថេរវាទត្រូវបានផ្សព្វផ្សាយកាន់តែទូលំទូលាយឡើង ហើយបានផ្តល់ឥទ្ធិពលរបស់ខ្លួនទៅលើរដ្ឋតូចៗរបស់ជនជាតិសៀម និងឡាវ។ វត្តមានព្រះសង្ឃនៃពុទ្ធសាសនាខាងហីនយាន ដោយចំនួនច្រើនឥតគណនា ក៏បានតម្រូវឱ្យមានការចំណាយមិនអន់ណាស់ណាជាងការចំណាយសម្រាប់សំណង់ និងការផ្គត់ផ្គង់ព្រះវិហារខាងព្រហ្មញ្ញសាសនានាសតវត្សរ៍ទី១០-ទី១៣ ប៉ុន្មានដែរ។ ក៏ប៉ុន្តែវត្តមាននៃព្រះសង្ឃក៏បានផ្តល់ប្រសិទ្ធភា ពមិនអន់ក្នុងការបំពេញភារកិច្ចខាងសាសនា។ ការកម្រិតការចំណាយភោគទ្រព្យរបស់ចក្រភព ទោះបីដូចម្តេចក្តី បានផ្តល់គុណប្រយោជន៍ដ៏ប្រសើរដល់រដ្ឋខ្មែរ ក៏ប៉ុន្តែ ការចុះអន់ថយនៃភូមិភាគជង្រុកស្រូវនៃទិសខាងលិចដោយសង្វាក់យ៉ាងលឿន បានស្ថិតនៅជាបញ្ហាមិនទាន់ដោះស្រាយ។

នៅសម័យនោះ ការវិវត្តប្រហាក់ប្រហែលគ្នាបានប្រព្រឹត្តទៅនៅចក្រភពប៉ាហ្គ័ន (ភូមា) នៅចក្រភពស្រីវិជ័យ (ប្រទេសជ្វា) ហើយកន្លងមួយសតវត្សរ៍ក្រោយមក នៅម៉ានសាបហិតេ (ប្រទេសជ្វា)។នៅសតវត្សរ៍ទី១៤-១៥ជាទូទៅ នៅអាស៊ីអាគ្នេយ៍ ចក្រភពសក្តិភូមិនានាបានប្រែប្រួលទៅជាប្រទេសមានទំហំតូចជាងមុន (ជួនកាល ការប្រែប្រួលនេះបានប្រព្រឹត្តទៅដោយគ្មានភាពសង្កត់សង្កិនពីខាងក្រៅ) ក៏ប៉ុន្តែ ជាប្រទេសប្រកបដោយលក្ខណៈសម្បត្តិពេញលេញខាងរបៀបចាត់តាំងសង្គម (ជាប្រទេសធម្មតា ប៉ុន្តែឱបក្រសោបស្រទាប់បណ្តាជនច្រើនបែប) ហើយជួនកាល គឺជាប្រទេសប្រកបដោយឯកជាតិខ្មែរ មានបណ្តាជន

ច្រើនទៀតផង។ ចក្រភពមួយក្នុងបណ្ដាចក្រភពទាំងនេះ គឺចក្រភពកម្ពុជទេស ដែលជាមជ្ឈមណ្ឌលនៃប្រជាជនខ្មែរ នៅចុងសតវត្សរ៍ទី១៣ ប្រែត្រឡប់មកជាក្រុងកម្ពុជទេស ហើយដែលមានឈ្មោះថាជាប្រទេសកម្ពុជា។ ការវិវត្តនេះមានលក្ខណៈទូទៅនៅតំបន់នេះ ហើយមិនមែនជាសភាពការណ៍ប្លែកសម្រាប់ប្រទេសកម្ពុជា ទេ។ នៅសម័យនោះ បើយោងតាមយោបល់របស់អ្នកប្រាជ្ញបារាំងមួយរូប ឈ្មោះ ប. ប៉ែល្លីយ៉ូត៍ ៖ " ប្រទេសបានលូតលាស់រុងរឿងយ៉ាងពេញលេញ "។ យោបល់បែបនេះបានលេចចេញមកសេចក្ដីអធិប្បាយដ៏ក្បោះក្បាយ រៀបចំឡើងនាសម័យចុងសតវត្សរ៍ទី១៣ ដោយ ជី-តាក្វាន់ ដែលបានមករស់នៅប្រទេសកម្ពុជា នៅសម័យនោះ។ ជី-តាក្វាន់ ក៏ដូចជារដ្ឋការទូតចិន មួយចំនួននៅពេលនោះ គាត់បានពណ៌នាអំពីប្រទេសកម្ពុជា នាសតវត្សរ៍ទី១៣ បន្ទាប់ពីពេលដែលប្រទេសនេះ បានធ្វើឱ្យប្រទេសចិន ទទួលបរាជ័យនៅប្រទេសកម្ពុជា។ ទឹកដីចក្រភពបានរួមតូច ក៏ប៉ុន្តែ សភាពការណ៍នេះមិនបានផ្ដល់ឥទ្ធិពលអ្វីមកលើស្ថានភាពទឹកដីខ្មែរសុទ្ធសាធឡើយ ហើយការនេះអាចឱ្យគេសន្និដ្ឋានបានថា ការបញ្ឈប់នយោបាយចក្រភព គឺជាជំហានមួយប្រកបដោយលក្ខណៈចម្រើននិយម។ ដូចមានភស្តុតាងតាមប្រវត្តិសាស្ត្រទូទៅនៅភូមិភាគអាស៊ីអាគ្នេយ៍ គឺបន្ទាប់ពីសម័យកាលចក្រភពនេះហើយ ដែលរដ្ឋនានាបានចាប់បដិសន្ធិឡើងនៅសតវត្សរ៍ទី១៦-ទី១៩។

សង្គ្រាមជាមួយរដ្ឋសុខោទ័យ នៅភាគទី១ នៃទសវត្សរ៍ទី៥ មិនបានធ្វើឱ្យរបេះដែនដីខ្មែរ សូម្បីតែមួយភាគឡើយ ហើយការនេះមានទាំងភស្តុតាង បញ្ជាក់ក្នុងសេចក្ដីអធិប្បាយស្ដីអំពី

ជោគជ័យរបស់មហាក្សត្រសៀម។ ជី-តាក្វាន់ បានពណ៌នាអំពីស្ថានភាពសម្បូរសប្បាយរុងរឿងនៃកម្ពុជទេស ដែលអ្នកស្រុកដ៏ក្របំផុតនៅរដ្ឋធានី ក៏មានខ្ញុំបម្រើពីរបីនាក់ដែរ។ គាត់ពណ៌នាយ៉ាងល្អិតល្អន់អំពីសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់រដ្ឋធានី។ ព្រះមហារាជប្រកបដោយអំណាចដ៏ខ្លាំងក្លា ហើយកិត្តិនាមរបស់ព្រះអង្គបានរន្ទឺសុះសាយខ្ពង់ខ្ពស់។ នេះជាមតិស្រង់តាមឯកសារចិន។ អគ្គរដ្ឋទូតចិន (ជី-តាក្វាន់) មិនបានបញ្ជាក់អំពីអ្វីមួយស្ដីអំពីភាពមិនសប្បាយចិត្តរបស់ប្រជាជនទេ ទោះបីគាត់បានដឹងអំពីស្ថានភាពច្បាស់ ដោយបានទទួលព័ត៌មានតាមជនជាតិចិនដែលរស់នៅទីនេះក្ដី។

នៅក្នុងប្រទេស ប្រជាជនភាគច្រើនជាអ្នកកាន់ពុទ្ធសាសនានៅគ្រប់ទីកន្លែង មានរូបព្រះសម្មាសម្ពុទ្ធ ហើយព្រះវិហារមានលក្ខណៈជាវិហារពុទ្ធសាសនាហីនយាន។ ការអប់រំទាំងមូលស្ថិតនៅក្រោមកិច្ចគ្រប់គ្រងរបស់ភិក្ខុសង្ឃហីនយាន។ ជី-តាក្វាន់ជាអ្នកស្គាល់ពុទ្ធសាសនាមហាយានច្បាស់ បានគូសបញ្ជាក់នូវលក្ខណៈខុសគ្នារវាងពុទ្ធសាសនាថេរវាទ និងមហាយាន។

ប្រពៃណីពីសម័យកាលនៃព្រះបាទជ័យវរ្ម័នទី៧ បានលេចចេញច្បាស់នៅក្នុងវិស័យនានានៃជីវភាពប្រជាជន។ នៅក្នុងប្រពៃណីនេះ មានទាំងព្រះសង្ឃជាមន្ត្រីបម្រើរាជការប្រពៃណីនៃការរួមរស់រវាងអ្នកបម្រើរាជការ និងព្រះសង្ឃបានបាត់បង់នៅពេលក្រោយមកទៀត។មិនតែប៉ុណ្ណោះ មានទាំងទំនៀមទម្លាប់នៅក្នុងពិធីបុណ្យរដ្ឋផ្សេងៗ មានទាំងព្រះវិហារ - ចេតិយ។ ដូចសម័យមុន ប្រាសាទព្រហ្មបាយ័ន ប្រកបដោយកំពូលដងដោយពណ៌មាស បានទៅជាមជ្ឈមណ្ឌលកណ្ដាល មិនមែនតែតាម

គម្រោងផែនការប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់ជីវភាពសាសនានៅរដ្ឋធានីទៀតផង។ ប្រពៃណីបានភ្ជាប់ប្រវត្តិនៃរាជវង្សានុវង្សទៅនឹងរឿងទេវកថា ក៏ត្រូវបានរក្សាទុកតមក។ ព្រះបាទឥន្ទ្រវរ្ម័នទី៣ (គ.ស.១២៩៥ - គ.ស.១៣០៧) បានតាំងខ្លួនព្រះអង្គថា ជាមហាក្សត្របន្តរាជវង្សានុវង្សនៃតាបសកំពុ (កម្ពុ) និងព្រះនាងនាគី-សោមា។ នៅក្នុងរជ្ជកាលព្រះអង្គ ពិធីសក្ការៈបូជាទេវ-រាជា ត្រូវបានរក្សាទុក ប៉ុន្តែ រូបទេវ-រាជា គឺជារូបព្រះពោធិសត្វ ដែលជារូបភាពបន្តប្រពៃណីពីព្រះបាទជ័យវរ្ម័នទី៧។

ជ័យជម្នះខ្លះៗនៅក្នុងចម្បាំងជាមួយពួកសៀម នៅសម័យដើមនៃទសវត្សរ៍ទី៦ នៅពេលដែលពួកនេះវាយលុកចូលមកក្នុងទឹកដីខ្មែរ ម្តងៗ ដោយហេតុថា ពួកជននៅក្នុងមជ្ឈដ្ឋានដឹកនាំជាន់ខ្ពស់បានបញ្ឈប់ ជាបណ្តោះអាសន្ន នូវទំនាស់ទាស់ទែងគ្នា និងបញ្ឈប់ជាបណ្តោះអាសន្ននូវការសោកល្បងប្រតិកិរិយាក្នុងការរៀបចំឡើងវិញនូវជំនឿខាងសីវនិយម (សាសនាព្រះឥសូរ) ឡើងវិញ។ ការរីកចម្រើនរបស់សង្គមទាំងមូលបានទាក់ទងទៅនឹងការរីកសុះសាយ តទៅអនាគតកាលនូវពុទ្ធសាសនាថេរវាទ ហើយព្រះបរមរាជវាំងមិនអាចតស៊ូប្រឆាំងនឹងនិន្នាការបែបនេះតទៅមុខទៀតបានឡើយ។ មូលហេតុម៉្យាងប្រហែលជាកើតមក ពីកងទ័ពបានទទួលបរាជ័យ ក្នុងចម្បាំងក្រោមការដឹកនាំរបស់បរមរាជវាំង ហើយកងទ័ពបានដើរតួនាទីរបស់ខ្លួននៅក្នុងការលូតលាស់នៃព្រឹត្តិការណ៍ទាំងនេះ។

ព្រះបាទជ័យវរ្ម័នទី៨ ជាព្រះមហារាជកែប្រែនិយម ហើយត្រូវបានរំលំពីអំណាច ដោយបុត្រប្រសារបស់ព្រះអង្គដែលធ្វើជាមហាសេនាបតី ហើយបុត្រប្រសានេះក៏បានឡើងសោយរាជ

សម្បត្តិ ដោយមានព្រះនាមថា ព្រះបាទស្រីឥន្ទ្រវរ្ម័នទី៣។ ព្រះមហារាជថ្មីបានតាំងខ្លួនជាក្សត្រ ជាប់រាជវង្សនឹងតាបសកំពុ (កម្ពុ) ព្រះនាងនាគី-សោមា ហើយមានបំណងរៀបចំឡើងវិញរាជវង្សានុវង្សបូរាណ។ នៅក្នុងរជ្ជកាលព្រះបាទស្រីឥន្ទ្រវរ្ម័នទី៣ ពុទ្ធសាសនាបានទៅជាសាសនារបស់រដ្ឋ។ ព្រហ្មញ្ញសាសនាបានរក្សានៅស្ថានភាពរបស់ខ្លួននៅក្នុងពិធីសក្ការៈបូជានានានៅព្រះបរមរាជវាំង និងនៅតាមវត្តខ្លះៗ នៅតំបន់ឆ្ងាយៗ។ ព្រះបាទស្រីឥន្ទ្រវរ្ម័នទី៣ ក៏ជាពុទ្ធបរិស័ទមួយរូប។ នៅក្នុងរជ្ជកាលព្រះអង្គភាសាបាលីបានទៅជាភាសាផ្លូវការសម្រាប់ពុទ្ធសាសនាថេរវាទ ជំនួសភាសាសំស្រ្កឹតដែលធ្លាប់ត្រូវបានគេប្រើប្រាស់ពីមុនមក។ ស្ថានភាពខាងក្នុង និងក្រៅប្រទេសប្រកបដោយសេចក្តីសុខសាន្តត្រាណ។ បរិស័ទខាងសិវៈនិយមក៏គ្មាននរណាធ្វើទុក្ខបុកម្នេញ សង្រ្គាមក៏បានស្ងប់ស្ងាត់ ហើយបន្ទាប់ពីចម្បាំងមិនសម្រេចបំណងនាទសវត្សរ៍ទី៩ ជនជាតិសៀម ក៏គ្មានបំណងនឹងច្បាំងប្រឆាំងប្រជាជនខ្មែរទៀតដែរ។

ក៏ប៉ុន្តែ ស្ថានភាពក្នុងប្រទេសពុំទាន់មានស្ថិរភាពពេញលេញទេ ដោយហេតុថា ពួកតំណាងមជ្ឈដ្ឋានសិវៈនិយម ពិបាកកាត់ចិត្តពីទម្លាប់ចាស់របស់ខ្លួនក្នុងការប្រើប្រាស់អំណាច។ មិនតែប៉ុណ្ណោះ មហារាជខ្លះនៅនឹកស្រណោះដល់សម័យកាលនៃការគោរពបូជាទេវ-រាជា។ នៅឆ្នាំ១៣០៨ នៅពេលដែលព្រះបាទស្រីឥន្ទ្រវរ្ម័នទី៣ បានចេញទៅបំពេញផ្នួសនៅក្នុងវត្ត រដ្ឋអំណាចបានធ្លាក់ក្នុងកណ្តាប់ដៃព្រះបាទឥន្ទ្រាជ័យវរ្ម័ន (គ.ស.១៣០៨ - គ.ស.១៣២៧)។ ព្រះមហារាជអង្គនេះ បានចាប់ផ្តើមធ្វើការសាកល្បងជាចុងក្រោយ ដើម្បីរៀបចំឡើងវិញនូវលទ្ធិសិវៈនិយម

ដើម្បីឱ្យទៅជាសាសនារដ្ឋនៅក្នុងប្រទេស ដែលបណ្តារាស្ត្រសឹងទាំងអស់បានកាន់ព្រះពុទ្ធសាសនាទៅហើយ។ ព្រះអង្គមិនបានគិតគូរបន្ថយបន្តិចម្តងៗនូវឥទ្ធិពលនៃពុទ្ធសាសនាទេ ហើយបានសម្រេចចិត្តប្រើប្រាស់វិធានការតាមវិធីបង្ខិតបង្ខំ។ ដោយគ្មានកម្រិតដល់ការស្ថាបនាព្រះវិហារថ្មីៗខាងសិវៈនិយម និងដល់ការលំអព្រះវិហារមុនៗ សង់ឡើងក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៨។ ព្រះអង្គបានចាប់ផ្តើមឱ្យគេបំផ្លាញវត្តអារាម ខាងព្រះពុទ្ធសាសនា ហើយបានឱ្យគេធ្វើទុក្ខបុកម្នេញ ដល់ពុទ្ធបរិស័ទទាំងឡាយ។ នៅក្នុងរឿងនេះ ប្រមុខអ្នកកាន់សាសនាព្រះឥសូរ នាម ជ័យ-មង្គលរថៈ ដែលជាអតីតប្រមុខមនោគមវិជ្ជាក្នុងការរៀបចំឡើងវិញនូវលទ្ធិសិវៈនិយម តាំងពីក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី៨ មកម្ល៉េះ គឺជាអ្នកបំពេញតួនាទីដ៏សំខាន់។ គេអាចសន្និដ្ឋានបានថា បរាជ័យរបស់ព្រះបាទជ័យវរ្ម័នទី៨ ក្នុងកិច្ចការនេះបានបង្ខំជ័យ-មង្គលរថៈ និងអ្នកដឹកនាំលទ្ធិសិវៈនិយមដទៃទៀតឱ្យចាត់វិធានការដ៏តឹងតែងបំផុត ដើម្បីសម្រេចគោលដៅពីមុនមក។ ព្រះបាទជ័យវរ្ម័នទី៩ (គ.ស.១៣២៧ - គ.ស.១៣៣៦) ដែលបានឡើងសោយរាជសម្បត្តិបន្ទាប់ពីព្រះបាទឥន្ទ្រាជ័យវរ្ម័ន ក៏បានសាកល្បងបន្តនយោបាយបែបនេះ។ សិលាចារឹកត្រូវបានសរសេរជាថ្មីជាភាសាសំស្ក្រឹត អ្នកប្រាជ្ញខាងសិវៈនិយម ត្រូវបានអញ្ជើញពីប្រទេសឥណ្ឌា ឱ្យមកបំពេញមុខងារជាព្រះរាជគ្រូ។ ប្រាសាទព្រហ្មបាយ័ន ដែលជាបូជនីយដ្ឋានរបស់ពុទ្ធបរិស័ទបានទៅជាទីដៅនៃអំពើបំផ្លិចបំផ្លាញ។ អំពើទាំងអស់នេះបណ្តាលឱ្យមានចលនាប្រឆាំងពីសំណាក់នៃបណ្តាជនមួយភាគធំ។ ព្រះបាទ

ជ័យវរ្ម័នទី៩ ត្រូវបានរំលំ ហើយបើតាមឯកសារខ្លះ ព្រះអង្គត្រូវបានគេធ្វើឃាត។

ចលនាប្រឆាំងរបស់ប្រជាជនបាននាំរជ្ជបុរសពី " វណ្ណៈក្រោម " ឱ្យមកឡើងសោយរាជសម្បត្តិ។ នៅឆ្នាំ១៣៣៦ (កាលបរិច្ឆេទមិនសូវច្បាស់) រជ្ជបុរស នាមជ័យ (គ.ស.១៣៣៦ - គ.ស.១៣៤០) ឬព្រះបាទត្រសក់ផ្អែម ដែលគេសន្និដ្ឋានថា ជាអ្នកធ្វើឃាតព្រះមហារាជមុន បានឡើងកាន់កាប់រជ្ជអំណាច។ ដោយយោងតាមប្រពៃណីនៃពង្សាវតាខ្មែរ ព្រះបាទត្រសក់ផ្អែម បានទៅជាអ្នកបង្កើតរាជវង្សានុវង្សថ្មី ដែលកាន់តាមពុទ្ធសាសនាតទៅមុខទៀត។ នៅក្នុងរជ្ជកាលរបស់ព្រះបាទត្រសក់ផ្អែមរបបគ្រប់គ្រងរដ្ឋតាមរបៀបថ្មី ត្រូវបានរៀបចំឡើង សម្របសម្រួលទៅតាមមនោគមវិជ្ជា ដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃទស្សនវិជ្ជារបស់ព្រះពុទ្ធសាសនាថេរវាទ។

# ចំពូកទី៣
# ប្រទេសកម្ពុជា នៅភាគកណ្តាល
# នៃសតវត្សរ៍ទី១៤-ទី១៥

ដំណើរវិវត្តរដ្ឋអំណាចមកកាន់រាជវង្សានុវង្សថ្មី បានកំណត់នៅទីបញ្ចប់នៃវត្តមានរបស់ចក្រភព នាសម័យចុងក្រោយ។ ទសវត្សរ៍ទី២ - ទី៣ គឺជាសម័យកាលនៃស្ថិរភាពក្នុងនយោបាយក្រៅប្រទេសទាក់ទងនឹងរដ្ឋសៀម នានា និងប្រទេសដាយវៀត ព្រមទាំងប្រទេសចិន។ នៅពេលជាមួយគ្នា ការពង្រឹងស្ថានភាពរបស់អ្នកកាន់ពុទ្ធសាសនា បានបង្កើតឱ្យមាននិន្នាការពិសេសផ្សេងៗ មិនមែនសម្រាប់ដំណាក់កាលនៃចក្រភពទេ ប៉ុន្តែសម្រាប់ដំណាក់កាលតមកទៀតនៃការរីកចម្រើនរបស់ប្រទេស។ នៅក្នុងវិស័យវប្បធម៌ បាតុភូតនានាលេចចេញឡើង ហើយបានបង្ហាញឱ្យឃើញនូវការលូតលាស់នៃលក្ខណៈខ្មែរទាក់ទងនឹងការវិវត្តពីវប្បធម៌អភិជន មកកាន់វប្បធម៌ដែលប្រកបដោយលក្ខណៈប្រជាធិបតេយ្យជាង។

នៅក្នុងជីវភាពខាងសង្គមកិច្ច ជ័យជម្នះរបស់ពុទ្ធសាសនាថេរវាទ បានបង្កលក្ខណៈឱ្យមានការនិមន្តព្រះសង្ឃជាអ្នកប្រាជ្ញខាងពុទ្ធសាសនាពីប្រទេសស្រីលង្កា ឱ្យមានស្ថាបនកម្មវត្តអារាមខាងពុទ្ធសាសនា។ សិលាចារឹកតាមរបៀបថ្មី ក៏បានចាប់កំណើតឡើង គឺជាសិលាចារឹក ដែលមានទម្រង់ជាឯកសារខាងឃោសនា ដែលមានលក្ខណៈប្រជាជនជាងមុន ហើយបានបញ្ជាក់នូវអំណាចមិនសូវខ្លាំងក្លាពិសិដ្ឋរបស់មហាក្សត្រនៅក្នុង

ប្រទេស ដែលប្រកាន់តាមពុទ្ធសាសនាថេរវាទ។ គឺតាមជំនឿរបៀបថ្មីនេះហើយ ដែលមានចារឹកនូវកាលប្រវត្តិ ឬពង្សាវតាខ្មែរនាសម័យនោះ ហើយរបៀបចារឹកនេះ បានទទួលឥទ្ធិពលជាច្រើនពីប្រទេសស្រីលង្កា។ នៅសតវត្សរ៍ជាមួយគ្នា មិនមែនជាភាពចៃដន្យទេ ដែលជនជាតិសៀម បានទទួលឥទ្ធិពលពីជនជាតិខ្មែរ និងមន ក្នុងរបៀបចារឹកកាលប្រវត្តិនៅចុងសតវត្សរ៍ទី ១៣ - ទី១៤។ ឥទ្ធិពលខ្មែរទៅលើជនជាតិសៀម មានទាំងក្នុងវិស័យទំនៀមទម្លាប់ខាងពុទ្ធសាសនា អក្ខរាវិធី ច្បាប់ព្រហ្មទណ្ឌ របៀបស្ថាបនកម្មក្បាច់រចនាខាងនិម្មាបនកម្ម និងចម្លាក់សិល្បៈរបាំព្រះរាជទ្រព្យ និងដទៃទៀត។

នៅក្នុងវប្បធម៌នាសតវត្សរ៍ទី១៥-ទី១៦ ប្រពៃណីពីសម័យកាលចក្រភពបានបន្តការរីកចម្រើន ដោយគ្មានទទួលឥទ្ធិពលណាមួយពីខាងក្រៅ។ នៅតាមប្រាសាទ និងព្រះវិហារបូរាណខ្លះខាងព្រហ្មញ្ញសាសនា និងពុទ្ធសាសនា គេបានបន្ថែមក្បាច់រចនាចម្លាក់រូបសំណាកធ្វើពីឈើថ្មីៗ និងវត្ថុជាគ្រឿងសក្ការៈបូជាដទៃ។

រដ្ឋធានីយសោធរៈបុរៈ (អង្គរធំ) បានស្ថិតនៅជាមជ្ឈមណ្ឌលនៃជីវភាពវប្បធម៌ នៅក្នុងសម័យកាលនៃរាជវង្សានុវង្សថ្មី។ ក៏ប៉ុន្តែប្រសិទ្ធភាពនៃបាតុភូតខាងសង្គមកិច្ចថ្មីៗ មិនមែនកើតមានឡើងនៅក្នុងតំបន់ជាជង្រុកស្រូវនានានៅទិសខាងលិចទេ គឺបានកើតមានឡើងនៅតំបន់បូរាណនៅទិសខាងបូព៌ា ដែលស្ថិតនៅរវាងទន្លេមេកុង និងបឹងទន្លេសាប។ តំបន់ដីទំនាបតាមទន្លេមេកុងដែលនៅទីនេះ កាលមុន សម្បត្តិបម្រុងដីធ្លីត្រូវបានប្រើប្រាស់តាមរបៀបបូរាណដោយកសិករខ្មែរនាសតវត្សរ៍ទី១៤ នៅសតវត្សរ៍ក្រោយមក មិនបានទៅជាមជ្ឈមណ្ឌលនៃការលូតលាស់ខាង

វប្បធម៌ នយោបាយ និងសេដ្ឋកិច្ចទេ។ តំបន់ដីទំនាបប្រកបដោយការរីកចម្រើនជាងគេ គឺតំបន់ដីទំនាបនានា ដែលស្ថិតនៅខាងជើង ហើយជិតមកខាងទីក្រុងភ្នំពេញ ហើយតំបន់ជិតមាត់សមុទ្រនានា ដែលកាលពីដើម ជាភូមិភាគដ៏សំខាន់ៗរបស់ប្រទេស បានស្ថិតនៅតំបន់ឆ្ងាយដាច់ស្រយាល។

ស្ថានភាពចុះឱនថយនៃរដ្ឋធានីយសោធរបុរៈ បានបន្ទាញឱ្យមានាការចុះអន់ថយ នៃឥទ្ធិពលរបស់បព្វជិតកាន់សាសនាព្រះឥសូរ ហើយស្ថានភាពបែបនេះមានទំនាក់ទំនងនឹងពួកអភិជនសក្តិភូមិនៅរដ្ឋធានី ដែលមានទ្រព្យសម្បត្តិខាងដីធ្លីនៅទីនោះ។ ក្នុងកិច្ចការពារយ៉ាងរឹងមាំនូវព្រំប្រទល់របស់ប្រទេស ដែលបានប្រែត្រឡប់ជាប្រទេសប្រកបដោយប្រជាជនខ្មែរតែមួយ គណៈដឹកនាំប្រទេស កាន់តែយល់ច្បាស់នូវភាពចាំបាច់ក្នុងការស្វែងរកការកសាងរដ្ឋធានីថ្មីនៅក្នុងមជ្ឈមណ្ឌលសេដ្ឋកិច្ច គឺជារដ្ឋធានីដែលប្រកបដោយលក្ខណៈសម្បត្តិប្រហាក់ប្រហែលនឹងរដ្ឋធានីអង្គរពីពេលមុនការហួតហែងដីស្រែចម្ការនៅទីនោះ ។មជ្ឈមណ្ឌលថ្មីបែបនេះ គឺជាតំបន់ដីត្រីកោណ (លង្វែក -ឧត្តុង្គ -ភ្នំពេញ) ដែលស្ថិតនៅខាងបូព៌ានៃបឹងទន្លេសាប។ ការវិវត្តក្នុងការស្វាបស្វង់រកមជ្ឈមណ្ឌលនៃការលូតលាស់ខាងសេដ្ឋកិច្ច និងនយោបាយរបស់ប្រទេសបានប្រព្រឹត្តទៅអស់អំឡុង១០០ឆ្នាំ។

នៅសតវត្សរ៍ទី១៤ ជាទូទៅ នយោបាយក្រៅប្រទេសបានបង្កលក្ខណៈដ៏ប្រសើរសម្រាប់ប្រទេសកម្ពុជា។ ប្រទេសកម្ពុជាស្ថិតនៅជារដ្ឋដ៏ខ្លាំងក្លាដដែល ប្រទេសជិតខាងនៅទិសខាងលិចនៅតែទន់ខ្សោយ ហើយមិនអាចធ្វើចម្បាំងនឹងប្រទេសកម្ពុជាបានឡើយ។ គឺទាល់តែនៅសម័យក្រោយមក បន្ទាប់ពីបាន

ក្រេបជញ្ជក់យកឥទ្ធិពលមន និងខ្មែរ ខាងរបបគ្រប់គ្រងរដ្ឋ និងខាងរបៀបកៀបសង្កត់តាមលក្ខខណ្ឌនានានៃស្រុកអាយ ទើបរដ្ឋសៀម និងឡាវ នានា បានចាប់ផ្តើមបំពេញតួនាទីដ៏សកម្មនៅក្នុងឆាកប្រវត្តិសាស្ត្រ ហើយក្លាយទៅជាគូប្រឆាំងនឹងប្រទេសកម្ពុជា។

ក្នុងការសិក្សាវិនិច្ឆ័យប្រវត្តិសាស្ត្រខាងយោធា នាសម័យពាក់កណ្តាលនៃសតវត្សរ៍ទី១៤ ត្រូវតែកត់សម្គាល់ថា ចម្បាំងរវាងរដ្ឋ និងរដ្ឋ ភាគច្រើន បានកើតមានមកពីផលវិបាកនៃទំនាស់ និងការប្រយុទ្ធរវាងគ្នាឯងនៅក្នុងប្រទេស ហើយការប្រយុទ្ធបែបនេះតែងតែកើតមានឡើងមុន រួចហើយបានទាក់ទាញនូវសត្រូវពីខាងក្រៅ។ គឺមិនមែនជាភាពចៃដន្យទេ ដែលបន្ទាប់ពីទំនាស់ និងការប្រយុទ្ធគ្នា រវាងព្រះមហាក្សត្រប្រកាន់តាមសិរៈនិយម និងអ្នកប្រឆាំងរបស់ខ្លួន បណ្តាលឱ្យមានការផ្លាស់ប្តូរវេននៃរាជវង្សានុវង្ស ដែលជាហេតុធ្វើឱ្យប្រទេសខ្មែរមានការប្រេះឆា។ រួចបន្ទាប់ពីពេលនោះ២០ឆ្នាំ សភាពការណ៍បានបើកផ្លូវឱ្យកងកម្លាំងទ័ពសៀម ដែលទើបនឹងបានរឹងមាំអាចចូលមកធ្វើការវាយលុកដោយជោគជ័យ។

បណ្តាមហាក្សត្រជាបឋមនៃរាជវង្សានុវង្សថ្មី មានព្រះបាទត្រសក់ផ្អែម និងព្រះបាទនិព្វានបទ ដែលរវល់ជាប់ដៃនឹងការប្រយុទ្ធផ្ទៃក្នុង ព្រមទាំងការរៀបចំរដ្ឋបាលមជ្ឈិមថ្មី ព្រោះថា រដ្ឋបាលចាស់ជាចន្ទល់របស់ពួកគូប្រឆាំងនឹងព្រះអង្គ។ មហាក្សត្រទាំងពីរអង្គពុំបានរៀបចំការតទល់ប្រឆាំងនឹងស្ថានភាពប្រេះឆានៃដែនដីចក្រភព ជាចុងក្រោយនានា នៅតាមទន្លេចៅ-ប្រយ៉ា

ហើយប្រឆាំងនឹងស្ថានភាពប្រេះឆារបស់រដ្ឋសៀម និងឡាវនានា ដែលចូលរួមក្នុងចក្រភព។

សភាពការណ៍ជាតុល្យការ នៅភាគទីពីរនៃសតវត្សរ៍ទី១៤ បានប្រព្រឹត្តទៅ ដោយការបញ្ចប់ការប្រយុទ្ធផ្ទៃក្នុង ដោយការរៀបចំសង្គមខ្មែរឡើងវិញ និងដោយការបាត់បង់នូវទម្លាប់ចាស់បូរាណនៃសម័យចក្រភព។ ស្ថានភាពខាងសង្គម-សេដ្ឋកិច្ចនៅលើទឹកដីខ្មែរ មិនបានផ្លាស់ប្តូរប៉ុន្មានទេ ទោះបីតំបន់ជាជម្រុកស្រូវនៅទិសខាងលិច បានទៅជាតំបន់ក្រីក្របន្តិចក្តី។ នៅភាគកណ្តាលនៃសតវត្សរ៍ទី១៤ អ្នកនិពន្ធឈ្មោះ វ៉ាន់-ដាយ៉ន់ បានសរសេរអំពី “ ប្រទេសកម្ពុជា ដ៏សម្បូរសប្បាយ ” អំពី “ ប្រទេសប្រកបដោយព្រះវិហាររាប់រយ ”។

ទំនាក់ទំនងខាងកសិកម្មនាសតវត្សរ៍ទី១៤ បានលូតលាស់ទៅតាមលម្អាននៃទំនាក់ទំនងនាសតវត្សរ៍ទី១៣។ តាមឯកសារនានា ដែលបានពណ៌នាអំពីរបរកសិកម្ម មានការរំលឹកអំពីដីដំណាំ ដែលស្ថិតនៅតាមស្រុកតាមភូមិ និងតាមស្រែទាំងឡាយ។

វណ្ណៈអភិជនថ្នាក់កំពូល បានប្រែរូបរាងតាមទម្រង់ថ្មីៗ ហើយអំណាចមហាក្សត្រ បានខិតមកជិតវណ្ណៈសក្តិភូមិថ្នាក់មធ្យម និងតូចតាច ដែលជាពពួកនាហ្មឺនបម្រើរាជការ និងបណ្តារាស្ត្រ។ ពិធីសក្ការៈបូជាទេវ-រាជាដ៏ខ្ពង់ខ្ពស់ សឹងបានបាត់បង់ទាំងអស់ មហាក្សត្រលែងដើរតួជាអាផ្នាកណ្តាលរវាងអាទិទេព និងមនុស្សលោក។ មុខងារដ៏ពិសិដ្ឋរបស់ពួកព្រាហ្មណ៍បរោហិតនៅបរមរាជវាំង ត្រូវបានកម្រិតឱ្យនៅតិចតួចបំផុត។ ពុទ្ធសាសនាថេរវាទ បានពង្រឹងជំហររបស់ខ្លួន នៅក្នុងប្រទេស អក្សរសាស្ត្រសំស្ក្រឹតត្រូវបានជំនួសសឹងទាំងអស់ ដោយអក្សរ

សាស្ត្រជាភាសាបាលី ដែលអ្នកស្រុកទូទៅ ចេះដឹងច្រើន។ រូបចម្លាក់ព្រះពុទ្ធធ្វើអំពីឈើប្រកបដោយកម្រិត នៃក្បាច់រចនាដ៏ខ្ពស់ ក៏មិនអន់ជាងរូបបដិមាព្រះពុទ្ធធ្វើអំពីថ្ម ហើយមិនតែប៉ុណ្ណោះ រូបចម្លាក់ឈើមានចំនួនច្រើនជាងរូបចម្លាក់ថ្ម។ ភាពផ្លាស់ប្តូរទាំងអស់នេះ ត្រូវបានរក្សាទុកមកអស់មួយសតវត្សរ៍ ហើយពេលវេលាបានបញ្ជាក់នូវភាពត្រឹមត្រូវ និងវាសនាអនាគតនៃការផ្លាស់ប្តូរនេះ។

នៅសម័យខាងដើមនៃទសវត្សរ៍ទី៥ បណ្តារដ្ឋតូចតាចសៀមទាំងឡាយ បានបង្រួបបង្រួមគ្នាជារដ្ឋធំខ្លាំងមួយ មានឈ្មោះថារដ្ឋអយុធ្យា (ប្រទេសសៀម)។ នៅភាគទីពីរនៃសតវត្សរ៍ទី១៤ រដ្ឋនេះបានចាប់ផ្តើមធ្វើសកម្មភាពចម្បាំងមកខាងទិសបូព៌ា។ ក៏ប៉ុន្តែ ក្នុងចម្បាំងទាំងនេះ រដ្ឋអយុធ្យា គ្មានបានចំណេញអ្វីឡើយ។ ជាលើកទីមួយនៅក្នុងប្រវត្តិសាស្ត្ររបស់ប្រជាជនខ្មែរ ចម្បាំងរាំងជល់ទាំងនេះបានកើតមានឡើងនៅលើទឹកដីខ្មែរផ្ទាល់។ តាំងពីដើមទីមក(គឺពី គ.ស. ១៣៥០) ការទាក់ទងរវាងរដ្ឋអយុធ្យា និងប្រទេសកម្ពុជា មានសភាពតានតឹង ហើយការបង្រួបបង្រួមរដ្ឋសៀម នានា មានគោលដៅដើម្បីតទល់នឹងគូប្រឆាំងខ្លាំងក្លារបស់ខ្លួន គឺប្រជាជនខ្មែរ។ នៅឆ្នាំ១៣៥១ កងទ័ពសៀម ពីរកងបានចាប់ផ្តើមធ្វើការវាយលុកដ៏ធំជាលើកទី១។ បន្ទាប់ពីការវាយលុកលើបន្ទាយខ្មែរនានានៅតាមព្រំប្រទល់ខាងលិច ពួកសៀម បានវាយលុកចូលក្នុងប្រទេសកម្ពុជា។ ការសាកល្បងវាយលុកចូលរដ្ឋធានីយសោធរបុរៈ (អង្គរធំ) បានទទួលបរាជ័យ។ តមក កងទ័ពសៀម បានដកខ្លួនថយទៅវិញ។ ប៉ុន្តែ នៅពេលនោះ ព្រះបាទស្រីលំពង្សរាជា (គ.ស.

១៣៤៦-គ.ស.១៣៥២) ដែលគ្រប់គ្រងប្រទេសកម្ពុជា បាន ធ្វើកំហុសដ៏ធ្ងន់ធ្ងរមួយ ដោយមិនបានយល់ច្បាស់នូវទំហំនៃ គ្រោះថ្នាក់ ដែលអាចកើតមាន ដោយបណ្ដារដ្ឋសៀម ដែលបាន រួបរួមគ្នា។ ព្រះអង្គបានរំសាយកងកម្លាំងទ័ពខ្មែរ ហើយបាន បដិសេធកម្មវិធីកំណែនកងទ័ព។ ជាពិសេស គឺនៅពេលនោះ ហើយ ដែលកងកម្លាំងទ័ពសៀម ថ្មីមួយទៀត បានចេញដំណើរ មកបង្រួមកម្លាំងគ្នានឹងកងទ័ពសៀម ទាំងពីរកង ដែលបាក់ទ័ព ហើយបានចាប់ផ្ដើមធ្វើការឡោមព័ទ្ធរដ្ឋធានីខ្មែរ ជាថ្មី។ ដូចជា ក្នុងអតីតកាលដែរ គោលដៅរបស់កងទ័ពសៀម គឺការវាយ ដណ្ដើមយករដ្ឋធានី ក៏ប៉ុន្តែ កងទ័ពសៀមទាំងនេះ មិនអាចធ្វើ ចលនាទៅមុខទៀតបាន។ តំបន់ជាជង្រុកស្រូវនៅទិសខាងលិច ស្ថិតនៅជាទីពំនឹងដ៏រឹងមាំ សម្រាប់ការវាយតបវិញរបស់កងទ័ព ខ្មែរ និងសម្រាប់ការរំដោះរដ្ឋធានីយសោធរបុរៈ។

ការឡោមព័ទ្ធរដ្ឋធានី (ដែលមានបណ្ដាជន ជិត ២០០.០០០នាក់) បានប្រព្រឹត្តទៅអស់អំឡុងពេលមួយឆ្នាំ។ នៅពេលនោះ ព្រះបាទស្រីលំពង្សរាជា បានសោយទិវង្គត ហើយ រាជសម្បត្តិ បានធ្លាក់មកក្នុងកណ្ដាប់ដៃព្រះបាទសុរិយោទ័យ ដែលជាព្រះអនុជរបស់ព្រះអង្គ។ នៅពេលដែលកងកម្លាំងសៀម ទាំងអស់ ក្រោមកិច្ចបញ្ជាការរបស់មហាក្សត្រសៀម នាមរាមា ធិបតី បានឡោមព័ទ្ធរដ្ឋធានី។ នៅក្នុងរដ្ឋធានីមានជំងឺរាតត្បាត នានាកើតឡើង។ កងទ័ពខ្មែរខិតខំសាកល្បងបំបាក់ការឡោម ព័ទ្ធរបស់កងទ័ពសៀម ពីខាងក្រៅ។ ប៉ុន្តែ ការសាកល្បងទាំង នេះមិនបានសម្រេច។ តមក កងទ័ពខ្មែរបានដកខ្លួនថយទៅ ក្នុងខេត្តជិតខាង។ រួចនៅពេលជាបន្ទាប់មក ពួកសៀម បាន

វាយទម្លាយរបាំងការពារច្រកចូលខាងបូព៌ានៃអង្គរធំ។ ការប្រយុទ្ធគ្នាបានប្រព្រឹត្តទៅ នៅក្នុងផ្ទៃរដ្ឋធានីអស់រយៈពេលពីរបីថ្ងៃ។ ព្រះបាទសុរិយោទ័យ បានបាត់បង់ព្រះជន្មាយុក្នុងការប្រយុទ្ធតទល់សត្រូវនៅសមរភូមិ កងទ័ពខ្មែរ ក៏បានដកខ្លួនចេញពីរដ្ឋធានី។ ព្រឹត្តិការណ៍នេះបានកើតមានឡើងនៅឆ្នាំ១៣៥៣ អ្នកទីក្រុងរាប់ម៉ឺននាក់ត្រូវបានកងទ័ពសៀម ជម្លៀសនាំទៅទីក្រុងអយុធ្យា។ នៅក្នុងរដ្ឋធានីអង្គរធំ ពួកសៀម បានតាំងកងកម្លាំងរបស់ខ្លួនមួយចំនួន ឱ្យស្ថិតនៅក្រោមកិច្ចបញ្ជាការរបស់ព្រះអង្គម្ចាស់សៀម មួយរូប។ ប៉ុន្តែពួកសៀម មិនអាចស្ថិតនៅទីនោះបានយូរទេ។ នៅឆ្នាំ១៣៥៧ កងទ័ពខ្មែរ ក្រោមកិច្ចបញ្ជាការរបស់ព្រះបាទសុរិយោវង្ស (គ.ស.១៣៥៧-១៣៦៣) ជាព្រះរាជអនុជរបស់ព្រះបាទស្រីលំពង្សរាជា បានវាយកម្ទេចកងកម្លាំងសៀម ដែលស្ថិតនៅក្នុងរដ្ឋធានី។ មហាក្សត្រខ្មែរបានយាងជាឱឡារិកចូលមករដ្ឋធានី។ ដូចពេលមុន ទឹកដីខ្មែរទាំងអស់ត្រូវស្ថិតនៅគង់វង្សដដែល។ ការវាយលុករបស់ពួកសៀម ត្រូវបានបញ្ចប់ដោយគ្មាននរណាឈ្នះចាញ់។

ព្រះបាទបរមរាមា ជាក្មួយរបស់ព្រះបាទសុរិយោវង្ស បានឡើងសោយរាជសម្បត្តិបន្តមក (គ.ស.១៣៦៣-គ.ស.១៣៧៣)។ នៅពេលនោះ ពួកសៀម ប្រហែលទទួលការខូចខាតច្រើននៅឱកាសនៃការធ្វើចម្បាំង បានបញ្ឈប់មួយគ្រានូវការវាយលុករបស់ខ្លួន។ ប្រទេសកម្ពុជា ក៏មិនបានធ្វើការវាយលុកប្រឆាំងនឹងក្រុងអយុធ្យា វិញដែរ។ នៅឆ្នាំ១៣៧៣ ព្រះបាទធម្មាសោក (គ.ស.១៣៧៣-គ.ស.១៣៩៣) ជាព្រះរាជអនុជព្រះបាទបរមរាមា បានឡើងសោយរាជសម្បត្តិបន្ត។ គេមិនសូវដឹងច្បាស់អំពី

ព្រឹត្តិការណ៍ទាំងឡាយនៅក្នុងរជ្ជកាលព្រះអង្គ ទោះបីតាមព័ត៌មានខ្លះ ព្រះអង្គបានលើកទ័ពទៅវាយអយុធ្យា។

នៅឆ្នាំ១៣៩៣ គឺជិតពាក់កណ្ដាលសតវត្សរ៍បន្ទាប់ពីការវាយលុករបស់កងទ័ពសៀម ជាលើកទីមួយ កងទ័ពក្រុងអយុធ្យាបានវាយលុកម្ដងទៀតចូលក្នុងអង្គរធំ ហើយជាថ្មីម្ដងទៀត គេបានឃើញច្បាស់នូវអត្ថិភាព និងភាពខ្វះខាតនៃកងទ័ពទាំងសងខាង។ កងទ័ពសៀម បានសម្រេចជោគជ័យក្នុងការវាយលុកលើកទីមួយ។ ជាថ្មី ការប្រយុទ្ធគ្នាបានប្រព្រឹត្តទៅតាមវិថីនៃរដ្ឋធានី។ ជាថ្មីម្ដងទៀត មហាក្សត្រខ្មែរបានបាត់បង់ជន្មាយុក្នុងការប្រយុទ្ធតទល់គ្នានៅសមរភូមិ។ ក៏ប៉ុន្តែ កងទ័ពសៀម មិនអាចពង្រឹងស្ថានភាពរបស់ខ្លួននៅប្រទេសកម្ពុជា ទោះបីក្នុងរយៈពេលដ៏ខ្លីក្ដី ដូចលើកទីមួយ។ កងទ័ពមួយភាគត្រូវបានដកខ្លួនថយក្រោយ ដោយកៀរយកទាំងអ្នកស្រុករាប់ម៉ឺននាក់ ដើម្បីធ្វើជាឈ្លើយសង្គ្រាម។ រួចបន្ទាប់ពីពេលពីរបីខែក្រោយមក កងទ័ពខ្មែរ ក្រោមបញ្ជាការរបស់ព្រះបាទសុរិយោវង្សទី២ ឬព្រះបាទចៅពញា (គ.ស.១៣៩៤-គ.ស.១៤០៤) ជាព្រះរាជបុត្ររបស់ព្រះបាទសុរិយោទ័យ បានវាយកម្ទេចកងទ័ពសៀម។ នៅពេលប្រយុទ្ធគ្នា មេទ័ពសៀមត្រូវស្លាប់ ហើយកងទ័ពដែលនៅសល់ ត្រូវកងទ័ពខ្មែរឡោមព័ទ្ធចាប់បានទាំងអស់។ កាលនោះ ព្រះបាទចៅពញា បានប្រមែប្រមូលទ័ពខ្មែរ នៅស្រុកស្រីសន្ធរ ដែលបានទៅជារដ្ឋធានីខ្មែរក្នុងមួយគ្រានោះ។ នៅក្នុងរជ្ជកាលរបស់ព្រះបាទចៅពញា ការតស៊ូបានប្រព្រឹត្តទៅ ដើម្បីបំបាត់សំណល់កងទ័ពសៀមដែលស្ថិតនៅលើទឹកដីខ្មែរ។ បន្ទាប់ពីពេលដែលព្រះអង្គបានចូលទិវង្គតទៅ ព្រះបាទពញាយ៉ាត ជាបុត្រព្រះបាទសុរិយោទ័យ

(គ.ស.១៤០៥-១៤៦៧) បានឡើងគ្រងរាជ្យស្នងព្រះអង្គ។

នៅក្នុងរជ្ជកាលព្រះបាទពញាយ៉ាត ប្រទេសទាំងមូលត្រូវបានសំអាតជ្រះស្រឡះពីសំណល់នៃកងទ័ពសៀម។ នៅក្នុងការតស៊ូរំដោះរដ្ឋធានីយសោធរបុរៈ ប្រជាជនខ្មែរបានក្រោកឈរប្រកបដោយអាវុធនៅដៃ ហើយបានផ្ដល់ការគាំទ្រដល់កងទ័ពខ្មែរទាំងឡាយ។ ជ័យជម្នះរបស់ប្រជាជនខ្មែរម្ដងនេះ បានផ្ដល់លទ្ធភាពដល់ប្រទេសឱ្យពង្រីកទំនាក់ទំនងជាមេត្រីភាពជាមួយបណ្ដាប្រទេសជិតខាងអស់ពេលដ៏យូរមក។ ព្រះបាទពញាយ៉ាតបានទទួលពិធីអភិសេកដ៏ឱឡារិក ជាមហាក្សត្រប្រទេសកម្ពុជានៅរដ្ឋធានីយសោធរបុរៈ។

ស្ថានភាពខាងសេដ្ឋកិច្ចនៅតំបន់ខាងលិចប្រទេស ចេះតែចុះអន់ថយតទៅទៀត ជាពិសេស ដោយសារផលវិបាកកើតមកអំពីចម្បាំងរាំងជល់អស់ពេលដ៏យូរ និងដោយសារការហួតហែងដីស្រែចម្ការនៅទីនោះ។ សភាពការណ៍ទាំងនេះ បណ្ដាលឱ្យអ្នកស្រែចម្ការចាកចេញពីទីកន្លែងរបស់ខ្លួន។ ឯកសារនានាបានឱ្យព័ត៌មាន អំពីសេចក្ដីវិនាសអន្តរាយកើតឡើងដោយចម្បាំង។ ប៉ុន្តែ គេអាចសន្និដ្ឋានម្យ៉ាងទៀតថា ការវាយលុករបស់ពួកសៀមមានគោលដៅ ដើម្បីធ្វើឱ្យខ្សោយដល់តំបន់ជាជង្រុកស្រូវ របស់រដ្ឋធានីខ្មែរ ហើយគោលបំណងនេះបានសម្រេច។ ស្ថានភាពខាងសេដ្ឋកិច្ចដ៏ទន់ខ្សោយនៅតំបន់ជាជង្រុកស្រូវនេះ បានបង្កើតឱ្យមានស្ថានភាពដ៏លំបាកលំបិននៅរដ្ឋធានីអង្គរ។ ហេតុនេះហើយ បានជាដូចប្រវត្តិសាស្ត្រប្រទេសនៅសតវត្សរ៍ក្រោយៗមកបានបញ្ជាក់ជាភស្តុតាងស្រាប់ ព្រះបាទពញាយ៉ាត ឈ្វេងយល់ដ៏ត្រឹមត្រូវក្នុងសេចក្ដីសម្រេចផ្លាស់ទីតាំងរដ្ឋធានី ពីតំបន់ចាស់

មកកាន់តំបន់ខាងកើតបឹងទន្លេសាប វិញ គឺជាតំបន់សម្បូរដោយដីស្រែចម្ការ។ ម្យ៉ាងវិញទៀត ព្រះអង្គបានយោងទៅតាមមូលហេតុថា បណ្ដាជនកាន់តែមានចំនួនតិចទៅនៅតំបន់រដ្ឋធានីរបស់ចក្រភព។ នៅក្នុងញ្ហានេះ គេមិនគិតដល់តែអំពីរដ្ឋធានីអង្គរទេ (បើវិនិច្ឆ័យ ទៅតាមការរួបរួមរបស់អ្នកទីក្រុង ក្នុងចម្បាំងរំដោះរដ្ឋធានី និងតាមឯកសារស្ដីអំពីបណ្ដាជននៅរដ្ឋធានី នាសតវត្សរ៍ទី១៦ ឃើញថា មានបណ្ដាជនមិនតិច ដែលបានរស់នៅអង្គរ) ប៉ុន្តែ គេត្រូវគិតដល់ស្ថានភាពដីនៅតំបន់ដែលស្ថិតនៅតាមដងស្ទឹងសៀមរាប។ ដូចជា ព្រះបាទជ័យវរ្ម័នទី២ ព្រះបាទពញាយ៉ាត ពុំបានរកឃើញភ្លាមនូវទីកន្លែងសម្រាប់រដ្ឋធានីថ្មីទេ។ បន្ទាប់ពីការស្នាក់អាស្រ័យនៅស្រុកស្រីសន្ធរ នាឆ្នាំ១៤៣៣ ព្រះបាទពញាយ៉ាត បានយាងទៅគង់នៅតំបន់ចតុមុខ (គឺភ្នំពេញ សព្វថ្ងៃ)។ រដ្ឋធានីយសោធរបុរៈ ប្រកបដោយមហាកំពែងដ៏រឹងមាំ ត្រូវបានគេហៅថា ជាទីក្រុងអង្គរ ហើយបានប្រែទៅជាកំពែងការពារប្រទេសនៅទិសខាងលិច និងជាមជ្ឈមណ្ឌលនៃបូជនីយដ្ឋានរបស់ប្រទេស។

សិលាចារឹកសម័យសតវត្សរ៍ទី១៥ ត្រូវបានចារឹកឡើងនៅតំបន់នៃរដ្ឋធានីថ្មី។ នៅទីនេះ មានការចែករំលែកដីដល់អ្នកស្រុកឱ្យសង់លំនៅដ្ឋាន។ នៅតាមព្រះវិហារចាស់ៗខាងព្រហ្មញ្ញសាសនា រូបបដិមាព្រះពុទ្ធក៏បានលេចឡើងជំនួសរូបបដិមាចាស់ៗ។ ពុទ្ធសាសនាបានទទួលជ័យជម្នះទាំងនៅក្នុងបរមរាជវាំង ពុទ្ធបរិស័ទចាប់ផ្តើមនិពន្ធនូវពង្សាវតាររបស់ប្រទេស ដោយយោងទៅតាមទស្សនៈខាងពុទ្ធនិយម។ គួរកត់សម្គាល់ថា នៅពេលនោះ មហាក្សត្របានរក្សាទុកនូវមុខងារជាប្រមុខសាសនារបស់រដ្ឋ។

ការផ្លាស់ប្តូរទីកន្លែងនៃរដ្ឋធានី និងស្ថាបនកម្មរដ្ឋធានីថ្មី តម្រូវឱ្យមានការប្រើប្រាស់ពេលវេលាដ៏យូរ រាប់សតវត្សរ៍សម្រាប់កិច្ចរៀបចំតម្រែតម្រង់អង្គការ និងស្ថាប័នរដ្ឋជាថ្មី និងសម្រាប់កិច្ចរៀបចំនានាក្នុងវិស័យសង្គម-សេដ្ឋកិច្ច និងយោធា។ ដូចជាអតីតរដ្ឋធានីយសោធរបុរៈ ភ្នំពេញ មិនមែនជាទីក្រុងសំខាន់សង់ហើយស្រេចទេ ប៉ុន្តែ ត្រូវតែមានលក្ខណៈជារដ្ឋធានីពេញលេញ ទោះបីទស្សនៈនៃពុទ្ធសាសនាថ្មី មិនបានទាមទារឱ្យមានស្ថាបនកម្មព្រះវិហារដ៏ធើតធាយសម្រាប់ពិធីសក្ការៈបូជា ទេវ-រាជាក៏ដោយ។ ដូច្នេះហើយ បន្ទាប់ពីបានកសាងសន្តិភាពប្រទេសដោយការពង្រឹងនយោបាយក្រៅប្រទេស ព្រះបាទពញាយ៉ាតបានចាប់ផ្តើមកសាងទីក្រុង។ ដូចជាអតីតរដ្ឋធានី យសោធរបុរៈគេបានកសាងកំពែង ជីកព្រែក និងប្រឡាយទឹក កសាងវត្តអារាម។ ទីក្រុងដទៃទៀតនៅក្នុងប្រទេស ក៏មានការកសាងបែបដូចគ្នា។

នៅក្នុងរជ្ជកាលព្រះបាទពញាយ៉ាត ទំនាក់ទំនងខាងពាណិជ្ជកម្មជាមួយប្រទេសចិន ត្រូវបានបន្តទៅទៀត។ ប្រទេសកម្ពុជា បានតែងតាំងស្ថានទូតរបស់ខ្លួននៅប្រទេសនេះ និងនៅប្រទេសដទៃនៅអាស៊ីអាគ្នេយ៍។ ចរាចរណ៍តាមផ្លូវទឹក ក៏ត្រូវបានពង្រីកតាមទន្លេមេកុង។ ការទាក់ទងជាមួយប្រទេសចម្ប៉ា នៅពេលនោះ ប្រកបដោយភាពសុខសាន្ត។ បន្ទាប់ពីពេលចម្បាំងជាមួយរដ្ឋសៀម និងបន្ទាប់ពីពេលរៀបចំតាក់តែងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ប្រទេសកម្ពុជាសក្តិភូមិត្រូវបានកសាងឡើង ដោយការពង្រឹងព្រំប្រទល់ និងអង្គការគ្រប់គ្រងរដ្ឋតាមរបៀបថ្មី។ រដ្ឋអំណាចរបស់ប្រទេសបានប្រែប្រួលទៅជារដ្ឋអំណាច ដែលស្ថិតនៅក្នុងកិច្ចគ្រប់គ្រងរបស់ពួកមន្ត្រីជាគ្រហស្ថ និងយោធា។ ស្ថាប័នរដ្ឋ

នានាក៏ត្រូវបានពង្រឹង។ នៅតំបន់ដាជង្រុកស្រូវខាងលិចប្រទេស តួនាទីរបស់ទីក្រុងនានាបានចុះអន់ថយ ហើយតំបន់បានប្រែបន្តិចម្តងៗ ទៅជាតំបន់កសិកម្ម ជាពិសេសគឺតំបន់ភាគខាងលិច ដែលនៅទីនេះ មានទីក្រុងបាត់ដំបង កំពុងលូតលាស់។

នៅឆ្នាំ១៤៦៧ ព្រះបាទពញាយ៉ាត បានចាកចេញពីរាជសម្បត្តិ ហើយបានផ្ទេររាជសម្បត្តិនេះដល់រាជបុត្រច្បងរបស់ព្រះអង្គ គឺព្រះបាទរាមាធិបតី (គ.ស.១៤៦៧-១៤៧២) ដែលស្ថិតនៅក្នុងរាជសម្បត្តិមិនយូរប៉ុន្មាន ដោយហេតុថា ព្រះអង្គមានព្រះជន្មាយុច្រើននៅពេលឡើងគ្រងរាជ្យ។ ក្នុងអំឡុងពីរបីឆ្នាំក្រោយមក ព្រះបាទពញាយ៉ាត បានសោយទិវង្គត ហើយព្រះធាតុព្រះអង្គ ត្រូវបានបញ្ចុះនៅក្នុងមហាចេតិយលើភ្នំដូនពេញ ដែលនៅទីនោះ មានទាំងរូបបដិមាព្រះពុទ្ធដ៏បូរាណមួយអង្គ។ នៅពេលនោះ ការស្ថាបនាព្រះវិហារចេតិយដែលជាប្រពៃណីនៃស្ថាបនកម្មនាសម័យរដ្ឋធានីអង្គរ ត្រូវបានអនុវត្តតទៅទៀត។ នៅឆ្នាំ១៤៧២ ព្រះបាទស្រីរាជារាមាធិបតី (គ.ស.១៤៧២-គ.ស. ១៤៧៣) ជារាជបុត្រពៅរបស់ព្រះបាទពញាយ៉ាត បានឡើងគ្រងរាជនៅប្រទេសកម្ពុជា។ ប្រសិនបើព្រះបាទរាមាធិបតី ប្រកបដោយរាជអំណាចពេញលេញ នៅពេលដែលព្រះបាទពញាយ៉ាត មិនទាន់ចូលទិវង្គតនោះ រជ្ជកាលរបស់ព្រះបាទស្រីរាជារាមាធិបតី នឹងកើតមានវិបត្តិប្រយុទ្ធគ្នា ក្នុងការដណ្តើមរាជសម្បត្តិ។ សភាពការណ៍នេះតែងកើតមានជាញឹកញាប់នៅប្រទេសកម្ពុជា ដោយហេតុថា គ្មានគោលការណ៍ច្បាស់លាស់នៅក្នុងកិច្ចបន្តរាជសម្បត្តិ។ មន្ត្រីជាន់ខ្ពស់នៃបរមរាជវាំងបានទទួលភារៈជ្រើសរើសបេក្ខជនជាអនាគតមហាក្សត្រ (ក្នុងបណ្តាសាច់ញាតិផ្ទាល់របស់អតីត

មហាក្សត្រ ) គឺជាទំនៀមទម្លាប់ដែលអាចជានាដល់ប្រទេស ក្នុងលក្ខខណ្ឌដែលមានចែដន្យ នៃការប្រសូតបុត្ររបស់មហាក្សត្រ ក៏ប៉ុន្តែ នៅពេលជាមួយគ្នា រមែងមានអំពើឃុបឃិតគំនិតក្បត់ នៅក្នុងបរមរាជវាំង ។ នៅពេលនោះ ព្រះសុរិយោទ័យ ជាបុត្រ របស់ព្រះបាទរាមាធិបតី បះបោរលើកទ័ពច្បាំងដណ្ដើមរាជសម្បត្តិ ហើយក្សត្រអង្គនេះ បានទាំងពឹងដល់ជំនួយរបស់កងទ័ពក្រុង អយុធ្យា ទៀតផង ។ ពួកសៀម មិនបានផ្ដល់ជំនួយអ្វីពិតទេ ប៉ុន្តែ ពួកវាបានឆ្លៀតឱកាសនៃការបែកបាក់បែបនេះ ដើម្បីចូល វាយលុករាតត្បាតនៅដែនដីខ្មែរខាងលិច ដូចជា ចន្ទតាប៊ុន កូរ៉ាត់ (ភូមិភាគខាងលិចនៃទន្លេមូន ) និងតំបន់អង្គរ នៅពេលដែល កងទ័ពខ្មែរមួយភាគធំ ត្រូវបានប្រមែប្រមូលមកប្រយុទ្ធគ្នានៅ ភូមិភាគកណ្ដាលនៃប្រទេស ។ នៅពេលជាមួយគ្នានោះ កងទ័ព មហាក្សត្រកំពុងជាប់ដៃឡោមព័ទ្ធ កងទ័ពព្រះសុរិយោទ័យ ដែល ការពារខ្លួននៅស្រុកស្រីសន្ធរ ។

នៅពេលនោះ នៅបរមរាជវាំង ព្រះបាទស្រីរាជារាមាធិបតី បានតែងតាំងព្រះធម្មោរាជា ជាព្រះអនុជ ដោយបានផ្ដល់នូវរាជ អំណាចដ៏ពេញលេញ ក្នុងការដឹកនាំកងទ័ព ទៅប្រយុទ្ធនៅ សមរភូមិខាងលិច ប្រឆាំងនឹងកងទ័ពសៀម ។ ដោយមានជំនឿ ជឿជាក់លើជ័យជម្នះ មហាក្សត្របានចែករំលែកកងទ័ពនឹង ព្រះអនុជ ហើយព្រះអង្គទទួលខុសត្រូវចំពោះការវាយបង្ក្រាប កងទ័ពព្រះសុរិយោទ័យ ។ ក៏ប៉ុន្តែ កងទ័ពព្រះធម្មោរាជា មិន ចេញទៅច្បាំងតទល់នឹងសត្រូវ ហើយបែរជាធ្វើចលនាមកកាន់ ក្រុងភ្នំពេញ ។ ព្រះធម្មោរាជា ក៏បានចាប់ផ្ដើមធ្វើការចរចានឹង ក្រុងអយុធ្យា ។ នៅក្នុងប្រវត្តិសាស្ត្រប្រទេស គេអាចសន្និតថា

ព្រះធម្មោរាជា បានប្រព្រឹត្តសកម្មភាពក្បត់នឹងប្រទេសជាតិ។ ក្សត្រនេះបានព្រមព្រៀងប្រគល់ដែនដីចន្ទតាប៊ុន និងកូរ៉ាត់ ដែលមានសុទ្ធតែជនជាតិខ្មែររស់នៅ ឱ្យទៅក្រុងអយុធ្យា មែនពិតទោះបីគ្មានការកំណត់រយៈកាលក្តី។ នៅពេលនោះ មហាក្សត្រស្រីរាជារាមាធិបតី បាននាំទ័ពបន្តការឡោមព័ទ្ធព្រះសុរិយោទ័យ ដែលការពារខ្លួននៅស្រុកស្រីសន្ធរ។ ស្ថានភាពរបស់ព្រះធម្មោរាជានៅពេលនោះ ក៏មិនរឹងមាំ។ ពួកសៀម សម្រេចជ្រៀតជ្រែកក្នុងការប្រយុទ្ធផ្ទៃក្នុង ព្រោះជាលើកទីមួយ ពួកសៀម យល់ថានឹងបានកាន់កាប់លើទឹកដីខ្មែរសុទ្ធសាធ។

ការរួមកម្លាំងគ្នារវាងកងទ័ពនៃក្រុងអយុធ្យា និងកងទ័ពរបស់ព្រះបាទធម្មោរាជា ចាប់ផ្តើមធ្វើការប្រយុទ្ធប្រឆាំងកងកម្លាំងមហាក្សត្រនៅសំរោងទង។ ដោយទ្រង់យល់ច្បាស់នូវកម្លាំងលើសលប់របស់កងទ័ពសត្រូវ មហាក្សត្រស្រីរាជារាមាធិបតី បានបញ្ឈប់ការបង្ហូរឈាម ព្រោះថា បើច្បាំងតទៅទៀតក៏ព្រះអង្គមិនអាចយកជ័យជម្នះបានដែរ។ ព្រះអង្គបានធ្លាក់ខ្លួនទៅជាឈ្លើយសង្គ្រាមរបស់ក្រុងអយុធ្យា (ហើយដោយការបង្អត់អាហារ ព្រះអង្គបានចូលទិវង្គតនៅពេលពីរបីខែក្រោយមក)។ ស្តេចសៀម ក៏បានធ្វើឱ្យព្រះសុរិយោទ័យ ដែលជាក្សត្រក្បត់ចូលទិវង្គតនៅប្រទេសសៀម តាមរបៀបនេះដែរ។ កាលបានចូលខ្លួនទៅខាងជំរំស្តេចសៀម ក្សត្រអង្គនេះមានសង្ឃឹមចំពោះរង្វាន់ ប៉ុន្តែត្រូវស្តេចសៀម នាំទៅក្រុងអយុធ្យា ហើយនៅទីនោះព្រះសុរិយោទ័យ ក៏បានចូលទិវង្គត។

ព្រះបាទធម្មោរាជា ក៏បានឡើងសោយរាជសម្បត្តិ (ពីគ.ស. ១៤៧៤ ដល់ គ.ស.១៤៩៤) ដោយគ្មានកិត្តិយសអ្វីឡើយ។

បន្ទាប់ពីព្រមព្រៀងឱ្យដែនដីចន្ទតាប៊ុន និងកូរ៉ាត់ ទៅប្រទេសសៀម និងបានឡើងសោយរាជ្យដោយសារការឧបត្ថម្ភរបស់ស្តេចសៀម ព្រះបាទធម្មោរាជា ក៏បានរៀនសូត្រធម៌អាថ៌នៃពុទ្ធសាសនា ហើយបានចេញទៅបំពេញផ្នួសនៅវត្តអារាម។

រាជបុត្រព្រះបាទធម្មោរាជា នាមព្រះបាទស្រីសុគន្ធបទ ឬស្រីសុគន្ធរ (គ.ស. ១៤៩៤-គ.ស.១៤៨៩) បានឡើងគ្រងរាជបន្ត ប៉ុន្តែ ព្រះអង្គពុំមានប្រជាប្រិយភាពអ្វីឡើយ។ តាំងពីដើមទីមក ព្រះអង្គចន្ទ ជាអនុជព្រះអង្គ បានថ្លែងប្រឆាំង ហើយបានប្រមែប្រមូលទ័ពវាយដណ្តើមយករដ្ឋធានី។ ព្រះបាទស្រីសុគន្ធបទ បានយាងទៅគង់ការពារខ្លួននៅស្រុកស្រីសន្ធរ។

ការទាស់ទែង និងការដណ្តើមអំណាចក្នុងរាជវង្សានុវង្ស ដោយសារចម្បាំងបង្ហូរឈាមនៅក្នុងប្រទេស ការព្រមព្រៀងប្រគល់ដែនដីខ្មែរ យ៉ាងអាម៉ាស់មុខឱ្យដល់ក្រុងអយុធ្យា ដោយព្រះបាទធម្មោរាជា ទាំងអស់នេះបណ្តាលឱ្យប្រជាករកើតក្តីក្តៅក្រហាយ ហើយក្រោកឈរបង្កើតជាចលនាបះបោរកុបកម្មប្រឆាំងនឹងមហាក្សត្រទាំងពីរអង្គ។ អ្នកដឹកនាំចលនាកុបកម្មនេះ គឺអតីតនាយផ្ទាំប្រាសាទ នាម នាយ-កន ដែលធ្លាប់បម្រើរាជការនៅបរមរាជវាំង។ ចលនាបះបោរបានរាលដាលយ៉ាងឆាប់រហ័សទៅលើខេត្តពីរបី ហើយកងកម្លាំងទ័ពដឹកនាំដោយនាយ-កន បានធ្វើចលនាឆ្ពោះមករដ្ឋធានី។ ដោយគ្មានបំណងប្រឆាំងចេញមុខនឹងបណ្តាប្រជាករបះបោរ ព្រះអង្គចន្ទ ក៏គេចភៀសខ្លួនពីទឹកដីខ្មែរ ទៅក្រុងអយុធ្យា ហើយបានរស់នៅទីនោះក្រោមកិច្ចគ្រប់គ្រងរបស់ស្តេចសៀម។ នៅពេលនោះ កងកម្លាំងដឹកនាំដោយ “ស្តេចកន ” បានចូលមកទីក្រុងភ្នំពេញ ហើយបានប្រកាស

នូវកម្មវិធីនយោបាយដោយពាក្យស្លោក ដែលបានបញ្ជាក់នូវការកសាងឯកភាពប្រទេសឡើងវិញ និងការតស៊ូប្រឆាំងនឹងព្រះមហាក្សត្រ។ កងកម្លាំងទ័ពរបស់ “ ស្តេចកន ” បានពង្រីកជួរយ៉ាងឆាប់រហ័ស ដោយមានយុទ្ធជន ១០០ពាន់នាក់។ នាយ-កន បានបដិសេធនូវ “ របបសក្តិភូមិចាស់ ” ហើយបានប្រកាសខ្លួនជាមហាក្សត្រនៃរាជវង្សានុវង្សថ្មី ដោយមានការបង្កើតរដ្ឋធានីនៅស្រឡប់ពិជ័យ ស្រុកត្បូងឃ្មុំ នាឆ្នាំ១៤៩៨។ ដោយពឹងផ្អែកលើការគាំទ្រ ពីសំណាក់នៃខេត្តខាងត្បូងនានា កងកម្លាំងនាយ-កន បានទទួលជ័យជម្នះជាច្រើនដងលើកងទ័ពព្រះបាទស្រីសុគន្ធបទ ក៏ប៉ុន្តែ ពួកសក្តិភូមិនៅតាមខេត្តនានា និងនៅរដ្ឋធានី បានរួបរួមគ្នាតស៊ូប្រឆាំងនឹងកងកម្លាំងនាយ-កន។ ពួកសក្តិភូមិខិតខំរំខាន ដល់ពិធីរៀបចំអភិសេក នាយ-កន ជាមហាក្សត្រតាមរាជប្រពៃណីត្រឹមត្រូវ (ព្រោះថា នៅសម័យនោះ ពិធីដ៏សំខាន់បែបនេះ អាចបញ្ជាក់ដល់បណ្តារាស្ត្រឱ្យយល់នូវអំណាចព្រះមហាក្សត្រ) ដោយការលាក់បំបាំងនូវគ្រឿងកេតនភណ្ឌរាជ្យ មានព្រះខ័នរាជ្យ និងលំពែងរាជ្យ។ គឺពួកព្រាហ្មណ៍បរោហិតនៅបរមរាជវាំង បានលាក់បំបាំងនូវគ្រឿងប្រដាប់សម្រាប់រាជ្យទាំងនេះ។ ក៏ប៉ុន្តែ ភាពខ្វះខាតនូវរាជអំណាចដ៏ពិសិដ្ឋនេះ មិនបានរំខានដល់កងកម្លាំងរបស់ នាយ-កន ឱ្យអាចវាយដណ្តើមយកបន្ទាយនៅតាមស្ទឹងសែន ដែលព្រះបាទស្រីសុគន្ធបទ បានស្ថិតនៅទីនេះ។ អគ្គមគ្គុទ្ទេសក៍នៃពួកសក្តិភូមិត្រូវបានកាត់ទោសប្រហារជីវិត។ នាយ-កន បានចាប់ផ្តើមធ្វើការបោសសំអាតស្ថាប័នរដ្ឋទូទៅ ដោយបានតែងតាំងបណ្តាអ្នកដឹកនាំចលនាកុបកម្មក្នុងតំណែងជាអ្នកដឹកនាំស្ថាប័នរដ្ឋ។ គេដឹងថា ព្រះ

អង្គចន្ទ ជាអនុជព្រះបាទស្រីសុគន្ធបទ បានរត់គេចខ្លួនទៅប្រទេសសៀម ហើយបានចាប់ផ្ដើមប្រមែប្រមូលកម្លាំងពួកសក្ដិភូមិ។

បន្ទាប់ពីបានកាន់កាប់រដ្ឋអំណាច នាយ-កន ក៏បានចាត់វិធានការមួយចំនួនក្នុងការបន្ធូរបន្ថយពន្ធដារ និងរបបជិះជាន់ក្នុងការសម្រាលទណ្ឌកម្មដល់បណ្ដារាស្ត្រ។ល។ ស្ថានភាពសេដ្ឋកិច្ចបានចម្រើន។ នាយ-កន បានលើកទឹកចិត្ត និងពង្រីកសកម្មភាពខាងពាណិជ្ជកម្ម។ គឺនៅក្នុងសម័យកាល នាយ-កន នេះហើយ ដែលមានការចាប់ផ្ដើមប្រើប្រាស់រូបិយប័ណ្ណខ្មែរធ្វើពីមាស ប្រាក់ និងស្ពាន់។ គឺជាវិធានការក្នុងវិស័យសេដ្ឋកិច្ចដ៏សំខាន់បំផុត ដែលបានរីកចម្រើនតទៅមុខទៀត។ សំណាករូបិយប័ណ្ណនាយ-កន មួយចំនួនត្រូវបានរក្សាទុករហូតដល់ពេលបច្ចុប្បន្ន។ នៅជិតរដ្ឋធានី គេបានចាប់ផ្ដើមសាងប្រព័ន្ធប្រឡាយបង្ហូរទឹកធំៗ សម្រាប់សាធារណជន។

ក៏ប៉ុន្តែ របបគ្រប់គ្រងរដ្ឋអំណាចរបស់ “ ព្រះមហាក្សត្រកសិករ ” មិនបានធ្វើឱ្យពួកសក្ដិភូមិសប្បាយសោមនស្សទេ។ ពួកនេះបានឈានជំហានដល់ការប្រព្រឹត្តអំពើក្បត់ ដល់ផលប្រយោជន៍ប្រទេសជាតិ។ម្ដងនេះ ព្រះអង្គចន្ទ ភ្លេចដល់សកម្មភាពប្រឆាំងក្រុងអយុធ្យា របស់ខ្លួន ហើយបានធ្វើការចរចាសុំជំនួយយោធាពីប្រទេសនេះ។ កងកម្លាំងពួកសក្ដិភូមិជាមួយនឹងកងទ័ពសៀម ចាប់ផ្ដើមធ្វើការប្រយុទ្ធចូលកាន់កាប់ប្រាសាទអង្គរ (គ.ស. ១៥០៥) ហើយបានកាន់កាប់បណ្ដាខេត្តខាងលិច ដែលស្ថិតនៅឆ្ងាយពីមូលដ្ឋាននៃចលនាបះបោរកុបកម្ម។ សង្គ្រាមដ៏យូរអង្វែង ក៏បានកើតមានឡើងទៀតនៅលើទឹកដីខ្មែរ។

ពួកសត្រូវ បានធ្វើចលនាចូលមកកាន់តែជិតទីក្រុងភ្នំពេញ។ គឺនៅទីនេះហើយ ដែលព្រះអង្គចន្ទ បានប្រើកលល្បិចបន្លំ “ មហាក្សត្រកសិករ ”។ ក្រោមកលល្បិចនៃការបញ្ឈប់សកម្មភាពសឹកនៅឱកាសបុណ្យចូលឆ្នាំថ្មី និងនៅរដូវធ្វើស្រែ ព្រះអង្គចន្ទ បានប្រមូលផ្តុំពួកដឹកនាំសក្តិភូមិ ហើយពួកនេះបានឆ្លៀតប្រារព្ធពិធីអភិសេកព្រះអង្គជាព្រះមហាក្សត្រ។ ឥឡូវ ការប្រយុទ្ធគ្នាក៏បានប្រព្រឹត្តទៅរវាងមហាក្សត្រពីរអង្គ ប៉ុន្តែ សភាពការណ៍បែបនេះ បានពង្រឹងកងកម្លាំងរបស់ពួកសក្តិភូមិ។ ភ្លើងសង្គ្រាមក្នុងស្រុកបានឆួលឆេះអស់រយៈពេល ជាង១៥ឆ្នាំ។ នាយ-កន បានទទួលការគាំទ្រពីភូមិភាគខាងកើតនៃប្រទេស។ ព្រះអង្គចន្ទ (គ.ស.១៥០៥-១៥៥៦) បានទទួលការគាំទ្រពីភូមិភាគខាងលិចនៃប្រទេស។ បន្ទាប់ពីទិញកាំភ្លើង និងគ្រាប់រំសេវពីពួកអឺរ៉ុប កងកម្លាំងរបស់ពួកសក្តិភូមិមានប្រៀបលើកងកម្លាំងរបស់នាយ-កន។ ផលវិបាកនេះបានជំរុញឱ្យនាយ-កន និងកងកម្លាំងរបស់ខ្លួន នៅការពារខ្លួនក្នុងបន្ទាយនៅសំរោងព្រៃនគរ ដែលត្រូវឡោមព័ទ្ធដោយកងកម្លាំងសត្រូវ។ បន្ទាប់ពីការឡោមព័ទ្ធអស់ពេលបីខែ កងកម្លាំងរបស់សត្រូវបានវាយសម្រុកចូលបន្ទាយ។ ពេលនោះ នាយ-កន ត្រូវរបួសបានធ្លាក់ខ្លួនទៅក្នុងកណ្តាប់ដៃសត្រូវ ហើយត្រូវបាត់បង់ជីវិតនៅពេលនោះ។ ម្យ៉ាងវិញទៀត កងកម្លាំងរបស់នាយ-កន ដែលស្ថិតនៅទីកន្លែងនានានៃប្រទេស បានបន្តយុទ្ធនាការរបស់ខ្លួនអស់រយៈពេលពីរបីឆ្នាំក្រោយមកទៀត។

ចលនាកុបកម្មបះបោរជ័យួរអង្វែង ក្រោមកិច្ចដឹកនាំរបស់នាយ-កន (ពីគ.ស.១៤៩៧-ទសវត្សរ៍ទី២ នៃសតវត្សរ៍ទី១៦)

មានលក្ខណៈជាចលនាប្រឆាំងរបបសក្តិភូមិ ហើយមានទិសដៅជាចលនាស្នេហាជាតិ។ ចលនានេះបានបង្ហាញដល់ព្រះបាទអង្គចន្ទ និងរាជបរិវាររបស់ខ្លួនឱ្យយល់ច្បាស់នូវសន្ទុះនៃកម្លាំងចលនាស្នេហាជាតិ ព្រមទាំងបានផ្តល់ឥទ្ធិពលរបស់ខ្លួនដល់កិច្ចការដឹកនាំនយោបាយ របស់ពួកអ្នកដឹកនាំសក្តិភូមិជាន់ខ្ពស់នៅក្នុងអនាគតកាល។ ហេតុនេះហើយ បានជានៅពេលដែលក្រុងអយុធ្យា ជាលើកទីមួយនៅក្នុងប្រវត្តិសាស្ត្រនៃទំនាក់ទំនងរវាងប្រទេសទាំងពីរ បានទាមទារជាផ្លូវការពីការទទួលស្គាល់ពីសំណាក់ប្រទេសកម្ពុជា នូវឧត្តមភាពរបស់ខ្លួន ដោយទាមទារនូវដង្វាយដំរីស។ ព្រះបាទអង្គចន្ទ ចាប់ផ្តើមធ្វើសង្គ្រាមប្រឆាំងប្រទេសនេះភ្លាម។ មែនពិត ការទាមទាររបស់ក្រុងអយុធ្យា មិនមានលក្ខណៈស្របទៅតាមស្ថានភាពនៃកម្លាំងទ័ពទេ ទោះបីនៅពេលនោះ ចលនាកុបកម្មក្រោមការដឹកនាំរបស់នាយ-កន មិនទាន់ទទួលបរាជ័យ ក៏ដោយ។ នៅក្នុងការប្រយុទ្ធគ្នាផ្តាច់ព្រ័ត្រក្នុងសមរភូមិជិតទីក្រុងអង្គរ កងទ័ពសៀម ត្រូវបានកម្ទេចរាបគ្មានសល់ម្នាក់ដោយកងទ័ពខ្មែរ។ ចាប់ពីពេលនោះមក គេបានឱ្យឈ្មោះទីសមរភូមិនោះថាជា “ សៀមរាប ”។

បន្ទាប់ពីបានពង្រឹងមហិទ្ធិឫទ្ធិប្រទេស ដោយការអនុវត្តនយោបាយក្រៅប្រទេសដ៏ត្រឹមត្រូវ និងដោយពឹងផ្អែកលើប្រសិទ្ធភាពនៃវិធានការខាងសេដ្ឋកិច្ចនានា នៅសម័យនាយ-កន ដែលបានបន្ធូរបន្ថយ ដល់បណ្តាកសិករឱ្យបង្កើនរបរកសិកម្ម របស់ពួកគេ ព្រះបាទអង្គចន្ទ បានចាប់ផ្តើមអនុវត្តនយោបាយខាងស្ថាបនកម្មដ៏ទូលំទូលាយនៅក្នុងវិស័យសាធារណការ និងយោធាដែលនៅក្នុងនេះ មានទាំងការកសាងប្រព័ន្ធប្រឡាយបង្ហូរទឹក

ទៀតផង។ ជនជាតិអឺរ៉ុប ដែលបានចូលមកដល់ប្រទេសកម្ពុជា ជាលើកទីមួយ បានសរសេររៀបរាប់ថា ជាប្រទេសចម្រើនរុងរឿងខ្លាំង។ សេចក្តីពណ៌នាអំពីប្រទេសកម្ពុជា មុនគេបង្អស់ គឺជាសេចក្តីពណ៌នារបស់ តុម-ពីរ៉េស (គ.ស.១៥១២-គ.ស.១៥១៥)។ លោកបានសរសេរថា កម្ពុជា ជាប្រទេសមានកម្លាំងខាងយោធាខ្លាំង ដែលមិនព្រមចុះចូលនឹងប្រទេសណាមួយ ហើយធ្វើសង្គ្រាមជាមួយប្រទេសចម្ប៉ា និងប្រទេសភូមា។ កងនាវាចរណ៍នៃប្រទេសកម្ពុជា បានធ្វើការប្រយុទ្ធបណ្តេញពួកសត្រូវគ្រប់បែបពីដែនទឹករបស់ខ្លួន ទូក សំពៅខ្មែរ បានបើកបរទៅកាន់រដ្ឋម៉ាឡាយូ នានា នៅទិសខាងជើង។ នៅសម័យនោះ គេស្គាល់ប្រទេសកម្ពុជា ថាជាប្រទេសមួយដ៏សំខាន់ក្នុងការនាំស្រូវចេញទៅលក់ខាងក្រៅ ជាប្រទេសសម្បូរខាងគ្រឿងបរិភោគ។

នៅក្នុងរជ្ជកាលរបស់ព្រះបាទអង្គចន្ទ មានការស្ថាបនារដ្ឋធានីថ្មី គឺទីក្រុងលង្វែក ដែលស្ថិតនៅត្រើយខាងស្តាំនៃដៃទន្លេមេកុង។ វត្តអារាមមួយចំនួនត្រូវបានកសាងឡើង។ នៅក្នុងវត្តមួយធំជាងគេ ឈ្មោះវត្តត្រឡែងកែង មានព្រះពុទ្ធរូបមួយយ៉ាងធំប្រកបដោយមុខបួន។ នៅឆ្នាំ១៥២៩ នៅទីក្រុងលង្វែក គេបានប្រារព្វរាជពិធីអភិសេកព្រះបាទអង្គចន្ទ ដ៏មហោឡារិក ជាលើកទីពីរ។ រវាងពីរឆ្នាំក្រោយមក ព្រះបាទអង្គចន្ទ បានចាប់ផ្តើមធ្វើចម្បាំងប្រឆាំងក្រុងអយុធ្យា ហើយដណ្តើមបានដែនដីកូរ៉ាត់ និងចន្ទ តាប៊ុន មកវិញ។ កងទ័ពខ្មែរបានវាយលុកចូលទីក្រុងអយុធ្យា ហើយបានចូលរាតត្បាតទីក្រុងប្រាឈិន។

មហាក្សត្រសៀម បានសាកល្បងប្រើកលល្បិចបង្កើតការប្រយុទ្ធដណ្តើមអំណាចរវាងបងប្អូន ដោយប្រើប្រាស់ព្រះអង្គម្ចាស់

ខ្មែរ ឈ្មោះព្រះអង្គ-អោង។ ចម្បាំងបែបនេះបានកើតឡើងនៅតំបន់កូរ៉ាត់ ក៏ប៉ុន្តែ នៅឆ្នាំ១៥៣៤ ព្រះអង្គ-អោង បានទទួលបរាជ័យ ពួកទាហានសៀម ដែលជួយច្បាំងត្រូវបានចាប់ជាឈ្លើយសង្គ្រាម។ ចម្បាំងប្រកបដោយជ័យជម្នះប្រឆាំងក្រុងអយុធ្យា បានធ្វើឱ្យពួកសក្តិភូមិទាំងអស់នៅក្នុងប្រទេសទទួលស្គាល់ ហើយគោរពព្រះបាទអង្គចន្ទ។ នៅឆ្នាំ១៥៣៩ គេបានធ្វើពិធីដ៏ឱឡារិក ដើម្បីប្រគល់គ្រឿងកេតនភណ្ឌរាជ្យ ដែលត្រូវបានរកឃើញដោយចៃដន្យ។ ព្រះខ័នរាជ្យជានិមិត្តរូបរបស់ចក្រភព ហើយលំពែងរាជ្យជានិមិត្តរូបនៃរាជវង្សានុវង្សព្រះបាទត្រសក់ផ្អែម។ នៅឆ្នាំ១៥៤៩ កងទ័ពព្រះបាទអង្គចន្ទ បានធ្វើការលុកចូលទីក្រុងអយុធ្យា ម្តងទៀត។

ក្នុងបណ្តាជនជាតិអឺរ៉ុប ដែលបានមកដល់ប្រទេសកម្ពុជាជាលើកទី១ គឺមានលោកសង្ឃផ្សាយគ្រឹស្តសាសនា ជាតិព័រទុយហ្កែសមួយរូប ដែលគេស្គាល់ច្បាស់។ លោកមានឈ្មោះហ្គាស្ប៉ា-ដឺឡាក្រ៊ូ ហើយបានចូលដល់បរមរាជវាំងកម្ពុជា នាឆ្នាំ១៥៥៥។ ប្រកបដោយសេចក្តីសណ្តោសខន្តី មហាក្សត្របានអនុញ្ញាតឱ្យផ្សាយគ្រឹស្តសាសនា ក៏ប៉ុន្តែ នៅទីបំផុត បណ្តាជនខ្មែរ មិនចាប់អារម្មណ៍ដល់សាសនានេះ ហើយនៅឆ្នាំ១៥៥៧ លោកសង្ឃផ្សាយគ្រឹស្តសាសនានេះ បាននិមន្តត្រឡប់ទៅម៉ាឡាកា វិញ។

ក្នុងប្រទេស គេបានរក្សានូវប្រពៃណីគោរពព្រះមហាក្សត្រដូចអាទិទេព។ នៅទីកន្លែងដែលមានជ័យជម្នះក្នុងចម្បាំង គេបានកសាងវត្តអារាម ដែលនៅទីនេះបានតម្កល់ធាតុនៃព្រះញាតិវង្សានុវង្ស។ ព្រះបាទអង្គចន្ទ យកចិត្តទុកដាក់ជាខ្លាំង

ដល់ព្រៃពណីបូរាណនៃសម័យចក្រកពកម្ពុជា ហើយចាប់អារម្មណ៍ដល់ស្ថានភាពនៃប្រាសាទនានានៅអង្គរធំ។ ហេតុនេះ បានជានៅក្នុងទសវត្សរ៍ទី៥ គេបានចាប់ផ្តើមបំពេញការងារជួសជុលប្រាសាទនានា។ ការងារជួសជុលបានប្រព្រឹត្តទៅចំពោះប្រាសាទខ្លះៗ ដែលទទួលការខូចខាតនៅទីក្រុងអង្គរធំ។ គេបានបន្តស្ថាបនកម្មទីក្រុងឧត្តុង្គ និងទីក្រុងដទៃទៀត។ មានការកសាងប្រព័ន្ធប្រឡាយបង្ហូរទឹក និងការកាប់គាស់ព្រៃឈើដើម្បីធ្វើស្រែចម្ការ។ ព្រះវិហារ និងវត្តអារាមទាំងឡាយ ដែលបានកសាងឡើង ស្ថិតនៅក្រោមកិច្ចគ្រប់គ្រងរបស់រដ្ឋ មិនតែប៉ុណ្ណោះ មានការចាប់ផ្តើមជីកអណ្តូងរ៉ែផ្សេងៗទៀតផង។

សន្ទុះនៃការកសាងប្រទេសជាតិ ដែលចាប់ផ្តើមឡើងតាំងពីសម័យកាលនាយ-កន ត្រូវបានបន្តរហូតដល់សម័យនៃរជ្ជកាលព្រះបាទបរមរាជា (គ.ស.១៥៥៦-គ.ស. ១៥៦៧) ជារាជបុត្ររបស់ព្រះអង្គចន្ទ។ ព្រះបាទបរមរាជា បានមកតាំងរដ្ឋធានីនៅកំពង់ក្រសាំង ជិតរដ្ឋធានីចាស់ យសោធរបុរៈ។ ព្រះអង្គបានចាប់ផ្តើមកសាងសំណង់ផ្សេងៗ ក៏ប៉ុន្តែ តមក ទ្រង់បានយាងត្រឡប់មកគង់នៅទីក្រុងលង្វែក វិញ។ នៅក្នុងរជ្ជកាលព្រះបាទបរមរាជា កងទ័ពខ្មែរបានធ្វើការវាយលុកជាបន្តបន្ទាប់ចូលក្រុងអយុធ្យា ដណ្តើមបានដែនដីកូរ៉ាត់ មកខ្មែរវិញ ហើយបានកាន់កាប់ខេត្តសៀមខ្លះៗ ជាបណ្តោះអាសន្ន។ តមក កងទ័ពខ្មែរបានធ្វើឱ្យកងទ័ពឡាវ ក្រោមកិច្ចបញ្ជាការរបស់មហាក្សត្រសេដ្ឋាទិរាជ ទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរក្នុងការប្រយុទ្ធគ្នានៅភ្នំសន្ទុក។ កងទ័ពជើងគោក និងជើងទឹកឡាវ បានបែកខ្ញែករត់ខ្ចាត់ខ្ចាយ ហើយកងទ័ពព្រះបាទបរមរាជា ចាប់ពួកឡាវ បានជា

ឈ្លើយសង្គ្រាមមួយចំនួនធំ។ បន្ទាប់ពីចម្បាំងនេះ កងទ័ពខ្មែរ បានវាយលុកចូលក្រុងអយុធ្យា (ប្រទេសសៀម) ហើយចូលដល់ រដ្ឋធានី។ នៅពេលនោះ ទីក្រុងអយុធ្យា មិនទទួលចុះចាញ់ទេ ក៏ប៉ុន្តែ ប្រទេសកម្ពុជា មានប្រៀបយ៉ាងខ្លាំងខាងយោធា។ នៅ ឆ្នាំ១៥៦៦ ក្រុងអយុធ្យា ដោយមិនបានគិតដល់ការវាយលុកជា ថ្មីរបស់កងទ័ពខ្មែរបែបនេះ បានយល់ព្រមប្រគល់ដែនដីចន្ទ តា ប៊ុន មកឱ្យខ្មែរវិញ។

នៅសតវត្សរ៍ទី១៤ មានការកំណត់ព្រំប្រទល់រវាងប្រទេស សៀម និងប្រទេសកម្ពុជា ដោយការដាំសីមាព្រំប្រទល់ធ្វើអំពីថ្ម។ កងទ័ពខ្មែរ បានធ្វើចម្បាំងប្រឆាំងកងទ័ពឡាវ ដែលស្ថិតនៅ ក្រោមកិច្ចបញ្ជាការរបស់មហាក្សត្រសេដ្ឋាទិរាជ ម្តងទៀត។ កងទ័ពឡាវ បានទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរជាលើកទីពីរនៅក្នុង ការប្រយុទ្ធគ្នានៅសមរភូមិកោះជ្រាំ ដែលនៅទីនេះ ទាហានឡាវ ត្រូវចាប់បានជាឈ្លើយសង្គ្រាមរាប់ពាន់នាក់។ បន្ទាប់ពីបរាជ័យ នៅកោះជ្រាំ ប្រទេសឡាវលែងទៅជាមូលដ្ឋាននៃការគំរាមកំហែង ខាងយោធាទៀតសម្រាប់ប្រទេសកម្ពុជា ទោះបីប្រទេសឡាវ ពុំ ច្បាំងដណ្តើមទឹកដីណាមួយបានឡើយ ក៏ដោយ។

ប្រទេសកម្ពុជា បានប្រែក្លាយទៅជាប្រទេសខ្លាំងជាងគេ មួយនៅឧបទ្វីបឥណ្ឌូចិន នៅក្នុងរជ្ជកាលព្រះបរមរាជា និងនៅ ក្នុងរជ្ជកាលបុត្ររបស់ព្រះអង្គ នាមព្រះសត្ថាទី១ (គ.ស. ១៥៦៧-គ.ស.១៥៧៤)។ ព្រះបាទសត្ថាទី១ បានទទួលរាជាភិសេកជា មហាក្សត្រប្រទេសកម្ពុជា នៅទីក្រុងលង្វែក។ ព្រះអង្គបានបញ្ជូន កងទ័ពឱ្យធ្វើការវាយលុកក្រុងអយុធ្យា ជាច្រើនលើក។ នៅឆ្នាំ ១៥៧៤ ព្រះបាទសត្ថាទី១ បានផ្ទេររាជសម្បត្តិទៅឱ្យរាជបុត្រ

ច្បងរបស់ព្រះអង្គ ព្រះនាមព្រះបាទជ័យជេដ្ឋាទី១ (គ.ស.១៥៧៤-គ.ស.១៥៩៥) ដែលមានជន្មាយុ១០វស្សាប៉ុណ្ណោះ។ ប៉ុន្តែ រដ្ឋអំណាចបានស្ថិតនៅក្នុងកណ្តាប់ដៃព្រះបាទសត្ថាទី១ ទាំងអស់ រហូតដល់ឆ្នាំ១៥៩៤។ នៅក្នុងទសវត្សរ៍នេះ មានការកសាងវត្តអារាមជាច្រើន ជាពិសេស បើតាមសិលាចារឹកនាឆ្នាំ១៥៧៧ និង១៥៧៩ មានការជួសជុលប្រាសាទអង្គរវត្ត ឡើងវិញ ទោះបីប្រាសាទនេះបានកសាងឡើងដើម្បីឧទ្ទិសដល់សាសនាព្រះវិស្ណុក៏ដោយ។ នៅទីនេះ មានរៀបចំពិធីបុណ្យសាសនាដ៏គគ្រឹកគគ្រេងដោយមានការចូលរួបរួមពីសំណាក់នៃរាជវង្សានុវង្សទៀតផង។

នៅទសវត្សរ៍ទី១៦ ខុសពីប្រទេសនានានៅអាស៊ីអាគ្នេយ៍ ប្រទេសកម្ពុជា លូតលាស់រុងរឿង។ គេបានពង្រីកការកសាងប្រព័ន្ធប្រឡាយបង្ហូរទឹកបន្ថែមជារឿយៗ។ មិនតែប៉ុណ្ណោះ នៅក្នុងការបំពេញកិច្ចការទូទៅជាសាធារណៈ រដ្ឋបានប្រើប្រាស់ពលកម្មរបស់កសិករ។ ប្រទេសកម្ពុជា បានផលិត និងនាំចេញនូវធញ្ញជាតិ សត្វពាហណៈ ត្រី។ ស្រូវអង្ករខ្មែរ ត្រូវបានគេឱ្យតម្លៃយ៉ាងខ្ពស់។ នៅក្នុងវិស័យកសិកម្ម ច្បាប់ទម្លាប់បូរាណបន្សល់ពីសម័យចក្រភពអង្គរ បានបាត់បង់សឹងទាំងអស់។ កម្មសិទ្ធិខ្ពង់ខ្ពស់នៃមហាក្សត្រលើដីធ្លីនៃប្រទេស ប្រែក្លាយជាផុតរលត់។ កសិករនឹងមានសិទ្ធិលើដីរបស់ខ្លួន លុះត្រាតែធ្វើរបរលើដីនេះ។ កាលណាមេគ្រួសារ ដែលធ្វើរបរលើដីបានបាត់បង់ជីវិត របរលើដីនោះក៏ត្រូវបាត់សិទ្ធិ គ្រួសារបុគ្គលនោះមិនអាចទាមទារសិទ្ធិធ្វើជាម្ចាស់ដីតទៅទៀតបានឡើយ។ នៅក្នុងលក្ខខណ្ឌនៃភាពសម្បូរដីនៅក្នុងប្រទេស និងក្នុងលក្ខខណ្ឌនៃការបាត់បង់ភូមិសហគមន៍ ដែលជាសភាពការណ៍ពិសេសសម្រាប់ប្រទេស

កម្ពុជា នាសតវត្សរ៍ទី១៥-ទី១៦ អ្នកបន្តមរតក ភេទប្រុស ដែលមានអាយុតិច រហូតដល់មានអាយុពេញវ័យ(តាមឯកសារខ្លះមុនពេលនេះ គ្រួសារបែបនេះបានទទួលការគាំទ្រពីសំណាក់បងប្អូននានា) បានទទួលឡូត៍ដីថ្មីទៀត ប្រសិនបើសាមីខ្លួនមានសមត្ថភាពធ្វើរបរលើដីនេះបាន។

នៅក្នុងវិស័យរដ្ឋអំណាច មហាក្សត្របានបន្តកាន់កាប់អំណាចផ្ដាច់ការដដែល ហើយគ្មានសមាជិកដទៃនៃរាជវង្ស និងវណ្ណៈអភិជនដទៃណាអាចកម្រិតអំណាចមហាក្សត្រ បានឡើយ។

ទីក្រុងនានានៃប្រទេសកម្ពុជា ដូចជា លង្វែក អង្គរ ស្រីសន្ធរ ភ្នំពេញ និងដទៃទៀត ពោរពេញទៅដោយបណ្ដាជន ដែលជាសិប្បករ អ្នកជំនួញ មន្ត្រី នាហ្មឺន ទាហាន និងខ្ញុំបម្រើច្រើនឥតគណនា។ ប្រទេសកម្ពុជា បានផលិតសំពត់ក្រណាត់ធ្វើពីសូត្រកប្បាស ក្រចៅ បានផលិតជ័រអោចម៍ល័ក្ត ម្រក្សណ៍ សាច់ជូរបានជីកយកមាស ប្រាក់ ស្ពាន់ សំណ សំណស័ង្កសី។ ភោគផលទាំងនេះ ត្រូវបានផលិតឡើងដើម្បីសេចក្ដីត្រូវការក្នុងស្រុក និងដើម្បីនាំចេញទៅលក់នៅប្រទេសក្រៅ។ ប្រទេសកម្ពុជា បាននាំចូលនូវតវ៉ាន់ដូចតទៅ៖ ខ្លឹមចន្ទន៍ អាភៀន ភ្លុកដំរី ប្រេងកប៉ូរក្រមួន ទៀនធូប ត្បូងពេជ្រផ្សេងៗ។ល។ វិស័យនៃពាណិជ្ជកម្មក្រៅប្រទេស ដែលមានមកជាប្រពៃណី គឺការលក់ដំរីស្រុក។

ប្រទេសបាននាំចូលជាពិសេសនូវគ្រឿង ចានប៉ាសឺឡែនស្ពាន់ធ័រ ទឹកម្រេត សំពត់សូត្រប្រកបដោយគុណសម្បត្តិខ្ពស់ កាំភ្លើងកាណុង កាំភ្លើងដៃ គ្រាប់រំសេវ។ រដ្ឋបាលជាន់ខ្ពស់ដែលគ្រប់គ្រងពាណិជ្ជកម្ម ក្នុងប្រទេស និងក្រៅប្រទេស មានសមាសភាព ដូចតទៅ គឺអស់មុខមន្ត្រីពិសេស និងសមាជិក

នៃរាជវង្ស។ រាជបល្ល័ង្កកាន់កាប់ពាណិជ្ជកម្មផ្ដាច់មុខចំពោះការលក់ទិញឥវ៉ាន់សំខាន់ៗជាច្រើនមុខ។

នៅទសវត្សរ៍ទី៧ ប្រទេសសៀម មានបំណងចាប់ផ្ដើមធ្វើចម្បាំងសាជាថ្មីជាមួយប្រទេសកម្ពុជា។ នៅឆ្នាំ១៥៨៣ កងទ័ពសៀម បានវាយលុកចូលខេត្តបាត់ដំបង ពោធិ៍សាត់ ហើយបន្តដំណើរមកឡោមព័ទ្ធរដ្ឋធានី។ ដូចពេលមុនៗ កងទ័ពជើងគោកខ្មែរ បានវាយចូល ហើយកម្ចាត់កងទ័ពសៀម ពីរដ្ឋធានី។ កងទ័ពខ្មែរ បានវាយបណ្ដេញកងទ័ពសៀម ចេញអស់ពីទឹកដីប្រទេសកម្ពុជា។ ក៏ប៉ុន្តែ នៅសម័យនោះ នៅប្រទេសកម្ពុជា មានកើតជំងឺអាសន្នរោគ ដែលបានរាលដាលលើខេត្តជាច្រើន ហើយបណ្ដាលឱ្យបណ្ដាជនមួយភាគធំស្លាប់បាត់បង់ជីវិត ហើយទុរ្ភិក្សក៏បានកើតមានឡើង។ ទោះបីកងទ័ពខ្មែរ ដណ្ដើមបានជ័យជម្នះក្ដី ក៏ស្ថានភាពនយោបាយក្រៅប្រទេសនៅតែតានតឹង គឺត្រូវតែពង្រឹងកម្លាំងកងទ័ពជាដាច់ខាត។

នៅសម័យនោះ នៅបរមរាជវាំងខ្មែរ ក៏ដូចជានៅបរមរាជវាំង នៅប្រទេសដទៃខ្លះនៅអាស៊ីអាគ្នេយ៍ ដើម្បីពង្រឹងកម្លាំងកងទ័ពមានការបង្កើតកងឆ្មាំរក្សា ដោយមានការជ្រើសរើសទាហានស៊ីឈ្នួល ពីជនជាតិម៉ាឡាយូ ព័រទុយហ្គេស និងអេស្ប៉ាញ៉ុល។ ក្នុងបណ្ដាទាហានស៊ីឈ្នួលទាំងនេះ មានជនជាតិព័រទុយហ្គេសម្នាក់ ឈ្មោះវែលឡូសូ បានរៀបការនឹងអ្នកអង្គម្ចាស់មួយរូបជាប់ជាញាតិសន្តានឆ្ងាយនឹងព្រះបាទសត្ថាទី១។ ពួកព័រទុយហ្គេសចាប់អារម្មណ៍ជាពិសេសដល់បូរាណរដ្ឋ ធានីអង្គរ ហើយបានសរសេរថា៖ “ ជាទីក្រុងដ៏ស្អាត ដ៏ល្អឆើតឆាយ ជាងគេនៅលើពិភពលោក ដែលបានកសាងឡើងសម្រាប់ជីវភាព។ ជាទីក្រុង

ប្រកបដោយសួនបុប្ផាស្ដុះស្ដាយ ដោយប្រាង្គប្រាសាទនានា ដោយវិថី និងប្រឡាយបង្ហូរទឹកដ៏ធំទូលាយ ដោយប្រព័ន្ធបង្ហូរទឹកដ៏ល្អ ដែលធ្វើសកម្មភាព ”។ បើតាមសេចក្ដីពណ៌នាខាងលើឃើញថា ទីក្រុងអង្គរ មានទិដ្ឋភាពបែបនេះនៅសម័យទសតវត្សរ៍ទី៨នៃសតវត្សរ៍ទី១៦។

យើងសូមរំលឹកថា គឺគ្មានឯកសារជាប្រភពណាមួយដែលបាន ឱ្យព័ត៌មានអំពីការបំផ្លិចបំផ្លាញទីក្រុងអង្គរ នៅសតវត្សរ៍មុន ប៉ុន្តែ បានពណ៌នាតែអំពីអំពើលួចប្លន់ និងអំពីការជន្លៀសបណ្ដាជនចេញ ពីទីក្រុង។ បន្ទាប់ពីពេលអាសន្នទាំងនេះ ទីក្រុងអង្គរបានស្ថិតនៅគង់វង្ស ហើយមានបណ្ដាជនច្រើនកុះករ ដូចពេលមុន។ អ្នកនិពន្ធទាំងអស់ បានសរសេរអំពីឫទ្ធិអំណាចដ៏ទូលំទូលាយ នៃមហាក្សត្រខ្មែរ នៅក្នុងកិច្ចការប្រទេស ខាងនយោបាយ និងខាង សេដ្ឋកិច្ច អំពីភាពស្កុកស្ដម្ភគគ្រឹកគគ្រេង នៃពិធីបុណ្យនៅក្នុងបរមរាជវាំង ទោះបីនៅសម័យនោះ មានការសង្វេបខ្លះៗផង បើប្រៀបធៀបទៅនឹងពិធីបុណ្យនៅចុង សតវត្សរ៍ទី១៣ ក្នុងសម័យចក្រភព។មូលដ្ឋាននៃវណ្ណៈសក្ដិភូមិ គឺបណ្ដាមុខមន្ត្រី សេនាបតី និងនាហ្មឺនទាំងឡាយ គឺជាសមាជិកនៃរាជវង្សានុវង្ស ដែលមានចំនួនច្រើនលើសលប់ គឺគណៈសង្ឃខាងពុទ្ធសាសនា និងព្រាហ្មបរោហិតខាងព្រហ្មញ្ញសាសនា ដែលបានបម្រើរាជការនៅបរមរាជវាំង។ កម្មសិទ្ធក្នុងការបន្តមរតកលើដីធ្លីមាននៅតទៅទៀត។ ក៏ប៉ុន្តែ បើតាមការសន្និដ្ឋាន ឃើញថាសិទ្ធិនេះមានសម្រាប់តែបណ្ដាពួកអភិជនសក្ដិភូមិ ដែលជាប់ជាញាតិសន្តាននឹងមហាក្សត្រប៉ុណ្ណោះ។ កម្មសិទ្ធិលើដីរបស់វត្តអារាម ស្ថិតនៅទាំងស្រុង ប៉ុន្តែ ទំហំដីត្រូវបានបំព្រួញឱ្យនៅ

តូចជាងពេលមុនឆ្ងាយ។ តាមផ្លូវច្បាប់ ឃើញថា កសិករពេញច្បាប់បានធ្វើស្រែចម្ការលើដីធ្លីរបស់ខ្លួន ហើយនៅលើសម្បត្តិដីភូមិរបស់ពួកសក្តិភូមិជាគ្រហស្ថ និងបព្វជិត មានការប្រើកម្លាំងពលកម្មរបស់អ្នកងារ និងរបស់ពួកខ្ញុំជា " ពលព្រះ " ដែលរស់ពាននៅលើដីទាំងនេះ។

អ្នកនិពន្ធអឺរ៉ុប បានអធិប្បាយច្បាស់លាស់អំពីប្រព័ន្ធដ៏ស្មុគស្មាញនៃស្ថាប័នរបស់រដ្ឋខ្មែរ ហើយបានកត់សម្គាល់ជាពិសេសនូវការរីកចម្រើនដ៏ខ្ពស់ នៃស្ថាប័នតុលាការ នៃប្រទេសកម្ពុជា ដែលមាននៅរដ្ឋធានី និងនៅតាមខេត្តនានា។ ប្រទេសត្រូវបានបែងចែកជាខេត្ត ជាស្រុក ជាឃុំ និងភូមិទាំងឡាយ។ នៅតាមទីក្រុងនានា មានមន្ត្រីជាតំណាងរាជបល្ល័ង្កត្រួតត្រា ប៉ុន្តែទីក្រុងនីមួយៗគ្មានរបបស្វ័យគ្រប់គ្រងរបស់ខ្លួនទេ។

ពុទ្ធសាសនាថេរវាទ បានផ្តល់ឥទ្ធិពលទាំងស្រុងរបស់ខ្លួនទៅលើជីវភាពខាងសតិអារម្មណ៍របស់ប្រទេស។ ដូចនៅប្រទេសប្រកាន់តាមពុទ្ធសាសនាថេរវាទទាំងអស់ នៅប្រទេសកម្ពុជា មានភិក្ខុសង្ឃ និងសាមណេរច្រើនឥតគណនា។ ប៉ុន្តែវត្តអារាមពុំមានដីធ្លីច្រើនដូចមុនទៀត។

នៅសតវត្សរ៍ទី១៦-ទី១៧ រាជការមហាក្សត្របានធ្វើសេក្តីអញ្ជើញពួកអេស្ប៉ាញ៉ុល និងពួកព័រទុយហ្គេស មិនមែនសម្រាប់បំពេញសេចក្តីត្រូវការកម្លាំងទ័ពទេ (តាមការនិទាន ការចូលរួមរបស់ពួកអឺរ៉ុប ក្នុងចម្បាំងនានា មិនបានជះឥទ្ធិពលដល់លទ្ធផលនៃយុទ្ធនាការទេ) ក៏ប៉ុន្តែ សម្រាប់បំពេញតួនាទីជាអ្នកអាជ្ញាកណ្តាល ដើម្បីទាក់ទាញកងនាវាចរណ៍អឺរ៉ុប ឱ្យចូលមករួបរួមក្នុងយុទ្ធនាការផ្សេងៗ។ ក្នុងការអញ្ជើញបែបនេះ គឺរដ្ឋការសៀម

និងវៀតណាម ក៏បានធ្វើរបៀបនេះដូចគ្នាដែរ។ នៅក្នុងរបៀបព្រមព្រៀងគ្នាបែបនេះ មានទាំងការបន្ធូរបន្ថយដោយការផ្តល់សិទ្ធិក្នុងកិច្ចការពាណិជ្ជកម្ម និងសិទ្ធិក្នុងការផ្សាយគ្រីស្តសាសនា។ នៅរវាងទសវត្សរ៍ទី៩នៃសតវត្សរ៍ទី១៦ នៅពេលដែលកងទ័ពសៀមបានទទួលជ័យជម្នះក្នុងការវាយលុកប្រទេសកម្ពុជា ជនជាតិព័រទុយហ្គេសម្នាក់ ឈ្មោះ វែលឡូសូ បានត្រូវបញ្ជូនជាបេសកជនទៅកោះហ្វីលីពីន។ ព្រះបាទសត្ថាទី១ បានធ្វើសំណើឱ្យមានការបញ្ជូននាវាចម្បាំង ដែលនៅពេលនោះ គឺជាគ្រឿងបច្ចេកទេសអឺរ៉ុប ដ៏សក្តិសិទ្ធិនៅក្នុងចម្បាំងនៅប្រទេសនានានៅទ្វីបអាស៊ី ហើយជាការតបឆ្លើយនឹងសំណើនេះ ព្រះអង្គបានអនុញ្ញាតឱ្យលោកសង្ឃខាង គ្រីស្តសាសនាផ្សាយសាសនា របស់ខ្លួននៅប្រទេសកម្ពុជា។ នៅពេលនោះ នៅបរមរាជវាំង គ្មាននរណាកាន់សាសនាគ្រីស្តនោះឡើយ។ បេសកជន វែលឡូសូ បានធ្វើការចរចានឹងអាជ្ញាធរអេស្ប៉ាញ៉ុល នៅកោះហ្វីលីពីន ប៉ុន្តែ មិនបានសម្រេច ហើយកិច្ចព្រមព្រៀង ក៏មិនបានធ្វើឡើង។ នៅឆ្នាំ ១៥៩៤ កងទ័ពសៀម បានវាយលុកចូលទីក្រុងលង្វែក ទោះបីពួកវាបានទទួលការខូចខាតជាច្រើនក៏ដោយ។ ដោយយល់ថា ពួកវាមិនអាចស្ថិតនៅទីក្រុងនេះបានយូរ ពួកសៀម បានរាតត្បាតទីក្រុង បានបំផ្លិចបំផ្លាញឯកសារព្រះមហាក្សត្រ ប្រវត្តិពង្សាវតារ ច្បាប់ទម្លាប់នានាសម្រាប់រដ្ឋ និងគម្ពីសាសនាមួយចំនួនធំ។

ពួកវាបានលួចយកព្រះពុទ្ធរូបជាច្រើន ដែលនៅក្នុងចំនួននេះ មានទាំងព្រះកែវ ព្រះពុទ្ធរូបធ្វើពីកែវមរកត និងព្រះគោរូបគោណន្ទិន ព្រមទាំងសៀវភៅជាក្បួនតម្រាផ្សេងៗ។ ជាផលវិបាកអំពីរឿងនេះ ពង្សាវតារខ្មែរនាមធ្យមសម័យបានសរសេរថា

ពួកសៀម បានលួចគម្ពីចំណេះវិជ្ជាពីខ្មែរ ហើយបានខ្លាំងពូកែ ក៏ដោយសារគម្ពីទាំងនេះ។

ជាលើកទីបី ស្ថានភាពបែបនេះបានកើតឡើង គឺថាកងទ័ពសៀម បានទៅសណ្ឋិតនៅក្នុងរដ្ឋធានី ហើយមហាក្សត្រ និងកងទ័ពខ្មែរបានគ្រប់គ្រងលើទឹកដីប្រទេសទាំងអស់។ ម្តងនេះចម្បាំងបានទៅជាធ្ងន់ធ្ងរជាងចម្បាំងនៅពេលមុនៗ។ ព្រះបាទសត្ថាទី១ និងរាជបុត្ររបស់ព្រះអង្គ (ជាមហាក្សត្រ) ត្រូវបានបង្ខំចិត្តថយខ្លួនទៅតាំងទីការពារនៅស្រុកស្រីសន្ធរ ហើយតពីនេះព្រះអង្គបានថយខ្លួនទៅទីកន្លែងកាន់តែឆ្ងាយ ដែលស្ថិតនៅជិតព្រំប្រទល់ប្រទេសឡាវ។ សង្គ្រាមបានផ្ទុះឡើងនៅក្នុងប្រទេសទាំងមូល នៅពេលនោះ សមាជិកនៃរាជវង្សរបស់ព្រះបាទសត្ថាទី១ មួយរូប បានដឹកនាំការប្រយុទ្ធប្រឆាំងនឹងពួកសៀម ដោយបានបង្កបង្កើតកងទ័ពមួយយ៉ាងធំ ហើយអស់រយៈពេលពីរបីខែកន្លងមក បន្ទាប់ពីពេលដែលទីក្រុងលង្វែក បានធ្លាក់មកក្នុងអំណាចរបស់ពួកសត្រូវ កងទ័ពខ្មែរបានធ្វើការវាយលុកយ៉ាងខ្លាំងក្លា ហើយដណ្តើមទីក្រុងបានមកវិញ។ មហាសេនាបតីកងទ័ពខ្មែរ បានឡើងសោយរាជ្យ ដោយមាននាមថា ព្រះបាទរាមាជើងព្រៃ (គ.ស.១៥៩៥-គ.ស.១៥៩៦)។ ព្រះអង្គបានតាំងព្រះបរមរាជវាំង នៅស្រុកស្រីសន្ធរ។ ក៏ប៉ុន្តែ ព្រះបាទរាមាជើងព្រៃ មិនបាននៅគ្រងរាជ្យយូរទេ។ នៅក្នុងការប្រយុទ្ធពេលរាត្រីមួយ ព្រះអង្គបានចូលទិវង្គតដោយត្រូវគ្រាប់កាំភ្លើងរបស់សត្រូវ។

បន្ទាប់ពីសោយទិវង្គតរបស់ព្រះបាទរាមាជើងព្រៃ រាជសម្បត្តិបានធ្លាក់មកក្នុងបណ្តាប់ដៃរបស់ព្រះបាទបរមរាជាទី១ (ព្រះថៅ

ពញាតន់ ) ជារាជបុត្រមួយអង្គរបស់ព្រះបាទសត្ថាទី១។ ព្រះបាទថៅពញាតន់ បានធ្វើសំណើជាថ្មីទៅដល់អដ្ឋាធរអេស្ប៉ាញ៉ុលនៅហ្វីលីពីន ស្តីអំពីសម្ពន្ធភាពខាងនយោបាយ។ សម្ពន្ធភាពបានទទួលការចុះហត្ថលេខា។ ក៏ប៉ុន្តែ នៅពេលដែលកប៉ាល់អេស្ប៉ាញ៉ុលមកដល់ មានកើតវិបត្តិទាស់ទែងរវាងពួកនាវិកអេស្ប៉ាញ៉ុល និងបណ្តាអ្នកស្រុកនៅក្នុងសង្កាត់ឈ្មួញបរទេស (ចិន ចាម ជ្វា)។ កងទ័ពមហាក្សត្របានចេញមកជួយបង្ក្រាបពួកអ្នកបះបោរទាំងនេះនៅត្បូងឃ្មុំ ប៉ុន្តែមិនអាចជួយយកអាសាដល់បណ្តាសម្ពន្ធមិត្តដ៏អភ័ព្វទាំងនេះ។ ដោយមិនអាចទប់ទល់នឹងការវាយប្រហាររបស់ពួកឈ្មួញដែលខឹងសម្បា ពួកនាវិកអេស្ប៉ាញ៉ុល និងព័រទុយហ្គេស បានរត់ខ្វាត់ខ្វាយ ហើយសឹងបានបាត់ជីវិតទាំងអស់គ្នានៅពេលនោះ។

ការយកចិត្តទុកដាក់ដល់ “ជំនួញ” ពួកអឺរ៉ុប បានស្ងប់ស្ងាត់បន្ទាប់ពីមានព្រឹត្តិការណ៍បែបនេះ ហើយការផ្សាយគ្រីស្តសាសនាក៏បានឈប់។ កងទ័ពបានស្ងប់ស្ងៀមវិញ បន្ទាប់ពីបានបង្ក្រាបពួកបះបោរទាំងនេះយ៉ាងរហ័ស។ ព្រះថៅពញាតន់ បានបាត់បង់ជន្មាយុ (គ.ស.១៥៩៧) នៅក្នុងការប្រយុទ្ធនៅខេត្តត្បូងឃ្មុំ ហើយបរមរាជវាំងបានប្រគល់រាជសម្បត្តិ ដល់ឪពុកមារបស់ព្រះថៅពញាតន់ គឺព្រះថៅពញាអន (គ.ស.១៥៩៧-គ.ស.១៥៩៩)។ មហាក្សត្រអង្គនេះ បានបង្ក្រាបអំពើបះបោរនានានៅទីក្រុងភ្នំពេញ។ ក៏ប៉ុន្តែ នៅក្នុងប្រទេស ពោរពេញទៅដោយភាពច្របូកច្របល់ កើតមកពីវិបត្តិបង្ហូរឈាមគ្នា ដើម្បីដណ្តើមរាជសម្បត្តិរវាងសមាជិកនៃរាជវង្ស និងដោយការឈឺចាប់ចំពោះអំពើរំលោភនឹងការវាយលុករបស់ពួកសៀម កំហឹងប្រជាជនក៏

បានធ្លុះធ្លាយឡើង ដោយហេតុថា ពួកអ្នកដឹកនាំសក្តិភូមិពុំមានសមត្ថភាពក្នុងការរៀបចំសណ្តាប់ធ្នាប់ក្នុងប្រទេស ហើយចៅហ្វាយខេត្តទាំងឡាយ បានគ្រប់គ្រងខេត្តតាមតែការយល់ឃើញរបស់ខ្លួន។ វណ្ណៈកសិករបានធ្លាក់ខ្លួនក្រីក្រតោកយ៉ាកឥតឧបមា។ ចលនាបះបោរកុបកម្មប្រជាករក៏បានកើតមានឡើង ក្រោមការដឹកនាំរបស់ " នាយកែវ "។ គឺជាចលនាដែលមានសភាពប្រហាក់ប្រហែលគ្នានឹងចលនារបស់ " នាយកន "។ នៅក្នុងការប្រយុទ្ធប្រឆាំងចលនាបះបោរប្រជាករ ព្រះចៅពញាអន បានបាត់បង់ជន្មាយុ ក៏ប៉ុន្តែ ចលនាបះបោរកុបកម្មក្រោមការដឹកនាំរបស់ " នាយកែវ " បានជំរុញឱ្យពួកសក្តិភូមិបង្រួបបង្រួមកម្លាំងគ្នានៅជុំវិញព្រះពញាយុម។ ក្នុងគោលបំណងចៀសវាងការបង្ហូរឈាមគ្នាក្នុងការដណ្តើមរាជសម្បត្តិ រាជវង្សានុវង្សបានសម្រេចប្រគល់តំណែងមិនមែនជាមហាក្សត្រទេ តែជាឧបរាជដល់ព្រះពញាយុម។ ព្រះពញាយុម បានចាប់ផ្តើមវាយបង្ក្រាបចលនាបះបោរកុបកម្ម ហើយ " នាយកែវ " ជាអ្នកដឹកនាំចលនានេះត្រូវបានប្រហារជីវិត។ ក៏ប៉ុន្តែ តមក ឧបរាជក៏ត្រូវបានធ្លាក់ពីតំណែង តាមសេចក្តីទាមទាររបស់ព្រះវររាជមាតា។ នៅពេលនោះព្រះរាជវង្សានុវង្ស អស់មុខមន្ត្រី ព្រះសង្ឃ និងចៅហ្វាយខេត្តនានាបានព្រមព្រៀងគ្នាសុំយាងព្រះបាទសុរិយោពណ៌ (ឬព្រះបាទបរមរាជាទី៤, គ.ស.១៦០៣-គ.ស.១៦១៨) ដែលជាប់ជាឈ្លើយសង្គ្រាមនៅប្រទេសសៀម ដើម្បីឱ្យមកគ្រប់គ្រងរាជ្យនៅប្រទេសកម្ពុជា វិញ។ ស្តេចសៀម បានទទួលព្រមព្រៀងដោយដាក់លក្ខខណ្ឌខ្លះ ដែលគេនឹងអាចដឹងច្បាស់បន្ទាប់ពីដំណើរយាងត្រឡប់របស់ព្រះបាទសុរិយោពណ៌ មកកាន់មាតុភូមិវិញ។ ដំណើរ

យ៉ាងត្រឡប់របស់ព្រះអង្គ បានធ្វើឱ្យមានចលនាប្រយុទ្ធពីសំណាក់របស់ពួកអ្នកប្រឆាំងនឹងឥទ្ធិពលសៀម ដឹកនាំដោយព្រះឧបរាជ។ នៅក្នុងចម្បាំងនេះ មហាក្សត្របានសុំជំនួយពីក្រុងអយុធ្យា ហើយខេត្តនានានៅខាងត្បូងប្រទេស ត្រូវបានដណ្តើមយកមកវិញ ដោយសារកងកម្លាំងរបស់ព្រះឧទ័យ ដែលជារាជបុត្ររបស់ព្រះអង្គ។ ខេត្តទាំងនេះបានទៅជាមូលដ្ឋានដ៏រឹងមាំរបស់ព្រះអង្គ។ កងទ័ពរបស់ព្រះពញាយុម ជាឧបរាជ បានទទួលបរាជ័យ ហើយបាក់បែកខ្ចាត់ខ្ចាយ។ ព្រះពញាយុម ក៏ត្រូវគេចាប់បាន រួចធ្វើគតនៅពេលនោះ។ កងទ័ពព្រះបាទសុរិយោពណ៌ ក៏បានចូលទៅរៀបចំសណ្តាប់ធ្នាប់ឡើងវិញ នៅលើដែនដីខេត្តកំពង់ស្វាយ តមកនៅទីក្រុងអង្គរ និងនៅតំបន់ជាជម្រុកស្រូវនៅទិសខាងលិចប្រទេស។ កងទ័ពបានចូលទៅរៀបចំសណ្តាប់ធ្នាប់នៅខេត្តទ្រាំង ដែលបានបន្តការតស៊ូប្រឆាំងនឹងរាជអំណាចថ្មី។ សប្បុរសធម៌របស់មហាក្សត្រថ្មី ក្នុងការធ្វើអំណោយទានដល់ព្រះសង្ឃ ដោយការចែករំលែកដី និងស្ថាបនកម្មវត្តអារាមថ្មីៗ បានដើរតួនាទីដ៏សំខាន់ នៅក្នុងការពង្រឹងរាជអំណាច របស់មហាក្សត្រ។

ក្នុងការតបស្នងដល់ជំនួយយោធារបស់សៀម មានការរៀបចំបង្កើតឥទ្ធិពលសៀម នៅបរមរាជវាំងខ្មែរ។ ក្នុងរយៈពេលដ៏ខ្លី ព្រះបាទសុរិយោពណ៌ បានអនុញ្ញាតឱ្យមានការនិយមតាមរបៀបរបបទម្លាប់សៀម នៅបរមរាជវាំង ក៏ប៉ុន្តែឥទ្ធិពលនេះមិនបានវិវត្តទៅមុខឆ្ងាយទេ។ នៅឆ្នាំ១៦១៨ ព្រះអង្គបានលាចាកពីរាជសម្បត្តិ ហើយរដ្ឋអំណាចបានធ្លាក់ទៅក្នុងកណ្តាប់ដៃរបស់ព្រះបាទជ័យជេដ្ឋាទី២ (គ.ស.១៦១៨ - គ.ស.១៦២៨)។

មហាក្សត្រថ្មីបានវិលត្រឡប់មកកាន់តាមទំនៀមទម្លាប់ និងប្រពៃណីខ្មែរវិញ ហើយបានបដិសេធចោលនូវរបៀបរបបទម្លាប់សៀម ព្រមទាំងបានមកតាំងរដ្ឋធានីនៅក្រុងឧត្តុង្គ វិញ។ នៅក្នុងរជ្ជកាលព្រះអង្គ ព្រះបាទជ័យជេដ្ឋាទី២ បានអនុវត្តននយោបាយកែប្រែអង្គការរាជការនានា និងរៀបចាត់តាំងខាងក្រសួងយុត្តិធម៌។

# ចំពូកទី៤
## ប្រទេសកម្ពុជា នៅសតវត្សរ៍ទី១៧-១៨

សម័យកាលដ៏សុខសាន្ត ក្នុងរាជ្យព្រះបាទសុរិយោពណ៌ បានផ្តល់លទ្ធភាពឱ្យមានការពង្រឹងវិស័យសេដ្ឋកិច្ច របស់ប្រទេស។ សភាពការណ៍នេះបានអនុញ្ញាតឱ្យព្រះបាទជ័យជេដ្ឋាទី២ ចាប់ផ្តើមសាងរដ្ឋធានីឧដុង្គ ដែលទៅជារីកចម្រើនក្នុងវេលាខ្លី។ ប្រទេសជាតិបានប្រកបដោយក្តីសុខសប្បាយ និងសេចក្តីចម្រើន។ នៅជិតរដ្ឋធានី មានការស្ថាបនាមហាចេតិយនានា ដែលនៅក្នុងនេះគេបានតម្កល់ធាតុព្រះមហាក្សត្រ គឺជាមហាចេតិយដែលបានកសាងឡើងដើម្បីជាកិត្តិយស ដើម្បីរំលឹកដល់ជ័យជម្នះនានារបស់កងទ័ពខ្មែរ។ នៅក្នុងរាជ្យព្រះបាទជ័យជេដ្ឋាទី២ មានការពង្រឹងទំនាក់ទំនងផ្លូវទូត ជាមួយរាជវង្សានុវង្សស្តេចប្រទេសដាយវៀត (វៀតណាម) នាម ង្វូន។ នៅពេលនេះ ប្រទេសដាយវៀត កំពុងពង្រីកពង្រឹងមកទិសខាងត្បូង បុត្រីរបស់រាជវង្សានុវង្សស្តេចសក្តិភូមិនេះ បានធ្វើជាមហេសីមួយរបស់ព្រះបាទជ័យជេដ្ឋាទី២ នៅឆ្នាំ១៦២០។ នៅទីក្រុងឧដុង្គ ចាប់ផ្តើមមានពួកអ្នកជំនួញ និងអ្នកលក់ដូរវៀតណាម ដែលធ្វើការប្រណាំងប្រជែងជាមួយអ្នកជំនួញចិន និងជប៉ុន។ នៅពេលនោះ ក្រុមហ៊ុនពាណិជ្ជកម្មហុល្លង់ បានចាប់ផ្តើមធ្វើសកម្មភាពរបស់ខ្លួនដ៏សកម្មនៅទីក្រុងឧដុង្គ។

នៅឆ្នាំ១៦២៥ កងទ័ពខ្មែរបានទទួលជ័យជម្នះពីរដងក្នុងចម្បាំងប្រឆាំងនឹងពួកកងទ័ពសៀម។ ជ័យជម្នះមួយបានទទួល

ក្នុងចម្បាំងក្រោមការដឹកនាំរបស់ព្រះបាទជ័យជេដ្ឋាទី២ នៅជិតស្រុកបរិបូណ៌។ ជ័យជម្នះមួយទៀតបានទទួលក្រោមការដឹកនាំរបស់ព្រះអង្គម្ចាស់ឧទ័យ។ ការសាកល្បងរបស់កងនាវាចរណ៍យោធាសៀម ដើម្បីចូលរួមលុកលុយតាមឆ្នេរសមុទ្រខ្មែរ ក៏ត្រូវបានទទួលបរាជ័យជាដំណំ។ នៅពេលក្រោយៗមក នៅក្នុងរាជ្យព្រះបាទជ័យជេដ្ឋាទី២ នៅក្នុងដែនដីភាគខាងអាគ្នេយ៍ គឺព្រៃនគរ ចាប់ផ្ដើមមានពួកកសិករវៀតណាម ដែលមកធ្វើស្រែចម្ការលើដីទំនេរនៅទីនេះ ដោយសារការអនុញ្ញាតរបស់រដ្ឋបាលខ្មែរ។ ការចូលមករស់នៅ និងការបង្កើតភូមិដ្ឋានវៀតណាម នៅតាមដីស្រែចម្ការតាមមាត់ទន្លេមេកុង មិនបានធ្វើឱ្យប៉ះពាល់ដល់ដីស្រែចម្ការ កាន់កាប់ដោយកសិករខ្មែរនៅទីនេះ ដោយហេតុថាកសិករខ្មែរតាមទម្លាប់របស់ខ្លួនចូលចិត្តរស់នៅលើទីទួល ហើយកសិករវៀតណាម ចូលចិត្តរស់នៅតាមមាត់ព្រែក និងពាមទន្លេនានា។ កសិករទាំងនេះបានបង់ពន្ធដារដូចជាកសិករខ្មែរដែរ។ បន្តិចម្ដងៗ ជនជាតិវៀតណាម បានចូលទៅបង្កភូមិដ្ឋាននៅទីក្រុងនានា។ នៅសម័យនោះ ទំនាក់ទំនងរវាងរដ្ឋបានប្រកបដោយលក្ខណៈមិត្តភាព ដោយហេតុថា រាជការនៃរាជាណាចក្រកម្ពុជា តំបន់នេះបានត្រួតត្រា ហើយរាជការខ្មែរក៏បានទទួលពន្ធដារកាន់តែច្រើន។

នៅសម័យកាលភាគខាងចុងនៃទសវត្សរ៍ទី២ វិបត្តិដ៏ខ្លាំងក្លាបានកើតមានឡើងរវាងរាជវង្សានុវង្ស ក្នុងការដណ្ដើមរាជសម្បត្តិ។ ព្រះបាទពញានូ ក៏បានឡើងសោយរាជ្យ នៅប្រទេសកម្ពុជា (១៦៣០-១៦៤០) ក៏ប៉ុន្តែ តាមការពិត អំណាចរបស់រដ្ឋទាំងអស់បានស្ថិតក្នុងកណ្ដាប់ដៃរបស់ព្រះឧទ័យ ដែលធ្វើជា

ឧបរាជនៅឆ្នាំ១៦២៧ មានកើតវិបត្តិមួយជាមួយនឹងក្រុមហ៊ុនពាណិជ្ជកម្មហុល្លង់។ ប៉ុន្តែ វិបត្តិនេះត្រូវបានដោះស្រាយបន្ទាប់ពីការយល់ព្រមចុះចាញ់របស់ក្រុមហ៊ុននេះ ដែលបាននៅបន្តសកម្មភាពរបស់ខ្លួនតទៅទៀត រហូតដល់ក្រុមហ៊ុននេះបានពង្រីកសកម្មភាពរបស់ខ្លួន ជាពិសេសនៅឆ្នាំ១៦៤០-១៦៤២។ នៅទសវត្សរ៍ទី៣ ចលនាបះបោរបណ្តារាស្ត្របានកើតមានឡើងនៅខេត្តខ្លះ ក៏ប៉ុន្តែ ចលនានេះ ត្រូវបានបង្ក្រាបដោយកងទ័ពមហាក្សត្រ។

ព្រះឧទ័យជាឧបរាជ បានខិតខំសាកល្បងលើករាជបុត្របង្កើត នាមព្រះអង្គនន់ ឱ្យឡើងសោយរាជ្យសម្បត្តិ (ឆ្នាំ១៦៤០-១៦៤២) ហើយការនេះបានបង្កើតឱ្យមានវិបត្តិដ៏មួយខ្លាំងក្នុងរាជវង្សានុវង្ស។ ព្រះអង្គម្ចាស់ព្រះនាមអង្គចន្ទ បានចេញមុខធ្វើការប្រយុទ្ធប្រឆាំង ហើយព្រះឧទ័យជាឧបរាជត្រូវបានគេធ្វើឃាត មានការបង្ក្រាបដ៏កាចសាហាវបំផុត ដល់អ្នកគាំទ្រទាំងឡាយរបស់ព្រះឧទ័យ។ ព្រះអង្គចន្ទ បានឡើងសោយរាជ្យ ហើយបានទទួលនាមថា ព្រះបាទរាមាធិបតីចន្ទ (១៦៤២-១៦៥៩)។ បន្ទាប់ពីការឡើងសោយរាជ្យសម្បត្តិ ព្រះបាទរាមាធិបតីចន្ទ បានយល់ព្រមធ្វើការសម្រុះសម្រួលនឹងរាជវង្សានុវង្ស ដែលជាសាច់ញាតិនឹងព្រះឧទ័យ ហើយរាជវង្សានុវង្សជាសាច់ញាតិព្រះឧទ័យមួយរូប បានទទួលតំណែងជាឧបរាជ។

នៅសម័យពាក់កណ្តាលសតវត្សរ៍ទី១៧ នៅប្រទេសកម្ពុជាមានកើតវិបត្តិដ៏ខ្លាំងខាងសាសនា។ ប្រកបដោយចិត្តកាចសាហាវ ហើយមិននឹងន ព្រមទាំងប្រកបដោយការមន្ទិលសង្ស័យគ្រប់យ៉ាងដល់រាជវង្សានុវង្ស ព្រះបាទរាមាធិបតីចន្ទ បានជ្រើសរើសបរិវារ

ហែហមរបស់ខ្លួនក្នុងបណ្តាកងផ្ទាំជាតិចាម-ម៉ាឡាយូ ហើយនៅឆ្នាំ១៦៤៣ ព្រះអង្គបានចាប់ផ្តើមកាន់សាសនាឥស្លាម បានប្រែឈ្មោះថាជា ព្រះបាទអង្គចន្ទអ៊ីប្រាហ៊ីម ហើយតមក ដោយពឹងផ្អែកទៅលើឥទ្ធិពលខាងសាសនារបស់ព្រះមហាក្សត្រ អ្នកកាន់សាសនាមហាម៉ាត់ ក៏បានចាប់ផ្តើមឃោសនាសាសនាថ្មីនៅក្នុងប្រទេស។ ក៏ប៉ុន្តែ ការឃោសនាសាសនាឥស្លាម ពុំបានទទួលជោគជ័យធំដុំប៉ុន្មាន ដូចជាការឃោសនាសាសនាគ្រឹស្តដែរ។ ហេតុនេះហើយ បានជានៅពេលក្រោយមក ព្រះបាទអង្គចន្ទអ៊ីប្រាហ៊ីម បានឈមមុខចំពោះការប្រឆាំងពីសំណាក់បណ្តាជនក្នុងប្រទេស និងពីសំណាក់នៃរាជវង្សានុវង្ស។

អ្នកកាន់ពុទ្ធសាសនា បានចាប់ផ្តើមគាំទ្រដល់រាជបុត្ររបស់ព្រះបាទឧទ័យ ព្រះនាមព្រះបទុមរាជា ដែលបានចាប់ផ្តើមធ្វើការប្រឆាំងចេញមុខនឹងព្រះបាទអង្គចន្ទអ៊ីប្រាហ៊ីម នៅឆ្នាំ១៦៥៨។ ទោះបីក្នុងការប្រយុទ្ធប្រឆាំងជាដំបូងនេះ ព្រះបទុមរាជាបានទទួលបរាជ័យក្តី ក៏នៅពេលតមក ដោយសារការគាំទ្ររបស់ប្រជាជន ព្រះអង្គបានបន្តការតស៊ូ បានធ្វើចម្បាំងឈ្នះព្រះបាទអង្គចន្ទ ហើយបានចាប់ព្រះបាទអង្គចន្ទ ជាឈ្លើយសង្គ្រាម។ នៅពេលក្រោយបន្តិចមក ព្រះបាទអង្គចន្ទ បានទទួលអនិច្ចកម្មនៅឆ្នាំ១៦៥៩។ នៅពេលគ្រងរាជ្យសម្បត្តិប្រទេសកម្ពុជាពីឆ្នាំ១៦៥៩-១៦៧២ ព្រះបាទបទុមរាជា បានរៀបចំចាត់ទុកថាពុទ្ធសាសនាជាសាសនារបស់រដ្ឋ។ ក្នុងការថ្លែងអំណរគុណដល់ការគាំទ្រនៅក្នុងការតស៊ូប្រឆាំងការពង្រីកសាសនាឥស្លាម នៅក្នុងប្រទេស ព្រះអង្គបានបន្ធូរបន្ថយ ហើយផ្តល់សិទ្ធិនានាដល់ជនជាតិវៀតណាម នៅព្រៃនគរ ដោយការផ្តល់សិទ្ធិខាងការ

កាន់កាប់កេរមរតកឱ្យស្មើគ្នានឹងសិទ្ធិរបស់ជនជាតិខ្មែរ។ ព្រះអង្គបានធ្វើជំនួយជាភស្តុភារដល់ស្តេចវៀតណាម នាមង្វន។ស្ថានភាពនៅក្នុងប្រទេសពេលនោះ ក៏មិនទាន់បានប្រកបដោយសេចក្តីស្ងប់ស្ងៀមសុខសាន្តនៅឡើយ ហើយគេអាចបញ្ជាក់នូវសភាពការណ៍បែបនេះ ដោយសារការសុខចិត្តសម្របសម្រួលរបស់វៀតណាម។

នៅឆ្នាំ១៦៧២ អំពើឃុបឃិតគំនិតក្បត់រវាងរាជវង្សានុវង្សបានកើតមានឡើង ហើយបានបណ្តាលឱ្យព្រះបាទបទុមរាជាសោយទិវង្គតពេលនោះ។ ព្រះរាជបុត្រព្រះបាទបទុមរាជា បានឡើងសោយរាជ្យបន្តនៅឆ្នាំ១៦៧៣។ ក៏ប៉ុន្តែ នៅពេលជាមួយគ្នានោះ បងប្អូនជីដូនមួយរបស់ព្រះអង្គព្រះនាមអង្គតន់ បានចេញមុខប្រឆាំង។

យើងសូមកត់បញ្ជាក់ថា វិបត្តិ និងអំពើឃុបឃិតគំនិតក្បត់រវាងរាជវង្សានុវង្ស ដែលជាលក្ខណៈពិសេស មិនតែសម្រាប់ប្រទេសកម្ពុជា ត្រូវបានកត់ត្រាយ៉ាងល្អិតល្អន់ដោយរាជពង្សាវតារនានា ដែលបានយកចិត្តទុកដាក់ជាពិសេសដល់វិបត្តិ និងទំនាស់ក្នុងរាជវង្សានុវង្សទាំងនេះ នៅក្នុងសម័យកាលសក្តិភូមិ។ វិបត្តិរវាងបងប្អូនទាំងពីររូបនៅក្នុងរាជវង្សានុវង្ស បានផ្តល់កលល្បិចដល់មហាក្សត្រវៀតណាម នាម ង្វន ឱ្យចូលមកជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេស។ សមាជិកនៃរាជវង្សានុវង្សស្តេចវៀតណាមនាម ហៀន ដែលត្រួតត្រាទឹកដីដាងឈ្វង (នៅវៀតណាមខាងត្បូង) បានបញ្ជូនកងកម្លាំងទ័ពមកធ្វើចម្បាំងនៅកម្ពុជា ដែលនៅពេលនោះ កងទ័ពសៀម ក៏បានចូលមកធ្វើចម្បាំងនៅទីនេះដែរ។ នៅពេលនោះ គឺស្តេចវៀតណាម បានចូលរួបរួមយ៉ាង

ខ្លាំងទៅក្នុងកិច្ចការនៅប្រទេសកម្ពុជា។ កងទ័ពវៀតណាម បានមកជួយយកអាសារ ដល់គូរប្រណាំងប្រជែងដណ្ដើមរាជ្យមួយរូប គឺព្រះអង្គតន់។ សមាជិកមួយរូបនៃរាជវង្សានុវង្សបានសម្រេចបណ្ដេញសមាជិកមួយរូបទៀតនាមអង្គនន់ ចេញពីរដ្ឋធានី និងតំបន់ខាងកណ្ដាលនៃប្រទេស ហើយតមក សមាជិករាជវង្សានុវង្សបានឡើងសោយរាជ្យក្នុងបរមនាម ឈ្មោះ ជ័យជេដ្ឋាទី៤។ នៅពេលនោះ កងទ័ពស្ដេចវៀតណាម មិនបានប្រថុយចូលលុកលុយយ៉ាងជ្រៅមកក្នុងប្រទេសទេ។ក៏ប៉ុន្តែ ស្ដេចវៀតណាម បានទាក់ទងនឹងព្រះអង្គនន់ ហើយបានជួយឱ្យក្សត្រនេះពង្រឹងឥរិយាបថរបស់ខ្លួននៅលើដែនដីព្រៃនគរ។ នៅទីនេះ ព្រះអង្គនន់បានប្រកាសខ្លួនជាព្រះមហាក្សត្រ ដែលស្ថិតនៅក្រោមអនិស្សរភាពរបស់ស្ដេចវៀតណាម។ ទោះបីនៅក្នុងការធ្វើចម្បាំង ស្ដេចវៀតណាម ពុំបានជ័យជម្នះអ្វីនៅពេលនោះ ហើយស្ដេចវៀតណាមគ្មានការចំណេញខាងទឹកដីក៏ដោយ ក៏នេះគឺជាជោគជ័យទី១ ដ៏សំខាន់នៅក្នុងនយោបាយរបស់ស្ដេចវៀតណាម នៅទឹកដីប្រទេសមកទិសខាងត្បូង។

ព្រះបាទជ័យជេដ្ឋាទី៤ បានឡើងគ្រប់គ្រងប្រទេសពីឆ្នាំ១៦៧៥។ ក្នុងរាជ្យរបស់ព្រះអង្គ នៅក្នុងប្រទេសមានស្ថេរភាពខាងនយោបាយ។ នៅក្នុងការគ្រប់គ្រងប្រទេសមានការអនុវត្តនូវគោលការណ៍ដូចតទៅ គឺទោះបីមានការឃ្លាតចាកពីរាជបល្ល័ង្ក ក៏ដោយ ក៏មហាក្សត្រនៅតែរក្សានូវអំណាចរដ្ឋពេញលេញ ព្រមទាំងរក្សានូវសិទ្ធិចំពោះការវិលត្រឡប់មកសោយរាជ្យវិញ។ គោលការណ៍នេះ ត្រូវបានអនុវត្ត ដើម្បីចៀសវៀងនូវវិបត្តិក្នុងរាជវង្សានុវង្ស ក្នុងការជ្រើសរើសស្ដេចឡើងសោយរាជ្យ ដែល

ជាហេតុបណ្ដាលឱ្យប្រទេសទៅជាទន់ខ្សោយ (គឺជាគោលការណ៍ដែលមិនបានកំណត់ ឱ្យព្រះរាជបុត្រច្បងឡើងសោយរាជ្យស្នងព្រះវរបិតា)។ គោលការណ៍បែបនេះ បានកើតមានឡើងតាំងពីសម័យចក្រភពកម្ពុជទេស នៅពេលដែលព្រះមហារាជបានកាន់កាប់អំណាចរដ្ឋដ៏ធំធេង ហើយអាចចែករំលែកអំណាចបាននៅក្នុងកាលៈទេសៈនៃចែជន្យ ដែលកើតមានឡើងនៅក្នុងការជ្រើសរើសមហាក្សត្រ ហើយសភាពការណ៍នេះមិនបានផ្ដល់ជាកលល្បិចដល់ប្រទេសជាតិ ខាងឱ្យប្រើប្រាស់បាននៅក្នុងសម័យកាលដែលមានអស្ថិរភាព ក្នុងឱកាសនៃការសោយទិវង្គតរបស់មហាក្សត្រ។ នៅក្នុងពេលឥឡូវ គោលការណ៍បែបនេះបានទៅជាគោលការណ៍មិនសមហេតុសមផល ហើយអាចផ្ដល់គ្រោះថ្នាក់ដល់ប្រទេស។ ហេតុនេះហើយបានជាមានការឃ្លាតចាកអំពីគោលការណ៍បែបនេះ។

ព្រះបាទជ័យជេដ្ឋាទី៤ បានលើករាជធានីពីឧត្តុង្គ ទៅតាំងនៅទ្រទំជ្រុង (សំរោងទង)។ ចម្បាំងជាមួយព្រះអង្គនន់នៅតែបន្តទៅទៀត។ នៅសម័យនោះ ពួកអ្នកភៀសខ្លួនពីប្រទេសចិន បានមកតាំងទីលំនៅនៅតាមមាត់ទន្លេដាងឈូងនាសតវត្សរ៍ទី៧។ ស្ដេចវៀតណាម នឹកឃើញដល់ស្ដេចចំណុះមកខាងខ្លួន គឺព្រះអង្គនន់ ហើយបានបញ្ចុះបញ្ចូលឱ្យព្រះអង្គនន់ព្រមព្រៀងឱ្យជនជាតិភៀសខ្លួនចិន ដែលមានចំនួនពីរ-បីពាន់នាក់តាំងលំនៅឋាននៅលើដីក្នុងទីវាលទំនាបនៃទន្លេមេកុង។

ចំពោះរឿងនេះ ព្រះបាទជ័យជេដ្ឋាទី៤ បានបញ្ចេញយោបល់ប្រឆាំង ពុំព្រមព្រៀងតាម។ ទីកន្លែងនៅទីនេះ មិនសូវមានបណ្ដាជនរស់នៅច្រើន ហើយក្នុងកាលៈទេសៈខ្លះ បានទៅ

ជាជម្រករបស់ចោរប្លន់សមុទ្រ។ មិនតែប៉ុណ្ណោះ រដ្ឋក៏ពុំមានអំណាចពេញលេញនៅទីកន្លែងដ៏ឆ្ងាយនេះ។ នៅក្នុងខេត្តទាំងនេះដែលគេហៅថា ខេត្តបារីយ៉ា និងឌុងង៉ៃ ក្រៅពីភូមិឋានកសិករខ្មែរមានទាំងភូមិឋានកសិករវៀតណាម ទៀតផង។ តាមពិត មាត់ទន្លេខាងឆ្វេងនៃទីវាលទំនាបទន្លេមេកុង ស្ថិតនៅក្នុងការគ្រប់គ្រងរបស់ព្រះអង្គនន់។

នៅឆ្នាំ១៦៨២ ព្រះអង្គនន់ បានបង្កើតកម្លាំងទ័ពរបស់ខ្លួន ដោយការកំណែនថ្មីៗពីបណ្ដាជនចិន ហើយបានចាប់ផ្ដើមធ្វើការវាយប្រហារមកលើកងទ័ពព្រះបាទជ័យជេដ្ឋាទី៤។ ក៏ប៉ុន្តែនៅក្នុងចម្បាំងនេះ ព្រះអង្គនន់ ពុំបានទទួលជោគជ័យអ្វីឡើយ។ នៅឆ្នាំ១៦៨៧ ព្រះបាទជ័យជេដ្ឋាទី៤ បានដាក់រាជ្យ ហើយផ្ដល់រាជ្យសម្បត្តិដល់ក្មួយប្រុសរបស់ព្រះអង្គ។ ក៏ប៉ុន្តែ នៅពេលក្រោយបន្តិចមក ក្មួយប្រុសនេះបានទទួលសោយទិវង្គត ហើយព្រះបាទជ័យជេដ្ឋា បានចាកចេញពីផ្នួស រួចត្រឡប់មកសោយរាជ្យសម្បត្តិវិញ។ នៅឆ្នាំ១៦៨៨ នាយក្រុមពួកជនភៀសខ្លួនចិន ឈ្មោះ ហ្វូហ្វូហ្វួញស៊ិញ ដែលដាក់ឈ្មោះខ្លួនឯងថាជា “ មេទ័ពដ៏កាចសាហាវ ” បានចាប់ផ្ដើមធ្វើជាមេក្លោងរបស់ក្រុមពួកចោរប្លន់តាមទន្លេ ហើយបានកសាងបន្ទាយ និងតាំងអំណាចរបស់ខ្លួននៅទីនេះ។ ព្រះបាទជ័យជេដ្ឋាទី៤ ដោយបានឃើញថាព្រះអង្គនន់ គ្មានសមត្ថភាពនឹងបង្ក្រាបកងចោរប្លន់តាមទន្លេនេះក៏បានចាប់ផ្ដើមធ្វើការប្រយុទ្ធ ដើម្បីភ្ជាប់ដែនដីព្រៃនគរ មកប្រទេសកម្ពុជា វិញ។ ទំនាក់ទំនងទូតជាមួយស្ដេចវៀតណាមនៅដាងឈ្នួង ត្រូវបានផ្ដាច់ ហើយបន្ទាយបីក៏ត្រូវបានស្ថាបនាឡើងនៅតាមមាត់ទន្លេមេកុង។ ភិតភ័យអំពីសកម្មភាពបែបនេះ

ព្រះអង្គនន់ បានផ្ដល់ព័ត៌មានអំពីព្រឹត្តិការណ៍ទាំងនេះដល់ស្ដេចវៀតណាម។ ស្ដេចវៀតណាមនាម ហួរ-ងា បន្ទាប់ពីបានពិភាក្សាជាមួយនឹងទីប្រឹក្សារបស់ខ្លួន ក៏បានសាកល្បងបង្ក្រាបក្រុមចោរប្លន់ដឹកនាំដោយ ហ្វូហ្វូហួញស៊ិញ ដោយកងកម្លាំងតំបន់ ហើយបើការបង្ក្រាបបែបនេះមិនបានសម្រេច នឹងត្រូវមានការបញ្ជូនកងកម្លាំងទ័ពរបស់ព្រះអង្គនន់ និងកងកម្លាំងទ័ពវៀតណាម ថែមទៀត។

ព្រះបាទជ័យជេដ្ឋាទី៤ បានគំរាមកំហែងនិរទេសជនជាតិចិនទាំងនេះ ចំពោះអំពើជ្រៀតជ្រែករបស់ពួកនេះនៅក្នុងកិច្ចការនៃប្រទេសទាំងពីរ។ ពួក ហ្វូ-ហ្វ៊ង-សាញ់ ជានាយកងកម្លាំងចោរប្លន់ចិន បានរត់ទៅលាក់ខ្លួនពួនអាត្មា នៅក្នុងបន្ទាយសង់ឡើងនៅក្នុងព្រៃស្រោង ហើយលែងធ្វើការប្រយុទ្ធជាមួយនឹងកងទ័ពខ្មែរ និងកងទ័ពវៀតណាម តទៅទៀត។ នៅពេលតមក មេទ័ពវៀតណាមឈ្មោះ វ៉ាន់-ឡុង បានចូលទៅឡោមព័ទ្ធបន្ទាយរបស់ហ្វូ-ហ្វ៊ង-សាញ់ ហើយវាយលុយបន្ទាយនេះបាន។ បន្ទាប់ពីបង្ក្រាបកងកម្លាំងចោរប្លន់ចិន ហើយដោយទទួលបញ្ជាការបន្ថែមពីថ្នាក់លើ កងកម្លាំងរបស់ វ៉ាន់-ឡុង ក៏បានធ្វើចលនាឡើងតាមទន្លេ ហើយបានវាយដណ្ដើមយកបន្ទាយទាំងបីរបស់ព្រះបាទជ័យជេដ្ឋាទី៤ ដោយមិនឥតដឹងខ្លួន។ កងកម្លាំងជួរមុខរបស់កងទ័ពសម្ពន្ធមិត្តដឹកនាំដោយព្រះអង្គនន់ មានទាហានចំនួន ៥ពាន់នាក់ ត្រូវបានវាយកម្ទេចដោយកងទ័ពរបស់ព្រះបាទជ័យជេដ្ឋាទី៤ នៅសមរភូមិវាលវង់។ ក្រោយពីបានដឹងដំណឹងអំពីបរាជ័យនេះ កងកម្លាំងវៀតណាម ដែលបានធ្វើចលនាចូលជ្រៅមកក្នុងប្រទេសកម្ពុជា ក៏បានវិលត្រឡប់ថយក្រោយវិញ។

នៅពេលក្រោយមកទៀត ព្រះអង្គនន់ បានរៀបចំយ៉ាងហ្មត់ចត់នូវកងទ័ពរបស់ខ្លួន ដើម្បីធ្វើចម្បាំងវាយលុកសារជាថ្មី។ នៅឆ្នាំ១៦៨៩ បន្ទាប់ពីការធ្វើកំណែនជនជាតិចាម នៅដាងឈ្លួង និងជនជាតិចិន នៅតាមទីទំនាបនៃទន្លេមេកុង កងកម្លាំងរបស់ព្រះអង្គនន់ បានធ្វើចលនាវាយលុកមកទិសខាងជើង ហើយវាយដណ្ដើមបានទីក្រុងភ្នំពេញ។ម្ដងនេះ ព្រះបាទជ័យជេដ្ឋាទី៤ ត្រូវបានបង្ខំចិត្តបែងចែកទីក្រុងស្រីសន្ធរ ឱ្យព្រះអង្គនន់។ ក៏ប៉ុន្តែនៅពេលក្រោយនេះបន្តិច ព្រះអង្គនន់ បានសោយទិវង្គត។ ដោយឆ្លៀតឱកាសប្រើប្រាស់ស្ថានភាពបែបនេះ ស្ដេចវៀតណាម បានប្រកាសថា រាជសម្បត្តិជាកេរមរតករបស់ព្រះអង្គនន់ នៅព្រៃនគរ មានទាំងដែនដីនៅត្រើយខាងឆ្វេង នៃទីវាលទំនាបទន្លេមេកុង ត្រូវបញ្ចូលមកក្នុងទឹកដីដាងឈ្លួង (ទឹកដីវៀតណាម)។

នៅឆ្នាំ១៦៩១ ព្រះបាទជ័យជេដ្ឋាទី៤ បានទទួលការអភិសេកជាមហាក្សត្រប្រទេសកម្ពុជា ជាផ្លូវការ រយៈកាលនៃការសោយរាជ្យលើកទី១ គឺពី១៦៩១-១៦៩៣។ នៅសម័យកាលនៃទសវត្សរ៍ទី៩ មានការពង្រឹងការិយាល័យសក្តិភូមិនិយម និងអំណាចរបស់ពួកសក្តិភូមិលើបណ្ដាកសិករ ដោយមានការធ្វើច្បាប់កែប្រែមួយចំនួនធំ នៅក្នុងរាជ្យសម្បត្តិនៃមហាក្សត្រអង្គនេះ។ អត្ថបទច្បាប់នានាត្រូវបានត្រួតពិនិត្យឡើងវិញ ស្របទៅតាមសភាពការណ៍ថ្មីៗ ដោយមានការបដិសេធនូវការផ្ដន្ទាទោសដោយប្រហារជីវិតដ៏ឃោរឃៅមួយចំនួន ដោយមានការបង្កើតច្បាប់ទាក់ទងនឹងការផ្លាស់ប្ដូរខាងសង្គមកិច្ច ដែលត្រូវបានអនុវត្តជាធរមាននៅក្នុងសង្គមនៅសតវត្សរ៍ទី ១៦-១៧។

ទំនាក់ទំនងជាមួយប្រទេសវៀតណាមខាងត្បូង (ដាងឈ្ចុង) មានសភាពតឹងតែងជានិច្ច។ នៅឆ្នាំ១៦៩២ ជនជាតិចាម ដែលរស់នៅក្នុងរដ្ឋចាម ចុងក្រោយបង្អស់ ឈ្មោះ ប៉ាន់ដូរ៉ាំង ដែលទើបនឹងរលាយរលត់ បានរត់ភៀសខ្លួនចូលមកប្រទេសកម្ពុជា ហើយបានមកតាំងទីលំនៅនៅជិតទីក្រុងលង្វែក។ នៅពេលជាមួយគ្នានោះ ពួកឈ្លើយសង្គ្រាមជាតិឡាវ ក៏ត្រូវបានអនុញ្ញាតឱ្យតាំងទីលំនៅនៅក្នុងខេត្តបាទី។ ការឡើងសោយរាជ្យលើកទីពីររបស់ព្រះបាទ ជ័យជេដ្ឋាទី៤ បន្ទាប់ពីការសោយទិវង្គតរបស់ក្មួយព្រះអង្គ ដែលបានឡើងសោយរាជ្យចំនួនពីរឆ្នាំ (ពី១៦៩៥-១៦៩៧) ត្រូវបានកំណត់ដោយមានការបះបោរ របស់រដ្ឋមន្ត្រីជាន់ខ្ពស់មួយរូបរបស់ព្រះអង្គ នាមឈ្មោះ អេម។ ទោះបីការបះបោរប្រឆាំងនឹងព្រះអង្គ បានទទួលការគាំទ្រពីប្រទេសវៀតណាមក្តី ក៏ការបះបោរនេះត្រូវបានបង្ក្រាបឱ្យសូន្យទៅវិញ។ ប៉ុន្តែគោលដៅធំរបស់មហាក្សត្រប្រទេសកម្ពុជា គឺការតស៊ូដើម្បីភ្ជាប់ដែនដីព្រៃនគរ បារីយ៉ា កំពាំង ស្រកាត្រី មកមាតុភូមិដើមវិញ ក៏ប៉ុន្តែគោលបំណងនេះមិនបានសម្រេចសោះ។

នៅឆ្នាំ១៦៩៩ ព្រះបាទជ័យជេដ្ឋាទី៤ បានដាក់រាជ្យលើកទីពីរ ដើម្បីឱ្យកូនប្រសាព្រះអង្គឡើងសោយរាជ្យជំនួស គឺមេទ័ពនាម ព្រះអង្គអេម (១៦៩៩ - ១៧០១)។ ក៏ប៉ុន្តែ នៅពេលក្រោយមក ព្រះអង្គអេងត្រូវបានគេដកចេញពីរាជ្យសម្បត្តិ ហើយជាលើកទីបី ព្រះបាទជ័យជេដ្ឋាទី៤ បានវិលត្រឡប់មកសោយរាជ្យសម្បត្តិម្តងទៀត។ វិបត្តិជាមួយប្រទេសវៀតណាម នៅតែមានដំណើរតទៅទៀត។ ដោយមានការគាំទ្រពីស្តេចប្រទេសវៀតណាម មន្ត្រីជាន់ខ្ពស់មួយរូបរបស់ព្រះបាទជ័យជេដ្ឋា នាម

ឈ្មោះ គីម បានដឹកនាំការបះបោរប្រឆាំងព្រះអង្គ ក៏ប៉ុន្តែ ការបះបោរនេះត្រូវបានបង្ក្រាបក្នុងពេលដ៏ឆាប់រហ័ស ហើយមន្ត្រី គីម ត្រូវគេចាប់បានជាឈ្លើយសង្គ្រាម។ នៅឆ្នាំ១៧០២ ព្រះបាទជ័យជេដ្ឋាទី៤ បានចាកចេញពីរាជ្យសម្បត្តិ ហើយបានផ្តល់រាជ្យសម្បត្តិនេះដល់ព្រះរាជបុត្រនាមធម្មោរាជា ដែលមានជន្មាយុ ១២វស្សា ហើយដែលបានឡើងសោយរាជ្យលើកទី១ ពីឆ្នាំ ១៧០២-១៧០៤។ក៏ប៉ុន្តែ តាមការពិតដោយហេតុថា មហាក្សត្រថ្មីមានវ័យក្មេងពេក ក៏ព្រះបាទជ័យជេដ្ឋា បាននៅកាន់កាប់កិច្ចការរាជ្យសម្បត្តិជំនួស។ នៅឆ្នាំ១៧០៤ ព្រះបាទជ័យជេដ្ឋាទី៤ បានឡើងសោយរាជ្យជាថ្មីម្តងទៀត ហើយការសោយរាជ្យរបស់ព្រះអង្គត្រូវបានចប់សព្វគ្រប់នៅឆ្នាំ១៧០៦។ នៅពេលតមក ព្រះបាទធម្មោរាជា ក៏បានឡើងមកដោយរាជ្យជាលើកទីពីរ ពីឆ្នាំ១៧០៦-១៧១០។រហូតដល់ឆ្នាំ១៧១៧ព្រះបាទធម្មោរាជាបាន សោយរាជ្យសម្បត្តិនៅប្រទេសកម្ពុជា ជាមួយគ្នានឹងព្រះអង្គ អេម។

ពេលវេលាដ៏យូរយានៃរជ្ជកាល របស់ព្រះបាទជ័យជេដ្ឋាទី៤ ត្រូវបានកំណត់ដោយការពង្រឹងស្ថានភាពនយោបាយនៅក្នុងប្រទេស និងក្រៅប្រទេស។ នាសម័យពាក់កណ្តាល នៃសតវត្សរ៍ទី១៧ ប្រទេសកម្ពុជា ស្ថិតនៅជាប្រទេសខ្លាំងជាងគេមួយនៅឧបទ្វីបឥណ្ឌូចិន។ ទឹកដីប្រទេសកម្ពុជា លាតសន្ធឹងចាប់ពីភាគមធ្យម និងភាគខាងក្រោមនៃទន្លេមេកុង បានគ្របដណ្តប់លើទីវាលទំនាបនៃទន្លេមកុង និងភូមិភាគខាងកើតនៃទីវាលទំនាបទន្លេមេណាម។ ប្រទេសកម្ពុជា បានធ្វើការតស៊ូយ៉ាងអង់អាចនៅភូមិភាគខាងជើង និងខាងលិច ប្រឆាំងនឹងពួកសក្តិភូមិសៀម។

នៅពេលនោះ ការបែងចែកដ៏សំខាន់ជាងគេខាងរដ្ឋបាលប្រទេស គឺខេត្តដែលកើតមកពីការប្រមូលផ្តុំនៃស្រុកនានា។ ស្រុកកើតមកពីការប្រមូលផ្តុំនៃឃុំនានា ហើយឃុំនីមួយៗកើតមកពីការប្រមូលផ្តុំនៃភូមិនានា។ មេឃុំដែលត្រូវបានជ្រើសរើសឡើងជាអ្នកគ្រប់គ្រង និងដឹកនាំកិច្ចការសព្វសារពើរបស់ឃុំ។ នៅតាមឃុំ មានរក្សានូវសំណល់របៀបរបបសហគមន៍បូរាណខ្លះៗនៅក្នុងជីវភាពនៅស្រុកស្រែ ដូចជាការប្រវាស់ដៃគ្នានៅក្នុងកិច្ចការកសិកម្ម ការដោះស្រាយរឿងក្តីក្តាំខ្លះៗរបស់អ្នកឃុំដោយមេឃុំ។ល។

សហគមន៍ បានឈប់លែងបំពេញតួនាទីជាមូលដ្ឋាន នៃរបៀបរស់នៅស្រុកស្រែទៀតហើយ។ មូលដ្ឋាននៃរបៀបរស់នៅនៅស្រុកស្រែ គឺភូមិឋាន ឬភូមិ។ កសិករគ្មានទទួលការកំណត់ឱ្យរស់នៅតែនៅស្រុកស្រែណាមួយឡើយ ហើយគេទាំងឡាយអាចធ្វើដំណើរទៅតាមប្រទេស ដើម្បីស្វះស្វែងរកដីធ្វើស្រែចម្ការដោយហេតុថា នៅក្នុងប្រទេសមានដីទំនេរមួយចំនួនធំ ដែលគេអាចត្រួសត្រាយធ្វើស្រែចម្ការ។ ក៏ប៉ុន្តែ ទោះបីជាកសិករបានទៅរស់នៅទីណាក្តី គេត្រូវតែបង់ពន្ធដារដល់រដ្ឋ ហើយត្រូវតែបំពេញកាតព្វកិច្ចរបស់ខ្លួនចំពោះជនសក្តិភូមិដែលជា “មេកម្លាំង” ដោយចូលខ្លួនធ្វើជា “មនុស្ស” ឬជាសមាជិករបស់មេកម្លាំងណាមួយ។ សភាពការណ៍នេះ គឺជាបែបបទម្យ៉ាងនៃរបបសក្តិភូមិ គឺថាកសិករម្នាក់ៗត្រូវតែមាន “ មេកើយ ” ជាមេកម្លាំង ក្នុងបណ្តាពួកសក្តិភូមិ ដែលជាអ្នករស់នៅរដ្ឋធានី (ដែលនៅទីនេះ មានច្រើនតែពួកមន្ត្រីនាហ្មឺនធំៗរបស់រាជាណាចក្រ)។ ការពឹងផ្អែកទៅលើ “ មេកើយជាមេកម្លាំង ” របស់ខ្លួនបានធ្វើឱ្យកសិករទៅ

ជាបុគ្គលត្រឹមត្រូវតាមច្បាប់ បើកាលណាគេចង់បំពេញកិច្ចការណាមួយក្រៅពីស្រុករបស់ខ្លួន។ ដូច្នេះ កសិករត្រូវតែធ្វើវិភាគទានជាប្រាក់ ឬជាផលដំណាំដល់ " មេកើយ " របស់ខ្លួន ដោយការបំពេញពលកម្មសម្រាប់រដ្ឋ ក្រោមការដឹកនាំរបស់ " មេកើយ " បានសេចក្ដីថា គេធ្វើការសម្រាប់ " មេកើយ " ដែលជាជនសក្ដិភូមិ។ ក៏ប៉ុន្តែ ការបំពេញពលកម្មដោយបង្ខំបែបនេះនឹងប្រព្រឹត្តទៅបាន លុះត្រាណាកសិករត្រូវការពឹងពាក់អ្វីមួយពី " មេកើយ " ឬក៏គេបានទទួលការគាំទ្រពីមេកើយរួចមកហើយ ឬក៏គេបានមកបំពេញងារសម្រាប់រដ្ឋ។ របៀបកៀបសង្កត់មួយ ដែលមានសភាពជាទូទៅជាងគេ គឺការបង់ពន្ធដារដល់នាហ្មឺនសក្ដិភូមិទីអាយ ឬដល់សមាជិករាជវង្សានុវង្ស និងមន្ត្រីធំៗនៅរដ្ឋធានី។ សមាជិករាជវង្សានុវង្ស ដែលជាជនសក្ដិភូមិដ៏សំខាន់ជាងគេ មានសិទ្ធិទារយកពន្ធដារនៅក្នុងខេត្តទាំងមូល ពួកនាហ្មឺនជាជនសក្ដិភូមិមធ្យម និងតូច មានសិទ្ធិទារយកពន្ធដារនៅក្នុងដែនដីមានទំហំមធ្យម ហើយមានដីភូមិសម្រាប់ឱ្យប្រវាស់ដល់បណ្ដាកសិករ។ វត្តអារាមខាងពុទ្ធសាសនា មានដីភូមិសម្រាប់ប្រវាស់បែបនេះ។

នៅសតវត្សរ៍ទី១៧-ទី១៨ នៅក្នុងវិស័យវប្បធម៌ មានការផ្លាស់ប្ដូរជាច្រើន។ សិល្បៈថ្មីប្រកបដោយរចនាបទខ្មែរសុទ្ធសាធបានចូលមកផ្លាស់វេនសិល្បៈបូរាណ ប្រកបដោយរូបរាងធំសម្បើមនៅសម័យចក្រភព។ រូបចម្លាក់ទាំងឡាយបានកសាងឡើងអំពីឈើ ហើយមានរូបរាងសមស្របទៅតាមរាងរៅនៃជនជាតិខ្មែរ។

នៅសម័យដើមសតវត្សរ៍ទី១៨ ទំនាក់ទំនងខាងកម្លាំងទ័ពស្មើគ្នា នៅតាមព្រំប្រទល់ខាងលិចនៃប្រទេសកម្ពុជា បាននៅ

ស្ថិតស្ថេរអស់ពេលដ៏យូរ។ ពួកសៀម គ្មានទាំងលទ្ធភាពនឹងស្រូបយកដី ដែលខ្លួនដណ្តើមបានពីពេលមុននៅភាគខាងកើតនៃប្រទេសសៀម ទៀតផង។

នៅសម័យខាងដើម នៃការសោយរាជ្យលើកទីពីររបស់ព្រះបាទធម្មោរាជាទី២ (១៧០៦ - ១៧១០) ជាទូទៅ ប្រទេសបានសុខសាន្ត។ ក៏ប៉ុន្តែ នៅឆ្នាំ១៧០៨ មានកើតការបះបោររបស់ពួកឈ្លើយសង្គ្រាមឡាវ ដែលពីពេលមុនត្រូវបានជន្លៀសឱ្យទៅរស់នៅស្រុកបាទី។ មគ្គុទេសក៍ពួកអ្នកបះបោរទាំងនេះ គឺអតីតមហាក្សត្រអង្គ អេម ដែលត្រូវបានរំលំដោយព្រះបាទជ័យជេដ្ឋាទី៤ នាឆ្នាំ១៧០១។ កាលនោះ ជនជាតិសម្រែ និងកួយនៅតំបន់អង្គរ និងកំពង់ធំ ក៏ចូលជួយយកអាសារចលនាបះបោរនេះ។ មិនតែប៉ុណ្ណោះ ព្រះអង្គអេងបានទាំងទទួលការគាំទ្រពីសំណាក់វៀតណាម ថែមទៀត។ បន្ទាប់ពីការឡោមព័ទ្ធទីក្រុងឧត្តុង្គ អស់ពេលដ៏យូរ ព្រះបាទធម្មោរាជា ក៏បានដកខ្លួនថយពីរដ្ឋធានី ទៅទិសខាងលិច គឺប្រទេសសៀម។ ព្រះអង្គអេងក៏បានឡើងសោយរាជ្យជាថ្មី (គ.ស.១៧១០ - គ.ស.១៧២២) ក៏ប៉ុន្តែ ព្រះអង្គអេម ត្រូវបង្ខំចិត្តបន្តចម្បាំងប្រឆាំងព្រះបាទធម្មោរាជា ដែលបានទទួលការគាំទ្រពីប្រទេសសៀម។

ស្ថានភាពដ៏ស្មុគស្មាញ បានកើតមានឡើងមិនយូរនៅក្នុងទំនាក់ទំនង និងដែនដីសាមន្តរាជរបស់ជនជាតិចិន មួយរូបឈ្មោះ ម៉ាក់-គៀវ។ នៅសតវត្សរ៍ទី១៧ នៅពេលដែលមានពួកភៀសខ្លួនចិនគួន ឌុង ដែលជាបក្សពួករបស់រាជវង្សចិនខាងត្បូងបានរត់ចូលមកក្នុងប្រទេសនានានៅតាមសមុទ្រខាងត្បូង ពួកចិនភៀសខ្លួនទាំងនេះ មួយភាគបានចូលមករស់នៅក្នុងខេត្តខ្មែរមួយ

ឈ្មោះណាម ដោយមានសេចក្តីអនុញ្ញាតពីរដ្ឋអំណាចកម្ពុជា។ នាយករបស់ជនភៀសខ្លួនចិនទាំងនេះ មានឈ្មោះថា ម៉ាក់-គៀវ ដែលបានទទួលរ៉ាប់រងកម្ចាត់ពួកចោរប្លន់ ពីតំបន់តាមឆ្នេរសមុទ្រ ដែលពួកវាចូលចិត្តចូលមកជ្រកនៅ។ ល្គឹកណាមានជោគជ័យ ក្នុងការកម្ចាត់ចោរប្លន់សមុទ្រទាំងនេះ ដែនដីមួយកន្លែង (គឺបន្ទាយមាស) នឹងទៅជាទីស្នាក់អាស្រ័យរបស់ជនជាតិចិន ដែលរស់នៅដូចជាពលរដ្ឋ របស់មហាក្សត្រខ្មែរ។ នៅឆ្នាំ១៧៧០ ម៉ាក់-គៀវ បានកម្ចាត់ពួកចោរប្លន់ដោយជោគជ័យ ហើយបានទទួលគោរមងារជាចៅហ្វាយខេត្តពាម តមកបានទៅជាចៅហ្វាយខេត្តនៅខេត្តជិតខាង ដូចជា កំពត កំពង់សោម និងកោះ ដែលមានឈ្មោះថា កោះត្រល់។ ទីតាំងនៃទីរួមខេត្តពាម មានឈ្មោះថា ហាទៀន។ ពួកជនភៀសខ្លួនចិន មានទាំងជនជាតិវៀតណាម ក៏បានរត់ចូលយ៉ាងកុះករមកតាំងលំនៅ នៅលើទឹកដីទាំងនោះ ទោះបីនៅពេលនោះ ដែនដីទាំងនេះ នៃប្រទេសកម្ពុជា ពុំទាន់មានព្រំប្រទល់ជាមួយប្រទេសវៀតណាម នៅឡើយ ក៏ដោយ។ ទីក្រុងហាទៀន បានទៅជាទីប្រជុំជនកុះករប្រកបដោយការរីកចម្រើនខាងពាណិជ្ជកម្ម ដែលជាហេតុនាំឱ្យប្រទេសកម្ពុជា ទទួលបានប្រាក់ចំណូលជាច្រើន ហើយអាចធ្វើកំណែនទាហាន ដើម្បីបម្រើកងទ័ពជើងគោក និងជើងទឹក នៅសម័យមានសង្គ្រាមជាមួយប្រទេសសៀម។ បណ្តាជននៅភាគខាងលិច នៃទីក្រុងហាទៀនមានសុទ្ធតែជាជនជាតិខ្មែរនៅឡើយ ក៏ប៉ុន្តែ នៅភាគខាងកើតនៃទីក្រុង ជនជាតិចិន និងវៀតណាម ដែលទើបនឹងបានតាំងលំនៅមានចំនួនកាន់តែច្រើន។ នៅរវាងឆ្នាំ១៧០៨ និង១៧១៥ ម៉ាក់-គៀវ បានប្រែឥរិយាបថ ហើយបានទទួល

ស្គាល់នូវរបបគ្រប់គ្រងមហាក្សត្រវៀតណាម នៅលើដែនដីទាំងនេះ ដោយការដកខ្លួនពីការគ្រប់គ្រងផ្ទាល់របស់មហាក្សត្រខ្មែរ ទោះបីមហាក្សត្រខ្មែរ បានស្ថិតនៅជាមហាក្សត្រនៅលើដែនដីទាំងនេះនៅឡើយ។ នៅពេលនោះ ចំពោះស្ថានការបែបនេះ មហាក្សត្រខ្មែរ បានដកហូតដែនដីមួយចំនួនបានពីម៉ាក-គៀវ ប៉ុន្តែ នៅសល់ដែនដីពាម កោះត្រល់ រាជា និងកាមៅ។

សង្គ្រាមប្រឆាំងព្រះបាទធម្មោរាជា និងពួកសៀម ដែលជាសម្ពន្ធមិត្តរបស់ព្រះអង្គនៅឆ្នាំ១៧១១ ឥតបានផ្តល់ជោគជ័យអ្វីឡើយ។ នៅឆ្នាំ១៧១៧ ប្រទេសសៀម បានបញ្ជូនកងទ័ពរបស់ខ្លួនជាថ្មី ដើម្បីគាំទ្រព្រះបាទធម្មោរាជា ពេលនោះ ម៉ាក-គៀវ បានគាំទ្រព្រះបាទអង្គ-អែម ដោយយោងទៅតាមកាតព្វកិច្ចរបស់ខ្លួនជាស្តេចចំណុះប្រទេសកម្ពុជា ផង ប្រទេសវៀតណាមខាងត្បូងផង។ ហេតុនេះហើយ បានជាកងនាវាសៀម ដែលចូលមកដល់ក្រុងហាទៀន បានដុតបំផ្លាញទីក្រុងនេះ។ នៅពេលនោះ នៅសមរភូមិ កងនាវាចរណ៍របស់មហាក្សត្រវៀតណាមខាងត្បូងនាម តួក-គួ បានចូលរួមច្បាំង ហើយបានទទួលជោគជ័យខ្លះលើកងនាវាសៀម។ ការគំរាមកំហែងនៃគ្រោះទុរ្ភិក្ស បានបង្ខំឱ្យកងនាវាចរណ៍សៀម ដកខ្លួនចេញទៅវិញ។ កងកម្លាំងរបស់ព្រះបាទធម្មោរាជា និងកងកម្លាំង “ អ្នកស្រុកព្រៃ ” បានវាយដណ្តើមយកបានទីក្រុងបាត់ដំបង រួចទីក្រុងឧត្តុង្គ ហើយព្រះធម្មោរាជា ក៏បានឡើងគ្រងរាជ្យម្តងទៀត។ រីឯព្រះអង្គ-អែម ក៏បានចូលទៅពួនខ្លួនក្នុងព្រៃ ដោយនៅបន្តយុទ្ធនាការតទៅទៀត។ កងកម្លាំងព្រះអង្គ-អែម បានធ្វើការវាយចូលទីក្រុងឧត្តុង្គ ហើយព្រះបាទធម្មោ-រាជា ក៏បានចាកចេញពីការគ្រងរាជ្យនៅឆ្នាំ១៧១៧។

ការវាយលុកពីតំបន់ខាងលិចក៏ត្រូវបានបង្ក្រាប ក៏ប៉ុន្តែ ស្ថានភាពតានតឹងបែបនេះ បានសម្រួលឱ្យទីក្រុងហាទៀនប្រកាន់ឥរិយាបថខិតជិតនឹងប្រទេសដាយវៀត (វៀតណាម)។ នៅឆ្នាំ១៧១៥ ពូជពង្សរបស់ម៉ាក់-គៀវ បានទៅជាអ្នកចំណុះមហាក្សត្រវៀតណាម ដោយរក្សាទុកនូវថៅហ្វាយខេត្តខ្មែរ ដែលបាននៅគ្រប់គ្រងបន្តពូជពង្សតមក។

នៅឆ្នាំ១៧២២ ព្រះបាទអង្គអេងបានផ្ទេររាជ្យសម្បត្តិទៅឱ្យព្រះបាទសត្ថាទី២ (គ.ស.១៧២២-គ.ស១៧៣៨) ជារាជបុត្រព្រះអង្គ ដែលទើបមានជន្មាយុ ២០ឆ្នាំ។ រជ្ជកាលរបស់ព្រះអង្គមួយភាគធំបានប្រព្រឹត្តទៅក្នុងលក្ខខណ្ឌ នៃស្ថិរភាពក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ទោះបីពុំសូវមានស្ថិរភាពខាងនយោបាយក្តី ជាពិសេស នៅសម័យកាលក្នុងភាគទីមួយនៃសតវត្សរ៍ទី១៧។ ក៏ប៉ុន្តែ នៅឆ្នាំ១៧៣០ ទំនាស់ទាស់ទែងមួយដងមួយកាលរវាងជនជាតិខ្មែរ និងវៀតណាម នៅតាមតំបន់ទីវាលទំនាបនៃទន្លេមេកុង មានលក្ខណៈជាការទាស់ទែងខ្លាំងក្លាដ៏ចំហ។ បណ្តាជនខ្មែរមួយភាគធំនៅតាមដងទន្លេមេកុង បានរួបរួមគ្នាជុំវិញអ្នកដឹកនាំមួយរូប ដែលឱ្យឈ្មោះខ្លួនថាជា “ ក្សត្រឯក ” ហើយបានចាប់ផ្តើមធ្វើទុក្ខទោសដល់ជនជាតិវៀតណាម នៅស្រុកបាណាម។ រាជរដ្ឋាភិបាលចាត់វិធានការបង្ក្រាបចលនា ដោយបានធ្វើការស៊ើបអង្កេតតាមអ្នកផ្តើមគំនិតបង្កើតចលនា ក៏ប៉ុន្តែមហាក្សត្រវៀតណាម បានប្រើប្រាស់ការចែដន្យបែបនេះជាមធ្យោបាយ ដើម្បីចាប់ផ្តើមធ្វើសង្គ្រាមប្រឆាំងប្រទេសកម្ពុជាដែលនៅទីបំផុត នៅឆ្នាំ១៧៣១ ត្រូវបានបាត់បង់ខេត្តនានានៅ

តាមទន្លេមេគុង គឺខេត្តមេ.ស (ខេត្តមីថ សព្វថ្ងៃ) និងខេត្តលង់ហោរ (ខេត្តវិញឡុង សព្វថ្ងៃ)។

សង្គ្រាមនៅតំបន់ព្រំប្រទល់ បានធ្វើឱ្យព្រះបាទសត្ថាទី២ បាត់បង់ប្រជាប្រិយភាព ដោយហេតុថា កងទ័ពព្រះអង្គបានទទួលបរាជ័យនៅតំបន់នោះ ហើយនៅឆ្នាំ១៧៣៦ នៅបរមរាជវាំង មានកើតក្រុមអ្នកផ្តើមគំនិតឃុបឃិតសុំឱ្យព្រះធម្មោរាជា យាងមកគ្រប់គ្រងរាជ្យវិញ។ ការផ្តើមគំនិតបែបនេះ បានទទួលការគាំទ្រពីសំណាក់បណ្ដាជននៅទីក្រុង។ ព្រះបាទសត្ថាទី២ បានភៀសខ្លួនទៅប្រទេសដាងឈួង។ នៅឆ្នាំ១៧៣៨ ព្រះបាទធម្មោរាជា ត្រូវបានអភិសេកឱ្យឡើងគ្រងរាជ្យលើកទី៣ និងជាលើកក្រោយបំផុត (គ.ស.១៧៣៨ - គ.ស.១៧៤៧)។

ដោយហេតុថា គ្មានវិបត្តិទឹកដីរវាងប្រទេសកម្ពុជា និងប្រទេសសៀម ការគំរាមកំហែងនៅភូមិភាគខាងលិច ក៏ពុំអាចមានឡើងបាន។ ដូច្នេះ នៅពេលនោះ ការប្រុងប្រយ័ត្នបានសង្កត់ខ្លាំងនៅលើផែនដីអាគ្នេយ៍។

បន្ទាប់ពីបានចាត់វិធានការមួយចំនួន ដើម្បីពង្រឹងអង្គការរដ្ឋបាលមក ព្រះបាទធម្មោ-រាជា បានចាប់ផ្តើមធ្វើការវាយលុកចូលតាមខេត្តពាម ខេត្តហាទៀនហើយបានដកហូតសិទ្ធិគោរមងារជាចៅហ្វាយខេត្តតពូជពីម៉ាក់-ធៀនគី ជាកូនរបស់ ម៉ាក់-គៀវ។ ដោយពឹងផ្អែកលើជំនួយរបស់មហាក្សត្រវៀតណាម ម៉ាក់-ធៀន-គី បានប្រកាសផ្តាច់របបគ្រប់គ្រងលើខេត្តខ្មែរ ទាំងឡាយរបស់ខ្លួនពីរដ្ឋអំណាចនៃប្រទេសកម្ពុជា ដែលជាហេតុបណ្ដាលឱ្យចម្បាំងផ្ទុះឡើង។ នៅឆ្នាំ១៧៣៦ កងកម្លាំងរបស់ម៉ាក់-ធៀន-គី និងកងកម្លាំងមហាក្សត្រវៀតណាម បានរួមគ្នាវាយប្រឆាំងកង

ទ័ពព្រះបាទធម្មោ-រាជា ក៏ប៉ុន្តែ កងកម្លាំងសត្រូវមិនបានប្រថុយធ្វើការវាយលុកចូលមកក្នុងប្រទេស។ ព្រះបាទធម្មោ-រាជា បានរៀបចំរបបគ្រប់គ្រងលើខេត្តកំពត និងកំពង់ស្ពឺ ឡើងវិញ ហើយព្រមទាំងបានបញ្ឈប់សកម្មភាពយោធា ដោយហេតុថា នៅក្នុងប្រទេស ពេលនោះ មានកើតទុរ្ភិក្សដោយសារផលដំណាំអាក្រក់។

បន្ទាប់ពីការទាស់ទែងប្រយុទ្ធគ្នាពីឆ្នាំ១៧៤៧ដើម្បីដណ្តើមរាជសម្បត្តិ ព្រះបាទជ័យ-ជេដ្ឋាទី៥ (គ.ស.១៧៤៩-១៧៥៥) ដែលជាមហាក្សត្រប្រឆាំងនឹងវៀតណាមយ៉ាងសកម្ម បានឡើងគ្រងរាជ្យ។ ចម្បាំងរវាងប្រទេសទាំងពីរ បានប្រព្រឹត្តទៅយ៉ាងយូរហើយបានបណ្តាលឱ្យមានការសអន្តរាយជាច្រើន។ ប្រទេសវៀតណាម ក៏ដូចជាប្រទេសកម្ពុជា ពុំមានកម្លាំងគ្រប់គ្រាន់ដើម្បីយកជ័យជម្នះបាន។

នៅក្នុងការប្រយុទ្ធដ៏ស្វិតស្វាញ កងកម្លាំងរបស់ព្រះបាទជ័យ-ជេដ្ឋាទី៥ អាចការពារព្រំប្រទល់រាជាណាចក្រទាំងខាងលិចនិងខាងកើត។ ព្រះបាទជ័យ-ជេដ្ឋាទី៥ បានសាកល្បងពង្រឹងរដ្ឋអំណាចនៃរាជាណាចក្រ ក៏ប៉ុន្តែ នៅពេលក្រោយមក អង្គបានចូលទិវង្គត នៅក្នុងពេលដែលកើតមានអំពើឃុបឃិតគំនិតក្បត់នានានៅបរមរាជវាំង (មានអំពើក្បត់របស់មន្ត្រីអោក និងដទៃទៀត)។ វិបត្តិទាស់ទែងរបស់សង្គមសក្តិភូមិជាន់ខ្ពស់ បានទៅជាវិបត្តិដ៏ចំហ ហើយព្រះអង្គទង ក៏បានឡើងគ្រងរាជ្យពីឆ្នាំ១៧៥៥ - ដល់ឆ្នាំ១៧៥៧។ សម្រាប់សង្គមខ្មែរ ជម្លោះហែកហួរគ្នារបស់ពួកសក្តិភូមិជាន់ខ្ពស់ បានទៅជាដំបៅដ៏ធ្ងន់ធ្ងរនៅក្នុងជីវភាពរបស់សង្គមក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ហើយហេតុការណ៍ទាំងនេះ បានរំខានដល់ការលូតលាស់របស់សង្គម

ខ្មែរទៅអនាគត។ ប្រទេសជិតខាង ដូចជាប្រទេសសៀម និង ប្រទេសវៀតណាម បានលូតលាស់យ៉ាងឆាប់រហ័ស ហើយបាន ទៅមុខលឿនជាងប្រទេសកម្ពុជា នៅក្នុងវិស័យសេដ្ឋកិច្ច ហើយ ប្រទេសទាំងពីរ បានទៅជាគូប្រឆាំងកាន់តែគ្រោះថ្នាក់ សម្រាប់ ប្រទេសកម្ពុជា។ ទោះបីមជ្ឈដ្ឋានជាន់ខ្ពស់នៃសង្គមក៏កាន់តែ ប្រកាន់ជំហរប្រឆាំងនឹងជម្លោះហែកហួរគ្នា ក្នុងបរមរាជវាំង ហើយ ការប្រឆាំងនេះ ក៏កាន់តែមានកម្រិតខ្លាំងឡើង។

នៅក្នុងរជ្ជកាលព្រះបាទអង្គ-ទង មានការសាកល្បងពង្រឹង អំណាចមហាក្សត្រតាមមាគ៌ា នៃការអនុវត្តរាជអំណាច សម្រប ទៅតាមការរីកចម្រើនខាងសង្គម-សេដ្ឋកិច្ច របស់ប្រទេស ដោយ មានការបោះបង់ចោល នូវប្រពៃណីចាស់ហួសសម័យ នៃរាជ វង្សានុវង្ស និងជំនឿចាស់បូរាណខាងសាសនាចំពោះបុគ្គលភាព របស់មហាក្សត្រ។ ទស្សនៈថ្មីត្រឹមត្រូវតាមការពិតបានលេចជា រូបរាងឡើងនៅក្នុងនយោបាយរបស់ព្រះអង្គ-ទង និងរបស់ព្រះបាទ ឧទ័យទី២ (គ.ស.១៧៥៨ - គ.ស.១៧៧៥) ដែលជាចៅរបស់ ព្រះអង្គ។ វិធានការទីមួយ នៅក្នុងនយោបាយថ្មី គឺការផ្តល់ទម្ងន់ នៃអំណាចខាងនយោបាយដល់គោរមងារឧបរាជ ជាងការផ្តល់ អំណាចដល់ព្រះអង្គម្ចាស់។ ពីពេលនេះទៅ នៅក្រោមការ គ្រប់គ្រងនៃមហាក្សត្រ អំណាចដ៏ច្រើនមិនមែនមានដល់រាជបុត្រ ស្តេចទេ តែដល់បុគ្គលដែលស្មោះស្ម័គ្រដ៏ច្បាស់លាស់ដល់ភាព នឹងនរនៃអំណាចរបស់មហាក្សត្រសោយរាជ្យ។ នៅពេលជាមួយគ្នា ព្រះអង្គ បានបង្ក្រាបចលនាកុបកម្មបះបោរយ៉ាងសាហាវ។ ព្រះបាទ ឧទ័យទី២ បានអនុវត្តវិធានការបែបនេះកាន់តែវែងឆ្ងាយ ដោយ ហេតុថា នៅពេលនោះ គេមានជំនឿយល់ថា ការពង្រឹងស្ថាន

ភាពរបស់ប្រទេសជិតខាង បានតម្រូវឱ្យមានការអនុវត្តនូវវិធានការដ៏ច្បាស់លាស់ ដើម្បីពង្រឹងស្ថាប័នរដ្ឋ។ ការពិសោធដ៏ជូរចត់កើតមានមកពីជម្លោះទាស់ទែងគ្នាក្នុងរាជវាំង តែងបានបង្កើតផលវិបាកជាបរាជ័យជានិច្ចកាលសម្រាប់កងទ័ពខ្មែរ ដែលធ្វើចម្បាំង ហើយការណ៍នេះបានតម្រូវឱ្យមានការបដិសេធនូវបុព្វសិទ្ធិមួយចំនួនរបស់សមាជិកនៃរាជវង្សានុវង្ស ហើយបានបង្កើនកាន់តែខ្លាំងដល់បុព្វសិទ្ធិរបស់មហាក្សត្រ។ ការគោរពហួសហេតុដល់សមាជិកនៃរាជវង្សានុវង្ស ដែលបានធ្វើឱ្យពួកអភិជនទាំងនេះបានចៀសផុតពីទោសពៃរ៍ ទោះបីក្នុងលក្ខខណ្ឌនៃបរាជ័យក្នុងអំពើឃុបឃិតរបស់ខ្លួនក្ដី ត្រូវបានបញ្ឈប់នៅក្នុងច្បាប់សម្រាប់រដ្ឋខ្មែរ។

តាំងពីមុនពេលឡើងគ្រងរាជ្យ គឺនៅក្នុងរជ្ជកាលព្រះបាទអង្គ-ទង ក្នុងឋានៈជាឧបរាជ និងក្នុងពេលឡើងគ្រងរាជ្យព្រះបាទឧទ័យទី២ បានកាត់ទោសប្រហារជីវិតដល់សមាជិករាជវង្សានុវង្ស និងដល់បុគ្គលទាំងឡាយជាគ្រហស្ថ និងជាបុព្វជិតក្ដី ដែលបានសាកល្បងបង្កើតចលនាបះបោរ (ដូចមានចលនាបះបោររបស់អង្គ-ហេង និងរបស់មាតាមីងមហាក្សត្រ)។ វិធានការនេះ មិនមែនជាសភាពនៃអំពើកាចសាហាវរបស់បុគ្គលទេ (ព្រោះថា គ្មាននរណាចង់ការពារអ្នកបង្កបង្កើតអំពើក្បត់ ដែលមានគ្រោះថ្នាក់ដល់ប្រទេសទេ) ក៏ប៉ុន្តែ គឺជាការអនុវត្តនូវគោលការណ៍ថ្មីនៃអំណាចមហាក្សត្រ ក្នុងក្របខ័ណ្ឌជាអំណាចរបស់បុគ្គលជាគ្រហស្ថ ហើយមិនមែនជាអំណាចរបស់គ្រួសារ។ នៅពេលជាមួយគ្នា មានការដកសិទ្ធិស្ដេចក្នុង “ ការដកខ្លួនថយពីរាជសម្បត្តិ ” បណ្ដាមន្ត្រីទាំងអស់ត្រូវបានតែងតាំងដោយ

មហាក្សត្រផ្ទាល់។ ព្រះបាទឧទ័យទី២ បានបង្កើតមូលដ្ឋានថ្មី នៅក្នុងរបបគ្រប់គ្រងរបស់មហាក្សត្រសក្តិភូមិ ដែលកាន់តែមាន លក្ខណៈឆ្លើយតបទៅនឹងលក្ខខណ្ឌនានា នៃនយោបាយផ្ទៃក្នុង និងក្រៅប្រទេស គឺជាមូលដ្ឋានដែលមានសភាពប្រហាក់ប្រហែល គ្នានឹងច្បាប់ទម្លាប់ទាំងឡាយ ដែលត្រូវបានអនុវត្តនៅពេលនោះ នៅប្រទេសដទៃនៃអាស៊ីអាគ្នេយ៍ ហើយមិនមែនជាភាពចៃដន្យទេ ដែលអនាគតមហាក្សត្រអង្គ-ឌួង បានអនុវត្តនយោបាយដូចគ្នា នេះនៅសតវត្សរ៍ទី១៩។

ជម្លោះទាស់ទែងនៅបរមរាជវាំង ត្រូវបានស្ងប់ស្ងៀមអស់ ពេលយ៉ាងយូរ ក្បាលម៉ាស៊ីនរដ្ឋត្រូវបានសំអាតយ៉ាងតឹងរឹង។ ព្រះបាទឧទ័យទី២ បានព្រមទទួលស្គាល់សិទ្ធិរបស់វៀតណាម ក្នុងការគ្រប់គ្រងលើខេត្តពីរនៅក្នុងដែនដីខាងអាគ្នេយ៍ គឺខេត្ត ត្រាវិញ និងស្រុកទ្រាំង។ ស្ថានភាពនៅតាមព្រំប្រទល់ខាងកើត បាននឹងនរឡើងវិញ។

ប្រព័ន្ធនៃអាណាព្យាបាលទ្វេភាគីនៅប្រទេសកម្ពុជា ក្នុង ទំនាក់ទំនងជាមួយប្រទេសសៀម និងវៀតណាម ដែលបានកើត មានឡើងបន្តិចម្តងៗ បានបង្ហាញឱ្យឃើញនូវកត្តានៃសេចក្តី ប៉ុនប៉ងរបស់ប្រទេសទាំងពីរ ក្នុងការដណ្តើមប្រទេសកម្ពុជា។

យើងសូមរំលឹកថា ចំពោះសភាពការណ៍ទាំងនេះ បណ្តា អ្នកប្រវត្តិសាស្ត្របារាំង មានទស្សនៈយល់ថា ស្ថានភាពនៃការ បែងចែកទឹកដីដើម្បីត្រួតត្រាបែបនេះនៅប្រទេសកម្ពុជា មានសភាព ប្រហាក់ប្រហែលគ្នានឹងលក្ខណៈពិសេស សម្រាប់សម័យកាល នៃចក្រពត្តិនិយម។ តាមការពិត ស្ថានភាពនេះបានកើតមាន ឡើងពីទម្រង់នៃទំនាក់ទំនងរវាងរដ្ឋសក្តិភូមិ ដែលបានលេចជា

រួបរាងឡើង នៅក្នុងការខ្វះសមត្ថភាពចំពោះរបៀបគ្រប់គ្រងប្រទេសច្បាស់លាស់។

ជាផលវិបាកខាងនយោបាយ នៅពេលដែលព្រះបាទឧទ័យទី២ បានបញ្ឈប់ដាឯកតោភាគី នូវរបបអាណាព្យាបាលនៃប្រទេសសៀម ស្តេចសៀម នាមប្រយា-តក្កសីន (ព្រះតក្កសីលា) បានសងសឹកវិញ ដោយបានផ្តល់សេចក្តីគាំទ្រដល់ព្រះអង្គម្ចាស់អង្គ-នន់ ដែលបានភៀសខ្លួនទៅប្រទេសសៀម។ នៅពេលក្រោយមក ស្តេចប្រយា-តក្កសីន បានសាកល្បងបញ្ជូនទ័ពសៀម មកច្បាំងនឹងកងទ័ពខ្មែរ នៅឆ្នាំ១៧៦៩ ក៏ប៉ុន្តែ ពួកសៀម បានទទួលបរាជ័យ។ នៅឆ្នាំ១៧៧០ កងទ័ពសៀម បានវាយលុកចូលជាថ្មី។ នៅក្នុងចម្បាំងនេះ ដែនដីក្រោមការត្រួតត្រារបស់ពូជពង្សម៉ាក់ បានគាំទ្រព្រះឧទ័យទី២។ សកម្មភាពចម្បាំងបានប្រព្រឹត្តទៅដោយមានឈ្នះ និងចាញ់។

កងទ័ពខ្មែរបានច្បាំងកម្ចាត់ទ័ពសៀម ចេញពីស្រុកទេស ក៏ប៉ុន្តែ នៅពេលនោះ នៅបរមរាជវាំងមានកើតវិបត្តិផ្ទៃក្នុងបណ្តាលមកពីការបង្កើនឥទ្ធិពលពីសំណាក់មហាក្សត្រវៀតណាម ដែលបានបញ្ជូនកងកម្លាំងមកជួយព្រះបាទឧទ័យទី២។ ព្រះអង្គ-នន់ និងបក្សពួកមួយក្រុមតូច បានមកតាំងទីនៅខេត្តកំពត ហើយនៅទីនេះ ស្ថានភាពព្រះអង្គ-នន់ បានទៅជាប្រសើរ ដោយហេតុថា បណ្តាអ្នកប្រឆាំងនឹងឥទ្ធិពលមហាក្សត្រវៀតណាម បានរត់មករួបរួមកម្លាំងនឹងព្រះអង្គ។ ព្រះបាទឧទ័យទី២ផ្ទាល់ក៏មានការទាក់ទងដ៏តឹងតែងនឹងមហាក្សត្រវៀតណាម ព្រោះថា នៅពេលនោះ មានកើតការបះបោរកុបកម្មនៅតំបន់តាមដងទន្លេមេកុង។ មិនតែប៉ុណ្ណោះ ពួកនាហ្មឺនមន្ត្រីសក្តិភូមិស្នេហា

ជាតិមួយភាគ (ជាពិសេសនៅតាមខេត្តនានា) និងព្រះសង្ឃបានបង្កបង្កើតចលនាប្រឆាំងនឹងក្សត្រទាំងពីរ (គឺព្រះអង្គនន់ និងព្រះបាទឧទ័យទី២)។ ចម្បាំងបង្ហូរឈាមឥតន័យរវាងពួកអ្នកដណ្ដើមរជ្ជអំណាច ក៏បានឆេះឆួលឡើងបន្ទាប់ពីសម័យកាលនៃទសវត្សរ៍ទី៥ ហើយស្ថានភាពច្របូកច្របល់ទាំងនេះបានប៉ះទង្គិចទៅនឹងសកម្មភាពបដិកម្ម ក្នុងនយោបាយផ្ទៃក្នុងដែលមានកម្រិតកាន់តែខ្លាំង។ ភាពច្របូកច្របល់ដូចគ្នា បានកើតមានមកដោយសេចក្ដីអន្តរាយនៅខេត្តបាត់ដំបង និងខេត្តពោធិ៍សាត់ នៅពេលសង្គ្រាមជាមួយពួកសៀម នៅពេលដកខ្លួនថយពីទឹកដីខ្មែរ ពួកវាបានខិតខំកៀរអ្នកស្រុក ដែលជាប្រជាពលករមួយចំនួនធំទៅស្រុកសៀម។ ភាពលំបាកលំបិនដ៏ធ្ងន់ធ្ងរម៉្យាងទៀត បានកើតមក ដោយកាលនោះមានកើតជំងឺអាសន្នរោគ និងជំងឺអុត ដែលបានរាតត្បាតយ៉ាងខ្លាំង។

នៅឆ្នាំ១៧៧៥ ព្រះបាទឧទ័យទី២ បានផ្ទេររាជសម្បត្តិឱ្យដល់គូសត្រូវរបស់ព្រះអង្គ គឺព្រះបាទអង្គ-នន់ទី២ (គ.ស. ១៧៧៥ - គ.ស.១៧៧៩)។ នៅក្នុងរជ្ជកាលរបស់ព្រះអង្គ-នន់ទី២ មានការចាត់វិធានការមួយចំនួន ដើម្បីបន្ថយឥទ្ធិពលរបស់មហាក្សត្រវៀតណាម។ ការនេះអាចប្រព្រឹត្តទៅបាន ដោយហេតុថា នៅវៀតណាមខាងត្បូង ពេលនោះមានកើតចម្បាំងក្នុងស្រុកជាមួយបណ្ដាកសិករជនជាតិតៃ សឺន ដែលបានធ្វើឱ្យរាជវង្ស ង្វូន សឹងវិនាសអន្តរាយ។ នៅតាមដងទន្លេមេកុង កងទ័ពព្រះបាទអង្គ-នន់ បានវាយកម្ទាត់កងកម្លាំងអ្នកគាំទ្ររាជវង្សង្វូន ដែលបានមកប្រមូលផ្ដុំគ្នានៅជាយទីក្រុងព្រៃនគរ។

នៅប្រទេសកម្ពុជា ការកាត់ទោសប្រហារជីវិតដល់ព្រះឧទ័យទី២ និងរាជបុត្ររបស់ព្រះអង្គ ព្រមទាំងរដ្ឋមន្ត្រីក្រសួងសាធារណការ បានបណ្ដាលឱ្យមានសេចក្ដីខឹងសម្បាពីសំណាក់បរមរាជវាំង។ កូនប្រុសប្អូនរូបរបស់រដ្ឋមន្ត្រី ដែលត្រូវបានប្រហារជីវិត ដែលមានមុខងារជាចៅហ្វាយខេត្តបានបង្កើតចលនាបះបោរ បានរំលំ ហើយកាត់ទោសប្រហារជីវិតដល់ព្រះអង្គ-នន់ទី២។ ចៅហ្វាយខេត្តមួយរូបឈ្មោះ មូ បានឡើងជានាយករដ្ឋាភិបាល។ព្រះអង្គ អេង (១៧៧៩ - ១៧៩៦) ជារាជបុត្រដ៏ក្មេងរបស់ព្រះបាទឧទ័យទី២ ដែលត្រូវបានគេប្រហារជីវិតត្រូវបានអភិសេកឱ្យឡើងគ្រងរាជ្យ។ ប៉ុន្តែ តាមពិត រដ្ឋអំណាចទាំងអស់បានស្ថិតក្នុងការគ្រប់គ្រងរបស់មន្ត្រីជាន់ខ្ពស់ទាំងបីរូប គឺមន្ត្រី មូ, បែននិងសួរ។

នៅសម័យពាក់កណ្ដាលសតវត្សរ៍ទី១៨ ទឹកជំនន់ធំបានធ្វើឱ្យខូចខាតដល់សេដ្ឋកិច្ចប្រទេស ដោយផលដំណាំស្រូវមិនបានល្អ។ នៅសម័យខាងចុងនៃទសវត្សរ៍ទី៥ មានការបះបោររបស់ “ អ្នកស្រុកព្រៃ ” ហើយតមក “ អ្នកស្រុកស្រែ ” ក៏បានចូលរួមបះបោរជាមួយ។ មេដឹកនាំការបះបោរនេះ ពីឆ្នាំ១៧០០ ដល់ឆ្នាំ១៧១០ គឺមេកន្ទ្រាញមួយរូប ដែលបានប្រកាសនូវមនោគមវិជ្ជារបស់ខ្លួន ខុសពីមនោគមវិជ្ជាជាផ្លូវការដល់អ្នកស្រុកស្រែចម្ការ។ ហេតុភេទបែបនេះ មិនមែនកើតមានតែម្ដងនៅក្នុងប្រទេសកម្ពុជាសក្តិភូមិទេ គឺហេតុភេទ ដែលត្រូវបានផ្សព្វផ្សាយអំពីបុគ្គលអស្ចារ្យណាមួយដែលមាន “ មន្តអាគមគាថា ”។ តាមឯកសារអ្នកប្រវត្តិសាស្ត្រមានការឱ្យការណ៍ថា នៅក្នុងតំបន់ទាំងឡាយកាន់កាប់ដោយបក្ខពួកមេកន្ទ្រាញនេះ មានការអនុវត្ត

ច្បាប់ទម្លាប់ " ដ៏តឹងរឹងបំផុត "។ បន្ទាប់ពីប្រមែប្រមូលបានកងកម្លាំងប្រហែលបីពាន់នាក់ មេកន្ទ្រាញបានធ្វើចលនាតម្រង់ទៅកាន់រដ្ឋធានី។ បន្ទាប់ពីបានទទួលបរាជ័យក្នុងការបះបោរនេះ មេកន្ទ្រាញត្រូវបានចាប់ឃុំឃាំងក្នុងទ្រុង ហើយត្រូវបានកាត់ទោសប្រហារជីវិត។

សូមកត់សម្គាល់ថា នាសតវត្សរ៍ទី១៨ នៅប្រទេសកម្ពុជា រមែងមានការចូលរួមក្នុងការប្រយុទ្ធពីសំណាក់នៃ "អ្នកស្រុកព្រៃ" ដែលបានបង្កបង្កើតជាកងកម្លាំង ហើយបានប្រយុទ្ធប្រឆាំងនឹងរដ្ឋអំណាចមជ្ឈិម ដោយការវាយលុកចូលរដ្ឋធានី។ បើវិនិច្ឆ័យតាមឯកសារនៃ " រាជពង្សាវតារ " អ្នកទាំងនេះ មិនមែនជាតំណាងកុលសម្ពន្ធនានាទេ ហើយមិនមែនជាកសិករនៅតំបន់ស្រែចម្ការដ៏សំខាន់ៗទេ ដោយហេតុថា ការចូលរួមក្នុងចលនាតស៊ូរបស់គេ ត្រូវបានបញ្ជាក់ច្បាស់លាស់នៅក្នុងឯកសារ ក៏ប៉ុន្តែគឺជាបណ្តាកសិករ ដែលរស់នៅតំបន់ព្រៃ មិនសូមមានមនុស្សច្រើន ហើយនៅទីទាំងនេះ ការត្រួតត្រារបស់រដ្ឋអំណាច ក៏មិនសូវជាខ្លាំងក្លាដែរ។

នៅសម័យខាងចុងទសវត្សរ៍ទី៧ មានកើតការបះបោរកុបកម្មដ៏ខ្លាំងក្លាជាងមុន ពីសំណាក់បណ្តាកសិករ នៅតំបន់កណ្តាលនៃខេត្តកំពង់ស្វាយ ហើយម្តងនេះ គ្មានការចូលរួមនៃ " អ្នកស្រុកព្រៃ " ទេ។ មនុស្សប្រុសៗ ត្រូវបានគេធ្វើកំណែនឱ្យចូលកងទ័ព ហើយមនុស្សស្រីៗ និងកុមារ ត្រូវបានគេបង្ខំឱ្យរៀបចំស្រូវអង្ករសម្រាប់សេចក្តីត្រូវការ របស់កងកម្លាំងយោធាដែលត្រូវបញ្ជូនទៅទីនោះជាមួយនឹងកងទ័ពសៀម។ តាមឯកសារនៃរាជពង្សាវតារ ពួកទាហាននៃកងទ័ពទាំងនេះ បានធ្វើទុក្ខបុក

ម្នេញអ្នកស្រុកឱ្យវិនាសអន្តរាយដ៏សែនទារុណ។ អ្នកស្រុកដែលត្រូវគេកែនជាច្រើននាក់ បានចាប់ផ្ដើមចាកចោលកងទ័ព ហើយរត់ទៅពួនក្នុងព្រៃជាមួយគ្រួសារ។ ក្នុងការសាកល្បងបញ្ឈប់ការរត់ពួនលាក់ខ្លួនបែបនេះ អាជ្ញាធរបានប្រើមធ្យោបាយដ៏ឃោរឃៅហួតដល់ការកាត់ទោសសម្លាប់។ គឺអំពើឃោរឃៅទាំងនេះ ដែលបានបណ្ដាលឱ្យមានការបះបោរកុបកម្ម។ ចៅហ្វាយខេត្តកំពង់ស្វាយ និងរាជតំណាងរបស់មហាក្សត្រ ត្រូវបានគេសម្លាប់ ហើយយកក្បាលព្យួរនៅតាមផ្លូវធំ។ ព្រះបាទអង្គ-នន់ បានបញ្ជាឱ្យធ្វើការស៊ើបអង្កេត ហើយផ្ដន្ទាទោសដល់ពួកមនុស្សប្រព្រឹត្តអំពើឃោរឃៅនោះ។ នៅឆ្នាំ១៧៧៩ ចលនាបះបោរកុបកម្មបានស្ងប់ស្ងាត់បន្តិចម្ដងៗ ក៏ប៉ុន្តែ នៅវង្វង់ឆ្នាំទី៨០ បណ្ដាកសិករគ្មានបានទទួលការបន្ធូរបន្ថយអ្វីឡើយ។ របបគ្រប់គ្រងបណ្ដោះអាសន្នរបស់បក្ខពួកមន្ត្រី បែននិងអ្នកដទៃទៀត បានប្រព្រឹត្តទៅដោយមានអំពើរំលោភគ្រប់បែបយ៉ាង ដោយមានភាពគ្មានសណ្ដាប់ធ្នាប់ពីពួកនាហ្មឺនមន្ត្រី ដោយមានការធ្វើកំណែនមនុស្សឱ្យចូលកងទ័ព និងឱ្យធ្វើការនៅការដ្ឋានសំណង់នៅប្រទេសសៀមក៏ដូចជានៅប្រទេសកម្ពុជា (ដូចជា សំណង់កំពែងការពារទីក្រុងឧត្តុង្គ និងដទៃទៀត)។ នៅតាមភូមិនៅស្រុកស្រែជាច្រើន នៅសល់តែមនុស្សស្រី មនុស្សប្រុសៗមួយភាគធំបានរត់ទៅពួនលាក់ខ្លួននៅក្នុងព្រៃ ហើយនៅសម័យនោះ ដូចការពណ៌នាតាមឯកសារនៃរាជពង្សាវតារ បនចោរប្លន់បានដើរលួចប្លន់ “ ពេញទាំងរាជាណាចក្រ ”។

នៅភាគខាងចុងនៃសតវត្សរ៍ទី១៨ ប្រទេសដាយវៀត (វៀតណាម) ដែលកំពុងតែជាប់ដៃនឹងចម្បាំងរវាងពួកសក្តិភូមិ

និងប្រជាកសិករ ពុំមានលទ្ធភាពនឹងចូលជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងប្រទេសកម្ពុជា បាន ក៏ប៉ុន្តែ ប្រទេសសៀម នៅពេលនោះ បានធ្វើការសាកល្បងគ្រប់យ៉ាង ដើម្បីដាក់ប្រទេសកម្ពុជា ឱ្យនៅក្នុងអាណាព្យាបាលរបស់ខ្លួន។ ការសាកល្បងទាំងនេះ មិនបានសម្រេចផល ទោះបីប្រទេសត្រូវទទួលការខូចខាតជាច្រើនក៏ដោយ។ ការបញ្ជូនកងទ័ពសៀម ដោយមហាក្សត្រ ប្រយា-តក្កសីន មកវាយលុកប្រទេសកម្ពុជា បានទទួលបរាជ័យ ហើយមហាក្សត្រ ប្រយា-តក្កសីន ខ្លួនឯង ក៏ត្រូវទទួលការកាត់ទោសប្រហារជីវិត នៅប្រទេសសៀម (នៅឆ្នាំ១៧៨២)។ តមកសកម្មភាពរបស់ប្រទេសសៀម បានស្ងប់ស្ងៀមបន្តិចជាបណ្ដោះអាសន្ន។ ក៏ប៉ុន្តែ នៅក្នុងប្រទេសកម្ពុជា ក្នុងមជ្ឈដ្ឋានគ្រប់គ្រងរដ្ឋនៃមន្ត្រីទាំងបីរូប មានកើតវិបត្តិទាស់ទែងគ្នារវាងមន្ត្រី មូ និង មន្ត្រី សូរ។ មន្ត្រី បែនបានគាំទ្រមន្ត្រី សូរ ហើយបានរេហ៍ពល វាយលុកចូលទីក្រុងឧត្តុង្គ។ មន្ត្រី មូ ត្រូវបានកាត់ទោសប្រហារជីវិត។ អំពើឃុបឃិតមួយប្រកបដោយជោគជ័យ បណ្ដាលឱ្យមានការធ្វើឃាតកម្មលើមន្ត្រី សូរ ហើយបានផ្ដល់លទ្ធភាពដល់មន្ត្រី បែន ក្នុងការកាន់កាប់រដ្ឋអំណាច ក៏ប៉ុន្តែ កងទ័ពរបស់មន្ត្រីដែលបានបាត់បង់ជីវិត មិនបានអនុញ្ញាតឱ្យមន្ត្រី បែនសម្រេចបំណងខ្លួនបានឡើយ។ នៅក្នុងស្ថានភាពបែបនេះ មន្ត្រី បែនបានរត់គៀសខ្លួនទៅប្រទេសសៀម ដោយបាននាំទាំងយុវមហាក្សត្រ ទៅជាមួយផង។ ពួកសៀម បានបង្ខំឱ្យយុវមហាក្សត្រទទួលស្គាល់ជាថ្មីនូវអាណាព្យាបាលរបស់ខ្លួន នៅឆ្នាំ១៧៨៤។ បន្ទាប់ពីពេលនោះមក មន្ត្រី បែនព្រមទាំងកងទ័ពសៀម បានហែហមយុវមហាក្សត្រ មកកាន់ទីក្រុងឧត្តុង្គ វិញ។

នៅឆ្នាំ១៧៩៥ មានអនុវត្តការកែប្រែដ៏សំខាន់នៅក្នុងវិស័យរដ្ឋបាល ដោយតម្រូវឱ្យមានការបង្កើតរបៀបគ្រប់គ្រងប្រមូលផ្ដុំ ក៏ប៉ុន្តែស្ថានភាពខាងនយោបាយ មិនបានបង្កលក្ខណៈឱ្យប្រទេសកម្ពុជា ទទួលជោគជ័យ។ ដោយយល់ច្បាស់ថា នៅប្រទេសកម្ពុជា គ្មានរដ្ឋអំណាចដ៏រឹងមាំទេ ប្រទេសសៀម បានផ្តល់ការកាន់កាប់ និងគ្រប់គ្រងលើដែនដីកូរ៉ាត់ ស៊ីសូផុន បាត់ដំបង អង្គរ និងមង្គលបូរីដល់សម្តេចចៅហ្វា បែន ។ សម្តេចចៅហ្វា បែន មានទីស្នាក់ការរបស់ខ្លួននៅខេត្តបាត់ដំបង ហើយបានគ្រប់គ្រងដែនដី ដូចបានរៀបរាប់ខាងលើ តាងនាមព្រះអង្គ- អេង ប៉ុន្តែពន្ធដារទារបានមកត្រូវបញ្ជូនទៅឱ្យទីក្រុងបាងកក។ នៅពេលនោះ ខ្មែរចំនួន ១០០០០នាក់ ត្រូវបានកេណ្ឌបញ្ជូនទៅប្រទេសសៀម ដើម្បីបំពេញការងារសំណង់ព្រែកជីក និងការងារដទៃទៀត។

នៅពេលដែលព្រះបាទអង្គ-អេង បានចូលទិវង្គតនៅឆ្នាំ ១៧៩៦ សម្តេចចៅហ្វា បែន មិនបានទទួលស្គាល់អំណាចរបស់យុវរាជបុត្រ នៃព្រះបាទអង្គ-អេង ឡើយ។ ដោយមានសេចក្តីព្រួយបារម្ភដល់ភ័ព្វវាសនា នៃខេត្តខាងលិចទាំងឡាយ មជ្ឈដ្ឋានដឹកនាំនៅបរមរាជវាំង បានគិតដល់មហាក្សត្រសៀម ហើយមិនបានប្រញាប់ប្រញាល់ជ្រើសរើសមហាក្សត្រថ្មី។ តាមការពិតរដ្ឋអំណាចប្រទេសបានស្ថិតទៅក្នុងកណ្តាប់ដៃ នៃរាជានុសិទ្ធិ ដែលជាមហាមន្ត្រីចាស់ទុំមួយរូប គឺសម្តេចចៅហ្វា ប៉ុក ដែលត្រូវបានតែងតាំងក្នុងតំណែង ក្រោមការបង្ខិតបង្ខំរបស់រាជការសៀម។ នៅឆ្នាំ១៧៩៦ - ដល់១៨០៦ មហាមន្ត្រី ប៉ុក ដែលជាអ្នកនយោបាយចេះប្រុងប្រយ័ត្ន បានគ្រប់គ្រងប្រទេស ដោយខិតខំធ្វើយ៉ាងណា ដើម្បីកុំឱ្យប្រទេសសៀម ឆ្លៀតឱកាសចូលជ្រៀត

ជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសកម្ពុជា។ ហេតុនេះហើយ បានជាកងទ័ពខ្មែរ បានចូលរួមធ្វើចម្បាំងជាមួយពួកសៀម ប្រឆាំងប្រទេសភូមា។ ឈ្លើយសង្គ្រាមភូមា មួយភាគចាប់បានក្នុងពេលធ្វើចម្បាំង ត្រូវបានបញ្ជូនមកប្រទេសកម្ពុជា ហើយបានឱ្យទៅរស់នៅភ្នំបប៉ៃលិន ដែលនៅទីនេះ ពួកនេះ បានធ្វើការជីករកត្បូងពេជ្រដ៏មានតម្លៃ។

នៅឆ្នាំ១៨០០ កងទ័ពខ្មែរបានទៅជួយកងទ័ពមហាក្សត្រវៀតណាម នៅក្នុងចម្បាំងប្រឆាំងបណ្តាកសិករបះបោរតៃ-សឺន។ ក៏ប៉ុន្តែ ទាហានខ្មែរ មិនបានពេញចិត្តនឹងចូលច្បាំង ម្ល៉ោះហើយមានចៃដន្យ ដែលពួកទាហានបានរត់ចេញពីកងទ័ពជាច្រើន។ មិនតែប៉ុណ្ណោះ ទាហានខ្មែរ មិនបានយល់ច្បាស់អំពីសភាពការណ៍ទូទៅ ហើយរមែងយល់ថា ពួកមខាងមហាក្សត្រវៀតណាម គឺជាសត្រូវនឹងខ្លួន ហើយក៏បានទាំងគំរាមកំហែងដល់ទាហានមហាក្សត្រវៀតណាម។ ទោះបីដូចម្តេចក្តី ង្វួន ហ្វុក-អាញ់ (អនាគតមហារាជវៀតណាម នាមយ៉ា-ឡុង) បានថ្លែងអំណរគុណ និងបានប្រគល់ជ័យភណ្ឌនានាដល់កងទ័ពខ្មែរ។

នៅឆ្នាំ១៨០៦ ព្រះបាទអង្គ-ចន្ទទី២ (គ.ស.១៨០៦ - គ.ស.១៨៣៤) ដែលជារាជបុត្រព្រះបាទអង្គ-អេង បានឡើងគ្រងរាជ្យបន្ត។ ទោះបីបរមោរាជវាំងសៀម មិនបានសម្រេចជោគជ័យនៅក្នុងការរៀបចំពិធីអភិសេកព្រះអង្គនៅទីក្រុងបាងកកក្តី តាំងពីសម័យខាងដើម នៃរជ្ជកាលរបស់យុវមហាក្សត្រ និងបណ្តាមន្ត្រីទាំងឡាយ បានចាប់ផ្តើមតស៊ូប្រឆាំងនឹងនយោបាយបង្ខិតបង្ខំរបស់ពួកសៀម ដោយជោគជ័យ។

នៅក្នុងវិស័យសង្គម-សេដ្ឋកិច្ច តើប្រទេសកម្ពុជា នាសម័យសតវត្សរ៍ទី១៨ មានសភាពការណ៍ដូចម្ដេច? នៅពេលនោះ នៅក្នុងប្រទេសមានការកកើតទម្រង់មួយបែប នៃរបបសក្តិភូមិ។ ការចុះអន់ថយនូវសហគមន៍ស្រុកស្រែ ដែលបានលេចឡើងជាលក្ខណៈពិសេសនៃសង្គមខ្មែរ ស្ថិតនៅលើហេតុថា នៅក្នុងប្រទេសមានដីទំនេរមួយចំនួនធំ ដែលគេអាចត្រួសត្រាយធ្វើស្រែចម្ការ។ ទោះបីតាមផ្លូវការ ដែនដីទាំងអស់ជាកម្មសិទ្ធិផ្ទាល់របស់មហាក្សត្រក៏ដោយ ក៏មូលនិធិដីមួយចំនួនធំ ស្ថិតនៅជាកម្មសិទ្ធិឯកជនរបស់កសិករសេរីទាំងឡាយ និងរបស់ពួកសក្តិភូមិតូចតាច ហើយដែលនៅក្នុងរឿងនេះ កសិករមានគ្រួសារច្រើនបានបំពេញតួនាទីដ៏សំខាន់។ ក្រៅអំពីដីទាំងនេះ នៅមានដីភូមិជាកម្មសិទ្ធិបន្តពូជពង្សរបស់រាជវង្សានុវង្ស មានដីភូមិជាកម្មសិទ្ធិរបស់ពួកអ្នកបម្រើរាជការ ដែលជាមន្ត្រីសក្តិភូមិធំៗ និងមធ្យម មានដីជា “ កម្មសិទ្ធិអចិន្ត្រៃយ៍ ” របស់វត្តអារាម។

ដីប្រកបដោយរបរដាំដំណាំ បានទៅជាមូលហេតុដ៏សំខាន់ក្នុងការទទួលកម្មសិទ្ធិលើដី ដែលស្ថិតនៅក្នុងមូលនិធីដីទូទៅ ព្រោះថា ដីគ្មានរបរដាំដំណាំ បន្ទាប់ពីការទុកចោលរវាងបី-បួនឆ្នាំ មានស្មៅដុះទ្រុប ហើយមានលក្ខណៈមិនខុសគ្នាពីដីគ្មានរបរដាំដំណាំ។ មូលនិធីដីទាំងនេះ គេអាចបែងចែកជាឡូត៍ដី ដើម្បីចែកដល់កសិករសេរី នៅក្នុងលក្ខខណ្ឌ នៃការទទួលព្រមបង់ពន្ធដារ ឬ ការបំពេញការងារណាមួយ។

កម្មសិទ្ធិលើដី បានមកដោយការដាំដំណាំលើដីនោះ ហើយបើមានការឈប់ដាំដំណាំលើដីនោះ បុគ្គលដទៃទៀត អាចទទួលសិទ្ធិលើដីទំនេរនោះ ក៏ប៉ុន្តែ បុគ្គលថ្មីដែលធ្វើរបរលើដីនោះ មាន

ភារៈបង់ពន្ធដារដល់រដ្ឋ។ មន្ត្រីទទួលបន្ទុកក្រសួងភូមិបាលជាអ្នកបញ្ជាក់កម្មសិទ្ធិលើដី។

ល្គឹកណា កសិករបានទទួលកម្មសិទ្ធិត្រឹមត្រូវតាមច្បាប់លើឡូត៍ដី ដែលខ្លួនប្រកបរបរដាំដំណាំនោះ កសិករមានសិទ្ធិយកដីនោះ ទៅប្រើប្រាស់ក្នុងការចែកមរតក ធ្វើអំណោយ លក់-ទិញ ឬបញ្ចាំបាន។ នៅគ្រប់កាលៈទេសៈ ដីប្រកបដោយរបរដាំដំណាំ និងការងារគ្រប់យ៉ាងលើដី ដើម្បីផលដំណាំទាំងអស់នេះអាចទៅជាប្រភពនៃកិច្ចការ នៅក្នុងរបៀបលក់-ទិញគ្រប់បែបយ៉ាង។ ក៏ប៉ុន្តែ ការទទួលកម្មសិទ្ធិលើដី ទាក់ទងជាប់ទៅនឹងការធ្វើរបរដំណាំលើដី និងការបំពេញកាតព្វកិច្ចគ្រប់យ៉ាងដល់រដ្ឋ និងដល់ពួកមន្ត្រីបម្រើរាជការ។ នៅក្នុងលក្ខខណ្ឌបែបនេះជួនកាលគ្មានការចូលរួមក្នុងការធ្វើដំណាំលើដី ពីសំណាក់នៃម្ចាស់ដី ដូចជា ដីរបស់ពួកក្តុម្ពីសក្តិភូមិ។ នៅលើដីរបស់ពួកនេះគឺ “ ពួកខ្ញុំ ” ដែលជាប្រជាពលករអ្នកងារ។ ពួកខ្ញុំមួយភាគ បានបាត់បង់សេរីភាពរបស់ខ្លួន ដោយគ្មានប្រាក់បង់បំណុល ហើយបានទៅជាខ្ញុំបម្រើ នៅតាមគេហដ្ឋាន របស់អ្នកម្ចាស់បំណុល។ ពួកខ្ញុំមួយភាគទៀត ហៅថា “ ខ្ញុំក្រៅ ” បានធ្វើរបរដាំដំណាំឱ្យម្ចាស់បំណុល។ កសិករអ្នកជាទាំងឡាយ ដែលគ្មានមធ្យោបាយនឹងកាប់គាស់ដីថ្មី អាចធ្វើស្រែចម្ការលើដីរបស់ពួកក្តុម្ពីសក្តិភូមិ ក៏ប៉ុន្តែកសិករទាំងនេះត្រូវបង់ឈ្នួលដីដល់អ្នកម្ចាស់ដី ប្រហាក់ប្រហែលគ្នានឹងពួកខ្ញុំ ដែលត្រូវបង់ផលដំណាំរបស់ខ្លួនដល់អ្នកម្ចាស់ដីដែរ។ នៅប្រទេសកម្ពុជា គ្មានការកំណែនកសិករឱ្យបំពេញរបរកសិកម្មទេ។ អ្នកម្ចាស់ដីមធ្យម ហើយជួនកាលអ្នក

ម្ចាស់ដីធំៗមានដីនៅទីកន្លែងផ្សេង គឺពួកខ្ញុំក្រៅជាអ្នកធ្វើស្រែចម្ការនៅលើដីទាំងនោះ។

តាមផ្លូវច្បាប់ អ្នកម្ចាស់ដីទាំងអស់ ដូចជាបណ្ដាកសិកជាអ្នកជា ពួកអភិជនដែលជាមន្ត្រីក្ដីត្រូវតែបំពេញការងារជូនរាជការ គឺការងារដោយបង្ខំ ហើយបង់ពន្ធដារជូនរដ្ឋ។ ក៏ប៉ុន្តែ ពួកជនប្រភេទទីពីរ គឺពួកអភិជន និងពួកខ្ញុំរបស់ខ្លួន ត្រូវបានរំដោះខ្លួនផុត។ ដូច្នេះ ពន្ធអាករទាំងអស់បានចូលទៅក្នុងហោប៉ៅរបស់ពួកសក្ដិភូមិ។ បើកសិករអ្នកជា ដែលជាអ្នកជួលដីរបស់ពួកសក្ដិភូមិបង់ពន្ធដារ ក៏ពន្ធដារទាំងនេះ មិនបានចូលដល់រតនាគារដ្ឋដែរ។

វណ្ណៈពួកសក្ដិភូមិបានកកើតឡើង ជាពិសេស ដោយសារសមាជិកជាសាច់ញាតិជិតឆ្ងាយមួយចំនួនធំ នៃរាជវង្សានុវង្សទាំងប្រាំសន្ដាន (ដំណ)។ គឺជាបឋម មានព្រះរាជវង្សានុវង្សដែលមានសមាជិករាប់រយនាក់ តមក មានរាជវង្ស ដែលមានសមាជិកជាសាច់ញាតិឆ្ងាយចំនួនរាប់ពាន់នាក់។ព្រះរាជវង្សានុវង្សមានជីវភាពរស់នៅជាពិសេស ដោយសាររាជអំណោយរបស់មហាក្សត្រ ដែលពួកជនទាំងនេះបានទទួលនៅបរមរាជវាំង។ ដោយហេតុថា អ្នកទាំងនេះ ភាគច្រើនបានរស់នៅរដ្ឋធានី ហើយបានបម្រើកិច្ចការរាជការ ក៏ប៉ុន្តែ ពួកគេអាចមានដីធ្លីដែរ។ បណ្ដាសមាជិកនៃព្រះរាជវង្ស ដែលបានរស់នៅ ជាពិសេសតាមខេត្តនានា បានទទួលប្រាក់ចំណូលពីដីធ្លីរបស់ខ្លួន។ ពួកមន្ត្រី នាហ្មឺន ដែលបម្រើរាជការនៅអង្គការមជ្ឈិមនៅរដ្ឋធានី និងពួកមន្ត្រីនាហ្មឺននៅអង្គការទីអាយ ដូចជា ពួកចៅហ្វាយខេត្ត និងមន្ត្រីដទៃទៀត ក៏ជាម្ចាស់ដីឯកជនដែរ។ ពួកនាហ្មឺនថ្នាក់

តូចទាបនៅទីអាយ ពុំមានសិទ្ធិបង់ពន្ធដារទេ ក៏ប៉ុន្តែ នៅក្នុងកាលៈទេសៈភាគច្រើន ពួកទាំងនេះមានលទ្ធភាព តែមិនបង់ពន្ធដារក៏បាន។ កម្មសិទ្ធិគ្រប់បែបយ៉ាងលើដីរបស់ជនសក្តិភូមិទាំងនេះ មានតែលើដីប្រកបដោយរបរដាំដំណាំ ហើយដីមិនទាន់កាប់គាស់ទាំងអស់ត្រូវស្ថិតនៅជាសម្បត្តិរបស់រដ្ឋ។ គឺនៅក្នុងលក្ខខណ្ឌបែបនេះហើយ ដែលមានអ្នកម្ចាស់ជាន់ខ្ពស់បំផុតលើកម្មសិទ្ធិដីនៃរដ្ឋខ្មែរ គឺមហាក្សត្រជាម្ចាស់ផែនដី។

ហេតុដូច្នេះហើយ បានជាមានកម្មសិទ្ធិក្នុងការបន្តមរតកដីពីសំណាក់ពួកជនសក្តិភូមិ ដែលជាព្រះរាជវង្សានុវង្ស ប៉ុន្តែមានកម្មសិទ្ធិប្រកបដោយលក្ខខណ្ឌពីសំណាក់ពួកមន្ត្រី នាហ្មឺនសក្តិភូមិ (មានពួកចៅហ្វាយខេត្ត ជាដើម) ពីសំណាក់បណ្តាកសិករអ្នកជា ដែលបង់ពន្ធដារជូនរដ្ឋ និងពីសំណាក់បណ្តាកសិករអ្នកងារ ដែលធ្វើស្រែចម្ការលើដីរបស់ពួកសក្តិភូមិ។ តាមផ្លូវច្បាប់ ពួកជនទាំងអស់នេះ ក្រៅពីពួកអ្នកងារចេញ ត្រូវមានករណីយកិច្ចចំពោះមហាក្សត្រ ឬមួយដោយសារការបង់ពន្ធដារ ឬមួយដោយសារការបំពេញការងារដោយបង្ខំ ឬមួយដោយសារការបម្រើរាជការក្នុងរដ្ឋបាល។ គឺស្ថានភាពរបស់កសិករអ្នកងារបែបនេះ ដែលបានកំណត់តាមផ្លូវច្បាប់នូវទម្រង់នៃរបបសង្គមសក្តិភូមិ ព្រោះថា ជាស្ថានភាពដែលបានផ្តល់អភ័យឯកសិទ្ធិដល់ពួកអភិជន និងផ្តល់ពលកម្មដល់កសិករអ្នកងារ។ ក៏ប៉ុន្តែសភាពការណ៍ដ៏សំខាន់ជាងគេ គឺកម្មសិទ្ធិលើដី ហើយហាក់បីដូចជាអ្វីៗទាំងអស់ មានភាពស្មើគ្នាចំពោះព្រះមហាក្សត្រ ហើយសភាពការណ៍នេះបានបង្កើតឱ្យមានទស្សនៈភាន់ច្រឡំ ចំពោះភាពរឹងមាំជាឯកភាពនៃសង្គម ដែលជាមួយនឹងសភាពការណ៍

នេះ គឺជាសេចក្តីទូន្មានខាងពុទ្ធសាសនាថេរវាទមួយបែប ស្តីអំពីអនិស្សរភាពពីសំណាក់បណ្តាប្រជាពលករ។ ក៏ប៉ុន្តែ ធាតុពិតនៃទំនាក់ទំនងខាងសង្គម-សេដ្ឋកិច្ច មានលក្ខណៈជារបបសក្តិភូមិសុទ្ធសាធ។

ពន្ធអាករដ៏សំខាន់ជាងគេ មានឈ្មោះ "ពន្ធអាករពងស្រូវ" គឺជាពន្ធអាករទារយកជាស្រូវសម្រូប នៅរដូវច្រូតកាត់ គឺមានការបង់ពន្ធជារជាស្រូវចំនួន១ភាគ១០ នៃផលដំណាំស្រូវ។ ក្រៅពីពន្ធពងស្រូវ មានពន្ធជារដ៏ទៀងទាត់ជាច្រើនចំពូកទៀត មានការងារបង្ខំក្នុងការដឹកនាំផលដំណាំ ជួនកាលពន្ធនេះស្មើនឹង១ភាគ១០ នៃផលដំណាំ។ ពន្ធអាករអាចបង់ជាស្រូវក៏បាន ជាប្រាក់ក៏បាន ហើយស្រូវ និងប្រាក់បានទៅជារបស់សម្រាប់ការប្តូរផ្តោះជាទូទៅនៅស្រុកស្រែ នៅសតវត្សរ៍ទី១៨។ ដើម្បីជាឧទាហរណ៍ គេអាចបញ្ជាក់បានថា ផលដំណាំស្រូវនៅប្រទេសកម្ពុជា ពេលនោះ មានពី២ ០០០ ដល់ ៣ ២០០គីឡូក្រាមក្នុងមួយហិកតា បានសេចក្តីថា មានស្ថានភាពល្អក្នុងរបរកសិកម្ម នៅពេលនោះ ទោះបីមានសេចក្តីលំបាកខាងវិស័យនយោបាយ នៅទសវត្សរ៍ខាងដើមនានា នៃសតវត្សរ៍ទី១៩។ គួរកត់សម្គាល់ថា នៅក្នុងរង្វង់ឆ្នាំទី៣០ នៃសតវត្សរ៍ទី២០ នៅពេលដែលប្រទេសកម្ពុជា ស្ថិតនៅក្រោមរបបអាណានិគមនិយម ផលដំណាំស្រូវរបស់កសិករមានទំហំតិចជាងមុន។

របៀបកៀបសង្កត់ម៉្យាងដ៏សំខាន់ គឺការចែករំលែកដីដោយបង្ខំដល់បណ្តាអ្នកម្ចាស់ដី ដែលមានផលដំណាំខុសគ្នា។ ដីមានដីជាតិដ៏ល្អជាងគេ ហើយដែលមានការប្រកបរបរកសិកម្មតាមរបៀបបង្ខំ មិនស្របតាមមធ្យោបាយសេដ្ឋកិច្ច បានស្ថិតនៅក្នុង

កណ្តាប់ដៃរបស់ពួជពង្សស្តេច និងពួកសក្តិភូមិ។ ហេតុនេះហើយ បានជាជួនកាល សម្រាប់បណ្តាកសិករសេរី ការជួលដីទាំងនេះ ដើម្បីធ្វើបរស្រែចម្ការ ឃើញថា បានចំណោញច្រើនជាងធ្វើបរស្រែចម្ការលើដីគ្មានដីជាតិរបស់ខ្លួន។ នៅលើដីមានដីជាតិមធ្យម និងលើដីអាក្រក់ ផលដំណាំមិនល្អ តែងបណ្តាលឱ្យកសិករអ្នកជាមួយភាគ ធ្លាក់ខ្លួនក្រីក្រ ហើយការណ៍នេះ បានផ្តល់ផលចំណោញដល់ពួកក្តុម្ពីជាម្ចាស់ដី ក្នុងវិស័យនៃការប្រមូលកម្លាំងពលករបម្រុង ដោយហេតុថា អ្នកជាបានធ្លាក់ខ្លួនទៅជាពួកខ្ញុំជាប់បំណុល។ ស្ថានភាពរបស់កសិករអ្នកជាមិននឹងន នៅភាគខាងដើម នៃសតវត្សរ៍ទី១៩។ ការរត់ចោលស្រែចម្ការបានទៅជាសភាពការណ៍ធម្មតាសម្រាប់បណ្តាកសិករ។ ទោះបីគេពុំទាន់បានធ្លាក់ខ្លួនទៅជាពួកខ្ញុំក្តី ក៏បណ្តាកសិករជាប់បំណុលពុំមានកម្លាំងនឹងបំពេញការងារឱ្យម៉ឺងម៉ាត់ នៅលើដីស្រែចម្ការរបស់ខ្លួន។ នៅក្នុងរជ្ជកាល នៃព្រះបាទអង្គ-ឌួង (គ.ស.១៨៤១ - ១៨៦០) មានវិធានការហាមឃាត់ មិនឱ្យប្រើមធ្យោបាយទម្លាក់ស្ថានភាពកសិករអ្នកជាទៅជាពួកខ្ញុំជាប់បំណុល។ បើវិនិច្ឆ័យតាមសភាពការណ៍ជាក់ស្តែង វិធានការ និងប្រសិទ្ធភាពនៃការវិធានការនេះ ដែលត្រូវបានអនុវត្តនៅប្រទេសដទៃនៅអាស៊ីអាគ្នេយ៍ គឺជានយោបាយដែលមានអនាគតដ៏ល្អ។ ក៏ប៉ុន្តែ នយោបាយនេះ ពុំទាន់បានលេចចេញជាផ្លែផ្កា នៅភាគពាក់កណ្តាល នៃសតវត្សរ៍ទី១៩។

ទាក់ទងនឹងអំពើកៀបសង្កត់ ជាមធ្យមដល់បណ្តាកសិករសេរី យើងសូមបញ្ជាក់ថា ពន្ធដារបានគ្របសង្កត់លើទំហំពី ១ភាគ៥ ដល់ ១ភាគ៤ នៃផលដំណាំស្រូវមួយភាគ។ ក្រៅពីស្រូវ

ផលដំណាំដទៃទៀត ដូចជា ម្រេច ល្ង សណ្តែកដី សូត្រ បាន ផ្តល់ចំណូលដ៏សំខាន់ដល់រតនាគារ។

ការបំពេញការងារដោយបង្ខំ ត្រូវបានរៀបចំឡើងដោយ សារជំនួយជាពិសេស នៃការចូលរួមរបស់បណ្តាជនជាអ្នកជា ហើយនៅប្រទេសកម្ពុជា គេហៅជាពួក “ ពលកម្លាំង ” ។ ប្រព័ន្ធ បំពេញការងារបែបនេះ បានតម្រូវឱ្យបណ្តាជនជាអ្នកជាម្នាក់ៗ ចូលរួមក្នុង “ ពលកម្លាំង ” ដែលស្ថិតនៅក្រោមកិច្ចដឹកនាំរបស់ សមាជិករាជវង្ស ឬរបស់មន្ត្រីនៅរដ្ឋធានី។ នៅក្រោមកិច្ចដឹកនាំ របស់មន្ត្រីនេះ មានបណ្តាជនជាពលកម្លាំង ដែលនៅក្នុងស្ថាន ភាពអនិស្សរភាពផ្ទាល់ខ្លួន ប៉ុន្តែ មិនមែនបន្តពូជពង្សទេ។ មេពលកម្លាំង ឬនាយពលកម្លាំងអាចជ្រើសរើសសមាជិកពល កម្លាំងរបស់ខ្លួនតាមគោលការណ៍ផ្ទាល់ ហើយមិនមែនយោង ទៅតាមតំបន់ណាមួយច្បាស់លាស់ទេ។ ជាទូទៅ មេពលកម្លាំង រស់នៅរដ្ឋធានី។ របៀបបែងចែកដី និងបែងចែកស្ថានភាព អនិស្សរភាព បានបញ្ជាក់ឱ្យឃើញនូវជាតុពិតដ៏ពិសេសនៃ សង្គមខ្មែរ ក៏ប៉ុន្តែ ទម្រង់នៃអនិស្សរភាពទាំងពីរបែបនេះ គឺជា លក្ខណៈនៃរបបសក្តិភូមិ ដោយហេតុថា ក្នុងការបំពេញពល កម្មដោយបង្ខំ (បំពេញងារ) បណ្តាកសិករអ្នកជាបានបំពេញ ពលកម្មនៅក្នុងសមាសភាពនៃពលកម្លាំង ក្រោមកិច្ចដឹកនាំ របស់មេពលកម្លាំង។ នៅពេលបំពេញពលកម្មដោយបង្ខំ កសិករ អ្នកជាបានស្ថិតក្នុងស្ថានភាពអនិស្សរភាពចំពោះមេពលកម្លាំង ដែលបានទទួលបន្ទុកកសាងការដ្ឋានណាមួយ ឬបំពេញការងារ ណាមួយច្បាស់លាស់។ សភាពការណ៍បែបនេះ បានជំរុញឱ្យ កសិករអ្នកជាធ្លាក់ខ្លួន កាន់តែជ្រៅទៅក្នុងស្ថានភាពអនិស្សរភាព

ហើយជាស្ថានភាពដែលអាចផ្លាស់ប្តូរបាន នៅប្រទេសកម្ពុជា នៅក្នុងរដ្ឋបាលសហគមន៍ ដែលតែងទទួលបន្ទុកនៅក្នុងការបំពេញការងារទាំងនេះ។ ការវិវឌ្ឍ នៃសង្គម និងការបង្កើនសកម្មភាពច្រើនបែបយ៉ាងនៅក្នុងរបរកសិកម្ម បានបណ្តាលឱ្យមានការលំបាក នៅក្នុងកិច្ចអនុវត្តការងារជាសាធារណៈទូទៅ។ ហេតុនេះហើយ បានជាមិនមែនជាចៃដន្យទេ ដែលព្រះបាទអង្គ-ឌួង បានធ្វើការកែប្រែមួយក្នុងការបង្កើតប្រព័ន្ធកំណែនបណ្តាកសិករឱ្យបំពេញពលកម្មដោយបង្ខំ តាមរយៈ និងដោយជំនួយរបស់ពួកចៅហ្វាយខេត្ត តាមទឹកដី នៃខេត្តរបស់ខ្លួន។ ក៏ប៉ុន្តែ នៅសតវត្សរ៍ទី១៨ ពួកមេពលកម្លាំងបានស្ថិតនៅជាអ្នកចាត់ចែងការបំពេញការងាររដ្ឋដ៏សំខាន់។ ដូច្នេះហើយ បានជាគេរាប់បញ្ចូលការងារទាំងនេះ ថា ជា១ភាគ៤ នៃការងារទូទៅ។ គឺជាការងារដែលត្រូវបានបំពេញ ដោយរបបមិនស្របតាមរបៀបសេដ្ឋកិច្ចចំពោះបណ្តាកសិករសេរី។ ទំហំនៃការបំពេញពលកម្មច្រើនតែលើសពីការបំពេញការងារធម្មតា។ ក្នុងការបំពេញពលកម្មសម្រាប់រដ្ឋ បណ្តាអ្នកជាក៏ដូចជាអ្នកងារ នៅសម័យសតវត្សរ៍ពីទី៨ ដល់ទី១៤ គេទាំងឡាយបានកសាងផ្លូវ កំពែងបន្ទាយ ជង្រុកស្រូវ និងរៀបចំគ្រឿងសម្ភារៈសម្រាប់សំណង់នានា។ អ្នកខ្លះក៏បានលោះខ្លួន រួចផុតពីការបំពេញពលកម្មដោយបង្ខំ ហើយបានចាប់ផ្តើមធ្វើស្រែចម្ការ ដើម្បីបង់ពន្ធដារធម្មតាដល់រដ្ឋ។ សភាពការណ៍នេះ គឺជាការវិវត្តទូទៅនៅក្នុងវិស័យសេដ្ឋកិច្ចប្រទេសកម្ពុជា នាសម័យសតវត្សរ៍ទី១៩។

ដូចបានពណ៌នារួចមកហើយ គឺថា ពួកម្ចាស់ដីសក្តិភូមិបានប្រើប្រាស់ពលកម្មរបស់អ្នកងារ ដែលជាពួកខ្ញុំ ឬប្រើប្រាស់

ពលកម្មរបស់អ្នកជួលដី ដែលជាអ្នកជា។ ស្ថានភាពក្រីក្រ តោកយ៉ាកនៃអ្នកជា ដែលមិនមានលទ្ធភាពអាចសងបំណុល បានបន្ទាញអ្នកទាំងនេះឱ្យធ្លាក់ខ្លួនទៅក្នុងចំពូកពួកជន ដែលជាពួកខ្ញុំ។ ជនទាំងនេះមួយភាគជាកម្មសិទ្ធិរបស់ពួកអ្នកម្ចាស់បំណុល អ្នកខ្លះទៀតដែលរស់នៅទីក្រុង បានធ្លាក់ខ្លួនទៅជាខ្ញុំបម្រើនៅគេហដ្ឋានរបស់អ្នកម្ចាស់បំណុល ឬធ្លាក់ខ្លួនទៅជួញប្រែតូចតាច។ សភាពការណ៍ជាទូទៅ គឺអំពើជិះជាន់ពួកខ្ញុំដែលជាពិសេស គឺពួកអតីតកសិករក្នុងឋានៈជាពួកខ្ញុំក្រៅ បានសេចក្ដីថា មានការប្រើប្រាស់ពលកម្មរបស់គេទាំងឡាយនៅក្នុងរបរកសិកម្ម។ គេអាចប្រើប្រាស់ពលកម្មរបស់ពួកខ្ញុំជាអចិន្ត្រៃយ៍ ឬក៏ប្រើប្រាស់បានតែក្នុងកាលៈទេសៈដ៏ច្បាស់លាស់។ ស្ថានភាពតាមផ្លូវច្បាប់របស់អ្នកទាំងនេះមិនទាន់រឹងមាំ។ ដោយហេតុថាពួកខ្ញុំមួយភាគអាចលោះខ្លួនបាន គេអាចនិយាយបានថា អំពើជិះជាន់លើពួកខ្ញុំដោយពួកសក្ដិភូមិ មិនអាចប្រៀបបានទៅនឹងរបបទាសភាពទាំងខាងស្ថានភាពសង្គម និងសេដ្ឋកិច្ច។ សម្បត្តិទ្រព្យសន្សំដោយពួកខ្ញុំ ដើម្បីការលោះខ្លួន ឬដើម្បីសេចក្ដីត្រូវការរបស់គេ គឺមានសត្វពាហណៈ ប្រដាប់ប្រដារធ្វើស្រែចម្ការស្រូវបម្រុង។ សម្បត្តិទ្រព្យទាំងនេះ គេមិនអាចរឹបអូសយកបានឡើយ។ តាមពិត ខ្ញុំក្រៅ គឺជាសភាពសក្តិភូមិច្បាស់លាស់។

មានរបបបំពេញពលកម្មស៊ីឈ្នួលមួយបែបទៀត ដែលរីកសាយជាទូទៅ គឺ “ ជំនួយ ” ដល់ម្ចាស់ដីសក្តិភូមិពីសំណាក់នៃអ្នកជានៅក្នុងរង្វង់នៃរបៀប “ យកការ ” - គឺរបៀបជួយគ្នាទៅវិញទៅមក។ នៅក្នុងរបៀបដ៏ចាស់បូរាណបែបនេះ គឺថាអ្នកជាមានកាតព្វកិច្ច បំពេញពលកម្មដ៏ធ្ងន់ធ្ងរជាប្រយោជន៍ដល់

ជនសក្តិភូមិណាមួយជាអ្នកជិតខាង។ ជនសក្តិភូមិមិនបានចេញថ្លៃឈ្នួលចំពោះពលកម្មនេះទេ គឺគេគ្រាន់តែទទួលរៀបចំបាយទឹកឱ្យហូបប៉ុណ្ណោះ។

យើងសូមពិនិត្យបន្តិច ដល់អង្គការចាត់តាំងនៃរបបសក្តិភូមិ ដែលបានកើតមានឡើងនាសតវត្សរ៍ទី១៨។ នៅលើកំពូលនៃរដ្ឋ គឺមានមហាក្សត្រ ហើយស្ថានភាពរបស់ពួកសក្តិភូមិមួយភាគធំនៅប្រព័ន្ធ នៃឋានន្តរសក្តិបានទាក់ទងនឹងអនិស្សរភាពខ្លាំង ឬតិចរបស់ពួកជនទាំងនេះចំពោះមហាក្សត្រ។ បានសេចក្តីថា បុព្វសិទ្ធិនៃរបបសក្តិភូមិនៅប្រទេសកម្ពុជា មិនមែនមានតពូជពង្សទេ ដោយហេតុប្រាក់ចំណូលរបស់បណ្តាសមាជិករាជវង្សជិតឆ្ងាយមិនដូចគ្នា។ ក្រៅអំពីនេះ ពួកនាយកបានជ្រើសរើសបណ្តាមនុស្ស ក្រោមបង្គាប់របស់ខ្លួនដោយខ្លួនឯង ហើយសភាពការណ៍បែបនេះ បានបង្កើននូវចលនភាពនៃសមាសភាពក្របខ័ណ្ឌនៃរដ្ឋការ។ នៅពេលជាមួយគ្នានោះមានកើតនូវនិន្នាការក្នុងការកាន់កាប់តំណែងបន្តពូជពង្ស។ ជាទូទៅ ប្រទេសកម្ពុជា បានបង្កើតនូវស្ថានភាពអនិស្សរភាពដ៏សក្តិសិទ្ធរវាងវណ្ណៈសក្តិភូមិ និងមហាក្សត្រ ជាងរបបសក្តិភូមិដែលបានស្ថិនៅក្នុងប្រទេសសក្តិភូមិដទៃមួយចំនួនធំ។

សភាពការណ៍បែបនេះ អាចពន្យល់ឱ្យឃើញច្បាស់នូវទំនាស់តស៊ូប្រយុទ្ធគ្នាដ៏កាចសាហាវ ក្នុងការដណ្តើមរាជបល្ល័ង្ក។ ក៏ប៉ុន្តែ នៅពេលខ្លះ ការប្រយុទ្ធបង្ហូរឈាមគ្នាបែបនេះ មិនបានធ្វើឱ្យប្រទេសទាំងមូលរំជើបរំជួលទេ។

ជាទម្រង់ខាងក្រៅ មូលដ្ឋាននៃអង្គការរដ្ឋបាលរដ្ឋមានបួនប្រភេទ គឺវាសនដ្ឋានសម្រាប់មហាក្សត្រ វាសនដ្ឋានសម្រាប់

ឧបរាជ និងវាំសនដ្ឋានសម្រាប់វររាជិនី ដែលជាអគ្គមហេសីមហាក្សត្រ។ ជាទូទៅ វាំសនដ្ឋាននីមួយៗ មានវាំងហ្លួង និងមហាមន្ត្រី ព្រមទាំងបរិវារដទៃទៀត។ ក៏ប៉ុន្តែ តាមពិត គឺមានតែវាំសនដ្ឋានមហាក្សត្រ (រាជវាំង) ទេ ដែលមានលក្ខណៈជាស្ថាប័នកំពូលរបស់រដ្ឋ។ វាំសនដ្ឋានផ្សេងៗទៀត គឺជាស្ថាប័នទទួលបន្ទុកក្នុងការប្រមែប្រមូលប្រាក់ចំណូល ពីខេត្តនានា ដែលស្ថិតនៅក្រោមអំណាចរបស់ឥស្សរជនជាន់ខ្ពស់ណាមួយ ដែលជាប់ជារាជវង្សនឹងមហាក្សត្រ។ ក្នុងបណ្តាលខេត្តទាំង៥០នៅក្នុងរាជាណាចក្រ មានខេត្តចំនួន៣៥ ដែលស្ថិតនៅក្នុងអំណាចរបស់វាំសនដ្ឋានមហាក្សត្រ។ វាំសនដ្ឋានក្រៅពីនេះ មានខេត្តចំនួន៧ (ស្ថិតនៅក្រោមអំណាចរបស់ឥស្សរជនជាន់ខ្ពស់ម្នាក់) ខេត្តចំនួន៥ (ស្ថិតនៅក្រោមអំណាចរបស់ឥស្សរជនជាន់ខ្ពស់ម្នាក់ទៀត) និងខេត្តចំនួន៣ទៀត (ស្ថិតនៅក្រោមអំណាចរបស់ឥស្សរជនជាន់ខ្ពស់ម្នាក់ផ្សេងទៀត)។ ចំណូលគឺផលស្រូវ ឬ "ពងស្រូវ" ត្រូវបានប្រមូលពីខេត្តទាំងនេះ ដើម្បីបញ្ចូលមកជាប្រយោជន៍នៃវាំសនដ្ឋាននីមួយៗ ដោយសារមន្ទីរ នៃនាហ្មឺន និងភ្នាក់ងារទាំងឡាយ ដែលធ្វើការអមវាំសនដ្ឋាននីមួយៗ។ វាំសនដ្ឋានមហាក្សត្រ គឺជាស្ថាប័នកំពូលទូទៅរបស់រដ្ឋ ហើយនៅទីនេះ គឺមានមហាមន្ត្រីវាំង ដែលទទួលបន្ទុកក្នុងការប្រមូលផលស្រូវ។ អំណាចខាងរដ្ឋបាលនៅតាមខេត្តទាំងអស់ ស្ថិតនៅក្រោមអំណាចរបស់មហាក្សត្រ។ ចៅហ្វាយខេត្ត ជាប្រមុខខេត្តនីមួយៗ មេស្រុកជាប្រមុខស្រុកនីមួយៗ។ ជាលំដាប់លំដោយមកទៀត គឺមានឃុំ និងភូមិ ដែលមានមេឃុំ និងមេភូមិ ដែលត្រូវបានជ្រើសរើសពីសំណាក់បណ្តារាស្ត្រក្នុងឃុំ និងភូមិនីមួយៗ។

ចំណូលជាផលស្រូវ ដែលត្រូវប្រមូលបានមក ត្រូវប្រើប្រាស់សម្រាប់ការផ្គត់ផ្គង់វណ្ណៈអភិជននៅរដ្ឋធានី និងមន្ត្រីនាហ្មឺនបម្រើរាជការ សម្រាប់ការចំណាយរបស់បរមរាជវាំង និងសម្រាប់កងទ័ព។ ចំណូលជាផលស្រូវមួយភាគធំរបស់ពួកមន្ត្រីនាហ្មឺនសក្តិភូមិនៅរដ្ឋធានី និងនៅតាមជនបទនានា បានឡើងដល់១ភាគ១០ (ជួនកាល ១ភាគ៣) នៃចំណូលពន្ធដារទូទៅ ដោយហេតុថា ពួកមន្ត្រីនាហ្មឺនទាំងនេះជាអ្នករៀបចំការប្រមែប្រមូលពន្ធដារគ្រប់យ៉ាង។ ការធ្វើអំណោយដីដោយមហាក្សត្រមិនបានបំពេញតួនាទីអ្វីសំខាន់ដល់ថវិការបស់ពួកសក្តិភូមិឡើយ ព្រោះថា បុគ្គលជាអ្នកជាគ្រប់រូបអាចទទួលយកដីទំនេរ មិនទាន់មានការត្រួសត្រាយ។ ចំពោះដីស្រែចម្ការនាសម័យកាលនៃសតវត្សរ៍ទី១៨-១៩ កាលណាមហាក្សត្រប្រគល់ជារាជអំណោយគឺត្រូវតែបង់ថ្លៃ បានសេចក្តីថា តាមពិត មហាក្សត្របានលក់ដីស្រែចម្ការ។ ជារឿយៗ គឺពួកម្ចាស់ដីគេប្រវិញ្ញ ដែលបានទទួលឬបានទទួលដោយការបញ្ចាំនូវដីស្រែចម្ការទាំងឡាយ។ ច្បាប់ទម្លាប់ជាមូលដ្ឋានក្នុងការពង្រីកកម្មសិទ្ធិដី គឺការកាប់គាស់ដីធ្លីថ្មីៗដោយពួកជនទាំងឡាយណា ដែលមានមធ្យោបាយចំពោះការបំពេញកិច្ចការនេះ ឬមានសិទ្ធិលើការប្រើប្រាស់ពលកម្មដោយបង្ខំ។

នៅប្រទេសកម្ពុជា នាសម័យពាក់កណ្តាលសតវត្សរ៍ទី១៨ ស្ថានភាពវិបត្តិខាងនយោបាយបានកើតមានឡើង ហើយឥទ្ធិពលរបស់ប្រទេសសៀម ក៏បានរីកសាយកាន់តែខ្លាំងនៅក្នុងបរិយាកាសបែបនេះ។ ឫសគល់ច្បាស់លាស់នៃវិបត្តិទាំងនេះ - គឺទម្រង់ដ៏ចាស់បូរាណរបស់ពួកអភិជនសក្តិភូមិជាន់ខ្ពស់ នៅក្នុងសង្គមខ្មែរ

ដែលមានស្រទាប់ពួកសក្តិភូមិដ៏សំខាន់ៗមួយចំនួនធំ ជាប់ទាក់ទង នឹងរាជវង្សមហាក្សត្រ ដែលមានករិយាច្រើន។ នៅក្នុងរជ្ជកាល ព្រះបាទអង្គ-ទង និងព្រះបាទឧទ័យ មានការចាប់ផ្តើមប្រយុទ្ធ ប្រឆាំងនឹងទម្លាប់ និងប្រពៃណីដ៏ចាស់បូរាណនេះ ក៏ប៉ុន្តែ មិនទាន់ បានសម្រេចផលនៅឡើយ។ ទម្លាប់ និងប្រពៃណីចាស់បូរាណ នេះ ដែលបានកើតមានមកតាំងពីសម័យនៃការគោរពបូជា អាទិទេព មហាក្សត្របានយកចិត្តទុកដាក់ដល់ផលប្រយោជន៍ របស់មហាក្សត្រគ្រប់គ្រងរដ្ឋ (ឬដល់ព្រះអង្គម្ចាស់ ដែលនឹង ឡើងសោយរាជ្យ) ជាងការយកចិត្តទុកដាក់ដល់ផលប្រយោជន៍ របស់ប្រទេសទូទៅ ព្រមទាំងជាងផលប្រយោជន៍របស់អនាគត នៃរាជវង្សានុវង្ស។ សភាពការណ៍បែបនេះ បានបណ្តាលឱ្យ មានទំនាក់ទំនងប្រកបដោយសេចក្តីមើលងាយ ពីសំណាក់គូ ប្រឆាំងដើម្បីរាជសម្បត្តិ និងពីសំណាក់បណ្តាមុខមន្ត្រីធំៗ ដល់ សេចក្តីត្រូវការនានារបស់ប្រទេស និងរបស់ប្រជាជន ។ទោះជា សភាពការណ៍បែបនេះ ពុំអាចមានការគាំទ្រពីសំណាក់ប្រជា ជនក្តី ក៏នៅក្នុងមជ្ឈដ្ឋានពួកសក្តិភូមិ ជាពិសេសក្នុងមជ្ឈដ្ឋាន ព្រះសង្ឃ និងបរិវារបម្រើរាជការមហាក្សត្រ បានទទួលការទិតៀន ដែលស្តីអំពី កិច្ចការចាំបាច់ក្នុងកិច្ចការពារផលប្រយោជន៍រដ្ឋទូទៅ នៅសម័យពាក់កណ្តាលនៃសតវត្សរ៍ទី១៨ គឺជាសភាពការណ៍ ដែលមានលក្ខណៈជាទូទៅនៅសម័យនោះ។ អ្នកដឹកនាំទាំងឡាយ នៃនិន្នាការបែបនេះ មិនដែលបានទទួលការគាំទ្រពីសំណាក់ ប្រជាជនម្តងណាឡើយ ហើយជួនកាល ប្រជាជនបានស្ថិតនៅ ខាងមហាក្សត្រនានា ដែលកាន់កាប់នយោបាយម្រមូលផ្តុំនិយម។ ដូច្នេះហើយ បានជាអ្នកដឹកនាំនិន្នាការបែបនេះតែងបានសុំជំនួយ

ពីប្រទេសក្រៅ។ ការពង្រឹងកម្លាំងយោធានៃប្រទេសជិតខាងបណ្តាលឱ្យសភាពការណ៍ទាំងនេះ ដែលបានកកើតមានមកនៅក្នុងសង្គមខ្មែរតាំងពីមុន ទៅជាធាតុដ៏អាក្រក់ ចង្រៃ ដែលរំខានដល់ការលូតលាស់របស់សង្គមនាសម័យនោះ។

ដោយគ្មានការគាំទ្រពីមជ្ឈដ្ឋានពួកម្ចាស់ដីតូចតាច និងមធ្យម របបគ្រប់គ្រងរដ្ឋសក្តិភូមិត្រូវតែប្រើប្រាស់កម្លាំងគ្រប់យ៉ាងដើម្បីទប់ទល់ដល់ស្ថានភាពផ្ទាល់ខ្លួន ព្រោះថា កាលនោះ នៅក្នុងប្រទេសគ្មានក្រុមពួកសក្តិភូមិផ្សេងទៀត។ ចំណែកឯគណៈសង្ឃខាងពុទ្ធសាសនានៅសតវត្សរ៍ទាំងនោះ គឺគណៈសង្ឃពុំទាន់មានមូលដ្ឋានខាងការរៀបចំចាត់តាំងរឹងមាំ ទាំងខាងសម្ភារៈ និងខាងចំនួនមនុស្ស ដែលអាចជួយឧបត្ថម្ភដល់រដ្ឋអំណាចប្រមូលផ្តុំអំណាចបានឡើយ។ នៅក្នុងលក្ខខណ្ឌនៃការធ្វើចម្បាំងនៅក្រៅប្រទេស និងវិបត្តិទាស់ទែងផ្ទៃក្នុងមិនចេះចប់ រដ្ឋអំណាចមជ្ឈិមត្រូវបានខូចខាត ខូចសណ្តាប់ធ្នាប់ជាខ្លាំង។ ទោះបីមានការគំរាមកំហែងពីការបះបោរ ដឹកនាំដោយបណ្តាអតីតមហាមន្ត្រីក្តី ទោះបីមានការតស៊ូរបស់បណ្តាមហាក្សត្រខ្លះ ដើម្បីការពង្រឹងរដ្ឋអំណាចមជ្ឈិមក្តី ក៏ជាទូទៅ ឥទ្ធិពលរបស់មហាក្សត្រសៀម និងរបស់បុគ្គល ដែលទទួលការគាំទ្រពីពួកសៀម ដើម្បីកាន់កាប់អំណាចរដ្ឋនៅតែខ្លាំងដដែល។ គឺទាល់តែដល់ទសវត្សរ៍ទី៤ នៃសតវត្សរ៍ទី១៩ ទើបសន្ទុះនៃចលនាស្នេហាជាតិទូទៅ បានទៅជាមូលដ្ឋាននៃការពង្រឹងរដ្ឋអំណាចមជ្ឈិម។

ភាពចុះអន់ថយអំណាចរបស់ព្រះមហាក្សត្រ បានទាក់ទាញឱ្យមានការបង្កើនតួនាទីរបស់មន្ត្រីធំៗនៅរដ្ឋធានី ដែលជួនកាលបានរស់នៅតាមខេត្តនានា។ មន្ត្រីទាំងនេះបានត្រួតត្រា

ខេត្ត បានចែករំលែកអំណាចជាមួយមហាក្សត្រ ស្របទៅតាមមុខតំណែងរបស់ខ្លួន ហើយបានទទួលចំណូលភោគផលមកពីខេត្តនេះ ក៏ប៉ុន្តែ មន្ត្រីទាំងនេះ មិនបានត្រួតត្រាខេត្តជាអចិន្ត្រៃយ៍ទេ។ នៅក្នុងអតីតកាល ក៏ដូចជានៅពេលបច្ចុប្បន្ន គេមិនអាចពង្រឹងអំណាចត្រួតត្រារបស់ខ្លួន ឱ្យបានរឹងមាំអស់ពេលដ៏យូរបានឡើយ ទោះបីនៅពេលនោះ និន្នាការក្នុងការរក្សាអំណាចជាអចិន្ត្រៃយ៍បានពិតមែនក្តី។ មន្ត្រីត្រួតត្រាខេត្តទាំងនេះ គេមិនមែនជាពួកម្ចាស់ដីសក្តិភូមិធំៗឡើយ ព្រោះថា កម្លាំងសំខាន់ខាងនយោបាយ និងខាងសេដ្ឋកិច្ចរបស់ពួកគេ គឺចំណូលភោគផលទទួលបានមកពីខេត្ត ហើយបណ្តាភ្នាក់ងារ និងមនុស្សដែលនៅក្រោមបង្គាប់របស់ពួកមន្ត្រីទាំងនេះ មិនមែនជាអ្នកស្រុកនៅក្នុងខេត្ត ប៉ុន្តែ ជាសមាជិកនៃពលកម្លាំងរបស់មន្ត្រីនោះ។ បើតាមការសន្និដ្ឋានឥទ្ធិពលរបស់នាយកពលកម្លាំង បានលូតលាស់យ៉ាងរហ័ស។ ហេតុនេះ បានជាពលកម្លាំងដ៏សំខាន់ៗ មានទាំងពួកខ្ញុំ ទាហាន និងនាយក ព្រមទាំងគ្រួសារទាំងមូល ត្រូវបានជម្លៀសជារឿយៗ ទៅក្នុងខេត្តផ្សេងទៀត ជួនកាលត្រូវជម្លៀសឱ្យចេញក្រៅប្រទេសទៀតផង។ សភាពការណ៍នេះមានលក្ខណៈផ្ទុយនឹងគោលការណ៍របស់ចៅហ្វាយខេត្តធំៗ ដែលចង់រក្សាអំណាច និងទឹកដីឱ្យនៅក្នុងកណ្តាប់ដៃរបស់ខ្លួន ហើយគេនឹងអាចការពារទឹកដីនេះឱ្យបានខ្ជាប់ខ្ជួន។ សភាពការណ៍នេះ ដែលកើតមានឡើង បានក្លាយទៅជាទម្លាប់ក្នុងការជម្លៀសបណ្តាជនជាកសិករពីស្រុកស្រែមួយទៅស្រុកស្រែមួយទៀត ហើយនៅពេលមានចម្បាំងរាំងដល់ ពួកអ្នកកាន់កាប់អំណាចរដ្ឋតែងបាន

ជម្លៀសបណ្តាជនកសិករ ព្រមទាំងគ្រួសារទាំងអស់ ពីស្រុកមួយទៅស្រុកមួយទៀត។

នយោបាយបែបនេះ បានបណ្តាលឱ្យដែនដីខ្លះប្រែក្លាយទៅជាទីរហោឋាន បានធ្វើឱ្យរដ្ឋអំណាចមជ្ឈិមទៅជាទន់ខ្សោយ បានបន្ថយដល់អំណាចរបស់មហាក្សត្រ និងតួនាទីរបស់រដ្ឋធានីដែលនៅក្នុងអតីតកាល គឺជាស្ថាប័នប្រកបដោយអំណាចដ៏ខ្លាំងក្លានៅក្នុងសង្គមសក្តិភូមិខ្មែរ។ នៅសតវត្សរ៍ទី១៨ មានការផ្លាស់ប្តូរមិនចេះចប់ ពីកន្លែងមួយទៅកន្លែងមួយទៀត រដ្ឋធានីបានក្លាយទៅជាទីសមរភូមិជាញឹកញាប់។ ជួនកាល បណ្តាជននៅរដ្ឋធានី បានចូលរួមការប្រយុទ្ធ ដើម្បីគាំទ្រដល់ក្សត្រណាមួយដែលតស៊ូដើម្បីដណ្តើមរាជសម្បត្តិ។ ក្នុងកាលៈទេសៈដទៃទៀត រដ្ឋធានីត្រូវបានឡោមព័ទ្ធដោយបណ្តា “ អ្នកស្រុកព្រៃភ្នំ ” ដោយកុលសម្ពន្ធនានា ដោយកងទ័ពសៀម ដោយកងកម្លាំងរបស់បនសក្តិភូមិទាំងឡាយ។ នៅទីបំផុត រដ្ឋធានីបានបំពេញតួនាទីកាន់តែខ្សោយនៅក្នុងជីវភាពរបស់ប្រទេស។ មិនតែប៉ុណ្ណោះ ព្រឹត្តិការណ៍ទាំងនេះ បានបណ្តាលឱ្យមានភាពទន់ខ្សោយដល់ស្ថានភាពខាងសេដ្ឋកិច្ច និងវប្បធម៌របស់បណ្តាអាណិកជនបរទេស ដូចជា ជនជាតិចាម ចិន ជ្វា និងកូនចៅជាប់ឈាមនឹងជនជាតិព័រទុយហ្គេស។ ជនជាតិទាំងនេះ បានរស់នៅជាពិសេសនៅក្នុងរដ្ឋធានីនៃប្រទេសកម្ពុជា នាសម័យនោះ ហើយជនជាតិទាំងនេះ តែងបានទទួលក្តីអន្តរាយដែលកើតមកពីអំពើរាតត្បាតបះបោរគ្រប់យ៉ាង។

ទំនាស់ហែកហួរគ្នា រវាងបក្ខពួកនានានៅបរមរាជវាំង ដែលប្រទេសសៀម បានប្រើប្រាស់ជាលេសដើម្បីបង្កើតរបបអាណា

ព្យាបាលរបស់វាលើមហាក្សត្រខ្មែរកាន់តែខ្លាំងឡើង។ ទំនាស់បែបនេះ ត្រូវបានចាប់ផ្តើមទទួលប្រតិកម្មប្រឆាំងកាន់តែខ្លាំងពីសំណាក់ប្រជាជននៅក្នុងប្រទេស។ នៅបរមេរាជវាំង ពួកគេបានទិតៀនចោទប្រកាន់យ៉ាងចំហដល់ពួកជន “ ក្បត់ប្រទេសជាតិ ” របស់ខ្លួន ហើយការចោទប្រកាន់បែបនេះបានទៅជានិន្នាការដ៏សំខាន់នៅក្នុងមជ្ឈដ្ឋាននានានៃបរមេរាជវាំង។ គណៈសង្ឃខាងពុទ្ធសាសានា បានប្រកាន់ជំហរក្នុងការគាំទ្រសន្តិភាពផ្ទៃក្នុង ហើយព្រះសង្ឃ បានទេសនាផ្សព្វផ្សាយ នូវការរៀបចំស្ថានភាពសុខសាន្តនៅក្នុងប្រទេស។ ព្រះសង្ឃរាជ ដែលជាប្រធានគណៈសង្ឃបានបំពេញតួនាទី ជាអ្នករៀបចំការចរចារវាងព្រះឧទ័យ និងព្រះអង្គ-នន់ទី២ ហើយការចរចានេះបានចប់សព្វគ្រប់ដោយកិច្ចសម្រុះសម្រួលជាតិឡើងវិញ។ គេអាចនិយាយបានថា នយោបាយសម្រុះសម្រួលដោយសន្តិវិធីបែបនេះ បានទទួលការគាំទ្រដ៏ទូលំទូលាយពីសំណាក់បណ្តាជននៅស្រុកស្រែ នៅរដ្ឋធានី នៅទីក្រុងនានា និងពីសំណាក់បណ្តានាហ្មឺនតូចតាច ព្រមទាំងបណ្តាមហាមន្ត្រីសំខាន់ៗជាច្រើន នៅបរមេរាជវាំង។ បណ្តាកសិករខ្មែរ ដែលមានទុក្ខវេទនាជាច្រើន ព្រមទាំងបណ្តាជននៅរដ្ឋធានី និងនៅទីក្រុងឯទៀត ក៏បានគាំទ្រដល់នយោបាយសន្តិភាពផ្ទៃក្នុងនេះដែរ។ ក៏ប៉ុន្តែ នៅសម័យចុងសតវត្សរ៍ទី១៨ ចលនាបង្រួបបង្រួមគ្នាដោយសន្តិវិធី ពុំទាន់មានកម្លាំងគ្រប់គ្រាន់នៅឡើយ។

ប្រទេសកម្ពុជា នាសតវត្សរ៍ទី១៨ បានស្ថិតនៅជាប្រទេសប្រកបដោយរបរកសិកម្មពិតប្រាកដ។ ហេតុនេះហើយ បានជាបណ្តាជននៅទីក្រុង ទោះបីបានលូតលាស់ខាងបរិមាណ បើ

ប្រៀបធៀបទៅនឹងសតវត្សរ៍មុនៗក្តី ក៏តួនាទីរបស់បណ្តាជននៅទីក្រុង ពុំសូវមានឥទ្ធិពលខ្លាំងដូចជានៅក្នុងប្រទេសជិតខាងឡើយ។ បណ្តាជនប្រកបរបរសិប្បកម្មនៅស្រុកស្រែ និងនៅទីក្រុង បានផ្តល់គ្រឿងផលិតរបស់ខ្លួនដល់ទីផ្សារនានា ដែលបានកើតមានឡើងនៅក្នុងប្រទេស ប៉ុន្តែ មូលនិធិ និងក្របខ័ណ្ឌខាងសិប្បកម្មបានចូលមកសណ្ឋិតនៅទីក្រុងនានា ដោយសង្វាក់ដ៏យឺតយ៉ាវ។ នៅតាមទីក្រុងទាំងឡាយនៅប្រទេសកម្ពុជា ក៏ដូចជានៅប្រទេសសៀម ពួកពាណិជ្ជករធំៗ ដែលបានដើរតួដ៏សំខាន់នៅក្នុងវិស័យពាណិជ្ជកម្ម គឺមានច្រើនតែជនជាតិចិន។ នៅសតវត្សរ៍ទី១៨ ប្រទេសកម្ពុជា ពុំទាន់បានពង្រីកនូវពាណិជ្ជកម្មតាមផ្លូវសមុទ្រ។ ដូច្នេះហើយ បានជាការនាំចេញទំនិញទៅលក់នៅប្រទេសក្រៅ នៅមានស្ថានភាពទន់ខ្សោយ។

# ចំពូកទី៥
## ប្រទេសកម្ពុជា នាសម័យពាក់កណ្ដាលភាគទី១ នៃសតវត្សរ៍ទី១៩

នៅសម័យពាក់កណ្ដាលភាគទី១ នៃសតវត្សរ៍ទី១៩ នៅប្រទេសកម្ពុជា មានការរីកចម្រើនខាងពាណិជ្ជកម្មនៅក្នុងប្រទេស ខាងការប្រើប្រាស់នៅក្នុងការលក់ទិញអីវ៉ាន់ និងខាងសំណង់ទូទៅនៅក្នុងប្រទេស។ ស្ថានភាពទូទៅដ៏ប្រសើរ ដែលកើតឡើងដោយសារសេចក្ដីត្រូវការ ស្រូវអង្ករនៅលើទីផ្សារពិភពលោក បានធ្វើឱ្យស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេសមានលក្ខណៈប្រសើរ។

ក៏ប៉ុន្តែ ផ្ទុយពីប្រទេសសៀម នៅក្នុងវិស័យនយោបាយ ស្ថានភាពអនិស្សរភាពរបស់ប្រទេសកម្ពុជា ពុំអាចឱ្យប្រទេសដកខ្លួនចេញពីឥទ្ធិពលរបស់ប្រទេសខាងជើង ដើម្បីក្រេបជញ្ជក់នូវស្ថានភាពដ៏ពិសិដ្ឋនេះបានពេញលេញឡើយ។

ការសោយរាជសម្បត្តិដ៏យូរ របស់ព្រះបាទអង្គចន្ទទី២ (១៨០៦-១៨៣៤) ជាពិសេស សម័យកាលខាងដើមនៃការឡើងសោយរាជ្យនេះ បានប្រព្រឹត្តទៅដោយការតស៊ូប្រឆាំងនឹងឥទ្ធិពលឈ្លានពានរបស់សៀម ដែលមានកម្រិតកាន់តែខ្លាំងឡើង។ ការរៀបអាពាហ៍ពិពាហ៍ជាមួយនឹងបុត្រីរបស់ស្ដេចត្រាញ់ នៅតំបន់ខាងបស្ចិមប្រទេស ព្រះនាមក្សត្រី បេង បានផ្ដល់លទ្ធភាពដល់ព្រះបាទអង្គចន្ទទី២ ឱ្យព្រះអង្គអាចរៀបចំការត្រួតត្រាពេញលេញលើទឹកដីទាំងនេះ ដោយហេតុថា ចាប់ពីពេលនេះទៅ អ្នកគ្រប់គ្រងទឹកដីនេះ គឺជាមហាក្សត្រ ដែលជាប់សាច់ញាតិជាមួយ

អ្នកដឹកនាំនៅទីនេះ។ ក៏ប៉ុន្តែ ឥទ្ធិពលពិតប្រាកដនៃរដ្ឋអំណាចមហាក្សត្រ នៅលើទឹកដីទាំងនេះមានលក្ខណៈពេញលេញ បន្ទាប់ពីការពង្រឹងខាងកងកម្លាំងប្រដាប់អាវុធ និងបន្ទាប់ពីមានការផ្លាស់ប្តូរស្ថានភាពនយោបាយអន្តរជាតិ។ ស្ថានភាពនយោបាយអន្តរជាតិបែបនេះ បានកើតមានឡើង បន្ទាប់ពីអធិរាជប្រទេសវៀតណាម នាម យ៉ា ឡុង បានពង្រឹងស្ថានភាពរបស់ខ្លួននៅលើរាជបល្ល័ង្ក ហើយដើម្បីជាផលប្រយោជន៍ដល់ពួកសក្តិភូមិវៀតណាម អធិរាជបានចាប់ផ្តើមធ្វើការប្រឆាំងនឹងឥទ្ធិពលសៀមនៅបរមរាជវាំងខ្មែរ។ ទោះបីមានការកៀបសង្កត់ខាងយោធាមកលើប្រទេសកម្ពុជា យ៉ាងណាក្តី មហាក្សត្របានរកឃើញនូវរូបមន្តមួយនៅក្នុងសេចក្តីព្រមព្រៀង ដែលបើកផ្លូវឱ្យព្រះអង្គ មានយោបល់យល់ចំពោះអំពើជ្រៀតជ្រែកមិនត្រឹមត្រូវ របស់ប្រទេសសៀម មកក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជា។ ព្រះបាទអង្គចន្ទ បានព្រមព្រៀងចំពោះសំណើរបស់អធិរាជយ៉ា ឡុង ដែលបានស្នើឱ្យមានអាណាព្យាបាលពីរបែប គឺប្រទេសសៀម និងវៀតណាម។ ដូចមានការបញ្ជាក់តាមស្ថានភាពនៃសភាពការណ៍ដែលបានរីកចម្រើនតទៅមុខទៀត នយោបាយតាមផ្លូវទូតបែបនេះ អនុញ្ញាតឱ្យមានការរៀបចំស្ថានភាពប្រកបដោយតុល្យភាពស្មើគ្នារវាងប្រទេសជិតខាងទាំងពីរ ហើយបានផ្តល់សេរីភាពដ៏ទូលំទូលាយនៅក្នុងការដឹកនាំនយោបាយដ៏យូរអង្វែងតទៅមុខនៃប្រទេសកម្ពុជា។ នៅឆ្នាំ១៨០៧ គណៈតំណាងទូតខ្មែរ បានទៅដល់រដ្ឋធានី វៀតណាម ទីក្រុងវ៉េ ដោយនាំទាំងជំនួយនានាដូចជា ដំរីស្រុក ភ្លុកដំរី ក្រវាញ និងរបស់ដទៃទៀត។ នៅពេល

នោះ កងទ័ពវៀតណាម ឥតមានស្ថិតនៅប្រទេសកម្ពុជា ហើយស្ថានភាពនៅក្នុងប្រទេសអាចសន្មតថា មានស្ថានភាពនឹងន។

ក៏ប៉ុន្តែ ប្រទេសសៀម បានបន្តនយោបាយជាទម្លាប់របស់ខ្លួនក្នុងការប្រើប្រាស់ទំនាស់រវាងសមាជិកនានា នៃរាជវង្សានុវង្ស។ ហេតុនេះហើយ បានជានៅក្នុងពេល នៃការស្នាក់អាស្រ័យនៅរបស់ព្រះអង្គម្ចាស់អង្គឌួង និង អង្គអេង នៅទីក្រុងបាងកក ដើម្បីចូលរួមក្នុងពិធីបូជាព្រះសពនៃមហាក្សត្រសៀមនាមរាមាទី១ មហាក្សត្រថ្មីនៃប្រទេសសៀម នាម រាមាទី២ បានតែងតាំងព្រះអង្គឌួង និង អង្គអេងឱ្យមានឋានៈជាឧបយុវរាជ និងឧបរាជ ដោយគ្មានសេចក្តីយល់ព្រមអ្វីពីព្រះបាទអង្គចន្ទ។ ព្រឹត្តិការណ៍នេះបានកើតឡើង នាឆ្នាំ១៨១០។ ការទាក់ទងរវាងមហាក្សត្រ និងបងប្អូនប្រុសរបស់ព្រះអង្គទាំងពីររូប ដែលបានត្រឡប់មកប្រទេសវិញ មានស្ថានភាពតឹងតែងបំផុត ហើយបណ្តាសេនាមាត្យជាអ្នកធ្វើដំណើរកំដ ត្រូវបានកាត់ទោសប្រហារជីវិត ហើយព្រះអង្គឌួង បានគេចខ្លួនទៅរស់នៅក្នុងខេត្តខាងបស្ចិមនៃប្រទេសត្រួតត្រាដោយមហាមន្ត្រី បេង។ បន្ទាប់ពីព្រឹត្តិការណ៍នេះមក ប្រទេសសៀម បានចូលជ្រៀតជ្រែកមកក្នុងប្រទេសកម្ពុជា ជាខ្លាំង ហើយមហាក្សត្របានស្នើសុំជំនួយពីអធិរាជយ៉ា ឡុង ក៏ប៉ុន្តែ ជំនួយជាកម្លាំងទ័ព ដែលបានបញ្ជូនមក មានចំនួនមិនគ្រប់គ្រាន់។ កងទ័ពសៀម បានធ្វើឱ្យកងទ័ពព្រះបាទអង្គចន្ទ ទទួលបរាជ័យ ហើយនៅឆ្នាំ១៨១២ ព្រះអង្គបានយាងទៅប្រទេសវៀតណាម។ នៅពេលជាបន្ទាប់មក ព្រះអង្គឌួង និងព្រះអង្គអេង បានត្រឡប់មកតាំងរបបត្រួតត្រាជាបណ្តោះអាសន្ន នៅក្នុងរយៈពេលដ៏ខ្លី នៅទីក្រុងឧត្តុង្គ ហើយដែលនៅពេលនោះ ជាលើកទី១ មានពួក

មន្ត្រីសៀម ធ្វើការនៅក្នុងរដ្ឋបាលខ្មែរ។ នៅពេលនោះ ស្ថានភាពនៃរដ្ឋធានីឧត្តុង្គ មានលក្ខណៈមិនច្បាស់លាស់ ដោយហេតុថា ចំពោះព្រះអង្គឌួង សម្ពន្ធភាពជាមួយប្រទេសសៀម បែបនេះ គឺគ្រាន់តែជាកិច្ចការបណ្តោះអាសន្នតែប៉ុណ្ណោះ។ ហេតុនេះហើយបានជាព្រះអង្គឌួង មិនយល់ព្រមឡើងសោយរាជ្យ ហើយនៅពេលក្រោយមក បានធ្វើដំណើរចាកចេញពីទីក្រុងឧត្តុង្គ។ ក្នុងរឿងនេះ គេអាចសន្និដ្ឋានបានម្យ៉ាងទៀតថា ដោយគ្មានសេចក្តីទុកចិត្តលើព្រះអង្គ ពួកសៀម បាននាំព្រះអង្គចេញពីទីក្រុង។ ទោះបីដូចម្តេចក្តី ព្រះអង្គឌួង និងអង្គអេង ពុំបានព្រមព្រៀងតាំងខ្លួនជាកូនអុករបស់ប្រទេសសៀម ដែលជារឿងធ្លាប់មានមកហើយចំពោះការដណ្តើមរាជបល្ល័ង្ក ហើយសភាពការណ៍បែបនេះបានសម្រួលដល់ការវិលត្រឡប់របស់ព្រះបាទអង្គចន្ទ មកមកាន់មាតុភូមិវិញ។ ប្រទេសវៀតណាម បានបញ្ជូនកម្លាំងទ័ពប្រកបដោយទាហាន២០ពាន់នាក់ ក្រោមកិច្ចបញ្ជាការរបស់សេនាប្រមុខឡេ វ៉ាន់យៀត បានវាយកម្ចាត់កងទ័ពសៀម ពីក្រុងឧត្តុង្គ ហើយនៅឆ្នាំ១៨១៣ បន្ទាប់ពីការចាកចេញពីរដ្ឋធានីអស់រយៈពេលពីរ-បីខែ ព្រះបាទអង្គចន្ទ បានយាងត្រឡប់មកសោយរាជ្យនៅទីនេះវិញ។ ក៏ប៉ុន្តែ នៅពេលនោះ កងទ័ពសៀម បានវាយបង្ក្រាបដល់កុបកម្មបះបោរ ក្រោមការដឹកនាំរបស់ចៅហ្វាយខេត្តកំពង់ស្វាយ ហើយដោយសារសេចក្តីព្រមព្រៀងរបស់ចៅហ្វាយខេត្តនេះ ប្រទេសសៀម បានកាន់កាប់លើខេត្តចំនួនបីនៅតំបន់ខាងជើងនៃប្រទេស។ នៅពេលជាបន្ទាប់មក កងទ័ពសៀម បានចាប់ផ្តើមធ្វើការវាយលុកដ៏ធំ បណ្តាលឱ្យកងទ័ពប្រទេសកម្ពុជា ទប់ទល់មិនឈ្នះ ហើយទទួលបរាជ័យ។ នៅឆ្នាំ១៨១៤ ពួកសៀម បាន

វាយដណ្ដើមយកខេត្តម្លូរព្រៃ និងទន្លេពៅ ដែលស្ថិតនៅតំបន់ខាងជើងនៃប្រទេស។ មិនតែប៉ុណ្ណោះ ពួកវាបានវាយដណ្ដើមយកបានទាំងខេត្តជិតខាង គឺស្ទឹងត្រែង មកដាក់ក្នុងរបបត្រួតត្រារបស់ខ្លួន។

ព្រះបាទអង្គចន្ទ ពុំបានទទួលស្គាល់ការកាន់កាប់ដែនដីទាំងនេះ ដោយប្រទេសសៀម ក៏ប៉ុន្តែ នៅពេលនោះ ខ្មែរពុំអាចកម្ចាត់សៀម ពីទីនោះបានឡើយ។ ជ័យជម្នះរបស់ប្រទេសសៀមបានជំរុញឱ្យអធិរាជ យ៉ា ឡុង ធ្វើជំហានថ្មីទៀត បានសេចក្ដីថាដែនដីនៅជាប់មាត់ទន្លេមេកុងខាងស្ដាំ ចាប់តាំងពីភាគខាងត្បូងព្រែកជីកហាទៀនដែលបានកសាងឡើង ដោយកសិករខ្មែរ និងវៀតណាម នៅឆ្នាំ១៨១៥ - ១៨២០ ត្រូវបានដាក់ឱ្យនៅក្រោមរបបត្រួតត្រារដ្ឋបាល នៃប្រទេសវៀតណាម។ នៅពេលជាមួយគ្នាការទាក់ទងស៊ីវិល និងយោធាជាមួយប្រទេសកម្ពុជា ត្រូវបានផ្ដាច់ចេញពីរាជរដ្ឋាភិបាលកម្ពុជា ហើយការទាក់ទងរបស់ដែនដីទាំងនេះ ត្រូវបានភ្ជាប់ទៅនឹងកិច្ចការត្រួតត្រារបស់ចៅហ្វាយខេត្តវៀតណាមខាងត្បូង វិញ។ ទោះបីរដ្ឋអំណាចពិតស្ថិតនៅក្នុងរដ្ឋអំណាចរបស់ព្រះបាទអង្គចន្ទ ក៏ដោយ ដែលមានបំណងបន្តការតស៊ូ ដើម្បីទាក់ទាញយកដែនដីទាំងនេះមកវិញ ក៏បំណងនេះមិនបានសម្រេច ដោយហេតុថា នៅពេលនោះ មានភយន្តរាយដោយទឹកជំនន់ ភាពរាំងស្ងួត និងជំងឺអាសន្នរោគ ដែលធ្វើឱ្យប្រទេសទៅជាទន់ខ្សោយ ហើយមិនអាចផ្ដល់លទ្ធភាពឱ្យមានការរៀបចំយុទ្ធនាការប្រឆាំងដ៏មុឺងម៉ាត់ តាមព្រំប្រទល់ទាំងនេះបានឡើយ។ នៅពេលក្រោយមក សង្គ្រាមក៏បានកើតឡើងនៅតំបន់កណ្ដាល នៃប្រទេសកម្ពុជា។

នៅសម័យនៃទសវត្សរ៍ទី១ - ៣ នៃសតវត្សរ៍ទី១៩ គឺជាសម័យកាលនៃការបង្កើនកងកម្លាំងយោធារបស់ប្រទេសសៀម និងវៀតណាម។ ក៏ប៉ុន្តែ សម្រាប់ប្រទេសកម្ពុជា គឺជាសម័យកាលនៃការចុះអន់ថយកាន់តែខ្លាំងឡើង។ នៅឆ្នាំ១៨១៨ រាជវាំងវៀតណាម បានទាមទារឱ្យមានការបង្ក្រាបកុបកម្មនៅតាមតំបន់ទិសអាគ្នេយ៍ នៃខេត្តបាភ្នំ ហើយព្រះបាទអង្គចន្ទ ត្រូវបានបង្ខំចិត្តទទួលយល់ព្រម។ ក៏ប៉ុន្តែ នៅពេលក្រោយមកទៀត កងទ័ពវៀតណាម ក៏បានដកចេញពីប្រទេសកម្ពុជា។ នៅក្នុងប្រទេសមានសេចក្ដីស្ងប់ស្ងៀមសុខសាន្តអស់អំឡុងពេលជិត១៥ឆ្នាំ។

នៅសម័យ នៃទសវត្សរ៍ទី៣ ព្រឹត្តិការណ៍នានា ដែលបានទាក់ទាញឱ្យប្រទេសកម្ពុជា ធ្លាក់ទៅក្នុងភ្លើងសង្គ្រាមដ៏អន្តរាយខូចខាត និងដែលបង្កើតបានជាមធ្យោបាយឱ្យប្រទេសក្រៅចូលជ្រៀតជ្រែក ធ្វើការសោកល្បងឱ្យបាត់បង់ឯករាជភាព នៃប្រទេស ក៏បានកើតមានឡើងជាបន្តបន្ទាប់។ នៅឆ្នាំ១៨៣១ កងទ័ពសៀម របស់ព្រះមហារាជារាមាទី៣ ក៏បានវាយលុកចូលប្រទេសកម្ពុជា។ នៅក្នុងការប្រយុទ្ធគ្នា កងទ័ពខ្មែរបានទទួលបរាជ័យនៅក្នុងខេត្តកំពង់ឆ្នាំង ហើយនៅពេលនោះ រដ្ឋធានីឧត្តុង្គ និងទីក្រុងភ្នំពេញ ក៏បានធ្លាក់ទៅក្នុងកណ្ដាប់ដៃរបស់សត្រូវ។ នៅរដ្ឋធានីឧត្តុង្គ ព្រះអង្គឌួង និងអង្គអេង ក៏បានលេចមុខសាជាថ្មី។ ក៏ប៉ុន្តែ នៅតំបន់ខេត្តខាងលិចនានា កងទ័ពមហាក្សត្រកម្ពុជា ក៏បានប្រមែប្រមូលគ្នាឡើងវិញ។ បន្ទាប់ពីការទទួលបរាជ័យ នៅពេលតទៅទៀត ចលនាចម្បាំងលបធ្មក់ក៏បានកើតឡើងនៅក្នុងប្រទេស។ នៅក្នុងស្ថានភាពបែបនេះ ការវាយលុកតបវិញយ៉ាងរហ័សរបស់កងទ័ពវៀតណាម ដែល

ប្រកបដោយទាហានចំនួនមួយម៉ឺនប្រាំពាន់នាក់ បានធ្វើឱ្យកងទ័ពសៀម ទទួលបរាជ័យ ហើយរត់ថយចេញពីកន្លែងនានាដែលខ្លួនទើបនឹងបានកាន់កាប់។ កងទ័ពវៀតណាម មិនបានវាយដេញតាមកងទ័ពសៀម តទៅទៀតដល់ខេត្តបាត់ដំបង ទេ ហើយបានត្រឡប់ទៅកាន់មាតុភូមិរបស់ខ្លួនវិញ បន្ទាប់ពីការតែងតាំងឱ្យព្រះបាទអង្គចន្ទ ឡើងសោយរាជ្យ ដូចដើមវិញ។

ការទាក់ទងនានាជាមួយប្រទេសវៀតណាម បានផ្លាស់ប្តូរបន្ទាប់ពីព្រះបាទអង្គចន្ទ សោយទិវង្គតនៅឆ្នាំ១៨៣៤ ហើយអធិរាជវៀតណាម នាម មិញ-ម៉ាង បានពង្រឹងស្ថានភាពនយោបាយរបស់ប្រទេសនៅវៀតណាមខាងត្បូង ដោយមិនបានឱ្យតម្លៃច្បាស់ដល់អត្ថន័យ នៃចម្បាំងលបច្ចក់របស់ប្រជាជនខ្មែរដែលបានធ្វើឱ្យកងទ័ពសៀម ទទួលបរាជ័យ បែរជាឱ្យតម្លៃដ៏ខ្ពស់ដល់តួនាទីបំពេញដោយកងទ័ពវៀតណាម ទៅវិញ។ អធិរាជមិញ - ម៉ាង ហ៊ានចាប់ផ្តើមដំណើរការ ដោយប៉ុនប៉ងដាក់ប្រទេសកម្ពុជា ឱ្យចូលជាសមាសភាព នៃប្រទេសរបស់ខ្លួន។ កាលមកដល់ទីក្រុងឧត្តុង្គ អ្នកតំណាងអធិរាជវៀតណាម បានបង្ខំឱ្យមានការជ្រើសរើសយុវមហាក្សត្រិយានី អង្គម៉ី ឱ្យឡើងសោយរាជ្យ។ នៅពេលនោះ មានមន្ត្រីរបស់អធិរាជ មិញ-ម៉ាង បីរូប ដែលស្ថិតនៅក្នុងកិច្ចការកំពូលរបស់រដ្ឋកម្ពុជា ហើយរដ្ឋធានីត្រូវបានគេផ្លាស់ឈ្មោះ។ នៅក្នុងសម័យកាលនៃមហាក្សត្រិយានីអង្គម៉ី ( ១៨៣៣ - ១៨៤១ ) បណ្តារដ្ឋមន្ត្រី ដែលត្រូវបានគេនាំទៅកាន់ទីក្រុងព្រៃនគរ ត្រូវបានផ្តាច់ពីឋានន្តរស័ក្តិរបស់ខ្លួន ហើយកិច្ចការរដ្ឋបាល ត្រូវបានកាន់កាប់ដោយនាហ្មឺនមន្ត្រីរបស់ មិញ - ម៉ាង។ នៅអមចៅហ្វាយខេត្តនីមួយៗ មានទេសាភិបាលតំណាង

មិញ-ម៉ាង ម្នាក់ ហើយកងទ័ពខ្មែរ ត្រូវបានកែប្រែឱ្យទៅជាកងនគរបាល ដែលស្ថិតនៅក្រោមបញ្ជាការរបស់ពួកនាយទាហានអធិរាជ មិញ-ម៉ាង។

កាលព្រះអង្គអេង ត្រូវគេចាប់បាន អធិរាជ មិញ-ម៉ាង មិនបានអនុញ្ញាតឱ្យព្រះអង្គគ្រប់គ្រងប្រទេសទេ ហើយត្រូវបានគេនាំទៅកាន់ប្រទេសវៀតណាម។ នៅឆ្នាំ១៨៤១ មហាក្សត្រិយានីព្រមទាំងបងស្រីជាឧបរាជ ក៏ត្រូវបាននាំចេញពីប្រទេសទៅដែរ។ នៅប្រទេសកម្ពុជា ក្នុងរយៈពេល៤ឆ្នាំ ការត្រួតត្រារបស់ប្រទេសបានស្ថិតនៅក្រោមអំណាចរបស់ឧត្តមសេនីយ៍ ទ្រៀង-មិញយ៉ាង។ ក៏ប៉ុន្តែ នៅពេលនោះ កុបកម្មបះបោរក៏បានកើតមានឡើងនៅទូទាំងប្រទេស យុទ្ធជននៃកុបកម្មប្រកបដោយពួកកសិករ ក្រោមការដឹកនាំរបស់មគ្គុទ្ទេសក៍នានា ដែលជាកសិករ ជាព្រះសង្ឃ ជាភ្នាក់ងាររាជការបានធ្វើការវាយលុក ហើយដណ្ដើមយកបានបន្ទាយចំនួន៥០កន្លែង។ នៅពេលនោះ ប្រទេសសៀម ពុំទាន់មានពេលនឹងពង្រឹងស្ថានភាពរបស់ខ្លួន ហើយពុំទាន់មានពេលចូលជ្រៀតជ្រែកក្នុងកិច្ចការនានា ទាក់ទងនឹងព្រឹត្តិការណ៍នៅប្រទេសកម្ពុជា។ ព្រះបាទអង្គ ឌួង បានឡើងសោយរាជ្យលើប្រទេសកម្ពុជា នាឆ្នាំ១៨៤៥-១៨៥៩។ ព្រះអង្គជាអ្នកនយោបាយមួយរូប ដែលធ្វើការតស៊ូប្រឆាំងនឹងឥទ្ធិពលបរទេស ហើយបានប្រកាន់នយោបាយបែបនេះតាំងពីដើមទីមក គឺនយោបាយទទួលយល់ព្រមឱ្យមានអាណាព្យាបាលទ្វេភាគី ដើម្បីជាមូលដ្ឋានសម្រាប់ការតស៊ូប្រឆាំងនឹងសេចក្ដីប៉ុនប៉ងទាមទារនានា របស់ប្រទេសជាអាណាព្យាបាលទាំងពីរនេះ។

តាំងពីសម័យនៃការឡើងសោយរាជ្យ ជាបឋម ការតស៊ូរួមគ្នារវាងកងទ័ពខ្មែរ-សៀម ប្រឆាំងនឹងកងកម្លាំងរបស់ ទ្រឿង-មិញយ៉ាង មានលក្ខណៈដ៏ស្វិតស្វាញ។ ជាច្រើនដង កងទ័ពខ្មែររបស់ព្រះបាទអង្គឌួង បានមកជួយយកអាសាកងទ័ពសៀម ហើយបានធ្វើចម្បាំងតាមរបៀបការពារនៅនឹងកន្លែង។ នៅពេលតមកទៀត កងកម្លាំងរបស់ព្រះបាទអង្គឌួង បានចេញមុខធ្វើយុទ្ធនាការនៅលើសមរភូមិ។ ទោះបីមានគ្រឿងអាវុធយុទ្ធភណ្ឌមិនស្មើភាពគ្នាក្តី ទោះបីមានជ័យជម្នះខ្លះៗនៅតំបន់បាភ្នំ បន្ទាយដែក ចតុមុខក្តី ក៏ជាទូទៅ កងទ័ពវៀតណាម មិនអាចដណ្តើមយកជោគជ័យបានឡើយ។ នៅពេលនោះ កងកម្លាំងប្រដាប់អាវុធកសិករ ក៏បានលូតលាស់ឡើងយ៉ាងរហ័ស ហើយនៅក្នុងការតស៊ូរួមគ្នា កងកម្លាំងទាំងនេះបានវាយបំបាក់បំបែកកងទ័ពមិញ-ម៉ាង នៅជិតទីក្រុងលង្វែក។ ព្រះបាទអង្គឌួង ទ្រង់បានយាងចូលមកទីក្រុងភ្នំពេញ ហើយនៅក្នុងសភាពការណ៍បែបនេះ ដែលមានពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីអំពីសន្តិភាព នាឆ្នាំ១៨៤៥។ ទោះបីព្រះអង្គបានទៅជាមហាក្សត្រ នៃប្រទេសកម្ពុជា ដោយសារការជួយឧបត្ថម្ភគាំទ្ររបស់ប្រទេសសៀម ក្តី ក៏ព្រះបាទអង្គឌួង មិនដែលសំដែងសេចក្តីទុកចិត្តលើពួកសៀម ម្តងណាឡើយ។ គោលការណ៍ដ៏សំខាន់ក្នុងនយោបាយក្រៅប្រទេស បានប្រព្រឹត្តទៅនៅលើគោលបំណងរបស់មហាក្សត្រ ដែលតែងតែថ្លឹងឱ្យមានតុល្យភាពរវាងឥទ្ធិពលសៀម និងវៀតណាម នៅក្នុងប្រទេស។ នៅឆ្នាំ១៨៤៧ ព្រះបាទអង្គឌួង ត្រូវបានអភិសេកជាមហាក្សត្រ នៃប្រទេសកម្ពុជា ដោយមានការចូលរួមរបស់អ្នកតំណាងប្រទេសសៀម និងវៀតណាម។ ដោយគ្មានគោលបំណង

នឹងបង្កើតចលនាប្រជាជនដ៏ធំដុំ ក្នុងកិច្ចការពារឯករាជ្យរបស់ប្រទេស មជ្ឈដ្ឋានដឹកនាំសក្តិភូមិប្រទេសកម្ពុជា បានខិតខំស្វែងរកអានុភាពក្រៅប្រទេសថ្មីណាមួយ ដែលអាចធ្វើជាជំហរដល់ការតស៊ូប្រឆាំងនឹងខ្មាំងនានា កិច្ចការបែបនេះធ្លាប់មានមកហើយទាក់ទងនឹងរដ្ឋភូមា ឈ្មោះ អាវ៉ា និងរាជាណាចក្រឡាវ ដែលបានប្រឆាំងនឹងប្រទេសសៀម។ អានុភាពបែបនេះ ព្រះបាទអង្គឌួង និងអស់មុខមន្ត្រីរបស់ព្រះអង្គមានក្តីសង្ឃឹមទៅលើប្រទេសអឺរ៉ុបទាំងឡាយ ដែលនៅពេលនោះ មិនទាន់ចាប់ផ្តើមអនុវត្តនយោបាយកាន់កាប់ទឹកដីនៅឥណ្ឌូចិន នៅឡើយ។ មជ្ឈដ្ឋានដឹកនាំនយោបាយប្រទេសកម្ពុជា មានក្តីសង្ឃឹមទៅលើជំនួយបែបនេះមួយបែប ដែលអធិរាជ យ៉ា ឡុង ធ្លាប់បានទទួលនៅប្រទេសវៀតណាម នាទសវត្សរ៍ទី៩ នៃសតវត្សរ៍ទី១៨ នៅពេលដែលអធិរាជ បានស្ថិតនៅក្នុងស្ថានភាពដ៏ធ្ងន់ធ្ងរចំពោះមុខកុបកម្មបះបោរកសិករ ដែលកើតមានឡើងនៅក្នុងប្រទេស។ ក្នុងគំនិតគិតដល់ការរៀបចំទំនាក់ទំនងនឹងប្រទេសអឺរ៉ុប នានា ព្រះបាទអង្គឌួង បានឈ្វេងយល់ដល់នយោបាយរបស់មហាក្សត្រសៀម នាម មង្ឃុត (រាមាទី៤) ដែលបានឡើងកាន់កាប់អំណាចនៅប្រទេសនេះ ក្រោយសម័យកាលនៃពិធីរៀបអភិសេកព្រះបាទអង្គឌួង ៤ឆ្នាំ ហើយចាប់ពីឆ្នាំ១៨៥៥ទៅ មហាក្សត្រអង្គនេះ ចាប់ផ្តើមអនុវត្តនយោបាយអឺរ៉ុបនិយម តាមកិច្ចការសម្រួលទំនាក់ទំនងនឹងប្រទេសមហាអំណាចនៅទ្វីបអឺរ៉ុប នានា។ ក៏ប៉ុន្តែ នៅក្នុងនយោបាយរៀបចំទំនាក់ទំនងជាមួយប្រទេសអឺរ៉ុបណាមួយបែបនេះ និងនៅក្នុងការយល់ឃើញដល់កិច្ចការចាំបាច់ក្នុងនយោបាយកែប្រែ មជ្ឈដ្ឋានដឹកនាំនយោបាយខ្មែរមិនបានដើរ

តាមមាគ៌ានយោបាយបែបអឺរ៉ុបនិយមទេ។ ព្រះបាទអង្គឌួង បាន ចាប់ផ្តើមធ្វើការកែប្រែក្នុងប្រទេស នូវស្ថាប័ននយោបាយមួយចំនួន ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងស្ថាប័ននយោបាយប្រទេសសៀម។ ក៏ប៉ុន្តែ ការកែប្រែនេះ មានចំណុចខុសគ្នាមួយដ៏សំខាន់ - គឺគ្មានឥទ្ធិពលអឺរ៉ុបនិយម (ជាពិសេស នៅក្នុងកិច្ចការកងទ័ព និងក្នុងស្ថាប័នដឹកនាំរដ្ឋថ្នាក់លើ)។ នៅក្នុងរឿងនេះកត្តាមួយដ៏សំខាន់ ដែលប្រទេសកម្ពុជា ខ្វះខាត គឺការពិសោធអនុវត្តដោយប្រទេសសៀម គឺជាការពិសោធប្រកបដោយភាពសម្បូរក្នុងទំនាក់ទំនងជាមួយនឹងប្រទេសនៅអឺរ៉ុប នានា។ នៅប្រទេសកម្ពុជា គ្មានអីវ៉ាន់ដ៏សំខាន់ៗណា ដែលអាចទាក់ទាញអារម្មណ៍របស់ពួកអឺរ៉ុប ហេតុនេះហើយ បានជាពួកនេះពុំមានបំណងធ្វើការទាក់ទងជាមួយនឹងប្រទេសកម្ពុជា ប៉ុន្មានទេ។ ក៏ប៉ុន្តែ ទោះបីដូចម្តេចក្តី ក៏ព្រះបាទអង្គឌួង បានធ្វើសេចក្តីអញ្ជើញដល់សង្ឃសាសនាកាតូលិកមួយក្រុម ឱ្យមកប្រទេសកម្ពុជា ដើម្បីធ្វើការចរចាជាមួយព្រះអង្គ។

ការកែប្រែទម្រង់ស្ថាប័ននយោបាយ ក្នុងប្រទេសនៅក្នុងសម័យព្រះបាទអង្គឌួង បានដើរតួដ៏សំខាន់ក្នុងការរីកចម្រើនរបស់ប្រទេស។ វិធានការដ៏សំខាន់ជាងគេ គឺការសំអាតជាមូលដ្ឋាននូវអង្គការរដ្ឋនានា ពីឥទ្ធិពលដ៏អាក្រក់របស់បណ្តានាហ្មឺនមន្ត្រីមួយចំនួនធំ ដែលបានលក់ខ្លួនឱ្យបរទេស ឬមួយដែលបានធ្វើជាភ្នាក់ងាររបស់របបសក្តិភូមិបរទេស។ អង្គការគ្រប់គ្រងរដ្ឋ ដែលរង្គោះរង្គើដោយចម្បាំងដ៏យូរអង្វែង និងដោយគ្មានមេកើយរឹងមាំត្រូវបានពង្រឹងឱ្យមានរដ្ឋអំណាចកណ្តាលឡើងវិញ។ កិច្ចការដ៏សំខាន់ទាំងអស់ របស់ប្រទេសត្រូវបានដោះស្រាយ ដោយការ

ចូលរួមផ្ទាល់របស់មហាក្សត្រ។ ឯកសារជាផ្លូវការរបស់រដ្ឋទាំងអស់ត្រូវមានត្រា ព្រមទាំងឡាយព្រះហស្តលេខារបស់ព្រះមហាក្សត្រ។ មានការឃោសនាបង្រួបបង្រួមឱ្យអ្នកស្រុកស្ថិតនៅជុំវិញមហាក្សត្រ ក្រោមពាក្យស្លោកពុទ្ធនិយមទាំងឡាយ។ ពុទ្ធសាសនានៅប្រទេសកម្ពុជា ក៏ដូចជានៅប្រទេសដទៃ នៅអាស៊ីអាគ្នេយ៍បានលូតលាស់ចម្រើន នៅសម័យកាលពាក់កណ្ដាលនៃសតវត្សរ៍ទី១៩។ ច្បាប់ព្រហ្មទណ្ឌប្រទេសកម្ពុជា ត្រូវបានកែប្រែរៀបចំឡើងវិញ។ ការប្រាក់ត្រូវបានបន្ថយ ហើយកម្រិតឱ្យយកការតែ៣០ភាគរយ ក្នុងមួយឆ្នាំ។ ប្រាក់បំណុលត្រូវបានបដិសេធចោល បើសិនជាគ្មានឯកសារជាលាយល័ក្ខណ៍អក្សរ បញ្ជាក់នូវការខ្ចីត្រឹមត្រូវ។ ពន្ធដារត្រូវបានបន្ថយ ហើយត្រូវបានទារទៅតាមពេលវេលាដ៏សមរម្យ ដើម្បីកុំឱ្យមានការរំខានដល់ការប្រកបការងាររបស់អ្នកស្រែចម្ការ។

ការប្រមូលផ្ដុំនៃរដ្ឋអំណាច និងការបង្កើនលទ្ធភាពក្នុងកិច្ចការពារប្រទេសមិនអាចប្រព្រឹត្តទៅបាន ប្រសិនបើគ្មានការកសាងបណ្ដាញផ្លូវថ្នល់ និងផ្លូវគមនាគមន៍ផ្សេងៗទៀតនៅក្នុងតំបន់ដ៏សំខាន់ៗ នៃប្រទេសកម្ពុជា។ ការកសាងផ្លូវគមនាគមន៍ទាំងនេះបានសម្រួលដល់ការទាក់ទង ខាងសេដ្ឋកិច្ចនៅក្នុងប្រទេស ហើយបានផ្ដល់ការងារដល់មនុស្សមួយចំនួនធំ ដែលគ្មានការងារធ្វើ បន្ទាប់ពីមានសង្គ្រាមដ៏យូរនៅក្នុងប្រទេស។ ផ្លូវថ្នល់ដ៏សំខាន់មួយត្រូវបានកសាងឡើង នៅចំពាក់កណ្ដាលប្រទេសឆ្ពោះទៅកាន់សមុទ្រ គឺផ្លូវថ្នល់ពីឧត្តុង្គ ឆ្ពោះទៅកំពង់ផែកំពត កាត់តាមទីក្រុងភ្នំពេញ។ ផ្លូវថ្នល់ទាំងមូលបានឆ្លងកាត់តាមទីកន្លែងដែលមានទំនប់ខ្ពស់រឹងមាំ មិនលិចទឹកនៅរដូវវស្សា

ហើយអាចធានាដល់ចរាចរពេញមួយឆ្នាំ។ នៅតាមផ្លូវថ្នល់នេះ មានស្ពានជាច្រើនកន្លែង មានសង់សាលាសំណាក់ និងស្រះសម្រាប់សត្វពាហនៈ។ ផ្លូវថ្នល់មួយទៀតដ៏រឹងមាំដូចជាផ្លូវថ្នល់ពីឧត្តុង្គ ទៅកំពត ដែរ គឺជាផ្លូវថ្នល់ ដែលតភ្ជាប់ពីទីក្រុងឧត្តុង្គទៅទីរួមខេត្តកំពង់ឆ្នាំង ដែលជាកំពង់ផែនៅមាត់បឹងទន្លេសាប។

នៅក្នុងការពង្រឹងស្ថានភាពនយោបាយ នៅក្នុងប្រទេស ព្រះសង្ឃព្រះពុទ្ធសាសនាបានបំពេញតួនាទីដ៏សំខាន់។ ព្រះសង្ឃបានទទួលការគាំទ្រដ៏ទូលំទូលាយខាងផ្លូវសម្ភារៈ ដោយហេតុថា ការគាំទ្រនេះត្រូវបានទុកជាការតបស្នងដល់គុណូបការៈរបស់គណៈសង្ឃ ដែលបានថ្លែងគាំទ្រដល់មហាក្សត្រក្នុងឱកាសឡើងសោយរាជសម្បត្តិ។ ការគាំទ្រដល់ពុទ្ធសាសនាបានផ្តល់លទ្ធភាពដល់លោកសង្ឃ និងពុទ្ធបរិស័ទទាំងឡាយឱ្យទទួលនូវពន្លឺនៃចំណេះវិជ្ជា និងផ្តល់លទ្ធភាពឱ្យមានការសំអាតដល់គណៈសង្ឃ ហើយមិនតែប៉ុណ្ណោះ ការនេះបានគាំទ្រដល់ព្រះបាទអង្គឌួង ឱ្យមានជ័យជម្នះលើពួកប្រឆាំងនឹងព្រះអង្គទៀតផង។

ការកែប្រែមួយដ៏សំខាន់ខាងសង្គមកិច្ច ដែលមានលក្ខណៈចម្រើននិយម គឺការផ្តល់លទ្ធភាពដល់ការរំដោះ និងការលោះខ្លួនពីស្ថានភាពទាសភាពឱ្យមកជាអ្នកជាវិញ គឺជាស្ថានភាពដែលជាជំងឺដ៏ធ្ងន់ធ្ងរនៅក្នុងសង្គមខ្មែរនាសតវត្សរ៍ទី១៩។ ការកែប្រែនេះបានចាប់ផ្តើមឡើងនៅក្នុងអំឡុងពេលមិនយូរប៉ុន្មានមុនពេលសោយទិវង្គតរបស់ព្រះបាទអង្គឌួង ហើយការកែប្រែក៏បានប្រព្រឹត្តទៅមុខទៀត បន្ទាប់ពីការសោយទិវង្គតរបស់ព្រះអង្គ។

ក្នុងការដោះស្រាយបញ្ហានយោបាយផ្ទៃក្នុង ប្រទេស ព្រះបាទអង្គឌួង បានអនុវត្តនយោបាយសន្តិភាពនិយមនៅក្នុង

ដែនដីខាងត្បូង នៃប្រទេស ដោយបានប្រមែប្រមូលបណ្ដាជនជាតិខ្មែរ ដែលរស់នៅតំបន់នានានៅទិសខាងកើតនៃព្រៃកដីកហាទៀនឱ្យមករស់នៅតំបន់កណ្ដាលនៃប្រទេសវិញ។

ស្ថានភាពដ៏តឹងតែងធ្ងន់ធ្ងរ បានស្ថិតនៅតទៅទៀតនៅតំបន់ភាគខាងលិចនៃប្រទេស។ អ្នកដឹកនាំប្រទេសសៀម ដែលជាប្រទេសប្រកបដោយអ្នកស្រែចម្ការតិចតួចនៅឡើយ មានបំណងចង់ទាក់ទាញដែនដីខ្មែរ ដែលប្រកបដោយបណ្ដាជនកុះករឱ្យស្ថិតនៅក្រោម នយោបាយកៀបសង្កត់ខាងពន្ធដាររបស់ខ្លួន។ ក្នុងរឿងនេះ យើងចង់និយាយអំពីទឹកដីខ្មែរពីបូរមបូរាណ ដែលជាជង្រុកស្រូវ នៃប្រទេសនៅទិសបស្ចិម ហើយដែលជាមជ្ឈមណ្ឌលប្រវត្តិសាស្ត្រ របស់រាជាណាចក្រខ្មែរ -គឺតំបន់អង្គរ។ ក្នុងការដាក់ឱ្យស្ថិតនៅក្រោមកិច្ចត្រួតត្រារបស់ខ្លួននៅដែនដីខេត្តខាងលិចចំនួនបី និងដែនដីខេត្តខាងជើងចំនួន៣នៃប្រទេសកម្ពុជា នៅទីនេះ ប្រទេសសៀម បានរក្សាទុកនូវរដ្ឋបាលខ្មែរទាំងអស់ រហូតដល់បណ្ដាចៅហ្វាយខេត្តទៀតផង។ ក្នុងការប៉ុនប៉ងពង្រឹងឥទ្ធិពលរបស់ខ្លួននៅក្នុងទឹកដី ដែលមានជនជាតិមិនជាជនជាតិសៀម និងក្នុងបំណងចង់បង្កើតរដ្ឋបាលទ្វេភាគីខ្មែរ-សៀម ពួកសក្ដិភូមិសៀម បានបង្កើតប្រព័ន្ធពន្ធដារដ៏ធូរថយដល់អ្នកស្រុកនៅទីនេះ ដោយគ្មានការសោកល្បងអនុវត្តនយោបាយលេបជាតិសាសន៍។ ជនជាតិខ្មែរមានឋានន្តរសក្តិខ្ពង់ខ្ពស់នៅក្នុងកងទ័ព ហើយអ្នកខ្លះបានចូលធ្វើជាកងកម្លាំងនៅក្នុងកងនាវាចរណ៍សៀម ទៀតផង។

ក្នុងការរៀបចំសង្គ្រាម ប្រឆាំងនឹងប្រទេសសៀម ព្រះបាទអង្គឌួង បានបង្គ្រាបដល់ពួកជនចូលដៃជាមួយសៀម នៅក្នុង

ប្រទេស ហើយព្រះអង្គបានបំពេញកិច្ចការនេះដោយជោគជ័យ។ នៅក្នុងរឿងនេះ គឺមានតែកុបកម្មបះបោររបស់ជនជាតិចាម ដែលត្រូវបានបង្ក្រាបដោយកងទ័ពមហាក្សត្រខ្មែរ។ ភារកិច្ចមួយដ៏សំខាន់ទៀត គឺការពង្រឹងកងកម្លាំងប្រដាប់អាវុធប្រទេសកម្ពុជា។ ក៏ប៉ុន្តែ ដើម្បីបំពេញភារកិច្ចនេះ ត្រូវតែរិះរកមធ្យោបាយដើម្បីរៀបចំសម្ពន្ធភាពជាមួយនឹងប្រទេសជាមហាអំណាច នៅតំបន់អឺរ៉ុប ណាមួយ។

# វគ្គទី២
# ប្រទេសកម្ពុជា នាសម័យអាណានិគមនិយម

## ជំពូកទី១
## អំពើជ្រៀតជ្រែកចូលប្រទេសកម្ពុជា ដោយប្រទេសបារាំង

ដូចគេបានដឹងច្បាស់មកហើយថា លក្ខណៈពិសេសមួយនៃមធ្យោបាយផលិតកម្មមូលធននិយម ស្ថិតនៅលើអំពើជិះជាន់អាណានិគមនិយម។ ជាមួយនឹងការរីកចម្រើន នៃទំនាក់ទំនងមូលធននិយមនៅក្នុងប្រទេសនានា នៃទ្វីបអឺរ៉ុប នៅសតវត្សរ៍ទី១៦ គឺមានការចាប់ផ្តើមនូវការបង្កើន នយោបាយវាតទីនិយមរបស់ប្រទេសនៅអឺរ៉ុបនានា ទៅលើប្រទេសទាំងឡាយនៅអាស៊ីអាគ្នេយ៍ ដែលនៅក្នុងនេះ មានទាំងប្រទេសនានានៅឥណ្ឌូចិន ទៀតផង។

ការសាកល្បងទី១របស់ប្រទេសបារាំង ដើម្បីជ្រៀតជ្រែកចូលក្នុងប្រទេសកម្ពុជា ស្ថិតនៅក្នុងមូលហេតុទូទៅនៃនយោបាយវាតទីនិយមរបស់ប្រទេសបារាំង នៅលើប្រទេសនានានៅអាស៊ីអាគ្នេយ៍ និងនៅចុងបូព៌ា។ នៅក្នុងការជ្រៀតជ្រែករបស់ប្រទេសបារាំង កាន់តែជ្រៅទៅក្នុងដែនដីឥណ្ឌូចិន ពួកអាណានិគមនិយមបារាំង បានចាប់ផ្តើមយកចិត្តទុកដាក់កាន់តែខ្លាំងទៅលើប្រទេសកម្ពុជា។

នៅក្នុងដំណាក់កាលទី១ នៃការជ្រៀតជ្រែកចូលប្រទេសកម្ពុជា (១៨៥២-១៨៥៨) រដ្ឋាភិបាលបារាំង ខិតខំប្រើប្រាស់

មធ្យោបាយទូត នៅក្នុងប្រទេសនេះ។ អ្នកតំណាងប្រទេសបារាំង ត្រូវបានបញ្ជូនទៅឱ្យចុះហត្ថលេខា លើកិច្ចព្រមព្រៀងពាណិជ្ជកម្ម មួយជាមួយប្រទេសកម្ពុជា ក៏ប៉ុន្តែ នៅពេលនោះ ប្រទេសសៀម បានថ្លែងប្រឆាំងដាច់អហំការ ហើយពិធីចុះហត្ថលេខានេះ ក៏ត្រូវ ផ្អាកទៅវិញ។ នៅទីបំផុត នៅពេលដែលអ្នកតំណាងប្រទេស បារាំង បានស្នើគំរោងកិច្ចព្រមព្រៀង ដែលមានលក្ខណៈជាកិច្ច ព្រមព្រៀងពាណិជ្ជកម្មសុទ្ធសាធ កិច្ចព្រមព្រៀងនេះ មិនស្រប តាមគោលបំណងរបស់មហាក្សត្រអង្គឌួង ដែលចាប់ផ្តើមមាន ការទាក់ទងជាមួយនឹងរដ្ឋាភិបាលបារាំង។ រដ្ឋាភិបាលប្រទេស កម្ពុជា មានគោលបំណងប្រើប្រាស់បទពិសោធន៍របស់អធិរាជ វៀតណាម នាម យ៉ា - ឡុង បានសេចក្តីថា មានបំណងទទួល គ្រឿងអាវុធ និងអ្នកបង្ហាត់បង្រៀនស៊ីឈ្នួលខាងយោធា ហើយ ចុះហត្ថលេខា លើកិច្ចព្រមព្រៀងស្តីអំពីសម្ពន្ធភាពជាមួយប្រទេស បារាំង។ នៅពេលដែលទទួលព័ត៌មានច្បាស់ថា ប្រទេសបារាំង មិនព្រមផ្តល់ជំនួយបែបនេះ មហាក្សត្រអង្គឌួង ក៏មិនយល់ព្រម ចុះហត្ថលេខាបែបនេះឡើយ។

ដំណាក់កាលជាបន្ទាប់ នៃការជ្រៀងជ្រែកចូលក្នុងប្រទេស កម្ពុជា ដោយប្រទេសបារាំង (១៨៥៨-១៨៦២) មានការទាក់ទង ជិតស្និទ្ធទៅនឹងការបញ្ជូនបេសកកម្មកងទ័ព របស់ចក្រភពបារាំង ទី២ ទៅប្រទេសវៀតណាមខាងត្បូង។ នៅទីនេះ ស្ថានភាពភូមិ សាស្ត្ររបស់ប្រទេសកម្ពុជា បានទាក់ទាញអារម្មណ៍របស់ពួក អាណានិគមបារាំង ដោយហេតុថា អំពើជ្រៀតជ្រែកក្រសោប យកប្រទេសកម្ពុជា នឹងអាចពង្រីកអត្ថន័យខាងសេដ្ឋកិច្ចទៅ លើទឹកដីនៅវៀតណាមខាងត្បូង កាន់កាប់ដោយប្រទេសបារាំង

ហើយអាចបង្កើតជាមូលដ្ឋាន សម្រាប់ការជ្រៀតជ្រែកយ៉ាងជ្រៅ ទៅខាងទិសឧត្តរ និងបស្ចិម នៃដែនដីឥណ្ឌូចិន។មិនតែប៉ុណ្ណោះ ការនេះអាចបង្កើតបានរបាំងមួយ រវាងដែនដីកាន់កាប់ដោយពួកបារាំង នៅឥណ្ឌូចិន និងដែនដីដែលប្រទេសអង់គ្លេស មានបំណងនឹងកាន់កាប់។ បន្ទាប់ពីពេលដែលទីក្រុងព្រៃនគរ បានធ្លាក់ទៅក្នុងកណ្ដាប់ដៃបារាំង នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៨៥៩ មហាក្សត្រអង្គឌួង ក៏បានប៉ុនប៉ងប្រើប្រាស់អន្តរាគមន៍បារាំង នៅឥណ្ឌូចិន ដើម្បីសម្រេចគោលដៅម្យ៉ាង - គឺការវាយយកដែនដីកូសាំងស៊ីន មកវិញ។ ក្រោមកលល្បិចនៃការកើតឧបទ្វវហេតុតាមព្រំប្រទល់ជាមួយពួកវៀតណាមខាងជើង នៅជិតទីក្រុងចូវដុក មហាក្សត្រអង្គឌួង បានឱ្យបញ្ជាដល់អង្គភាពកងទ័ពរបស់ព្រះអង្គវាយចូលទៅក្នុងទឹកដីកូសាំងស៊ីន។ក្នុងការបញ្ជាកងទ័ពឱ្យធ្វើសកម្មភាពយោធាបែបនេះ ព្រះអង្គបានគន់គូរថា នឹងអាចធ្វើការចរចាជាមួយនឹងមេបញ្ជាការបារាំង ដើម្បីពិភាក្សាទាមទារសិទ្ធិរបស់ប្រទេសកម្ពុជា នៅលើដែនដីនេះ។ ក៏ប៉ុន្តែ តែការចូលទិវង្គតរបស់មហាក្សត្រអង្គឌួង នាខែតុលា ឆ្នាំ១៨៦០ បានរំខានមិនឱ្យគំនិតរបស់មហាក្សត្រសម្រេចគោលដៅបាន។ បន្ទាប់ពីទទួលដំណឹងអំពីការចូលទិវង្គតរបស់មហាក្សត្រ កងទ័ពខ្មែរក៏បានចាកចេញពីដែនដីកូសាំងស៊ីន។

ភារកិច្ចសំខាន់នៅក្នុងនយោបាយបារាំង នាឆ្នាំ១៨៦១-១៨៦៣ គឺខិតខំទប់ទល់នឹងបំណងរបស់ប្រទេសសៀម ដើម្បីកុំឱ្យប្រទេសនេះក្រសោបចាប់យកប្រទេសកម្ពុជា ដែលនឹងអាចបង្កើតឱ្យមានគ្រោះថ្នាក់ដ៏ធំធុំ ដោយហេតុថា នៅពីខាងក្រោយខ្នងប្រទេសសៀម គឺមានប្រទេសអង់គ្លេស ដែលនឹង

អាចមានលទ្ធភាព ចូលមកដល់ព្រំប្រទល់ប្រទេសវៀតណាម ខាងត្បូង។

នៅពេលជាមួយគ្នានោះ ដោយបេសកកម្មកងទ័ពបារាំង នៅវៀតណាមខាងត្បូង ស្ថិតនៅក្នុងស្ថានភាពធ្ងន់ធ្ងរ កិច្ចការដ៏សំខាន់របស់នយោបាយការទូតបារាំង គឺខិតខំយ៉ាងណា បើយ៉ាងអន់ណាស់ ក៏ឱ្យមានការធានារ៉ាប់រងដល់អព្យាក្រឹតភាពនៃប្រទេសកម្ពុជា នៅក្នុងរឿងនេះ។ នៅពេលនោះ ព្រះបាទនរោត្តម (១៨៦០ - ១៩០៥) ជាបុត្ររបស់មហាក្សត្រអង្គឌួង នឹងឡើងគ្រងរាជ្យនៅប្រទេសកម្ពុជា។

ស្របតាមកិច្ចព្រមព្រៀងរវាងប្រទេសសៀម និងប្រទេសកម្ពុជា បេក្ខភាពរបស់ព្រះបាទនរោត្តម ឱ្យឡើងសោយរាជ្យលើប្រទេសកម្ពុជា ត្រូវបានស្នើឡើងដើម្បីទទួលសេចក្តីយល់ព្រមពីសំណាក់នៃមហាក្សត្រប្រទេសសៀម។ នៅពេលជាមួយគ្នានោះ មហាក្សត្រប្រទេសសៀម បានបញ្ជូនប្អូនរបស់ព្រះបាទនរោត្តម នាម ស៊ីវត្ថា មកប្រទេសកម្ពុជា ដែរ។ ព្រះអង្គម្ចាស់ ស៊ីវត្ថា បាន គង់នៅទីក្រុងបាងកក នៅក្នុងឋានៈជាជនដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់មហាក្សត្រ ដែលមានបំណងនឹងប្រើប្រាស់ស្ថានភាពព្រះអង្គម្ចាស់ស៊ីវត្ថា ជាល្បិចកលនយោបាយ ដើម្បីកៀបសង្កត់ដល់មហាក្សត្រថ្មី នៃប្រទេសកម្ពុជា។ ព្រះអង្គម្ចាស់ស៊ីវត្ថា ក៏មានគោលបំណងចង់ឡើងសោយរាជ្យដែរ ហើយបានធ្វើសកម្មភាពប្រឆាំងនឹងមហាក្សត្រ នរោត្តម។

នេះគឺជាស្ថានភាពនៃប្រទេសកម្ពុជា នៅពេលដែលទីបញ្ជាការបារាំង បានចាប់ផ្តើមរៀបចំការទាក់ទងជាមួយមហាក្សត្រនរោត្តម។ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ១៨៦១ តាងនាមរដ្ឋាភិបាល

បារាំង គេបានផ្ញើសារពិសេសមួយមកថ្វាយមហាក្សត្រនរោត្តម ដែលនៅក្នុងនេះមានបញ្ជាក់អំពី “ សន្តានចិត្ត នៃមេត្រីភាព ”។ ក្នុងការឆ្លើយតបនឹងសកម្មភាពបារាំង បែបនេះ មហាក្សត្រនរោត្តម បានឱ្យបង្កើតស្ថានទូតមួយយ៉ាងធំ នៅទីក្រុងព្រៃនគរ ហើយបានបញ្ជាក់ដល់រដ្ឋាភិបាលបារាំង ដើម្បីឱ្យយល់នូវមេត្រីភាពរបស់មហាក្សត្រ។ ព្រះបាទនរោត្តម មានបំណងចង់ទទួលការគាំទ្រពីសំណាក់ នៃប្រទេសបារាំង។ មិនតែប៉ុណ្ណោះ នៅពេលនោះ ភាពទន់ខ្សោយ នៃប្រទេសវៀតណាម បានបង្កើនកម្លាំងចិត្តដល់ប្រទេសសៀម ក្នុងបំណងក្រសោបយកប្រទេសកម្ពុជា ឱ្យស្ថិតនៅក្នុងរង្វង់ឥទ្ធិពលរបស់ខ្លួន។ នៅក្នុងស្ថានភាពបែបនេះ មហាក្សត្រនរោត្តម មានបំណងពឹងផ្អែកទៅលើប្រទេសបារាំង ដោយព្រះអង្គយល់ថា ជាប្រទេសមិនសូវមានគ្រោះថ្នាក់ប៉ុន្មានដល់ប្រទេសកម្ពុជា។

នៅប្រទេសបារាំង អ្នកប្រកាន់នយោបាយ កាន់កាប់ទឹកដីអាណានិគម បានរៀបចំខឿននយោបាយរបស់ខ្លួនយ៉ាងរឹងមាំ ដើម្បីពង្រីកការកាន់កាប់ទឹកដីនៅឥណ្ឌូចិន ដែលនៅក្នុងនេះ មានទាំងប្រទេសកម្ពុជា ផងដែរ។ នៅខែសីហា និងខែតុលា ឆ្នាំ១៨៦១ កប៉ាល់ចម្បាំងបារាំង បានបើកបរចូលមកតាមទន្លេមេកុង ហាក់ដូចជាក្នុងគោលបំណង “ ផ្តល់កិច្ចការពារ ” ដល់បរិស័ទកាន់សាសនាយេស៊ូគ្រិស្ត។ នៅខែកញ្ញា ឆ្នាំ១៨៦២ ទេសាភិបាលជាន់ខ្ពស់បារាំង នៅវៀតណាមខាងត្បូង គឺឧត្តមនាវី នាម បូណារ បានធ្វើដំណើរមកកាន់ប្រទេសកម្ពុជា ហើយនៅពេលត្រឡប់ទៅវិញ លោកបានរៀបចំបញ្ជូនបេសកកម្មឃោជាមួយមក

ប្រទេសកម្ពុជា ដើម្បីធ្វើការស្រាវជ្រាវអំពីទន្លេមេកុង និងបឹងទន្លេសាប។

សម័យកាលនៃការរៀបចំសកម្មភាពដ៏ សកម្មរបស់ប្រទេសបារាំង ដើម្បីចូលជ្រៀតជ្រែកក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមឡើងបន្ទាប់ពីពេលបញ្ឈប់ប្រតិបត្តិការយោធា នៅប្រទេសវៀតណាម។ អ្នកផ្តើមគំនិត នៃការផ្សងព្រេងនៅប្រទេសកម្ពុជា នៅពេលនោះ គឺទេសាភិបាលជាន់ខ្ពស់បារាំង នៅវៀតណាមខាងត្បូង នាមឡាប្រ៉ាំងឌីយេរ បានទទួលឯកសិទ្ធិបរិបូណ៌ក្នុងសកម្មភាពរបស់ខ្លួនទាក់ទងនឹងប្រទេសកម្ពុជា ដោយហេតុថា លោកគិតថានឹងទទួលការគាំទ្រពីក្រុមអ្នកនយោបាយនៅទីក្រុងប៉ារីស ដែលមានឥទ្ធិពល ហើយដែលប្រកាន់នយោបាយអាណានិគមនិយមនៅឥណ្ឌូចិន។

នៅក្នុងសារបង្គាប់បញ្ជាផ្សេងៗ ដល់លោកឡាប្រ៉ាំងឌីយេរ រដ្ឋមន្ត្រីបារាំងខាងនាវាចរណ៍យោធា បានកត់សម្គាល់ជាពិសេសនូវសារៈសំខាន់ នៃស្ថានភាពភូមិសាស្ត្រ នៃប្រទេសកម្ពុជា ក្នុងកិច្ចការពារទឹកដីអាណានិគមនិយមបារាំង នៅវៀតណាមខាងត្បូង (ល្អិកណាមានសង្គ្រាមជាមួយមហាអំណាចណាមួយរបស់អឺរ៉ុប)។ នៅក្នុងសារបង្គាប់បញ្ជាទាំងនេះ មានសេចក្តីបញ្ជាក់អំពីការហាមឃាត់ មិនឱ្យ “ ចាត់វិធានការណាថ្មីទៀត ” ក៏ប៉ុន្តែ នៅពេលជាមួយគ្នា សារបង្គាប់បញ្ជាបានទូន្មាន “ ឱ្យធ្វើការទាក់ទងស្ទាបស្ទង់ដល់មហាក្សត្រកម្ពុជា ដោយការបញ្ជូននាយទាហាននានា ដែលអាចធ្វើដំណើរទៅប្រទេសកម្ពុជា ដើម្បីឱ្យស្គាល់ច្បាស់ដល់ភោគផលនៃប្រទេសនេះ...”។ ក្នុងការរៀបចំការកាន់កាប់ប្រទេសកម្ពុជា លោកឡាប្រ៉ាំងឌីយេរ បានបញ្ជូនភ្នាក់ងារ

នានារបស់ខ្លួនឱ្យធ្វើដំណើរតាមទន្លេមេកុង ក្នុងគោលបំណង ស្វែងរកព័ត៌មានទាក់ទងនឹងស្ថានភាពប្រទេសកម្ពុជា។ ដូច្នេះ ហើយ នៅខែមេសា ឆ្នាំ១៨៦៣ នាយទាហានបារាំង ឈ្មោះ ប្រឺយេរដឺលីល បានមកដល់ទីក្រុងឧត្តុង្គ ហើយបានចរចាជាមួយ មហាក្សត្រនរោត្តម ស្តីអំពីបញ្ហានៃការរៀបចំអាណាព្យាបាល បារាំង នៅប្រទេសកម្ពុជា។

បន្ទាប់ពីការចុះហត្ថលេខា លើសន្ធិសញ្ញាស្តីអំពីសន្តិភាព ជាមួយប្រទេសវៀតណាម (នាឆ្នាំ១៨៦២) ប្រទេសបារាំង បានទទួលលទ្ធភាព ក្នុងការចាប់ផ្តើមដូចពួកអាណានិគមហៅថា “ ជ្រៀតចូលដោយសន្តិភាព ” ទៅក្នុងប្រទេសកម្ពុជា។ តមក នាយទាហានបារាំងម្នាក់ នាម ឌូដាដឺឡាហ្គ្រេ ត្រូវបានបញ្ជូន មកប្រទេសកម្ពុជា ដើម្បីធ្វើជាអ្នកតំណាងប្រទេសបារាំង ក្នុង វិស័យនយោបាយ យោធា និងពាណិជ្ជកម្ម ដើម្បីសម្រេចគោល បំណងរបស់បារាំង ក្នុងការបង្កើតអំណាចអាណាព្យាបាលបារាំង នៅប្រទេសកម្ពុជា។ នៅពេលនោះ នៅក្នុងបរមរាជវាំង របស់ មហាក្សត្រនរោត្តម មានឥទ្ធិពលជាខ្លាំងពីសំណាក់មជ្ឈដ្ឋាន នៃអ្នកប្រឆាំង និងការស្ថិតនៅក្រោមអនិស្សរភាពរបស់ប្រទេស សៀម ទៅអនាគតទៀត។ ដោយមានការគាំទ្រពីសំណាក់ នៃ ព្រះសង្ឃសាសនាកាតូលិក ដែលបានផ្តល់ឥទ្ធិពលយ៉ាងខ្លាំង របស់ខ្លួននៅបរមរាជវាំងកម្ពុជា អ្នកតំណាងអភិជន នៃបរមរាជ វាំងមួយភាគ ព្រមទាំងអស់មុខមន្ត្រីជាន់ខ្ពស់នានា បានគាំទ្រ ដល់ឥរិយាបថរបស់ប្រទេសបារាំង នៅប្រទេសកម្ពុជា។

លោកឌូដាដឺឡាហ្គ្រេ បានឆ្លៀតឱកាសប្រើប្រាស់នូវរាជ បំណងរបស់មហាក្សត្រនរោត្តម ដែលចង់ដកខ្លួនចេញពីស្ថានភាព

ក្រោមអាណាព្យាបាលរបស់ប្រទេសសៀម ដែលរំខាន ហើយនឹងអាចផ្ដល់ការគំរាមកំហែងដ៏ច្បាស់លាស់ ដល់ឯករាជភាពនៃប្រទេសកម្ពុជា។ លោកឌូដាជឺឡាហ្គ្រេ បានខិតខំពន្យល់មហាក្សត្រនរោត្ដម ឱ្យយល់ថា ព្រះអង្គនឹងអាចការពាររាជបល្ល័ង្កបាន ដោយសារតែកិច្ចគាំទ្ររបស់ប្រទេសបារាំង។ មហាក្សត្របានយល់ព្រមឱ្យលោកឡាហ្គ្រង់ឌីយេរ មកធ្វើទស្សនកិច្ចនៅប្រទេសកម្ពុជា ហើយយល់ព្រមចុះហត្ថលេខាលើសន្ធិសញ្ញាស្ដីអំពីអាណាព្យាបាលបារាំង នៅប្រទេសកម្ពុជា។ នៅខែសីហា លោកឡាហ្គ្រង់ឌីយេរ បានមកដល់ប្រទេសកម្ពុជា ហើយបន្ទាប់ពីការចរចានានា នៅថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ មានការរៀបចំពិធីចុះហត្ថលេខា លើសន្ធិសញ្ញាសំងាត់បារាំង-កម្ពុជា ស្ដីអំពីអាណាព្យាបាលបារាំង។ នៅពេលជាបន្ទាប់មក កាលណាប្រទេសសៀម បានជ្រួតជ្រាបអំពីរឿងនេះ ប្រទេសសៀម បានធ្វើសេចក្ដីថ្លែងការណ៍ប្រឆាំងដល់រដ្ឋាភិបាលបារាំង។ ចំពោះរឿងនេះ លោកឡាហ្គ្រង់ឌីយេរ បានបដិសេធចំពោះការចោទប្រកាន់ដល់ការបង្ខិតបង្ខំគ្រប់បែបយ៉ាង ហើយនៅពេលនោះមហាក្សត្រនរោត្ដម បានធ្វើការពន្យល់ដល់ឥរិយាបថរបស់ព្រះអង្គក្នុងការចុះហត្ថលេខាដោយការបង្ខិតបង្ខំ។ គេអាចដឹងបានថាជនទាំងឡាយ ដែលបានជ្រួតជ្រាបចំពោះការរៀបចំពិធីចុះហត្ថលេខាថ្មីនេះ យល់ថា ពួកបារាំង មិនគ្រាន់តែបង្ខិតបង្ខំមហាក្សត្រនរោត្ដម ប៉ុណ្ណោះទេ ប៉ុន្តែ ថែមទាំងបន្លំដល់ព្រះអង្គទៀតផង។

សន្ធិសញ្ញាមាន១៩ មាត្រា។ មាត្រាទី១ បានបញ្ជាក់ថា អធិរាជបារាំង ព្រមព្រៀងដាក់ប្រទេសកម្ពុជា ឱ្យស្ថិតនៅក្រោម

អាណាព្យាបាល នៃប្រទេសបារាំង ហើយប្រទេសបារាំង ទទួលសិទ្ធិតែងតាំងកុងស៊ុលរបស់ខ្លួន ដែលត្រូវទទួលកិត្តិយសស្មើនឹងមុខមន្ត្រីដ៏សំខាន់បំផុត នៃប្រទេសកម្ពុជា។ មាត្រាទី៤ បានបញ្ជាក់ថា គ្មានអ្នកតំណាង នៃរដ្ឋាភិបាលបរទេសណាមួយ (នៅក្នុងនេះ មានទាំងអ្នកតំណាងប្រទេសអង់គ្លេស និងប្រទេសសៀម) អាចមានសិទ្ធិស្ថិតនៅលើទឹកដីប្រទេសកម្ពុជា បានឡើយ ល្គឹកណា គ្មានសេចក្តីអនុញ្ញាតជាមុនពីទេសាភិបាលជាន់ខ្ពស់បារាំង នៅវៀតណាមខាងត្បូង និងពីរដ្ឋាភិបាលប្រទេសកម្ពុជា។ សន្ធិសញ្ញាបានដកសិទ្ធិ មិនឱ្យរដ្ឋាភិបាលកម្ពុជា អាចអនុវត្តនយោបាយពាណិជ្ជកម្មឯករាជ្យបាន ដោយហេតុថា កំពង់ផែទាំងអស់នៃប្រទេស ត្រូវបើកចំហសម្រាប់កប៉ាល់ពាណិជ្ជកម្មបារាំង ហើយពលរដ្ឋបារាំង អាចទទួលលទ្ធភាពធ្វើចលនាដោយសេរី និងធ្វើពាណិជ្ជកម្ម ដោយគ្មានការហាមឃាត់ (មាត្រាទី១០)។

មាត្រាទី១៥ បានសរសេរបញ្ជាក់អំពីសេរីភាពនៅក្នុងសកម្មភាពរបស់សង្ឃកាតូលិក ហើយបានបញ្ជាក់អំពីការផ្តល់សិទ្ធិដល់អ្នកតំណាងនៃសាសនានេះ ក្នុងការកសាងវិហារ អគារផ្សព្វផ្សាយសាសនា សាលារៀន។ល។ ប្រទេសបារាំង បានទទួលកាតព្វកិច្ចគាំទ្រដល់ប្រទេសកម្ពុជា ក្នុងការធានាដល់សណ្តាប់ធ្នាប់ ស្ថិរភាព និងកិច្ចការពារប្រទេសប្រឆាំងនឹងខ្មាំងពីខាងក្រៅ។ រដ្ឋាភិបាលបារាំង បានទទួលសេចក្តីអនុញ្ញាតពីរដ្ឋាភិបាលកម្ពុជា ក្នុងការកសាងចំណតកប៉ាល់ និងឃ្លាំងស្តុកធ្យូងថ្មនៅកំពង់ផែ សម្រាប់សម្រួលដល់ចរាចរណ៍កប៉ាល់បារាំង

(មាត្រាទី១៦)។ រដ្ឋាភិបាលកម្ពុជា ផ្តល់សិទ្ធិដល់ប្រទេសបារាំង ឱ្យប្រើប្រាស់ឈើធ្វើសំណង់កប៉ាល់ (មាត្រាទី១៧-១៨)។

សន្ធិសញ្ញាមិនស្មើភាពគ្នានេះ បានផ្តល់ផលចំណេញខាងសម្ភារៈដល់ប្រទេសបារាំង ហើយមិនតែប៉ុណ្ណោះ សន្ធិសញ្ញានេះបានទៅជាឯកសារតាមផ្លូវច្បាប់ដ៏សំខាន់ ដែលបានប្រគល់សិទ្ធិដល់ប្រទេសបារាំង ឱ្យពង្រឹងស្ថានភាពរបស់ខ្លួនកាន់តែខ្លាំងនៅប្រទេសកម្ពុជា។

នៅទីក្រុងប៉ារីស មជ្ឈដ្ឋានរដ្ឋាភិបាលបានជ្រួតជ្រាបអំពីពិធីចុះហត្ថលេខាលើសន្ធិសញ្ញា ហើយបានបញ្ចេញនូវប្រតិកម្មបញ្ជាក់ដោយមតិផ្សេងៗ ពុំស្របគ្នា។ ហេតុនេះហើយ បានជារដ្ឋមន្ត្រីក្រសួងការបរទេសបារាំង បានភិតភ័យថា “ការផ្សងព្រេងនៅប្រទេសកម្ពុជា” នឹងបង្កើតឱ្យមានស្ថានភាពស្មុគស្មាញក្នុងទំនាក់ទំនងជាមួយប្រទេសអង់គ្លេស។ សេចក្តីថ្លែងការណ៍ចំពោះទឹកចិត្តព្រួយបារម្ភបែបនេះបានទៅជាការពិត ដោយហេតុថាសារព័ត៌មានអង់គ្លេស បានចាប់ផ្តើមចុះផ្សាយឃោសនាប្រឆាំងនឹងបារាំង ដ៏ខ្លាំងក្លាបំផុត ទាក់ទងនឹងរឿងសន្ធិសញ្ញាបារាំង-កម្ពុជា។ ជាពិសេសសារព័ត៌មានអង់គ្លេស បានបង្ហាញឱ្យឃើញនូវកំហឹងរបស់ខ្លួនចំពោះមាត្រានានានៃសន្ធិសញ្ញា ដែលបានប្រគល់សិទ្ធិឱ្យប្រទេសបារាំង ទៅជាមហាអំណាចដ៏សំខាន់ជាងគេនៅប្រទេសកម្ពុជា។ ផ្ទុយពីនេះ ពួកអ្នកកាន់នយោបាយអាណានិគមនិយម កាន់កាប់ទឹកដីនៅក្នុងរដ្ឋាភិបាល នៃប្រទេសបារាំង បានខិតខំពន្យល់ដល់អធិរាជ ណាប៉ូឡេអុងទី៣ ឱ្យយល់ព្រមធ្វើសច្ចាប័នលើសន្ធិសញ្ញា។

រដ្ឋាភិបាលប្រទេសសៀម បានខិតខំប្រើប្រាស់ឥរិយាបថ វេរា ដែលកើតមានឡើងក្នុងមជ្ឈដ្ឋានរដ្ឋាភិបាលបារាំង ដែលទាក់ទងទៅនឹងការធ្វើសច្ចាប័នលើសន្ធិសញ្ញា ជាមួយប្រទេសកម្ពុជា សម្រាប់ជាប្រយោជន៍របស់ខ្លួន។ ពួកមន្ត្រី នៃប្រទេសសៀម ដែលបម្រើការនៅបរមរាជវាំងរបស់មហាក្សត្រនរោត្តម នៅពេលសន្ទនាជាមួយមហាក្សត្រ បានខំបញ្ជាក់ដល់មហាក្សត្រឱ្យមានជំនឿដល់ឥរិយាបថ មិនច្បាស់លាស់របស់ប្រទេសបារាំង ហើយបានធ្វើឱ្យព្រះអង្គមានជំនឿថា រដ្ឋាភិបាលបារាំង គឺជាសម្ពន្ធមិត្ត ដែលគេមិនអាចមានសេចក្តីសង្ឃឹមបាន ដោយហេតុថា មិនយូរមិនឆាប់ សម្ពន្ធមិត្តនេះនឹងចាកចេញពីវៀតណាមខាងត្បូង។ ពួកមន្ត្រីសៀមទាំងនេះ បានថ្លែងគំរាមកំហែងដល់មហាក្សត្រថា ប្រទេសសៀម នឹងអាចតែងតាំងបងប្អូនប្រុសរបស់មហាក្សត្រនរោត្តម ឱ្យឡើងសោយរាជ្យលើរាជបល្ល័ង្ក នៅប្រទេសកម្ពុជា។ ពាក្យគំរាមកំហែងទាំងនេះ ធ្វើឱ្យមហាក្សត្រមានវិតក្កក្នុងហឫទ័យជាខ្លាំង ពីព្រោះមកុដរាជ និងគ្រឿងឥស្សរិយយសមហាក្សត្រកម្ពុជា ត្រូវបានថែរក្សាទុកនៅទីក្រុងបាងកក ហើយបញ្ហាស្តីអំពីពិធីរៀបចំអភិសេក និងអំពីច្បាប់បញ្ជាក់អំពីការសោយរាជ្យពេញច្បាប់ នៃមហាក្សត្រកម្ពុជា មានទាក់ទងជាប់ទៅនឹងប្រទេសសៀម។

ហេតុនេះហើយ បានជានៅថ្ងៃទី១ ខែធ្នូ ឆ្នាំ១៨៦៣ ប្រទេសកម្ពុជា បានធ្វើកិច្ចព្រមព្រៀងមួយដ៏សម្ងាត់ ដែលមាន ១១មាត្រា ជាមួយនឹងប្រទេសសៀម។ នៅក្នុងកិច្ចព្រមព្រៀងនេះ ព្រះបាទនរោត្តម ត្រូវបានទទួលស្គាល់ថា ជាប្រមុខរដ្ឋពេញច្បាប់ នៃប្រទេសកម្ពុជា ហើយរាជាណាចក្រ ត្រូវស្ថិតនៅក្នុងស្ថាន

ភាពអនិស្សរភាពនឹងប្រទេសសៀម។ កិច្ចព្រមព្រៀងនេះបាន បញ្ជាក់ថា ប្រមុខរដ្ឋកម្ពុជា អាចតាំងឡើងបានតែដោយសារការ អនុញ្ញាតពីទីក្រុងបាងកក។ តាមសេចក្ដីនៃកិច្ចព្រមព្រៀង មហាក្សត្រនរោត្តម បានបាត់បង់សិទ្ធិទាំងអស់លើខេត្តបាត់ដំបង និងអង្គរ ហើយប្រទេសសៀម បានរក្សាសិទ្ធិរបស់ខ្លួនក្នុងការ ក្រសោបយកខេត្តពោធិ៍សាត់ និងកំពង់ស្ពឺ ទៀត ប្រសិនបើ " ប្រមុខរដ្ឋកម្ពុជា មានការប្រព្រឹត្តមិនល្អ " ចំពោះប្រទេសសៀម (មាត្រា១១) ។

រដ្ឋាភិបាលបារាំង បានជ្រួតជ្រាបអំពីកិច្ចព្រមព្រៀងរវាង ប្រទេសសៀម និងប្រទេសកម្ពុជា តែនៅខែកញ្ញា ឆ្នាំ១៨៦៤ តាមសារព័ត៌មានចុះផ្សាយជាភាសាអង់គ្លេស នៅទីក្រុងសិង្ហបុរី។

បន្ទាប់ពីពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ជាមួយ ប្រទេសសៀម ការចរចាគ្នាស្ដីអំពីពិធីរៀបចំអភិសេកព្រះបាទន រោត្តម បានប្រព្រឹត្តនៅពេលខាងមុខទៀត។ រដ្ឋាភិបាលប្រទេស សៀម ដោយចង់ពង្រីកនូវឥទ្ធិពលរបស់ខ្លួននៅប្រទេសកម្ពុជា មានបំណងចង់ឱ្យព្រះបាទនរោត្តម ទទួលមកុដរាជ្យផ្ទាល់ពី ហត្ថារបស់មហាក្សត្រសៀម ដោយគ្មានការចូលរួមពីសំណាក់ នៃអ្នកតំណាងប្រទេសបារាំង។ លោកឌូដាជីឡាហ្គ្រេ ដែល តំណាងឱ្យមជ្ឈដ្ឋានអ្នកនយោបាយ អាណានិគមនិយមបារាំង បានខិតខំប្រឹងប្រែងរំខានដល់ពិធីអភិសេកបែបនេះ។ នៅក្នុង លក្ខខណ្ឌដែលមហាក្សត្រ ពុំព្រមយល់ស្របតាមសេចក្ដីទូន្មាន របស់ខ្លួន លោកឌូដាជីឡាហ្គ្រេ នឹងអាចរៀបចំធ្វើរដ្ឋប្រហារណា មួយ ដែលខ្លួនបានរៀបចំឡើងដោយសម្ងាត់។

ស្ថានភាពក្នុងប្រទេស មានលក្ខណៈល្អសម្រាប់សេចក្តីសម្រេចដល់គំនិតបែបនេះ។ នៅពេលនោះ នៅប្រទេសកម្ពុជាមានបក្ខពួកពីរយ៉ាង។ បក្ខពួកមួយ បានធ្វើសកម្មភាពប្រឆាំងនឹងពួកបារាំង ដើម្បីភ្ជាប់ប្រទេសខ្លួនជាមួយប្រទេសសៀម ហើយអ្នកដឹកនាំបក្ខពួកនេះ គឺជាចៅហ្វាយនៃខេត្តកំពង់ធំ និងខេត្តបាត់ដំបង។ ក្រុមពួកមួយទៀត ដែលមានឥទ្ធិពលខ្លាំងស្ថិតនៅក្រោមការដឹកនាំរបស់ក្រឡាហោម ដែលជាមហាមន្ត្រីមួយរូបទទួលបន្ទុកខាងកិច្ចការនាវាចរណ៍យោធា កសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្ម ដែលមាននិន្នាការស្របតាមប្រទេសបារាំង។ ក្រុមពួកនីមួយៗមានបំណងបញ្ចុះបញ្ចូលមកខាងខ្លួននូវប្រជាជនមូលដ្ឋានទាំងឡាយ ដែលមានកំហឹងនឹងរបបជិះជាន់សក្តិភូមិ និងស្ថានភាពតឹងតែងជាមួយបារាំង និងប្រទេសសៀម ដែលខិតខំផ្តល់ឥទ្ធិពលរបស់ខ្លួនមកលើប្រទេសកម្ពុជា ហើយដែលជាប្រភពធ្វើឱ្យអ្នកស្រុកសំដែងទឹកចិត្តប្រឆាំងនឹងប្រទេសសៀម ក៏ដូចជាប្រឆាំងនឹងប្រទេសបារាំង ដែរ។

នៅថ្ងៃទី៣ ខែមេសា ឆ្នាំ១៨៦៤ បក្ខពួកស្របតាមនិន្នាការប្រទេសសៀម បានរៀបចំដំណើររបស់មហាក្សត្រនរោត្តម ទៅកាន់កំពត ហើយដែលចេញពីទីនេះទៅ ព្រះអង្គត្រូវយាងទៅទីក្រុងបាងកក ក្រោមកិច្ចការពាររបស់កងទ័ពសៀម ក៏ប៉ុន្តែលោក ឌូដាដឺឡាហ្គ្រេ ជាមួយនឹងក្រុមកងទ័ពជើងទឹកមួយក្រុមបានមកឡោមព័ទ្ធរាជវាំងមហាក្សត្រ។ នៅពីមុខរាជវាំង គេបានដោតទង់ជ័យបារាំង ហើយលោក ដាដឺឡាហ្គ្រេ បានថ្លែងដល់នាហ្មឺនរបស់មហាក្សត្រនរោត្តម ថា នេះជានិមិត្តរូបបញ្ជាក់ថា ប្រទេសបារាំង ពុំព្រមបោះបង់ចោលនូវ “សិទ្ធិរបស់ខ្លួនឡើយ

ហើយនឹងប្រើប្រាស់មធ្យោបាយគ្រប់បែបយ៉ាង ដើម្បីធានារ៉ាប់រងដល់ស្ថិរភាពនៃប្រទេសកម្ពុជា ”។ សេចក្តីព្រួយបារម្ភពិតប្រាកដនៅក្នុងការបាត់បង់រាជបល្ល័ង្ក បានទាក់ទាញឱ្យព្រះបាទ នរោត្តមបែរថយក្រោយវិញ។ បន្ទាប់ពីពេលនោះមក មានការបញ្ជូនកងកម្លាំង នៃកងទ័ពបារាំង ពីទីក្រុងព្រៃនគរ ហើយនៅក្រោមបញ្ជាការរបស់លោកឌូដាដឺឡាហ្រេ្ក មានទាំងកប៉ាលចម្បាំងតូចៗចំនួន៥គ្រឿង និងទាហានជើងទឹក ១០០នាក់ ដែលបានឡើងកាន់កាប់ទីក្រុងឧត្តុង្គ និងទីក្រុងភ្នំពេញ។ នៅពេលនោះ កងទ័ពសៀមដែលស្ថិតនៅលើទឹកដីប្រទេសកម្ពុជា ពុំបានធ្វើសកម្មភាពអ្វីប្រឆាំងនឹងកងទ័ពបារាំង ឡើយ។

រដ្ឋាភិបាលប្រទេសបារាំង សម័យចក្រភពទី២ បានធ្វើសច្ចាប័នលើសន្ធិសញ្ញាជាមួយប្រទេសកម្ពុជា ស្តីអំពីអាណាព្យាបាលបារាំង ហើយនៅថ្ងៃទី៨ ខែមេសា ឆ្នាំ១៨៦៤ លោកឡាហ្រ្កង់ឌីយេរ បានថ្វាយព័ត៌មាននេះដល់មហាក្សត្រនរោត្តមហើយតមក ពិធីប្តូរឯកសារសច្ចាប័នបានប្រព្រឹត្តទៅថ្ងៃទី១២ ខែមេសា ឆ្នាំ១៨៦៤។ នៅពេលជាមួយគ្នា ដោយមានការសម្របសម្រួលជាមួយប្រទេសសៀម ដែនដីមួយភាគនៃប្រទេសកម្ពុជា ដែលសម្បូរដោយផលដំណាំស្រូវ មានខេត្តបាត់ដំបងនិងអង្គរ ក៏ត្រូវបានបាត់បង់ ហើយរដ្ឋាភិបាលបារាំង បានធ្វើកិច្ចព្រមព្រៀងជាមួយប្រទេសសៀម ស្តីអំពីពិធីអភិសេកមហាក្សត្រនរោត្តម ដោយមានការចូលរួមពីសំណាក់អ្នកតំណាងប្រទេសបារាំង និងប្រទេសសៀម។ ពិធីអភិសេកស្តេច បានប្រព្រឹត្តទៅនៅថ្ងៃទី៣ ខែកក្កដា នៅទីក្រុងឧត្តុង្គ។ នៅថ្ងៃទី១៩ ខែកក្កដា កងកម្លាំងកងទ័ពសៀម បានចាកចេញអស់ពីដែនដីរបស់កម្ពុជា។

ចាប់តាំងពីពេលនោះមក ពួកអាណានិគមនិយមបារាំង បានធ្វើការសាកល្បងដ៏មុឹងម៉ាត់ ដើម្បីធ្វើការពិភាក្សាជាមួយប្រទេសសៀម ស្តីអំពីការទទួលស្គាល់ជាចុងក្រោយបង្អស់ដល់ "សិទ្ធិ"របស់បារាំង នៅប្រទេសកម្ពុជា។ ការចរចាគ្នាដ៏ស្មុគស្មាញបានប្រព្រឹត្តទៅ ហើយបានចប់សព្វគ្រប់នៅឆ្នាំ១៨៦៧។

រដ្ឋាភិបាលប្រទេសបារាំង សុខចិត្តធ្វើការសម្របសម្រួលជាមួយប្រទេសសៀម ក្នុងការចុះហត្ថលេខាលើសន្ធិសញ្ញាឆ្នាំ១៨៦៧ ហើយតាមសេចក្តីនៃសន្ធិសញ្ញានេះ លក្ខខណ្ឌទាំងឡាយនៃកិច្ចព្រមព្រៀង រវាងប្រទេសកម្ពុជា និងប្រទេសសៀម ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ១៨៦៣ ត្រូវបានបដិសេធចោល។ ប្រទេសសៀមយល់ព្រមទទួលស្គាល់ជាផ្លូវការដល់ " សិទ្ធិ " របស់ប្រទេសបារាំង ចំពោះរបបអាណាព្យាបាលលើប្រទេសកម្ពុជា ហើយក្នុងការតបស្នងចំពោះការទទួលស្គាល់នេះ ប្រទេសសៀម បានទទួលខេត្តបាត់ដំបង និងអង្គរ។ តាមការពិត ប្រទេសកម្ពុជាត្រូវបានបែងចែករវាងប្រទេសបារាំង និងប្រទេសសៀម។

នៅថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៨៧០ នៅទីក្រុងព្រៃនគរ មានពិធីចុះហត្ថលេខាបំពេញលើមាត្រាបន្ថែម នៃសន្ធិសញ្ញា ដោយបានប្រកាស អំពីអព្យាក្រឹតភាព នៃទឹកដីបឹងទន្លេសាប ដែលជាទឹកដី ប្រកបដោយអត្ថន័យសេដ្ឋកិច្ចដ៏សំខាន់សម្រាប់ប្រទេសកម្ពុជា ក៏ដូចជា សម្រាប់ប្រទេសសៀម។

សន្ធិសញ្ញានៃឆ្នាំ១៨៦៧ មិនបានធ្វើឱ្យមជ្ឈដ្ឋាននយោបាយអាណានិគមនិយមបារាំង នៅទីក្រុងប៉ារីស ព្រមព្រៀងតាមបានឡើយ។ អ្នកតំណាងទាំងឡាយនៃមជ្ឈដ្ឋាននេះ ជះឥទ្ធិពលកាន់តែខ្លាំងឡើងដល់រដ្ឋាភិបាលបារាំង ហើយបាន

ទាមទារដល់រដ្ឋាភិបាល ឱ្យខិតខំដំណើរការយ៉ាងណាដើម្បីឱ្យប្រទេសសៀម ព្រមព្រៀងប្រគល់ខេត្តបាត់ដំបង និងអង្គរ មកប្រទេសកម្ពុជា វិញ ដោយហេតុថា ការបាត់បង់ខេត្តទាំងនេះអាចបណ្តាលឱ្យខូចខាតដល់ការដឹកនាំទំនិញពីទីដីទំនាប នៃទន្លេមេកុង ទៅកាន់ទីក្រុងព្រៃនគរ។

# ជំពូកទី២

## រាជានិយមខ្មែរ និងរបបគ្រប់គ្រងអាណានិគមបារាំង

រដ្ឋអំណាចបារាំង បានចាប់ផ្តើមរៀបចំរបបគ្រប់គ្រងអាណានិគមនៅប្រទេសកម្ពុជា នៅពេលដ៏យូរ បន្ទាប់ពីពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីអំពីអាណាព្យាបាលបារាំង។ នៅថ្ងៃទី១៥ ខែមករា ឆ្នាំ១៨៧៧ ក្រោមឥទ្ធិពលបារាំង និងក្រោមសេចក្តីបង្ខិតបង្ខំរបស់អ្នកតំណាងបារាំង មហាក្សត្រនរោត្តមបានចុះហត្ថលេខាលើក្រឹត្យមួយ ដែលនៅក្នុងនេះ មានការកម្រិតដល់អំណាចមហាក្សត្រ និងរាជវង្សានុវង្ស គឺជាក្រឹត្យដែលកម្រិតដល់របបសក្តិភូមិចាស់ របស់ប្រទេសឱ្យមានលក្ខណៈស្របខ្លះៗទៅតាមសេចក្តីទាមទារនៃសម័យទំនើប។ តាមសេចក្តីនៃក្រឹត្យនេះ សមាជិកទាំងអស់នៃរាជវង្សានុវង្សត្រូវបានរំដោះពីមុខតំណែងរដ្ឋាភិបាលគ្រប់បែបយ៉ាង ក៏ប៉ុន្តែ អាចរក្សាទុកនូវឋានន្តរស័ក្តិរបស់ខ្លួន។ រដ្ឋផ្តល់ប្រាក់បៀវត្សរ៍សម្រាប់ការចិញ្ចឹមជីវភាព។ នៅក្នុងក្រឹត្យនេះមានសេចក្តីគូសបញ្ជាក់ថា ពន្ធអាករថ្មីៗទាំងអស់នឹងអនុវត្តជាធរមាននៅក្នុងប្រទេស ក្រោមសេចក្តីព្រមព្រៀងនៃក្រុមប្រឹក្សាព្រះរាជាណាចក្រ។ មានការបង្កើតច្បាប់មួយស្តីអំពីការបង់ប្រាក់ជំនួសការបំពេញ “ ងារ ” ជាសាធារណៈដោយឥតយកប្រាក់ឈ្នួលចំនួន៩០ថ្ងៃ ក្នុងមួយឆ្នាំ។ មានការបដិសេធចោលនូវការលក់ដូរផ្តាច់មុខគ្រប់យ៉ាង របស់រាជានិយមលើកលែងតែការលក់ដូរផ្តាច់មុខនូវគ្រឿងអាភៀន និងស្រា ស។

នៅរដ្ឋធានីមានការបង្កើតស្ថាប័នខាងតុលាការជាន់ខ្ពស់ សាលាវិនិច្ឆ័យ ដែលនៅពេលជាមួយគ្នាអាចបំពេញមុខងារជាសាលាឧទ្ធរណ៍បាន ល្អិកណាសាលាកាត់ក្ដីថ្នាក់ក្រោម មានសាលាលហុជាដើម មិនអាចធ្វើសេចក្ដីសម្រេចបាន។ មុខងាររបស់ចៅក្រម និងមន្ត្រីតុលាការនានាត្រូវបានបញ្ជាក់ និងកម្រិតយ៉ាងច្បាស់លាស់។

ស្របតាមសេចក្ដី នៃក្រឹត្យចុះហត្ថលេខាដោយព្រះមហាក្សត្រ នៅក្នុងប្រទេស មានការបដិសេធចោលនូវទាសភាពបន្តពូជពីឪពុក ទៅកូន។ មនុស្សម្នាក់ៗដែលបានស្ថិតនៅក្នុងស្ថានភាពទាសភាព ដោយសារជាប់បំណុលប្រាក់ អាចយកប្រាក់មកសងដើម្បីរំដោះខ្លួនវិញ ឬអាចទទួលសិទ្ធិដើម្បីការរំដោះខ្លួន ដោយសារការបំពេញការងាររបស់ខ្លួន សម្រាប់ជាប្រយោជន៍នៃម្ចាស់ប្រាក់។ លទ្ធភាពក្នុងការទទួលយកទាសៈថ្មីទាក់ទងទៅនឹងលទ្ធភាពនៃការទិញ ដើម្បីរំដោះទាសៈនេះវិញ។ មិនតែប៉ុណ្ណោះ ក្រឹត្យនេះបានគូសបញ្ជាក់ជាពិសេសថា “ជនជាតិ” ឬជនជាតិបរទេសណាមួយដែលបានធ្លាក់ខ្លួនទៅក្នុងស្ថានភាពទាសភាព ក៏អាចទិញរំដោះខ្លួនវិញបានដែរ។ ក្រឹត្យក៏បានចែងបញ្ជាក់អំពីសិទ្ធិ នៃគ្រួសារ ក្នុងការទិញរំដោះខ្លួនដល់សមាជិកគ្រួសារណា ដែលបានធ្លាក់ខ្លួនទៅក្នុងស្ថានភាពទាសភាពដោយសារបំណុលប្រាក់។

ក៏ប៉ុន្តែ អត្ថន័យនៃក្រឹត្យនេះបានស្ថិតនៅតែលើក្រដាសអស់រយៈពេលដ៏យូរ ដោយហេតុថា ក្រឹត្យរបស់មហាក្សត្របានជួបប្រទះនឹងការប្រឆាំងដ៏ខ្លាំង ពីសំណាក់ពួកអភិជននៃបរម

រាជវាំង និងពីអស់មុខមន្ត្រី នៃរាជវង្សានុវង្សដែលបានយល់ថា ជាការប៉ះពាល់មួយដល់ប្រាក់ចំណូល និងសិទ្ធិអំណាចរបស់ខ្លួន។

តាំងពីសម័យនោះមក ការតស៊ូសម្ងាត់ដ៏យូរអង្វែងដ៏ច្បាស់លាស់របស់វណ្ណៈអភិជនសក្តិភូមិ ដើម្បីរក្សាទុកនូវរាជានិយមកម្ពុជា ដូចជា ស្ថាប័ននយោបាយ ដោយហេតុថា គឺនៅក្នុងក្របខ័ណ្ឌ នៃការរក្សារាជានិយមបែបនេះហើយ ដែលស្រទាប់នៃពពួកជនទាំងនេះ អាចរក្សាទុកនូវបុព្វសិទ្ធិរបស់ខ្លួនទាំងអស់ដោយជោគជ័យ។

ម្យ៉ាងវិញទៀត របបគ្រប់គ្រងអាណានិគមនិយមបានខិតខំបន្តការសាកល្បង របស់ខ្លួនដើម្បីកែប្រែរាជានិយមកម្ពុជាឱ្យមាន “ លក្ខណៈទំនើប ” ដោយហេតុថា រាជានិយមនេះពុំមានស្ថានភាពសមស្របតាមប្រព័ន្ធ នៃទំនាក់ទំនងខាងសង្គមរបស់វណ្ណៈគហបតី ដែលនាំចូលមកដោយសារពួកអាណានិគមនិយមឡើយ។ ក៏ប៉ុន្តែ ដើម្បីបំពេញកិច្ចការនេះ ពួកអាណានិគមនិយម បានធ្វើជំហានទៅមុខដោយសេចក្តីប្រុងប្រយ័ត្នតាមមាគ៌ានៃការចេញប្រកាសរាជក្រឹត្យ និងដោយ “ ការទិញទឹកចិត្ត ” ដល់មហាក្សត្រ និងដល់មន្ត្រីសក្តិភូមិជាន់ខ្ពស់មួយចំពូក។

រដ្ឋាភិបាលបារាំង បានបំពេញសកម្មភាពបែបនេះ តាមរយៈរបបគ្រប់គ្រងរបស់ខ្លួននៅឥណ្ឌូចិន ហើយបានបន្តរៀបចំសណ្តាប់ធ្នាប់ថ្មីបន្តិចម្តងៗនៅប្រទេសកម្ពុជា។ នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ១៨៨២ មហាក្សត្រនរោត្តម បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ដែលបញ្ជាក់ថា ការដឹកនាំអាវុធចូលមកប្រទេសកម្ពុជា អាចប្រព្រឹត្តទៅបានតែតាមទីក្រុងព្រៃនគរ។

នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៨៨២ មានការចេញផ្សាយរាជក្រឹត្យព្រះបាទនរោត្តម ដែលនៅក្នុងនេះ មានសរសេរបញ្ជាក់ថា ជនជាតិអឺរ៉ុប ដែលរស់នៅប្រទេសកម្ពុជា នឹងអាចទទួលការពិន័យទោសបាន តែតាមអង្គការតុលាការរបស់អាណាព្យាបាលបារាំងដែលស្ថិតនៅរដ្ឋធានី នៃទឹកដីចំណុះបារាំង កូសាំងស៊ីន គឺក្រុងព្រៃនគរ។

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៨៨៤ ក្រោមការគំរាមកំហែងដោយអាវុធ មហាក្សត្រកម្ពុជា ត្រូវបានបង្ខំចិត្តចុះហត្ថលេខាជាមួយប្រទេសបារាំង លើកិច្ចព្រមព្រៀងមួយថ្មីទៀត ដែលបានធ្វើឱ្យប្រទេសបាត់បង់នូវអធិបតេយ្យភាពរបស់ខ្លួន។ តាមការនិទាននៃជនដែលបានឃើញនឹងភ្នែកជាក់ មានការបញ្ជាក់ថា នៅថ្ងៃទី១៧ កក្កដា ១៨៨៤ នៅវេលាម៉ោង១០ ទាហានមួយក្រុមប្រកបដោយគ្រឿងអាវុធ បានឡោមព័ទ្ធព្រះបរមរាជវាំង។ ទេសាភិបាលបារាំង នាម ថុមសុន និងមនុស្សកំដររបស់ខ្លួន បានទាមទារសុំឱ្យមហាក្សត្រនរោត្តម ទទួលខ្លួន។ នៅពេលនោះមហាក្សត្រកំពុងផ្ទុំនៅឡើយ ហើយគ្មាននរណាហ៊ានដាស់ព្រះអង្គពីរាជដំណេកឡើយ។ បរិវាររបស់មហាក្សត្រភ័យរំជើបរំជួលដោយហេតុថា ថុមសុន ចង់ប្រឡោតខឹង។ នៅទីបំផុត មហាក្សត្របានភ្ញាក់ពីផ្ទុំដោយសារសំឡេងអ៊ូអរនៅខាងក្រៅ។ គេបានអានគំរោងអត្ថបទនៃកិច្ចព្រមព្រៀងថ្មីឱ្យមហាក្សត្រស្តាប់។

មហាក្សត្រនរោត្តម បានសុំឱ្យគេទុកព្រះអង្គនៅស្ងៀមមួយកន្លែង។ ប៉ុន្តែ គេបានពន្យល់ព្រះអង្គថា ចំពោះភាគីបារាំងល្មគេអាចយល់ព្រមធ្វើសេចក្តីស្នើដល់ឧបរាជ ដែលប្រុងប្រៀបខ្លួនកាន់តំណែងជំនួសព្រះមហាក្សត្រ។ នៅពេលជាបន្តបន្ទាប់ ពួក

រដ្ឋមន្ត្រី ដែលធ្លាប់មានភក្តីភាពដល់មហាក្សត្រពីពេលមុន ភ័យខ្លាចបាត់បង់តំណែងរបស់ខ្លួន ហើយបានចាប់ផ្តើមគោរពដ៏ក្លៀវក្លាដល់មហាឧបរាជ...។ មហាក្សត្រនរោត្តម ស្ថិតនៅឯកោ ហើយបានសាកល្បងប្រឆាំងនឹងពួកបារាំង។ ថុមសុន ក៏បានបើកបង្អួច ដែលមានទន្លេនៅពីមុខ ហើយបានធ្វើសេចក្តីថ្លែងទៅកាន់មហាក្សត្រថា៖ “ សូមព្រះអង្គជ្រើសរើសរវាងការយល់ព្រម និងការដកខ្លួនចេញពីរាជបល្ល័ង្ក។ សូមព្រះអង្គសម្រេចចិត្ត... ”។

មហាក្សត្រទ្រង់បានឆ្លើយតបទៅវិញថា៖ “ ចុះបើយើងមិនព្រមចុះហត្ថលេខា ហើយមិនព្រមចុះចេញពីរាជបល្ល័ង្ក ”។ នៅពេលនោះ លោកថុមសុន បានចង្អុលបង្ហាញកប៉ាល់ចម្បាំងដែលបោះយុថ្កានៅមាត់ទន្លេខាងមុខព្រះបរមរាជវាំង ហើយបានទាំងឆ្លើយតបទៅព្រះអង្គវិញថា៖ សូមព្រះអង្គទ្រង់ទតទៅផ្សែងដែលកំពុងតែហុយឆ្លោមពីបំពង់ផ្សែងកប៉ាល់ “ អាឡូត ”។ ប្រសិនបើព្រះអង្គមិនព្រមចុះហត្ថលខានោះ កប៉ាល់នេះនឹងបើកបនាំព្រះអង្គទៅទីឆ្ងាយ។ មហាក្សតបានសួរថា៖ “ តើអ្នកចង់ធ្វើអ្វីដល់យើងនៅក្នុងកប៉ាល់? ” ។ លោកថុមសុន បានឆ្លើយតបទៅព្រះអង្គវិញថា៖ “ នេះជារឿងអាថ៌កំបាំងរបស់ទូលបង្គំ ” ។ ព្រះបាទនរោត្តម បានឱនក្បាលចុះ ហើយយល់ព្រមចុះហត្ថលេខាដោយក្រៀមក្រំបំផុត។

តាមកិច្ចព្រមពៀងនាឆ្នាំ១៨៨៤ មហាក្សត្របានយល់ព្រមអនុម័តលើការកែប្រែទាំងឡាយ ដែលរដ្ឋាភិបាលបារាំងយល់ថា ជាការចាំបាច់នឹងអនុវត្តនៅប្រទេសកម្ពុជា។ បណ្តាមុខមន្ត្រីកម្ពុជាទាំងអស់ ដែលត្រួតត្រាលើខេត្តនានាត្រូវនៅ

ក្រោមការត្រួតពិនិត្យផ្ទាល់របស់ពួកទេសាភិបាលបារាំង (តាមមាត្រាទី១, មាត្រាទី៣) ហើយចំនួនខេត្តទាំងឡាយដែលពីមុនមានដល់៥៧ខេត្ត ត្រូវបង្រួមឱ្យមកនៅត្រឹមចំនួន៨ខេត្ត។ ខេត្តទាំងនេះ ត្រូវបានបែងចែកជាស្រុកនានា ហើយបណ្តាមុខមន្ត្រីនៅស្រុកនឹងអាចកាន់តំណែងបាន ទាល់តែមានការទទួលការយល់ព្រមពីទេសាភិបាលបារាំង។ នៅក្រោមសម័យកាលនៃមហាក្សត្រនរោត្តម ប្រទេសបារាំង មិនមែនមានអ្នកតំណាងទូតរបស់ខ្លួននៅប្រទេសកម្ពុជា ដូចពេលមុនទេ ប៉ុន្តែ មានទេសាភិបាលជាន់ខ្ពស់ របស់ខ្លួនមួយរូបដែលស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់ទេសាភិបាលជាន់ខ្ពស់ នៅកូសាំងស៊ីន។ ទេសាភិបាលជាន់ខ្ពស់ មានទំនាក់ទំនងដោយសេរីជាមួយនឹងមហាក្សត (តាមមាត្រាទី៥)។ សម្រាប់មហាក្សត្រមានការផ្តល់ប្រាក់បៀវត្សរ៍ ចំនួន ៣០០ពាន់រៀល (១រៀល= ៤,៥៥ហ្វ្រង់)។ សម្រាប់រាជបុត្រាបុត្រី និងរាជវង្សានុវង្សមានការផ្តល់ប្រាក់បៀវត្សរ៍ចំនួន ២៥០ពាន់រៀល (តាមមាត្រាទី៧)។

ការតែងតាំងប្រព័ន្ធពន្ធដារ ពន្ធគយ ពន្ធអាករមិនចំពោះមុខ ការដឹកនាំការងារសាធារណៈទាំងអស់បានធ្លាក់ទៅក្នុងអំណាចរដ្ឋបាលរបស់បារាំង ទាំងមូល (តាមមាត្រាទី៣)។ ទេសាភិបាល ឬបុគ្គលដែលបំពេញតំណែងជាទេសាភិបាលត្រូវបានតែងតាំងឡើងដោយ រដ្ឋការអាណានិគមឱ្យទៅបំពេញមុខងារតាមខេត្តនានានៅក្នុងប្រទេស (តាមមាត្រាទី៤) ទេសាភិបាលទាំងអស់ ស្ថិតនៅក្រោមរបបត្រួតត្រារបស់ទេសាភិបាលជាន់ខ្ពស់បារាំង នៅភ្នំពេញ ។ ចាប់ពីពេលនោះមករដ្ឋធានីភ្នំពេញ បានស្ថិតនៅក្រោមរបបត្រួតត្រារបស់ទេសាភិបាល

ជាន់ខ្ពស់បារាំង ឬរបស់អនុទេសាភិបាលជាន់ខ្ពស់។ ទេសាភិបាលជាន់ខ្ពស់មានមុខងារជាប្រធានក្រុមប្រឹក្សារដ្ឋជានី ដែលមានសមាសភាពដូចតទៅ គឺបារាំង ៦រូប (ជាមន្ត្រី ឬជាអ្នកជំនួញ) ចាត់តាំងដោយទេសាភិបាលជាន់ខ្ពស់កូសាំងស៊ីន, ខ្មែរ៣រូប, ជនជាតិវៀតណាម ១រូប, ចិន២រូប និងចាម ១រូប ។ អ្នកទាំងអស់នេះត្រូវបានចាត់តាំង ដោយមហាក្សត្រខ្មែរ ដោយមានសេចក្តីយល់ព្រមពីទេសាភិបាលជាន់ខ្ពស់កូសាំងស៊ីន។ ទាសភាពត្រូវបានបដិសេធចោលតាមច្បាប់។ ដីធ្លីត្រូវបានប្រកាសជារបស់ដែលគេអាចលក់ទិញបាន។ នៅក្នុងប្រទេស គេបានចាប់ផ្តើមរៀបចំតុលាការកាត់ទោសតាមរបៀបបារាំង។

ចលនាបះបោរជនជាតិខ្មែរ ដែលមានឈ្មោះថា៖ "ចលនាការពារមហាក្សត" មិនបានជួយដល់ប្រទេសឱ្យចៀសផុតពីការអនុវត្តរបបគ្រប់គ្រងរដ្ឋបាលបារាំង បានឡើយ ហើយដោយសារចលនាទាំងនេះ ពួកអាណានិគមបារាំង សុខចិត្តចុះហត្ថលេខាលើសេចក្តីព្រមព្រៀងមួយជាមួយព្រះមហាក្សត្រនរោត្តម នៅខែមិថុនា ឆ្នាំ១៨៨៦។ ក្នុងសេចក្តីព្រមព្រៀងនេះ ពួកអាណានិគមព្រមប្រគល់មុខតំណែងខាងរដ្ឋបាលនានាដល់មហាក្សត្រ និងអស់មុខមន្ត្រីវិញ។ ចាប់តាំងពីថ្ងៃទី១ ខែមករា ឆ្នាំ១៨៨៧ កិច្ចការរដ្ឋបាលនៃប្រទេសកម្ពុជា ត្រូវបានរៀបចំឡើងវិញនៅក្នុងប្រទេស។ ពួកអាណានិគមបានរក្សាទុកនូវទេសាភិបាលរបស់ខ្លួននៅក្នុងខេត្តកំពត។ ចំពោះកិច្ចការត្រួតពិនិត្យវិស័យនានាគឺមានតែក្រសួងគយ និងការធ្វើជំនួញអាភៀនទេ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ពួកបារាំង ប៉ុន្តែ នេះគ្រាន់តែជាកលល្បិចបណ្តោះអាសន្នរបស់ពួកអាណានិគមតែប៉ុណ្ណោះ។

នាសម័យកាលឆ្នាំ១៨៨៨-១៨៩៦ របបគ្រប់គ្រងអាណានិគមបារាំង បានធ្វើកិច្ចព្រមព្រៀងមួយចំនួន ជាមួយព្រះមហាក្សត្រ នរោត្តម (តាមបែបបទជារាជក្រឹត្យ) ដែលនៅក្នុងនេះមានការបន្ទូរបន្ថយបន្តិចម្តងៗ ដល់ការទាមទាររបស់បារាំង ហើយដែលនៅពេលមុនមហាក្សត្រ ពុំបានព្រមព្រៀងម្តងណាឡើយ គឺនៅឆ្នាំ១៨៨៤។ នៅថ្ងៃទី៣ ខែសីហា ឆ្នាំ១៨៩០ ជាឧទាហរណ៍ រដ្ឋការបារាំង បានទិញសិទ្ធិផ្តាច់មុខដល់រាជបល្ល័ង្កកម្ពុជា នូវសិទ្ធិក្នុងការយកពន្ធអាករលើអង្ករនាំចេញពីប្រទេស (ដោយហេតុថា ពាណិជ្ជកម្មក្រៅប្រទេសស្ថិតនៅជាសិទ្ធិផ្តាច់មុខរបស់រាជបល្ល័ង្ក) ដោយបង់ប្រាក់ចំណូលដល់រាជរតនាគារ។ នៅឆ្នាំ១៨៩១ ពន្ធអាករទាំងអស់ត្រូវបានដាក់ឱ្យនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋការបារាំង ទាំងអស់ ហើយក្នុងការតបសងដល់កិច្ចការនេះ រដ្ឋការបារាំង បានផ្តល់មហាក្សត្រខ្មែរនូវបៀវត្សរ៍ជាប្រាក់បរិបូរ សម្រាប់ការផ្គត់ផ្គង់រាជវង្សានុវង្ស និងសេចក្តីត្រូវការដទៃទៀត។ នៅថ្ងៃទី១ ខែមករា ឆ្នាំ១៨៩២ គេបានបង្កើតក្រសួងហិរញ្ញវត្ថុ ដែលស្ថិតនៅក្រោមការត្រួតពិនិត្យរបស់បារាំង។ ពន្ធអាករទាំងអស់ដែលត្រូវប្រមូលបាន នៅក្នុងរាជាណាចក្រត្រូវបានបញ្ជូនបញ្ចូលមកក្នុងក្រសួងហិរញ្ញវត្ថុនេះ។ តាមការបង្កើតក្រសួងនេះ ប្រាក់ពន្ធអាករ ទាំងពន្ធដារចំពោះមុខ និងមិនចំពោះមុខទាំងអស់ ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់រដ្ឋបាលបារាំង។

នៅពេលជាមួយគ្នានោះ នៅក្នុងប្រទេស ប្រព័ន្ធរដ្ឋបាលបារាំង ត្រូវបានពង្រឹងកាន់តែមាំឡើង។ ប្រសិនបើឆ្នាំ១៨៨៩

នៅប្រទេសកម្ពុជា មានទេសាភិបាលបារាំង តែបួនរូបនោះ នៅឆ្នាំ១៨៩៤ ទេសាភិបាលបារាំង នឹងកើនឡើងដល់ចំនួនដប់រូប។

បន្ទាប់ពីពេលចេញប្រកាស បង្កើតសហភាពឥណ្ឌូចិន (ថ្ងៃទី១៧ តុលា ឆ្នាំ១៨៨៧ ) ប្រទេសបារាំង ចង់បង្រួបបង្រួមប្រទេសកម្ពុជា ជាមួយនឹងដែនដីអាណានិគមរបស់ខ្លួនដទៃទៀតនៅឥណ្ឌូចិន តាមរយៈប្រព័ន្ធសហភាពឥណ្ឌូចិន។

នាឆ្នាំ១៨៩៧, ១៨៩៨, ១៩០១ ក្រោមការកៀបសង្កត់របស់រដ្ឋបាលបារាំង មហាក្សត្រប្រទេសកម្ពុជា បានចេញផ្សាយព្រះរាជក្រឹត្យថ្មីៗស្តីអំពី ការអនុវត្តជាធរមាននូវការរៀបចំអំណាចនានាខាងរដ្ឋបាល ខាងអង្គការតុលាការ ខាងក្រសួងប៉ូលិសខាងក្រសួងពន្ធដារ ព្រមទាំងព្រះរាជក្រឹត្យស្តីអំពីទាសភាព។ ព្រះរាជក្រឹត្យទាំងនេះ បានពង្រីក និងពង្រឹងនូវស្ថានភាពព្រះរាជក្រឹត្យទាំងឡាយនាឆ្នាំ១៨៧៧ ព្រមទាំងកិច្ចព្រមព្រៀងនៅឆ្នាំ១៨៨៤។

រាជក្រឹត្យចេញផ្សាយដោយមហាក្សត្រនរោត្តម ដែលមានអត្ថន័យសំខាន់ជាងគេ គឺរាជក្រឹត្យចុះថ្ងៃទី១១ កក្កដា ឆ្នាំ១៨៩៧។ តាមសេចក្តីនៃរាជក្រឹត្យនេះ ដែលត្រូវបានផ្សាយចេញតាមការទាមទារ របស់រដ្ឋបាលនៃសហភាពឥណ្ឌូចិនមហាក្សត្រនរោត្តម បានព្រមព្រៀងមិនចូលរួមផ្ទាល់ក្នុងកិច្ចការត្រួតត្រារដ្ឋ ដោយយោងទៅតាមគោលការណ៍ដែលបញ្ជាក់ថា៖ “ មហាក្សត្រសោយរាជ្យ ប៉ុន្តែ មិនមែនត្រួតត្រាទេ ”។

រដ្ឋបាលអាណានិគមបារាំង បានចាត់វិធានការជាបន្តបន្ទាប់ដើម្បីបដិសេធបុព្វសិទ្ធិខ្លះ របស់ពួកអភិជនសក្តិភូមិដែលបានរំខានដល់ ការអនុវត្តកិច្ចត្រួតត្រាអាណានិគមនៅក្នុង

ប្រទេស ប៉ុន្តែ ការនេះ មិនមែនបានសេចក្តីថា ពួកបារាំង ចាត់វិធានការដើម្បីបន្ថយដល់ប្រាក់ចំណូល របស់ពួកអភិជនទាំងនេះទេ។ នៅថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩០៤ មានការចេញច្បាប់ (ច្បាប់នេះមិនបានអនុវត្តទូទៅ ហើយស្ថិតនៅតែលើក្រដាស) ស្តីអំពីការបដិសេធរបៀប “ កម្លាំង ” (បំពេញពលកម្មសម្រាប់មេកើយ) ដែលមានអនុវត្តនៅប្រទេសកម្ពុជា។ ច្បាប់ចេញផ្សាយនាថ្ងៃទី៥ ឧសភា ឆ្នាំ១៩០៥ និងច្បាប់ចេញផ្សាយនាថ្ងៃទី១ ឧសភា ឆ្នាំ១៩០៧ បានបដិសេធរបៀបកាន់កាប់ដែនដីដោយសមាជិករាជវង្សានុវង្ស ដោយមហាមន្ត្រី (ដែលចូលក្នុងសមាសភាពក្នុងក្រុមប្រឹក្សារដ្ឋមន្ត្រី) ដែលតំណាងឱ្យមហាក្សត្រនូវចំនួនខេត្តនានាក្នុងព្រះរាជាណាចក្រ ហើយដែលទទួលប្រាក់ចំណូលរួមគ្នា។

សន្ធិសញ្ញាបារាំង-សៀម នាឆ្នាំ១៩០២, ១៩០៤ និង ១៩០៧ ដែលទាក់ទងនឹងប្រទេសកម្ពុជា ក៏មិនបានផ្លាស់ប្តូរអ្វីដល់ស្ថានភាពប្រទេសនេះឡើយ។ តាមសេចក្តីនៃសន្ធិសញ្ញានាឆ្នាំ១៩០៤ ប្រទេសកម្ពុជា ត្រូវបានទទួលដែនដីមលូព្រៃ ទន្លេរពៅ។ នៅឆ្នាំ១៩០៧ ប្រទេសកម្ពុជា បានទទួលដែនដីបាត់ដំបង និងអង្គរ មកវិញ ជាដែនដីដែលប្រទេសសៀម ដណ្តើមយកកាលពីពេលមុន។

នៅដើមសតវត្សរ៍ទី២០ ប្រទេសកម្ពុជា ត្រូវបានពួកអាណានិគមនិយមបារាំង បញ្ចូលឱ្យស្ថិតនៅក្នុងប្រព័ន្ធសហភាពឥណ្ឌូចិន ពួកវាបានបញ្ចូលទាំងកិច្ចការរៀបចំរដ្ឋបាលផ្ទៃក្នុងឱ្យស្ថិតនៅក្នុងរបបត្រួតត្រា ដែលមានទំនាក់ទំនងទៅនឹងរបបត្រួតត្រាកណ្តាល។

បន្ទាប់ពីពេលរៀបចំរបបអាណាព្យាបាល (នាឆ្នាំ១៨៦៣) មកភ្លាម ប្រទេសកម្ពុជា ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ទីស្តីការរដ្ឋមន្ត្រីក្រសួងនាវាចរណ៍យោធា។ តមកបានស្ថិតនៅក្រោមសមត្ថកិច្ចរបស់ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងអាណានិគមនៃប្រទេសបារាំង។ ទេសាភិបាលជាន់ខ្ពស់បារាំង នៅប្រទេសកម្ពុជា ស្ថិតនៅក្រោមសមត្ថកិច្ចរបស់ទេសាភិបាលជាន់ខ្ពស់បារាំង នៅកូសាំងស៊ីន។

តាមសេចក្តីនៃក្រឹត្យចេញផ្សាយនៅថ្ងៃទី១៧ តុលា ឆ្នាំ១៨៨៧ ប្រទេសស្ថិតនៅក្រោមរបបអាណានិគមបារាំងទាំងអស់នៅឥណ្ឌូចិន ដែលនៅក្នុងចំនួននេះ មានទាំងប្រទេសកម្ពុជាទៀតផង បានស្ថិតនៅក្នុងសមត្ថកិច្ចរបស់ទីស្តីការរដ្ឋមន្ត្រីនៃក្រសួងពាណិជ្ជកម្ម និងអាណានិគមបារាំង។ ទេសាភិបាលជាន់ខ្ពស់បារាំងមួយរូប បំពេញមុខងារជាប្រមុខនៃសហភាពឥណ្ឌូចិន។មានការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ឥណ្ឌូចិនមួយដែលជាអង្គការនីតិប្រតិបត្តិ ហើយស្ថិតនៅក្រោមការបង្គាប់បញ្ជារបស់ទេសាភិបាលជាន់ខ្ពស់។ នៅឆ្នាំ១៨៩៧ នៅក្នុងសមាសភាពនៃក្រុមប្រឹក្សានេះ មានសេចក្តីអនុញ្ញាតឱ្យមានអ្នកតំណាងបណ្តាជននៅឥណ្ឌូចិន ពីររូប។ នៅឆ្នាំ១៩២៨ ក្រុមប្រឹក្សានេះត្រូវបានកែប្រែទៅជាក្រុមប្រឹក្សាជាន់ខ្ពស់ខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៅឥណ្ឌូចិន ដែលនៅក្នុងនេះមានអ្នកតំណាងអភិជនឥណ្ឌូចិន ចូលជាសមាជិក។ របបអាណានិគមបារាំង នៅឥណ្ឌូចិន បានពឹងផ្អែកលើកម្លាំងកងទ័ព និងប៉ូលិសជ្រើសរើសចេញពីជនជាតិបារាំង និងបណ្តាជនទីអាយ។ របបអាណា

និគមបារាំង បានតែងតាំងការត្រួតត្រារបស់ខ្លួនលើសកម្មភាពតុលាការ ក្រសួងគយ និងក្រសួងហិរញ្ញវត្ថុ។

កិច្ចការផ្ទៃក្នុងនៃប្រទេសកម្ពុជា ត្រូវបានអនុវត្តនៅលើមូលដ្ឋានពីរយ៉ាងដ៏សំខាន់ គឺ៖ កិច្ចព្រមព្រៀងបារាំង - កម្ពុជា នាថ្ងៃទី១៧ កក្កដា ឆ្នាំ១៨៨៤ និងរាជក្រឹត្យចុះផ្សាយនាថ្ងៃទី ១១ កក្កដា ឆ្នាំ១៨៩៧។ មហាក្សត្រជាប្រមុខរដ្ឋនៃរដ្ឋាភិបាលកម្ពុជា ព្រមទាំងជាអធិបតីនៃគណៈសង្ឃពុទ្ធសាសនានៅក្នុងប្រទេស ហើយដូចពេលមុន មហាក្សត្រកាន់កាប់អំណាចតុលាការជាន់ខ្ពស់បំផុត ក្នុងការទាក់ទងនឹងប្រជារាស្ត្ររបស់ព្រះអង្គ គឺសិទ្ធិនៃការលើកលែងទោស។ រាជក្រឹត្យ និងរាជក្រមរបស់មហាក្សត្រនឹងអាចអនុវត្តជាធរមានបាន បន្ទាប់ពីទទួលការចុះហត្ថលេខារបស់ទេសាភិបាលជាន់ខ្ពស់បារាំង ជាមុនសិន។ ស្របតាមកិច្ចព្រមពៀងជាមួយរបបត្រួតត្រា នៃសហភាពឥណ្ឌូចិនជារៀងរាល់ឆ្នាំ ព្រះមហាក្សត្រទទួលប្រាក់បំណាច់ ដែលជាហេតុធ្វើឱ្យព្រះអង្គស្ថិតនៅក្នុងស្ថានភាពអនិស្សរភាព។ រីឯពួកសក្តិភូមិថ្នាក់ក្រោម និងអស់មុខមន្ត្រីគ្រប់ជាន់ថ្នាក់ក៏បានទទួលប្រាក់បំណាច់ប្រចាំឆ្នាំដែរ។ របបគ្រប់គ្រងអាណានិគមបារាំង មានបំណងចៀសវាងពីការងាររបស់នាហ្មឺនមន្ត្រី នៃរបបសក្តិភូមិចាស់ ហើយប្រើប្រាស់មន្ត្រីជំនាន់ថ្មីជំនួសវិញ។ នៅពេលជាមួយគ្នា មានការបង្ហាត់បង្រៀនរៀបចំក្របខ័ណ្ឌមន្ត្រី “ ជំនាន់ថ្មី ” ពីបណ្តាបញ្ញាជនថ្មី ដែលបានធ្វើសហការយ៉ាងជិតស្និទ្ធជាមួយរបបគ្រប់គ្រងអាណានិគមបារាំង។

តាមពិត កិច្ចត្រួតត្រាប្រទេសបានស្ថិតនៅក្នុងអំណាចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ដែលមានសមាជិកប្រាំរូប។ សម័យ

ប្រជុំរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី បានប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ទេសាភិបាលជាន់ខ្ពស់បារាំង។ ក្រុមប្រឹក្សារដ្ឋមន្ត្រីបើកសម័យប្រជុំពេញអង្គក្នុងមួយអាទិត្យម្តង ហើយក្នុងកាលៈទេសៈចាំបាច់ ក្រុមប្រឹក្សាអាចបើកសម័យប្រជុំក្រៅរបៀបវារៈតាមសេចក្តីសម្រេចរបស់មហាក្សត្រ ឬរបស់ទេសាភិបាលជាន់ខ្ពស់។ នៅពេលចន្លោះនៃសម័យប្រជុំក្រុមប្រឹក្សារដ្ឋមន្ត្រី កិច្ចការទូទៅត្រូវបានបំពេញដោយអស់មុខមន្ត្រី នៃលេខាធិការដ្ឋានរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី (មានអគ្គលេខាធិការមួយរូប និងលេខាធិការពីររូប)។ ក្រៅពីនេះ បណ្តារដ្ឋមន្ត្រីអាចធ្វើការប្រជុំការងាររាល់ថ្ងៃក្រោមអធិបតីភាពរបស់រដ្ឋមន្ត្រីទី១ សម្រាប់ការដោះស្រាយបញ្ហានានាទាក់ទងនឹងមុខក្រសួងរបស់រដ្ឋមន្ត្រី។

ផ្សេងពីក្រុមប្រឹក្សារដ្ឋមន្ត្រី នៅក្រោមអំណាចមហាក្សត្រមានទាំងក្រុមប្រឹក្សាព្រះរាជសម្បត្តិ ឬក្រុមសង្គហៈព្រះរាជវង្សានុវង្ស និងតុលាការនៃការសម្រុះសម្រួល។ តាមរាជក្រឹត្យមហាក្សត្រ ចុះថ្ងៃទី១៧ មេសា ឆ្នាំ១៩១៥ មានការបង្កើតក្រុមប្រឹក្សារាជបល្ល័ង្ក ដែលក្នុងនេះ មានក្សត្រាក្សត្រីចំនួន៨រូបនៃរាជវង្សានុវង្ស ជាសមាជិក តែងតាំងដោយមហាក្សត្រ។ ក្រុមប្រឹក្សារាជបល្ល័ង្កត្រួតពិនិត្យលើការប្រព្រឹត្ត របស់សមាជិកនៃរាជវង្សានុវង្ស ដោះស្រាយបញ្ហានានាទាក់ទងនឹងហិរញ្ញវត្ថុ សាសនារដ្ឋបាល និងការជ្រើសរើសមហាក្សត្រសម្រាប់ការបន្តរាជសម្បត្តិ។ សម័យប្រជុំរបស់ក្រុមប្រឹក្សារាជបល្ល័ង្កប្រព្រឹត្តទៅក្រោមអធិបតីភាពរបស់ទេសាភិបាលជាន់ខ្ពស់បារាំង។ តុលាការនៃការសម្រុះសម្រួលដោះស្រាយបញ្ហាវិបត្តិ ដែលកើតមានឡើងរវាងបុគ្គល

ទាំងឡាយដែលរស់នៅក្នុងបរមរាជវាំង ឬរវាងបុគ្គលិកបម្រើការព្រមទាំងបញ្ហាដទៃទៀត។

ឋានន្តរស័ក្តិរបស់មន្ត្រីនៃរដ្ឋបាលខ្មែរ មានស័ក្តិដប់ពាន់។ រដ្ឋមន្ត្រីទីមួយអាចមានស័ក្តិដល់ដប់មួយពាន់ លុះត្រាណាមានការសម្រេចជោគជ័យក្នុងការបំពេញបេសកកម្មពិសេសណាមួយ។ រដ្ឋមន្ត្រីទីមួយ ជាមន្ត្រីដែលមានឋានន្តរស័ក្តិខ្ពស់ជាងគេបំផុតនៅក្នុងរដ្ឋាភិបាលខ្មែរ។ បន្ទាប់មក មានបណ្តារដ្ឋមន្ត្រីដទៃហើយឋានន្តរស័ក្តិរដ្ឋមន្ត្រីទាំងនេះ ឡើងទៅតាមពេលវេលានៃការកាន់តំណែង។ បន្ទាប់ពីបណ្តារដ្ឋមន្ត្រី មានអគ្គលេខាធិការ និងនាយមន្ទីរទាំងឡាយ។

ទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងធម្មការ ស្ថិតនៅក្រោមការត្រួតត្រារបស់រដ្ឋមន្ត្រីទីមួយផ្ទាល់។ មិនតែប៉ុណ្ណោះ រដ្ឋមន្ត្រីទីមួយជាប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សារដ្ឋមន្ត្រី ហើយទទួលបន្ទុកក្នុងទំនាក់ទំនងរវាងរដ្ឋបាលខ្មែរ (ក្រុមប្រឹក្សារដ្ឋមន្ត្រី) និងរដ្ឋបាលអាណានិគមបារាំង។ នៅក្នុងទីស្តីការរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងធម្មការ មានមន្ទីរចាត់ការពីរបែប។ ក្នុងមន្ទីរចាត់ការទីមួយ មានអង្គការរដ្ឋបាលក្រសួងមហាផ្ទៃ ហើយនៅក្នុងមន្ទីរចាត់ការទីពីរ មានអង្គការរដ្ឋបាលក្រសួងធម្មការដែលចាត់ចែងអំពីបញ្ហាសាសនានៅក្នុងប្រទេសទូទៅ។

ទីស្តីការរដ្ឋមន្ត្រីនៃបរមរាជវាំង ហិរញ្ញវត្ថុ និងសិល្បៈចាត់ចែងកិច្ចការបរមរាជវាំង ការទាក់ទងរបស់បរមរាជវាំង និងរដ្ឋបាលអាណានិគមបារាំង ពិធីបុណ្យប្រពៃណីផ្សេងៗ បូរាណវត្ថុវិទ្យា បណ្ណាល័យ គួរឃ្លាំងគ្រឿងព្រះរាជទ្រព្យ។ ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានមន្ទីរចាត់ការបីបែប។ ទីស្តីការរដ្ឋមន្ត្រី

ពិសេសមួយ ចាត់ចែងវិស័យយោធា វិស័យសិក្សាធិការ និងសាធារណការ។ វិស័យនាវាចរណ៍យោធា កសិកម្ម ឧស្សាហកម្ម និងពាណិជ្ជកម្មស្ថិតនៅក្រោមសមត្ថភាព របស់ទីស្ដីការរដ្ឋមន្ត្រីមួយរូប។

នៅអមក្រុមប្រឹក្សារដ្ឋមន្ត្រីខ្មែរ មាននាហ្មឺនជាន់ខ្ពស់បារាំងមួយរូប តែងតាំងដោយរដ្ឋបាលអាណានិគម ដើម្បីសម្របសម្រួលកិច្ចការរដ្ឋាភិបាលខ្មែរនៅក្នុងក្រុមប្រឹក្សារដ្ឋមន្ត្រី និងនៅក្នុងទីស្ដីការរដ្ឋមន្ត្រីនីមួយៗ។ នាហ្មឺនជាន់ខ្ពស់នេះ ធ្វើការត្រួតពិនិត្យលើសកម្មភាពរបស់រដ្ឋាភិបាលខ្មែរ ជាទូទៅ។

កិច្ចការរដ្ឋបាលទូទៅនៅក្នុងប្រទេសទាំងមូល ត្រូវបានបង្កើតឡើងស្របតាមការបែងចែកប្រទេស ជាតំបន់រដ្ឋបាលនានា។ ចំនួនខេត្តត្រូវបានបង្កើនជាថ្មី ពី៨ខេត្ត ដល់១៤ខេត្ត ហើយនៅពេលក្រោយមក ពី១៤ ដល់១៦។ នាហ្មឺនខ្មែរមួយរូប គឺចៅហ្វាយខេត្តធ្វើជាប្រមុខនៃខេត្តនីមួយៗ ក៏ប៉ុន្តែ ចៅហ្វាយខេត្តនីមួយៗ មានឧបការីដូចតទៅ៖ បាឡាត់ខេត្ត យោក្បត្រស្នង និងក្រឡាពាស។ សារាចរទាំងអស់នៃរដ្ឋបាលខេត្តនឹងអនុវត្តជាធរមានទៅបាន លុះត្រាតែមានហត្ថលេខាយល់ព្រមរបស់ទេសាភិបាលបារាំង ជាមុនសិន។ ចៅហ្វាយខេត្តត្រួតពិនិត្យលើកិច្ចអនុវត្តក្រឹត្យក្រមរបស់មហាក្សត្រ និងសារាចរទាំងឡាយលើការរៀបចំសណ្ដាប់ធ្នាប់នៅក្នុងខេត្ត និងកិច្ចការដទៃទៀត។ ទេសាភិបាល និងនាហ្មឺនបារាំង ត្រួតពិនិត្យលើសកម្មភាពរបស់រដ្ឋបាលខេត្តទាំងអស់ មានទាំងបញ្ជីអ្នកជាប់ពន្ធ ការបង់ពន្ធដារ និងការងាររបស់តុលាការ។

នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩០៤ នៅអមមន្ត្រីបារាំង មានការបង្កើតក្រុមប្រឹក្សាដែលជាអង្គការសម្រាប់ពិភាក្សា ហើយដែលមានអ្នកតំណាងបណ្តាជនទីអាយចូលជាសមាជិក។ ក្រុមប្រឹក្សានេះបើកសម័យប្រជុំក្នុងមួយឆ្នាំម្តង ដើម្បីពិភាក្សាកិច្ចការផ្ទៃក្នុង។ ក្រុមប្រឹក្សាបែបនេះ ត្រូវបានតែងតាំងដោយការបោះឆ្នោតមិនចំពោះ។

បន្ទាប់ពីរដ្ឋបាលខេត្ត មានរដ្ឋបាលស្រុក ដែលមានចៅហ្វាយស្រុក ដែលជានាហ្មឺនខ្មែរមួយរូបធ្វើជាប្រមុខ ហើយដែលត្រូវតែងតាំងដោយចៅហ្វាយខេត្ត ពីបណ្តាតំណាងអ្នកមាននៃសង្គមខ្មែរ (បើមានការយល់ព្រមរបស់ទេសាភិបាលបារាំង)។ ចៅហ្វាយស្រុកមានអំណាច និងសមត្ថកិច្ចរបស់ខ្លួននៅក្នុងស្រុក ដូចជាចៅហ្វាយខត្តនៅក្នុងខេត្តរបស់ខ្លួន។ នៅក្នុងរដ្ឋបាលសាលាស្រុក មានបុគ្គលិកសំខាន់បួនរូប ដែលនៅក្នុងនេះ មានបាឡាត់ស្រុក ស្មៀនពីររូប និងយោក្ប័ត្រ។ នៅថ្នាក់ក្រោមជាងគេ គឺរដ្ឋបាលសាលាឃុំ ដែលមានមេឃុំជានាយក។ រដ្ឋបាលសាលាឃុំ គឺជាសំណាញ់រដ្ឋបាលពន្ធដារដ៏ទាបតូចបំផុតនៅក្នុងប្រទេស បង្កបង្កើតឡើងដោយរបបគ្រប់គ្រងអាណានិគមបារាំង ដើម្បីត្រួតត្រាលើបណ្តាជនស្រុកស្រែចម្ការ ដែលរស់នៅលើទឹកដីដ៏ធំធេងនៃប្រទេស។ នៅក្រោមសមត្ថកិច្ចរបស់មេឃុំមានមេភូមិ ដែលជួយឧបត្ថម្ភមេឃុំ ក្នុងការអនុវត្តរបបគ្រប់គ្រងភូមិទាំងឡាយ ក្នុងការផ្តល់ព័ត៌មានអំពីស្ថានភាពកិច្ចការផ្សេងៗដល់អ្នកស្រុក និងក្នុងការទារពន្ធដារគ្រប់សារពើ។ ឃុំនីមួយៗមានតាំងពីភូមិពីរ-បី រហូតដល់បួនដប់ ហើយទំហំឃុំនីមួយៗ

ទាក់ទងទៅនឹងចំនួនបណ្ដាជននៅតំបន់នេះ។ តាមធម្មតា បណ្ដាជនឃុំមានចំនួនពីបួនពាន់ រហូតដល់ប្រាំបីពាន់នាក់។

ឃុំ និងរដ្ឋបាលសាលាឃុំបានបង្កបង្កើតឡើងតាមរាជក្រឹត្យចុះផ្សាយនៅថ្ងៃទី៥ មិថុនា ឆ្នាំ១៩០៥ និងរាជក្រឹត្យចុះផ្សាយនៅថ្ងៃទី២៤ កញ្ញា ឆ្នាំ១៩១៩ និងថ្ងៃទី១៥ វិច្ឆិកា ឆ្នាំ១៩២៥។ មេឃុំត្រូវបានតែងតាំងដោយការបោះឆ្នោត របស់ក្រុមជំនុំឃុំដែលមានអ្នកស្រុកនៅក្នុងឃុំ អាយុមិនតិចជាង២១ឆ្នាំ (ប៉ុន្តែបើតាមការពិត មេឃុំត្រូវបានតែងតាំងពីមន្ត្រីថ្នាក់លើជាមុនមកហើយ)។ តមក មេឃុំតែងតាំងជំនួយការរបស់ខ្លួន(គឺជំទប់ទី១ ជំទប់ទី២) ពីបណ្ដានៃសមាជិករបស់ក្រុមប្រឹក្សាឃុំ។ តាមលំដាប់នៃឋានន្តរស័ក្តិ មេឃុំជានាហ្មឺនមានស័ក្តិបួនពាន់ ឯជំទប់ឃុំ គឺជានាហ្មឺនមានស័ក្តិបីពាន់។ ក្រុមជំនុំឃុំ ត្រូវបានបើកសម័យប្រជុំបួនដងក្នុងមួយឆ្នាំ។ ក្រុមជំនុំឃុំបង្កើតថវិកាឃុំ ដែលត្រូវទទួលសេចក្ដីយល់ព្រមរបស់ចៅហ្វាយខេត្ត និងទេសាភិបាលបារាំង។ ជាពិសេស ក្រុមជំនុំឃុំបំពេញការងាររបស់ខ្លួនក្នុងការទារពន្ធដារពីអ្នកស្រុក ហើយមានសមត្ថកិច្ចដ៏ធំទូលាយក្នុងបញ្ហាទារពន្ធដារ និងការរៀបចំបញ្ជីឈ្មោះមនុស្សជាប់ពន្ធ ក្នុងការចែករំលែកការងារដោយបង្ខំដល់អ្នកស្រុក ក្នុងការកែនកំណែនមនុស្សបញ្ចូលកងទ័ព ទទួលខុសត្រូវចំពោះការប្រព្រឹត្តរបស់អ្នកស្រុក។ ក្រុមជំនុំឃុំមានសមាជិករបស់ខ្លួន ជ្រើសរើសពីបណ្ដាអ្នកតំណាងភូមិនានានៅក្នុងឃុំ។

រដ្ឋធានីភ្នំពេញ ត្រូវបានតែងតាំងឱ្យទៅជាទីស្នាក់ការពិសេសនៃរដ្ឋបាល ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ទេសាភិបាលជាន់ខ្ពស់បារាំង។ នៅភ្នំពេញ មានតែងតាំងក្រុមប្រឹក្សា

មួយដែលមានសមាជិកជ្រើសរើសពីបណ្ដាអ្នកទីក្រុង។ ក្រុមប្រឹក្សានេះបំពេញមុខងារជាអង្គការសម្រាប់ពិភាក្សា។

ក្នុងក្របខ័ណ្ឌនៃ "កងកម្លាំងមូលដ្ឋាន" ដែលទទួលធានាដល់របបគ្រប់គ្រងអាណានិគមបារាំង នៅក្នុងប្រទេស និងក្រៅពីកងកម្លាំងទ័ព ដែលស្ថិតនៅប្រទេសកម្ពុជា ក្រោមទីបញ្ជាការយោធាបារាំង ស្របតាមសេចក្ដីបង្គាប់បញ្ជារបស់ទេសាភិបាលជាន់ខ្ពស់នៃសហភាពឥណ្ឌូចិន។ នៅក្នុងប្រទេសកម្ពុជា មានការបង្កើតកងកម្លាំងប៉ូលិសស្រុកស្រែ និងកងទ័ពទាហានជើងខ្មៅ ដែលមានចំនួនដល់មួយកងវរសេនាតូច ហើយបំពេញមុខងារជាកម្លាំងភ្នាក់ងារនគរបាល។

ជីវភាពរបស់អ្នកស្រុក បានប្រព្រឹត្តទៅនៅក្រោមអំណាចច្បាប់អាណានិគមបារាំង និងច្បាប់ព្រហ្មទណ្ឌ។ នៅក្នុងច្បាប់ទាំងនេះ មានបញ្ជាក់អំពីវិធានការស្ដីអំពីការកម្រិតសេរីភាពបណ្ដាជន ជាពិសេសបណ្ដាជនស្រុកស្រែ។ បើសិនជាគ្មានសំបុត្របញ្ជាក់អំពីការបង់ពន្ធ ឬមួយគ្មានអត្តសញ្ញាណប័ណ្ណផ្ទាល់ខ្លួន ដោយមានការផ្ដិតខ្មៅដៃត្រឹមត្រូវនោះ កសិករគ្មានសិទ្ធិធ្វើដំណើរដោយសេរី ទៅតាមទីកន្លែងនានានៃប្រទេសបានឡើយ។ នៅស្រុកស្រែ បើគ្មានសេចក្ដីអនុញ្ញាតពីរដ្ឋការទីអាយអ្នកស្រុកមិនអាចឱ្យបុគ្គលដទៃ សំណាក់នៅផ្ទះខ្លួនបានឡើយ។ ការរំលោភលើសេចក្ដីហាមឃាត់នេះ អាចទទួលការពិន័យជាប្រាក់ ឬត្រូវជាប់ពន្ធនាគារ។

ដោយមានស្ថានភាពបែបនេះ តាមការពិត អ្នកម្ចាស់ការនៃប្រទេសមិនមែនជាមហាក្សត្រទេ គឺពិតជាទេសាភិបាលជាន់ខ្ពស់បារាំង។

ស្របតាមការវិវត្តទូទៅ នៃរបបគ្រប់គ្រងអាណានិគម និងអង្គការចាត់តាំងនានានៃសហភាពឥណ្ឌូចិន នៅក្រោមអំណាចរបស់ទេសាភិបាលជាន់ខ្ពស់ គេបានបង្កើតឱ្យមានក្រុមប្រឹក្សានៃអង្គការសម្រាប់ពិភាក្សាមួយ ដែលមានសមាជិកជ្រើសរើសពីបណ្តាពួកមន្ត្រីនៃរបបអាណានិគម។

តាមក្រឹត្យចុះផ្សាយនាថ្ងៃទី១៨ មីនា ឆ្នាំ១៩១៣ មានការបង្កើតសភាសម្រាប់ពិភាក្សាមួយ ដែលមានសមាជិកជ្រើសរើសពីបណ្តាអ្នកតំណាងបណ្តាជន។ សមាជិកទាំងនេះអាចធ្វើការពិភាក្សា ប៉ុន្តែមិនអាចធ្វើសេចក្តីសម្រេចអំពីបញ្ហាទាក់ទងនឹងហិរញ្ញវត្ថុ កិច្ចត្រួតត្រា និងបញ្ហាដទៃទៀត។ សមាជិកមួយភាគតូចរបស់សភានេះត្រូវបានជ្រើសរើសដោយការបោះឆ្នោត ប៉ុន្តែសមាជិកមួយភាគប្រាំបីនាក់ ត្រូវបានតែងតាំងដោយរបបគ្រប់គ្រងបារាំង។ នៅក្រោមអំណាចរបស់ទេសាភិបាលជាន់ខ្ពស់ មានទាំងការបង្កើតក្រុមប្រឹក្សាចម្រុះមួយខាងសេដ្ឋកិច្ច និងពាណិជ្ជកម្ម។

មុនដំបូង នៅប្រទេសកម្ពុជា ពួកអាណានិគមបារាំង បានអនុវត្តនីតិច្បាប់ដូចតទៅ ជនជាតិបារាំង និងជនជាតិអឺរ៉ុបដទៃទៀតគោរពតាមច្បាប់បារាំង ពលរដ្ឋខ្មែរគោរពតាមច្បាប់របស់ប្រទេស។ ចាប់ពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩១១ មក ពលរដ្ឋខ្មែរគោរពតាមច្បាប់ព្រហ្មទណ្ឌ រៀបចំតាមទម្រង់នៃច្បាប់ជាធរមាននៃប្រទេសបារាំង ដោយកែសម្រួលតាមច្បាប់ទម្លាប់របស់ប្រទេសកម្ពុជា។

ប្រព័ន្ធការិយាល័យនិយម នៃរបបអាណានិគមបារាំង ដែលបានរៀបចំឡើងនៅប្រទេសកម្ពុជា បានទៅជាគ្រឿង

ឧបករណ៍ នៃការប្រមូលផ្តុំអំណាចឱ្យនៅក្នុងរដ្ឋបាលបារាំងទាំងអស់ គឺដោយសារការត្រួតត្រាបែបនេះហើយ ដែលពួកអាណានិគមបារាំង បានធ្វើការកៀបសង្កត់មកលើប្រជាជនកម្ពុជា មិនតែប៉ុណ្ណោះ ពួកវាបានកៀបរឹបយកភោគផលពីប្រទេសកម្ពុជា ដើម្បីបង្កើតជាសម្បត្តិទ្រព្យដ៏សម្បូរសម្រាប់វណ្ណៈគហបតីនៃប្រទេសបារាំង។

# ជំពូកទី៣

## ចលនាប្រឆាំងនៅប្រទេសកម្ពុជា និងការចាប់ផ្ដើម នៃការតស៊ូរបស់ប្រជាជនខ្មែរ ដើម្បីឯករាជភាពប្រទេស

ចលនាប្រឆាំងរបស់ប្រជាជន ដែលបានកើតមានឡើងនៅប្រទេសកម្ពុជា នាសម័យកាលនៃភាគទីពីរ នៅសតវត្សរ៍ទី១៩ ជាភស្តុតាងបញ្ជាក់ឱ្យឃើញប្រចក្សថា ប្រជាជនខ្មែរអាចដឹកនាំការតស៊ូរបស់ខ្លួនដើម្បីដណ្ដើមយកអធិបតេយ្យភាព និងឯករាជភាពជាតិ។ មិនតែប៉ុណ្ណោះ កាលៈទេសៈខ្លះ បានបញ្ជាក់ឱ្យដឹងនូវលទ្ធភាពដ៏ល្អក្នុងការធ្វើសកម្មភាពរួមគ្នា រវាងយុទ្ធជនខ្មែរ និងវៀតណាម ដើម្បីតស៊ូប្រឆាំងនឹងពួកអាណានិគមបារាំង។ តាមពិត ចលនាតស៊ូប្រឆាំងនៅប្រទេសកម្ពុជា បានទទួលបរាជ័យនៅពេលនោះ បានកើតមានឡើង ដោយមកពីមានសម្ពន្ធភាពរបស់មហាក្សត្រនរោត្តម និងបណ្ដាមុខមន្ត្រីសក្តិភូមិជាន់ខ្ពស់មួយភាគជាមួយរបបគ្រប់គ្រងអាណានិគមបារាំង។ ស្ថានភាពបែបនេះ ក៏បានកើតមានឡើងដូចគ្នានៅប្រទេសវៀតណាម ជិតខាង។

តាមទម្រង់ខាងក្រៅ ចលនាតស៊ូរបស់ប្រជាជននាសម័យភាគទីពីរនៃសតវត្សរ៍ទី១៩ មានលក្ខណៈពីរយ៉ាង៖ ម្យ៉ាង គឺជាចលនាដែលមានឈ្មោះថា “ ចលនារាជសម្បត្តិនិយម ” ដែលអាចហៅម្យ៉ាងទៀតថា ជាចលនាដែលមានគោលបំណងដណ្ដើមយករាជបល្ល័ង្ក ដោយមគ្គុទ្ទេសក៍នៃចលនាទាំងនេះ (ដូចជា

ចលនាតស៊ូរបស់អាចារ្យស្វា ពោធិ៍កំបោរ និងស៊ីវត្ថា) ម្យ៉ាងទៀតគឺ “ ចលនាតស៊ូដើម្បីការពារមហាក្សត្រ ”។ ចលនាតស៊ូទាំងអស់នេះ បានស្ថិតនៅក្រោមទង់អ្នកជាតិនិយម និងរាជានិយមសក្តិភូមិ។

នៅក្នុងចលនា “ រាជសម្បត្តិនិយម ” មានលក្ខណៈប្រជាជនប្រឆាំងនឹងសក្តិភូមិ ហើយមានការចូលរួមពីសំណាក់កសិករខ្លាំងជាង “ ចលនាតស៊ូដើម្បីការពារមហាក្សត្រ ”។ ម្យ៉ាងវិញទៀត “ ចលនាតស៊ូដើម្បីការពារមហាក្សត្រ ” មានទិសដៅប្រឆាំងបារាំងខ្លាំងជាងគេ ដោយហេតុថា បណ្តាមគ្គុទ្ទេសក៍ “ ចលនារាជសម្បត្តិនិយម ” ខ្លះ ស្វែងរកការគាំទ្រពីសំណាក់រដ្ឋអំណាចអាណានិគមបារាំង ឬអង់គ្លេស នៅបាងកក។

បន្ទាប់ពីពេលចុះហត្ថលេខា លើកិច្ចព្រមព្រៀងបារាំង-កម្ពុជា ស្តីអំពីការតែងតាំងអាណាព្យាបាលនាឆ្នាំ១៨៦៣ មានកើតកុបកម្មបះបោរជាច្រើនប្រឆាំងពួកអាណានិគមបារាំង និងមហាក្សត្រនរោត្តម។ មនោគមវិជ្ជារបស់អ្នកចូលរួមក្នុងការបះបោរទាំងនេះមានកម្រិត មិនហួសពីស្មារតីអ្នកជាតិនិយមសក្តិភូមិ ហើយឧត្តមគតិខាងសង្គម របស់គេតែងតែស្ថិតជាប់ទៅនឹងកេរដំណែលនៃអតីតកាល។ ហេតុនេះហើយ បានជាកម្មវិធីតស៊ូរបស់គេរមែងស្ថិតជាប់នឹងការទាមទារ ឱ្យមានការផ្លាស់ប្តូររាជសម្បត្តិនៃព្រះមហាក្សត្រ។ ក៏ប៉ុន្តែ តាមការពិត ទោះបីកុបកម្មបះបោរទាំងនេះមានកម្រិតស្មារតី និងសតិអារម្មណ៍ដូចម្តេចក្តី ក៏គោលបំណងរបស់ពួកគេ សំដៅឆ្ពោះទៅរកការពង្រឹងរបបគ្រប់គ្រងរដ្ឋនៅក្នុងស្ថានភាព នៃការកាន់កាប់ទឹកដីរបស់ពួកអាណានិគមបារាំង។

កុបកម្មបះបោរទីមួយបានកើតមានឡើង ក្រោមការដឹកនាំរបស់អាចារ្យស្វា។ នៅឆ្នាំ១៨៦៤ អាចារ្យស្វា បានប្រកាសខ្លួនឯងថាជាក្មួយរបស់អតីតមហាក្សត្រប្រទេសកម្ពុជា ព្រះបាទអង្គចន្ទទីពីរ ហើយបានចាប់ផ្តើមតស៊ូទាមទាររាជសម្បត្តិ។

ក្នុងយុទ្ធនាការរបស់ខ្លួន អាចារ្យស្វា បានដឹកនាំកងកម្លាំងខ្មែរ ជនជាតិវៀតណាម និងចាម រាប់រយនាក់ បានទទួលការគាំទ្រពីសំណាក់រដ្ឋការវៀតណាម នៅខេត្តចូវដុក មាត់ជ្រូក។ នៅពេលនោះ កងកម្លាំងអាចារ្យស្វា បានពង្រឹងស្ថានភាពរបស់ខ្លួននៅភូមិភាគខាងត្បូងនៃប្រទេស និងនៅតំបន់ព្រៃកជីកហាទៀន។ អ្នកចូលរួមក្នុងចលនាប្រយុទ្ធរបស់អាចារ្យស្វា មានចំនួនកាន់តែច្រើន ហើយតមក ចលនានេះបានប្រែក្លាយទៅជាចលនាប្រយុទ្ធប្រឆាំងពួកអាណានិគមបារាំង។ កុបករទាំងឡាយបានធ្វើការវាយលុកនៅក្នុងខេត្តខាងត្បូងនៃប្រទេសកម្ពុជា គឺខេត្តទ្រាំង (សព្វថ្ងៃ ខេត្តកំពត និងតាកែវ)។ យុទ្ធជននៃចលនាអាចារ្យស្វា វាយយកបានខេត្តកំពត និងធ្វើឃាតប្រមុខខេត្ត ហើយបន្តធ្វើយុទ្ធនាការសំដៅមកកាន់ទីក្រុងភ្នំពេញ។ នៅពេលនោះ ព្រះបាទនរោត្តម បានបញ្ជូនទ័ពទៅទប់ទល់ ដែលជាហេតុបណ្តាលឱ្យទ័ពអាចារ្យស្វា ទទួលបរាជ័យ រួចដកថយត្រឡប់ទៅកាន់មូលដ្ឋាននៅតំបន់ព្រៃកជីក ហាទៀនវិញ។

នៅឆ្នាំ១៨៦៥ កងកម្លាំងនៃចលនាអាចារ្យស្វា បានចាប់ផ្តើមធ្វើយុទ្ធនាការជាថ្មីនៅប៉ែកខាងត្បូងនៃប្រទេស។ ក្នុងការប្រយុទ្ធម្តងនេះ ទាល់តែកងទ័ពបារាំង ចូលធ្វើអន្តរាគមន៍ ទើបចលនានេះត្រូវបានបញ្ឈប់។ ទេសាភិបាលជាន់ខ្ពស់បារាំងនៅកម្ពុជា បានគំរាមកំហែងប្រើកម្លាំងទ័ព ហើយបានបង្ខំដល់រដ្ឋការ

វៀតណាម ឱ្យបញ្ឈប់ការគាំទ្រដល់បណ្តាកុបករបះបោរ។ នៅថ្ងៃទី១៩ សីហា ឆ្នាំ១៨៦៦ អាចារ្យស្វា ត្រូវរបួសនៅសមរភូមិ ហើយត្រូវបានពួកបារាំង ចាប់បាន។ នៅពេលក្រោយមក ពួកអាណានិគមបារាំង បានបញ្ជូនអាចារ្យស្វា ទៅឃុំឃាំងនៅកោះពូឡូ កុងដ័រ (កោះត្រឡាច) ហើយតមកទៀត បានបញ្ជូនលោកទៅឃុំឃាំងនៅពន្ធនាគារនៅកោះឡេ សង់ទីយ នៅពួដ៏កណ្តាលមហាសាគរប៉ាស៊ីហ្វិក។

ពីឆ្នាំ១៨៦៥ ដល់១៨៦៧ នៅប្រទេសកម្ពុជា មានចលនាកុបកម្មបះបោរមួយទៀត ដែលបានកើតមានឡើងក្រោមការដឹកនាំរបស់ពោធិ៍កំបោរ ក៏ដូចជា អាចារ្យស្វា ដែរ បានប្រកាសខ្លួនឯងថា ជាចៅរបស់អតីតមហាក្សត្រប្រទេសកម្ពុជា ព្រះបាទអង្គចន្ទទីពីរ។ ចលនាប្រយុទ្ធបានទាក់ទាញឱ្យមានអ្នកចូលរួមជាច្រើនពីសំណាក់នៃបណ្តាកសិករ ដែលបានក្តៅក្រហាយអំពីការដំឡើងពន្ធដារហួសប្រមាណ និងពីសំណាក់ជនជាតិដែលរស់នៅតំបន់ភ្នំ។

នៅខែឧសភា ឆ្នាំ១៨៦៥ ពោធិ៍កំបោរ ទាមទារទេសាភិបាលបារាំង នៅប្រទេសវៀតណាមខាងត្បូង ឱ្យទទួលស្គាល់សិទ្ធិរបស់លោកយករាជបល្ល័ង្ក។ ពោធិ៍កំបោរ បានធ្វើដំណើរទៅកាន់ទីក្រុងព្រៃនគរ ដើម្បីធ្វើការចរចាជាមួយនឹងរដ្ឋការបារាំង នៅទីនោះ ប៉ុន្តែលោកត្រូវបានពួកវាចាប់ឃុំឃាំង។ តមក នៅខែឧសភា ឆ្នាំ១៨៦៦ លោកបានរត់គេចខ្លួនដល់តំបន់ព្រំប្រទល់ខេត្តតៃនិញ។ នៅទីនោះ លោកប្រមែប្រមូលបានអ្នកស្ម័គ្រចិត្តចំនួនប្រហែលពីរពាន់នាក់ ហើយនៅខែកក្កដានៃឆ្នាំដដែល កងកម្លាំងរបស់ពោធិ៍កំបោរ បានធ្វើការវាយប្រហារ

យ៉ាងដំណំលើកងទ័ពបារាំង។ តមក ចលនាប្រយុទ្ធរបស់ពោធិ៍កំបោរ បានពង្រឹង និងពង្រីកជួរនៅប្រទេសកម្ពុជា ធ្វើឱ្យកងទ័ពមហាក្សត្រទទួលបរាជ័យនៅច្រើនកន្លែង (នាខែសីហា និងខែតុលា ឆ្នាំ១៨៦៦)។ បន្ទាប់ពីការទទួលជ័យជម្នះទាំងនេះ កិត្តិនាមរបស់ពោធិ៍កំបោរ កាន់តែលាន់ឮទូទាំងប្រទេស ហើយកងកម្លាំងរបស់ចលនាពោធិ៍កំបោរ មានអ្នកស្ម័គ្រចិត្តចំនួនដល់ដប់ពាន់នាក់។ កុបកម្មបះបោរបានកើតមានឡើងនៅតំបន់នានានៃប្រទេស នៅតាមព្រំប្រទល់ប្រទេសឡាវ នៅតាមតំបន់ទាំងសងខាងនៃទន្លេមេគង្គ នៅតំបន់ដែលស្ថិតនៅរវាងទីក្រុងឧត្តុង្គ និងភ្នំពេញ។

ចលនាប្រយុទ្ធរបស់ពោធិ៍កំបោរ ក៏ដូចជារបស់អាចារ្យស្វាតែងបានទទួលគាំទ្រយ៉ាងសកម្ម ពីសំណាក់រដ្ឋការវៀតណាមនៅកូសាំងស៊ីន។ យុទ្ធជននៃចលនានេះសាកល្បងវាយចូលរដ្ឋធានីឧត្តុង្គ ពីរ-បីដង ហើយនៅពេលនោះ កងទ័ពបារាំង បានមកជួយឧបត្ថម្ភមហាក្សត្រនរោត្តម ក្នុងកិច្ចការពាររដ្ឋធានី។ ស្ថានភាពរបស់មហាក្សត្រនរោត្តម បានទន់ខ្សោយ។ តាមឯកសារខ្លះ មានការបញ្ជាក់ថា ដោយចង់ចៀសវាងពីកំហឹងរបស់ប្រជាជន និងមុខមន្ត្រីជាន់ខ្ពស់ មហាក្សត្រមិនចង់បញ្ជូនទ័ពទៅច្បាំងតទល់នឹងចលនាប្រយុទ្ធរបស់ពោធិ៍កំបោរ ហើយនៅឆ្នាំ១៨៦៦ ព្រះបាទនរោត្តម បានលើករដ្ឋធានីពីឧត្តុង្គមកតាំងនៅភ្នំពេញវិញ។

នៅថ្ងៃទី៧ មករា ឆ្នាំ១៨៦៧ នៅក្នុងការប្រយុទ្ធគ្នាដ៏សាហាវនៅជាយទីក្រុងភ្នំពេញ កងកម្លាំងរបស់ពោធិ៍កំបោរ ត្រូវ

បានរលំរលើង ហើយពោធិ៍កំបោរផ្ទាល់ត្រូវរងរបួស និងបាន បាត់បង់ជីវិតនៅក្នុងសមរភូមិ នៅខែធ្នូ ឆ្នាំ១៨៦៧។

កុបកម្មបះបោរក្រោមការដឹកនាំរបស់ស៊ីវត្ថា គឺជាចលនាប្រយុទ្ធប្រឆាំងដ៏ធំធេងនៅសម័យនោះ។ កម្មវិធីប្រយុទ្ធរបស់ស៊ីវត្ថា មានការទាមទាររាជសម្បត្តិ ក៏ប៉ុន្តែ មានទិសដៅដ៏សំខាន់ គឺការប្រយុទ្ធប្រឆាំងនឹងរបបអាណានិគមបារាំង ដូចជាចលនាប្រយុទ្ធក្រោមការដឹកនាំរបស់អាចារ្យស្វា និងពោធិ៍កំបោរដែរ។

ស៊ីវត្ថា ជារាជបុត្រពៅរបស់មហាក្សត្រអង្គឌួង ហើយបានសំដែងកំហឹងដល់ក្រុមប្រឹក្សារាជសម្បត្តិ ដែលបានតែងតាំងព្រះបាទនរោត្តម ជាមហាក្សត្រ នៃប្រទេសកម្ពុជា។ ជាលើកទីមួយ ស៊ីវត្ថា បានចាប់ផ្តើមបង្កបង្កើតចលនាប្រយុទ្ធប្រឆាំងនឹងមហាក្សត្រនរោត្តម នៅខេត្តកំពង់ចាម នាខែមិថុនា ឆ្នាំ១៨៦១។ នៅពេលនោះ យុទ្ធជននៃចលនាប្រយុទ្ធរបស់ស៊ីវត្ថា វាយលុកយករដ្ឋធានីបាន ហើយប្រយុទ្ធតម្រង់មកកាន់ទីក្រុងភ្នំពេញ។

ព្រះបាទនរោត្តម បានភៀសខ្លួនទៅកាន់ទីក្រុងបាងកក រួចទើបយាងត្រឡប់ពីទីនោះមកវិញនៅខែមីនា ឆ្នាំ១៨៦២។ នៅពេលដែលចលនាកុបកម្មត្រូវបានបង្ក្រាប ហើយតមក ស៊ីវត្ថា បានភៀសខ្លួនទៅនៅប្រទេសសៀម។

ចលនាប្រយុទ្ធប្រឆាំងទីពីរដឹកនាំដោយស៊ីវត្ថា បានកើតមានឡើងនៅឆ្នាំ១៨៧៦។ កងទ័ពអាណានិគមបារាំង ចេញមុខប្រយុទ្ធយ៉ាងសកម្មនឹងកងកម្លាំងរបស់ស៊ីវត្ថា។ នៅឆ្នាំ១៨៧៧ ស៊ីវត្ថា ត្រូវបានជាប់ជាឈ្លើយសង្គ្រាម ហើយសត្រូវបានដោះ

លែងវិញ បន្ទាប់ពីមានការបង្ខំឱ្យស៊ីវត្ថា ស្ថិតនៅក្រៅជីវភាពនយោបាយ។ ក៏ប៉ុន្តែ នៅឆ្នាំ១៨៨៥ ស៊ីវត្ថា បានបន្តចលនាប្រយុទ្ធប្រឆាំងតទៅមុខទៀត ដោយមានគោលបំណងដណ្តើមយករាជបល្ល័ង្ក។ មូលដ្ឋានសំខាន់នៃចលនាប្រយុទ្ធប្រឆាំងរបស់ស៊ីវត្ថា គឺខេត្តកំពង់ចាម ហើយមិនតែប៉ុណ្ណោះ ចលនានេះមានអ្នកស្ម័គ្រចិត្តចូលរួបរួមច្រើនពីសំណាក់បណ្តាជននៅតំបន់ភាគខាងជើង និងខាងកើតនៃប្រទេស។ គេពិបាកធ្វើការវិនិច្ឆ័យអំពីចំនួនយុទ្ធជនក្នុងកងកម្លាំងស៊ីវត្ថា ប៉ុន្តែទោះបីដូចម្តេច ក៏នៅពេលដំបូង មានចំនួនមិនតិចជាងពី៣ពាន់ ទៅដល់៥ពាន់នាក់។ នៅខេត្តកំពង់ចាម កងកម្លាំងចលនាប្រយុទ្ធនេះ មាន១៣កង ហើយមួយកងៗ មានយុទ្ធជនចំនួន ពី២០០ ទៅ៥០០នាក់។ ចលនាប្រយុទ្ធរបស់ស៊ីវត្ថា ពឹងផ្អែកទៅលើបណ្តាកសិករ។ តាមឯកសារខ្លះទៀតមានការបញ្ជាក់ថា ស៊ីវត្ថា បានទទួលគ្រឿងអាវុធយុទ្ធភណ្ឌពីប្រទេសសៀម តាមខេត្តបាត់ដំបង និងអង្គរ។

កុបកម្មបះបោរក្រោមការដឹកនាំរបស់ស៊ីវត្ថា បានបង្កើតឱ្យមានសេចក្តីលំបាកជាខ្លាំងដល់មហាក្សត្រនរោត្តម និងដល់មេបញ្ជាការកងទ័ពអាណានិគមបារាំង។ នៅឆ្នាំ១៨៨៥ ដោយមានសំណើពីមហាក្សត្រ មហាសង្ឃរាជ ប្រទេសកម្ពុជា បានសាកល្បងធ្វើការចរចាជាមួយស៊ីវត្ថា។ រាជរដ្ឋាភិបាលបានស្នើផ្តល់បៀវត្សរ៍ជាប្រាក់ ចំនួន១០ពាន់រៀលក្នុងមួយឆ្នាំ ហើយបានដាក់លក្ខខណ្ឌដល់ស៊ីវត្ថា ឱ្យដាក់អាវុធ ឈប់ធ្វើយុទ្ធនាការ ក៏ប៉ុន្តែ នៅពេលនោះ ស៊ីវត្ថា បានប្រកែក មិនយល់ព្រមតាមសំណើទាំងនេះ។

កងទ័ពអាណានិគមបារាំង បានប្រយុទ្ធយ៉ាងខ្លាំងប្រឆាំងចលនាស៊ីវត្ថា ក៏ប៉ុន្តែ យុទ្ធជននៃចលនាស៊ីវត្ថា ចេះតែប្រើយុទ្ធសាស្ត្ររបៀបកងអាសាស្ម័គ្រ គឺលាក់បំពួនខ្លួនកាលណាកងកម្លាំងអាណានិគមបារាំង ទៅជិត ហើយងើបធ្វើការវាយប្រហារលើពួកនេះ នៅក្នុងឱកាសដ៏ចាំបាច់។ នៅក្នុងយុទ្ធនាការមួយស៊ីវត្ថា ត្រូវរងរបួស ហើយការប្រយុទ្ធបានស្ងប់ស្ងាត់បន្តិច តែនៅខែសីហា ឆ្នាំ១៨៨៦ នៅពេលដែលបណ្ដារដ្ឋមន្ត្រីរបស់មហាក្សត្រនរោត្តម បានសាកល្បងធ្វើការចរចានឹងអ្នកដឹកនាំនានានៃចលនាស៊ីវត្ថា ក្នុងគោលបំណងលួងលោមឱ្យអ្នកទាំងនេះសុខចិត្តចុះចូលមកខាងមហាក្សត្រ។ អ្នកដឹកនាំចលនាជាច្រើនរូបសុខចិត្តចុះចូលមកខាងមហាក្សត្រ នៅខែកញ្ញា និងខែតុលា ឆ្នាំ១៨៨៦។បន្ទាប់ពីនោះមក ស៊ីវត្ថា ស្ថិតនៅក្នុងស្ថានភាពសឹងឯកោ ហើយបានថយខ្លួនទៅរស់នៅតំបន់ព្រៃនៃប្រទេសជាមួយនឹងយុទ្ធជនដ៏ស្មោះស្ម័គ្រទាំងឡាយនៃចលនា។ នៅឆ្នាំ១៨៩០ អ្នកតំណាងនៃរដ្ឋបាលអាណានិគមបារាំង បានសាកល្បងធ្វើការចរចាជាមួយស៊ីវត្ថា ដោយធ្វើសំណើផ្ដល់ប្រាក់និវត្តន៍ពីរដ្ឋការបារាំង ផ្ទាល់។ប៉ុន្តែ ចំពោះសំណើបែបនេះ នៅទីបំផុត ស៊ីវត្ថាប្រកែក ហើយបានទាមទារឱ្យមានការផ្ដល់ប្រាក់និវត្តន៍ មិនមែនសម្រាប់តែមនុស្សម្នាក់ទេ តែសម្រាប់យុទ្ធជនដទៃនៃចលនាតស៊ូហើយបានទាមទារឱ្យរក្សាឯកសិទ្ធិរបស់វណ្ណៈសក្តិភូមិ។ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៨៩១ ស៊ីវត្ថា ក៏បានទទួលសោយទិវង្គត។ ចលនាប្រយុទ្ធក្រោមការដឹកនាំរបស់ស៊ីវត្ថា បានប្រព្រឹត្តទៅនៅពេលដែលចលនាប្រឆាំង ម្យ៉ាងទៀត បានកើតមានឡើង ចលនាគាំទ្រដោយមហាក្សត្រ និងបណ្ដាមន្ត្រី គឺចលនាមានគោលបំណង

ជាអាទិ៍ប្រឆាំងនឹងកិច្ចព្រមព្រៀងនាឆ្នាំ១៨៨៤ គឺជាកិច្ចព្រមព្រៀងធ្វើឡើងដោយការបង្ខិតបង្ខំ របស់រដ្ឋការអាណានិគមនិយមបារាំង មកលើមហាក្សត្រនរោត្តម។ នៅពេលនោះ ក្នុងការទប់ទល់ប្រឆាំងនឹងរដ្ឋការបារាំង រាជានិយមខ្មែរ ពឹងផ្អែកលើចលនាស្នេហាជាតិប្រជាករដ៏ធំធេង។ គឺដោយសារការគាំទ្របែបនេះហើយ បានជាវណ្ណៈសក្តិភូមិអាចរក្សានូវរបបគ្រប់គ្រងរាជានិយម ដែលធានារ៉ាប់រងដល់ស្ថានភាពនៃឯកសិទ្ធិរបស់វណ្ណៈនេះនៅក្នុងសង្គម។ នៅពេលជាមួយគ្នា រាជានិយមខ្មែរអាចរក្សាទុកនូវឯកសិទ្ធិរបស់វណ្ណៈអភិជនសក្តិភូមិ នៅក្រោមរបបអាណានិគមបារាំង។ គឺស្ថានភាពនេះហើយ ដែលបានជួយជាកម្លាំងដល់របបគ្រប់គ្រងរាជានិយម ឱ្យទៅជាកត្តាពិតនៅប្រទេសកម្ពុជា។ នៅពេលនោះ របបគ្រប់គ្រងរាជានិយមមានសមត្ថកិច្ចជារដ្ឋអំណាចពិតប្រាកដ ហើយតាមឯកសារខ្លះ មានការបញ្ជាក់ថា នៅចុងខែកុម្ភៈ ឆ្នាំ១៨៨៥ មានការធ្វើកំណែនចំពោះបុគ្គលដែលអាចចូលបម្រើកងទ័ព ឱ្យចូលក្នុងកងទ័ពកម្ពុជា ដែលបានប្រុងប្រៀបខ្លួន និងរំខានដល់ការបង្កើតរបបអាណានិគមនៅក្នុងប្រទេស។

នៅសម័យនោះ ចលនាតស៊ូទាំងឡាយ ដែលបានរីកសាយបានក្លាយទៅជាចលនាតស៊ូប្រឆាំងនឹងរបបអាណានិគមនិយមបារាំង នៅប្រទេសកម្ពុជា ព្រមទាំងប្រឆាំងនឹងរបបសក្តិភូមិខ្លះៗ ទោះបី ក្នុងបញ្ហានេះគេពុំទាន់មានឯកសារបញ្ជាក់គ្រប់គ្រាន់ក៏ដោយ។ ចលនាបះបោរបានកើតមានឡើងខ្លាំងនៅតំបន់នានា ប៉ែកខាងត្បូង និងខាងអាគ្នេយ៍នៃប្រទេស។ យុទ្ធជនតស៊ូនៅពេលនោះ បានទាំងប្រើប្រាស់គ្រឿងអាវុធដ៏បូរាណ ដូចជា ធ្នូ ស្នា

កាំបិត ដាវ។ នៅឆ្នាំ១៨៨៦ តំណាងព្រះសង្ឃមួយភាគបានចូលរួបរួមក្នុងចលនាតស៊ូក្នុងការដឹកនាំកងកម្លាំង តាមភូមិទាំងឡាយ។ កងកម្លាំងរបស់ចលនាតស៊ូបែងចែកបានជាបីសណ្ឋាន គឺកងទ័ពតំបន់ ដឹកនាំដោយមន្ត្រីជាន់ចាស់ កងអាសាស្ម័គ្រ (កងឆ្មក់) ព្រមទាំងកងកម្លាំងដែលមានការចូលរួមពីសំណាក់ជនជាតិចិនខ្លះៗនៅប្រទេសកម្ពុជា។ កងទ័ពបារាំង ត្រូវបានឡោមព័ទ្ធនៅពេលនោះ នៅក្នុងទីក្រុង និងនៅតាមបន្ទាយនានាដោយកងអាសាស្ម័គ្រ។ យុទ្ធជនទាំងឡាយនៃចលនាតស៊ូ បានកាន់កាប់ទឹកដីមួយភាគធំនៃប្រទេស បានទាមទារពន្ធដារ បានធ្វើកំណែនមនុស្សឱ្យចូលក្នុងចលនាតស៊ូ។ល។

យុទ្ធជននៃចលនាតស៊ូ បានធ្វើការប្រយុទ្ធយ៉ាងសកម្មអស់រយៈពេលពីរឆ្នាំ។ ពួកគេទាំងឡាយបានច្បាំងតទល់យ៉ាងអង់អាចប្រឆាំងពួកទាហានបារាំង។ នៅពេលណាគេទទួលបរាជ័យម្តងៗ គេបានប្រមូលផ្តុំកម្លាំងដាច់ដោចឡើង និងបានបំពេញជួរដោយយុទ្ធជនថ្មីៗ ហើយលបឆ្មក់វាយសម្រុកលើកងកម្លាំងបារាំង សាជាថ្មី។

នៅពេលនោះ ស្ថានភាពកងទ័ពបារាំង នៅប្រទេសកម្ពុជាមានលក្ខណៈលំបាកដុនដាប ដោយហេតុថា កងកម្លាំងបារាំងមួយភាគ ត្រូវបានដកយកទៅភាគឧត្តរនៃឥណ្ឌូចិន ដើម្បីចូលរួមក្នុងសង្គ្រាមបារាំង-ចិន នាឆ្នាំ១៨៨៤-១៨៨៥ និងដើម្បីបង្ក្រាបកុបកម្មបះបោរនានានៅវៀតណាម។ នៅក្នុងចលនាតស៊ូទាំងនេះមានការបញ្ជាក់ ឱ្យឃើញនូវយុទ្ធសាមគ្គីភាពរវាងអ្នកដឹកនាំចលនាតស៊ូនៅប្រទេសកម្ពុជា និងអ្នកដឹកនាំចលនាតស៊ូនៅប្រទេសវៀតណាម។ ជាឧទាហរណ៍ តាមឯកសារជាសំបុត្រ

ដែលរដ្ឋការអាណានិគមបារាំង ចាប់បាន មានសរសេរថា៖ នាហ្មឺនដាន់ខ្ពស់វៀតណាមនៅខេត្តចូវដុក និងអ្នកតំណាងចលនាតស៊ូខ្មែរនៅខេត្តទ្រាំង បានព្រមព្រៀងគ្នាដើម្បីបញ្ជូន “ អ្នកតំណាងប្រជាជនទាំងពីរឱ្យជួបពិភាក្សាគ្នា ស្ដីអំពីគម្រោងការនៃយុទ្ធនាការរួមគ្នា ”។

ឯកសារនានា ស្ដីអំពីអង្គការរៀបចំចាត់តាំងរបស់អ្នក តស៊ូ អំពីទំនាក់ទំនងនៃយុទ្ធនាការ និងការប្រើប្រាស់កលល្បិចប្រយុទ្ធ នៅសម័យនោះមានតិចតួចពេក។ ក៏ប៉ុន្តែ គេអាចបំពេញសេចក្ដីខ្វះខាតនេះបាន បើគេយោងទៅតាមប្រពៃណីនៃការនិទានតាមមាត់ទទេតៗគ្នារបស់ព្រឹទ្ធាចារ្យ និងរបស់អ្នកចូលរួមក្នុងព្រឹត្តិការណ៍ការតស៊ូទាំងនេះ។ តាមការណ៍ទាំងនេះ គេអាចស្រង់យកប្រវត្តិរបស់អ្នកតស៊ូ ជាវីរជនប្រជាប្រិយពីររូប គឺ៖ក្រឡាហោម គង់ និងមន្ត្រីពិស្ណុលោក ឈូក។ សកម្មភាពតស៊ូរបស់អ្នកទាំងពីរបានចាប់ផ្ដើមឡើងពីឆ្នាំ១៨៨៥ - ១៨៨៦។ ក្រឡាហោម គង់ ជាចៅអធិការវត្តនៅកោះក្របី ដែលស្ថិតនៅតាមទន្លេបាសាក់ នៅខាងត្បូងភ្នំពេញ។ លោកបានក្លាយទៅជាអ្នកដឹកនាំកុបកម្មបះបោរបន្ទាប់ពីកងទ័ពអាណានិគមនិយមបារាំង បានវាយលុកវត្ត ហើយធ្វើទុក្ខទោសដល់អ្នកកាន់ពុទ្ធសាសនា នៅកោះក្របី ដើម្បីតាមរកចាប់អ្នកតស៊ូ។ មុនដំបូង ចលនាតស៊ូក្រោមការដឹកនាំក្រឡាហោម គង់ បានធ្វើយុទ្ធនាការនៅត្រើយខាងស្ដាំទន្លេបាសាក់ ហើយបានធ្វើចម្បាំងចេញមុខតទល់នឹងពួកទាហានបារាំង។ ក៏ប៉ុន្តែ ដោយទាហានបារាំង មានកម្លាំងលើសលប់ក្នុងការប្រើប្រាស់គ្រឿងអាវុធទំនើបៗ ចលនាតស៊ូនេះបានប្រើយុទ្ធសាស្ត្រធ្វើចម្បាំងលបធ្មក់។ នៅពេលនោះ នៅក្រោមកិច្ចបញ្ជាការរបស់

ក្រឡាហោម គង់ មានកងកម្លាំងទ័ពមួយយ៉ាងធំ។ ក្នុងយុទ្ធនាការរបស់ខ្លួន យុទ្ធជនតស៊ូបានប្រើដំរីសម្រាប់ការចម្លងតាមទីថ្លុកត្រពាំង ប្រើទ័ពសេះសម្រាប់ការទាក់ទង ប្រើរទេះគោក្របីសម្រាប់ដឹកស្បៀង និងគ្រាប់រំសេវ។ ក្រឡាហោម គង់ បានសាកល្បងបង្រួបបង្រួមកងកម្លាំងយុទ្ធទាំងប្រាំបួន ដែលធ្វើការតស៊ូនៅខាងត្បូងភ្នំពេញ ឱ្យស្ថិតនៅក្រោមបញ្ជាការតែមួយ។ ក៏ប៉ុន្តែ ក្នុងការអំពាវនាវនេះមានតែចលនាតស៊ូក្រោមកិច្ចបញ្ជាការរបស់ពិស្ណុលោក ឈូក តែមួយដែលយល់ព្រមតាម។ ពិស្ណុលោកឈូក បានធ្វើជាមន្ត្រីនៅខេត្តទ្រាំង ហើយស្រុកចំនួនប្រាំពីរនៅខេត្តនេះ ស្ថិតនៅក្រោមសមត្ថកិច្ចមន្ត្រីរបស់គាត់។ នៅពេលដែលពួកអាណានិគម ចូលមកតែងតាំងអំណាចរបស់ខ្លួននៅប្រទេសកម្ពុជា លោកបានចាកចេញពីតំណែងដោយទទួលការយល់ព្រមពីមហាក្សត្រ ហើយបានអំពាវនាវដល់នាហ្មឺន និងអ្នកស្រុកទាំងឡាយក្នុងខេត្ត ឱ្យចេញធ្វើការតស៊ូប្រឆាំងនឹងពួកអាណានិគមបារាំង។

ម្តងនេះ ចលនាតស៊ូក្រោមកិច្ចបញ្ជាការរបស់ក្រឡាហោម គង់ និងពិស្ណុលោក ឈូក បានធ្វើយុទ្ធនាការរួមគ្នាវាយប្រហារលើកងទ័ពបារាំង ឱ្យមានការខូចខាតជាខ្លាំង។ ការប្រយុទ្ធដ៏ធំបំផុត ដោយមានការចូលរួមរបស់យុទ្ធជនចំនួន៥ពាន់នាក់បានប្រព្រឹត្តទៅនៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៨៨៥ ក្នុងគោលដៅដើម្បីវាយដណ្តើមយករដ្ឋធានីភ្នំពេញ (តាមឯកសារខ្លះ មានការបញ្ជាក់ថា នៅឆ្នាំ១៨៨៦)។ ការសាកល្បងវាយលុកចូលភ្នំពេញនៅពេលនោះ មិនបានទទួលជោគជ័យ ដោយហេតុថាម្យ៉ាងកងកម្លាំងនានា នៃអ្នកតស៊ូពុំអាចបង្រួបបង្រួមកម្លាំងគ្នា

ឱ្យបានរឹងមាំ ហើយម្យ៉ាងទៀត ការវាយលុកនេះបានចាប់ផ្តើមធ្វើឡើងមុនពេលមកដល់នៃកងកម្លាំងក្រោមកិច្ចបញ្ជាការរបស់ក្រឡាហោម គង់ និងពិស្ណុលោក ឈូក។ បន្ទាប់ពីពេលដែលកងទ័ពអាណានិគមបារាំង ទទួលការខូចខាតយ៉ាងដំណំ (នៅឆ្នាំ១៨៨៦) មហាក្សត្រនរោត្តម បានធ្វើសេចក្តីអំពាវនាវដល់ចលនាតស៊ូទាំងឡាយឱ្យបញ្ឈប់សង្គ្រាម។ គេបានធ្វើសេចក្តីអញ្ជើញក្រឡាហោម គង់ និងពិស្ណុលោក ឈូក ឱ្យមកកាន់កាប់បរមរាជវាំង។ នៅពេលនោះ ដោយមានបំណងបំបាត់សត្រូវដ៏សកម្មរបស់ខ្លួន ពួកអាណានិគមបារាំង បានអញ្ជើញក្រឡាហោម គង់ ឱ្យមកឡើងលើកប៉ាល់យោធា ហើយប្រើកលល្បិចលបចាប់បញ្ជូនក្រឡាហោម គង់ ទៅឱ្យតុលាការកាត់ទោសប្រហារជីវិតយ៉ាងសាហាវបំផុត។ រីឯ ពិស្ណុលោក ឈូក វិញ តាមរឿងនិទានខ្មែរ លោកត្រូវបានពួកភ្នាក់ងារបារាំង លួចធ្វើឃាតនៅគេហដ្ឋានបងប្អូនរបស់លោកនៅភ្នំពេញ។

តាមរឿងនិទានក្តី តាមសេចក្តីនៃរបាយការណ៍យោធាបារាំងក្តី មានការសង្កេតឃើញថា ចលនាតស៊ូខ្មែរនានានៅពេលនោះ ពុំមានឯកភាពរឹងមាំរវាងគ្នាឡើយ។ អ្នកដឹកនាំចលនាតស៊ូនីមួយៗ ទោះបីអ្នកដឹកនាំនោះជាមន្ត្រីជំនាន់ចាស់ក្តីក៏ពុំដែលមានការព្រមព្រៀងគ្នា ក្នុងការប្រយុទ្ធរួមគ្នាប្រឆាំងនឹងអាណានិគមបារាំង ដែរ។ ចលនាតស៊ូនីមួយៗបានធ្វើការប្រយុទ្ធដោយពឹងផ្អែកតែទៅលើកងកម្លាំងផ្ទាល់ខ្លួន ហើយជួនកាល មានកើតទំនាស់រវាងអ្នកដឹកនាំផ្សេងៗទៀតផង។

ភាពកង្វះសាមគ្គីភាព រវាងចលនាតស៊ូនានាមានកម្រិតកាន់តែខ្ពស់ខ្លាំង នៅពេលបន្ទាប់ពីពួកអាណានិគមបារាំង បាន

ចុះហត្ថលេខាលើកិច្ចព្រមព្រៀង នាឆ្នាំ១៨៨៦ ដែលនៅក្នុងនេះ មានការយល់ព្រមប្រគល់មុខងារខាងរដ្ឋបាលមកឱ្យមហាក្សត្រ និងអស់មុខមន្ត្រីខ្មែរវិញ។

គេអាចធ្វើការសន្និដ្ឋានបានថា មិនមែនអ្នកដឹកនាំចលនាតស៊ូ និងមុខមន្ត្រីអមមហាក្សត្រទាំងអស់ យល់ព្រមតាមសេចក្តីអំពាវនាវឱ្យបញ្ឈប់យុទ្ធនាការទេ។ នៅក្នុងស្ថានភាពបែបនេះ បន្ទាប់ពីមានការប្រកាសសេចក្តីអំពាវនាវរបស់ព្រះបាទនរោត្តម ក្រឡាហោម គង់ បានឆ្លើយតបទៅព្រះមហាក្សត្រ វិញថា៖ “ព្រះករុណាថ្លៃវិសេស ទូលបង្គំនឹងអាចដាក់អាវុធចុះឈប់ច្បាំងមួយគ្រា ហើយធ្វើការសង្កេត តើស្ថានភាពផ្លាស់ប្តូរយ៉ាងណាខ្លះនៅក្នុងប្រទេស។ បើសិនជាពួកបារាំង នឹងចាប់ផ្តើមធ្វើចម្បាំងឡើងវិញនោះ ទូលបង្គំយើងខ្ញុំនឹងកាន់អាវុធនៅដៃសាជាថ្មីដើម្បីធ្វើការតស៊ូប្រឆាំងអំពើអយុត្តិធម៌ រហូតដល់ដំណាក់ឈាមចុងក្រោយបង្អស់”។ នៅក្នុងចម្លើយតបទៅក្រឡាហោម គង់ វិញ ព្រះមហាក្សត្របានបញ្ចេញយោបល់ថា៖ “ការតទល់ប្រឆាំងនឹងពួកបារាំង ដែលប្រកបដោយគ្រឿងអាវុធដ៏ទំនើបៗជាការឥតប្រយោជន៍”។ ចំពោះយោបល់មហាក្សត្របែបនេះ ក្រឡាហោម គង់ បានឆ្លើយតបទៀតថា៖ “ព្រះករុណាថ្លៃវិសេស ទូលបង្គំយើងខ្ញុំយល់ឃើញថា ពួកបារាំង មិនអាចច្បាំងឈ្នះយើងបានទេ បើសិនប្រជាជនទាំងមូលបន្តការតស៊ូទៅមុខទៀត”។

គេអាចសង្កេតឃើញម្យ៉ាងទៀតថា ភាពកង្វះឯកភាពនៅក្នុងចលនាតស៊ូប្រជាជនកម្ពុជា នាឆ្នាំ១៨៨៤-១៨៨៦ ស្ថិតនៅលើសមាសភាពនៃជនជាតិនានា នៃប្រទេសលើសភាពខុសគ្នារវាងជនជាតិ និងសាសនា។ គឺកត្តាទាំងនេះហើយ ដែលពួក

អាណានិគមបារាំង បានប្រើប្រាស់នៅក្នុងការតទល់នឹងចលនាតស៊ូនានា។ ជាឧទាហរណ៍ នៅក្នុងចម្បាំងបង្ក្រាបចលនាតស៊ូដឹកនាំដោយស៊ីវត្ថា ពួកបារាំង បានប្រើប្រាស់ជនជាតិម៉ាឡាយូ និងជនជាតិដទៃទៀត។ ពួកអាណានិគមបារាំង បានបណ្ដាញភ្នាក់ងារជាច្រើនរបស់ខ្លួន ដែលជាអ្នកឱ្យការណ៍ ជាអ្នកនាំផ្លូវក្នុងបណ្ដាអ្នកស្រុកទីអាយ។ ដោយសារការចូលដៃទាំងនេះ ពួកបារាំង មានលទ្ធភាពដើម្បីចាប់ឃុំឃាំង និងបំបាត់ជនដែលពួកវាមិនពេញចិត្ត ជាពិសេសគឺបណ្ដាអ្នកដឹកនាំចលនាតស៊ូដ៏ប៉ិនប្រសប់។

នៅក្នុងចលនាតស៊ូទាំងនេះ រមែងមានការគាំទ្រពីសំណាក់កសិករនៅស្រុកស្រែ។ ស្របតាមលក្ខណៈនៃការវិវត្តនៃទស្សនៈនាសម័យនោះ កសិករខ្លះបានគាំទ្រដល់បណ្ដាអ្នកដឹកនាំចលនាតស៊ូណា ដែលបានប្រកាសខ្លួនថា ជាអ្នកជាប់សាច់ញាតិនឹងរាជវង្សានុវង្ស ហើយមានបំណងធ្វើចម្បាំងដើម្បីដណ្ដើមយករាជសម្បត្តិ។ កសិករខ្លះទៀត បានគាំទ្រដល់ចលនាប្រឆាំងនឹងអាណានិគមនិយមបារាំង ហើយដោយមានសេចក្ដីសង្ឃឹមថានឹងមានការផ្លាស់ប្ដូររបបគ្រប់គ្រងនៅក្នុងប្រទេស។ ប៉ុន្តែ ចលនាតស៊ូទាំងអស់ បានច្បាំងតទល់នឹងពួកទាហានអាណានិគមបារាំង ដោយហេតុថា រដ្ឋការអាណានិគមបារាំង បានស្ថិតនៅខាងព្រះបាទនរោត្តម ព្រោះព្រះបាទនរោត្តម បានទទួលស្គាល់នូវរដ្ឋអំណាចនៃពួកអាណានិគមបារាំង។ មានការលើកលែងតែចលនាកុបកម្មបះបោរប្រជាករប្រឆាំងពួកអាណានិគមបារាំង នៅឆ្នាំ ១៨៨៤ - ១៨៨៦ គាំទ្រដោយព្រះមហាក្សត្រ និងរាជវង្សានុវង្ស។

បណ្ដាអ្នកដឹកនាំចលនាតស៊ូនៅសម័យនោះ មានស្ថានភាពសង្គមប្លែកៗគ្នា។ អ្នកដឹកនាំខ្លះជានាហ្មឺន ឬមន្ត្រីជាន់ចាស់ ដែលលេចចេញពីវណ្ណៈជាន់ខ្ពស់នៃសង្គម ហើយចលនាកុបកម្មបែបនេះបានកើតមានឡើងដោយកំហឹងចំពោះការបាត់បង់បុព្វសិទ្ធិ អំណាច និងចំណូលតាមរបបសក្តិភូមិ។ អ្នកដឹកនាំខ្លះទៀត គឺជាអ្នកតំណាងនៃអ្នកកាន់ពុទ្ធសាសនា។ ពួកអាណានិគមបារាំងទទួលជ័យជម្នះលើចលនាតស៊ូនានាជាបន្តបន្ទាប់ ដោយការប្រើប្រាស់កលល្បិចគ្រប់បែបយ៉ាងចំពោះអ្នកដឹកនាំចលនាតស៊ូនានាតាំងពីការទិញទឹកចិត្ត រហូតដល់ការចាប់ឃុំឃាំងធ្វើទុក្ខទោសសម្លាប់ជីវិត។

កិច្ចព្រមព្រៀងនាឆ្នាំ១៨៨៦ មានអត្ថន័យសម្រាប់ពួកអាណានិគមបារាំង គឺគ្រាន់តែជាការបន្ធូរបន្ថយបណ្ដោះអាសន្នប៉ុណ្ណោះ។ សម្រាប់មហាក្សត្រនរោត្ដម គឺជាមធ្យោបាយសម្រាប់ពង្រឹងអំណាចរាជបល្ល័ង្កដែលទន់ខ្សោយ ដោយហេតុថា នៅពេលនោះ អ្នកដឹកនាំចលនាតស៊ូខ្លះមិនមែនគ្រាន់តែបះបោរប្រឆាំងពួកបារាំង ដើម្បីការពាររាជានិយមព្រះបាទនរោត្ដម ទេ ប៉ុន្តែ បានចិញ្ចឹមគោលបំណងដើម្បីសម្រេចផែនការផ្ទាល់ខ្លួនទៀតផង។ កុបកម្មបះបោរប្រឆាំងបារាំង ចេះតែកើតមានឡើងបន្តបន្ទាប់ រហូតដល់ឆ្នាំ១៨៩៦ ដែលជាសម័យខាងចុងក្នុងរាជ្យព្រះបាទនរោត្ដម។

បាតុកម្មបះបោរប្រឆាំងបារាំង ទូទៅ នៅប្រទេសកម្ពុជាមានលក្ខណៈប្រជាជន ហើយពន្លកនៃសាមគ្គីភាពរវាងចលនាតស៊ូនៅប្រទេសវៀតណាម និងនៅប្រទេសឡាវ បានលូតលាស់បង្កើតជាមូលដ្ឋាននៃការតស៊ូរួមគ្នាទៅអនាគត របស់ប្រជាជន

នានានៅឥណ្ឌូចិន ដើម្បីការរំដោះប្រទេសពីនឹមអាណានិគមនិយមបារាំង ដើម្បីអធិបតេយ្យភាពរបស់ប្រទេសជាតិ។

នៅសម័យកាលក្រោយៗមក មនោគមវិជ្ជាដែលដឹកនាំចលនាតស៊ូប្រជាជនខ្មែរ ពឹងផ្អែកមួយភាគធំទៅលើ " វណ្ណៈកសិករ " ហើយគ្មានលក្ខណៈអ្វីប្រហាក់ប្រហែលនឹងចលនាកុបកម្មបះបោរដែលមានលាយឡំនឹងឥទ្ធិពលរបស់រាជានិយមសក្តិភូមិនាសម័យកាលទសវត្សរ៍ទី៨ នៃសតវត្សរ៍ទី១៩ឡើយ។ ហើយការណ៍នេះ គេមិនពិបាកយល់ទេ ព្រោះថា មន្ត្រីសក្តិភូមិជាន់ខ្ពស់ខ្លះៗដែលបានធ្វើជាអ្នកដឹកនាំចលនាកុបកម្មបះបោរ បានប្រែខ្លួនទៅជាអ្នកបម្រើដ៏ស្លូតបូត របស់ពួកអាណានិគមបារាំង ដោយបានធ្វើជានាហ្មឺននៅក្នុងរដ្ឋបាលបារាំង។

បន្ទាប់ពីការតែងតាំងរបបអាណានិគមបារាំង នៅក្នុងប្រទេស និងបន្ទាប់ពីពេលដែលប្រទេសកម្ពុជា បានចូលក្នុងសហភាពឥណ្ឌូចិន កំហឹងរបស់វណ្ណៈកសិករបានរីកសាយកាន់តែធំ ដោយមានការដំឡើងពន្ធដារ និងអំពើពុករលួយដែលបានកើតមានតាំងពីពេលក្រោយការតែងតាំង របបអាណានិគមបារាំង នៅក្នុងប្រទេស។

តទៅអនាគត សន្ទុះនៃចលនាតស៊ូរំដោះប្រទេសជាតិរបស់ប្រជាជនខ្មែរ មានទំនាក់ទំនងនឹងសម័យកាលនៃការចាប់ផ្តើមកកើតប្រព័ន្ធមូលធននិយម ដែលបានបង្កើតឱ្យមានវណ្ណៈគហបតី នៅក្នុងប្រទេសកម្ពុជា។

# ចំពូកទី៤
## ប្រទេសកម្ពុជា នៅក្នុងសម័យកាល នៃរបប អាណាព្យាបាលរបស់ប្រទេសបារាំង

នៅសម័យកាលខាងដើមសតវត្សរ៍ទី២០ មូលដ្ឋាននៃរបបគ្រប់គ្រងអាណានិគមបារាំង នៅប្រទេសកម្ពុជា បានលូតលាស់វិវឌ្ឍជាបន្តបន្ទាប់ រហូតដល់ឆ្នាំ១៩៤៥ គឺជាពេលដែលអំណាចយោធានិយមជប៉ុន បានបង្កើតរដ្ឋប្រហារ ហើយបានរំលំរបបគ្រប់គ្រងអាណានិគមនិយមបារាំង ទាំងមូលនៅប្រទេសកម្ពុជា។ សម័យកាលប្រវត្តិសាស្រ្តបែបនេះនៃប្រទេស បានស្ថិតនៅក្នុងសម័យកាលនៃការសោយរាជសម្បត្តិ របស់មហាក្សត្រស៊ីសុវត្ថិ (១៩០៤ - ១៩២៧) និងមហាក្សត្រមុនីវង្ស (១៩២៧ - ១៩៤១)។

សម្រាប់បណ្តាប្រទេសមូលធននានា មានទាំងប្រទេសបារាំង ...ជាដើម សម័យកាលខាងចុងសតវត្សរ៍ទី១៩ និងខាងដើមសតវត្សរ៍ទី២០ បានវិវឌ្ឍទៅដោយការកកើតនូវរបបចក្រពត្តិនិយម ដែលជាសភាពការណ៍ស្របទៅតាមសម្តីរបស់ វ.ឥ. ឡេនីន ដែលបានបញ្ជាក់ថា៖ “ គឺមានមូលធននិយមនៅក្នុងកម្រិតនៃការលូតលាស់បែបនេះ បានសេចក្តីថា កាលណារបបផ្តាច់ការនៃផ្សារផ្តាច់មុខ និងមូលធនខាងហិរញ្ញវត្ថុ បានកកើតមានឡើង កាលណាការនាំចេញ នៃមូលធនបានបំពេញតួនាទីដ៏សំខាន់ កាលណាមានការចាប់ផ្តើមបែងចែកពិភពលោក ជាផ្សារអន្តរ

ជាតិធំៗ កាលណាមានការបញ្ចប់ការបែងចែកទឹកដីទាំងនៅលើផែនដី ដោយប្រទេសមូលធននិយមធំៗ ” * ។

នៅឆ្នាំ១៩០០ នៅប្រទេសកម្ពុជា ជនជាតិអឺរ៉ុប មានដីចម្ការធំៗទាំងអស់ ១៥កន្លែង ដែលមានទំហំ២៣៥ហិកតា។ នេះគឺជាការសាកល្បងជាលើកទីមួយ នៅក្នុងការបង្កើតកសិដ្ឋានដំណាំតាមរបៀបមូលធននិយម ជាពិសេស កសិដ្ឋានសម្រាប់ធ្វើដំណាំស្រូវ។ នៅក្នុងការលូតលាស់នៃមូលធននិយមនៅក្នុងវិស័យឧស្សាហកម្ម ដែលជាដំណាក់កាលចម្លងប្រទេសបារាំង ទៅកាន់ដំណាក់កាលចក្រពត្តិនិយម។ នៅប្រទេសកម្ពុជា មានការផ្លាស់ប្តូរជាច្រើននៅក្នុងវិស័យសង្គមកិច្ច ដែលបានលេចចេញជារូបរាងនៅក្នុងលក្ខខណ្ឌ នៃការរីកចម្រើនទំនាក់ទំនងតាមបែបមូលធននិយម នៃការកកើតកម្លាំងជាមូលដ្ឋាននៅក្នុងសង្គមមូលធននិយម គឺវណ្ណៈអធន ពលករ និងវណ្ណៈគហបតី។ នៅក្នុងស្ថានភាពរបបផ្តាច់ការនៃផ្សារផ្តាច់មុខរបស់មូលធន និងដោយមានសង្វាក់យឺតយ៉ាវ ក្នុងដំណើរលំរលាយនៃទំនាក់ទំនងចាស់តាមបែបសក្តិភូមិ នៅប្រទេសកម្ពុជា ការវិវត្តសង្គមតាមរបៀបមូលធននិយមបែបនេះ មានសង្វាក់ដ៏យឺតបំផុត។

រហូតមកដល់សម័យសង្គ្រាមលោកលើកទីមួយ មូលធនហិរញ្ញវត្ថុបារាំង ខិតខំបង្កើតលក្ខខណ្ឌដ៏ចាំបាច់ ដើម្បីទាក់ទាញដើមទុនឯកជនបារាំង ឱ្យចូលហ៊ុនក្នុងវិស័យសំខាន់ៗនៃសេដ្ឋកិច្ចប្រទេសកម្ពុជា។ ក៏ប៉ុន្តែ ដើមទុនបារាំង សម្រាប់ចូលហ៊ុននៅ

---

* ១- វ.ឥ. ឡេនីន - “ ចក្រពត្តិនិយម ជាកម្រិតខ្ពស់ នៃមូលធននិយម ” -កម្រងស្នាដៃពេញលេញ ក្បាលទី៧ ទំព័រ ៣៨៧។

ប្រទេសកម្ពុជា បានមកដល់យឺតបន្តិច គឺនៅសម័យកាលក្នុងរង្វង់ឆ្នាំ១៩២០។

វិបត្តិសេដ្ឋកិច្ចពិភពលោកនាឆ្នាំ១៩២៩ - ១៩៣៣ បានជះចំហាយដ៏អាក្រក់មកលើវិស័យកសិកម្ម នៃប្រទេសកម្ពុជា ដោយហេតុថា ឥទ្ធិពលបែបនេះបានបន្ទាញឱ្យមានការតម្លៃឥវ៉ាន់នាំចេញ ឱ្យមានការកម្រិតពាណិជ្ជកម្មក្រៅប្រទេស និងផលិតកម្មកសិកម្មក្នុងស្រុក។ កត្តាទាំងនេះបណ្តាលឱ្យស្ថានភាពរបស់ប្រជាពលករចុះដុនដាប ហើយជំរុញឱ្យមានការពន្លឿនបណ្តាចលនារំដោះជាតិនៅប្រទេសកម្ពុជា ក៏ដូចជានៅប្រទេសជិតខាងដទៃនៅឥណ្ឌូចិន ដែលស្ថិតនៅក្រោមរបបគ្រប់គ្រងនៃអាណានិគមបារាំង។ វិបត្តិសេដ្ឋកិច្ចបានផ្តល់លទ្ធភាពឱ្យមានការប្រមូលផ្តុំមូលធននៅក្នុងកណ្តាប់ដៃ របស់ក្រុមហ៊ុនពាណិជ្ជកម្មផ្តាច់មុខធំៗជាងគេ។

ចាប់តាំងពីសម័យកាល នៃពេលពាក់កណ្តាលទសវត្សរ៍ទី៣ រហូតដល់សម័យកាល នៃការចាប់ផ្តើមសង្គ្រាមលោកលើកទីពីរ សេដ្ឋកិច្ចប្រទេសកម្ពុជា បានលូតលាស់ដោយសង្វាក់ខ្លាំងក្លា។ នៅក្នុងស្ថានភាពនៃការរៀបចំសង្គ្រាមលោកបែបនេះ ប្រទេសកម្ពុជា បាននាំចេញនូវផលិតផលកសិកម្មដ៏សំខាន់របស់ខ្លួន គឺស្រូវ និងកៅស៊ូ។ ដើមទុនបារាំង ក៏កាន់តែហូរចូលមកប្រទេសកម្ពុជា។ រីឯ ក្រុមហ៊ុនពាណិជ្ជកម្មផ្តាច់មុខក៏កាន់តែបានប្រាក់ចំណេញយ៉ាងច្រើន។ ជីវភាពខាងសេដ្ឋកិច្ចទាំងមូលនៅប្រទេសនានានៅឥណ្ឌូចិន មានទាំងប្រទេសកម្ពុជា...ជាដើម ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ “ ធនាគារឥណ្ឌូចិន ”។ នៅមុនសម័យសង្គ្រាមលោកលើកទីពីរ ប្រទេសនានានៅឥណ្ឌូចិន ប្រែទៅជា

ប្រទេសផលិតករ ផលិតកម្មកសិកម្ម និងវត្ថុធាតុដើម សម្រាប់ប្រទេសបារាំង។

ការកកើតនៃទំនាក់ទំនងតាមបែបមូលធននិយម និងការបង្កើតប្រព័ន្ធរបបអាណានិគម នៃអំពើជិះជាន់លើប្រទេសកម្ពុជា បានផ្តល់ឥទ្ធិពលជាពិសេសទៅលើស្ថានភាពកសិករ។ នៅប្រទេសកម្ពុជា ដែលប្រកបដោយកម្មសិទ្ធិលើដីធ្លី មានកសិករមធ្យម និងកសិករ ដែលមានដីស្រែចម្ការតូចតាច។ ដើម្បីបង់ពន្ធដារជាប្រាក់កាសដល់រាជការ ជាពន្ធដារតាក់តែងឡើងដោយរបបអាណានិគមបារាំង កសិករទាំងឡាយបានបែរទៅរកការពង្រីកដំណាំឧស្សាហកម្ម មានដំណាំកៅស៊ូ ជាអាទិ ហើយមិនតែប៉ុណ្ណោះ គេទាំងឡាយបានទាំងពង្រីកដំណាំជាប្រពៃណីទៀតផង ដូចជា ស្រូវ ពោត ដែលជាផលិតកម្មកសិកម្មដ៏សំខាន់សម្រាប់ការនាំចេញទៅក្រៅប្រទេស។ ក៏ប៉ុន្តែ ទោះបីមានការខិតខំយ៉ាងដូច្នេះក្តី ក៏ផលដំណាំនៅក្នុងសម័យអាណានិគម នៅមិនសូវបានចម្រើន ហើយក្នុងមួយហិកតា បានផលស្រូវ ពី១ ដល់១,២តោន។ ដូច្នេះហើយ បានជាកសិករក្រីក្រទៅជាមនុស្សជាប់បំណុលនឹងអ្នកឈ្មួញកណ្តាល ឬឈ្មួញឯកជនជាពិសេសជនជាតិចិន បារាំង ឥណ្ឌា វៀតណាម ដែលរស់នៅស្រុកស្រែចម្ការ ក៏ដូចជានៅទីក្រុង។ ជីវភាពរស់នៅឆ្ងាយពីទីផ្សារបណ្តាលឱ្យកសិករ មានការទាក់ទាមកាន់តែខ្លាំងនឹងអ្នកជំនួញដែលជាអ្នកចងការប្រាក់។ ម្ល៉ោះហើយ ប្រាក់បំណុលកសិករកាន់តែកើន ហើយសេចក្តីខ្វះខាតមធ្យោបាយជាប្រាក់កាសបានបង្ខំឱ្យកសិករខ្ចីប្រាក់ ពីអ្នកចងការប្រាក់ដែលមិនមែនជា

ជនជាតិខ្មែរ។ ចំណែកការប្រាក់នៅពេលនោះ គឺមានកម្រិតខ្ពស់បំផុត។

សកម្មភាពរបស់ពួកអាណានិគមបារាំង នៅប្រទេសកម្ពុជាមានគោលដៅដើម្បីបង្កបង្កើតឱ្យមាន វណ្ណៈអ្នកម្ចាស់ដីធំៗពីសំណាក់ពួកសក្តិភូមិជាន់ខ្ពស់ និងពីសំណាក់ពួកនាហ្មឺនវណ្ណៈគហបតី។ អ្នកម្ចាស់ដីធំៗ គឺជាអ្នកតំណាងក្រុមហ៊ុនជនជាតិអឺរ៉ុប និងបុគ្គលជាឯកជននានា ដែលបានទទួលច្បាប់កាន់កាប់ដីស្រែធំៗ។

ការនាំចូលឥវ៉ាន់ផលិតពីទ្វីបអឺរ៉ុប មកលក់នៅប្រទេសកម្ពុជា មិនបានធ្វើឱ្យទន់ខ្សោយដល់របរសិប្បកម្មនៅក្នុងប្រទេសណាស់ណាទេ ហើយមានតែវិស័យសិប្បកម្មខ្លះបានចុះអន់ថយដូចជា៖ ផលិតកម្មក្រណាត់សំពត់ គ្រឿងភេសជ្ជៈ ស្រា អំបិល។ ជាទូទៅ នៅក្នុងវិស័យដទៃទៀត ដូចជា ផលិតកម្មគ្រឿងបរិភោគ គ្រឿងចានឆ្នាំង គ្រឿងចម្លាក់លើភ្លុកដំរី គ្រឿងមាសប្រាក់ និងសំរឹទ្ធ។ របរទាំងអស់នេះមានដំណើរដូចប្រក្រតី ហើយមិនតែប៉ុណ្ណោះ ថែមទាំងមានការនាំចេញគ្រឿងផលិតទាំងនេះទៅបរទេសទៀតផង។ ប្រភពនៃដំណើរការដ៏ល្អប្រសើរនៅក្នុងវិស័យសិប្បកម្ម កើតឡើងដោយសារការទាក់ទងដ៏ល្អរវាងសិប្បករទាំងឡាយ និងស្រុកស្រែ ដែលជាស្រុកកំណើតរបស់ខ្លួន ហើយដែលមានដីទំនេរច្រើន។ នៅពេលណាមានការខាតបង់ក្នុងមុខរបរ សិប្បករអាចប្រែត្រឡប់ទៅជាកសិករវិញបាន។

សេចក្តីត្រូវការក្របខ័ណ្ឌជាតិនៃប្រទេសកម្ពុជា បានតម្រូវឱ្យរដ្ឋការអាណានិគមបង្កើតមជ្ឈមណ្ឌលសិក្សាតាមរបៀបអឺរ៉ុបសម្រាប់ស្រទាប់បណ្តាជនខ្លះៗ។ ហេតុនេះហើយ បានជានៅ

ប្រទេសកម្ពុជា នាចុងសម័យនៃទសវត្សរ៍ទី២ និងនាសម័យដើមទសវត្សរ៍ទី៣ បញ្ញវន្តជាតិបានកើតមានឡើងជាលំដាប់។

លក្ខណៈពិសេសនាសម័យដើមសតវត្សរ៍ទី២០ គឺការពង្រឹងខាងនយោបាយនៃរបបអាណានិគមបារាំង និងការង្កើតរដ្ឋការអាណានិគមនៅប្រទេសកម្ពុជា និងនៅឥណ្ឌូចិន ទាំងមូល។ ការណ៍ទាំងអស់នេះ បានដើរតួនាទីដ៏សំខាន់ក្នុងការពង្រឹងអំពើជិះជាន់របស់របបអាណានិគម និងការបង្កើតលក្ខខណ្ឌនានាសម្រាប់ការកៀបសង្កត់ដោយមូលធនហិរញ្ញវត្ថុ។ នៅក្នុងកិច្ចការទាំងអស់នេះ គឺរដ្ឋាភិបាលបារាំង ដែលទទួលខុសត្រូវក្នុងការចំណាយដ៏ចាំបាច់គ្រប់បែបយ៉ាង ដើម្បីអនុវត្តជាធរមាននូវនយោបាយអាណានិគម នៅក្នុងធ្វើចម្បាំងដើម្បីកាន់កាប់ទឹកដី នៅក្នុងការងារស្រាវជ្រាវ ឬត្រួសត្រាយដែនដីថ្មីៗ។ ប៉ុន្តែ ប្រាក់ចំណាយទាំងនេះ បានមកដោយសារពន្ធដារទារយកពីប្រជាជនបារាំង។ ហេតុដូច្នេះហើយ បានជាពួកអាណានិគមតែងតែខិតខំរិះរកមូលហេតុ ដ៏សមហេតុផលនៅលើមូលដ្ឋាន មនោគមវិជ្ជា ដើម្បីបង្ហាញនូវភាពត្រឹមត្រូវ នៃនយោបាយអាណានិគមរបស់ខ្លួន។ មូលហេតុបែបនេះ ត្រូវបានធ្វើឡើងដើម្បីលើកទឹកចិត្តដល់អ្នកបង់ពន្ធដារបារាំង បញ្ជាក់ដល់ពួកគេទាំងឡាយឱ្យយល់ច្បាស់នូវភាពចាំបាច់ក្នុងការចំណាយថ្មីៗ ដែលនៅទីបំផុតប្រាក់ចំណាយទាំងនេះ ត្រូវបានហូរចូលហោប៉ៅរបស់ពួកអ្នកកាន់កាប់ផ្សារអន្តរជាតិផ្តាច់មុខ និងរបស់នាយទុន ដែលទុកប្រាក់នៅធនាគារ។

នៅពេលដែលរដ្ឋបាលបារាំង បានត្រួសត្រាយនូវដែនដីអាណានិគមរបស់ខ្លួន ពួកអាណានិគមមានបំណងចង់ “ស្រង់

យកប្រាក់ចំណេញ"មកវិញ ដោយបង្ខំឱ្យប្រជាជនទីអាយទទួលបន្ទុកយ៉ាងធ្ងន់ក្នុងការចំណាយដ៏សំខាន់ៗ ដើម្បីផ្គត់ផ្គង់ដល់រដ្ឋការអាណានិគម និងរដ្ឋបាលរបស់ប្រទេសនៅទីអាយ ដើម្បីបំពេញការងារគ្រប់បែបយ៉ាង ជាពិសេស គឺពួកនេះបានធ្វើយ៉ាងណាដើម្បីឱ្យមូលធនបារាំង បានចំណេញច្រើន។

ក្នុងការកៀបសង្កត់លើដែនដីអាណានិគម របស់ខ្លួននៅឥណ្ឌូចិន ប្រទេសបារាំង បានបង្កើតប្រព័ន្ធពន្ធដារចំពោះមុខលើប្រាក់ ក៏ប៉ុន្តែ មានដើមទុនតិចចូលហ៊ុននៅក្នុងវិស័យឧស្សាហកម្ម។ ស្ថានភាពទន់ខ្សោយនៃដែនដីអាណានិគមខាងសេដ្ឋកិច្ចតម្រូវឱ្យអាណានិគមបារាំង បំពេញភាពទន់ខ្សោយនេះដោយការពង្រឹងរបបការិយាល័យនិយម របស់ខ្លួនតាមការបំពេញការងារដោយបង្ខំ។ នៅទីបំផុត ការប្រើវិធីក្រៅពីវិធានការសេដ្ឋកិច្ចនៅក្នុងការកៀបសង្កត់ដែនដីអាណានិគម បានទៅជារបៀបចាត់ការងារទូទៅរបស់ពួកអាណានិគមបារាំង ដោយយោងទៅតាមការលូតលាស់តែខាងវិស័យមួយបែប នៃសេដ្ឋកិច្ចបារាំង។ ភាពទន់ខ្សោយនៃឧស្សាហកម្ម និងពាណិជ្ជកម្មរបស់វណ្ណៈគហបតីបារាំង បានជំរុញឱ្យមានការពង្រីកការប្រើប្រាស់មូលធនហិរញ្ញវត្ថុ។ នៅក្នុងកិច្ចការនេះ ការកៀបសង្កត់ខាងហិរញ្ញវត្ថុបានបំពេញតួនាទីដ៏សំខាន់ ដោយហេតុថា នៅពេលជាមួយគ្នាមានការបង្កើតឱ្យមានលក្ខខណ្ឌដ៏ប្រសើរ សម្រាប់ការពង្រីកវង្វង់សកម្មភាពរបស់មូលធនពាណិជ្ជកម្ម និងមូលធនចងការប្រាក់។

ប្រភពមួយដ៏សំខាន់ក្នុងប្រាក់ចំណូលនៃថវិកា របស់ប្រទេសកម្ពុជា និងថវិកានៃសហភាពឥណ្ឌូចិន ជាទូទៅ បានមកពីប្រាក់ចំណូលពន្ធដារចំពោះមុខ និងមិនចំពោះមុខ ពីប្រាក់

ចំណូលនៃពន្ធគយ និងប្រាក់ចំណូលពីការលក់ដូរគ្រឿងភេសជ្ជៈ អំបិល និងអាភៀន។ល។ នៅប្រទេសកម្ពុជា អ្នកស្រុកបានបង់ពន្ធដារគ្រប់ចំពូកទាំងអស់ តាំងពីពន្ធលើមនុស្ស ដែលជាសមាជិកគ្រួសារ រហូតដល់ពន្ធដី ពន្ធលំនៅ ពន្ធសត្វពាហនៈ ពន្ធយានជំនិះ មានទូក...ជាដើម ពន្ធរបរអាជីវកម្ម។ល។ តាមសេចក្ដីឱ្យការណ៍នៃទិន្នន័យ ៥០ភាគរយនៃប្រាក់ចំណូលថវិការបស់ប្រទេសកម្ពុជា បានមកពីការទារពន្ធដារចំពោះមុខ ហើយប្រាក់ថវិកាមួយភាគធំត្រូវបានចំណាយដើម្បីផ្គត់ផ្គង់ដល់រដ្ឋការអាណានិគម។

ប្រាក់ពន្ធដារដ៏សំខាន់ បានមកពីពន្ធលើមនុស្សជាសមាជិកគ្រួសារ និងពន្ធដី។ នៅប្រទេសកម្ពុជា អ្នកស្រុកបង់ពន្ធផ្ទាល់ខ្លួនពន្ធលើមនុស្ស ម្ដងក្នុងមួយឆ្នាំ។ បុគ្គលជាប់ពន្ធ គឺជាជនដែលមានអាយុពី២១ ដល់៥០ឆ្នាំ ហើយត្រូវបង់ពន្ធផ្ទាល់ខ្លួន ២,៥០ រៀល ជនដែលមានអាយុពី៥១ ដល់៦០ឆ្នាំ ត្រូវបង់ពន្ធផ្ទាល់ខ្លួន ០,៨រៀល ជនដែលមានអាយុពី១៨ ដល់២០ឆ្នាំ ត្រូវបង់ពន្ធផ្ទាល់ខ្លួន ០,៨រៀល ដោយមានការសម្រេចមិនផ្ដាច់ចំណងពីប្រពៃណី ដែលធ្លាប់មានមកហើយ ក្នុងលក្ខខណ្ឌខ្លះ រដ្ឋបាលអាណានិគមបារាំង បានយកពន្ធខុសៗគ្នាពីបុគ្គលជាប់ពន្ធទាំងឡាយ និងពីបុគ្គលដែលមិនជាប់ពន្ធតាំងពីសម័យក្រោមរដ្ឋអំណាចរាជានិយម មកដល់សម័យអាណានិគមនិយម។

មិនតែប៉ុណ្ណោះ បុគ្គលជាប់ពន្ធត្រូវបង់ពន្ធបន្ថែម ០,១រៀល ក្នុងមួយថ្ងៃ សម្រាប់រយៈពេល២០ថ្ងៃ បើសិនជាខ្លួនត្រូវរំដោះពីការចូលរួមក្នុងការងារសាធារណៈ។ នៅពេលដទៃទៀត ប្រចាំឆ្នាំ រដ្ឋការអាចកោះហៅអ្នកស្រុក ឱ្យជួយបំពេញការងារជួសជុល

ទំនប់ទឹក ប្រព័ន្ធប្រឡាយបង្ហូរទឹក ឬធ្វើសំណង់អគារសាធារណៈ ។ល។

ប្រជារាស្ត្រប្រទេសកម្ពុជា បានបង់ពន្ធដីប្រមាណមួយភាគដប់នៃផលដំណាំស្រូវ។ រដ្ឋការអាណានិគមបានបង្កើនពន្ធលើដីអ្នកស្រុក ដោយមានបំណងនឹងបង្កើតឱ្យមានកម្មសិទ្ធិឯកជនតាមបែបមូលធននិយមនៅលើដីស្រែចម្ការ។ និន្នាការបែបនេះទាក់ទងនឹងការបង្កើតក្រសួងសុរិយោដី ការរៀបចំគម្រោងការបង្កើតកសិដ្ឋានតាមបែបអឺរ៉ុប និងការអនុវត្តនយោបាយនៃការផ្តល់ដីសម្បទានដល់ក្រុមហ៊ុន ដោយរដ្ឋការអាណានិគម។

រហូតដល់សម័យអាណានិគមនិយមបារាំង តាមប្រពៃណីសិទ្ធិលើទឹកដីនៅក្នុងប្រទេសមានដល់រាជាណាចក្រ បានសេចក្តីថា មហាក្សត្រជាម្ចាស់លើទឹកដីកម្ពុជា ក៏ប៉ុន្តែ នៅក្នុងជីវភាពពិតដីស្រែចម្ការស្ថិតនៅក្នុងការប្រើប្រាស់ របស់កសិករទាំងឡាយដែលបានបង់ពន្ធដី គិតជាមួយភាគដប់នៃផលដំណាំស្រូវជូនដល់រាជរតនាគារ។ កាលមុន ដីមិនមែនជារបស់សម្រាប់ការទិញលក់បានស្រួល ដោយហេតុថា នៅពេលនោះ នៅមានភាពអន់ថយក្នុងការប្រើប្រាស់ប្រាក់កាស និងដោយមានដីទំនេរច្រើន។ ពួកអាណានិគម មានគោលបំណងបង្កើតកម្មសិទ្ធិឯកជនលើដីតាមបែបមូលធននិយម។ ហេតុនេះហើយ បានជាស្របទៅតាមកិច្ចព្រមព្រៀងចុះថ្ងៃទី១៧ មិថុនា ឆ្នាំ១៨៨៤ និងស្របទៅតាមក្រឹត្យក្រមមួយចំនួនរបស់មហាក្សត្រនរោត្តម និងសារាចរនានារបស់ទេសាភិបាលជាន់ខ្ពស់ រដ្ឋការអាណានិគមបារាំងបានអនុវត្តច្បាប់នៃការផ្តល់កម្មសិទ្ធិឯកជនលើដី។ នៅក្នុងកិច្ចព្រមព្រៀង ចុះថ្ងៃទី១៧ មិថុនា ឆ្នាំ១៨៨៤ មានសេចក្តីបញ្ជាក់

ថា៖ ចាប់ពីពេលនេះទៅ ដីទាំងឡាយនៃរាជាណាចក្រដែលពីពេលមុនជាកម្មសិទ្ធិផ្ទាល់របស់រាជបល្ល័ង្ក ឈប់នៅជាទឹកដីដែលគេមិនអាចលក់ទិញបានទៀតហើយ។ នៅក្នុងរាជក្រឹត្យព្រះបាទនរោត្តម ចុះថ្ងៃទី១១ កក្កដា ឆ្នាំ១៨៩៧ មានសេចក្ដីបញ្ជាក់ថារាជរដ្ឋាភិបាលរក្សាទុកនូវសិទ្ធិក្នុងការបែងចែកដីទំនេរទាំងអស់របស់រាជាណាចក្រ ក៏ប៉ុន្តែ ម្ចាស់កម្មសិទ្ធិដីសម្បទានទាំងឡាយអាចប្រើប្រាស់សិទ្ធិពេញច្បាប់ ក្នុងការរក្សាកម្មសិទ្ធិឯកជនចំពោះដីទិញ ឬផ្ដល់ជាសម្បទានទាំងឡាយ (មាត្រាទី១២)។ នៅក្នុងសារាចរចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ១៨៩៧ ស្ថានភាពច្បាប់បែបនេះ បានត្រូវកំណត់ច្បាស់លាស់ដោយមានសេចក្ដីបញ្ជាក់ថា៖ “ រាជរដ្ឋាភិបាលរក្សានូវសិទ្ធិរបស់ខ្លួនក្នុងការលក់ ឬបែងចែកដីទាំងអស់នៅក្នុងរាជាណាចក្រ ក្នុងគោលបំណងធ្វើឱ្យដីទាំងនេះទៅជាកម្មសិទ្ធិឯកជនរបស់ម្ចាស់ដីទាំងឡាយ ធានាប៉ារ៉ាប់រងដល់ស្ថិរភាពនៃកម្មសិទ្ធិលើដីទាំងនេះ ហើយព្រមទាំងបង្កបង្កើតលក្ខខណ្ឌដ៏ប្រសើរ ក្នុងការប្រើប្រាស់ដីឱ្យមានទំហំច្រើនជាអតិបរមាក្នុងការធ្វើដំណាំស្រូវ ដែលអាចបង្កើតទ្រព្យសម្បត្តិរបស់ម្ចាស់ដី ព្រោះថា នៅក្នុងប្រទេសមាននៅសល់ដីទំនេរ និងមិនទាន់ត្រួសត្រាយដែលមានទំហំដ៏ធំធេង ”។

ក្នុងការបង្កើតច្បាប់ឱ្យមានកម្មសិទ្ធិឯកជនលើដី និងក្នុងការបង្កើតច្បាប់លក់ទិញដី រដ្ឋការអាណានិគមបារាំង បានអនុវត្តនូវរបបគហបតីនិយម នៅក្នុងការបង្កើតកម្មសិទ្ធិឯកជនលើដីនៅប្រទេសកម្ពុជា។ ពួកអាណានិគមបានខិតខំបង្កើតក្រសួងសុរិយោដីនៅក្នុងប្រទេស។ ហេតុនេះហើយ បានជានៅថ្ងៃទី២៥ មេសា ឆ្នាំ១៩០២ មានការចុះផ្សាយរាជក្រឹត្យមហាក្សត្រ

ដែលក្នុងនេះមានសេចក្តីបង្គាប់ ដល់ភូមិទាំងអស់ឱ្យចុះបញ្ជីដី និងម្ចាស់ដី ដោយមានការបញ្ជាក់អំពីទំហំដី។ ក៏ប៉ុន្តែ នៅពេលនោះ រាជក្រឹត្យនោះបានស្ថិតនៅតែលើក្រដាស។ ក្រសួងសុរិយោដី បានចុះបញ្ជីតែដីស្រែចម្ការដែលស្ថិតនៅជាយទីក្រុងភ្នំពេញ និងនៅតំបន់ទាំងឡាយណាដែលមានដីសម្បទានរបស់ជនជាតិអឺរ៉ុប សម្រាប់ការដាំដំណាំស្រូវ កប្បាស ម្រេច និងកៅស៊ូ។ ការចុះបញ្ជីដីដោយក្រសួងសុរិយោដី បានប្រព្រឹត្តទៅនៅឆ្នាំ១៩០៨ម្តង, ឆ្នាំ១៩១៨ម្តង និងនៅសម័យឆ្នាំ១៩៣០ - ១៩៤៥ម្តង។ បើនិយាយឱ្យខ្លីទៅ ការចុះបញ្ជីដីបានប្រព្រឹត្តទៅនៅពេញសម័យកាលនៃរបបអាណានិគមទាំងមូល។

កម្មសិទ្ធិឯកជនលើដីអនុវត្ត ដោយរដ្ឋការអាណានិគមបារាំង ត្រូវបានបញ្ចូលក្នុងច្បាប់ព្រហ្មទណ្ឌនៃប្រទេសកម្ពុជា នាឆ្នាំ១៩២០។ នៅក្នុងច្បាប់នេះមានការបញ្ជាក់លក្ខណៈខុសគ្នារវាង “ ម្ចាស់ដី ” គឺអ្នកមានដី ហើយប្រកបអាជីវកម្មលើដី និង “ អ្នកមានកម្មសិទ្ធិលើដី ” គឺអ្នកមានដីដោយមានសំបុត្រដីបញ្ជាក់ដោយក្រសួងសុរិយោដី ថាមានការបង់ពន្ធ និងចុះបញ្ជីត្រឹមត្រូវ។ ម្ចាស់ដីនឹងអាចទៅជាអ្នកមានកម្មសិទ្ធិលើដី លុះត្រាដីរបស់ខ្លួនត្រូវបានចុះបញ្ជីត្រឹមត្រូវដោយក្រសួងសុរិយោដី។

តាមច្បាប់ទម្លាប់ដែលមានមក ម្ចាស់ដីក៏មានសិទ្ធិ និងករណីយកិច្ច ដូចជាអ្នកមានកម្មសិទ្ធិលើដីដែរ ដោយហេតុ ថាម្ចាស់ដីក៏អាចផ្ទុកផ្តាក់កេរមរតករបស់ខ្លួនតាមបំណងចិត្ត។ សិទ្ធិនៃកម្មសិទ្ធិលើដីបានមកតាមការទិញ ការទទួលកេរមរតក ឬការប្រើប្រាស់ដីទំនេរក្នុងរយៈពេលប្រាំឆ្នាំ។ រដ្ឋការនៅស្រុក ឬនៅ

មូលដ្ឋានមានសិទ្ធិផ្តល់កម្មសិទ្ធិដី ដល់បណ្តាកសិករដែលប្រើប្រាស់ដី។

នៅឆ្នាំ១៩២៦ រដ្ឋបាលអាណានិគមបារាំង បានបង្កើតច្បាប់មួយ ដែលបញ្ជាក់ថា បុគ្គលដែលមិនមែនជាពលរដ្ឋបារាំង ឬដែលមិនមែនស្ថិតក្នុង " ក្រុមបុគ្គលប្រកបដោយបុព្វសិទ្ធិ " ត្រូវបានហាមឃាត់ មិនឱ្យមានកម្មសិទ្ធិលើដីនៅប្រទេសកម្ពុជា។ ច្បាប់បែបនេះ បានបង្កើតឱ្យមានវណ្ណៈមនុស្សខ្ពង់ខ្ពស់ថ្មីដែលមានការទាក់ទងជាមួយពួកអាណានិគម។

ដូច្នេះ នយោបាយកែប្រែដីអនុវត្តដោយរបបអាណានិគមនៅប្រទេសកម្ពុជា មានគោលដៅឆ្ពោះទៅរកការបង្កើតប្រព័ន្ធនៃកម្មសិទ្ធិឯកជនលើដីតាមបែបមូលធននិយម ហើយដែលត្រូវអនុវត្តជាបន្តមក ជាមួយនឹងការកាន់កាប់ដីជាប្រពៃណីពីសម័យរបបសក្តិភូមិ។ ដោយយោងទៅតាមច្បាប់ទម្លាប់ថ្មីៗស្តីអំពីការកាន់កាប់ដី តាំងពីពេលនោះមក រដ្ឋការអាណានិគមបានបែកចែកឡូត៍ដីធំៗ ដល់ពលរដ្ឋបារាំង ជាពិសេស ដល់ក្រុមហ៊ុនផ្តាច់មុខ សម្រាប់ការដាំដំណាំស្រូវ កាហ្វេ ម្រេច កៅស៊ូ និង សម្រាប់ការចិញ្ចឹមសត្វ។ ឡូត៍ដីធំៗជាច្រើន ត្រូវបានបែងចែកដល់បណ្តាមន្ត្រីខ្មែរ ដែលបានធ្វើសហការយ៉ាងសកម្មជាមួយរដ្ឋបាលអាណានិគមបារាំង។

នៅសម័យដាដំបូង បន្ទាប់ពីការតែងតាំងរបបអាណាព្យាបាលបារាំង នៅប្រទេសកម្ពុជា ទេសាភិបាលជាន់ខ្ពស់មានសិទ្ធិបែងចែកដីជាសម្បទានដោយឥតយកថ្លៃ ហើយដោយមានទំហំដល់មួយពាន់ហិកតា។ នៅឆ្នាំ១៩១៣ ទំហំធំបំផុតនៃដីផ្តល់ជាសម្បទានត្រូវបានកម្រិត តែត្រឹម៣០០ហិកតា។

នៅឆ្នាំ១៩២៨ មានការបដិសេធនូវការផ្តល់ដីជាសម្បទាន។ ជំនួសការបដិសេធបែបនេះ ដីបែងចែកជាដីសម្បទានត្រូវបាន ដាក់លក់តាមរបៀបលក់ដេញថ្លៃ ហើយមានការអនុញ្ញាតឱ្យ ចូលរួមដេញថ្លៃ មិនមែនគ្រាន់តែពលរដ្ឋបារាំង ទេ ប៉ុន្តែ អភិជន ជនជាតិខ្មែរ ទៀតផង។ តាមទិន្នន័យនាឆ្នាំ១៩៣០ ទំហំទូទៅ នៃដីសម្បទានបែងចែកដោយរដ្ឋការអាណានិគមបារាំង មានពី ១៩០ ដល់២០០ពាន់ហិកតា។ ពលរដ្ឋបារាំង បានទទួលដីស ម្បទានដែលមានទំហំ៧០ភាគរយ។ ដីសម្បទានដែលនៅសល់ ត្រូវបានបែងចែកជាពិសេសដល់អភិជនខ្មែរទាំងឡាយ។

ដីទាំងនេះចំនួនមួយភាគ ត្រូវបានប្រើប្រាស់ក្នុងការដាំ ដំណាំស្រូវសម្រាប់នាំចេញទៅក្រៅប្រទេស។ នៅឆ្នាំ១៩២៧ ទំហំដីសម្រាប់ដំណាំស្រូវនៅប្រទេសកម្ពុជា មានដល់៩០០ពាន់ ហិកតា បានសេចក្តីថា មានការបង្កើនទំហំដី បើគេប្រៀបធៀប ទៅនឹងឆ្នាំ១៩០៤ ដែលមានដីដាំស្រូវតែ៣០០ពាន់ហិកតា។ ដីដំណាំស្រូវមានច្រើននៅខេត្តបាត់ដំបង ស្វាយរៀង និងព្រៃវែង។ ផលិតផលស្រូវបានមកពីការដាំដំណាំស្រូវ នៅកសិដ្ឋានធំៗ និងពីការធ្វើស្រែដោយសារការប្រវាស់។ ជារៀងរាល់ឆ្នាំ ប្រទេស កម្ពុជា ជាមធ្យមមានការនាំស្រូវចេញទៅប្រទេសក្រៅ ពី១៥០ ដល់២៥០ពាន់តោន។ នៅឆ្នាំ១៩៣៧ មានការនាំចេញទៅក្រៅ នូវផលដំណាំដូចតទៅ គឺស្រូវ៤០០ពាន់តោន ពោតពី៣០០ ដល់៤០០ពាន់តោន ម្រេច ៣២០០តោន។

ដីសម្បទានមួយចំនួនធំ ជិត៥០ភាគរយត្រូវបានប្រើប្រាស់ ដើម្បីរៀបចំចម្ការដំណាំកៅស៊ូ។ នៅឆ្នាំ១៩២១ - ១៩២២ នៅ ពេលដែលមានការចាប់ផ្តើមវាយសម្រុកធ្វើដំណាំកៅស៊ូ ចម្ការ

កៅស៊ូ មានដីទំហំ ១.២២៤ហិកតា។ នៅឆ្នាំ១៩៤៥ ដំណាំកៅស៊ូបានគ្របដណ្តប់លើដីទំហំដល់ ២៩.៩២២ហិកតា។ នៅឆ្នាំ១៩៣៧ មានការនាំជ័រកៅស៊ូទម្ងន់១២ពាន់តោន ទៅប្រទេសក្រៅ។ តាមសេចក្តីឱ្យការណ៍នៃទិន្នន័យនានានៅមុនសម័យសង្គ្រាមពិភពលោកលើកទីពីរ ដើមទុនក្រុមហ៊ុនផ្តាច់មុខចំណាយសម្រាប់រៀបចំចម្ការដំណាំកៅស៊ូ មានប្រហែល ៦០ភាគរយនៃដើមទុនចូលហ៊ុន នៅគ្រប់វិស័យទាំងអស់នៃប្រទេសកម្ពុជា។

វិធានការក្នុងការពង្រីកទំហំដី នៃកសិដ្ឋានធំៗដែលបានកើតមានឡើងនៅប្រទេសកម្ពុជា នាសម័យអាណានិគមនិយម មិនបានបន្ទាញ ឱ្យមានវណ្ណៈកសិករក្រីក្រគ្មានដីច្រើនទេ។ កសិករចំនួនជាង៨០ភាគរយ ដែលជាអ្នកធ្វើស្រែចម្ការ គឺជាម្ចាស់នៃកម្មសិទ្ធិឯកជនលើដីធ្លីរបស់ខ្លួន។ សភាពការណ៍បែបនេះបញ្ជាក់ឱ្យឃើញថា កាលនោះ នៅប្រទេសកម្ពុជា នៅមានដីទំនេរជាច្រើន ហើយការត្រួសត្រាយដីទាំងនោះ មិនបាច់ទាមទារឱ្យមានការចំណាយប្រាក់ច្រើនទេ។

ម្ចាស់កម្មសិទ្ធិដីចំនួនប្រហែល៨៨ភាគរយ គឺជាកសិករ។ គឺជាដីស្រែចម្ការដ៏មានដីជាតិ ហើយជាមធ្យម កសិករម្នាក់ៗមានដីមានទំហំមិនលើសពី៥ហិកតា។ ក្នុងបណ្តាកសិករទាំងនេះ មានកសិករចំនួន ពី១,២ ដល់២ភាគរយប៉ុណ្ណោះ ដែលមានដីស្រែចម្ការលើសពី១០ហិកតា*។

---

* តាមស្ថិតិ នាឆ្នាំ១៩៣០ ស្តីអំពីខេត្តបាត់ដំបង កណ្តាល កំពង់ចាម ព្រៃវែង ស្វាយរៀង។

តាមទិន្នន័យនាឆ្នាំ១៩៥៦ ក្នុងបណ្ដាម្ចាស់កម្មសិទ្ធិដីចំនួន ៧២៧ពាន់នាក់ នៅតំបន់ដីស្រែចម្ការ នៅភាគកណ្ដាលនៃប្រទេសកម្ពុជា មានម្ចាស់ដី ចំនួន៤០២ពាន់នាក់ (គឺ៥៥ភាគរយ) មានដីទំហំប្រហែលតិចជាង ១ហិកតា, ម្ចាស់ដីចំនួន ១៨៣ ពាន់នាក់ (គឺ២៥ភាគរយ) មានដីទំហំ ពី១ ដល់២ហិកតា, ម្ចាស់ដីចំនួន៩០ពាន់នាក់ (គឺ១២ភាគរយ) មានដីទំហំ ពី២ ដល់៥ហិកតា, ម្ចាស់ដីចំនួន៤៨ពាន់នាក់ (គឺ៧ភាគរយ) មានដីទំហំ ពី៥ ដល់១០ហិកតា, ម្ចាស់ដីចំនួន ៩.៣០០នាក់ (គឺ១ភាគរយ) មានដីទំហំ ពី១០ ដល់២០ហិកតា និងម្ចាស់ដីចំនួន ១.១៩១នាក់ (គឺ0,១៧ភាគរយ) មានដីទំហំ ពី២០ហិកតាឡើងទៅ។ ដូច្នេះ នៅក្នុងសម័យកាលនៃអាណាព្យាបាលបារាំង ទោះបីមានការខិតខំបង្កើតទម្រង់ផលិតកម្មតាមបែបមូលធននិយមក្ដី (គឺការបង្កើតកសិដ្ឋានដំណាំធំៗ) ក៏ប្រទេសកម្ពុជា ស្ថិតនៅជាប្រទេសប្រកបដោយកសិដ្ឋាន កសិករមធ្យម និងតូចតាច។

និន្នាការជាមូលដ្ឋាននៃការលូតលាស់ស្រុកស្រែចម្ការនៅប្រទេសកម្ពុជា ដែលបានវិវឌ្ឍនៅសម័យទសវត្សរ៍ទី៣ - ៤ នៃសតវត្សរ៍ទី២០ បានបង្កបង្កើតឱ្យមានស្រទាប់នៃវណ្ណៈកសិករដែលមានដីស្រែចម្ការតូចៗ។ គេអាចពន្យល់នូវនិន្នាការនេះបានដោយហេតុថា កសិករក្រីក្រទាំងឡាយពុំមានលទ្ធភាពខាងសម្ភារៈគ្រប់គ្រាន់ដើម្បីត្រួសត្រាយដីទំនេរថ្មីៗ។ សភាពការណ៍បែបនេះបានពន្យឺតការកាន់កាប់ដីទំនេរ ដោយវណ្ណៈកសិករ។ ជាលទ្ធផលគឺថា ចលនាពង្រីកមូលនិធិដីដាំដំណាំ នៅតំបន់ភាគកណ្ដាលនានានៃប្រទេស មានដំណើរយឺតយ៉ាវជាងសង្វាក់នៃការលូតលាស់

បណ្ដាជនស្រុកស្រែ គឺជាហេតុដែលមិនអាចផ្ដល់លទ្ធភាពដើម្បីបំបាត់សេចក្ដីខ្វះខាតខាងដីធ្លីនៅតំបន់ទាំងនេះ។ នៅពេលជាមួយគ្នា ដីកាប់គាស់ថ្មីៗបានទៅជាមូលដ្ឋាននៃការកកើតវណ្ណៈម្ចាស់កម្មសិទ្ធិដីមធ្យម និងដីធំៗទៅវិញ។ ម្ចាស់កម្មសិទ្ធិដីធំៗ (មានទំហំលើសពី២០ហិកតា) គឺជាសមាជិកទាំងឡាយនៃរាជវង្សានុវង្ស គឺបណ្ដានាហ្មឺនមន្ត្រីជំនាន់ចាស់ និងថ្មី ហើយនៅទីបំផុត គឺជាជនទាំងឡាយដែលបានទទួលដីសម្បទាន មានអាទិ គឺពួកពាណិជ្ជករដែលបានទទួលបានដីពីរដ្ឋការបារាំង ដើម្បីរៀបចំចម្ការដំណាំធំៗ។

នៅក្នុងលក្ខខណ្ឌ នៃរបបគ្រប់គ្រងអាណានិគមបារាំង ទំនាក់ទំនងខាងឥវ៉ាន់ (គឺការធ្វើជំនួញ) បានលូតលាស់ដោយសង្វាក់យ៉ាងឆាប់រហ័ស ប៉ុន្ដែការលូតលាស់បែបនេះ បានពឹងផ្អែកជាបន្តទៅលើការកៀបសង្កត់ តាមបែបសក្តិភូមិទៅលើវណ្ណៈកសិករ។ របៀបកៀបសង្កត់មួយដ៏ធ្ងន់ធ្ងរ គឺការប្រើប្រាស់មូលធនចងការប្រាក់ ដែលបានទាក់ទាញកសិដ្ឋានកសិករចំនួនពី ៨០ ទៅ៨៥ភាគរយ ឱ្យស្ថិតនៅក្រោមរង្វង់នៃឥទ្ធិពលរបស់ពួកពាណិជ្ជករចងការប្រាក់។ ប្រាក់ចងការរមែងផ្ដល់ដល់រដូវច្រូតកាត់ ហើយការប្រាក់យកពី១០០ ដល់១៥០ភាគរយ ជួនកាលយកដល់២០០ភាគរយ។ ក្នុងស្ថានភាពបែបនេះ កសិករមិនអាចរំដោះខ្លួនពីទម្ងន់នៃប្រាក់បំណុលបានឡើយ។

របបគ្រប់គ្រងអាណានិគម បានបង្កើតឧបសគ្គដល់ការលូតលាស់នៃផលិតកម្មជាតិនៅប្រទេសកម្ពុជា ដោយហេតុថាផ្សារក្នុងប្រទេស ត្រូវបានបើកចំហដល់ការនាំចូលដោយសេរី (គឺឥតយកពន្ធគយ) នូវគ្រឿងផលិតឧស្សាហកម្មពីក្រៅប្រទេស។

នៅពេលជាមួយគ្នា ការប្រើប្រាស់មូលធនបារាំង នៅប្រទេសកម្ពុជា បានប្រព្រឹត្តទៅតាមទំហំដ៏ស្ដួចស្ដើងជាងនៅប្រទេសវៀតណាម។ ការណ៍នេះបណ្ដាលមកពីភាពកង្វះខាងកម្លាំងកម្មករ មកពីមានផ្សារក្នុងប្រទេសតិចពេក មកពីភាពកង្វះប្រភពធម្មជាតិដើមខាងជាតុរ៉ែ។

ក្រុមហ៊ុនផ្ដាច់មុខផ្សេងៗចំនួនម្ភៃសាមសិបក្រុម បានចូលរួបរួមក្នុងការបង្កើតកសិដ្ឋានដំណាំ ការរៀបចំយានជំនិះ ការកសាងរោងឧស្សាហកម្ម (ជាពិសេស រោងឧស្សាហកម្មកែច្នៃប្រែបម្រាញ់ធម្មជាតិដើមខាងកសិកម្ម) និងការស្ថាបនាទីក្រុង។ សកម្មភាពរបស់ក្រុមហ៊ុនទាំងនេះ បានស្ថិតនៅក្រោមកិច្ចត្រួតត្រារបស់ធនាគារឥណ្ឌូចិន។

នៅពេលជាមួយគ្នានឹងការប្រើប្រាស់ដើមទុនបារាំង នៅក្នុងសេដ្ឋកិច្ចប្រទេសកម្ពុជា មានការចូលហ៊ុនពីសំណាក់ដើមទុនជំនួញ និងឈ្មួញកណ្ដាលរបស់ជនជាតិចិន និងវៀតណាម។ ក្រុមហ៊ុនជំនួញជនជាតិចិន និងវៀតណាម បានដើរតួជាឈ្មួញកណ្ដាលរវាងក្រុមហ៊ុនផ្ដាច់មុខបារាំង និងផ្សារនានានៅក្នុងប្រទេសទាំងឡាយនៃសហភាពឥណ្ឌូចិន។ ក្រៅពីការបំពេញមុខងារជាឈ្មួញកណ្ដាល ក្រុមហ៊ុនទាំងនេះបានដើរតួនាទីដ៏សំខាន់ម៉្យាងនៅក្នុងការពង្រីកឧស្សាហកម្មធុនស្រាល (ដូចជា រោងកិនស្រូវ រោងអារឈើ រោងផលិតចានឆ្នាំង ព្រមទាំងរោងផលិតគ្រឿងសម្ភារៈសំណង់មួយចំនួន)។

នៅក្រោមរបបគ្រប់គ្រងអាណាព្យាបាលបារាំង វណ្ណៈគហបតីជាតិនៃប្រទេសកម្ពុជា បានកើតមានឡើងពីសំណាក់ពួកពាណិជ្ជករ និងម្ចាស់រោងផលិតមួយភាគតូច។

ការអនុវត្តរបបជិះជាន់ តាមរបៀបបុរេមូលធននិយម បានបង្កើតលក្ខខណ្ឌនានាសម្រាប់ការលូតលាស់នៃវណ្ណៈអធន នៅក្នុងប្រទេស។ តាមទិន្នន័យនានានៅសម័យមុនសង្គ្រាមពិភពលោកលើកទី២ ចំនួនទូទៅនៃកម្មករនៅក្នុងប្រទេសមានមិនលើសពី២០ពាន់ ដល់២៥ពាន់នាក់។ ទីប្រជុំជនធំនៃវណ្ណៈកម្មករ គឺកសិដ្ឋានដំណាំធំៗ (មានជាអាទិ ចម្ការដំណាំកៅស៊ូ) ដែលបានប្រើប្រាស់កម្មករពី១០ពាន់ ដល់១២ពាន់នាក់។ ទីប្រជុំជនបន្ទាប់បន្សំដទៃទៀតនៃវណ្ណៈកម្មករ គឺរោងចក្រ និងរោងផលិតនានា។ វណ្ណៈអធនដែលបានកកើតមានឡើងនៅពេលនោះ ប្រកបដោយលក្ខណៈពហុប្រជាជាតិ។ ជាឧទាហរណ៍ នៅឆ្នាំ១៩៣០ នៅចម្ការកៅស៊ូនានានៃប្រទេសមានកម្មករវៀតណាម ពីតំបន់តុងកឹង ចំនួន១០ពាន់នាក់ដែលបានធ្វើការតាមកិច្ចសន្យា។ នៅតាមរោងចក្រ និងរោងផលិតនានាកម្មករភាគច្រើន គឺជាជនជាតិខ្មែរ។

នៅប្រទេសកម្ពុជា នាសម័យអាណាព្យាបាលបារាំង មានសិប្បករមួយចំនួនធំ ដែលនៅក្នុងនេះ មានជនជាតិខ្មែរ និងវៀតណាម។ ចំនួនសិប្បករទាំងអស់ដែលបានធ្វើការក្នុងផលិតកម្មនាសម័យមុនសង្គ្រាមពិភពលោកលើកទីពីរ មានពី៣០ ដល់៤០ពាន់នាក់។ កម្មករ និងសិប្បករទាំងឡាយមានការទាក់ទងជាមួយស្រែចម្ការ និងស្រុកស្រែយ៉ាងជិតស្និទ្ធ។

នៅសម័យនោះ ការងារជាសាធារណៈទូទៅបានប្រព្រឹត្តទៅនៅក្នុងវិស័យនៃការស្ថាបនាទីក្រុងទាំងឡាយ ការកសាង

ប្រព័ន្ធបង្ហូរទឹក ការធ្វើដំហានទីមួយ ក្នុងការកសាងរោងចក្រឯកជន ជាពិសេស រោងចក្រកែប្រៃ និងចម្រាញ់ធម្មជាតិដើម* ។ ការបង្កើតមជ្ឈមណ្ឌលសម្រិតសម្រាំងពូជដំណាំកសិកម្ម ការពង្រីកខ្លះៗនូវមន្ទីរព្យាបាលរោគ។

មានការបំពេញការងារ ខាងស្ថាបនកម្មទីក្រុងភ្នំពេញ និងទីរួមខេត្តធំៗឡើងវិញ។ នៅឆ្នាំ១៩០២ ទីក្រុងភ្នំពេញ ចាប់ផ្តើមមានភ្លើងអគ្គិសនី មានខ្សែទូរស័ព្ទ និងទូរលេខ។ ក៏ប៉ុន្តែរបស់ទាំងអស់នេះត្រូវបានបង្កើតឡើងជាពិសេស ដើម្បីកសាងលក្ខខណ្ឌដ៏ប្រសើរសម្រាប់ជីវភាពរស់នៅរបស់ជនជាតិអឺរ៉ុប ជាពិសេស ជនជាតិបារាំង សម្រាប់ការពង្រឹងវិស័យសេដ្ឋកិច្ចដែលទាក់ទងនឹងរបបជិះជាន់អាណានិគមនៅក្នុងប្រទេស។

កិច្ចការសេដ្ឋកិច្ចនៃប្រទេសនានានៅឥណ្ឌូចិន មានទាំងសេដ្ឋកិច្ចប្រទេសកម្ពុជា ជាដើម ត្រូវបានដាក់ឱ្យនៅក្នុងការបម្រើផលប្រយោជន៍ចក្រពត្តិនិយមបារាំង។ ដូច្នេះហើយ បានជានៅសម័យខាងដើមនៃសង្គ្រាមលោកលើកទីពីរ ឥវ៉ាន់នាំចេញពីឥណ្ឌូចិន ទៅប្រទេសបារាំង មានតម្លៃរហូតដល់១១លានហ្វ្រង់ (ជាប្រាក់រូបិយប័ណ្ណ)។ ជនជាតិវៀតណាម និងជនជាតិខ្មែរមួយចំនួនធំធ្វើការនៅរោងចក្រយោធា និងនៅតាមការដ្ឋានសំណង់យោធានានានៅប្រទេសបារាំង។ ទាហានវៀតណាម និងខ្មែរទាំងឡាយ បានធ្វើយុទ្ធនាការនៅក្នុងជួរនៃកង

---

* នៅវង្វង់សម័យទសវត្សរ៍ទី២ មានការកសាងរោងចក្រផលិតបារី គ្រឿងភេសជ្ជៈ ស្ករស រោងកិនស្រូវ រោងផលិតសំពត់សូត្រចំនួនពីរ រោងចក្រក្រណាត់សំពត់ រោងអារឈើ។

ទ័ពបារាំង។ នៅក្នុងសម័យកាលនៃឆ្នាំ១៩១៤ - ១៩១៨ រដ្ឋការបារាំង បានធ្វើកំណែនមនុស្សនៅឥណ្ឌូចិន ចំនួនជិត១០០ ពាន់នាក់ (ជនជាតិខ្មែរ ត្រូវបានបញ្ចូលក្នុងកងទ័ពបារាំង ចាប់ពីឆ្នាំ១៩១៦ឡើងទៅ មុនដំបូងតាមសេចក្តីស្ម័គ្រចិត្ត)។

វិបត្តិសេដ្ឋកិច្ចពិភពលោកនាឆ្នាំ១៩២៩-១៩៣៣ និងភាពជុនដាបខាងសេដ្ឋកិច្ច នៅសម័យក្រោយមកទៀតបានផ្តល់ឥទ្ធិពលជាខ្លាំង មកលើនយោបាយសេដ្ឋកិច្ចអាណានិគមនៅប្រទេសកម្ពុជា ដោយមានការបន្ថយតម្លៃឥវ៉ាន់ និងផលដំណាំសម្រាប់ការនាំចេញ ការកម្រិតប្រាក់ថវិកាសម្រាប់ការចំណាយផ្សេងៗ ការចុះថយនៃដើមទុនចូលហ៊ុនបរទេស ក្នុងវិស័យសេដ្ឋកិច្ចនានា។ សភាពការណ៍បែបនេះបានបណ្តាលឱ្យប្រជាពលករមានស្ថានភាពជីវភាពកាន់តែតឹងតែងឡើង។

ដូចមានសេចក្តីអធិប្បាយខ្លះរួចមកហើយ លក្ខណៈពិសេសមួយនៃរបបគ្រប់គ្រងអាណានិគមនិយមបារាំង ជាពិសេសនៅប្រទេសកម្ពុជា គឺការកសាងនូវរបបការិយាល័យនិយមមួយប្រកបដោយការប្រមូលផ្តុំអំណាចមជ្ឈិម។ កិច្ចការនេះតម្រូវឱ្យមានសេចក្តីត្រូវការជានិរន្តន៍នូវក្រុមខ័ណ្ឌនាហ្មឺនថ្មីៗ ជាពិសេសពីសំណាក់បណ្តាជនក្នុងស្រុក ព្រមទាំងតម្រូវឱ្យមានការកសាងគ្រឹះស្ថានសិក្សានានាដែលនៅក្នុងនេះ មានទាំងសាលាបច្ចេទេសទៀតផង។

នៅសម័យនោះ មជ្ឈមណ្ឌលនៃបឋមសិក្សានៅប្រទេសកម្ពុជា គឺសាលារៀននៅតាមវត្តអារាម ដែលមានកុមារចូលរៀនចាប់ពីអាយុ៨ឆ្នាំឡើងទៅ។ សាលាទាំងនេះបានស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋការអាណានិគម។ នៅឆ្នាំ១៩១១ នៅក្នុង

ប្រទេសទាំងមូលមានសាលាបឋមសិក្សាប្រហែល ៣០ខ្នង ហើយនៅទីនេះ សិស្សានុសិស្សរៀនសរសេរ រៀនអានជាភាសាខ្មែររៀនលេខ ហើយរៀនភាសាបារាំង។ នៅឆ្នាំ១៩២៤ កម្មវិធីសិក្សានៅសាលារៀនទាំងនេះ ត្រូវបានពិនិត្យរៀបចំសាជាថ្មី ដើម្បីសម្របទៅតាមសេចក្ដីត្រូវការនៃបច្ចុប្បន្នភាព ហើយត្រូវបានដាក់ក្រោមការត្រួតត្រាដ៏តឹងរឹងរបស់រដ្ឋការបារាំង។ នៅឆ្នាំ១៩៣៧ សាលាបឋមសិក្សាមានចំនួនដល់ ៨១៣ខ្នង ហើយមានសិស្សានុសិស្ស ចំនួន៣៤ពាន់នាក់។

ជាមួយនឹងសាលារៀននៅវត្តអារាម មានទាំងសាលាបឋមសិក្សា (សាលាបារាំង) ហើយសិស្សានុសិស្សដែលចេះអានចេះសរសេរជាភាសាខ្មែរ អាចចូលរៀនសាលាទាំងនេះបាន។ នៅសាលាទាំងនេះ ការបង្រៀនបានប្រព្រឹត្តទៅជាភាសាបារាំង ហើយកម្មវិធីសិក្សា ត្រូវបានរៀបចំឡើងប្រហាក់ប្រហែលនឹងកម្មវិធីនៅសាលាបឋមសិក្សាបារាំង។ នៅឆ្នាំ១៩៣៧ សាលាបឋមសិក្សាតាមរបៀបបារាំង មានចំនួនដល់១១៧ ហើយមានសិស្សានុសិស្សចំនួនជាង១១ពាន់នាក់ រៀននៅសាលាទាំងនេះ។ តាមធម្មតា សាលាទាំងនេះត្រូវបានកសាងឡើងនៅក្នុងទីក្រុងសំខាន់ៗ នៃប្រទេស។

ដើម្បីរៀបចំការសិក្សា តាមកម្មវិធីពេញលេញនៃមធ្យមសិក្សានៅប្រទេសកម្ពុជា នាឆ្នាំ១៩១១ មានការបង្កើតអនុវិទ្យាល័យមួយ ឈ្មោះ “ អនុវិទ្យាល័យស៊ីសុវត្ថិ ” ហើយនៅទីនេះ សិស្សានុសិស្សត្រូវរៀនប្រាំឆ្នាំ។

នៅឆ្នាំ១៩៣៥ អនុវិទ្យាល័យនេះត្រូវបានកែប្រែទៅជាវិទ្យាល័យស៊ីសុវត្ថិ វិញ ហើយនៅទីនេះ មានការអប់រំរៀបចំ

ក្របខ័ណ្ឌរដ្ឋបាល និងគ្រូបង្រៀនទាំងឡាយសម្រាប់សាលាបឋមសិក្សានៅប្រទេសកម្ពុជា។

យុវជនខ្មែរ អាចទទួលការអប់រំខាងបច្ចេកទេសភាពនៃមុខរបរខាងសិល្បៈ និងសិប្បកម្មនៅសាលារចនា ដែលបានចាប់ផ្តើមធ្វើសកម្មភាពនាឆ្នាំ១៩១៧។ នៅទីនេះ មានការអប់រំសិស្សានុសិស្សឱ្យទៅជាសិប្បករ សិល្បករ ចម្លាក់ ជាងធ្វើគ្រឿងមាសប្រាក់ ជាងស្មូនឆ្នាំង។ នៅឆ្នាំ១៩៣៧ នៅសាលារចនាមានសិស្សានុសិស្សខ្មែរ រៀនចំនួន ១៣៥នាក់។ នៅទីក្រុងភ្នំពេញ នាឆ្នាំ១៩០៣ មានការបង្កើតសាលាអប់រំវិជ្ជាជីវៈកម្មករមួយ ហើយរវាង២០ឆ្នាំក្រោយមក សាលានេះត្រូវបានកែប្រែឱ្យទៅជាអនុវិទ្យាល័យបច្ចេកទេស សម្រាប់ការអប់រំក្របខ័ណ្ឌបច្ចេកទេសមធ្យមនៅក្នុងវិស័យបច្ចេកទេសផ្សេងៗ។ នៅឆ្នាំ១៩៣៧ មានសិស្សានុសិស្សចំនួនលើសពី១០០នាក់ រៀននៅអនុវិទ្យាល័យនេះ ហើយក្នុងបណ្តាអ្នកសិក្សាទាំងនេះ មានសិស្សខ្មែរ ៥០នាក់ សិស្សវៀតណាម ៦២នាក់។ នៅសម័យនោះ ដើម្បីបន្តការសិក្សានៅគ្រឹះស្ថានសិក្សាជាន់ខ្ពស់ ជនជាតិខ្មែរត្រូវទៅបន្តវិជ្ជានៅទីក្រុងហាណូយ នៅសាកលវិទ្យាល័យឥណ្ឌូចិន ឬនៅទីក្រុងប៉ារីស។

មានគ្រឹះស្ថានសិក្សាពីរ បានបំពេញតួនាទីដ៏សំខាន់នៅក្នុងការរៀបចំក្របខ័ណ្ឌបញ្ញវន្តជាតិ ហើយបានធ្វើការតស៊ូប្រឆាំងនឹងរបបគ្រប់គ្រងអាណានិគម គឺ៖ សាលាបាលីជាន់ខ្ពស់ និងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។ សាលាសិក្សាភាសាបាលីបានបើកទ្វារធ្វើការជាដំបូងនៅភ្នំពេញ នាឆ្នាំ១៩១៤។ សាលានេះត្រូវបានកែប្រែ ឱ្យទៅជាសាលាបាលីជាន់ខ្ពស់នាឆ្នាំ១៩២៣។

នៅឆ្នាំ១៩៣៧ នៅសាលាបាលីជាន់ខ្ពស់នេះមាននិស្សិតជាព្រះសង្ឃ រៀនចំនួន១៨០អង្គ។ វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យបានចាប់ផ្ដើមធ្វើការនៅឆ្នាំ១៩៣០ ហើយនៅទីនេះមានការសិក្សាស្រាវជ្រាវអំពីគម្ពីរពុទ្ធសាសនាផ្សេងៗ។

សាលាបាលីជាន់ខ្ពស់ និងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យមានការទាក់ទងនឹងសាលាបាលីដទៃទៀត ដែលមាននៅក្នុងទីរួមខេត្តទាំង១៥ ហើយនៅទីនេះ មានការរៀបចំគ្រូបង្រៀនសម្រាប់សាលាខ្មែរទាំងឡាយ។ ម្យ៉ាងទៀត គឺពីសាលាបាលីនៅក្នុងខេត្តនានាទាំងនេះហើយ ដែលមានការជ្រើសរើសនិស្សិតទាំងឡាយសម្រាប់ភាសាបាលីជាន់ខ្ពស់នៅភ្នំពេញ។

លទ្ធភាពដ៏ប្រសើរ ត្រូវបានបង្កបង្កើតឡើងនៅព្រៃនគរ និងហាណូយ ដើម្បីការរៀបចំក្របខ័ណ្ឌជ្រើសរើសពីសំណាក់ប្រជាជននានា ដោយហេតុថា នៅវៀតណាម មានការប្រមូលផ្ដុំអំណាច និងទីស្នាក់ការដ៏សំខាន់នៃសហភាពឥណ្ឌូចិន។

នាហ្មឺនជាន់ខ្ពស់នៃរដ្ឋបាលខ្មែរជាច្រើន ដែលពឹងផ្អែកលើអំណាច និងឫទ្ធានុភាពរបស់ពួកអាណានិគមបារាំង “ បានបិទភ្នែក ” ចំពោះសកម្មភាពរបស់ពួកទាំងនេះ ហើយបានចាប់ផ្ដើមប្រព្រឹត្តអំពើទាំងឡាយទាក់ទងនឹងសំណូកដែលបានក្លាយទៅជាជំងឺសង្គមដ៏ធ្ងន់ធ្ងរនៅក្នុងប្រទេស។ ពួកនាហ្មឺពុករលួយនៅសម័យនោះ មិនគ្រាន់តែស៊ីសំណូក ដើម្បីធ្វើកិច្ចការអ្វីមួយទេ ប៉ុន្តែ គ្រាន់តែសុំបោះត្រាលើឯកសារ ឬទទួលសំណុំរឿងក៏មានការទាមទារឱ្យបង់កម្រៃដែរ។ ម្ល៉ោះហើយ នៅក្នុងសម័យអាណានិគមនិយម ប្រជាជនក្នុងស្រុកបានទទួលការកៀបសង្កត់ក្រោមទម្ងន់ពន្ធដារ ការបង់កម្រៃដល់ពួកនាហ្មឺន ការសងការប្រាក់

ដល់អ្នកចងការប្រាក់ ហើយស្ថានភាពក្រីក្រលំបាកបានទៅជាភាពធម្មតាក្នុងជីវភាព។ សេដ្ឋកិច្ចរបស់ប្រទេសបានវិវឌ្ឍន៍ទៅដោយសង្វាក់យឺតយ៉ាវ។

# ជំពូកទី៥
# ចលនាតស៊ូរំដោះជាតិ នៅសម័យ អាណាព្យាបាលបារាំង

ការរិវត្តដោយសង្វាក់យ៉ាងយឺតនៅប្រទេសកម្ពុជា អំពើសង្កត់សង្កិនតាមរបៀបផ្សេងៗ អនុវត្តដោយពួកអាណានិគមទាំងអស់នេះ ជាមូលហេតុដែលបានបណ្តាលឱ្យមានចលនាតស៊ូរំដោះជាតិនៅក្នុងប្រទេសនាសម័យនោះ។ តាមរបាយការណ៍នានារបស់រដ្ឋបាលបារាំង មានសេចក្តីបញ្ជាក់ជានិច្ចកាលអំពីលក្ខណៈជនជាតិខ្មែរ ដែលប្រកបដោយកិរិយាស្ងប់ស្ងៀមទន់ភ្លន់ ចូលចិត្តសម្របសម្រួល។ ក៏ប៉ុន្តែ តាមការពិត ចលនាប្រយុទ្ធប្រឆាំងនឹងពួកអាណានិគមបារាំង បានកើតមានឡើងមិនចេះចប់ក្នុងអំឡុងសម័យអាណានិគមទាំងមូលនៅប្រទេសកម្ពុជា។ ជារឿយៗ ដូចជាសម័យមុនៗ ចលនាតស៊ូរបស់ប្រជាជនខ្មែរ តែងមានទំនាក់ទំនងនឹងចលនាតស៊ូនៃប្រជាជនវៀតណាម និងឡាវ។

ការតស៊ូរំដោះជាតិនៃប្រជាជនខ្មែរ នាសម័យអាណានិគមនិយមបានប្រព្រឹត្តទៅតាមពីរបីដំណាក់កាល។ ដំណាក់កាលទីមួយ បានប្រព្រឹត្តទៅប្រហែលហូតដល់សម័យខាងចុងទសវត្សរ៍ទី២ នៃសតវត្សរ៍ទី២០ គឺជាពេលដែលវណ្ណៈកសិករ បានក្រោកឈរធ្វើការតស៊ូប្រឆាំងនឹងពួកអាណានិគមបារាំង ដោយមានសេចក្តីសង្ឃឹមម៉្យាងមកលើមហាក្សត្ររបស់ខ្លួន។ ហេតុនេះហើយបានជាគេអាចហៅចលនាតស៊ូសម័យកាលនេះថា៖ “ ចលនា

តស៊ូមានសេចក្តីសង្ឃឹមលើមហាក្សត្រ ”។ គេទាំងឡាយបានធ្វើការតស៊ូប្រយុទ្ធ ដើម្បីរំដោះខ្លួនពីសេចក្តីអត់ឃ្លានក្រខ្សត់ ពីអំពើជិះជាន់របស់រដ្ឋការអាណានិគម ពីអំពើកៀបសង្កត់របស់ពួកនាហ្មឺនពុករលួយខ្មែរ។ ចលនាតស៊ូនាសម័យនោះ មានលក្ខណៈជាកុបកម្មបះបោរ ប្រជាជនប្រឆាំងនឹងរបបត្រួតត្រាអាណានិគមបារាំង ប្រឆាំងនឹងអំពើជិះជាន់ដ៏អយុត្តិធម៌របស់រដ្ឋការពួកនាហ្មឺនពុករលួយដើម្បីរំដោះខ្លួន ពីភាពក្រីក្រលំបាក ប៉ុន្តែ ចលនាតស៊ូទាំងនេះពុំទាន់មានការទាក់ទងគ្នាជាខ្សែសង្វាក់ផ្សារភ្ជាប់ដោយយុទ្ធសាមគ្គីភាពបានឡើយ។

ឆ្នាំ១៩០៧ ជាសម័យកាលដែលមានចលនាកុបកម្មបះបោរកសិករបានផុសផុលកើតឡើងនៅប្រទេសកម្ពុជា ក្រោមការដឹកនាំរបស់វិសេស-ញៀវ។ ចលនាកុបកម្មប្រជាជននៅតំបន់នានាប្រឆាំងនឹងរបបគ្រប់គ្រងអាណានិគម ក៏បានកើតមានឡើងជាបន្តបន្ទាប់នៅពេលក្រោយៗមកទៀត។ នៅខែមេសា ឆ្នាំ១៩០៩ កុបកម្មបះបោរកសិករបានប្រព្រឹត្តទៅនៅខេត្តកំពត។ តាមឯកសារជាប្រភពខ្លះ មានសេចក្តីបញ្ជាក់ថា នៅសម័យនោះ តាមព្រំប្រទល់កម្ពុជា - កូសាំងស៊ីន មានកងកម្លាំងកុបករអ្នកស្រុកដែលបានធ្វើការវាយលុកលើប៉ុស្តិ៍ប្រៃសណីយ៍ ហើយបានកាត់បំផ្លាញប្រព័ន្ធទូរគមនាគមន៍។

ចលនាកុបកម្មកសិករដ៏ធំមួយទៀត បានកើតមានឡើងនៅប្រទេសកម្ពុជា នាខែមករា - កុម្ភៈ ឆ្នាំ១៩១៦។ ប្រជារាស្ត្របានក្តៅក្រហាយនឹងការដំឡើងពន្ធដារ និងការកំណែនឱ្យចូលកងទ័ព។ ប៉ុន្តែ មូលហេតុដែលបណ្តាលឱ្យមានសន្ទុះកំហឹងបែបនេះ គឺអំពើកាចសាហាវអនុវត្តដោយរដ្ឋការអាណានិគម

ក្នុងការកោះហៅអ្នកស្រុក ឱ្យធ្វើសំណង់ផ្លូវថ្នល់លេខ១។ ចលនាកុបកម្មបះបោរបានរាលដាលគ្របដណ្តប់ លើតំបន់ខាងបស្ចិមនៃប្រទេស ដោយមានបណ្តាជនចូលរួមចំនួនជិត១០០ពាន់នាក់។ បណ្តាអ្នកចូលរួមក្នុងចលនានេះ បានវាយលុកចូលខេត្តក្រចេះ និងទីក្រុងតូចៗដទៃទៀតដែលកាន់កាប់ដោយកងទ័ពបារាំង។ នៅពេលនោះ កងទ័ពបារាំង ដែលមានទាហានចំនួនតិចបានទទួលបរាជ័យ ហើយការចរចាក៏បានចាប់ផ្តើម។ កុបករចំនួន ៣០ពាន់នាក់ត្រូវបានអនុញ្ញាតឱ្យចូលមករដ្ឋធានី ពីថ្ងៃទី៥ មករា ដល់ថ្ងៃទី២៤ កុម្ភៈ ឆ្នាំ១៩១៦ ដើម្បីសំដែងនូវសេចក្តីទាមទាររបស់ខ្លួនដល់មហាក្សត្រស៊ីសុវត្ថិ។ មហាក្សត្រ ចេះសំរបសំរួលជាមួយនឹងពួកបាតុករ ដែលសុខចិត្តត្រឡប់ទៅផ្ទះសម្បែងរៀងៗខ្លួន ហើយបានចាប់ផ្តើមធ្វើការងារជាប្រក្រតីវិញ។ ក៏ប៉ុន្តែ នៅពេលតមក ស្ថានភាពនៅក្នុងប្រទេសនៅដដែលឥតមានការផ្លាស់ប្តូរឱ្យសមស្រប តាមការទាមទាររបស់បណ្តាបាតុករឡើយ។

កំហឹងរបស់កសិករខ្មែរ បានសំដែងឱ្យឃើញកាន់តែខ្លាំងនៅក្នុងឃាតកម្មអភិបាលបារាំងម្នាក់ ទាហានពីរនាក់ ដែលនៅថ្ងៃទី១៦ មេសា ឆ្នាំ១៩២៥ បានទៅទារពន្ធដារពីអ្នកស្រុកភូមិក្រាំងលាវ នៅខេត្តកំពង់ឆ្នាំង នាឱកាសបុណ្យចូលឆ្នាំថ្មី។ កសិករទាំងអស់ដែលធ្វើឃាតកម្មនេះត្រូវចាប់ឃុំឃាំង ហើយកាត់ទោសដោយរដ្ឋការបារាំង។

កុបកម្មបះបោររបស់ជនជាតិភាគតិច នៅតំបន់ព្រៃប្រឆាំងនឹងអំពើជិះជាន់នៃរបបអាណានិគមបារាំង ក៏តែងកើតមានឡើងហើយមានសន្ទុះកាន់តែខ្លាំង បន្ទាប់ពីពេលដែលរដ្ឋការបារាំង បាន

ចាប់ផ្តើមចូលជ្រួតជ្រាបទៅក្នុងតំបន់ដីក្រហមដើម្បីបង្កើតចម្ការដំណាំកៅស៊ូ (ឆ្នាំ១៩២០-១៩២១)។

ហេតុនេះហើយ បានជាមុនពេលធ្វើសំណង់ផ្លូវថ្នល់ទៅកាន់តំបន់ព្រៃ នៅថ្ងៃទី២៦ ឧសភា ឆ្នាំ១៩៣១ វិស្វករបារាំងម្នាក់ដែលបានទៅសិក្សាទីកន្លែងនៅតំបន់នោះ ត្រូវបានស្លាប់។ ទាក់ទងនឹងសភាពការណ៍បែបនេះ រដ្ឋសភាបារាំង បានទូន្មានឱ្យបន្ថយទំហំដីក្រហម ដែលត្រូវដណ្តើមយកពីជនជាតិភាគតិចនៅតំបន់ព្រៃ។ ក៏ប៉ុន្តែ សេចក្តីទូន្មាននេះបានស្ថិតនៅតែលើក្រដាស។

ដំណាក់កាលនៃចលនាតស៊ូ គឺការរីកចម្រើននៃចលនាតស៊ូរំដោះជាតិនៅប្រទេសកម្ពុជា កំណត់ដោយការបង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិន នាឆ្នាំ១៩៣០ ហើយក្នុងសមាសភាពនៃបក្សកុម្មុយនិស្តឥណ្ឌូចិននេះ មានការបង្កើតផ្នែកខ្មែរ។

ការបង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិន បានប្រព្រឹត្តទៅនៅក្នុងបរិយាកាសនៃការលូតលាស់របស់ចលនារំដោះជាតិ និងកម្មករជាទូទៅនៅឥណ្ឌូចិន ជាពិសេស នៅវៀតណាម។ សន្ទុះនៃចលនានេះ បានកើតមានឡើងដោយសារស្ថានភាពដុនដាបនៃជីវភាពប្រជាជន ទាក់ទងនឹងវិបត្តិសេដ្ឋកិច្ចពិភពលោក។ ពីខែមេសា ឆ្នាំ១៩២៩ ដល់ខែឧសភា ឆ្នាំ១៩៣០ នៅវៀតណាមបាតុកម្មចំនួន៣៨បានកើតមានឡើង។ ចលនាបាតុកម្មក៏បានកើតមានឡើងដែរនៅប្រទេសកម្ពុជា។ នៅថ្ងៃទី២១ មិថុនា ឆ្នាំ១៩២៩ នៅទីក្រុងភ្នំពេញ កម្មករ “ ក្រុមហ៊ុនដឹកនាំ និងទូរគមនាគមន៍នៅឥណ្ឌូចិន ” បានចាប់ផ្តើមធ្វើបាតុកម្ម ហើយនៅថ្ងៃទី៣ តុលា កម្មករទាំងឡាយនៅភ្នំពេញ ក៏បានធ្វើបាតុកម្មដែរ។ តមក ការរំជើបរំជួលក៏បានកើតមានឡើងក្នុងបណ្តាកម្ម

ករនៅចម្ការកៅស៊ូ។ នៅខែសីហា ឆ្នាំ១៩៣០ ក្នុងបណ្ដាជនជាតិវៀតណាម និងចិន ដែលរស់នៅតាមព្រំប្រទល់កម្ពុជា-កូសាំងស៊ីន, នៅភ្នំពេញ និងនៅខេត្តកំពត មានការបោះត្រាក់អំពាវនាវឱ្យក្រោកឡើងធ្វើការតស៊ូប្រឆាំងនឹមអាណានិគម ដើម្បីបង្កើនស្ថានភាពខាងសម្ភារៈរបស់ប្រជាពលករ។ រដ្ឋអំណាចបារាំងយល់ថា ឧប្បត្តិហេតុបែបនេះត្រូវបានបង្កបង្កើតឡើងដោយ "ក្រុមកុម្មុយនិស្តចិន ទាក់ទងនឹងអង្គការកុម្មុយនិស្តវៀតណាម នៅកូសាំងស៊ីន"។ ក្នុងរឿងនេះ មនុស្ស១៤នាក់ត្រូវបានចាប់ឃុំឃាំង ហើយមនុស្ស២៥នាក់ ត្រូវបាននិរទេសចេញពីដែនដីសហភាពឥណ្ឌូចិន។

នៅក្នុងឯកសារ នៃកម្មវិធីទីមួយមានសេចក្ដីថ្លែងគោលការណ៍របស់បក្សកុម្មុយនិស្តឥណ្ឌូចិន ដោយបានបញ្ជាក់នូវគោលដៅនានា ដូចតទៅ៖ ការរំលំរបបគ្រប់គ្រងផ្ដាច់ការចក្រពត្តិ ការបំបាត់របបសក្ដិភូមិ ការរំដោះកម្មករ និងកសិករ ការដណ្ដើមយកអំណាចនយោបាយដោយវណ្ណៈអធន។ នៅក្នុងដំណាក់កាលទីមួយ ត្រូវតែមានដំណោះស្រាយភារកិច្ចនៃបដិវត្តន៍គហបតីប្រជាធិបតេយ្យ វណ្ណៈអធនក្នុងសម្ពន្ធភាពជាមួយវណ្ណៈកសិករត្រូវតែរំលំរបបអាណានិគមបារាំង បំបាត់របបសក្ដិភូមិ ហើយអនុវត្តការកែប្រែខាងកសិកម្ម។

បក្សកុម្មុយនិស្តឥណ្ឌូចិន បានទៅជាបក្សដឹកនាំនៃការតស៊ូរបស់ប្រជាជននានានៅឥណ្ឌូចិន (នៅវៀតណាម កម្ពុជា និងឡាវ) ប្រឆាំងនឹងអាណានិគមនិយមបារាំង ព្រមទាំងកម្លាំងប្រតិកិរិយានៅទីអាយ ដើម្បីឯករាជភាព និងសិទ្ធិខាងប្រជាធិបតេយ្យ។ នៅក្នុងការតស៊ូប្រឆាំងនឹងរបបគ្រប់គ្រងផ្ដាច់ការ

អាណានិគមនិយម ប្រជាជននានានៅវៀតណាម កម្ពុជា និងឡាវ បានចងសម្ពន្ធគ្នាយ៉ាងជិតស្និទ្ធ ទោះបីមានលក្ខណៈខុសគ្នាខាងភាសា ប្រពៃណី និងទំនៀមទម្លាប់ជាតិខុសៗគ្នាក្តី។

ជាមួយនឹងការចាប់ផ្តើម ដំណើរការរបស់ចលនាកុម្មុយនិស្តនិយម នៅប្រទេសកម្ពុជា ក៏មានការពង្រឹងនូវកម្លាំងសក្តិភូមិគហបតីជាតិនិយម របស់ក្រុមខាងស្តាំនៃចលនាតស៊ូរំដោះជាតិ។ ព្រឹត្តិការណ៍ទាំងនេះ បានកើតមានឡើងនៅសម័យខាងចុងទសវត្សរ៍ទី២ និងខាងដើមទសវត្សរ៍ទី៣។ វណ្ណៈអភិជនសក្តិភូមិមជ្ឈដ្ឋាននាហ្មឺននិយម វណ្ណៈគហបតីក្តុម្ពី ពាណិជ្ជករ ដែលជាទីបង្អែករបស់ចលនាអ្នកជាតិនិយម បានលូតលាស់ឡើងក្រោមកិច្ចដឹកនាំរបស់បញ្ញវន្ត គហបតី សក្តិភូមិ ដែលស្ថិតនៅក្រោមឥទ្ធិពលរបស់សាលាបាលីជាន់ខ្ពស់ និងវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

នៅឆ្នាំ១៩៣៥ នៅទីក្រុងភ្នំពេញ ក្រុមយុវបញ្ញវន្តមួយក្រុមបានកកើតមានឡើង ក្រោមការដឹកនាំរបស់ ប៉ួរ-ហ៊ាង និងសឺង-ង៉ុកថាញ់។ បុគ្គលពីររូបនេះមានការទាក់ទងយ៉ាងជិតស្និទ្ធនឹងរាជវង្សានុវង្សជាន់ចាស់នៃប្រទេសកម្ពុជា ដែលពុំបានឡើងសោយរាជ្យនៅពេលនោះ។ ក្នុងដំណាក់កាលទីមួយ ពួកនេះបានធ្វើការទាមទារឱ្យមានស្វ័យភាព ខាងនយោបាយនៃប្រទេសកម្ពុជា ចំពោះប្រទេសបារាំង ការបន្ធូរបន្ថយរបបអាណានិគមនិយមបារាំង។ នៅឆ្នាំ១៩៣៧ ក្រុមនេះបានបង្កើតអង្គការកាសែតមួយឈ្មោះ “ នគរវត្ត ” ដែលបានទិតៀនជាមធ្យមដល់របបគ្រប់គ្រងអាណានិគមនិយម ហើយបានថ្លែងបំណងចង់ឱ្យ

តំណាងរាជវង្សានុវង្សមួយទៀត ឡើងសោយរាជ្យនៅប្រទេសកម្ពុជា គឺខាងមហាក្សត្រនរោត្តម។

សង្គ្រាមលោកលើកទីពីរ បានចាប់ផ្ដើមកើតមានឡើងនៅឆ្នាំ១៩៣៩ ដោយរបបហ្វាស៊ីស្តអាល្លឺម៉ង់ ហើយព្រឹត្តិការណ៍បានទៅជាធ្ងន់ធ្ងរ ដោយមានអំពើឈ្លានពានរបស់របបយោធានិយមជប៉ុន នៅចុងបូព៌ា និងនៅអាស៊ីអាគ្នេយ៍។ នៅសម័យនោះដោយយោងទៅតាមភាពទន់ខ្សោយ របស់ប្រទេសបារាំង ប្រទេសសៀម បានសាកល្បងធ្វើការពិនិត្យអំពីបញ្ហាព្រំប្រទល់របស់ខ្លួនជាមួយប្រទេសឡាវ និងប្រទេសកម្ពុជា។ ហេតុដូច្នេះហើយ បានជានៅថ្ងៃទី៣០ វិច្ឆិកា ឆ្នាំ១៩៤០ ពួកអ្នកដឹកនាំសៀមបានចាប់ផ្ដើមធ្វើសកម្មភាពយោធា។ ទោះបី ពួកវាមានជោគជ័យក្នុងរយៈពេលដ៏ខ្លីក្ដី ក៏សកម្មភាពយោធាបែបនេះពុំបានផ្ដល់ជ័យជម្នះដល់ប្រទេសសៀម ឡើយ។ នៅថ្ងៃទី១៧ មករា ឆ្នាំ១៩៤១ កងនាវាចរណ៍សៀម ត្រូវបានកម្ទេចនៅក្នុងឈូងសមុទ្រសៀម ការវាយលុករបស់កងទ័ពជើងគោកសៀម ត្រូវបានបញ្ឈប់មិនឱ្យធ្វើចលនាទៅមុខ។ ក៏ប៉ុន្តែ ដោយមានជំនួយពីប្រទេសជប៉ុនយោធានិយមប្រទេសសៀម ក៏បានទទួលផលប្រយោជន៍នៅក្នុងរឿងព្រំប្រទល់ ជាមួយនឹងប្រទេសកម្ពុជា និងឡាវ។ នៅថ្ងៃទី៩ ឧសភា ឆ្នាំ១៩៤១ នៅទីក្រុងតូក្យូ មានពិធីចុះហត្ថលេខាលើសន្ធិសញ្ញា ស្ដីអំពីសន្តិភាពរវាងប្រទេសសៀម និងរដ្ឋាភិបាលបារាំងនៃទីក្រុងវីស៊ី ហើយតាមសេចក្ដីនៃសន្ធិសញ្ញានេះ ខេត្តខ្មែរមួយចំនួនដែលស្ថិតនៅខាងជើងខ្សែស្របលេខ១៥ ដូចជា ទីក្រុងស៊ីសូផុន ខេត្តសៀមរាប ខេត្តកំពង់ធំ និងខេត្តស្ទឹងត្រែង ត្រូវបានភ្ជាប់ដោយបង្ខំដោយខុសច្បាប់ទៅនឹង

ប្រទេសសៀម។ តំបន់អង្គរ បានស្ថិតនៅជាដែនដីនៃប្រទេសកម្ពុជា ដដែល។ មជ្ឈដ្ឋានចក្រពត្តិយោធានិយមជប៉ុន បានពង្រីកអំពើឈ្លានពានរបស់ខ្លួនមកលើប្រទេសនានា នៅអាស៊ីអាគ្នេយ៍ ហើយបានចូលកាន់តែមកជិតព្រំប្រទល់ នៃសហភាពឥណ្ឌូចិន។ ពួកវាមានបំណងប្រើប្រាស់កម្លាំងមនុស្ស កប៉ាល់ចម្បាំង និងគ្រឿងអាវុធយុទ្ធភណ្ឌដ៏ទំនើបក្នុងការធ្វើចម្បាំង ដើម្បីរៀបចំរបបគ្រប់គ្រងផ្ដាច់ការរបស់វានៅអាស៊ី។ នៅថ្ងៃទី២៩ កក្កដា ឆ្នាំ១៩៤១ ឧត្តមនាវីបារាំង ឈ្មោះ ដារឡង់ បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយ ហើយតាមសេចក្ដីនៃកិច្ចព្រមព្រៀងនេះ ប្រទេសជប៉ុន បានទទួលសិទ្ធិដាក់កងកម្លាំងទ័ពរបស់ខ្លួននៅលើទឹកដីទាំងអស់នៅឥណ្ឌូចិន ហើយមិនតែប៉ុណ្ណោះ ប្រទេសនេះបានទទួលទាំងសិទ្ធិក្នុងការកសាងមូលដ្ឋានខាងនាវាចរណ៍ និងអាកាសចរណ៍ថ្មីៗទៀត ដោយគ្មានការកម្រិតចំនួន។ នៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៤១ ឧត្តមនាវីបារាំង នាម ដេកូ បានចុះហត្ថលេខាជាមួយអ្នកតំណាងមេបញ្ជាការទ័ពជប៉ុន លើកិច្ចព្រមព្រៀងមួយស្ដីអំពីកិច្ចការពាររួមនៃដែនដីឥណ្ឌូចិន ហើយតាមសេចក្ដីនៃកិច្ចព្រមព្រៀងនេះ រដ្ឋាភិបាលបារាំង ត្រូវទទួលរ៉ាប់រងដល់កិច្ចការរក្សាសណ្ដាប់ធ្នាប់នៅលើទឹកដីឥណ្ឌូចិន។

ប្រជារាស្ត្រនៃប្រទេសកម្ពុជា ម្ដងនេះ ក៏បានស្ថិតនៅក្រោមរបបត្រួតត្រាបរទេសពីរបែប គឺ៖ របបត្រួតត្រារបស់ពួកអាណានិគមនិយមបារាំង និងជប៉ុន ទោះបីនៅក្នុងប្រទេសមានការរក្សាទុកនូវទម្រង់នៃរដ្ឋបាលបារាំង ក្ដី។ នយោបាយប្រទេសជប៉ុន នៅប្រទេសកម្ពុជា មានទិសដៅតម្រង់ទៅលើការប្រើប្រាស់ប្រទេសនេះ ដូចជា មូលដ្ឋានយោធាជប៉ុន និងលើការកៀបយកវត្ថុធាតុ

ដើមខាងកសិកម្ម ដោយតម្លៃថោកបំផុត។ តាមសេចក្តីទាមទារ របស់រដ្ឋការយោធាជប៉ុន រដ្ឋបាលបារាំង បានបង្ខិតបង្ខំឱ្យ កសិករខ្មែរទាំងឡាយប្រើប្រាស់ដីធ្លី របស់ខ្លួនដើម្បីដាំដំណាំ និងដំណាំបច្ចេកទេសដទៃទៀត ដើម្បីបំពេញសេចក្តីត្រូវការ សេដ្ឋកិច្ចយោធានិយមរបស់ជប៉ុន។ ពាណិជ្ជកម្មក្រៅប្រទេស របស់ប្រទេសកម្ពុជា បានស្ថិតនៅសឹងទាំងអស់ក្នុងកណ្តាប់ដៃ ប្រទេសជប៉ុន គឺថាមានការនាំចេញ៩០ភាគរយ និងការនាំចូល ៧០ភាគរយ។

នៅសម័យនោះ ប្រទេសកម្ពុជា បានខូចខាតប្រព័ន្ធបង្ហូរ ទឹកសំខាន់ៗ ហើយដីសម្រាប់ដាំដំណាំមួយភាគត្រូវបានបោះបង់ ចោល។ នៅឆ្នាំ១៩៤១ - ១៩៤៨ ផលិតកម្មខាងកសិកម្មបានចុះ ថយពី២០ - ៣០ភាគរយ។

ការចុះអន់ថយខាងសេដ្ឋកិច្ច ការចុះតម្លៃប្រាក់កម្រិត ជីវភាពចុះដុនដាបដែលកើតមានឡើងដោយសារសង្គ្រាម និង ការកាន់កាប់ប្រទេសដោយពួកយោធាជប៉ុន បានបណ្តាលឱ្យ មនុស្សគ្រប់ស្រទាប់នៅក្នុងសង្គមខ្មែរ នៅស្រុកស្រែ ក៏ដូចជា នៅទីក្រុងកើតសេចក្តីក្តៅក្រហាយ។

ស្ថានភាពជីវភាពរបស់សិប្បករតូចតាច និងមធ្យមរបស់ អ្នកបម្រើរដ្ឋការ ពួកបញ្ញវន្ត និស្សិត និងបណ្តាជនដទៃនៅទីក្រុង ក៏កាន់តែចុះដុនដាបឡើងៗ។

នៅសម័យសង្គ្រាមលោកលើកទីពីរ ស្រទាប់ជនជួរមុខ នៃសង្គមខ្មែរ បានចាប់អារម្មណ៍ជាខ្លាំងចំពោះវិសមភាពខាង នយោបាយដែលកើតមានឡើងនៅក្នុងប្រទេស។ មិនតែប៉ុណ្ណោះ ស្ថានភាពអន់ថយខាងសេដ្ឋកិច្ច និងសង្គមកើតឡើងដោយ

សង្គ្រាម និងការកាន់កាប់ទឹកដីដោយកងទ័ពជប៉ុន បានជំរុញឱ្យមានការពង្រីកមូលដ្ឋាននៃចលនាតស៊ូរំដោះជាតិ។

នៅក្នុងលក្ខខណ្ឌថ្មីៗបែបនេះ បក្សកុម្មុយនិស្តឥណ្ឌូចិន បានយល់នូវភារកិច្ចដ៏ចាំបាច់ ក្នុងការដាស់សតិអារម្មណ៍ជាតិរបស់ប្រជាជននានា ដើម្បីធ្វើការតស៊ូប្រយុទ្ធប្រឆាំងនឹងរបបហ្វាស៊ីស្តនិយម។ បក្សបានសម្រេចចិត្តបង្កើតរណសិរ្សសេរីកាជាតិ ដាច់ដោយឡែកៗសម្រាប់ប្រទេសនីមួយៗ។ គឺស្របទៅតាមសេចក្តីសម្រេចចិត្តបែបនេះហើយ បានជារណសិរ្សអ្នកស្នេហាមាតុភូមិខ្មែរ (ខ្មែរឥស្សរៈ) បានកកើតមានឡើងនៅប្រទេសកម្ពុជា។

នៅសម័យនោះ មជ្ឈដ្ឋានពួកបញ្ញវន្តអ្នកជាតិនិយមខ្លះក៏បានចាប់ផ្តើមធ្វើការតស៊ូប្រឆាំងប្រទេសបារាំង ដើម្បីឯករាជ្យជាតិ ហើយបានប្រកាន់ឥរិយាបថប្រកបដោយនិន្នាការស្របតាមប្រទេសជប៉ុន។ តាមមតិអ្នកដឹកនាំរបស់មជ្ឈដ្ឋានទាំងនេះដែលមានកាសែត “ នគរវត្ត ” ជាអង្គការផ្សាយរបស់ខ្លួន ពួកនេះយល់ថា ប្រទេសកម្ពុជា អាចទទួលការរីកចម្រើនតាមមាគ៌ាមូលធននិយមដោយដើរតាមឧទាហរណ៍របស់ប្រទេសជប៉ុន។

នៅសម័យនោះ អាចារ្យ ហែម-ចៀវ ជាសាស្ត្រាចារ្យនៅសាលាបាលីជាន់ខ្ពស់ បានសរសេរចុះផ្សាយអត្ថបទមួយចំនួនប្រឆាំងនឹងរបបគ្រប់គ្រងអាណានិគម ហើយត្រូវបានពួករដ្ឋការបារាំង ចាប់ឃុំឃាំងនៅថ្ងៃទី១៥ កក្កដា ឆ្នាំ១៩៤២ ដោយការចោទប្រកាន់ថាជា“អំពើបំបាក់បំបែក និងបំបះបំបោរប្រជាជន ”។ នៅក្នុងការប្រឆាំងនឹងអំពើចាប់ចងនេះ នៅទីក្រុងភ្នំពេញ នាថ្ងៃទី២០ កក្កដា បាតុកម្មមួយបានកើតឡើង ដោយមានការចូលរួម

ពីសំណាក់លោកសង្ឃប្រហែលពីរពាន់អង្គ និងពុទ្ធបរិស័ទចំនួនរាប់ពាន់នាក់។ ក៏ប៉ុន្តែ បាតុកម្មនេះត្រូវបានបង្ក្រាបដោយពួកប៉ូលិសរដ្ឋការបារាំង។ អាចារ្យហែម-ចៀវ ត្រូវបានរដ្ឋការបារាំងកាត់ទោសប្រហារជីវិត។ ប៉ុន្តែដល់ពេលក្រោយមក បានបន្ធូរបន្ថយមកត្រឹមការជាប់ពន្ធនាគារដោយធ្វើការជាទម្ងន់ អស់មួយជីវិត។ លោកត្រូវបានពួកអាណានិគមនិយមបញ្ជូនទៅពន្ធនាគារនៅកោះត្រឡាច ហើយក៏បានទទួលអនិច្ចធម្មនៅទីនោះ នៅឆ្នាំ១៩៤៣។ នៅពេលនោះ សឺង-ង៉ុកថាញ់ បានរត់គៀសខ្លួនទៅប្រទេសជប៉ុន ហើយនៅទីនោះ បានចូលរៀនសូត្រនៅក្នុងសាលាអាស៊ីអាគ្នេយ៍ដ៏មហិមា គឺជាគ្រឹះស្ថានសម្រាប់អប់រំអ្នកធ្វើនយោបាយនៅប្រទេសអាស៊ីនានា ដែលសុខចិត្តបម្រើតាមនយោបាយរបស់យោធានិយមជប៉ុន ដែលមានបំណងរៀបចំរបបគ្រប់គ្រងផ្ដាច់ការខាងនយោបាយរបស់ខ្លួននៅទ្វីបអាស៊ី។

នៅប្រទេសកម្ពុជា រដ្ឋបាលអាណានិគមនិយមបារាំងបានធ្វើការបន្ធូរបន្ថយខ្លះៗ ដើម្បីទាក់ទាញទឹកចិត្តអ្នកជាតិនិយមរបស់ពួកបញ្ញវន្តមួយចំនួន ឱ្យប្រកាន់តាមទស្សនៈរបស់ខ្លួន។ ក្នុងការបន្ធូរបន្ថយនេះ មានការអនុញ្ញាតឱ្យលើកទង់ជ័យនៃប្រទេសកម្ពុជា ជាមួយនឹងទង់ជ័យបារាំង នៅក្នុងពិធីបុណ្យនានា។ ក៏ប៉ុន្តែ នៅពេលជាមួយគ្នា មានសំបុត្របញ្ជាពីរដ្ឋាភិបាលក្រុងវីស៊ី ឱ្យរំលំអង្គការរដ្ឋសភាទាំងអស់នៅប្រទេសកម្ពុជា។ ហេតុនេះហើយ បានជារដ្ឋសភាជាតិ (បង្កើតឡើងនៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៤០ ជំនួសអតីតសភាសម្រាប់ពិភាក្សា) ពុំបានបំពេញមុខងាររបស់ខ្លួននៅពេលនោះ។

នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៤១ នរោត្តម សីហនុ បានឡើងសោយរាជ្យនៅប្រទេសកម្ពុជា។ មហាក្សត្រអង្គនេះ ជាអ្នកតំណាងរាជវង្សានុវង្សចាស់ និងថ្មី។

បន្ទាប់ពីឆ្នាំ១៩៤២ មានចលនាអ្នកជាតិនិយមមួយបានកើតមានឡើងនៅក្នុងក្របខ័ណ្ឌ នៃចលនាយុវជនដែលមានឈ្មោះ "កីឡា និងយុវជន"។ ចលនានេះបានបង្រួបបង្រួមយុវជនមួយចំនួនធំឱ្យស្ថិតនៅក្រោមពាក្យស្លោក ដែលមានសេចក្ដីថា៖ "យើងសូមប្រព្រឹត្តឱ្យសមជាកូនចៅរបស់បុព្វបុរសសម័យអង្គរ"។

ក្នុងសភាពការណ៍បែបនេះ នៅឆ្នាំ១៩៤៥ សាខាពីរបានកើតមានឡើងក្នុងចលនាតស៊ូរំដោះជាតិប្រទេសកម្ពុជា។ អ្នកចូលរួបរួមក្នុងកម្លាំងខាងឆ្វេង បានប្រុងប្រៀបខ្លួនធ្វើការតស៊ូដើម្បីឯករាជ្យជាតិ ដែលនៅក្នុងនេះ មានប្រជាជនកម្ពុជា បានធ្វើការតស៊ូទៅមុខទៀត នៅក្នុងសម្ពន្ធមិត្តដ៏ជិតស្និទ្ធជាមួយនឹងបណ្ដាកម្លាំងប្រឆាំងចក្រពត្តិនិយម នៅប្រទេសវៀតណាម និងឡាវ។ នៅពេលជាមួយគ្នា នៅក្នុងពាក្យស្លោកនៃការតស៊ូ គេបានទាមទារឱ្យមានការបង្កើត នូវរបបគ្រប់គ្រងសាធារណរដ្ឋឯករាជ្យនៅក្នុងប្រទេស។ មជ្ឈដ្ឋាននានាដែលតំណាងឱ្យបណ្ដាកម្លាំងនយោបាយ ដែលបង្រួបបង្រួមគ្នានៅជុំវិញរាជបល្ល័ង្កបានប៉ុនប៉ងទាមទារឯករាជភាព នៃប្រទេសពីរដ្ឋការអាណានិគមនិយមបារាំង ដែរ។

អ្នកដឹកនាំកម្លាំងខាងឆ្វេងនៃចលនារំដោះជាតិ គឺជាសមាជិកនានានៃបក្សកុម្មុយនិស្តឥណ្ឌូចិន និងអ្នកចូលរួបរួមក្នុងចលនាខ្មែរឥស្សរៈទាំងឡាយ។ នៅពេលនោះ ចលនាប្រឆាំងមួយចំនួន ស្ថិតនៅក្រោមឥទ្ធិពលនៃពាក្យស្លោកខាង

មនោគមវិជ្ជាប្រើប្រាស់ដោយប្រទេសជប៉ុន ដើម្បីប្រព្រឹត្តអំពើឈ្លានពានរបស់ខ្លួននៅទ្វីបអាស៊ី។ ពួកអ្នកតំណាងក្រុមទាំងនេះបានសម្របសម្រួលដើម្បី ធ្វើការទាក់ទងខាងនយោបាយជាមួយរដ្ឋការយោធាជប៉ុន នៅក្នុងប្រទេស ដោយមានបំណងចង់ទទួលជំនួយពីជប៉ុន ដើម្បីបំបាត់របបអាណានិគមនិគមបារាំង ហើយនិងដើម្បីសម្រេច នូវការរៀបចំឯករាជភាពនៅប្រទេសកម្ពុជាតាមបែបនេះ។

ប្រទេសជប៉ុន ប៉ុនប៉ងប្រើប្រាស់បណ្ដាមជ្ឈដ្ឋានអ្នកជាតិនិយមទាំងនេះ ដើម្បីសម្រេចគោលដៅខាងនយោបាយរបស់ខ្លួន។ ការមិនសម្រេចជោគជ័យ ក្នុងនយោបាយរបស់រដ្ឋាភិបាលជប៉ុននាឆ្នាំ១៩៤៣ - ១៩៤៤ បានបង្ខំឱ្យពួកនេះស្វែងរកផ្លូវមួយទៀតក្នុងគោលបំណងបញ្ចូលសហភាពឥណ្ឌូចិន ទៅក្នុងនយោបាយផ្សងព្រេងរបស់របបយោធានិយមជប៉ុន។ នៅថ្ងៃទី៩ មីនា ឆ្នាំ១៩៤៥ នៅប្រទេសកម្ពុជា រដ្ឋការបារាំង ត្រូវបានផ្លាស់ប្ដូរដោយរដ្ឋការជប៉ុន ហើយកងកម្លាំងយោធាបារាំង ត្រូវបានចាប់ឃុំឃាំង។ នៅថ្ងទី១២ មីនា មហាក្សត្រនរោត្តម សីហនុ បានចេញផ្សាយរាជ្យក្រឹត្យពីរ ស្ដីអំពីការបដិសេធចោលនូវកិច្ចព្រមព្រៀងទាំងអស់ដែលមានការចុះហត្ថលេខាជាមួយប្រទេសបារាំង។ នៅថ្ងៃទី១៤ សីហា ឆ្នាំ១៩៤៥ ដោយមានការគាំទ្រពីមជ្ឈដ្ឋាននយោបាយជប៉ុន ផង នៅប្រទេសកម្ពុជា មានការបង្កើតរដ្ឋាភិបាលមួយដែលមាន សឺង-ង៉ុកថាញ់ ធ្វើជានាយករដ្ឋមន្ត្រី ហើយរដ្ឋាភិបាលនេះបានធ្វើសេចក្ដីប្រកាសប្រុងប្រៀបខ្លួនដើម្បីការពារ “ឯករាជ្យភាពរបស់ប្រទេសដល់ទីអវសាន្ត”។

# វគ្គទី៣

# ប្រទេសកម្ពុជា នាឆ្នាំ១៩៤៥ - ១៩៧០

## ចំពូកទី១

## យុទ្ធនាការ ដើម្បីរំដោះជាតិ

ការបញ្ចប់សង្គ្រាមលោកលើកទីពីរ បានបើកទំព័រថ្មីនៃប្រវត្តិសាស្ត្រកម្ពុជា។ នៅក្នុងអំឡុងឆ្នាំ១៩៤៥ - ១៩៥៣ មានការកំណត់នូវរបៀបផ្សេងៗ ក្នុងការរៀបចំការតស៊ូប្រយុទ្ធដោយអាវុធ ដើម្បីឯករាជ្យជាតិនៃប្រទេស។

ការចុះចាញ់ របស់របបឃោជានិយមប្រទេសជប៉ុន ហើយនិងបដិវត្តន៍ដ៏មានជ័យជម្នះនាខែសីហា ឆ្នាំ១៩៤៥ នៅប្រទេសវៀតណាម ស្ថានការណ៍ទាំងនេះ បានបណ្តាលឱ្យមានការបំបាត់របបអាណានិគមនិយម និងការកាន់កាប់ទឹកដីនៅប្រទេសនានានៃឥណ្ឌូចិន។ ព្រឹត្តិការណ៍បដិវត្តន៍នានានៅប្រទេសវៀតណាមបានជំរុញ ឱ្យមានការបង្កើតសកម្មភាពនយោបាយពីសំណាក់ប្រជាពលករនៅប្រទេសកម្ពុជា និងនៅប្រទេសឡាវ។ នៅខែសីហា ឆ្នាំ១៩៤៥ នៅក្នុងទីកន្លែងសំខាន់ៗជាច្រើននៃប្រទេសកម្ពុជា មានការធ្វើបាតុកម្មនានាដែលនៅពេលនោះ អ្នកចូលរួបរួមបានថ្លែងអបអរសាទរដល់ការរំដោះប្រទេស ពីនឹមរបស់ពួកចក្រពត្តិបារាំង និងជប៉ុន។

នៅដើមខែកញ្ញា ឆ្នាំ១៩៤៥ អង្គភាពនៃកងទ័ពបារាំងនិងអង់គ្លេស បានចូលទៅវៀតណាមខាងត្បូង ក្រោមកលល្បិច

ដែលបញ្ជាក់ថា ពួកវាចូលទៅដកសព្វាវុធសំណល់របស់កងទ័ពជប៉ុន ដែលស្ថិតនៅទីនេះ។ នៅថ្ងៃទី២៣ កញ្ញា អង្គភាពនៃកងទ័ពបារាំង និងអង់គ្លេស បានវាយលុកចូលទីក្រុងព្រៃនគរ ហើយតាមកម្មវិធីនេះ ពួកវាបានចាប់ផ្ដើមធ្វើអន្តរាគមន៍ដោយអាវុធនៅឥណ្ឌូចិន។ នៅពេលក្រោយមកទៀត អន្តរាគមន៍បែបនេះបានរីកសាយមកលើទឹកដីនៃប្រទេសកម្ពុជា។ នៅថ្ងៃទី៩ តុលា ឆ្នាំ១៩៤៥ អង្គភាពនៃកងទ័ពលោតឆត្របារាំង បានចូលមកដល់ទីក្រុងភ្នំពេញ តាមផ្លូវអាកាស។

តាមបញ្ជារបស់ឧត្តមសេនីយ៍បារាំង នាម ឡឺក្លែក សឺង-ង៉ុកថាញ់ និងសមាជិកនានានៃរដ្ឋាភិបាលរបស់ខ្លួនត្រូវបានចាប់ឃុំឃាំង។ ការបង្ក្រាបបែបនេះបានរាលដាលទៅដល់បណ្ដាអ្នកប្រឆាំងខាងនយោបាយ និងសឺង - ង៉ុកថាញ់ គឺបណ្ដាអ្នកស្នេហាមាតុភូមិ ដែលបានធ្វើការតស៊ូប្រឆាំងនឹងពួកឈ្លានពានជប៉ុន ដើម្បីរំដោះជាតិដ៏ពេញលេញ នៃប្រទេសរបស់ខ្លួន។

មជ្ឈដ្ឋានសក្តិភូមិ - រាជានិយមនានានៃប្រទេសកម្ពុជា ដឹកនាំដោយមហាក្សត្រ សីហនុ បានដើបដើរតាមមាគ៌ានៃកិច្ចព្រមព្រៀងសម្របសម្រួលជាមួយពួកចក្រពត្តិបារាំង នៅថ្ងៃទី៧ មករា ឆ្នាំ១៩៤៦ រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា បានចុះកិច្ចព្រមព្រៀងបណ្ដោះអាសន្នជាមួយរដ្ឋាភិបាលបារាំង “ម៉ូឌូសវីវ៉ែនឌី” ដែលតាមពិត បានអនុញ្ញាតឱ្យមានការរៀបចំឡើងវិញនូវរបបអាណាព្យាបាលបារាំង នៅប្រទេសកម្ពុជា។

ក្នុងការចុះហត្ថលេខា លើកិច្ចព្រមព្រៀងនាឆ្នាំ១៩៤៦ មជ្ឈដ្ឋានដឹកនាំនៃប្រទេសបារាំង បានធ្វើសេចក្ដីប្រកាសស្ដីអំពីការផ្ដល់ដល់ប្រទេសកម្ពុជា នូវ “ស្វ័យភាពផ្ទៃក្នុង” នៃប្រទេសនេះ

ដោយមានការពង្រីកខ្លះៗ នូវអំណាចរបស់រាជរដ្ឋាភិបាលចំពោះបញ្ហានានានៃការត្រួតត្រាខាងរដ្ឋបាលរបស់ប្រទេស។ កិច្ចព្រមព្រៀងនេះ បានទាំងពិនិត្យដល់ការកម្រិតខាងក្រៅខ្លះៗ ដល់សិទ្ធិរបស់ពួកអាណាព្យាបាលបារាំង ទាំងឡាយ។ ដូច្នេះ ស្នងការបារាំង ដែលមកជំនួសទេសាភិបាលជាន់ខ្ពស់ ឥឡូវនេះ បានទៅជាទីប្រឹក្សារបស់ស្ដេច។ នៅពេលមុន ទេសាភិបាល (រ៉េស៊ីដង់) គឺជាសមាជិកនៃក្រុមប្រឹក្សារដ្ឋមន្ត្រី នៃប្រទេសកម្ពុជា។

ប្រទេសបារាំង បានធ្វើការបន្ធូរបន្ថយដោយឡែកខ្លះៗ ដែលមានចុះនៅក្នុងកិច្ចព្រមព្រៀងបណ្ដោះអាសន្ន នាឆ្នាំ១៩៤៦ មិនបានផ្លាស់ប្ដូរអ្វីជាធំដុំដល់លក្ខណៈទូទៅ នៃកិច្ចព្រមព្រៀង ដែលយោងជាពិសេសទៅលើអត្ថន័យ ដែលបញ្ជាក់នូវការរៀបចំរបបអាណាព្យាបាលបារាំង ឡើងវិញ នៅប្រទេសកម្ពុជា។ តាមសេចក្ដីនៃកិច្ចព្រមព្រៀងនាឆ្នាំ១៩៤៦ ស្នងការបារាំងនៅប្រទេសកម្ពុជា បានកាន់កាប់អំណាចពេញលេញដ៏ទូលំទូលាយប្រហាក់ប្រហែលគ្នានឹងអំណាច របស់អ្នកអាណាព្យាបាលបារាំងជាន់ខ្ពស់នៅក្នុងអតីតកាល។ ស្របទៅតាមមាត្រា “ក” នៃកិច្ចព្រមព្រៀងនេះ សេចក្ដីសម្រេចទាំងអស់ខាងនីតិបញ្ញត្តិ និងនីតិប្រតិបត្តិរបស់រាជរដ្ឋាភិបាល ត្រូវទទួលការយល់ព្រមរបស់ស្នងការបារាំង ជាមុនសិន។ សកម្មភាពរបស់អង្គការនីតិប្រតិបត្តិស្ថិតនៅក្រោមការត្រួតត្រារបស់ទីប្រឹក្សាបារាំង ដែលមានការចាត់តាំងឱ្យធ្វើការអមទីស្ដីការរដ្ឋមន្ត្រី និងក្រសួងនានា។ នៅក្នុងកិច្ចព្រមព្រៀងមានការគូសបញ្ជាក់ ថា ការស្នាក់អាស្រ័យនៅនៃអង្គភាពកងទ័ពបារាំង លើទឹកដីប្រទេសកម្ពុជា ត្រូវស្ថិតនៅតែក្រោមកិច្ចបញ្ជាការបារាំង ម៉្យាង បានសេចក្ដីថា តាមអត្ថន័យនៃ

កិច្ចព្រមព្រៀងនេះ មានការអនុញ្ញាតឱ្យប្រទេសបារាំង រក្សានូវរបបកាន់កាប់ទឹកដីរបស់ខ្លួន។

ប្រទេសកម្ពុជា ត្រូវបានបញ្ចូលទៅក្នុងសមាសភាពសហព័ន្ធឥណ្ឌូចិន ដែលជាតំណាងនូវផ្នែកមួយដ៏សំខាន់នៃសហភាពបារាំង។ ប្រទេសកម្ពុជា មិនបានទទួលសិទ្ធិក្នុងការរៀបចំទំនាក់ទំនងខាងផ្លូវទូតជាមួយរដ្ឋាភិបាលបរទេសនានាទេ។

តាមពិត ការរៀបចំ នូវរបបអាណាព្យាបាលបារាំង ឡើងវិញនៅប្រទេសកម្ពុជា បានប្រព្រឹត្តទៅនៅក្នុងលក្ខខណ្ឌនៃការពង្រីកតទៅអនាគតនៃអន្តរាគមន៍ ខាងយោធារបស់ប្រទេសបារាំង នៅប្រទេសវៀតណាម។

បន្ទាប់ពីបានប្រមូលផ្តុំកម្លាំងកងទ័ព និងគ្រឿងបច្ចេកទេសយោធាមួយចំនួនធំនៅឥណ្ឌូចិន នៅខែធ្នូ ឆ្នាំ១៩៤៦ ពួកអាណានិគមនិយមបារាំង បានចាប់ផ្តើមធ្វើការវាយប្រហារភ្លាម ដោយមិនដឹងខ្លួន ទៅលើប្រទេសវៀតណាមខាងជើង ហើយផលវិបាកនៃអំពើឈ្លានពាន របស់ពួកវាត្រូវបានពង្រីកទៅលើទឹកដីទាំងអស់របស់សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម។ ក្នុងការប្រើប្រាស់គ្រឿងអាវុធយុទ្ធភណ្ឌដ៏ច្រើន លើសលុបនៅក្នុងកងកម្លាំងប្រដាប់អាវុធរបស់ខ្លួន និងដោយការវាយប្រហារភ្លាម ដោយមិនដឹងខ្លួន ពួកអន្តរាគមន៍បានធ្វើការវាយលុកចូលទីក្រុងហាណូយ និងទីក្រុងដទៃដ៏សំខាន់ៗ នៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម។

ការពង្រីកអន្តរាគមន៍យោធានៅវៀតណាម បានទាក់ទងទៅនឹងមធ្យោបាយខាងនយោបាយនានារបស់ពួកអាណានិគម

និយម ដែលមានប្រើប្រាស់នៅប្រទេសកម្ពុជា ដើម្បីពង្រឹងគោលជំហររបស់ខ្លួននៅប្រទេសនេះ។

នៅខែធ្នូ ឆ្នាំ១៩៤៦ ស្របតាមលក្ខខណ្ឌនៃសន្ធិសញ្ញាទីក្រុងវ៉ាស៊ីនតោន នាឆ្នាំ១៩៤៦ ប្រទេសថៃឡង់ដ៍ បានប្រគល់ខេត្តបាត់ដំបង និងសៀមរាប មកឱ្យប្រទេសកម្ពុជា វិញ។ ការបង្រួបបង្រួមខេត្តទាំងពីរនេះ ឱ្យចូលមកមាតុភូមិ នៃប្រទេសកម្ពុជា វិញ ត្រូវបានប្រើប្រាស់ដោយពួកអាណានិគមនិយមសម្រាប់ការឃោសនាអំពីលទ្ធផលជាវិជ្ជមាននៃសកម្មភាពរបស់ខ្លួននៅប្រទេសកម្ពុជា។

ការឃោសនារបស់ពួកបារាំង បានរីកសាយទៅដល់ការចាត់វិធានការផ្សេងៗ ជាអាទិ មានការរៀបចំប្រព័ន្ធរដ្ឋាភិបាលប្រទេសកម្ពុជា ឱ្យមានលក្ខណៈទំនើបសម័យថ្មី។ នៅឆ្នាំ១៩៤៦ របបអាណាព្យាបាលបារាំង បានព្រមព្រៀងអនុវត្តការកែប្រែខាងនយោបាយនៅប្រទេសកម្ពុជា ដោយមានគ្រោងទុកនូវការបង្កើតរដ្ឋសភា ព្រមទាំងបក្សនយោបាយនានា ដែលត្រូវតំណាងផលប្រយោជន៍ឱ្យវណ្ណៈគហបតីពាណិជ្ជករនៅក្នុងប្រទេស តំណាងផលប្រយោជន៍ឱ្យនាហ្មឺននានានៃរដ្ឋបាល ព្រមទាំងបញ្ញវន្តអភិរក្សនិយមមួយចំនួន។ តាមគំរោងរបស់ពួកអាណានិគមនិយម ការបង្កើតឱ្យមានជីវភាពរស់រវើកខ្លះ ក្នុងសកម្មនយោបាយរបស់ពួកអ្នកតំណាង នៃស្រទាប់ជាន់ខ្ពស់របស់សង្គមមនុស្សដូចមានអធិប្បាយខាងលើនេះ នឹងអាចបង្កើតឱ្យមានការយល់ដោយរវើរវាយនូវលក្ខណៈ “ ស្វ័យភាព ” នៃរដ្ឋកម្ពុជា។ ក៏ប៉ុន្តែតាមពិត ការណ៍នេះបានពន្យឺតដល់ការរីកចម្រើននូវចលនាតស៊ូរំដោះជាតិនៅក្នុងប្រទេស។

នៅឆ្នាំ១៩៤៦ នៅប្រទេសកម្ពុជា បក្សនយោបាយតូចបី ត្រូវបានបង្កើតឡើង គឺៈ បក្សប្រជាធិបតេយ្យ, បក្សសេរីភាព និងបក្សប្រជាធិបតេយ្យចម្រើននិយម។ បក្សទាំងអស់នេះបាន បង្កើតសកម្មភាព ដែលហៅថា បក្សទំនាស់គ្នាដ៏ត្រឹមត្រូវតាមច្បាប់ ហើយដែលបានធ្វើការទាមទារ ឱ្យមានការរៀបចំនូវអធិបតេយ្យភាព នៃប្រទេសបន្តិចម្តងៗតាមសន្តិវិធី ហើយនៅពេលជាមួយគ្នា បាន ថ្លែងប្រឆាំងនឹងកងកម្លាំងស្នេហាមាតុភូមិខ្មែរឥស្សរៈ។

នៅខែកញ្ញា ឆ្នាំ១៩៤៦ នៅទីក្រុងភ្នំពេញ មានការបង្កើត ការបោះឆ្នោតជ្រើសរើសរដ្ឋសភា ដែលត្រូវធ្វើការអនុម័តលើ គំរោងច្បាប់រដ្ឋធម្មនុញ្ញ។ នៅក្នុងការបោះឆ្នោតនេះ បក្សប្រជា ធិបតេយ្យ ដែលធ្វើការឃោសនាតាមកម្មវិធីទាមទារឱ្យមាន ស្វ័យភាពជាអតិបរមាដល់ប្រទេសកម្ពុជា និងឱ្យមានការពង្រីក សិទ្ធិរដ្ឋធម្មនុញ្ញរបស់អនាគតរដ្ឋសភា បានទទួលសំឡេងភាគ ច្រើន។

រដ្ឋធម្មនុញ្ញទី១ នៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ត្រូវ បានអនុម័តដោយមហាក្សត្រនាថ្ងៃទី៦ ឧសភា ឆ្នាំ១៩៤៧។ សេចក្តីប្រកាសថា ប្រទេសកម្ពុជា ជារាជាណាចក្រប្រកបដោយ រដ្ឋធម្មនុញ្ញ គឺជាជំហានទៅមុខមួយដ៏ច្បាស់លាស់ បើគេយោង យោបល់របស់ខ្លួន ទៅតាមទស្សនៈនៃការធ្វើឱ្យស្ថាប័នរដ្ឋមាន លក្ខណៈទំនើបនិយម។ ក៏ប៉ុន្តែ ការណ៍នេះមិនមែនមានន័យ ថា ជាចលនាអ្វីមួយនៅក្នុងវិស័យ នៃការពង្រីកអធិបតេយ្យភាព របស់ប្រទេសទេ។ ស្របទៅតាមរដ្ឋធម្មនុញ្ញ នាឆ្នាំ១៩៤៧ ប្រទេសកម្ពុជា ត្រូវបានប្រកាស ជា “រដ្ឋប្រកបដោយស្វ័យភាព” ដែលស្ថិតក្នុងសមាសភាព នៃសហភាពបារាំង បានសេចក្តីថា

តាមលក្ខណៈច្បាប់ ការណ៍នេះ ទៅជាបានពង្រឹងដល់អនិស្សរភាព (គឺភាពមិនម្ចាស់ការ) របស់ប្រទេស ទៅនឹងប្រទេសបារាំងទៅវិញ។

នៅខែធ្នូ ឆ្នាំ១៩៤៧ នៅក្នុងតំបន់នៃដែនដីកាន់កាប់ដោយអង្គភាពនៃកងទ័ពបារាំង មានការបង្កើតការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់រដ្ឋសភា ហើយនៅក្នុងការបោះឆ្នោតនេះ បក្សប្រជាធិបតេយ្យបានទទួលជ័យជម្នះថ្មី ដោយបក្សនេះទទួលបានតំណាងរាស្ត្រពីរភាគបី នៃតំណាងរាស្ត្រនៅរដ្ឋសភា។

ព្រឹត្តិការណ៍នានា ទាក់ទងទៅនឹងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់រដ្ឋសភា និងការអនុវត្តការកែប្រែរដ្ឋធម្មនុញ្ញ មិនបានផ្តល់លទ្ធភាពដល់ការបញ្ឈប់ភាពតានតឹងខាងនយោបាយ ដែលកើតមានឡើងនៅក្នុងប្រទេស និងស្ថានភាពអាក្រក់ខាងសេដ្ឋកិច្ច ដែលកើតមានកាន់តែខ្លាំងឡើង។ អន្តរាគមន៍បារាំង បានទៅជាទម្ងន់ដ៏ធ្ងន់ធ្ងរដល់សេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ដោយហេតុថា មូលដ្ឋានខាងហិរញ្ញវត្ថុ និងសម្ភារៈរបស់ប្រទេសត្រូវបានរង្គោះរង្គើយ៉ាងខ្លាំង ដោយរបបកាន់កាប់ទឹកដី នៃយោធានិយមរបស់ប្រទេសជប៉ុន។

នៅក្នុងអំឡុងឆ្នាំ១៩៤១ - ១៩៤៨ ទំហំនៃផលិតកម្មខាងកសិកម្មរបស់ប្រទេសបានចុះថយ ពី២០ - ៣០ភាគរយ។ ជាពិសេស ផលិតកម្មខាងធញ្ញជាតិបានទទួលការខូចខាតជាងគេ។ ដោយមានការបាត់បង់ផ្សារលក់ដូរចាស់របស់ខ្លួន ប្រទេសកម្ពុជាត្រូវបានបន្ថយកម្រិតនៃផលិតកម្មខាងធញ្ញជាតិ ៣ដង និងការនាំចេញនៃគ្រាប់ពោត ដែលនៅពេលនោះ ជាដំណាំដ៏សំខាន់ទី

ពីរនៅក្នុងប្រទេស។ ការបង់ខាតនេះបានផ្តល់ឥទ្ធិពលអាក្រក់ដល់ស្ថានភាពនៃរបរកសិកម្មរបស់កសិករតូចតាច ដែលជាពិសេសប្រកបអាជីវកម្មផលិតកម្មផលដំណាំ សម្រាប់ការនាំចេញទៅក្រៅប្រទេស។

នយោបាយខាងហិរញ្ញវត្ថុរបស់អាណានិគមនិយម ដែលយោងទៅលើការបន្ថោកតម្លៃ ដល់រូបិយប័ណ្ណរបស់ប្រទេស (ប្រាក់រៀលឥណ្ឌូចិន) បានធ្វើឱ្យមានការខូចខាតជាខ្លាំងដល់សេដ្ឋកិច្ចនៃប្រទេសកម្ពុជា។ កាលៈទេសៈបែបនេះ បានជំរុញឱ្យមានការបន្ថោកតម្លៃដល់វត្ថុធាតុដើមនៃសេដ្ឋកិច្ចកសិកម្មនៅក្នុងប្រទេសនានា នៃឥណ្ឌូចិន។ មធ្យោបាយគៃបន្លំខាងហិរញ្ញវត្ថុរបស់ធនាគារបារាំង បានជះឥទ្ធិពលអាក្រក់មកលើប្រទេសកម្ពុជា ដោយធ្វើឱ្យប្រទេសនេះមានការបង់ខាតខាងសម្ភារៈដ៏សំខាន់ ដែលទាក់ទងទៅនឹងការចាំបាច់ នៅក្នុងការនាំចេញនូវផលដំណាំខាងកសិកម្មរបស់ខ្លួនទៅតាមតម្លៃដ៏ថោកបំផុត។

ទម្ងន់ដ៏ធ្ងន់ធ្ងររបស់អន្តរាគមន៍បារាំង និងរបស់ពួកជប៉ុនកាន់កាប់ទឹកដីកម្ពុជា បានធ្លាក់មកលើស្មានៃវណ្ណៈកសិករកម្ពុជាដែលជាវណ្ណៈមួយ ប្រកបដោយប្រជាពលករច្រើនជាងគេនៅក្នុងប្រទេស។ ការចុះតម្លៃប្រាក់ ដែលកើតមានឡើងជាបន្តបន្ទាប់នៅប្រទេសនានានៃឥណ្ឌូចិន បានបណ្តាលឱ្យមានការបង្កើននូវអំពើជិះជាន់លើបណ្តាកសិករកម្ពុជា ដោយមូលធនរបស់ពួកពាណិជ្ជករ និងអ្នកចងការប្រាក់។ ហេតុនេះហើយ បានជាអាជីវកម្មរបស់កសិករដ៏ក្រីក្របំផុត កាន់តែមានស្ថានភាពយ៉ាប់យ៉ឺន។ នៅសម័យកាលនៃសង្គ្រាមលោកលើកទីពីរ នៅប្រទេសកម្ពុជា ស្រទាប់នៃកសិករគ្មានដីស្រែចម្ការបានកកើតឡើង

ការណ៍នេះបានជំរុញឱ្យមានការបង្កើនចំនួននៃវណ្ណៈអធននៅស្រុកស្រែ និងនៅទីក្រុង។

ស្ថានភាពរង្គោះរង្គើខាងសេដ្ឋកិច្ច និងសង្គមកិច្ចដែលកកើតមានឡើងដោយព្រឹត្តិការណ៍នានា ក្នុងសម័យកាលនៃការកាន់កាប់ទឹកដី ដោយប្រទេសជប៉ុន និងក្នុងសម័យកាលនៃអន្តរាគមន៍របស់ប្រទេសបារាំង បានផ្តល់លទ្ធភាពឱ្យមានការពង្រីកមូលដ្ឋាននយោបាយនៃចលនាតស៊ូរំដោះជាតិនានារបស់ខ្មែរឥស្សរៈនៅប្រទេសកម្ពុជា។ កាលនោះ ជនកុម្មុយនិស្តកម្ពុជាដែលបានចូលជាសមាសភាពនៃក្រុមខ្មែរ របស់បក្សកុម្មុយនិស្តឥណ្ឌូចិន បានបំពេញតួនាទីដ៏សំខាន់ក្នុងយុទ្ធនយោបាយជួរមុខនៃកងកម្លាំងស្នេហាមាតុភូមិរបស់ខ្មែរឥស្សរៈ។

នៅឆ្នាំ១៩៤៦ កងកម្លាំងស្នេហាជាតិមាតុភូមិខ្មែរឥស្សរៈបានបង្កើត “ គណៈកម្មាធិការរំដោះជាតិ ” នៅលើទឹកដីរំដោះដែលស្ថិតនៅតំបន់ពាយព្យនៃប្រទេសកម្ពុជា។ មូលដ្ឋានខាងក្រោយនានារបស់ខ្មែរឥស្សរៈ ត្រូវបានបង្កើតនៅតំបន់ប៉ែកខាងនិរតី និងឦសាននៃប្រទេស។ ដោយសារមូលដ្ឋានទាំងនេះ ចលនាខ្មែរឥស្សរៈ មានលទ្ធភាពក្នុងការពង្រីកចម្បាំងលបធ្មក់របស់ខ្លួន ប្រឆាំងពួកចក្រពត្តិនិយមបារាំង និងពួកចូលដៃរបស់ពួកវា ដែលមានទាំងពួកសក្តិភូមិរាជានិយមជាន់ខ្ពស់នៃប្រទេសកម្ពុជា ផង។

នៅក្នុងសម័យនោះ អង្គភាពនៃកងទ័ពបារាំងនៅវៀតណាមបានធ្វើការសាកល្បងវាយយកតំបន់វៀតបាក (ដែលជាតំបន់ព្រៃភ្នំនៅប្រទេសវៀតណាមខាងជើង) ហើយតាមការវាយលុកនេះ កងទ័ពបារាំង បម្រុងធ្វើការវាយលុកជាចុងក្រោយបង្អស់

នៅសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម។ ការវាយសម្រុកដ៏ខ្លាំងក្លាទៅលើតំបន់វៀតបាក រៀបចំឡើងដោយពួកអាណានិគមនិយម បានប្រព្រឹត្តទៅនៅរដូវភ្លៀងនៅឆ្នាំ១៩៤៧ ហើយតាមពិត ការវាយលុកនេះបានទទួលបរាជ័យ។ ចាប់តាំងពីឆ្នាំ១៩៤៨ មក មេបញ្ជាការបារាំង នៅឥណ្ឌូចិន មិនបានចាត់វិធានការដ៏ធំដុំក្នុងការធ្វើប្រតិបត្តិការវាយលុក ហើយបានប្រើប្រាស់យុទ្ធសាស្ត្រ នៃការធ្វើចម្បាំងការពារស្ថានភាពដែលខ្លួនបានកាន់កាប់។

អនាគតនៃសង្គ្រាមដ៏តានតឹង និងយូរអង្វែងនៅឥណ្ឌូចិន បានទាក់ទាញឱ្យពួកអាណានិគមនិយម ពិនិត្យសាជាថ្មីនូវឥរិយាបថនយោបាយរបស់ខ្លួននៅប្រទេសកម្ពុជា ហើយបណ្តាលឱ្យពួកនេះធ្វើការបន្ធូរបន្ថយខ្លះៗខាងនយោបាយ។

នៅថ្ងៃទី២៥ វិច្ឆិកា ឆ្នាំ១៩៤៨ ប្រធានាធិបតី នៃប្រទេសបារាំង នាម វ៉ាំងសង់-អូរីយ៉ូល បានផ្ញើសារលិខិតមួយមករាជរដ្ឋាភិបាលកម្ពុជា ដែលនៅក្នុងនេះមានបញ្ជាក់អំពីការទទួលស្គាល់នូវ “ ឯករាជភាព ” នៃប្រទេសកម្ពុជា “ នៅក្នុងក្របខ័ណ្ឌនៃសហភាពបារាំង ”។ នៅខែឧសភា ឆ្នាំ១៩៤៩ ពួកអាណានិគមនិយម បានយល់ព្រមដកកងទ័ពរបស់ខ្លួនបន្តិចម្តងៗ ថយចេញពីខេត្តខ្លះៗ នៃប្រទេសកម្ពុជា។ នៅក្នុងខេត្តទាំងនេះ មានការសម្រេចបង្កើត “ តំបន់ស្វ័យភាព ” ដែលស្ថិតនៅក្រោមអំណាចស៊ីវិល និងយោធារបស់មហាក្សត្រកម្ពុជា។

នៅរដូវប្រាំងនៃឆ្នាំ១៩៤៩ មានការប្រគល់ខេត្តពីរឱ្យស្ថិតនៅក្រោមការត្រួតត្រារបស់រាជរដ្ឋាភិបាល គឺខេត្តសៀមរាប និងខេត្តកំពង់ធំ។ ក៏ប៉ុន្តែ នៅពេលនោះ អាជ្ញាធរបារាំង មិន

យល់ព្រមបញ្ជាក់កាលបរិច្ឆេទច្បាស់លាស់ នៃការដកកងទ័ពរបស់ខ្លួនថយពីខេត្តដទៃទៀត នៃប្រទេសកម្ពុជា ហើយពួកវាខំសាកល្បងមិនព្រមបញ្ជាក់ឱ្យច្បាស់លាស់ អំពីការកម្រិតកិច្ចត្រួតពិនិត្យខាងនយោបាយ និងយោធារបស់ខ្លួនទៅលើខេត្តទាំងនេះ។ បំណងរបស់ពួកអាណានិគមនិយម ដើម្បីរក្សានូវរបបកាន់កាប់ទឹកដីរបស់ខ្លួន គេអាចឃើញច្បាស់នៅក្នុងអត្ថបទថ្មីនៃសន្ធិសញ្ញាបារាំង-កម្ពុជា ដែលត្រូវធ្វើឡើងដើម្បីជំនួសកិច្ចព្រមព្រៀងបណ្ដោះអាសន្ននាឆ្នាំ១៩៤៦។ ពិធីចុះហត្ថលេខាលើសន្ធិសញ្ញានេះ បានប្រព្រឹត្តទៅនៅថ្ងៃទី៨ វិច្ឆិកា ឆ្នាំ១៩៤៩ នៅទីក្រុងប៉ារីស។ ស្របតាមសន្ធិសញ្ញានេះ ប្រទេសបារាំង បានទទួលស្គាល់ថា ប្រទេសកម្ពុជា ជា “ រដ្ឋឯករាជ្យ ” (មាត្រា១)។ រាជរដ្ឋាភិបាលបានថ្លែងបញ្ជាក់នូវការរួបរួមរបស់ប្រទេសកម្ពុជា ក្នុងសហភាពបារាំង ក្នុងឋានៈជា “ រដ្ឋដែលចូលរួបរួមក្នុងសហភាពនេះ ”។ ប្រទេសកម្ពុជា បានទទួលសិទ្ធិតែងតាំងតំណាងរបស់ខ្លួន នៅក្នុងក្រុមប្រឹក្សាជាន់ខ្ពស់នៃសហភាពបារាំង ព្រមទាំងបានទទួលសិទ្ធិក្នុងការរៀបចំទំនាក់ទំនងកិច្ចការទូតដោយត្រង់ៗ ជាមួយនឹងរដ្ឋាភិបាលបរទេស។ នៅក្នុងសន្ធិសញ្ញា ឆ្នាំ១៩៤៩ មានគូសបញ្ជាក់ថា “ រាជរដ្ឋាភិបាលប្រទេសកម្ពុជា មានបុព្វសិទ្ធិ និងអំណាចពេញសមត្ថភាពក្នុងកិច្ចចាត់ចែងកិច្ចការផ្ទៃក្នុងរបស់ប្រទេស ” (មាត្រា ៤)។

ក៏ប៉ុន្តែ ការទទួលស្គាល់នូវសិទ្ធិនានារបស់ប្រទេសកម្ពុជាដូចមានចែងខាងលើ ប្រកបទៅដោយសេចក្ដីលើកលែងជាច្រើន ដែលធ្វើឱ្យស្វ័យភាពរដ្ឋ ទៅជាចង្អៀតចង្អល់ជាអតិបរមា។ ហេតុនេះហើយ បានជាក្នុងការផ្ដល់នូវសេរីភាពសម្រាប់ការ

រៀបចំទំនាក់ទំនងខាងក្រៅរបស់ប្រទេសកម្ពុជា នៅពេលជាមួយគ្នាសន្ធិសញ្ញាបានគូសបញ្ជាក់ថា បណ្តាឯកអគ្គរាជទូតកម្ពុជា នឹងអាចតែងតាំងបានក៏ដោយសារសេចក្តីយល់ព្រមរបស់រដ្ឋាភិបាលបារាំង ហើយសារតាំងអគ្គរដ្ឋទូត ក៏ត្រូវប្រគល់ដោយប្រធានាធិបតីបារាំង (មាត្រា១៧) ផងដែរ ។ ការទទួលស្គាល់នូវអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្លួន ក៏មានទម្រង់លំអតែខាងក្រៅ ដោយហេតុថា អំណាចយោធាជាន់ខ្ពស់បានស្ថិតនៅក្នុងកណ្តាប់ដៃរបស់ពួកបារាំង នៅឡើយ។

នៅក្នុងសេចក្តីបន្ថែមជាពិសេសទៅលើសន្ធិសញ្ញា ឆ្នាំ១៩៤៩ (របស់ដែលហៅថា អនុសញ្ញាបន្ថែម ស្តីអំពីបញ្ហាយោធា) មានសេចក្តីបញ្ជាក់ថា ប្រទេសកម្ពុជា ទទួលសិទ្ធិក្នុងការកសាងកងទ័ពជាតិ ដែលស្ថិតនៅក្រោមការត្រួតត្រាផ្ទាល់របស់មហាក្សត្រ។ ក៏ប៉ុន្តែ តមកទៀត មានសេចក្តីបញ្ជាក់ថា នៅពេលសង្គ្រាមកងទ័ពកម្ពុជា ត្រូវស្ថិតនៅក្រោមគណៈកម្មាធិការយោធាពិសេសដែលកិច្ចបញ្ជាការត្រូវ ស្ថិតនៅក្នុងកណ្តាប់ដៃអ្នកតំណាងទីបញ្ជាការបារាំង។

ហេតុនេះហើយ បានជាការទទួលស្គាល់ឯករាជភាពនៃប្រទេសកម្ពុជា នាខែវិច្ឆិកា ឆ្នាំ១៩៤៩ មានលក្ខណៈជាសេចក្តីថ្លែងការណ៍សុទ្ធសាធ។ តាមពិត ការបន្ធូរបន្ថយរបស់ប្រទេសបារាំង នានា មិនបានគ្រប់ដណ្តប់ទៅលើមូលដ្ឋាននៃការត្រួតត្រាជាច់មុខខាងយោធា និងនយោបាយរបស់ប្រទេសនេះនៅក្នុងប្រទេសកម្ពុជា ឡើយ។

នៅរដូវវស្សានៃឆ្នាំ១៩៥០ ប្រទេសកម្ពុជា ត្រូវបានបន្ទាញឱ្យចូលរួមក្នុងប្រព័ន្ធរដ្ឋបាលគយ និងរូបិយប័ណ្ណ ដែលមានចុះ

ជាកិច្ចព្រមព្រៀងរវាងប្រទេសបារាំង និងរដ្ឋជាសមាជិកសហភាពបារាំង នានានៅឥណ្ឌូចិន។ នៅក្នុងសមត្ថភាពរបស់ប្រព័ន្ធចតុភាគីនេះ មានទាំងការបញ្ចូលវិស័យដ៏សំខាន់ៗនៃកិច្ចត្រួតត្រា និងសកម្មភាពខាងសេដ្ឋកិច្ច ដូចជា ពាណិជ្ជកម្មក្រៅប្រទេស ការត្រួតពិនិត្យរបស់រដ្ឋការគយ ប្រព័ន្ធរូបិយប័ណ្ណ និងគមនាគមន៍របស់រដ្ឋ ដែលមានបញ្ជាក់ខាងលើ។ នៅក្រោមកិច្ចត្រួតត្រារបស់ប្រព័ន្ធចតុភាគី មានទាំងធនាគារឥណ្ឌូចិន ដែលកសាងឡើងដើម្បីការប្តូររូបិយប័ណ្ណ មានទាំងគ្រឹះស្ថានដទៃមួយចំនួនទៀតដែលមានភារៈដោះស្រាយបញ្ហាផ្សេងៗ ទាក់ទងទៅនឹងការធ្វើគម្រោងការសេដ្ឋកិច្ច ចរាចរណ៍កប៉ាល់តាមទន្លេមេកុង ការប្រើប្រាស់រួមនៃកំពង់ផែព្រៃនគរ និងបញ្ហាដទៃផ្សេងទៀត។ មុខងារដ៏សំខាន់របស់ប្រព័ន្ធចតុភាគី គឺការត្រួតត្រាលើប្រព័ន្ធក្រសួងគយនៃប្រទេសនានានៅឥណ្ឌូចិន។

តាមទម្រង់ខាងក្រៅស្ថាប័នទាំងអស់ នៃប្រព័ន្ធសេដ្ឋកិច្ចរបស់ប្រទេសទាំងនេះ បានកសាងឡើងលើគោលការណ៍នៃចតុភាគី ក៏ប៉ុន្តែតាមពិតសិទ្ធិនៃការបញ្ចេញសំឡេងក្នុងការសម្រេចបានធ្លាក់មកលើបន្ទុកប្រទេសបារាំង ដែលបានប្រើប្រាស់ស្ថានភាពអនិស្សរភាពរបស់ “ រដ្ឋជាសមាជិកសហភាពបារាំងនានានៅឥណ្ឌូចិន ” ដើម្បីបម្រើផលប្រយោជន៍ផ្ទាល់របស់ខ្លួន។

ការបង្កើតសហភាពចតុភាគី បានជួយដល់ពួកអាណានិគមនិយម ឱ្យបន្តការកាន់កាប់កិច្ចត្រួតត្រាខាងសេដ្ឋកិច្ចជាមូលដ្ឋានរបស់ប្រទេសនានានៅឥណ្ឌូចិន នៅក្នុងកណ្តាប់ដៃរបស់ខ្លួននៅក្នុងរយៈកាលមួយដ៏ច្បាស់លាស់។

គោលបំណងរបស់ពួកចក្រពត្តិបារាំង ដើម្បីស្រោចស្រង់របបអាណានិគមនិយមនៅប្រទេសកម្ពុជា ក្រោមទង់នៃ " ការរៀបចំឡើងវិញ " នូវឯករាជភាពរបស់ប្រទេសនេះ នៃការរៀបចំស្ថាប័នគ្រប់គ្រងអាណានិគមនិយម ឱ្យមានលក្ខណៈទំនើបសម័យថ្មី។ ការណ៍ទាំងនេះបណ្តាលឱ្យមានចលនាកំហឹងមិនពេញចិត្តនឹងការប្រឆាំងគ្រប់បែបយ៉ាងនៅក្នុងប្រទេស។ ស្ថានភាពនយោបាយក្នុងប្រទេសបានប្រែប្រួល ទៅជាមានលក្ខណៈតានតឹង។ ទោះបីមានប្រតិបត្តិការបង្ក្រាបដ៏កាចសាហាវ ដ៏សកម្មរបស់កងទ័ពបារាំង យ៉ាងណាក៏ដោយ ក៏កងកម្លាំងប្រដាប់អាវុធរំដោះជាតិខ្មែរឥស្សរៈ បានធ្វើការវាយប្រហារដ៏ដំណំកាន់តែខ្លាំងមកលើពួកអាណានិគមនិយម។

នៅឆ្នាំ១៩៥០ ចលនានៃការប្រយុទ្ធរំដោះជាតិនៅប្រទេសកម្ពុជា បានចូលក្នុងដំណាក់កាលមួយថ្មីនៃការរីកចម្រើនរបស់ខ្លួនដោយការលើកឡើងយ៉ាងខ្ពស់ នូវការប្រយុទ្ធដើម្បីរំដោះជាតិនៅប្រទេសនានានៃឥណ្ឌូចិន។ នៅថ្ងៃទី១៧ - ១៩ មេសា ឆ្នាំ ១៩៥០ នៅលើដែនដីរំដោះនៃប្រទេសកម្ពុជា តាមសេចក្តីផ្តើមគំនិតរបស់អង្គការបដិវត្តន៍ប្រជាធិបតេយ្យ ខ្មែរឥស្សរៈមានការបើកសម័យប្រជុំសន្និបាតមួយ របស់អ្នកតំណាងប្រជាជន។ ប្រតិភូចំនួនពីររយនាក់ដែលនៅក្នុងនេះ មានកសិករ សិប្បករ កម្មករ ព្រះសង្ឃស្នេហាមាតុភូមិ បញ្ញវន្ត និងពាណិជ្ជករតូចតាចទាំងអស់គ្នាបានចូលរួមក្នុងសន្និបាតនេះ។

សម័យប្រជុំនៃសន្និបាត បានបញ្ជាក់អំពីមាគ៌ានយោបាយនិងភារកិច្ចចំពោះមុខ ជាមូលដ្ឋាននានា របស់ចលនាតស៊ូរំដោះ

ជាតិប្រទេសកម្ពុជា ដោយពាក្យស្លោកទាំងឡាយដូចមានតទៅ៖ “ការពង្រឹង និងពង្រីកសង្គ្រាមលបធ្មក់ ការកសាង និងការពង្រឹងកងកម្លាំងប្រដាប់អាវុធរំដោះជាតិ ការពង្រឹងជួរ និងពង្រីករណសិរ្សខ្មែរឥស្សរៈ ការបង្កើតអង្គការអំណាចខាងនយោបាយនៃកងកម្លាំងរបស់ចលនាតស៊ូរំដោះជាតិ ការធានាប៉ះរងដល់សេរីភាពខាងសតិអារម្មណ៍ និងជំនឿសាសនា ការធានាប៉ះរងដល់សិទ្ធិនានា និងដល់កាតព្វកិច្ចនានា សម្រាប់ជនជាតិទាំងអស់នៃប្រទេសកម្ពុជា ការបង្កើតផលិតកម្មសម្រាប់បំពេញសេចក្តីត្រូវការរបស់អ្នកស្រុក ព្រមទាំងការបង្កើនកម្រិតជីវភាពរបស់ប្រជាជន ការរក្សា និងពង្រីកវប្បធម៌ប្រពៃណីខ្មែរ ការតស៊ូដើម្បីសន្តិភាព និងប្រជាធិបតេយ្យលើសកលលោកទាំងមូល”។

នៅក្នុងសម័យប្រជុំនៃសន្និបាត ប្រតិភូទាំងឡាយបានសម្រេចចិត្តបង្កើតរណសិរ្សឯកភាពជាតិខ្មែរឥស្សរៈ (សមាគមខ្មែរឥស្សរៈ) ដែលមានសមមិត្ត ទូ សាមុត ជាប្រធាន។ នៅពេលជាមួយគ្នា ប្រតិភូទាំងឡាយបានជ្រើសរើសគណៈកម្មាធិការរំដោះជាតិមជ្ឈិមបណ្តោះអាសន្នរបស់រណសិរ្ស ដែលមានសមមិត្ត សឺង-ង៉ុកមិញ (អាចារ្យមៀន) ជាប្រធាន។ នៅក្នុងជួរនានានៃរណសិរ្សឯកភាពជាតិ មានការបង្រួបបង្រួមនូវអង្គការផ្សេងៗ គឺអង្គការយោធា និងសង្គមកិច្ចរបស់ខ្មែរឥស្សរៈ ដែលបានកសាងឡើងបន្ទាប់ពីឆ្នាំ១៩៤៥ អង្គការកសិករ សហភាពសហជីពខ្មែរ សហភាពយុវជន និងនារី។ អង្គការទាំងនេះស្ថិតនៅលើដែនដីរំដោះរបស់ប្រទេស ហើយមានសាខានៃការប្រយុទ្ធដ៏លាក់កំបាំងរបស់ខ្លួននៅតំបន់នានា ដែលស្ថិតនៅក្នុងទឹកដីកាន់កាប់ដោយសត្រូវ។

នៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ១៩៥១ នៅក្នុងសម័យប្រជុំនៃសន្និបាតរបស់អ្នកតំណាងប្រជាជន តាងនាមនៃខ្មែរឥស្សរៈសមមិត្តអាចារ្យមៀន ប្រកាសសេចក្តីថ្លែងការណ៍ឯករាជ្យជូនប្រទេសកម្ពុជា។

ការបង្កើតរណសិរ្សឯកភាពជាតិខ្មែរឥស្សរៈ គឺតុល្យការមួយបែបនៃការតស៊ូរួមរបស់ប្រជាជនទាំងឡាយ នៃប្រទេសកម្ពុជា ប្រទេសវៀតណាម និងប្រទេសឡាវ ដើម្បីឯករាជ្យជាតិរបស់ខ្លួនក្រោមកិច្ចដឹកនាំរបស់បក្សកុម្មុយនិស្តឥណ្ឌូចិន (ប.ក.ឥ)។

នៅខែកុម្ភៈ ឆ្នាំ១៩៥១ មានការបើកសម័យមហាសន្និបាតទីពីររបស់បក្សកុម្មុយនិស្តឥណ្ឌូចិន។ ដោយយោងទៅតាមសភាពការណ៍ថ្មីៗ ដែលកើតមានឡើងនៅឥណ្ឌូចិន និងលើឆាកនយោបាយអន្តរជាតិ មហាសន្និបាតលើកទីពីររបស់បក្សកុម្មុយនិស្តឥណ្ឌូចិន បានអនុម័តលើសេចក្តីសម្រេច ដើម្បីបង្កើតបក្សរបស់ជនកុម្មុយនិស្តវៀតណាម ដែលមានឈ្មោះថាបក្សពលកររៀតណាម ហើយកម្មវិធីនយោបាយ និងលក្ខន្តិកៈរបស់បក្សនេះមានលក្ខណៈស្របទៅនឹងលក្ខខណ្ឌច្បាស់លាស់នានានៃប្រទេសវៀតណាម។ នៅពេលជាមួយគ្នា មហាសន្និបាតក៏បានអនុម័តលើសេចក្តីសម្រេច ស្តីអំពីការចាត់តាំងបក្សបដិវត្តន៍ម៉ាក្ស-ឡេនីននិយម ដោយជនកុម្មុយនិស្តនៃប្រទេសកម្ពុជា និងប្រទេសឡាវ។ នៅក្នុងប្រទេសទាំងនេះ និងដោយយោងទៅតាមលក្ខខណ្ឌច្បាស់លាស់នៃប្រទេសកម្ពុជា និងប្រទេសឡាវ ។ អនុវត្តតាមសេចក្តីសម្រេចខាងលើនេះ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៥១ មានការសម្រេចចិត្តបង្កើតឡើងបក្សប្រជាជនបដិវត្តន៍កម្ពុជា។

សមមិត្តសឹង - ង៉ុកមិញ ដែលជាយុទ្ធជនជើងចាស់ក្នុងចលនាតស៊ូរំដោះជាតិ ត្រូវបានគេជ្រើសរើសឱ្យធ្វើជាអ្នកដឹកនាំរបស់បក្ស។ បក្សប្រជាជនបដិវត្តន៍កម្ពុជា បានទៅជាបក្សជួរមុខនៃកងកម្លាំងស្នេហាមាតុភូមិរបស់ប្រទេស។ បក្សប្រជាជនបដិវត្តន៍កម្ពុជា ប្រកៀកស្មាគ្នាយ៉ាងជិតស្និទ្ធជាមួយបក្សពលកររៀតណាម និងបក្សប្រជាជនបដិវត្តន៍ឡាវ បានពង្រីកសកម្មភាពនៃការប្រយុទ្ធរបស់ខ្លួនប្រឆាំង ពួកអាណានិគមនិយមបារាំង និងបរិវាររបស់វានៅក្នុងប្រទេស។

ការរីកចម្រើនរបស់ចលនារំដោះជាតិ នៅប្រទេសនានានៃឥណ្ឌូចិន នៅសម័យខាងដើមនៃទសវត្សរ៍ទី៥ បានប្រព្រឹត្តទៅនៅក្នុងស្ថានភាព នៃការចូលជ្រៀតជ្រែកដ៏ចំហរបស់សហរដ្ឋអាមេរិក នៅក្នុង “ សង្គ្រាមដ៏ក្រខ្វក់ ” បង្កបង្កើតឡើងដោយពួកអាណានិគមនិយមបារាំង នៅក្នុងតំបន់នៃពិភពលោកនេះ។

សហរដ្ឋអាមេរិក យល់ព្រម និងគាំទ្រដល់នយោបាយបារាំងនៅប្រទេសកម្ពុជា ដោយមានគោលដៅដើម្បីបំបែកបំបាក់ និងបង្ក្រាបចលនាតស៊ូរំដោះជាតិ។ នៅខែកុម្ភៈ ឆ្នាំ១៩៥០ សហរដ្ឋអាមេរិក បានទទួលស្គាល់ “ ឯករាជភាព ” របស់ប្រទេសកម្ពុជា ដែលមានប្រកាសយ៉ាងគគ្រឹកគគ្រេង នៅក្នុងសន្ធិសញ្ញានាឆ្នាំ ១៩៤៩ ហើយនៅខែធ្នូ ឆ្នាំ១៩៥០ មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងបារាំង-អាមេរិក ស្តីអំពីការផ្តល់ជំនួយយោធាដល់កម្លាំងប្រដាប់អាវុធបារាំង នៅឥណ្ឌូចិន ដោយសហរដ្ឋអាមេរិក។ ស្របតាមកិច្ចព្រមព្រៀងនេះ ជំនួយខាងសម្ភារៈ និងហិរញ្ញវត្ថុដល់អង្គភាពនៃកងទ័ពបារាំង ត្រូវបានបង្កើនយ៉ាង

ខ្លាំង ហើយការផ្តល់គ្រឿងបច្ចេកទេសយោធាអាមេរិក ព្រមទាំងគ្រាប់រំសេវក៏ត្រូវបានបញ្ជូនផ្តល់មកដល់ឥណ្ឌូចិន នៅពេលនោះដែរ។ នៅពេលជាមួយគ្នា សហរដ្ឋអាមេរិក បានចាប់ផ្តើមបញ្ជូនទីប្រឹក្សាអ្នកឯកទេស និងគ្រូបង្ហាត់ខាងយោធាទាំងឡាយមកឥណ្ឌូចិន។

ជំនួយយោធា និងហិរញ្ញវត្ថុមួយភាគធំរបស់សហរដ្ឋអាមេរិក ត្រូវបានផ្តល់ ដើម្បីគាំទ្ររបបគ្រប់គ្រងរបស់ បាវ - ដាយ ដែលប្រឆាំងប្រជាជន និងដើម្បីបញ្ឆេះសង្គ្រាមស៊ីវិលក្នុងស្រុកនៅប្រទេសនានា នៃឥណ្ឌូចិន។ ការពង្រីកអំពើជ្រៀតជ្រែករបស់សហរដ្ឋអាមេរិក មកលើកិច្ចការផ្ទៃក្នុងរបស់ប្រទេសនានានៅឥណ្ឌូចិន បានជំរុញឱ្យមានការលើកឡើងនូវភារកិច្ចក្នុងការបង្រួបបង្រួមកងកម្លាំងប្រឆាំងចក្រពត្តិនិយម នៅប្រទេសទាំងបី៖ វៀតណាម កម្ពុជា ឡាវ។ គឺនៅក្នុងគោលដៅទាំងនេះហើយ បានជានៅខែមីនា ឆ្នាំ១៩៥១ មានការបើកសម័យប្រជុំសន្និសីទប្រជាជនទាំងឡាយនៅឥណ្ឌូចិន ដែលបានអនុម័តលើសេចក្តីសម្រេចចិត្តស្តីអំពីការបង្កើតរណសិរ្សរួម នៃការប្រយុទ្ធរំដោះជាតិរបស់ប្រជាជននានានៅឥណ្ឌូចិន នៅលើមូលដ្ឋានជាគោលការណ៍នានានៃសមភាព ភាពស្ម័គ្រចិត្ត និងលើជំនួយទៅវិញទៅមក រវាងអ្នកចូលរួមរណសិរ្សនេះ។ ស្របទៅតាមសេចក្តីសម្រេចនានារបស់សន្និសីទ នៅឆ្នាំ១៩៥១ អង្គភាពនៃកងកម្លាំងអ្នកស្ម័គ្រចិត្តប្រជាជនវៀតណាម បានចូលទៅក្នុងទឹកដីរបស់ប្រទេសកម្ពុជា ដើម្បីផ្តល់ជំនួយដល់កងកម្លាំងរំដោះជាតិខ្មែរឥស្សរៈ។

ពីឆ្នាំ១៩៥១ ដល់ឆ្នាំ១៩៥៣ ការប្រយុទ្ធដោយអាវុធដើម្បីឯករាជ្យជាតិនៃប្រទេសកម្ពុជា បានរីកសាយខ្លាំងឡើងដោយកម្លាំងថ្មី។ នៅក្នុងសម័យនោះ ទឹកដីនៃតំបន់រំដោះរបស់ប្រទេសបានរីកកាន់តែធំឡើង ហើយមានទំហំប្រហែល១ភាគ៣ នៃទឹកដីប្រទេសទាំងមូល។ នៅក្នុងតំបន់រំដោះនានាមានការអនុវត្តជាធរមាននូវវិធានការប្រកបដោយលទ្ធិប្រជាធិបតេយ្យ។ អង្គការដឹកនាំខ្មែរឥស្សរៈបានបំបាត់ប្រព័ន្ធពន្ធរបស់ពួកអាណានិគមនិយម ហើយបានចាត់ទុកវិធានការក្នុងការបង្អន់ដល់អំពើជិះជាន់កសិករ ដោយរបៀបចងការប្រាក់។

នៅឆ្នាំ១៩៥២ ខ្មែរឥស្សរៈបានប្រកបដោយកងកម្លាំងប្រដាប់អាវុធដ៏ខ្លាំងក្លា។ ចំនួនយុទ្ធជននៃកងអាសាស្ម័គ្រកាន់តែកើនឡើង កាន់តែរឹងមាំ ហើយត្រូវបានបញ្ចូលជាលំដាប់លំដោយទៅក្នុងអង្គភាព នៃកងទ័ពរៀបរយដែលស្ថិតនៅក្រោមទីបញ្ជាការតែមួយ ហើយប្រដាប់ដោយគ្រឿងអាវុធទំនើបៗ ដណ្តើមបានពីពួកអាណានិគមនិយម។ នៅឆ្នាំ១៩៥១ - ១៩៥២ កងកម្លាំងយោធារបស់ខ្មែរឥស្សរៈ បានធ្វើឱ្យពួកអាណានិគមទទួលបរាជ័យយ៉ាងដំណំ ហើយបានបង្ខំឱ្យពួកវាប្រើយុទ្ធសាស្ត្រការពារ ដោយការបង្កើតប្រព័ន្ធកិច្ចការពារនៅតាមដងផ្លូវថ្នល់នានា និងនៅជុំវិញទីរួមខេត្តនានា។ អង្គភាពនៃកងកម្លាំងប្រដាប់អាវុធខ្មែរឥស្សរៈបានកាត់ផ្លូវថ្នល់ជាច្រើនកន្លែងដែលភ្ជាប់ទីរួមខេត្តនានាពីមួយទៅមួយ។ នៅពេលក្រោយតមកទៀត ប្រតិបត្តិការសឹកដ៏សំខាន់ៗរបស់កងកម្លាំងរំដោះជាតិ បានប្រព្រឹត្តទៅនៅក្នុងតំបន់នៃផ្លូវថ្នល់យុទ្ធសាស្ត្រទី១៣ ដែលនៅតាមផ្លូវថ្នល់នេះពួក

វាតែងដឹកជញ្ជូនគ្រឿងអាវុធយុទ្ធភណ្ឌ ទៅឱ្យកងទ័ពបារាំង ដែលធ្វើចម្បាំងនៅប្រទេសវៀតណាម។

ការបង្កើនសកម្មភាព របស់ចលនាតស៊ូរំដោះជាតិធ្វើឱ្យមានទំនាស់កាន់តែខ្លាំងឡើង រវាងបក្សប្រជាធិបតេយ្យ និងរាជវង្សានុវង្ស។ បក្សប្រជាធិបតេយ្យក៏ដូចជាមជ្ឈដ្ឋាននានានៃរាជវង្សានុវង្សកម្ពុជា បានប្រកាន់ឥរិយាបថជាសត្រូវចំពោះកងកម្លាំងបដិវត្តន៍ប្រជាធិបតេយ្យខ្មែរឥស្សរៈ។ នៅពេលជាមួយគ្នាបក្សប្រជាធិបតេយ្យ បានធ្វើការទិតៀនដល់នយោបាយរបស់ ន. សីហនុ ដោយចោទប្រកាន់ថា ស្ដេចនេះមិនបានធ្វើសកម្មភាពឱ្យមាំមួនក្នុងការទាមទារឱ្យមានអធិបតេយ្យភាពរដ្ឋ នៃប្រទេសកម្ពុជា ពីសំណាក់របស់ពួកអាណានិគមនិយមនៅលើមូលដ្ឋាននៃការពង្រីក “ អធិបតេយ្យភាពផ្ទៃក្នុង ” របស់ប្រទេសនេះ។

នៅរដូវវស្សានៃឆ្នាំ១៩៥១ តាមសេចក្ដីទាមទាររបស់រដ្ឋសភារដ្ឋអំណាចបារាំង បានយល់ព្រមរំដោះ និងបញ្ជូន សឺង ង៉ុកថាញ់ ទៅឱ្យប្រទេសកម្ពុជា វិញ។ នៅមុនពេលធ្វើដំណើរត្រឡប់ទៅប្រទេសរបស់ខ្លួនវិញ សឺង ង៉ុកថាញ់ បានប្រកាសនូវភក្ដីភាពរបស់ខ្លួនចំពោះអ្នកតំណាងនៃរដ្ឋអំណាចបារាំង និងចំពោះមហាក្សត្រ។ ក៏ប៉ុន្តែ លុះត្រឡប់មកទីក្រុងភ្នំពេញ សឺង ង៉ុកថាញ់ បានចូលរួមធ្វើសកម្មភាពប្រឆាំងក្នុ ងជួរនៃបក្សប្រជាធិបតេយ្យ។ សឺង ង៉ុកថាញ់ បានធ្វើសេចក្ដីថ្លែងការណ៍ដោយធ្វើការទិតៀនដល់នយោបាយរបស់ ន. សីហនុ ហើយនៅពេលជាមួយគ្នាគាត់បានទាមទារឱ្យពង្រីកការតស៊ូប្រឆាំង “កងកម្លាំងកុម្មុយនិស្ត” ខ្មែរឥស្សរៈ។ នៅដើមឆ្នាំ១៩៥២ គាត់បានបោះពុម្ពផ្សាយកាសែត

ឈ្មោះ “ ខ្មែរក្រោក ” ដែលបានទៅជាកាសែតរបស់បក្សប្រឆាំងមួយតាមផ្លូវច្បាប់។

នៅពេលជាដំបូង សកម្មភាពរបស់សឺង ង៉ុកថាញ់ បានឆ្លើយស្របនឹងផលប្រយោជន៍ របស់អាជ្ញាធរបារាំង ដែលខំសាកល្បងប្រើប្រាស់ សេចក្តីថ្លែងការណ៍ប្រឆាំងកុម្មុយនិស្តរបស់គាត់ ក្នុងគោលបំណងដើម្បី បំបែកបំបាក់កងកម្លាំងស្នេហាជាតិនានា។ ក៏ប៉ុន្តែ ការទិតៀនដល់សន្ធិសញ្ញាបារាំង-កម្ពុជា នាឆ្នាំ១៩៤៩ ដែលតែងបានចុះផ្សាយនៅលើទំព័រកាសែត “ ខ្មែរក្រោក ” បានបង្ខំចិត្តឱ្យពួកអាណានិគមនិយមបំបិទការផ្សាយកាសែតនេះ ហើយចេញប្រកាសឱ្យចាប់ឃុំឃាំងចាងហ្វាងរបស់កាសែត។

នៅរដូវរំហើយឆ្នាំ១៩៥២ សឺង-ង៉ុកថាញ់ បានលួចរត់ពីភ្នំពេញ ទៅកាន់តំបន់ព្រំប្រទល់របស់ប្រទេស ហើយតមក បានភៀសខ្លួនចូលប្រទេសថៃឡង់ ដែលនៅទីនោះ គាត់បានចាប់ផ្តើមចាត់តាំងអង្គការប្រតិកិរិយា “ ខ្មែរសេរី ”។ សកម្មភាពបែបនេះរបស់សឺង-ង៉ុកថាញ់ បានបង្កើតភាពស្មុគស្មាញដល់ការទាក់ទងរវាងបក្សពួកនយោបាយផ្សេងៗនៅភ្នំពេញ ដែលប្រទង់ប្រទាញគ្នា ដើម្បីដណ្តើមអំណាច។

នៅឆ្នាំ១៩៥២ ន. សីហនុ បានធ្វើការសាកល្បងរៀបចំកិច្ចត្រួតត្រារបស់ខ្លួនលើខេត្តនានាខាងបស្ចិម ដែលនៅទីនេះមានមូលដ្ឋានខាងក្រោយរបស់ខ្មែរឥស្សរៈ។ មូលដ្ឋានការសាកល្បងនេះ បានទទួលបរាជ័យ។ កងទ័ពស្តេច ដែលត្រូវធ្វើដំណើរទៅខេត្តខាងលិច ត្រូវបានបញ្ឈប់ដោយកងកម្លាំងប្រដាប់អាវុធខ្មែរឥស្សរៈ ហើយត្រូវបានបង្ខំចិត្តធ្វើដំណើរត្រឡប់ថយ

ក្រោយវិញ។ នៅទីបំផុត រដ្ឋអំណាចស្ដេច ពុំបានសម្រេចគោលបំណងរបស់ខ្លួនក្នុងការពង្រីកដែនដីនៃ “តំបន់ស្វ័យភាព” នានាដែលស្ថិតនៅក្រោមការត្រួតត្រារបស់ខ្លួន។ នៅចុងឆ្នាំ១៩៥២ ក្នុងបណ្ដាខេត្តទាំង១៤ នៃប្រទេសកម្ពុជា មានតែខេត្តចំនួនបីដែលជា “ តំបន់ស្វ័យភាព ” ទាំងនេះ គឺខេត្តសៀមរាប កំពង់ធំ និងបាត់ដំបង។ នៅតំបន់កណ្ដាលទាំងឡាយរបស់ប្រទេស នៅមានរបបកាន់កាប់ទឹកដី ដោយពួកអាណានិគមនិយមបារាំងដដែល។

ខ្មែរឥស្សរៈបានត្រួតត្រាលើទឹកដីកម្ពុជា មួយចំនួនធំ។ ចលនាតស៊ូរំដោះជាតិ ដោយគ្រឿងអាវុធកាន់តែរីកសាយធំឡើង។ ពួកអាណានិគមនិយមបារាំង លែងមានលទ្ធភាពនឹងទប់ទល់ប្រឆាំងនឹងចលនានេះបាន។ នៅខែតុលា ឆ្នាំ១៩៥២ ពួកវាបានទទួលបរាជ័យ ខាងយោធាថ្មីៗទៀតនៅប្រទេសវៀតណាម ហើយបរាជ័យនេះមិនអាចមិនជះឥទ្ធិពលដល់ស្ថានភាពរបស់ពួកវានៅប្រទេសកម្ពុជា បានឡើយ។

នៅខែវិច្ឆិកា ឆ្នាំ១៩៥២ បាតុកម្ម និងកូដកម្មនានាធ្វើឡើងដោយសិស្សានុសិស្ស បានប្រព្រឹត្តទៅនៅទីក្រុងផ្សេងៗនៃប្រទេស។ នៅខែមករា ឆ្នាំ១៩៥៣ ចៅហ្វាយខេត្តមួយរូបត្រូវបានគេធ្វើឃាត។ ដោយយោងទៅតាមស្ថានការណ៍នយោបាយកាន់តែតានតឹងឡើង នៅខែមករា ឆ្នាំ១៩៥៣ ន. សីហនុ បានធ្វើសេចក្ដីប្រកាសអំពីភាពអាសន្ននៅក្នុងប្រទេស ហើយបានរំលាយរដ្ឋសភា។ នៅពេលជាមួយគ្នានេះ មហាក្សត្របានបង្កើតក្រុមប្រឹក្សាពិគ្រោះមួយដែលមានសមាជិកជាអ្នកប្រកាន់រាជានិយម។

ព្រឹត្តិការណ៍នានានៅឆ្នាំ១៩៥២ និងដើមឆ្នាំ១៩៥៣ បានបញ្ជាក់ឱ្យឃើញច្បាស់ នូវជោគជ័យកាន់តែរីកសាយធំឡើងរបស់ចលនាតស៊ូរំដោះជាតិនានានៅប្រទេសកម្ពុជា ក៏ដូចជា នៅប្រទេសជិតខាងនៃឥណ្ឌូចិន ដែរ។ នៅក្នុងលក្ខខណ្ឌបែបនេះ មជ្ឈដ្ឋានរាជានិយមនៃប្រទេសកម្ពុជា ដឹកនាំដោយ ន. សីហនុ លែងធ្វើការសាកល្បងរៀបចំអធិបតេយ្យភាពរដ្ឋ របស់ប្រទេសបន្តិចម្តងៗ នៅលើមូលដ្ឋាននៃការពង្រីក “ តំបន់ស្វ័យភាព ”។ ហេតុនេះហើយ បានជានៅដើមឆ្នាំ១៩៥៣ មហាក្សត្រ និងរាជបល្ល័ង្កបានបោះបង់នយោបាយសម្រុះសម្រួល ជាមួយពួកអាណានិគមនិយម ហើយបានចាប់ផ្តើមធ្វើការតស៊ូតាមផ្លូវទូត ដើម្បីឯករាជភាពនៃប្រទេស។

ការខិតខំនៅក្នុងវិស័យនេះ ត្រូវបានឃើញច្បាស់នៅក្នុងទស្សនកិច្ចក្រៅផ្លូវការរបស់មហាក្សត្រកម្ពុជា នៅប្រទេសបារាំង។ នៅខែមីនា ឆ្នាំ១៩៥៣ មានការជួបគ្នារវាង ន. សីហនុ និងប្រធានាធិបតីបារាំង ហើយនៅក្នុងការជួបនេះ ភាគីកម្ពុជា ពុំបានទទួលផលអ្វីសោះ។ អ្នកតំណាងមជ្ឈដ្ឋានជាផ្លូវការនៃប្រទេសបារាំង បានទទួលមហាក្សត្រទាំងទើសទាល់ ហើយព្រមទាំងបញ្ជាក់ឱ្យយល់ថា ពួកគេគ្មានបំណងនឹងបញ្ឈប់អន្តរាគមន៍ខាងយោធានៅប្រទេសកម្ពុជា ឡើយ។ បន្ទាប់ពីប្រទេសបារាំង ន. សីហនុ បានយាងទៅប្រទេសកាណាដា រួចទៅសហរដ្ឋអាមេរិក។ នៅទីក្រុងវ៉ាស៊ីនតោន មហាក្សត្រ បានជួបសន្ទនាយ៉ាងខ្លី ជាមួយនឹងរដ្ឋមន្ត្រីក្រសួងការបរទេសសហរដ្ឋអាមេរិក ឈ្មោះ ហ្វូស ស្ទ័រឌុល្ល។ឥស្សរជនសហរដ្ឋអាមេរិកនេះបានបញ្ជាក់ដល់ ន. សីហនុ ថា សហរដ្ឋអាមេរិក គាំទ្រដល់

នយោបាយបារាំង នៅក្នុងប្រទេសនានានៃឥណ្ឌូចិន។ តាមផ្លូវការ សេចក្ដីបញ្ជាក់នេះ បង្ហាញឱ្យឃើញនូវឥរិយាបថរបស់វ៉ាស៊ីនតោន ដែលមិនព្រមទទួលស្គាល់សិទ្ធិ នៃអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ទាក់ទងទៅនឹងការផ្ដល់ឯករាជ្យ ខាងនយោបាយដល់ប្រទេសនេះ។

ទស្សនកិច្ចរបស់ ន. សីហនុ នៅទីក្រុងប៉ារីស និងនៅទីក្រុងវ៉ាស៊ីនតោន បានប្រព្រឹត្តទៅនៅក្នុងបរិយាកាសនៃបរាជ័យថ្មីៗទៀតរបស់កងទ័ពបារាំង នៅឥណ្ឌូចិន។ សភាពការណ៍ទាំងនេះ ព្រមទាំងសាធារណមតិចម្រើននិយមនៅលើពិភពលោក ដែលបានធ្វើការឃោសនាទូទៅប្រឆាំងនឹង “ សង្គ្រាមដ៏កខ្វក់ ” នៅឥណ្ឌូចិន បានបង្ខំឱ្យមជ្ឈដ្ឋានជាផ្លូវការនៃប្រទេសបារាំង ចាប់ផ្ដើមធ្វើការចរចាជាផ្លូវការជាមួយរាជរដ្ឋាភិបាលកម្ពុជា ស្ដីអំពីការដោះស្រាយវិបត្តិបារាំង-កម្ពុជា នៅខែមេសា ឆ្នាំ១៩៥៣។

នៅឱកាសនៃការចរចាគ្នា ដែលបានប្រព្រឹត្តទៅនៅទីក្រុងបារីស ភាគីបារាំង បានប្រកាសអំពីការប្រុងប្រៀបខ្លួន ដើម្បីបន្ថយកម្រិតការត្រួតត្រាខាងយោធានៅប្រទេសកម្ពុជា។ ក៏ប៉ុន្តែ នៅពេលជាមួយគ្នា រដ្ឋាភិបាលបារាំង ពុំបានព្រមព្រៀងទទួលស្គាល់មហាក្សត្រកម្ពុជា ថា ជាមេបញ្ជាការជាន់ខ្ពស់ខាងកងទ័ព នៅលើទឹកដីនៃប្រទេសកម្ពុជា ឡើយ។ ប្រទេសបារាំង បានប្រកាន់ឥរិយាបថប្រហាក់ប្រហែលគ្នា នៅក្នុងបញ្ហាស្ដីអំពីអង្គការតុលាការនៃប្រទេសកម្ពុជា។ ភាគីបារាំង បានធ្វើសំណើឱ្យបង្កើត “តុលាការចម្រុះ” ហើយព្រមទាំងបានខិតខំសាកល្បងរក្សារបបអភ័យឯកសិទ្ធិនៅក្នុងប្រទេសកម្ពុជា សម្រាប់ជនជាតិបរទេស

ជាពិសេសសម្រាប់ពលរដ្ឋបារាំង ទាំងអស់។ ការចរចានានា ស្តីអំពីបញ្ហាសេដ្ឋកិច្ច ក៏មិនបានទទួលលទ្ធផលអ្វីជាធំដុំដែរ។

កលល្បិចនានារបស់បារាំង នៅក្នុងកិច្ចចរចាគ្នានាទីក្រុងបារីស បានបញ្ជាក់ឱ្យឃើញច្បាស់ថា មជ្ឈដ្ឋានដឹកនាំនៃប្រទេសបារាំង មានបំណងពន្យារការចរចានេះ ដើម្បីចំណេញពេលសម្រាប់ការឆ្លៀតបន្តអំពីឈ្លានពាន របស់ខ្លួននៅប្រទេសទាំងបី៖ កម្ពុជា វៀតណាម ឡាវ។ ក៏ប៉ុន្តែ ការពន្យារពេលវេលាទៅជាផ្តល់ផលវិបាកដ៏អាក្រក់ ដល់ពួកអាណានិគមនិយមទៅវិញ។ ជ័យជម្នះក្នុងការពង្រីកការប្រយុទ្ធដោយអាវុធរបស់ខ្មែរឥស្សរៈ និងជ័យជម្នះថ្មីៗរបស់កងកម្លាំងស្នេហាមាតុភូមិនៃប្រទេសវៀតណាម និងប្រទេសឡាវ នៅរដូវក្តៅ ឆ្នាំ១៩៥៣ បានធ្វើឱ្យស្ថានភាពខាងនយោបាយ និងយោធារបស់ពួកចក្រពត្តិបារាំង នៅប្រទេសនានានៅឥណ្ឌូចិន ទៅជាទន់ខ្សោយ។ នៅក្នុងសភាពការណ៍បែបនេះ រដ្ឋាភិបាលបារាំង យល់ច្បាស់ថា ការធ្វើឱ្យស្ថានភាពនៅប្រទេសកម្ពុជា មានលក្ខណៈតានតឹងតទៅទៀត នឹងអាចបង្កើតឱ្យមានគ្រោះថ្នាក់សម្រាប់ខ្លួន។ នៅខែកក្កដា ឆ្នាំ១៩៥៣ ប្រទេសបារាំង បានធ្វើសេចក្តីថ្លែងការណ៍ស្តីអំពីការយល់ព្រម របស់ខ្លួនក្នុងការផ្តល់ឯករាជភាពពេញលេញដល់ប្រទេសកម្ពុជា ដែលនៅក្នុងនេះ មានទាំងការផ្តល់ដល់រាជរដ្ឋាភិបាលនូវកិច្ចត្រួតត្រាទាំងអស់ លើកងកម្លាំងប្រដាប់អាវុធនៃប្រទេស ព្រមទាំងប្រព័ន្ធ នៃអង្គការតុលាការនានា។ ដូច្នេះ មជ្ឈដ្ឋានដឹកនាំនៃប្រទេសបារាំង បានសម្រេចចិត្តធ្វើការបន្ធូរបន្ថយដល់មជ្ឈដ្ឋានសក្តិភូមិរាជានិយម នៃប្រទេសកម្ពុជា ដោយមានគោលបំណង ដើម្បីរក្សាទុកមហាក្សត្រក្នុងឋានៈជា

សម្ពន្ធមិត្តនយោបាយ របស់ខ្លួននៅក្នុងក្របខ័ណ្ឌ នៃការបន្តអន្តរាគមន៍បារាំង នៅប្រទេសវៀតណាម។

នាថ្ងៃទី២៧ ខែសីហា ឆ្នាំ១៩៥៣ នៅភ្នំពេញ គណៈកម្មការបារាំង-កម្ពុជា បានចាប់ផ្តើមបំពេញការងារស្តីអំពីការប្រគល់រដ្ឋអំណាចពេញសមត្ថភាពជាន់ខ្ពស់ ដល់រាជរដ្ឋាភិបាលកម្ពុជា។ នៅថ្ងៃទី២៩ ខែសីហា មានធ្វើពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីអំពីការប្រគល់សិទ្ធិនៃកិច្ចត្រួតត្រាលើក្រសួងនគរបាល និងក្រសួងយុត្តិធម៌ ដល់រាជរដ្ឋាភិបាលប្រទេសកម្ពុជា។ ក៏ប៉ុន្តែ ការពិភាក្សាអំពីបញ្ហាដទៃទៀត ត្រូវបានពន្យារពេលអស់រយៈកាលដ៏យូរ ហើយទាល់តែមានភាពតានតឹងកើតមកអំពីការលំបាកកាន់តែខ្លាំងឡើងនៅលើសមរភូមិ ទើបពួកអាណានិគមនិយមបារាំង បង្ខំចិត្តចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីអំពីការប្រគល់សិទ្ធិលើកិច្ចបញ្ជាការយោធាជាន់ខ្ពស់ លើទឹកដីកម្ពុជាដល់រាជរដ្ឋាភិបាល នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ១៩៥៣។ ក្នុងរយៈពេលបីអាទិត្យកន្លងមក នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ នៅភ្នំពេញ មានការរៀបចំពិធីនៃការដកកងទ័ពបារាំង ថយពីរដ្ឋធានី ដោយមានទាំងការធ្វើសេចក្តីថ្លែងការណ៍ របស់ស្នងការជាន់ខ្ពស់នៃប្រទេសបារាំង ស្តីអំពីការបញ្ឈប់សកម្មភាពរបស់រដ្ឋការបារាំងនៅក្នុងប្រទេសនេះ។

ការប្រយុទ្ធ ដោយអាវុធរបស់កងកម្លាំងស្នេហាមាតុភូមិកម្ពុជា បានបំពេញតួនាទីដ៏សំខាន់នៅក្នុងការបំបាត់របបគ្រប់គ្រងផ្តាច់មុខរបស់អាណានិគមបារាំង នៅប្រទេសកម្ពុជា គឺជាការប្រយុទ្ធ ដែលបានដឹកនាំដោយរណសិរ្សរួបរួមជាមួយកងកម្លាំងរំដោះជាតិនៃប្រទេសវៀតណាម និងប្រទេសឡាវ។

អធិបតេយ្យភាពរដ្ឋ នៃប្រទេសកម្ពុជា ប្រកាសឡើងនៅខែវិច្ឆិកា ឆ្នាំ១៩៥៣ មានលក្ខណៈមិនទាន់ពេញលេញ ដោយហេតុថា ប្រទេសនេះស្ថិតនៅក្នុងសមាសភាពនៃសហភាពបារាំងតទៅទៀត ហើយអង្គភាពនៃកងទ័ពបារាំងខ្លះបានស្ថិតនៅលើទឹកដីនៃខេត្តខាងកើតនានា។

នៅដើមឆ្នាំ១៩៥៤ កងទ័ពបារាំង នៅវៀតណាម ទើបបានទទួលបរាជ័យថ្មីៗ ហើយនៅខែឧសភា ឆ្នាំ១៩៥៤ កងទ័ពរបស់ពួកអាណានិគមនិយមបានទទួលបរាជ័យយ៉ាងធ្ងន់ធ្ងរនៅឌៀនបៀនភូ។ មតិសាធារណបារាំង បានសំដែងការប្រឆាំង ហើយបានទាមទារយ៉ាងម៉ឺងម៉ាត់ឱ្យបញ្ឈប់ “ សង្គ្រាមដ៏កខ្វក់ ” នៅវៀតណាម។ តមក រដ្ឋាភិបាលរបស់ឡានីញ្ញែល - ប៊ីដូ បានបង្ខំចិត្តយល់ព្រមចូលរួបរួម ក្នុងសន្និសីទអន្តរជាតិស្តីអំពីការដោះស្រាយវិបត្តិយោធានៅឥណ្ឌូចិន ដោយសន្តិវិធី។

នៅខែឧសភា ឆ្នាំ១៩៥៤ នៅទីក្រុងហ្សឺណែវ មានការបើកសម័យប្រជុំនៃសន្និសីទ ដែលក្នុងនេះ មានការចូលរួមរបស់រដ្ឋមន្ត្រីក្រសួងការបរទេសសហភាពសូវៀត អង់គ្លេស សាធារណរដ្ឋប្រជាមានិតចិន សហរដ្ឋអាមេរិក និងបារាំង ដើម្បីធ្វើការដោះស្រាយបញ្ហាឥណ្ឌូចិន ដោយវិធីសន្តិភាព។ អ្នកតំណាងនៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម អ្នកតំណាងរបស់មហារាជ បៅ-ដាយ គណៈប្រតិភូរបស់រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា និងប្រទេសឡាវ បានទទួលការអញ្ជើញឱ្យចូលរួមក្នុងការងារនៃសន្និសីទអន្តរជាតិនេះ។ គណៈប្រតិភូរបស់សហភាពសូវៀត សាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម សាធារណរដ្ឋប្រជាមានិតចិន បានឡើងថ្លែងសំណើឱ្យអញ្ជើញអ្នកតំណាង

របស់រណសិរ្សជាតិខ្មែរឥស្សរៈ មកចូលរួមក្នុងសម័យប្រជុំ នៃសន្និសីទ ក៏ប៉ុន្តែ នៅពេលនោះ ប្រទេសជាមហាអំណាចខាងលិចបានជំទាស់នឹងសេចក្តីស្នើនេះ។

ការងាររបស់សន្និសីទទីក្រុងហ្សឺណែវ បានប្រព្រឹត្តទៅនៅក្នុងបរិយាកាស នៃការតស៊ូខាងផ្លូវទូតដ៏តានតឹងបំផុត។ នៅពេលដំបូងនៃការចរចា រដ្ឋាភិបាលបារាំង ដោយសំអាងទៅលើការគាំទ្រដ៏សកម្មរបស់សហរដ្ឋអាមេរិក បានខិតខំបង្កើតឧបសគ្គគ្រប់បែបយ៉ាង ដើម្បីកុំឱ្យកិច្ចព្រមព្រៀងស្តីអំពីការរៀបចំសន្តិភាពនៅឥណ្ឌូចិន សម្រេចឡើងបាន។ ក៏ប៉ុន្តែ ដោយបានជួបប្រទះនឹងសកម្មភាពប្រឆាំងដ៏មុឹងម៉ាត់ ពីសំណាក់បណ្តាប្រទេសសង្គមនិយម ហើយដោយទទួលរងទម្ងន់ពីសំណាក់របស់សាធារណមតិចម្រើននិយមនៃប្រទេសដទៃទៀត ដែលកំពុងតែសំដែងការប្រឆាំងនឹងសង្គ្រាមនៅឥណ្ឌូចិន កាន់តែខ្លាំងឡើងៗ មជ្ឈដ្ឋានដឹកនាំនៃប្រទេសបារាំង និងសហរដ្ឋអាមេរិក ក៏បានបង្ខំចិត្តទទួលស្របតាមការដោះស្រាយ “ វិបត្តិ ” ឥណ្ឌូចិន ដោយសន្តិភាព។ ការសម្របសម្រួលសកម្មភាពរួមគ្នាដ៏ជិតស្និទ្ធ រវាងអ្នកចូលរួមក្នុងចលនាតស៊ូរំដោះជាតិ នៅប្រទេសទាំងបី៖ កម្ពុជា វៀតណាមឡាវ ដឹកនាំដោយជនកុម្មុយនិស្តទាំងឡាយ នៃប្រទេសទាំងនេះបានទៅជាកត្តាដ៏សំខាន់ ដែលបង្កើតឱ្យមានការចុះហត្ថលេខាលើសន្ធិសញ្ញាហ្សឺណែវ នាឆ្នាំ១៩៥៤ ស្តីអំពីបញ្ហាឥណ្ឌូចិន។

នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៥៤ នៅក្នុងសន្និសីទទីក្រុងហ្សឺណែវ មានពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីអំពីការបញ្ឈប់សង្គ្រាម និងការរៀបចំសន្តិភាពនៅប្រទេសនានានៃឥណ្ឌូចិន ឡើងវិញ។ នៅក្នុងសេចក្តីថ្លែងការណ៍ជាបញ្ចប់នៃ

សន្និសីទទីក្រុងហ្សឺណែវ គណៈប្រតិភូមិចូលរួបរួមបានប្រកាសជាឱឡារិកនូវកាតព្វកិច្ចរបស់ខ្លួន ដើម្បីគោរពអធិបតេយ្យភាព ឯករាជភាព ឯកភាព និងបូរណភាពដែនដីនៃប្រទេសវៀតណាម កម្ពុជា និងឡាវ។

នៅសម័យប្រជុំ នៃសន្និសីទមានពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីអំពីការបញ្ឈប់សកម្មភាពយោធានៅប្រទេសកម្ពុជា ហើយស្របតាមសេចក្តីនៃកិច្ចព្រមព្រៀងនេះ កងកម្លាំងប្រដាប់អាវុធបរទេសដទៃ ទាំងអស់ត្រូវដកថយចេញពីទឹកដីនៃប្រទេសកម្ពុជា។ នៅពេលនោះ មានទាំងការអនុម័តលើសេចក្តីសម្រេច ស្តីអំពីការរំសាយទ័ព នៃកងកម្លាំងប្រដាប់អាវុធរបស់ខ្មែរឥស្សរៈ*។ ស្របតាមសន្និសញ្ញាហ្សឺណែវ មកដល់ថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៥៤ កងកម្លាំងប្រដាប់អាវុធនៃអ្នកស្ម័គ្រចិត្តប្រជាជនវៀតណាម ត្រូវបានដកថយចេញពីប្រទេសកម្ពុជា។

នៅក្នុងសេចក្តីថ្លែងការណ៍ដោយឡែក រាជរដ្ឋាភិបាលប្រទេសកម្ពុជា បានផ្តល់សេចក្តីធានាថា មិនតាមធ្វើទុកបុកម្នេញដល់អតីតយុទ្ធជន ដែលចូលរួមក្នុងចលនាតស៊ូរំដោះជាតិទេ។ នៅក្នុងសេចក្តីថ្លែងការណ៍នេះ រាជរដ្ឋាភិបាលបានគូសបញ្ជាក់នូវសេចក្តីសម្រេចចិត្តរបស់ខ្លួនដើម្បី “ ចាត់វិធានការដ៏មុឹងមាត់ ដើម្បីបង្រួបបង្រួមពលរដ្ឋទាំងអស់ដោយមិនរើស

---

* រយៈកាលនៃការរំសាយទ័ព នៃកងកម្លាំងប្រដាប់អាវុធរបស់ខ្មែរឥស្សរៈ គឺក្នុងអំឡុង៣០ថ្ងៃ ហើយការដកថយចេញពីប្រទេសកម្ពុជានូវកងកម្លាំងប្រដាប់អាវុធបរទេស មានរយៈកាល៩០ថ្ងៃ គឺចាប់ផ្តើមពីពេលអនុវត្តសន្និសញ្ញាហ្សឺណែវ ជាធរមាន។

មុខនៅក្នុងសង្គមជាតិ ហើយធានាដល់គេទាំងឡាយនូវការប្រើប្រាស់សិទ្ធិ និងសេរីភាពនានា ដែលមានចែងនៅក្នុងរដ្ឋធម្មនុញ្ញរបស់រាជាណាចក្រ ”។ រាជរដ្ឋាភិបាលទទួលភារកិច្ចដឹកនាំនយោបាយក្រៅប្រទេសដោយសន្តិវិធី។ នៅក្នុងសេចក្តីថ្លែងការណ៍នេះ មានគូសបញ្ជាក់ថា រាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា “ សូមសំដែងនូវសេចក្តីសម្រេចចិត្តរបស់ខ្លួនថា មិនចូលរួមក្នុងនយោបាយឈ្លានពានណាមួយឡើយ ហើយហាមឃាត់ មិនឱ្យមានការប្រើប្រាស់ទឹកដី នៃប្រទេសក្នុងគោលបំណងធ្វើនយោបាយឈ្លានពានណាមួយឡើយ។ រាជរដ្ឋាភិបាលកម្ពុជា មិនចូលរួបរួមក្នុងកិច្ចព្រមព្រៀងណាមួយជាមួយរដ្ឋាភិបាលដទៃ ប្រសិនបើកិច្ចព្រមព្រៀងនោះ មានការបង្ខិតបង្ខំឱ្យចូលរួមក្នុងបក្សសម្ពន្ធយោធាដែលមិនឆ្លើយតបនឹងគោលការណ៍នានា នៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ (អ.ស.ប) ”។

ដើម្បីអនុវត្ត កិច្ចត្រួតត្រាលើការបំពេញតាមសន្ធិសញ្ញាហ្សឺណែវ នៅប្រទេសកម្ពុជា មានសេចក្តីអនុម័តលើការបង្កើតគណៈកម្មការអន្តរជាតិមួយ ដែលមានអ្នកតំណែងនៃប្រទេសឥណ្ឌា ប្រទេសប៉ូឡូញ និងប្រទេសកាណាដា ធ្វើជាសមាជិក។

សន្ធិសញ្ញាហ្សឺណែវ នាឆ្នាំ១៩៥៤ បានពង្រឹងជោគជ័យទទួលបានមកដោយកងកម្លាំងរំដោះជាតិ ប្រទេសកម្ពុជា វៀតណាម ឡាវ ក្នុងការតស៊ូរបស់គេទាំងឡាយដើម្បីបំបាត់របបត្រួតត្រារបស់អាណានិគមនិយមបារាំង នៅឥណ្ឌូចិន។ សម្រាប់ប្រទេសកម្ពុជា សន្ធិសញ្ញាហ្សឺណែវ មានអត្ថន័យដ៏សំខាន់បំផុត ដោយហេតុថា បន្ទាប់ពីពិធីចុះហត្ថលេខាលើសន្ធិសញ្ញានេះ ប្រទេសកម្ពុជា បានទទួលការទទួលស្គាល់ពិតប្រាកដ លើឆាកអន្តរជាតិនូវ

អធិបតេយ្យភាព ឯករាជភាព ឯកភាព និងបូរណភាពទឹកដីរបស់ខ្លួន។ អត្ថន័យដ៏សំខាន់ម្យ៉ាងទៀតនៃសន្ធិសញ្ញានេះស្ថិតនៅលើហេតុដែលថា នៅលើកិច្ចការអន្តរជាតិមានការទទួលស្គាល់នូវភាពត្រឹមត្រូវតាមច្បាប់ នៃចលនាតស៊ូរំដោះជាតិរបស់ប្រជាជនកម្ពុជា។

# ចំពូកទី២

## ការបង្កើតសង្គមរាស្ត្រនិយម និងការរៀបចំនយោបាយអព្យាក្រឹត

បន្ទាប់ពីពេលទទួលបាននូវអធិបតេយ្យភាពរដ្ឋ នៃប្រទេសកម្ពុជា ឡើងវិញ ការផ្លាស់ប្ដូរដ៏សំខាន់ៗក្នុងតំរិយាបថប្រកាន់ដោយកម្លាំងនយោបាយផ្សេងៗ នៅប្រទេសបានកើតមានឡើង។

នៅចុងឆ្នាំ១៩៥៣ រាជរដ្ឋាភិបាលបានចាប់ផ្ដើមរៀបចំការត្រួតត្រាខាងរដ្ឋបាល និងយោធានៅក្នុងតំបន់នានាដែលស្ថិតនៅក្រោមសកម្មភាពរបស់ចលនាខ្មែរឥស្សរៈ។ នៅក្នុងនយោបាយនេះ មានការអនុវត្តវិធានការផ្សេងៗ និងការពង្រីកប្រព័ន្ធក្រុមនគរបាលនៅស្រុកស្រែ។ នៅពេលជាមួយគ្នា ប្រតិបត្តិការខាងយោធា និងរដ្ឋបាលបានប្រព្រឹត្តទៅដើម្បីធ្វើ " ការប្រមូលផ្ដុំ " បណ្ដាជនស្រុកស្រែ ដែលជាមូលដ្ឋានដ៏សំខាន់របស់ចលនាខ្មែរឥស្សរៈ។ គោលបំណងដ៏សំខាន់នៃប្រតិបត្តិការនេះ ស្ថិតនៅក្នុងការប៉ុនប៉ងបំបាត់ភូមិតូចៗដាច់ស្រយាល និងស្រុកស្រែតូចតាច ហើយប្រមូលផ្ដុំអ្នកស្រុកឱ្យមករស់នៅក្នុងស្រុកស្រែធំៗដែលស្ថិតនៅតាមផ្លូវគមនាគមន៍ ហើយដែលស្ថិតនៅក្រោមការត្រួតត្រារបស់កងកម្លាំងប្រដាប់អាវុធនៃរាជរដ្ឋាភិបាល។

វិធានការ " ប្រមូលផ្ដុំ " បណ្ដាជនស្រុកស្រែបានគ្របដណ្ដប់ទៅលើប្រជាជនមូលដ្ឋានប្រហែល១លាននាក់។ ការបំបាត់ជនបទតូចតាចចុងកាត់មាត់ញក និងការប្រមូលផ្ដុំបណ្ដាជនស្រុកស្រែឱ្យមករស់នៅតាមផ្លូវថ្នល់ បានប្រព្រឹត្តទៅរហូតដល់

សម័យកាលនៃភាគខាងចុង នៃឆ្នាំ១៩៥៤ បានសេចក្តីថា នៅពេលបន្ទាប់ពីការបញ្ឈប់សង្គ្រាមជាផ្លូវការនៅប្រទេសនានា នៃឥណ្ឌូចិន។

ស្របតាមសន្ធិសញ្ញាហ្សឺណែវ ក្នុងអំឡុងពេលចាប់ផ្តើមពីខែសីហា ដល់ខែកញ្ញា ឆ្នាំ១៩៥៤ យុទ្ធជននៃកងកម្លាំងប្រដាប់អាវុធខ្មែរឥស្សរៈត្រូវបានរំសាយជួរ។ ក៏ប៉ុន្តែ រាជរដ្ឋាភិបាលដោយមានការរំលោភលើសន្ធិសញ្ញាហ្សឺណែវ បានបន្តតាមពិនិត្យយុទ្ធជនរួបរួមក្នុងចលនាខ្មែរឥស្សរៈ ដោយមានកងប៉ូលិសតាមធ្វើទុក្ខបុកម្នេញដល់គេទាំងឡាយ តាមរបៀបផ្សេងៗ។ នយោបាយតាមពិនិត្យ ធ្វើទុក្ខបុកម្នេញដល់កម្លាំងប្រជាធិបតេយ្យបានបំបាត់នូវលទ្ធភាព មិនឱ្យបក្សប្រជាជនបដិវត្តន៍កម្ពុជា អាចធ្វើសកម្មភាពនយោបាយតាមផ្លូវច្បាប់បានឡើយ។ នៅក្នុងស្ថានភាពបែបនេះ នៅចុងឆ្នាំ១៩៥៤ មានការបង្កើតក្រុមនយោបាយមួយនៅក្នុងប្រទេស គឺក្រុម “ ប្រជាជន ” ដែលបានបំពេញមុខងាររបស់ខ្លួន តាមផ្លូវច្បាប់ឱ្យអង្គការបក្សប្រជាជនបដិវត្តន៍កម្ពុជា។ នៅក្នុងលក្ខន្តិកៈរបស់ក្រុម “ ប្រជាជន ” មានការគូសបញ្ជាក់ថា “ គោលដៅដ៏ចម្បងរបស់គេស្ថិតនៅលើ ” ការបង្រួបបង្រួមប្រជាជនកម្ពុជាទូទៅមកក្នុងសង្គមជាតិដោយគ្មានការប្រកាន់ពូជសាសន៍ វណ្ណៈ ទស្សនៈនយោបាយ និងជំនឿសាសនា ក្នុងគោលបំណងធ្វើការតស៊ូប្រឆាំងពួកចក្រពត្តិ និងបរិវាររបស់វា ធ្វើការតស៊ូដើម្បីសន្តិភាព ឯករាជភាព ប្រជាធិបតេយ្យ និងដើម្បីការសម្រិតសម្រាំង សុខុមាលភាពខាងសម្ភារៈរបស់ប្រជាជន ”។ ក្រុម “ ប្រជាជន ” បានទាមទារឱ្យមានការគោរពដ៏មឹុងម៉ាត់ដល់លក្ខខណ្ឌនានា នៃសន្ធិសញ្ញា

ហ្សីណែវ ឱ្យមានការតស៊ូដ៏សកម្មក្នុងកិច្ចការពារអធិបតេយ្យភាពជាតិ និងបូរណភាពដែនដីនៃប្រទេសកម្ពុជា។ ក្រុម “ ប្រជាជន ” បានធ្វើសេចក្តីថ្លែងការណ៍ប្រឆាំងមជ្ឈដ្ឋានដឹកនាំរបស់ប្រទេស ដោយធ្វើការទាមទារឱ្យមានការអនុវត្ត នូវនយោបាយប្រកបដោយលក្ខណៈចម្រើននិយមក្នុងការកែប្រែខាងសេដ្ឋកិច្ច និងសង្គមកិច្ចនៅប្រទេសកម្ពុជា។

នៅឆ្នាំ១៩៥៤ បក្សនយោបាយផ្សេងៗបានកើតមានឡើងនៅក្នុងជីវភាពនយោបាយ នៃប្រទេសកម្ពុជា នៅក្នុងនេះ មានបក្សប្រជាធិបតេយ្យ ដែលចាប់ផ្តើមបំពេញសកម្មភាពរបស់ខ្លួនឡើងវិញ បន្ទាប់ពីការបញ្ឈប់អនុវត្តស្ថានភាពអាសន្ននៅក្នុងប្រទេសនាឆ្នាំ១៩៥៣។

នៅក្នុងអំឡុងចាប់ពីឆ្នាំ១៩៥៣ ដល់ភាគខាងដើមនៃឆ្នាំ ១៩៥៤ អង្គការដឹកនាំបក្សប្រជាធិបតេយ្យបានគាំទ្រយ៉ាងចំហ ឬបានយល់ព្រមតាមដ៏ស្ងប់ស្ងៀម ដល់វិធានការខាងនយោបាយ និងយោធានានារបស់ ន. សីហនុ ដែលចាត់ឡើងដើម្បីធ្វើការប្រឆាំងនឹងកងកម្លាំងរំដោះជាតិខ្មែរឥស្សរៈ។ ក៏ប៉ុន្តែ បន្ទាប់ពីការបញ្ឈប់សង្គ្រាមនៅឥណ្ឌូចិន និងការរំសាយជួររបស់កងកម្លាំងខ្មែរឥស្សរៈមក បក្សប្រជាធិបតេយ្យបានប្រកាន់ឥរិយាបថប្រឆាំងនឹងការបង្កើតរដ្ឋអំណាចស៊ីវិល និងយោធារបស់រាជរដ្ឋាភិបាល ដោយយល់ថា កិច្ចការទាំងនេះអាចបង្កើតបានជាគ្រោះថ្នាក់ធំដុំដល់ផែនការនៃការប្រណាំងប្រជែងនយោបាយរបស់ខ្លួនក្នុងការដណ្តើមអំណាច។ នៅរដូវរងានៃឆ្នាំ១៩៥៥ បក្សប្រជាធិបតេយ្យបានថ្លែងប្រឆាំងបំណងរបស់មហាក្សត្រ ដើម្បីពង្រីកអង្គភាពនៃក្រុមនគរបាល និងកងកម្លាំងអាសាស្ម័គ្រ ដោយ

ជ្រើសរើសយកបញ្ហានេះ ទុកជាចំណុចមួយដ៏សំខាន់នៅក្នុងការឃោសនានយោបាយ ដើម្បីរៀបចំការឃោសនាបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់រដ្ឋសភា។

នៅដើមឆ្នាំ១៩៥៥ ន. សីហនុ បានសាកល្បងអនុវត្តការកែប្រែរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ក្នុងគោលបំណងនឹងពង្រីកអំណាចពេញលេញរបស់មហាក្សត្រ។

គម្រោងការកែប្រែរដ្ឋធម្មនុញ្ញ ត្រូវបានចុះផ្សាយជាទូទៅនៅថ្ងៃទី១៩ កុម្ភៈ ឆ្នាំ១៩៥៥។ ស្របតាមគម្រោងការនេះ រដ្ឋាភិបាលត្រូវតែទទួលខុសត្រូវ នៅចំពោះមុខមហាក្សត្រ ហើយមិនមែនចំពោះមុខរដ្ឋសភាទេ។ ធ្វើដូច្នេះ រដ្ឋសភាទៅជាគ្មានសិទ្ធិបោះឆ្នោតជ្រើសរើស ឬរំលំរដ្ឋាភិបាល ហើយបានប្រែទៅជាអង្គការពិគ្រោះពិភាក្សាធម្មតាទៅវិញ។ ក្នុងការកែប្រែដ៏សំខាន់នេះ ន. សីហនុ មានបំណងកែប្រែទាំងច្បាប់នៃការឃោសនាបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ។ គម្រោងការនៃការកែប្រែបានពិនិត្យពិច័យអំពីការអនុវត្តនៅប្រទេសកម្ពុជា នូវប្រព័ន្ធនៃការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រសម្រាប់រដ្ឋសភា តាមជាន់ថ្នាក់នានា ដែលនៅក្នុងនេះមិនមែនបណ្តាជនទេ ដែលជ្រើសរើសតំណាងរាស្ត្រ ក៏ប៉ុន្តែ គឺអង្គការ នៃសមាជិកសភាខេត្តទៅវិញ ដែលមានសិទ្ធិជ្រើសរើសតំណាងរាស្ត្រ។ បេក្ខជនតំណាងរាស្ត្រទាំងអស់ ត្រូវមានជីវភាពរស់នៅយ៉ាងតិចអស់រយៈពេលបីឆ្នាំនៅក្នុងមណ្ឌលរបស់ខ្លួន។ ការអនុវត្តវិធានការបែបនេះ បានធ្វើឱ្យអ្នករួបរួមនៅ ក្នុងចលនាតស៊ូខ្មែរឥស្សរៈបាត់បង់សិទ្ធិរបស់ខ្លួនក្នុងការឈរឈ្មោះជាបេក្ខជនបោះឆ្នោត។

ន. សីហនុ បានធ្វើសំណើឱ្យអ្នកស្រុកធ្វើប្រជាមតិជាថ្មីលើគម្រោងការកែប្រែរដ្ឋធម្មនុញ្ញ ដែល ន. សីហនុ ចង់រៀបចំមុនពេលបោះឆ្នោតទូទៅនៅប្រទេសកម្ពុជា ដែលត្រូវចាប់ផ្តើមធ្វើឡើងនៅខែមេសា ឆ្នាំ១៩៥៥ ស្របតាមសន្ធិសញ្ញាហ្សឺណែវ។ ក៏ប៉ុន្តែ ការបោះឆ្នោតនេះត្រូវបានពន្យារពេលដោយមហាក្សត្រដល់ខែកញ្ញា ទៅវិញ។

គោលបំណងរបស់ ន. សីហនុ ដើម្បី "អារកាត់" អត្ថន័យសំខាន់របស់រដ្ឋធម្មនុញ្ញ ហើយដើម្បីប្រមែប្រមូលអំណាចទាំងអស់ខាងរដ្ឋបាល និងយោធាឱ្យមកស្ថិតនៅក្នុងកណ្តាប់ដៃរបស់ខ្លួន បណ្តាលឱ្យមានប្រតិកម្មប្រឆាំងជាខ្លាំង ពីសំណាក់មជ្ឈដ្ឋានអ្នកប្រជាធិបតេយ្យកម្ពុជា ដែលមានបក្សប្រជាជនបដិវត្តន៍កម្ពុជាជាក្រុមស្នូល។ គណៈកម្មការអន្តរជាតិនៃការត្រួតត្រាលើការអនុវត្តសន្ធិសញ្ញាហ្សឺណែវ ក៏បានថ្លែងប្រឆាំងការកែប្រែរដ្ឋធម្មនុញ្ញបែបនេះ ដែលទាក់ទងនឹងគោលបំណងរបស់ ន. សីហនុ ដើម្បីផ្លាស់ប្តូរច្បាប់បោះឆ្នោត ក្នុងគោលបំណងបំបាត់លទ្ធភាពដល់អតីតអ្នករួបរួមក្នុងចលនាតស៊ូរំដោះជាតិ មិនឱ្យគេអាចឈរឈ្មោះជាបេក្ខជនតំណាងរាស្ត្របាន។ ដោយប៉ះទង្គិចដោយកម្លាំងនៃប្រតិកម្មប្រឆាំងបែបនេះ មហាក្សត្របានផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់ខ្លួន ដោយប្រើប្រាស់វិធីផ្សេងទៀតក្នុងការតស៊ូខាងនយោបាយដើម្បីពង្រីកអំណាចរបស់ខ្លួន។ នៅខែមីនា ឆ្នាំ១៩៥៥ មហាក្សត្រ ន. សីហនុ បានប្រកាសអំពីការចាកចេញពីរាជបល្ល័ង្ក ហើយបានឱ្យបិតា នាម នរោត្តម សុរាម្រឹត ឡើងសោយរាជ្យបន្តនៅប្រទេសកម្ពុជា ទៅទៀត។

បន្ទាប់ពីឈប់សោយរាជ្យ នរោត្តម សីហនុ បានចាប់ផ្តើមបង្កើតសង្គមរាស្ត្រនិយម ហៅកាត់ថា "សង្គម" គឺជាអង្គការ ដែលតមកបានជះឥទ្ធិពលដ៏ខ្លាំងក្លាទៅលើជីវភាពនយោបាយ និងសង្គមរបស់ប្រទេស។ នៅក្នុងលក្ខន្តិកៈរបស់សង្គម ដែលចុះផ្សាយជាទូទៅនៅខែមីនា ឆ្នាំ១៩៥៥ បានគូសបញ្ជាក់ថា សង្គមរាស្ត្រនិយមមិនមែនជាបក្សនយោបាយណាមួយ ក៏ប៉ុន្តែជា "អង្គការបង្រួបបង្រួមជាតិ" ដែលមានគោលបំណងនឹងកសាងរបស់ដែលគេហៅថា "រាជសង្គមនិយមពុទ្ធសាសនា" នៅប្រទេសកម្ពុជា។

តាមការពិត ទស្សនៈនៃមាគ៌ានយោបាយរបស់ "សង្គមរាស្ត្រនិយម" ដោយដឹកនាំដោយ ន. សីហនុ គ្មានលក្ខណៈអ្វីស្របតាមលទ្ធិសង្គមនិយមពិតប្រាកដទេ ដោយហេតុថា គោលការណ៍ទូទៅរបស់មាគ៌ានយោបាយនេះ មានគោលគំនិតរបស់អ្នកជាតិនិយមគហបតី។ ទស្សនៈគហបតីជាតិនិយម មានអត្ថន័យ ជាមូលដ្ឋាននៃ "រាជសង្គមនិយមពុទ្ធសាសនា"។ ទស្សនៈនេះបានបង្កើតឡើងដើម្បីអនុវត្តការកែប្រែខ្លះ ប្រឆាំងរបបសក្តិភូមិនៅប្រទេសកម្ពុជា ក្នុងគោលបំណងពង្រីកស្ថានភាពនយោបាយរបស់ប្រទេស ទៅតាមមាគ៌ាមូលធននិយម។

នៅរដូវក្តៅ នៃឆ្នាំ១៩៥៥ បក្សនយោបាយភាគច្រើនបានរំលាយខ្លួន ហើយចុះចូលក្នុងជួររបស់សង្គម។ ក្រុម "ប្រជាជន" និងបក្សប្រជាធិបតេយ្យមិនបានចូលរួមក្នុងអង្គការសង្គមទេ។ ក្រុមស្នូល នៃសង្គមរាស្ត្រនិយម កកើតឡើងដោយការរួបរួមជាបក្សពួកនយោបាយ របស់អ្នកតំណាងនៃវណ្ណៈអភិជនសក្តិភូមិជាតិនិយម នៃវណ្ណៈគហបតី ដែលកំពុងតែលូតលាស់

និងបណ្ឌាបញ្ញវន្ត ព្រមទាំងនាហ្មឺនដែលធ្វើការនៅក្នុងក្រសួងផ្សេងៗ នៃរដ្ឋបាល។

សង្គមបានខំប្រឹងប្រែងធ្វើសកម្មភាព ក្នុងការរៀបចំការឃោសនាបោះឆ្នោតជ្រើសរើសតំណាងទូទៅ ដែលត្រូវកំណត់ធ្វើឡើងនៅខែកញ្ញា ឆ្នាំ១៩៥៥។

កាលនោះ បេក្ខជនតំណាងក្រុម " ប្រជាជន " ដែលបានធ្វើការឃោសនាបោះឆ្នោត មានចំនួនដ៏តិចតួចបំផុត ដោយហេតុថា សកម្មភាពនយោបាយរបស់គេត្រូវបានហាមឃាត់នៅក្នុងតំបន់ជាច្រើន នៃប្រទេស។

ចំណែកឯបក្សប្រជាធិបតេយ្យវិញនោះ ឥទ្ធិពលរបស់បក្សនេះនៅទីក្រុងភ្នំពេញ និងទីប្រជុំជនដទៃ ក៏មិនមែនជាខ្លង់ខ្លស់ប៉ុន្មានដែរ។ ហេតុនេះហើយ បានជាគេគ្មានឆ្ងល់អ្វីទេថា នៅក្នុងសភាពការណ៍បែបនេះ បណ្ដាបេក្ខជនរបស់ " សង្គម " នាសម័យបោះឆ្នោតឆ្នាំ១៩៥៥ ប្រមូលបានសំឡេងភាគច្រើនលើសលុប ហើយតំណាងរាស្ត្រនៅរដ្ឋសភា ត្រូវបានបេក្ខជន " សង្គម " កាន់កាប់ទាំងអស់។

បន្ទាប់ពីសម័យបោះឆ្នោតនាឆ្នាំ១៩៥៥ អង្គការដឹកនាំសង្គម បានដឹកនាំមាគ៌ានយោបាយពង្រីកចំនួនសមាជិកភាពនៃអង្គការនេះ ដោយការខិតខំបញ្ចុះបញ្ចូលតំណាងបណ្ដាជនពេញវ័យនៅទីក្រុង និងនៅតំបន់ស្រុកស្រែនៃប្រទេសឱ្យចូលជាសមាជិករបស់ " សង្គម " គ្រាន់តែតាមទម្រង់ខាងក្រៅ។ ភាពប្រញាប់ប្រញាល់នៃការធ្វើ " កំណែន " បញ្ចុះបញ្ចូលបណ្ដាជនឱ្យចូលក្នុង " សង្គម " ដែលនៅក្នុងនេះ មានកសិករមួយភាគធំបានប្រព្រឹត្តទៅក្នុងគោលបំណង ប្រមែប្រមូលមហាជន

មកខាងខ្លួន ហើយបន្ថយឥទ្ធិពលរបស់កម្លាំងបដិវត្តន៍ប្រជាធិបតេយ្យពីសំណាក់ប្រជាពលករ។ ក៏ប៉ុន្តែ នយោបាយរបស់អង្គការដឹកនាំ “ សង្គម ” ដើម្បីកាន់អំណាចផ្តាច់មុខក្នុងជីវភាពនយោបាយរបស់ប្រទេស ទៅជាមិនបានសម្រេចផលប៉ុន្មាន។ លក្ខណៈរបស់ “ សង្គម ” ដែលកើតមកអំពីការរួបរួមនៃស្រទាប់មនុស្សនៅក្នុងវណ្ណៈសង្គមខុសៗគ្នា បានបង្កើតឱ្យមានកម្លាំងប្រតិកម្មនៅក្នុងជួរនានា នៃសមាជិករបស់ខ្លួន។

បើពិនិត្យទៅតាមព្រឹត្តិការណ៍នានា ដែលកើតមានឡើងនៅក្នុងអង្គការសង្គម នោះគេអាចឃើញច្បាស់ថា ចរន្តប្រតិកម្មពីរយ៉ាងបានកកើតមានឡើង។ ចរន្តមួយបានតំណាងឱ្យផលប្រយោជន៍ខ្លះនៃស្រទាប់ក្រោមនៃអង្គការ ហើយបានស្ថិតនៅជិតជិតនឹងប្រជាករ។ ចរន្តមួយទៀតតំណាងដល់ផលប្រយោជន៍របស់បក្ខពួកខាងស្តាំបំផុត ដែលជាជនជិះជាន់គេនៅក្នុងប្រទេស មានពួកនាយទុនកុំប្រាឌ័រ ពួកម្ចាស់ដី និងអ្នកចងការប្រាក់...។ល។

ជំហានទី១ដ៏សំខាន់របស់អង្គការសង្គម ដែលជាអង្គការដឹកនាំប្រទេស គឺការចាត់វិធានការរៀបចំនយោបាយរបស់រដ្ឋឱ្យមានលក្ខណៈស្របទៅតាមស្ថានភាពថ្មីនៃប្រទេស គឺស្ថានភាពជារដ្ឋប្រកបដោយអធិបតេយ្យភាព។ នៅខែកញ្ញា ឆ្នាំ១៩៥៥ តំណាងរាស្ត្រនៅរដ្ឋសភាបានអនុម័ត លើសេចក្តីសម្រេចចិត្តស្តីអំពីការដកថយប្រទេសកម្ពុជា ចេញពីសហភាពបារាំង។ នៅខែមករា ឆ្នាំ១៩៥៦ រដ្ឋសភាបានអនុម័តដល់សេចក្តីបន្ថែមជាពិសេសចំពោះអត្ថបទរដ្ឋធម្មនុញ្ញ ដែលនៅក្នុងនេះ មានសេចក្តី

ប្រកាសថា ប្រទេសកម្ពុជា ជារដ្ឋឯករាជ្យ ប្រកបដោយប្រជាធិបតេយ្យភាព។

នៅខែធ្នូ ឆ្នាំ១៩៥៥ ប្រទេសកម្ពុជា ត្រូវបានចូលជាសមាជិករបស់អង្គការសហប្រជាជាតិ។

ការរំលាយប្រព័ន្ធរដ្ឋការគយរវាងបារាំង និងរដ្ឋចូលរួមក្នុងសហភាពបារាំង នៅឥណ្ឌូចិន នៅខែធ្នូ ឆ្នាំ១៩៥៤ បានផ្តល់លទ្ធភាពឱ្យរដ្ឋាភិបាលកម្ពុជា អាចធ្វើការត្រួតត្រាលើប្រព័ន្ធរូបិយប័ណ្ណ និងរដ្ឋការគយរបស់ប្រទេស ហើយអាចដកខ្លួនថយចេញពីឥទ្ធិពលនៃតំបន់ប្រាក់ហ្វ្រង់។ នៅពេលនោះ មានការបង្កើតធនាគារជាតិ និងការបោះពុម្ពឱ្យប្រើប្រាស់ប្រាក់ថ្មី គឺប្រាក់រៀល។

នៅសម័យកាលនៃការកាន់កាប់អំណាច អង្គការសង្គមបានជួបប្រទះនឹងសភាពការណ៍ នយោបាយក្រៅប្រទេសដ៏ស្មុគស្មាញ នៅក្នុងស្ថានភាពដែលមានអំពើកៀបសង្កត់កាន់តែខ្លាំងឡើងរបស់ចក្រពត្តិនិយមអាមេរិក។ ដូចមានអធិប្បាយរួចមកហើយ ការចូលជ្រៀតជ្រែករបស់អាមេរិក នៅក្នុងប្រទេសកម្ពុជា បានចាប់ផ្តើមឡើងតាំងពីសម័យក្រោយសង្គ្រាមលោកលើកទីពីរ គឺនៅពេលដែលសហរដ្ឋអាមេរិក បានប្រើប្រាស់ស្ថានភាពទន់ខ្សោយរបស់បារាំង នៅឥណ្ឌូចិន ហើយបានចុះហត្ថលេខាជាមួយរាជរដ្ឋាភិបាលកម្ពុជា លើកិច្ចព្រមព្រៀងស្តីអំពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនៅឆ្នាំ១៩៥១។ តាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងនេះ ជំនួយសេដ្ឋកិច្ចអាមេរិក ត្រូវបានផ្តល់មកឱ្យប្រទេសកម្ពុជា ដោយយកពីប្រាក់ជំនួយដែលសហរដ្ឋអាមេរិកបានចែករំលែកឱ្យប្រទេសបារាំង ក្នុងគោលបំណងនឹងពង្រីក

សង្គ្រាមឈ្លានពានរបស់ប្រទេសនេះនៅឥណ្ឌូចិន។ ដូច្នេះ ជំនួយអាមេរិក ត្រូវបានផ្តល់មកកម្ពុជា តាមរយៈនៃរដ្ឋការអាណានិគមនិយមបារាំង ដែលបានប្រើប្រាស់ជំនួយនេះទាំងអស់ក្នុងផលប្រយោជន៍ នៃនយោបាយយោធារបស់ខ្លួននៅឥណ្ឌូចិន។ ក៏ប៉ុន្តែ របៀបរបបនៃការផ្តល់ជំនួយហិរញ្ញវត្ថុអាមេរិក បែបនេះបណ្តាលឱ្យមានការកម្រិតជាខ្លាំង នូវសេរីភាពនៃសកម្មភាពរបស់កិច្ចការទូតសហរដ្ឋអាមេរិក នៅប្រទេសកម្ពុជា។

បន្ទាប់ពីឆ្នាំ១៩៥៤ ស្ថានភាពនៅក្នុងផ្នែកនេះបានផ្លាស់ប្តូរយ៉ាងខ្លាំង។ ការរំលំរំលើងនៃប្រព័ន្ធអាណានិគមនិយមបារាំងនៅឥណ្ឌូចិន បានទាក់ទាញឱ្យសហរដ្ឋអាមេរិក បង្កើនសកម្មភាពរបស់ខ្លួនកាន់តែខ្លាំងឡើង តម្រង់ទៅរកការរៀបចំកិច្ចត្រួតត្រារបស់ខ្លួនលើវៀតណាមខាងត្បូង ប្រទេសកម្ពុជា និងឡាវ។ ដូចពេលមុន អាវុធជាមូលដ្ឋានដ៏សំខាន់មួយក្នុងនយោបាយវាតទីនិយមរបស់សហរដ្ឋអាមេរិក នៅឥណ្ឌូចិន គឺជំនួយយោធា និងសេដ្ឋកិច្ច។ ម្តងនេះ ជំនួយអាមេរិក ត្រូវបានផ្តល់ដោយផ្ទាល់ដល់អ្នកតំណាងនៃ “ របបគ្រប់គ្រងប្រឆាំងកុម្មុយនិស្តនិយម ” នៅឥណ្ឌូចិន។

ក្នុងបណ្តារបបគ្រប់គ្រងអាមេរិកនិយមទាំងនេះ ទីក្រុងវ៉ាស៊ីនតោន បានបញ្ចូលទាំងរាជរដ្ឋាភិបាលប្រទេសកម្ពុជា ដោយហេតុថា ចាប់ពីឆ្នាំ១៩៥៤ - ១៩៥៥ រាជរដ្ឋាភិបាលបានធ្វើការប្រឹងប្រែងគ្រប់យ៉ាងដើម្បីវាយបំបាក់អតីតអ្នករួបរួមក្នុងចលនាខ្មែរឥស្សរៈ និងដល់បណ្តាអ្នកតំណាងកម្លាំងប្រជាធិបតេយ្យដទៃ ហើយដែលនៅក្នុងកិច្ចការនេះ រាជរដ្ឋាភិបាលកម្ពុជា មានបំណងទទួលការគាំទ្រពីសំណាក់មជ្ឈដ្ឋានដឹកនាំនៃសហរដ្ឋអាមេរិក។

នៅខែឧសភា ឆ្នាំ១៩៥៥ រវាងរដ្ឋាភិបាលសហរដ្ឋអាមេរិក និងរាជរដ្ឋាភិបាលកម្ពុជា មានការចុះហត្ថលេខាលើសន្ធិសញ្ញាស្ដីអំពីការផ្ដល់ជំនួយយោធា និងសេដ្ឋកិច្ចអាមេរិក។ ការគំរាមកំហែងពិត បានកើតមានឡើងក្នុងការទាក់ទាញប្រទេសកម្ពុជាឱ្យចូលទៅក្នុងរង្វង់នៃបក្សសម្ពន្ធឈ្លានពាន សេ.អា.តូ (អង្គការសន្ធិសញ្ញាអាស៊ីអាគ្នេយ៍របស់ចក្រពត្តិ) ហើយដែលនឹងអាចធ្វើឱ្យប្រទេសនេះ ទៅជាមូលដ្ឋានខាងក្រោយរបស់ចក្រពត្តិនិយមអាមេរិក នៅឥណ្ឌូចិន។

នយោបាយពឹងផ្អែកតែម៉្យាង ទៅលើការគាំទ្ររបស់សហរដ្ឋអាមេរិក អនុវត្តដោយរាជរដ្ឋាភិបាលក្នុងរយៈពេលនៃឆ្នាំ១៩៥៤ - ១៩៥៥ បណ្ដាលឱ្យមានចលនាប្រឆាំងដ៏ខ្លាំងក្លាពីសំណាក់កម្លាំងស្នេហាមាតុភូមិ និងប្រជាធិបតេយ្យនៃប្រទេសកម្ពុជា។ នៅឆ្នាំ១៩៥៥ ចលនាប្រជាករនៃអ្នកគាំទ្រមាគ៌ានយោបាយក្រៅប្រទេសនៃកម្ពុជាឯករាជ្យ អព្យាក្រឹត បានលេចរូបរាងឡើង។ វិភាគទានដ៏ធំនៅក្នុងការពង្រីកចលនានេះ គឺសកម្មភាពរបស់បក្សប្រជាជនបដិវត្តន៍ ដែលបានដឹកនាំការតស៊ូដ៏ម៉ឺងម៉ាត់ដើម្បីកិច្ចការពារអធិបតេយ្យភាពជាតិនៃប្រទេសកម្ពុជា ប្រឆាំងនយោបាយវាតទីនិយមចក្រពត្តិនិយមអាមេរិក ប្រឆាំងនឹងសកម្មភាពផ្ទុយនឹងប្រយោជន៍ជាតិ របស់ពួកបរិវារចក្រពត្តិនៅក្នុងប្រទេស។

ការរីសាយនូវកំហឹងដ៏ខ្លាំងក្លាប្រឆាំង នយោបាយអាមេរិកនិយម និងសេចក្ដីទិតៀនដ៏ខ្លាំងដល់សន្ធិសញ្ញានាឆ្នាំ១៩៥៥ បានទាក់ទាញឱ្យ ន. សីហនុ និងបក្ខពួករបស់ខ្លួនបោះបង់ចោលនូវនយោបាយជិតស្និទ្ធជាមួយសហរដ្ឋអាមេរិក ដែលប្រព្រឹត្តទៅ

លើមូលដ្ឋានមិនស្មើភាពគ្នា ហើយដែលនាំឱ្យខូចខាតដល់អធិបតេយ្យភាពជាតិ នៃប្រទេស។

ហេតុនេះហើយ បានជានៅខែកុម្ភៈ ឆ្នាំ១៩៥៦ ជាលើកទី១ រដ្ឋាភិបាលកម្ពុជា បានប្រកាសនូវការបដិសេធការទាក់ទងដោយត្រង់ ឬដោយមិនត្រង់ក្នុងសកម្មភាពរបស់បក្សសម្ពន្ធយោធាឈ្លានពាន សេ.អា.តូ។

ឥរិយាបថបែបនេះធ្វើឱ្យសហរដ្ឋអាមេរិក និងប្រទេសជាបក្ខពួករបស់ខ្លួននៅអាស៊ីអាគ្នេយ៍ ចាប់ផ្តើមអនុវត្តនយោបាយកៀបសង្កត់ដ៏ចំហមកលើប្រទេសកម្ពុជា។ នៅឆ្នាំ១៩៥៦ ស្ថានបេសកកម្មអាមេរិក នៅទីក្រុងភ្នំពេញ បានបញ្ឈប់ជាបណ្តោះអាសន្ននូវសកម្មភាពសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលទាក់ទងនឹងការផ្តល់ជំនួយយោធា និងសេដ្ឋកិច្ចដល់ប្រទេសកម្ពុជា។ ដើរតាមខ្សែញាក់របស់សហរដ្ឋអាមេរិក រដ្ឋាភិបាលថៃ និងវៀតណាមខាងត្បូង បានបិទព្រំប្រទល់របស់ខ្លួន ដែលស្ថិតនៅជាប់ប្រទេសកម្ពុជា ហើយបានធ្វើសេចក្តីប្រកាសអំពីនយោបាយហ៊ុមព័ទ្ធ ខាងសេដ្ឋកិច្ចប្រឆាំងនឹងប្រទេសកម្ពុជា។ នៅពេលជាមួយគ្នា ការបង្កបង្កើតខាងយោធាបានកើតមានឡើងនៅតំបន់នានាតាមព្រំប្រទល់ប្រទេស ប៉ែកខាងត្បូង និងប៉ែកខាងលិច។

នយោបាយកៀបសង្កត់ ពីសំណាក់ទីក្រុងវ៉ាស៊ីនតោន បានបណ្តាលឱ្យចលនាកំហឹងក្តៅក្រហាយខ្លាំងក្លា នៅប្រទេសកម្ពុជា។ នៅខែកុម្ភៈ និងខែមីនា ឆ្នាំ១៩៥៦ នៅគ្រប់ខេត្តបាតុកម្មនានា បានធ្វើឡើងប្រឆាំងនឹងនយោបាយវាតទីនិយមរបស់សហរដ្ឋអាមេរិក ដើម្បីគាំទ្រដល់នយោបាយអព្យាក្រឹតភាព។

នៅឆ្នាំ១៩៥៦ អ្នកដឹកនាំ " សង្គម " បានចាប់ផ្តើមរៀបចំការទាក់ទងនយោបាយ និងខាងកិច្ចការទូតជាមួយសហភាពសូវៀត និងបណ្តាប្រទេសសង្គមនិយមដទៃទៀត។ គណៈប្រតិភូរាជរដ្ឋាភិបាលប្រទេសកម្ពុជា បានទៅធ្វើទស្សនកិច្ចនៅទីក្រុងម៉ូស្គូ និងរដ្ឋធានីនៃប្រទេសសង្គមនិយមដទៃ។ នៅក្នុងឱកាសនៃទស្សនកិច្ចទាំងនេះ មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនានាស្តីអំពីកាពង្រីកទំនាក់ទំនងខាងវប្បធម៌ និងសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ជាមួយប្រទេសសង្គមនិយមនានានៅលើមូលដ្ឋាននៃគោលការណ៍ " ប្រាំ.ខ " នៃសហវិជ្ជមានដោយសន្តិវិធី។ ការចាប់ផ្តើមរៀបចំទំនាក់ទំនងខាងផ្លូវទូតជាមួយសហភាពសូវៀត នៅខែឧសភា ឆ្នាំ១៩៥៦ បានផ្តល់អត្ថន័យដ៏ពិសេសសម្រាប់ពង្រឹងគោលជំហរអន្តរជាតិ និងអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា។

នយោបាយរបស់ពួកខាងឆ្វេង អង្គការសង្គមប្រឆាំងនយោបាយវាតទីនិយមអាមេរិក ព្រមទាំងការប្រឹងប្រែងរបស់អង្គការនេះ ដើម្បីការពារអធិបតយ្យភាពជាតិត្រូវបានអនុវត្តនៅក្នុងលក្ខខណ្ឌនានា ដែលនៅពេលនោះ មជ្ឈដ្ឋានតំណាងកម្លាំងប្រឆាំងខាងស្តាំនៅក្នុងប្រទេសកម្ពុជា បានធ្វើសកម្មភាពយ៉ាងខ្លាំងប្រឆាំងនឹងនយោបាយអព្យាក្រឹត ដោយមានបំណងចង់ឱ្យប្រទេសកម្ពុជា ធ្លាក់ទៅក្នុងរង្វង់ដៃរបស់ចក្រពត្តិនិយមអាមេរិក នៅក្នុងពេលខាងមុខ។

មូលដ្ឋានខាងសង្គមកិច្ច របស់អង្គការពួកប្រឆាំងខាស្តាំមានវណ្ណៈនាយទុន កុំប្រាឌ័រ ពួកពាណិជ្ជករ អ្នកចងការប្រាក់ព្រមទាំងបញ្ញវន្តការិយាល័យនិយមមួយភាគ ដែលប្រកាន់

ឥរិយាបថប្រតិកិរិយា។ ស្ថានភាពខាងសេដ្ឋកិច្ចរបស់វណ្ណៈគហបតីកុំប្រាឌ័រ បានចម្រុងចម្រើនយ៉ាងប្រសើរនៅអំឡុងសម័យកាលនៃភាគខាងចុងនៃទសវត្សរ៍ទី៥ ដោយសារការពង្រីកសកម្មភាពឈ្មួញកណ្តាល ទាក់ទងនឹងការអនុវត្តកម្មវិធីជំនួយសេដ្ឋកិច្ច និងយោធាអាមេរិក។

នៅឆ្នាំ១៩៥៥ វណ្ណៈគហបតីកុំប្រាឌ័រ មើលឃើញនៅក្នុងពាក្យស្លោកនយោបាយរបស់អង្គការ " សង្គម " ថា ជារបៀបប្រើយុទ្ធសាស្រ្តម្យ៉ាង ក្នុងការតស៊ូរបស់គេប្រឆាំងក្រុម " ប្រជាជន " និងបក្សប្រជាធិបតេយ្យ ក្រុមពួកកុំប្រាឌ័រនៃវណ្ណៈនេះមួយចំនួនធំព្រមទាំងក្រុមពួកការិយាល័យនិយម បានសុំចូលជាសមាជិករបស់អង្គការ " សង្គម " ដោយគ្មានរអេរ ហើយបានឱ្យឈ្មោះខ្លួនឯងថា " អ្នកសង្គមនិយម "។ ក៏ប៉ុន្តែ នៅក្នុងការរួបរួមរបស់ខ្លួនពួកនេះបានទាមទារយ៉ាងសកម្ម ឱ្យមានការពង្រីកជាអតិបរមានូវការទាក់ទងរវាងសហគ្រិនឯកជន និងឥណទានរូបិយប័ណ្ណអាមេរិក។ ស្រទាប់នៃពួកកុំប្រាឌ័រ មើលឃើញនៅក្នុងការអនុវត្តនយោបាយឯករាជ្យកម្ពុជា ថា ជាសេរីភាពម្យ៉ាង ក្នុងកិច្ចការគៃប្រវ័ញ្ចគ្មានព្រំដែន និងក្នុងការលួចបន្លំប្រាក់ថវិកាជាតិ។ មែនពិត សកម្មភាពរបស់ពួកឈ្មួញ និងឈ្មួញកណ្តាលបានប្រឆាំងនឹងផលប្រយោជន៍ជាតិ ជាសាធារណៈរបស់រដ្ឋកម្ពុជា ជាពិសេសប្រឆាំងនឹងមាគ៌ាអព្យាក្រឹតភាព នៃនយោបាយក្រៅប្រទេស។

នៅឆ្នាំ១៩៥៦ សកម្មភាពប្រឆាំងរបស់សត្រូវបិទមុខដល់នយោបាយអព្យាក្រឹត បានចាប់ផ្តើមរីកសាយកាន់តែធំនៅក្នុងប្រទេស។ ពួកនេះយល់ព្រមដើរតាមមាគ៌ានយោបាយនេះ តែ

តាមពាក្យសម្ដី។ ក៏ប៉ុន្តែ តាមការពិត ពួកនេះបានសំដែងឥរិយាបថប្រឆាំង ហើយបានទាំងធ្វើអ្វីៗគ្រប់យ៉ាង ដើម្បីពន្យឺតដល់កិច្ចការពង្រីកទំនាក់ទំនងខាងសេដ្ឋកិច្ច និងខាងផ្លូវទូតរបស់ប្រទេសកម្ពុជា ជាមួយប្រទេសសង្គមនិយមនានា ហើយខំទាក់ទាញប្រទេសខ្លួន ឱ្យធ្លាក់ចូលទៅក្នុងឥទ្ធិពលរបស់បក្សសម្ពន្ធចក្រពត្តិនិយម។

នៅសម័យកណ្ដាលនៃទសវត្សរ៍ទី៦ ក្រុមអាមេរិកនិយមខាងស្ដាំ នៃអង្គការសង្គម បានបង្កើនសកម្មភាពរបស់ខ្លួនជាខ្លាំងនៅក្នុងរដ្ឋសភា។ ហេតុនេះហើយ បានជានៅខែធ្នូ ឆ្នាំ១៩៥៦ មានវិបត្តិរដ្ឋាភិបាលផ្ទុះឡើង ពីព្រោះវណ្ណៈគហបតីពាណិជ្ជករព្រមទាំងមជ្ឈដ្ឋានចក្រពត្តិនិយម ធ្វើយ៉ាងណាឱ្យពួកខ្លួនអាចបង្កើតកិច្ចត្រួតត្រាលើសកម្មភាពរបស់អង្គការ “ សង្គម ” និងរដ្ឋសភាជាតិ។

នៅក្នុងរដ្ឋសភា បក្ខពួកប្រឆាំងបានបាក់បែកគ្នាជាក្រុមជាពួក។ ការបែកបាក់គ្នា និងបដិបក្ខកម្មនានាបែបនេះមានលក្ខណៈពិសេសម្យ៉ាងនៅជុំវិញបញ្ហានយោបាយអព្យាក្រឹត គឺថាកាលណាបញ្ហានេះចោទឡើងម្ដងៗ ពួកដឹកនាំក្រុមនានាបានបញ្ឈប់ជម្លោះទាស់ទែងគ្នា ហើយបានប្រកាន់ឥរិយាបថរួមគ្នាដើម្បីពង្រីកទំនាក់ទំនងរបស់ប្រទេសកម្ពុជា តែនឹងសហរដ្ឋអាមេរិក ព្រមទាំងជាមួយប្រទេសមូលធននិយមដទៃទៀត។ បក្ខពួកខាងស្ដាំនៅរដ្ឋសភា បានប្រកាន់ឥរិយាបថក្រៅផ្លូវការដែលអាចបញ្ជាក់តាមពាក្យស្លោកថា “ អព្យាក្រឹតភាពដោយគ្មានសហប្រតិបត្តិការខាងសេដ្ឋកិច្ច ជាមួយប្រទេសសង្គមនិយមនានា ”។

តាមធម្មតា បក្ខពួកប្រឆាំងនៅរដ្ឋសភាមិនសូវធ្វើការរិះគន់ខ្លាំងដល់អ្នកនិយមនយោបាយអព្យាក្រឹត ចំពោះបញ្ហាណាដែលមានលក្ខណៈបន្ទាប់បន្សំ។ ក៏ប៉ុន្តែ កាលណាមានបញ្ហាទាក់ទងទៅនឹងការបោះឆ្នោតសំដែងសេចក្តីទុកចិត្ត ឬមិនទុកចិត្តដល់រដ្ឋាភិបាល ពួកនេះបានរួបរួមសំឡេងគ្នា ដើម្បីធ្វើការវាយសម្រុកឥតត្រាប្រណី។

នៅដើមឆ្នាំ១៩៥៧ បក្ខពួកប្រឆាំងខាងស្តាំនៅរដ្ឋសភាបានទទួលការគាំទ្រពេញជំហរ ពីសំណាក់របស់បក្សប្រជាធិបតេយ្យ។ នៅឆ្នាំ១៩៥៦ ពួកអ្នកដឹកនាំបក្សប្រជាធិបតេយ្យដែលបានចងគំនុំនឹងបរាជ័យ របស់ខ្លួននាសម័យបោះឆ្នោតឆ្នាំ១៩៥៥ បានចាប់ផ្តើមធ្វើការប្រឆាំងរដ្ឋាភិបាល។ ក្នុងការចោទប្រកាន់ដល់អំពីស៊ីសំណូកពុករលួយរបស់មន្ត្រីនៃរដ្ឋបាល បក្សប្រជាធិបតេយ្យ បានទម្លាក់កំហុសទាំងអស់ទៅលើអង្គការ " សង្គម " ដែលក្នុងនោះ មានទាំងអ្នកតំណាងខាងឆ្វេងនៃអង្គការនេះផងដែរ។ ក្នុងបំណងប៉ុនប៉ងដណ្តើមអំណាចនយោបាយតាមមធ្យោបាយគ្រប់បែបយ៉ាង នៅទីបំផុត បក្សប្រជាធិបតេយ្យបានធ្លាក់ខ្លួនទៅក្នុងស្ថានភាពនៃការប្រឆាំងជាតិ ហើយបានប្រែក្លាយទៅជាអាវុធដ៏ងងឹតងងល់ របស់កម្លាំងភេរវកម្មនៃប្រទេសកម្ពុជា។

ឥរិយាបថប្រឆាំងដ៏ខ្លាំងក្លា របស់បក្សប្រជាធិបតេយ្យបានបព្រឹត្តទៅ នៅក្នុងស្ថានភាពនៃការកៀបសង្កត់ដោយយោធាជាចំហមកលើប្រទេសកម្ពុជា ពីសំណាក់បក្សសម្ពន្ធ សេ.អា.តូ។ ការកៀបសង្កត់ខាងយោធានេះ បានចាប់ផ្តើមឡើងពីសម័យភាគចុងឆ្នាំ១៩៥៦ ហើយដោយមានការគាំទ្រពីសហរដ្ឋអាមេរិក

ពួកអ្នកដឹកនាំនៃវៀតណាមខាងត្បូង និងប្រទេសថៃឡង់ដ៍ បាន រៀបចំបង្កបង្កើតហេតុដោយឃោជា នៅតាមព្រំប្រទល់របស់ ប្រទេស។ ចាប់ពីខែកក្កដា ឆ្នាំ១៩៥១ ដល់ខែឧសភា ឆ្នាំ១៩៥៧ គ្រាន់តែនៅប៉ែកខាងព្រំប្រទល់ខ្មែរ - វៀតណាមខាងត្បូង គេ បានកត់ត្រា ឃើញមានការបង្កបង្កើតហេតុ ដោយឃោជាជាង ៤៣ដង។ ការបង្កបង្កើតហេតុដ៏ខ្លាំងបំផុតបានធ្វើឡើងនៅ ខែមករា ឆ្នាំ១៩៥៧ ដែលនៅពេលនោះ អង្គភាពនៃកងទ័ព វៀតណាមខាងត្បូង បានវាយលុកចូលមកលើទឹកដីកម្ពុជា នៅ ក្នុងខេត្តស្វាយរៀង។

នៅរដូវក្តៅនៃឆ្នាំ១៩៥៧ ប្រទេសកម្ពុជា បានស្ថិតនៅ ចំពោះមុខ នៃការបង្កបង្កើតហេតុដ៏ចំហ ពីពួកសត្រូវនៃនយោបាយ អព្យាក្រឹត គឺម្ខាងមានពួកបក្សសម្ពន្ធ សេ.អា.តូ ហើយម្ខាងទៀត មានពួកប្រតិកិរិយា ខាងក្នុងប្រទេសដែលតំណាងឱ្យបក្ខពួក ខាងស្តាំនៃអង្គការ “ សង្គម ” និងបក្សប្រជាធិបតយ្យ។ ស្ថានភាព នយោបាយកាន់តែតានតឹង បានតម្រូវឱ្យរដ្ឋាភិបាលបិទការផ្សាយ កាសែតប្រជាធិបតេយ្យ ដែលជាអង្គការសោរព័ត៌មានដ៏សំខាន់ នៃបក្សប្រជាធិបតេយ្យ។ នៅខែសីហា ឆ្នាំ១៩៥៧ អ្នកដឹកនាំ អង្គការ “ សង្គម ” បានទាមទារដល់អង្គការដឹកនាំបក្សប្រជា ធិបតេយ្យឱ្យបញ្ឈប់សកម្មភាពប្រឆាំងរបស់ខ្លួន ព្រមទាំងធ្វើ សំណើឱ្យសមាជិកនានា របស់បក្សនេះចូលមករួបរួមក្នុងចលនា “ សង្គមជាតិ ” នៅលើមូលដ្ឋាន នៃកម្មវិធីនយោបាយរបស់អង្គការ “ សង្គម ”។ ស្របតាមការទាមទារនេះ សមាជិកមួយភាគធំរបស់ បក្សប្រជាធិបតេយ្យ បានចូលមកបម្រើការក្នុងជួររបស់អង្គការ

“ សង្គម ” ហើយនៅទីបំផុត បក្សនេះក៏លែងមានជីវិតតទៅទៀត តាំងពីពេលនោះមក។

នៅក្នុងលក្ខខណ្ឌ នៃការលំរលើងនៃបក្សប្រជាធិបតេយ្យ កម្លាំងប្រឆាំងជាតិត្រូវបានបង្ខំចិត្តនៅស្ងប់ស្ងៀមមួយរយៈពេល ហើយបញ្ឈប់កិច្ចការប្រឆាំងចំហមុខ របស់ខ្លួនចំពោះបញ្ហាសំខាន់ៗដែលទាក់ទងនឹងនយោបាយអព្យាក្រឹត។ នៅខែកញ្ញា ឆ្នាំ១៩៥៧ រដ្ឋសភាបានធ្វើសេចក្ដីអនុម័ត លើសេចក្ដីប្រកាសសុច្ឆន្ទៈស្ដីអំពីអព្យាក្រឹតភាពរបស់ប្រទេស ដែលទុកដូចជាច្បាប់ទម្លាប់នៃមាគ៌ានយោបាយអព្យាក្រឹត នៅក្នុងនយោបាយក្រៅប្រទេសរបស់ប្រទេសកម្ពុជា គឺជាច្បាប់ដែលហាមឃាត់ មិនឱ្យប្រទេសចូលរួមទៅក្នុងបក្សសម្ពន្ធនយោបាយ និងយោធាណាមួយឡើយ។ នៅក្នុងសេចក្ដីប្រកាសសុច្ឆន្ទៈអំពីអព្យាក្រឹតភាពមានគូសបញ្ជាក់ថា ប្រទេសកម្ពុជា មិនប្រើកម្លាំងអាវុធក្នុងការដោះស្រាយទំនាស់ជាមួយប្រទេសឯទៀត នៅក្នុងនយោបាយក្រៅប្រទេសរបស់ខ្លួន ក៏ប៉ុន្តែ ល្ពឹកណាមានការគំរាមកំហែងដោយការវាយលុកដោយយោធានោះ ប្រទេសកម្ពុជា នឹងប្រើប្រសិទ្ធិរបស់ខ្លួនដើម្បីការពារអធិបតេយ្យភាព របស់ប្រទេសដោយជំនួយអាវុធ ហើយនិងការប្រកាសសុំជំនួយដល់អង្គការសហប្រជាជាតិ និងដល់ប្រទេសជាមិត្តណាមួយទៀត។

ដោយមានបំណងពង្រឹងជ័យជម្នះ ខាងនយោបាយ អ្នកដឹកនាំអង្គការសង្គមបានធ្វើសេចក្ដីសម្រេច រំលាយរដ្ឋសភាមុនការបញ្ចប់នីតិកាល ហើយបានរៀបចំការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រជាថ្មី នៅខែមីនា ឆ្នាំ១៩៥៨។

. នៅឆ្នាំ១៩៥៨ សម័យឃោសនាបោះឆ្នោតរបស់អង្គការ " សង្គម " បានប្រព្រឹត្តទៅក្រោមពាក្យស្លោក នៃការពង្រឹងឯកភាពថា៖ " ជាតិ សាសនា ព្រះមហាក្សត្រ "។ ក្រៅពីអង្គការ " សង្គម " មានតែបក្សនយោបាយមួយប៉ុណ្ណោះ ដែលចូលរួមក្នុងការឃោសនាបោះឆ្នោតនៅពេលនោះ គឺក្រុម " ប្រជាជន "។ ស្ថានភាពរបស់ក្រុម " ប្រជាជន " នៅឆ្នាំ១៩៥៨ ក៏ដូចជាសម័យកាលមុនៗ គឺស្ថិតនៅលើគោលដំហរ នៃការពង្រឹងជួររបស់កម្លាំងប្រឆាំងចក្រភពត្តិនិយម ដើម្បីការពារអធិបតេយ្យភាព នៃប្រទេសកម្ពុជា ព្រមទាំងនយោបាយអព្យាក្រឹតក្រៅប្រទេសរបស់ខ្លួន។ ជាមួយនឹងការឃោសនានេះ ក្រុម " ប្រជាជន " បានគូសបញ្ជាក់ជាពិសេសនូវការបំបាត់សំណល់របបសក្តិភូមិ អាណានិគមនៅក្នុងវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច។ ដោយយោងទៅតាមស្ថានភាពនយោបាយពិសេសនៅក្នុងប្រទេស ក្រុម " ប្រជាជន " បានតែងតាំងបេក្ខជន របស់ខ្លួនតែក្នុងមណ្ឌលបោះឆ្នោតនៅ៥កន្លែងប៉ុណ្ណោះ។ នៅក្នុងមណ្ឌលបោះឆ្នោតទាំងនេះ ការឃោសនានយោបាយមានលក្ខណៈមិនស្មើភាពគ្នាខ្លាំង ហើយដោយគ្មានបំណងបំបាក់បំបែកឯកភាពជាតិ ក្រុម " ប្រជាជន " បានកម្រិតការឃោសនាប្រឆាំងអង្គការ " សង្គម " តែចំពោះនយោបាយក្នុងប្រទេសខ្លះៗប៉ុណ្ណោះ។

ជាលទ្ធផល ការបោះឆ្នោតនៅឆ្នាំ១៩៥៨ បានផ្តល់ឱ្យបេក្ខជនរបស់អង្គការ " សង្គម " ទទួលតំណែងទាំងអស់នៅក្នុងរដ្ឋសភាជាតិ សាជាថ្មី។

បរាជ័យរបស់បក្ខពួកខាងស្តាំនៅឆ្នាំ១៩៥៧ បានបង្ខំឱ្យពួកប្រតិកិរិយា ក្នុងប្រទេសផ្លាស់ប្តូរយុទ្ធសាស្ត្រពីវិធី នៃការប្រឆាំង

តាមផ្លូវច្បាប់នៅក្នុងរដ្ឋធម្មនុញ្ញ មកកាន់វិធីប្រឆាំងតាមរបៀបស្ងាត់កំបាំង តាមភេរវកម្ម និងតាមសកម្មភាពឃុបឃិតគំនិតក្បត់។ បក្សពួកប្រឆាំងដោយពុំមានកម្លាំងគ្រប់គ្រាន់ បានរំពឹងទៅលើការគាំទ្រដ៏ត្រង់ៗខាងយោធា និងហិរញ្ញវត្ថុពីសំណាក់បក្សសម្ពន្ធសេ.អា.តូ។ យុទ្ធសាស្ត្រនៃការតស៊ូរបស់បក្សពួកខាងស្តាំបែបនេះ បានទទួលសេចក្តីយល់ព្រមពី ទីក្រុងវ៉ាស៊ីនតោន ដែលបានសម្រេចបញ្ចេញឥទ្ធិពល របស់ខ្លួនមកលើប្រទេសកម្ពុជា តាមមាគ៌ានៃសកម្មភាពភេរវកម្មរបស់មជ្ឈដ្ឋានតំណាងកម្លាំងប្រឆាំងក្នុងស្រុក និងតាមការបង្កើនការកៀបសង្កត់ខាងយោធាពីសំណាក់ប្រទេសថៃឡង់ និងវៀតណាមខាងត្បូង។

ក្នុងការបំភិតបំភ័យប្រទេសកម្ពុជា ដោយការគំរាមកំហែងខាងយោធា រដ្ឋការវៀតណាមខាងត្បូង បានចាប់ផ្តើមពង្រីកសំណង់មូលដ្ឋានសឹកនៅតំបន់ព្រំប្រទល់នានានៅឆ្នាំ១៩៥៨។ នៅខែកក្កដា ពួកវាបានធ្វើការបង្កបង្កើតហេតុខាងយោធាដ៏ធ្ងន់ធ្ងរនៅក្នុងខេត្តស្ទឹងត្រែង ដែលនៅក្នុងនេះ មានទាហានចំនួនបីពាន់នាក់ បានចូលរួមធ្វើការវាយលុករំលោភលើទឹកដីកម្ពុជា។ ចាប់តាំងពីខែមករា រហូតដល់ខែមិថុនា ឆ្នាំ១៩៥៨ ទាហានរបស់រដ្ឋការវៀតណាមខាងត្បូង បានធ្វើការឈ្លានពានលើទឹកដីព្រំប្រទល់កម្ពុជា រហូតដល់២៩ដង។

នៅតាមព្រំប្រទល់ជាមួយប្រទេសថៃឡង់ ក៏មានអំពើឈ្លានពានដោយយោធាដូចគ្នាដែរ។ គ្រាន់តែចាប់តាំងពីខែមីនា រហូតដល់ខែឧសភា ឆ្នាំ១៩៥៨ ទាហានរបស់រដ្ឋការថៃឡង់ បានរំលោភលើទឹកដីព្រំប្រទល់របស់កម្ពុជា រហូតដល់៦ដង។ នៅក្នុងសារព័ត៌មានថៃឡង់ មានការសរសេរចុះផ្សាយការ

ទាមទារទឹកដី នៃខេត្តពីររបស់កម្ពុជា គឺខេត្តបាត់ដំបង និង សៀមរាប។ នៅរដូវក្តៅនៃឆ្នាំ១៩៥៨ រដ្ឋាភិបាលប្រទេសកម្ពុជា បានឡើងសំណើឱ្យចាប់ផ្តើមធ្វើការចរចាទ្វេភាគី ជាមួយទីក្រុង បាកក និងព្រៃនគរ ក្នុងគោលបំណង ដើម្បីរៀបចំការទាក់ទង រវាងគ្នានឹងគ្នា។ នៅដើមខែកក្កដា រដ្ឋាភិបាលនៃប្រទេសកម្ពុជា បានធ្វើសេចក្តីអញ្ជើញជាផ្លូវការដល់ ង៉ូ ឌិញយៀម ឱ្យមកទស្សនា ទីក្រុងភ្នំពេញ។ នៅខែដដែល នរោត្តម សីហនុ បានទៅទស្សនា ទីក្រុងបាងកក ក៏ប៉ុន្តែ ការសន្មតធ្វើការចរចាគ្នារវាងភាគីកម្ពុជា និងថៃឡង់ ដែលនឹងត្រូវធ្វើឡើងនៅខែសីហា ត្រូវបានផ្អាក ទៅវិញ ដោយការប្រឆាំងរបស់មជ្ឈដ្ឋានយោធានិយមថៃឡង់ ដែលបានបង្កើតបាតុកម្មប្រឆាំងនឹងទស្សនកិច្ចនៃគណៈប្រតិភូ រដ្ឋាភិបាលកម្ពុជា នៅទីក្រុងបាងកក។ ដោយឆ្លើយតបនឹងការ បង្កបង្កើតហេតុនេះ នៅខែវិច្ឆិកា ឆ្នាំ១៩៥៨ ប្រទេសកម្ពុជា ត្រូវ បានបង្ខំចិត្តបញ្ឈប់ ការទាក់ទងខាងផ្លូវទូតជាបណ្តោះអាសន្ន ជាមួយប្រទេសថៃឡង់ ហើយបានកោះហៅឯកអគ្គរាជទូត របស់ខ្លួនឱ្យមកទីក្រុងភ្នំពេញ វិញ។ កាលនោះ រដ្ឋការថៃឡង់ បានបិទព្រំប្រទល់ជាមួយប្រទេសកម្ពុជា ហើយបានប្រកាស ភាពអាសន្ននៅក្នុងខេត្តទាំងប្រាំមួយ នៃប្រទេសរបស់ខ្លួន។ នៅពេលជាមួយគ្នា រដ្ឋការព្រៃនគរ បានបិទព្រំប្រទល់ខាងត្បូង ជាមួយប្រទេសកម្ពុជា។

ក៏ប៉ុន្តែ នយោបាយកៀបសង្កត់មកលើប្រទេសកម្ពុជា នារដូវភ្លៀងឆ្នាំ១៩៥៨ ពុំបានផ្តល់លទ្ធផលអ្វីធំដុំដល់ពួកវា ហើយការគន់គូររបស់ទីក្រុងវ៉ាស៊ីនតោន ដើម្បីបំភិតបំភ័យមតិ មហាជនក្នុងគោលបំណង ធ្វើឱ្យមានភាពច្របូកច្របល់ខាង

នយោបាយនៅក្នុងប្រទេស ពុំបានសម្រេចផលឡើយ។ នៅខែធ្នូ ឆ្នាំ១៩៥៨ រដ្ឋាភិបាលប្រទេសថៃឡង់ដ៍ បានយល់ព្រមធ្វើការដោះស្រាយវិបត្តិជាមួយប្រទេសកម្ពុជា តាមរយៈអាជ្ញាកណ្ដាលនៃអង្គការនានារបស់អង្គការសហប្រជាជាតិ។

ពេលវេលាដ៏សុខសាន្តយ៉ាងខ្លី ដែលកើតមានឡើងនៅតំបន់ព្រំប្រទល់នៃប្រទេស នៅចុងខែធ្នូ ឆ្នាំ១៩៥៨ គឺជាពេលស្ងប់ស្ងៀម ដែលនឹងមានការចាប់ផ្ដើមបង្កបង្កើតហេតុរបស់ពួកចក្រពត្តិក្នុងការរៀបចំអំពើឃុបឃិតគំនិតក្បត់ ប្រឆាំងរដ្ឋាភិបាលនៅប្រទេសកម្ពុជា។ ពួកវាបានទាក់ទាញអ្នកនយោបាយដែលធ្លាក់ពីតំណែងរបស់ខ្លួន មាន សឺង - ង៉ុកថាញ់ និងសម - សារី ព្រមទាំងអតីតអ្នកដឹកនាំក្រុមនយោបាយនៅរដ្ឋសភាខ្លះ ដែលបានបាត់តំណែងរបស់ខ្លួន នាសម័យបោះឆ្នោតនៅឆ្នាំ១៩៥៨ ឱ្យពួកនេះចូលរួមក្នុងអំពើឃុបឃិតគំនិតក្បត់។ បន្ទាប់ពីការរត់ភៀសខ្លួនពីប្រទេសកម្ពុជា សឺង - ង៉ុកថាញ់ បានចាប់ផ្ដើមបង្កើតចលនាយោធាមួយ ឈ្មោះថា “ ខ្មែរសេរី ” នៅលើទឹកដីប្រទេសថៃឡង់ដ៍ ហើយចលនានេះបានថ្លែងប្រកាសគោលបំណងរបស់ខ្លួនក្នុងការដណ្ដើមអំណាចនយោបាយ នៅប្រទេសកម្ពុជា ដើម្បីផ្លាស់ប្ដូរមាគ៌ានយោបាយផ្ទៃក្នុង និងក្រៅប្រទេសនៃប្រទេសនេះ។ ដោយការប្រើពាក្យស្លោកប្រឆាំងកុម្មុយនិស្តនិយម សឺង - ង៉ុកថាញ់ និងបក្សពួករបស់ខ្លួន បានធ្វើការប្រឆាំងនឹងការពង្រីកទំនាក់ទំនងនយោបាយរបស់ប្រទេសកម្ពុជា ជាមួយប្រទេសសង្គមនិយម បានសេចក្ដីថា ពួកវាបានប្រឆាំងជាផ្លូវការនឹងនយោបាយអព្យាក្រឹតរបស់ប្រទេស។

ក្រុមពួកធ្វើភេរវកម្មនៅក្នុងប្រទេសខ្លះ ដែលនៅឆ្នាំ១៩៥៨ ស្ថិតនៅក្រោមបញ្ជារបស់ សម - សារី ក៏បានប្រកាន់ឥរិយាបថប្រឆាំងកុម្មុយនិស្តនិយមដូចគ្នាដែរ។ រហូតដល់ឆ្នាំ១៩៥៦ សម - សារី បានកាន់តំណែងជានាយករដ្ឋមន្ត្រីរង តមក បានធ្វើជាឯកអគ្គរាជទូតប្រទេសកម្ពុជា ប្រចាំទីក្រុងឡុង។ សម សារី បានប្រើស្ថានភាពរបស់ខ្លួន ដើម្បីធ្វើសកម្មភាពបំបាក់បំបែកផ្ទៃក្នុងរបស់រដ្ឋាភិបាល ដោយមានបំណងចង់ឱ្យប្រទេសកម្ពុជាចូលក្នុងបក្សសម្ពន្ធយោធាចក្រពត្តិនិយម។

នៅឆ្នាំ១៩៥៨ សម - សារី និងសឹង-ង៉ុកថាញ់ បានដឹកនាំអំពើឃុបឃិតគំនិតក្បត់ ដើម្បីរំលំរដ្ឋាភិបាលកម្ពុជា ហើយបញ្ចូលប្រទេសនេះទៅក្នុងបក្សសម្ពន្ធសេ.អា.តូ។ អ្នកដើរតួដ៏សំខាន់មួយនៅក្នុងការរៀបចំអំពើក្បត់នេះ គឺ ដាប - ឈួន ដែលនៅពេលនោះ ធ្វើជាចៅហ្វាយខេត្តយោធានៅខេត្តសៀមរាប។

តាមសេចក្តីបញ្ជាក់ របស់សារព័ត៌មានប្រទេសកម្ពុជា ផែនការច្បាស់លាស់ នៃអំពើក្បត់នេះរៀបចំឡើងនៅទីក្រុងបាងកក ដោយមានការចូលរួបរួមនៃអ្នកតំណាងជាផ្លូវការរបស់សហរដ្ឋអាមេរិក ប្រទេសថៃឡង់ដ៍ និងវៀតណាមខាងត្បូង។ ផែនការនេះ គ្រោងរៀបចំបង្កើតឱ្យមានស្ថានភាពនយោបាយប្របូកប្រប ល់នៅប្រទេសកម្ពុជា នៅដើមឆ្នាំ១៩៥៩ ដែលអាចបង្កើតជាមូលដ្ឋាន នៃការធ្វើរដ្ឋប្រហារដោយយោធានៅក្នុងខេត្តសៀមរាប ដោយមានការវាយប្រហាររបស់កងកម្លាំង " ខ្មែរសេរី " ពីប្រទេសថៃឡង់ដ៍។ នៅពេលជាមួយគ្នានោះ គំរោងនៃ " ផែនការទីក្រុងបាងកក " បញ្ជាក់នូវការវាយយកខេត្តនានានៅព្រំប្រទល់ប្រទេសកម្ពុជា និងការបង្កើតរដ្ឋាភិបាល

បណ្តោះអាសន្នលើដែនដីនេះដែលមាន សឺង-ង៉ុកថាញ់, សម - សារី និងដាប - ឈួន ជាអ្នកដឹកនាំ។

ការរៀបចំអំពើក្បត់ត្រូវបានកម្ទេចនៅខែមករា ឆ្នាំ១៩៥៩ នៅពេលដែលមានចេញសេចក្តីបញ្ជាឱ្យចាប់ឃុំឃាំង សម - សារី។

នៅខែកុម្ភៈ ឆ្នាំ១៩៥៩ ទីកន្លែងនៃការរៀបចំអំពើក្បត់ និងការរៀបចំរដ្ឋប្រហារដោយយោធានៅខេត្តសៀមរាប ដែលមាន ដាប - ឈួន ជាអ្នកដឹកនាំក៏ត្រូវបានកម្ទេចដែរ។ នៅទីបញ្ជាការរបស់ ដាប - ឈួន គេចាប់បានឃ្លាំងអាវុធ គ្រាប់រំសេវអាមេរិក ព្រមទាំងឯកសារនានា ដែលបញ្ជាក់អំពីអំពើជ្រៀតជ្រែកបរទេសមកលើកិច្ចការផ្ទៃក្នុងប្រទេសកម្ពុជា ហើយនៅទីនោះ គេចាប់បានទាំងនាយទាហានវៀតណាមខាងត្បូង ពីរនាក់ ដែលធ្វើការទាក់ទងខាងទូរលេខឆ្លើយឆ្លង។

អំពើក្បត់របស់ សម - សារី និងបក្សពួករបស់វាមានការទាក់ទងជាមួយផែនការរបស់បក្សសម្ពន្ធសេ.អា.តូ ដើម្បីបង្កើតប្រព័ន្ធប្រទេស “ រណសិរ្សប្រឆាំងកុម្មុយនិស្តនិយម ” ដែលមានប្រទេសសៀម កម្ពុជា វៀតណាមខាងត្បូង ហ្វីលីពីន ចិនតៃវ៉ាន់ និងកូរ៉េខាងត្បូង។

ទោះបីបរាជ័យនៃអំពើក្បត់របស់សម - សារី និង សឺង - ង៉ុកថាញ់ ក៏ដោយ ក៏ស្ថានភាពនយោបាយនៅក្នុងប្រទេសមានសភាពកាន់តែតានតឹងដែលកើតឡើង ដោយព្រឹត្តិការណ៍ទាក់ទងទៅនឹងសោយទិវង្គតរបស់មហាក្សត្រសុរាម្រឹត នៅរដូវរំហើយនៃឆ្នាំ១៩៦០។ ការសោយទិវង្គតរបស់មហាក្សត្រ បានបង្កើតឱ្យមានបញ្ហាដ៏ស្មុគស្មាញ ស្តីអំពីការជ្រើសរើសបេក្ខជនបន្តរាជសម្បត្តិ។ ស្របតាមរដ្ឋធម្មនុញ្ញកម្ពុជា នាឆ្នាំ១៩៤៧ មហាក្សត្រ

ថ្មីត្រូវជ្រើសរើសឡើងដោយក្រុមប្រឹក្សារាជបល្ល័ង្ក ពីបណ្ដាអ្នកបន្តរាជវង្សានុវង្សជាច្រើន។ វត្តមាននៃសមាជិករាជវង្សានុវង្សនានាដែលអាចបន្តរាជ្យបាន បានបង្កើតជាបញ្ហានយោបាយដ៏ស្មុគស្មាញ ហើយការដោះស្រាយអាចបង្កើតឱ្យមានការខ្វែងគំនិតគ្នារវាងក្រុមរាជវង្សានុវង្សនានា នៃរាជវាំងប្រទេសកម្ពុជា។

មជ្ឈដ្ឋានប្រតិកិរិយា ខាងក្នុងប្រទេសបានប្រើប្រាស់ពេលវេលានៃការសោយទិវង្គតរបស់មហាក្សត្រសុរាម្រឹត ដើម្បីបញ្ជេះទំនាស់នយោបាយ ហើយបង្កើតជាទំនាស់នៅក្នុង “ រាជវង្សានុវង្ស ” ក្នុងគោលបំណងនឹងតែងតាំងបេក្ខជននៃរាជបល្ល័ង្ករបស់ខ្លួន។ នរោត្តម សីហនុ បានផ្អាកការជ្រើសរើសមហាក្សត្រថ្មីដោយបង្កើតក្រុមប្រឹក្សារបស់ឧបយុវរាជ្យ ដោយមានតំណែងជាប្រមុខរដ្ឋ។

ព្រឹត្តិការណ៍ទាក់ទងនឹងការសោយទិវង្គតរបស់មហាក្សត្រសុរាម្រឹត បានធ្វើឱ្យសកម្មភាពចក្រពត្តិនិយម នៅក្នុងប្រទេសកើតមានឡើង ហើយបានបង្កើតជាសន្ទុះ ដល់ការចាប់ផ្ដើមការឃោសនាប្រឆាំងប្រទេសកម្ពុជា នៅប្រទេសថៃឡង់ដ៍ និងវៀតណាមខាងត្បូង។ នៅខែមេសា ឆ្នាំ១៩៦០ ការបង្កបង្កើតហេតុដោយឃោជាមកលើទឹកដីប្រទេសកម្ពុជា ក៏កើតមានឡើងសាជាថ្មី។

នៅថ្ងៃទី៥ ខែមិថុនា ឆ្នាំ១៩៦០ នៅប្រទេសកម្ពុជា មានធ្វើប្រជាមតិ ទាក់ទងនឹងបញ្ហា ស្ដីអំពីមាគ៌ានយោបាយក្រៅប្រទេស។ សំឡេងភាគច្រើនដ៏លើសលុបនៅក្នុងប្រជាមតិបានសំដែងដល់ការគាំទ្រនយោបាយអព្យាក្រឹតភាព។

សកម្មភាព បំបាក់បំបែកមិនចេះចប់ របស់បក្សសម្ពន្ធយោធា សេ.អា.តូ បានបង្ខំឱ្យអ្នកដឹកនាំអង្គការ “ សង្គម ” ចាត់វិធានការថ្មីៗតម្រង់ទៅរកការរៀបចំ ទំនាក់ទំនងដ៏ជិតស្និទ្ធរវាងប្រទេសកម្ពុជា និងប្រទេសសង្គមនិយម។ នៅខែវិច្ឆិកា និងខែធ្នូនាឆ្នាំ១៩៦០ គណៈប្រតិភូរដ្ឋាភិបាលប្រទេសកម្ពុជា បានទៅធ្វើទស្សនកិច្ចជាផ្លូវការនៅទីក្រុងមូស្គូ ទីក្រុងប្រាគ និងទីក្រុងប៉េកាំង។ នៅឱកាសនៃទស្សនកិច្ចទាំងនេះមានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងសំខាន់ៗមួយចំនួន ដែលបញ្ជាក់បំណងពង្រីកទំនាក់ទំនងនយោបាយ និងសេដ្ឋកិច្ចនៃប្រទេសកម្ពុជា ជាមួយប្រទេសសង្គមនិយមនានា។ នៅក្នុងកិច្ចព្រមព្រៀងទាំងនេះមានសេចក្ដីគូសបញ្ជាក់អំពីការប្រុងប្រៀបខ្លួន របស់ប្រទេសសង្គមនិយមទាំងឡាយ ដើម្បីពង្រីកជំនួយសេដ្ឋកិច្ចដល់ប្រទេសកម្ពុជា និងមានការបញ្ជាក់អំពីការគាំទ្រខាងផ្លូវចិត្តដល់ប្រជាជនកម្ពុជាក្នុងការតស៊ូរបស់ខ្លួនដើម្បីការពារអធិបតេយ្យភាពជាតិ។

ការគាំទ្រ របស់ប្រទេសសង្គមនិយមមានអត្ថន័យសំខាន់សម្រាប់ប្រទេសកម្ពុជា នាឆ្នាំ១៩៦១ - ១៩៦២ នៅពេលដែលសហរដ្ឋអាមេរិក បានបង្កើនសកម្មភាពនយោបាយវាតទីនិយមខាងយោធានៅវៀតណាមខាងត្បូង និងឡាវ។ ក្នុងការប្រើប្រាស់បណ្ដាមូលដ្ឋានប្រតិកិរិយានៅវៀតណាមខាងត្បូង និងថៃឡង់ សហរដ្ឋអាមេរិក បានបន្តបង្កើតឱ្យមានវិបត្តិនយោបាយ និងយោធាយ៉ាងខ្លាំងជាមួយប្រទេសកម្ពុជា។ ហេតុដូច្នេះហើយ បានជានៅឆ្នាំ១៩៦១ ក្នុងកលល្បិចនៃការកៀបសង្កត់ជាបន្តបន្ទាប់មកលើប្រទេសកម្ពុជា ពួកវាបានប្រើប្រាស់បញ្ហា ស្ដីអំពីទឹកដីព្រំប្រទល់នៃព្រះវិហារ ដែលជាបុរាណវត្ថុខាងប្រវត្តិសាស្ត្រ

និងសាសនារបស់ប្រទេសកម្ពុជា។ តាំងពីឆ្នាំ១៩៥៤ រដ្ឋការថៃឡុងដ៍ បានចូលកាន់កាប់ទឹកដីព្រះវិហារ ដោយខុសច្បាប់ ហើយទោះមានសេចក្តីប្រឆាំងពីសំណាក់រដ្ឋាភិបាលកម្ពុជា ក៏ពួកនេះនៅតែបន្តការកាន់កាប់របស់ខ្លួន នៅទីនេះតទៅទៀត។ សកម្មភាពបែបនេះរបស់ថៃឡុងដ៍ មានគោលដៅដ៏វែងឆ្ងាយ។ ប្រសិនបើប្រទេសកម្ពុជា សម្របសម្រួលខ្លួនតាមការកាន់កាប់ទឹកដីនៅតំបន់នេះ នោះនឹងមានផលវិបាកអាក្រក់សម្រាប់ការដោះស្រាយទំនាស់ទឹកដីដទៃទៀត ដែលស្ថិតនៅតំបន់ប៉ែកខាងលិចនៃប្រទេស។ ដោយយោងទៅលើកាលៈទេសៈបែបនេះ រដ្ឋាភិបាលប្រទេសកម្ពុជា បានបន្តការទាមទារឱ្យរៀបចំសិទ្ធិត្រឹមត្រូវតាមច្បាប់របស់ខ្លួនឡើងវិញនៅលើទឹកដីព្រះវិហារ។ ក្នុងការតស៊ូប្រឆាំង នយោបាយឈ្លានពានទឹកដី របស់ប្រទេសថៃឡុងដ៍ រដ្ឋាភិបាលប្រទេសកម្ពុជា បានសម្រេចចិត្តផ្តាច់ការទាក់ទងតាមផ្លូវការទូតជាថ្មីម្តងទៀតជាមួយទីក្រុងបាងកក នៅខែតុលា ឆ្នាំ១៩៦១។

នៅខែមិថុនា ឆ្នាំ១៩៦២ បន្ទាប់ពីការសិក្សាពិនិត្យទំនាស់កម្ពុជា - ថៃឡុងដ៍ ដ៏យូរមក តុលាការអន្តរជាតិនៅទីក្រុងឡាអេ បានសម្រេចគាំទ្រដល់សេចក្តីទាមទាររបស់ប្រទេសកម្ពុជា ក្នុងការផ្តល់ទឹកដីព្រះវិហារ មកឱ្យមាតុភូមិកម្ពុជា វិញ។ រដ្ឋការថៃឡុងដ៍ ត្រូវបានបង្ខំចិត្តដកកងទ័ពរបស់ខ្លួនថយពីតំបន់នេះ។ ក៏ប៉ុន្តែ នៅខែសីហា នៃឆ្នាំដដែល កងវរសេនាធំ នៃអាវុធហត្ថថៃឡុងដ៍ ពីរកង បានលុកលុយចូលទឹកដីខេត្តបាត់ដំបង ហើយបានវាយលុកមកលើប៉ុស្តិ៍ត្រួតពិនិត្យរបស់ប្រទេសកម្ពុជា។ ពីរថ្ងៃកន្លងមក កងវរសេនាតូចមួយទៀតដែលមានទាហាន និង

នាយទាហានចំនួន៤០០នាក់ ដឹកនាំដោយពួកបង្ហាត់ហ្វឹកហ្វឺនខាងយោធាអាមេរិក បានវាយដណ្ដើមយកជនបទហុត - លេខ នៅក្នុងខេត្តកោះកុង។ចំនួនមួយសប្ដាហ៍ក្រោយមក កងទ័ពវៀតណាមខាងត្បូង បានវាយលុកលើព្រំប្រទល់ប្រទេសកម្ពុជា ពីរដង ហើយយន្តហោះរបស់ពួកនេះ បានហោះរំលោភលើព្រំដែនអាកាសប្រទេសកម្ពុជា ជាច្រើនដង។ នៅក្នុងអំឡុងពេលចាប់ពីខែមករាដល់ខែសីហា ឆ្នាំ១៩៦២ យន្តហោះយោធាថៃឡង់ និងវៀតណាមខាងត្បូង បានហោះរំលោភលើដែនអាកាសកម្ពុជាចំនួន១៩១ដង។ នៅចុងខែតុលា ឆ្នាំ១៩៦២ យន្តហោះយោធាវៀតណាមខាងត្បូង បានហោះទម្លាក់គ្រាប់បែកលើភូមិខ្មែរមួយនៅក្នុងខេត្តរតនគិរី ហើយការបង្កបង្កើតហេតុដោយយោធាក៏បេះតែបន្តតទៅទៀត។

# ជំពូកទី៣

## លក្ខណៈពិសេស នៃការលូតលាស់ខាងសេដ្ឋកិច្ច និងសង្គមកិច្ច នៃប្រទេសកម្ពុជា

នយោបាយ របស់មជ្ឈដ្ឋានកាន់កាប់អំណាចប្រទេសកម្ពុជា ដឹកនាំដោយនរោត្តម សីហនុ បានបម្រើជាពិសេសដល់ផលប្រយោជន៍របស់វណ្ណៈគហបតីជាតិ ដែលកាន់តែលូតលាស់ខ្លាំងឡើងនៅក្នុងប្រទេស។

នៅសម័យកាលនៃភាគខាងចុងនៃទសវត្សរ៍ទី៥ និងទី៦ នៅប្រទេសកម្ពុជា មានការសង្កេតឃើញនូវការលូតលាស់របស់មូលធននិយមរដ្ឋ ដែលបានពឹងផ្អែកទៅលើវិស័យពីរបែបរបស់សេដ្ឋកិច្ចជាតិ គឺ វិស័យរដ្ឋ និងវិស័យមូលធននិយមឯកជន។ គោលដៅដ៏សំខាន់នៃការលូតលាស់វិស័យសេដ្ឋកិច្ចរដ្ឋ ស្ថិតនៅលើការបង្កលក្ខណៈខាងសេដ្ឋកិច្ចដ៏ប្រសើរ សម្រាប់ការពង្រីកវង្វង់នៃសកម្មភាពរបស់មូលធនឯកជននៅក្នុងប្រទេស។

បន្ទាប់ពីបានពង្រឹងអធិបតេយ្យភាពជាតិ នៅប្រទេសកម្ពុជា មក ការពង្រីកវិស័យឧស្សាហកម្ម នៃរោងផលិតបានប្រព្រឹត្តទៅបន្តិចម្តងៗ។ រោងឧស្សាហកម្មចំនួនប្រហែល១៨ ឬ២០បានដើរតួនាទីដ៏សំខាន់ នៅក្នុងផលិតកម្មឧស្សាហកម្ម។ រោងឧស្សាហកម្មទាំងនេះ មួយចំនួនត្រូវបានកសាងឡើងដោយសហការខាងសេដ្ឋកិច្ច និងបច្ចេកទេសរបស់ប្រទេសសង្គមនិយមនានា។ នៅពេលជាមួយគ្នា ឧស្សាហកម្មតូចតាច និងផលិតកម្មនៃរបរសិប្បកម្មក៏បានលូតលាស់ជាបន្តបន្ទាប់។

ក៏ប៉ុន្តែ ជាទូទៅ ស្ថិតិបញ្ជាក់ពីការលូតលាស់នៃផលិតកម្ម ឧស្សាហកម្ម បានស្ថិតនៅក្នុងស្ថានភាពទន់ទាបនៅឡើយ។ នៅឆ្នាំ១៩៦៧ នៅក្នុងវិស័យឧស្សាហកម្មទូទៅនៃផលិតកម្ម មានកម្រិតត្រឹម១២ភាគរយ បានសេចក្តីថា នៅមានសភាព ទាបជាងផលទុនជាតិ របស់ប្រទេសមួយចំនួនធំ នៅអាស៊ីភាគ អាគ្នេយ៍។

នៅសម័យកាលពាក់កណ្តាលនៃទសវត្សរ៍ទី៧ មូលធន បារាំង បានស្ថិតនៅជាមូលធនដ៏សំខាន់នៅក្នុងវិស័យសេដ្ឋកិច្ច របស់ប្រទេស។ ក្រុមហ៊ុនបារាំងទាំងឡាយ មានជាអាទិ៍គឺ “ ក្រុមហ៊ុនពាណិជ្ជកម្មកម្ពុជា ” បានផ្តាច់មុខផលិតកម្មកៅស៊ូ ដែលជាគ្រឿងនាំចេញមួយដ៏សំខាន់ជាងគេ នៅក្នុងវិស័យ សេដ្ឋកិច្ច។ តាមស្ថិតិនាឆ្នាំ១៩៦២ មូលធនបារាំង បានកាន់កាប់ ស្ថានភាព១ភាគ៣ នៃក្រុមហ៊ុនពាណិជ្ជកម្មនាំចេញទាំងអស់ នៅក្នុងប្រទេស។ ក្រុមហ៊ុនពាណិជ្ជកម្មធំៗឈ្មោះ “ឌុយម៉ារ៉េស្ត” “ ដឺនីសហ្វ្រែរ ” “ ឡាអាវរ៉េស ” បានប្រើប្រាស់មូលធននេះក្នុង ការនាំចេញកៅស៊ូ អង្ករ ម្រេច និងអីវ៉ាន់ដទៃទៀតមួយចំនួនធំ។

ប្រតិបត្តិការអាហរ័ណនីហរ័ណ នៃក្រុមហ៊ុនពាណិជ្ជកម្ម បារាំង បានប្រព្រឹត្តទៅតាមរយៈធនាគារបារាំង ចំនួន៣ គឺ “ធនាគារ នៃឥណ្ឌូចិន ” ( បង់ឌឺឡាំងដូស៊ីន ) ធនាគារបារាំងចិន ( បង់ ហ្វ្រង់កូ - ស៊ីណូវ៉ា ) និងធនាគារ ដើម្បីពាណិជ្ជម្ម និងឧស្សាហកម្ម (បង់ ពួរឡឺ កុំមែរ និង ឡាំឌុស្រ្ទី ) គឺធនាគារទាំងនេះហើយ ដែល បានផ្តល់ឥណទានពាណិជ្ជកម្មមួយភាគ យ៉ាងសំខាន់នៅ ប្រទេសកម្ពុជា។

ចាប់តាំងពីឆ្នាំ១៩៥៦ រង្វង់នៃការប្រើប្រាស់ឥណទានខាងពាណិជ្ជកម្មក្រៅប្រទេសនៅប្រទេសកម្ពុជា បានទៅជាមូលដ្ឋាន នៃការប្រកួតប្រជែងគ្នាដ៏ស្វិតស្វាញរវាងមូលធនបារាំង និងមូលធនអាមេរិក អង់គ្លេស និងជប៉ុន។ ការជ្រួតជ្រាបនូវមូលធនខាងហិរញ្ញវត្ថុ និងពាណិជ្ជកម្មនៃសហរដ្ឋអាមេរិក និងប្រទេសមូលធននិយមដទៃទៀត ចូលមកក្នុងប្រទេសកម្ពុជា មានការទាក់ទងដ៏ជិតស្និទ្ធទៅនឹងការអនុវត្ត នូវកម្មវិធីជំនួយខាងសេដ្ឋកិច្ច និងយោធារបស់សហរដ្ឋអាមេរិក។

តាំងពីឆ្នាំ១៩៥៥ សាខានៃក្រុមហ៊ុនពាណិជ្ជកម្ម និងក្រុមហ៊ុនជានារ៉ាប់រងអាមេរិក នានា បានកកើតឡើងនៅប្រទេសកម្ពុជា។ ដើមទុនអាមេរិក បានចូលជ្រួតជ្រាបទៅក្នុងក្រុមហ៊ុនពាណិជ្ជម្មបារាំង ខ្លះៗ ហើយនៅពេលក្រោយបន្តិចមក សាខានៃក្រុមហ៊ុនជានារ៉ាប់រងអាមេរិក ដ៏សំខាន់ពីរ គឺ “ អាមេរិកាំងអាំងទែរណាស៊ីយ៉ូណាល់ ” និង “ ញូវហែមព្សូរ ” ឈ្មោះ “ អេស្សូ ” និង“ កាល់តិច ” បានដើរតួដ៏សំខាន់នៅក្នុងការលក់ប្រេងកាតនៅក្នុងប្រទេស ហើយក្រុមហ៊ុនទាំងពីរនេះបានទទួលបន្ទុកលើការនាំចូល៣៥% នៃប្រេងកាតដែលត្រូវនាំចូលមកក្នុងប្រទេសកម្ពុជា។

ក្រុមហ៊ុនប្រេងកាត ដែលជាគូប្រណាំងប្រជែងនឹងក្រុមហ៊ុនប្រេងកាតអាមេរិក គឺក្រុមហ៊ុនប្រេងកាតអង់គ្លេស - ហុល្លង់ ឈ្មោះ “ ហ្សែល ” ដែលទទួលបន្ទុកក្នុងការនាំចូលចំនួន៦០% នៃប្រេងកាតប្រើប្រាស់ក្នុងប្រទេសកម្ពុជា។

បន្ទាប់ពីការកកើតនៃក្រុមហ៊ុនពាណិជ្ជកម្មអង់គ្លេស នៅប្រទេសកម្ពុជា តមកទៀត ក៏មានការកកើតនៃក្រុមហ៊ុន

ពាណិជ្ជកម្មជប៉ុន ដែលបានធ្វើការត្រួតពិនិត្យលើការនាំចូលគ្រឿងតម្បាញទាំងឡាយ។ សកម្មភាពរបស់មូលធនអង់គ្លេស និងជប៉ុន បានរីកសាយទៅលើការប្រើប្រាស់ឥណទានសម្រាប់ពាណិជ្ជកម្ម ដោយមានការបង្កើតធនាគារអង់គ្លេសពីរ គឺធនាគារ " ឆាទែររិដ បង់ " និង" ហុងកុងអេនស៊ាំហៃ បង់ " និងធនាគារជប៉ុន មួយឈ្មោះ " បង់អុហ្វតូក្យូ " តាមព័ត៌មានចុះផ្សាយក្នុងកាសែតបរទេស ការនាំចូលទុនឯកជនរបស់សហរដ្ឋអាមេរិក អង់គ្លេស និងជប៉ុន មកក្នុងវិស័យឧស្សាហកម្មកម្ពុជាមានសភាពស្ពួចស្ដើង។ រហូតមកដល់ឆ្នាំ១៩៦៤ រង្វង់នៃសកម្មភាព ក្នុងការផ្ដល់ទុនឯកជនថ្មីៗពីបរទេស ស្ថិតនៅតែក្នុងសកម្មភាពពាណិជ្ជកម្មក្រៅប្រទេស និងក្នុងប្រព័ន្ធការផ្ដល់ឥណទាន នៃប្រទេសកម្ពុជា។

ម្យ៉ាងទៀត សកម្មភាពរបស់មូលធនបរទេសនៅប្រទេសកម្ពុជា មិនមែនកម្រិតតែក្នុងរង្វង់នៃសកម្មភាពឧស្សាហកម្ម និងពាណិជ្ជកម្មឯកជនទេ។ លក្ខណៈពិសេសខាងសេដ្ឋកិច្ច ព្រមទាំងលក្ខណៈនៃនយោបាយវាតទីនិយម របស់មូលធនផ្ដាច់មុខបរទេស ស្ថិតនៅលើហេតុថា នាឆ្នាំ១៩៥៥ - ១៩៦៣ រដ្ឋាភិបាលសហរដ្ឋអាមេរិក និងបារាំង បានផ្ដល់ឥណទានរដ្ឋដោយគ្មានសំណងវិញ ក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីជំនួយសេដ្ឋកិច្ច និងយោធារបស់ខ្លួន។ រដ្ឋាភិបាលប្រទេសជប៉ុន អូស្ត្រាលី និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ក៏បានចូលរួមក្នុងការអនុវត្តកម្មវិធីជំនួយសេដ្ឋកិច្ចនេះដែរ (ប៉ុន្តែ តាមទំហំដែលមានកម្រិតច្បាស់លាស់)។

ការផ្តល់ឥណទានរដ្ឋដល់ប្រទេសកម្ពុជា ដោយប្រទេសមូលធននិយមនានាបានធ្វើឡើងក្នុងក្របខ័ណ្ឌនៃការបម្រើផលប្រយោជន៍នយោបាយរបស់ខ្លួន គឺបំណងទប់ទល់ប្រទេសកម្ពុជាឱ្យស្ថិតក្នុងវង្វង់ នៃឥទ្ធិពលរបស់ប្រទេសជាមហាអំណាចចក្រពត្តិនិយម និងបំណងចង់ធ្វើឱ្យប្រទេសនេះទៅជាមូលដ្ឋានគាំទ្រមួយដ៏សំខាន់ដល់នយោបាយវាតទីនិយម របស់ខ្លួននៅឥណ្ឌូចិន។

នៅឆ្នាំ១៩៥៥ រាជរដ្ឋាភិបាលបានចុះហត្ថលេខាលើកិច្ចសន្យាស្តីអំពីជំនួយយោធាជាមួយសហរដ្ឋអាមេរិក ព្រមទាំងចុះហត្ថលេខាលើកិច្ចព្រមព្រៀង ស្តីអំពីសហប្រតិបត្តិការខាងពាណិជ្ជកម្ម និងបច្ចេកទេស ជាមួយប្រទេសបារាំង ហើយកិច្ចព្រមព្រៀងទាំងនេះ បានបង្កើតជាមូលដ្ឋានតាមផ្លូវច្បាប់សម្រាប់ការផ្តល់ហិរញ្ញវត្ថុ ជាមូលដ្ឋាននៅក្នុងក្របខ័ណ្ឌនៃជំនួយឥតសំណងពីសំណាក់ប្រទេសមូលធននិយម ដល់ប្រទេសកម្ពុជា។

ការផ្តល់ទុនរបស់សហរដ្ឋអាមេរិក ក្នុងការពង្រីកផលិតកម្មឧស្សាហកម្ម តាមពិតមានលក្ខណៈស្តួចស្តើង។ សហរដ្ឋអាមេរិកមិនបានព្រមព្រៀងកសាងសំណង់ឧស្សាហកម្មទេ ហើយការចែករំលែកទុនហិរញ្ញវត្ថុអាមេរិក ក្នុងផ្នែកសេដ្ឋកិច្ច និងជំនួយយោធាបានបព្រឹត្តទៅតាមរយៈនៃ “ មូលនិធិប្តូរប្រាក់ ” ដែលស្ថិតនៅក្រោមកិច្ចត្រួតត្រា របស់ស្ថានបេសកកម្មសេដ្ឋកិច្ចរបស់សហរដ្ឋអាមរិក នៅទីក្រុងភ្នំពេញ។ ស្ថានបេសកកម្មសេដ្ឋកិច្ចនេះបានចែករំលែករូបិយប័ណ្ណសម្រាប់ការនាំចូល រវាងបណ្តាពាណិជ្ជករ សហគ្រិននៃប្រទេសកម្ពុជា។ ក្នុងការចែករំលែក

រូបិយប័ណ្ណ ស្ថានបេសកកម្មអាមេរិក បានបញ្ជាក់អំពីការកម្រិត និងរបៀបរបបជាចាំបាច់នៃទំហំ និងអីវ៉ាន់នៃការនាំចូល។ ប្រាក់រៀលដែលជារូបិយប័ណ្ណក្នុងស្រុក ហើយត្រូវបានប្រើប្រាស់នៅក្នុងការលក់ដូរអីវ៉ាន់អាមេរិក នៅផ្សារក្នុងស្រុក ហើយត្រូវបានប្រើប្រាស់តាមរយៈមូលនិធិនៃការប្តូរប្រាក់ ដែលយកប្រាក់រៀលនេះ ទៅធ្វើការចំណាយដើម្បីសម្រេចកម្មវិធីជំនួយសេដ្ឋកិច្ច និងយោធារបស់សហរដ្ឋអាមេរិក នៅប្រទេសកម្ពុជា។ នៅក្នុងស្ថានភាពបែបនេះ រដ្ឋាភិបាលប្រទេសកម្ពុជា មិនអាចធ្វើការត្រួតពិនិត្យលើពាណិជ្ជកម្មនាំចូលឱ្យបានដិតដិត ហើយបានផ្តល់លទ្ធភាពដល់អាមេរិក ឱ្យមានឥទ្ធិពលលើនយោបាយហិរញ្ញវត្ថុនៃប្រទេសកម្ពុជា។

ការអនុវត្ត “ ជំនួយ ” អាមេរិក នៅប្រទេសកម្ពុជា បានផ្តល់លទ្ធភាពដ៏ទូលំទូលាយដល់ពួកពាណិជ្ជករ ដល់ពួកឈ្មួញកណ្តាល និងពួកនាហ្មឺននៅក្រសួងរដ្ឋបាលនានា ឱ្យពួកនេះទៅជាមនុស្សអ្នកមានបានជាងគេ។ នៅក្នុងរយៈពេលដ៏ខ្លី ក្រុមហ៊ុនជំនួញរាប់រយបានកើតមានឡើងនៅក្នុងប្រទេស គឺជាក្រុមហ៊ុនដែលទទួលបន្ទុកខាងការលក់ដូរទំនិញអាមេរិក នៅក្នុងប្រទេសតាមការដំឡើងតម្លៃ និងការវាយតម្លៃដោយកេងប្រវ័ញ្ចនៅទីផ្សារ។ ផលវិបាកនៃការលក់ដូរបែបនេះ បានបង្កើតឱ្យមានផ្សារងងឹត ដែលទៅជាមូលដ្ឋានដ៏សំខាន់នៃការកកើតស្រទាប់វណ្ណៈ “ នាយទុនកុំប្រាឌ័រថ្មី ” ដែលតម្រែតម្រង់សកម្មភាពរបស់ខ្លួនទាំងអស់ទៅលើសហរដ្ឋអាមេរិក។

ប្រភពមួយដ៏សំខាន់ៗ ដែលបណ្តាលឱ្យវណ្ណៈគហបតីក្នុងស្រុក ទៅជាវណ្ណៈអ្នកមានបានជាងគេ គឺមានរបៀបរបប

“ បម្រើកិច្ចការ ” ទាំងឡាយដល់សាខាសេដ្ឋកិច្ចរដ្ឋ ( ដូចជាការទទួលបន្ទុកខាងការដេញថ្លៃសម្រាប់បំពេញសំណង់ ឬការផ្គត់ផ្គង់គ្រឿងសង្ហារណៈ ការប្រើប្រាស់កម្លាំងកម្មករ ការផ្គត់ផ្គង់វត្ថុធាតុដើមនៅក្នុងស្រុកដល់រោងចក្រ សហគ្រាសរដ្ឋ ...។ល។ )។ ជាមួយនឹងកិច្ចការបែបនេះ គឺមានរបៀបផ្សេងៗ នៃការលួចបន្លំថវិកាចំណាយរបស់រដ្ឋ ព្រមទាំងការគែប្រវ័ញ្ចនៅក្នុងការប្រើប្រាស់រូបិយប័ណ្ណបរទេស។

ការចំណាយប្រាក់កាស របស់វណ្ណៈគហបតីនៅក្នុងប្រទេស នៅក្នុងវិស័យផលិតកម្មមានលក្ខណៈដ៏ស្ដួចស្ដើង ហើយយឺតយ៉ាវបំផុត។ នៅក្នុងលក្ខខណ្ឌនៃការរីកចម្រើនខាងវិស័យសេដ្ឋកិច្ចឯកជន មូលធននិយមបានប្រព្រឹត្តទៅនៅលើស្ថានភាពរអាក់រអួល មិនស្មើគ្នា ដោយហេតុថា វណ្ណៈគហបតីនេះបានសន្សំ ហើយរក្សាទុកនូវប្រាក់ចំណូលរបស់ខ្លួនមួយភាគធំនៅក្នុងធនាគារបរទេស ឬមួយក៏បានប្រើប្រាស់ប្រាក់ចំណូលរបស់ខ្លួនសម្រាប់ទិញដូរគ្រឿងវត្ថុដ៏ប្រណិត និងសម្រាប់ធ្វើសំណង់ផ្ទះថ្ម និងវីឡាដ៏ល្អៗ ដ៏មានតម្លៃបំផុត។ ទាំងអស់នេះ បណ្ដាលឱ្យមានការកម្រិតជាខ្លាំង ដល់ទំហំនៃការចំណាយដើមទុនសម្រាប់សេចក្ដីត្រូវការក្នុងការពង្រីកឧស្សាហកម្ម និងកសិកម្ម ហើយបានរាំងរាដល់ការបំបាត់ភាពអន់ថយខាងសេដ្ឋកិច្ច និងបច្ចេកទេសរបស់ប្រទេស។

ក្នុងអំឡុងពេល២០ឆ្នាំ បន្ទាប់ពីសម័យសង្គ្រាមលោកលើកទីពីរ ឆ្នាំ១៩៤៥ - ១៩៦៥ គេសង្កេតឃើញនូវស្ថានភាពក្រីក្រលំបាក និងការចាកចេញពីលំនៅឋានរបស់វណ្ណៈកសិករកម្ពុជា។ ម្យ៉ាងវិញទៀត យុទ្ធនាការប្រេកបដោយការខូចខាត

អន្តរាយបានទៅជាប្រភពដែលធ្វើឱ្យកសិករជាច្រើន ជាពិសេសកសិករនៅក្នុងតំបន់ប៉ែកខាងត្បូង និងខាងលិចនៃប្រទេស បោះបង់នូវភូមិឋាន ស្រែចម្ការរបស់ខ្លួន ដើម្បីស្វះស្វែងរកការធ្វើនៅខេត្តនានានៅតំបន់កណ្តាលប្រទេស ឬនៅទីក្រុង។ដំណើរចាកចេញពីភូមិឋាន ដែលមានកម្រិតកាន់តែខ្លាំងឡើងបណ្តាលឱ្យបណ្តាជននៅទីក្រុងភ្នំពេញ កាន់តែមានចំនួនច្រើនឡើង។ នៅឆ្នាំ១៩៥៦ បណ្តាជនទីក្រុងភ្នំពេញ មានចំនួនចាប់ពី៣០០ ដល់៣៥០ពាន់នាក់ ខុសពីបណ្តាជននៅទីក្រុងភ្នំពេញ នាឆ្នាំ ១៩៣៩ ដែលមានចំនួនតែ១០០ពាន់នាក់។ សេដ្ឋកិច្ចទីក្រុង និងស្ថានភាពអន់ថយនៃឧស្សាហកម្មទីក្រុង មិនអាចជួយឧបត្ថម្ភបានដល់បណ្តាជនដែលទើបនឹងមកពីស្រុកស្រែ។ ជាផលវិបាកនៃសភាពការណ៍នេះ ទីក្រុងភ្នំពេញ បានក្លាយទៅជាទីផ្សារដ៏សំខាន់នៃកម្លាំងកម្មករស៊ីឈ្នួល ហើយមិនតែប៉ុណ្ណោះ សេចក្តីសុំការធ្វើ ឬសុំស៊ីឈ្នួលមានចំនួនច្រើនលើសជាងសេចក្តីត្រូវការ។ ដូច្នេះហើយ បានជានៅក្នុងប្រទេសមានបញ្ហាមានអ្នកឥតការធ្វើ បានចោទឡើងជាលើកទីមួយ។

ចលនាចាកចេញពីភូមិឋានរបស់កសិករពីខេត្តខាងត្បូង និងខេត្តខាងលិច បានចុះអន់ថយនៅចុងឆ្នាំ១៩៥៤។ ក៏ប៉ុន្តែ ចលនាចាកចេញពីស្រុកស្រែនេះ នៅតែមានបន្តទៅទៀត។ នៅសម័យចុងឆ្នាំ១៩៥០ និងដើមឆ្នាំ១៩៦០ ប្រភពដ៏សំខាន់នៃចលនាចាកចេញពីស្រុកស្រែ កើតមកអំពីភាពក្រីក្រតោកយ៉ាករបស់វណ្ណៈកសិករ ដែលស្ថិតនៅក្រោមការជិះជាន់របស់ពួកនាយទុនចងការប្រាក់នៅស្រុកស្រែ។

នៅឆ្នាំ១៩៥៤ នៅតំបន់ស្រុកស្រែទាំងឡាយមានអ្នកជំនួញចំនួន ៣៤ពាន់នាក់ គឺជាអ្នកជំនួញដែលមានតៀមទំនិញរបស់ខ្លួន ជាពិសេស គឺជនជាតិចិន ដែលដើរតួជាអ្នកទិញ និងលក់ទំនិញ និងជាអ្នកចងការប្រាក់។ ជាមធ្យមក្នុងចំនួនកសិដ្ឋាន ពី១៨ - ២០ មានឈ្មួញចងការម្នាក់។ តាមស្ថិតិនាឆ្នាំ១៩៥២ កសិដ្ឋាន៧៥% បានស្ថិតនៅក្នុងស្ថានភាពជាអ្នកជំពាក់បំណុលដល់ពួកអ្នកចងការប្រាក់។ ប្រាក់ទូទៅ ជាឥណទានប្រើប្រាស់សម្រាប់ចងការប្រាក់ នៅស្រុកស្រែបានឡើងដល់២០%នៃផលទុនផលិតកម្មទូទៅ ក្នុងវិស័យកសិកម្មរបស់ប្រទេស។

នៅក្រោមរបបអាណានិគមនិយម ពួកនាយទុនចងការប្រាក់មិនបានយកចិត្តទុកដាក់ដល់ការទិញដីធ្លី ដើម្បីធ្វើជាកម្មសិទ្ធិរបស់ខ្លួនទេ។ បន្ទាប់ពីសម័យដែលប្រទេសបានឯករាជ្យឡើងវិញ ស្ថានភាពបែបនេះបានផ្លាស់ប្តូរ ដោយហេតុថា មូលធនស្រុកស្រែបានទទួលលទ្ធភាព ចូលរួមក្នុងពាណិជ្ជកម្មនាំចេញនៃផលដំណាំកសិកម្មខ្លះៗ។ ដោយបានចូលរួមក្នុងការត្រួតត្រាលើពាណិជ្ជកម្មនាំចេញនៃផលស្រូវ និងពោត មូលធនពាណិជ្ជកម្មកម្ពុជា បានចាប់ផ្តើមពង្រីកកិច្ចត្រួតត្រារបស់ខ្លួនទៅលើផលិតកម្ម នៃដំណាំសម្រាប់ការនាំចេញទៅលក់ក្រៅប្រទេស។ ស្ថានភាពបែបនេះ បានជំរុញឱ្យមានការចំណាយដើមទុនពាណិជ្ជកម្មមួយភាគទៅលើរបរកសិកម្ម ហើយដែលបានបង្កើតឱ្យមានការប្រមូលផ្តុំដីធ្លីនៅក្នុងកណ្តាប់ដៃ របស់ពួកនាយទុនជិះជាន់នៅស្រុកស្រែ។ ក៏ប៉ុន្តែ ស្ថានភាពបែបនេះ ពុំបានបណ្តាលឱ្យស្រទាប់ធំទូលាយនៃវណ្ណៈម្ចាស់ដីធំៗ កើតឡើងបានទេ។

នៅសម័យកាលនៃឆ្នាំ១៩៥៣ - ១៩៦៤ នៅស្រុកស្រែ ស្រទាប់នៃវណ្ណៈកសិករ ដែលគេហៅថា ជាកសិករម្ចាស់ដីមធ្យម (ប្រកបដោយកសិដ្ឋានមានទំហំ ពី១០ - ២០ហិកតា) បានកកើតមានឡើងនៅពេលជាមួយគ្នានឹងការកកើត នៃស្រទាប់នៃវណ្ណៈកសិករម្ចាស់ដីតូចតាច ដែលមានចំនួនកាន់តែច្រើនឡើង។

នៅឆ្នាំ១៩៦៣ ដីស្រែចម្ការកាន់កាប់ដោយម្ចាស់ដីធំ (ដែលមានដីច្រើនជាង២០ហិកតា) បានគ្របដណ្តប់លើទំហំដី៥,៦%។ ដីស្រែចម្ការ ជិត១៦% បានស្ថិតក្នុងកណ្តាប់ដៃរបស់ម្ចាស់ដីមធ្យម ដែលតែងបានប្រវាស់ដីទាំងនេះដើម្បីយកបំណុលសម្រាប់ជាប្រយោជន៍ដល់ខ្លួន ដោយយកចំណេញលើការជិះជាន់លើកម្លាំងពលករស៊ីឈ្នួល និងលើរបៀបចងការប្រាក់។ ដីស្រែចម្ការចំនួន២១,៤ភាគរយនៃប្រទេស ស្ថិតនៅក្នុងកណ្តាប់ដៃរបស់ពួកអ្នកម្ចាស់ដីធំ និងមធ្យម ដែលមានកម្មសិទ្ធិពេញទីលើដីស្រែចម្ការទាំងនេះ។ ម្យ៉ាងវិញទៀត ទិន្នន័យ និងស្ថិតិទាំងនេះមិនបានបង្ហាញឱ្យឃើញទិដ្ឋភាពពិតពេញលេញក្នុងការប្រមូលផ្តុំដីធ្លី ឱ្យមកស្ថិតនៅក្នុងកណ្តាប់ដៃរបស់មនុស្សជិះជាន់អ្នកដទៃនៅស្រុកស្រែទេ។

នៅឆ្នាំ១៩៥៣ - ១៩៦៤ រាជរដ្ឋាភិបាលបានបញ្ឈប់ការឧបត្ថម្ភដល់ស្រទាប់នៃវណ្ណៈកសិករមានទ្រព្យសម្បត្តិ ដែលមានដីទំហំពី ៥ - ១០ហិកតា ហើយដីស្រែចម្ការរបស់កសិករទាំងនេះមានទំហំ២៤,៨ភាគរយ នៃដីស្រែចម្ការរបស់ប្រទេស។ ស្ថានភាពខាងសង្គមកិច្ចរបស់កសិករអ្នកមានបានទាំងនេះ មានលក្ខណៈមិនដូចគ្នាទេ។ កសិករមានទ្រព្យសម្បត្តិខ្លះ ដែលមានដីទំហំពី៥ - ១០ហិកតា បានប្រវាស់ដីស្រែចម្ការមួយភាគ ឬបានជួល

ដីនេះឱ្យកសិករដទៃ ឬបានធ្វើស្រែចម្ការលើដីនេះដោយកម្លាំងរបស់កសិករស៊ីឈ្នួល។ កិច្ចការបែបនេះ គឺរបៀបប្រវាស់ ឬ ជួលដី គឺមានលក្ខណៈពិសេស ដែលកើតមាននៅបណ្តាកសិដ្ឋានដែលស្ថិតនៅតាមទន្លេមេកុង គឺនៅតំបន់ដែនដីចម្ការ។ នៅលើដីចម្ការទាំងនេះ គេអាចធ្វើដំណាំពីរដងក្នុងមួយឆ្នាំ ហើយម្ចាស់ដី (មានទំហំ ពី៥ - ១០ហិកតា) តាមធម្មតា បានប្រវាស់ដីរបស់ខ្លួន ហើយបានទទួលប្រាក់ចំណេញច្រើនជាងម្ចាស់ដី (មានទំហំ ពី១៥ - ២០ហិកតា) នៅតំបន់ដទៃនៃប្រទេសកម្ពុជា ដែលបានជួលដីរបស់ខ្លួនឱ្យកសិករដទៃ*។ នៅក្នុងខេត្តខ្លះដែលស្ថិតឆ្ងាយពីទន្លេមេកុង ហើយដែលមានដីស្រែចម្ការ ម្ចាស់ដី (មានទំហំ ពី៥ - ១០ហិកតា) ជួនកាលបានធ្វើស្រែចម្ការដោយខ្លួនឯង ជួនកាលបានទទួលប្រាក់ចំណូល ដោយសារការប្រវាស់ដី ឬមួយដោយសារការចងការប្រាក់។

ស្ថានភាពបែបនេះ បញ្ជាក់ឱ្យឃើញថា បណ្តាម្ចាស់ដី (មានទំហំ ពី៥ - ១០ហិកតា) ស្ថិតនៅក្នុងស្រទាប់នៃម្ចាស់ដីដែលជាវណ្ណៈជិះជាន់នៅស្រុកស្រែចម្ការ។ ស្រទាប់នៃអ្នកម្ចាស់ដីមធ្យម និងអ្នកម្ចាស់ដីតូច (មានទំហំ ពី៥ - ១០ហិកតា ហើយដែលរស់នៅដោយសារការប្រវាស់ និងចងការប្រាក់។ គេអាចបញ្ចូលពួកទាំងនេះ ទៅក្នុងស្រទាប់នៃអ្នកម្ចាស់កម្មសិទ្ធិ

---

* ដំណាំបច្ចេកទេសលើដីល្បាប់ក្នុងមួយហិកតា បានផ្តល់ផលដំណាំ ឬប្រាក់ចំណូលពីរ - បីដង លើសដីស្រែសម្រាប់ធ្វើដំណាំស្រូវក្នុងមួយហិកតា។ ការនេះបញ្ជាក់ឱ្យឃើញនូវទំហំនៃការប្រវាស់ដីក្នុងតំបន់ខ្លះដែលស្ថិតនៅទន្លមេកុង។

ដែលជាកសិករប្រវាស់ដី និងជាអ្នកចងការប្រាក់។ អ្នកទាំងនេះរីកចម្រើនដោយសារការកៀបសង្កត់លើកសិករ ស្រទាប់នៃអ្នកម្ចាស់កម្មសិទ្ធិនេះរីកចម្រើនខាងចំនួន ដោយសារការទិញយកដី " ថ្មីៗ " និងដោយសារការកៀបសង្កត់លើកសិករក្រ និងកសិករគ្មានដី។

ការដុះដាល នៃស្រទាប់វណ្ណៈកសិករនានានៅស្រុកខ្មែរ បណ្តាលឱ្យមានចំនួនកសិករតូចតាច កាន់តែច្រើនឡើងៗ។ ហេតុនេះ ជាឧទាហរណ៍ នៅឆ្នាំ១៩៦៣ កសិដ្ឋានចំនួន៣០,៧ ភាគរយ នៃប្រទេស គឺជាកសិដ្ឋានតូច និងតូចតាចបំផុត ដែលមានទំហំត្រឹម១ហិកតា ហើយដែលគ្របដណ្តប់លើទឹកដីស្រែចម្ការចំនួនតែត្រឹម៥,២ភាគរយ នៃមូលនិធិដីស្រែចម្ការរបស់ប្រទេស។ ហេតុនេះហើយ បានជាម្ចាស់ដីតូចតាចមួយចំនួនធំទាំងនេះ តែងតែប្រវាស់ ឬជួលដីពីម្ចាស់ដីជាកសិករអ្នកមានទ្រព្យសម្បត្តិដោយផ្តល់ប្រាក់បំណុលយ៉ាងច្រើន។ តាមស្ថានភាពខាងសង្គមកិច្ច និងសេដ្ឋកិច្ចរបស់ខ្លួន កសិករក្រីក្រទាំងនេះអាចស្ថិតនៅក្នុងស្រទាប់នៃប្រជាកសិករវណ្ណៈអធនពាក់កណ្តាល។

កសិករមួយភាគដែលមានដី ( ទំហំ១ - ២ហិកតា ) ហើយដែលស្ថិតនៅក្នុងតំបន់ដីស្រែចម្ការ មិនសូវមានដីជាតិ ( ១ហិកតាផ្តល់បានផលដំណាំ ០,៧ - ០,៨តោន ) ក៏មានស្ថានភាពប្រហាក់ប្រហែលគ្នានឹងស្រទាប់កសិករក្រីក្រ នៅស្រុកស្រែខាងលើដែរ។ កសិករទាំងនេះ ត្រូវបង្ខំចិត្តស្វែងរករបររកស៊ីដទៃសម្រាប់បង្គ្រប់ការចំណាយក្នុងជីវភាព ដូចជា ទៅប្រវាស់ដី ឬធ្វើរបរសិប្បកម្មដទៃ។

នៅឆ្នាំ១៩៥៦ នៅប្រទេសកម្ពុជា គេបានបង្កើតគ្រឹះស្ថានរាជសហករណ៍មួយ (សរសេរកាត់ អូរ៉ុក)។

ការបង្កើតអង្គការសហករណ៍នានា " ត្រូវបានប្រគល់ដល់ការទិញ " ពីសំណាក់ពួកនាហ្មឺននៃគ្រឹះស្ថានអូរ៉ុក ដែលមានការនិយមដល់តំណែងរបស់ខ្លួន តាមទស្សនៈនៃលទ្ធភាពក្នុងការមានបានផ្ទាល់ខ្លួន។ ហេតុនេះហើយ បានជា គេគ្មានឆ្ងល់អ្វីទេថានៅក្នុងស្ថានភាព នៃការបង្កើតសហករណ៍ កសិកម្មបែបនេះរមែងមានអំពើពុករលួយ និងរបៀបផ្សេងៗនៃការបន្លំមូលនិធិប្រាក់សម្រាប់ផ្តល់ជាឥណទានដល់កិច្ចការកសិកម្ម។ ជាលទ្ធផល នៅចុងឆ្នាំ១៩៥០ សហករណ៍ជាច្រើនទៅជាសហករណ៍ " ខាតដើម "។ ការជំពាក់ប្រាក់រដ្ឋពីសំណាក់សហករណ៍ទាំងនេះ កាន់តែកើនខ្ពស់ឡើងក្នុងមួយឆ្នាំៗ។ នៅក្នុងអង្គការសហករណ៍ជាច្រើន គេបានសង្កេតឃើញថា មានបណ្តាអ្នកជិះជាន់នៅស្រុកស្រែបានកាន់កាប់តំណែងដ៏សំខាន់ៗ។ ដោយប្រើរបៀបដើរតាមទ្វារក្រោយ ដែលជារបៀបខុសច្បាប់ ពួកអ្នកមានទព្យសម្បត្តិនៅស្រុកស្រែបានប្រើប្រាស់ឥណទានរដ្ឋ ដែលខ្លួនទទួលក្នុងគោលបំណងដើម្បីចងការប្រាក់ និងដើម្បីទិញយកដីសម្រាប់ជាកម្មសិទ្ធិផ្ទាល់ខ្លួន ហើយនៅក្នុងកាលៈទេសៈភាគច្រើន ពួកនេះបានយកដីនេះទៅប្រវាស់ដល់កសិករក្រីក្រ។

ពួកអ្នកមាននៅស្រុកស្រែ បានប្រើប្រាស់ដើមទុនរបស់ខ្លួននេះមួយចំនួន ក្នុងការបង្កើតផលិតកម្មដំណាំបច្ចេកទេសមានជាពិសេស ដំណាំកប្បាស ថ្នៃ អំពៅ។ និន្នាការនៃការរីកចម្រើនកសិកម្មបែបនេះ បានបង្កើតឱ្យមានចំនួនកម្មករស៊ីឈ្នួលកាន់តែច្រើននៅតំបន់ស្រុកស្រែ ដែលមានកសិដ្ឋានធំៗ។ គឺ

នៅលើមូលដ្ឋាននៃកសិដ្ឋានទាំងនេះហើយ ដែលគេបានបង្កើត សហករណ៍ផលិតកម្មនានា ដោយហេតុថា នៅទីនេះគេអាច ប្រើប្រាស់ពលកម្មស៊ីឈ្នួលដ៏ថោករបស់អ្នកស៊ីឈ្នួល។

ជាទូទៅ គេអាចនិយាយថា កិច្ចការរៀបចំតាមការទាក់ទង របៀបមូលធននិយមនៅក្នុងរបរកសិកម្ម បានរីកចម្រើនយ៉ាង យឺតបំផុត។ សេដ្ឋកិច្ចនៃកសិដ្ឋានធំៗ និងមធ្យមមួយចំនួនក៏ បានយោងទៅតាមរបៀបរបប នៃអំពើជិះជាន់មូលធននិយម និងសក្តិភូមិនិយមពាក់កណ្តាល។ ការចងការប្រាក់ និងរបៀប ប្រវាស់ដីតាមបែបសម័យមុន របបមូលធននិយមបានទៅជាប្រភព នៃប្រាក់ចំណូល របស់ស្រទាប់មនុស្សជិះជាន់នៅស្រុកស្រែ។

ដោយយល់នូវសកម្មភាពវិទ្ធង្សនា នៃចក្រពត្តិនិយម អាមេរិក និងបរិវាររបស់វា នៅខែវិច្ឆិកា ឆ្នាំ១៩៦៣ មជ្ឈដ្ឋាន ដឹកនាំប្រទេសកម្ពុជា បានធ្វើសេចក្តីសម្រេច ដើម្បីបញ្ឈប់កម្ម វិធីជំនួយអាមេរិក ហើយបានអនុវត្តការកែប្រែ នៃប្រព័ន្ធធនាគារ និងពាណិជ្ជកម្មក្រៅប្រទេស។ ការកែប្រែបែបនេះ បានគ្រោង ទុកអំពីការហាមឃាត់ដល់សកម្មភាព របស់ក្រុមហ៊ុនពាណិជ្ជ កម្មឯកជនក្រៅប្រទេស និងធនាគារឯកជនខាងពាណិជ្ជកម្មខ្លះៗ នៅប្រទេសកម្ពុជា។

មុខងារខាងពាណិជ្ជកម្មអាហារ័ណនីហារ័ណ ដែលបាន បំពេញដោយក្រុមហ៊ុនបរទេស ត្រូវបានប្រគល់ជាថ្មីដល់ក្រុម ហ៊ុនពាណិជ្ជកម្មទើបបង្កើតថ្មី ហើយដែលមានឈ្មោះថា “ ក្រុម ហ៊ុនអាហារ័ណនីហារ័ណជាតិ ” សរសេរកាត់ “ សូណិចស៊ីម ”។ ក្រុមហ៊ុននេះ មានមូលនិធិ ២៤០លានរៀល ដែលនៅក្នុងនេះ មានមូលនិធិ៦០% ជាដើមទុនរបស់រដ្ឋ ហើយ៤០% ជាដើម

ទុនរបស់ពួកពាណិជ្ជករកម្ពុជា។ មុខងារនៃការផ្ដល់ឥណទានដែលបានបំពេញដោយធនាគារបរទេសនានា ត្រូវបានផ្ដល់ដល់ធនាគារពាណិជ្ជកម្មរដ្ឋ ឈ្មោះ " ឥណទានជាតិ "។

ការបង្កើតក្រុមហ៊ុនសូណិចស៊ីម និងធនាគារឥណទានជាតិ មិនបានបង្កើតឧបសគ្គពេញលេញ ដល់ការប្រើប្រាស់មូលធនអន្តរជាតិ នៅក្នុងវង្វង់ពាណិជ្ជកម្មទេ។ រដ្ឋាភិបាលកម្ពុជាបានអនុញ្ញាតឱ្យក្រុមហ៊ុនពាណិជ្ជកម្មបរទេសខ្លះ នៅបន្តសកម្មភាពរបស់ខ្លួន។ ក្រុមហ៊ុនធំជាងគេ ដែលត្រួតត្រាលើការនាំប្រេងកាតចូល មានជាអាទិ គឺក្រុមហ៊ុនអង់គ្លេស - ហុល្លង់ ឈ្មោះ " ហ្សែល " ព្រមទាំងក្រុមហ៊ុនអាមេរិក ឈ្មោះ " អេសូ " និង " កាល់តិច "។ ម្ដងនេះ ចាប់ពីឆ្នាំ១៩៦៥ ក្រុមហ៊ុនសូណិចស៊ីម បានកាន់កាប់របរពាណិជ្ជកម្មក្រៅប្រទេសសំខាន់ៗ នៅលើវិស័យដទៃទៀត។

នៅក្នុងឆ្នាំ១៩៦៤ មានការបង្កើតក្រុមហ៊ុនពាណិជ្ជកម្មរដ្ឋ និងឯកជនពីរ គឺក្រុមហ៊ុនខ្មែរនៃការទិញផលិតផលកសិកម្ម (សរសេរកាត់ " សូប៉ាប៉ា ") និងក្រុមហ៊ុនជាតិ នៃការចែករំលែកទំនិញនាំចូល (សរសេរកាត់ " សូណាព្រីម ")។ ភារកិច្ចដ៏សំខាន់របស់ក្រុមហ៊ុនទាំងពីរនេះ គឺការជួយឧបត្ថម្ភដល់ក្រុមហ៊ុនសូណិចស៊ីម ក្នុងការរៀបចំទំនិញសម្រាប់ការនាំចេញផ្ទាល់ពីសំណាក់អ្នកបង្កបង្កើតផល (ដែលនៅក្នុងនេះ មានអង្គការសហករណ៍នានា) ហើយព្រមទាំងជួយធ្វើការចែករំលែកទំនិញនាំចូល តាមរយៈសហករណ៍ពាណិជ្ជកម្ម និងអង្គការរដ្ឋនានា។

ការកសាងប្រព័ន្ធក្រុមហ៊ុនសូណិចស៊ីម និងសាខានានារបស់ក្រុមហ៊ុននេះ បានធ្វើឱ្យពួកសហគ្រិនធំៗខ្វះខាតដើមទុន

របស់ខ្លួន ទាក់ទងទៅនឹងសកម្មភាពពាណិជ្ជកម្មក្រៅប្រទេស ក្នុងឋានៈជាពាណិជ្ជករកណ្ដាល។ ក៏ប៉ុន្តែ ២ - ៣ឆ្នាំកន្លងមក បន្ទាប់ពីការកែប្រែនាខែវិច្ឆិកា ឆ្នាំ១៩៦៣ ពួកពាណិជ្ជករក្នុងប្រទេសបានឃុបឃិតគំនិតគ្នា ជាមួយពួកនាហ្មឺនការិយាល័យនិយម នៃរដ្ឋបាលបានរកឃើញប្រភពថ្មីៗទៀត ដែលអាចធ្វើឱ្យខ្លួនទៅជាមនុស្សអ្នកមានបាន។ ម្ដងនេះ ប្រភពនេះទាក់ទងទៅនឹងការរត់គយទំនិញ ដែលកើតមានឡើងកាន់តែខ្លាំង។ ហេតុនេះហើយ បានជានៅសម័យចុងឆ្នាំ១៩៦០ ស្រូវនាំចេញមួយភាគធំ និងស្បៀងដទៃទៀតមួយចំនួនធំ ត្រូវបាននាំចេញតាមរបៀបរត់គយ ខុសពីក្រុមហ៊ុនសូណិចស៊ីម ដែលទទួលបន្ទុកបង់ពន្ធគយឱ្យរដ្ឋ។

នៅក្នុងរង្វង់ នៃការធ្វើពាណិជ្ជកម្មតាមរបៀបរត់គយបែបនេះ ដែលទាក់ទងទៅនឹងពិធីគៃប្រវ័ញ្ចខាងហិរញ្ញវត្ថុ គឺមានការចូលរួមរបស់វណ្ណៈគហបតីពាណិជ្ជកម្មធំៗ នៅក្នុងប្រទេស និងរបស់ពួកមន្ត្រីជាច្រើន ដែលធ្វើការនៅក្នុងក្បាលម៉ាស៊ីនរដ្ឋ។ នៅក្នុងកិច្ចការបែបនេះ អ្នកតំណាងការិយាល័យនិយមបានដើរតួជា “ មន្ត្រីមុខពីរ ”។ នៅក្នុងសម័យប្រជុំនៃរដ្ឋសភា និងក្នុងការសរសេរសម្រាប់សារព័ត៌មាន ពួកនេះបានថ្លែងផ្ដន្ទាទោសយ៉ាងខ្ទរខ្ទារ ដល់ការរត់គយខាងពាណិជ្ជកម្ម ហើយបានទាមទារឱ្យចាត់វិធានការដ៏ស័ក្តិសិទ្ធិ ដើម្បីបំបាត់អំពើបែបនេះចោល។ នៅក្នុងការពិត មានមន្ត្រីជាន់ខ្ពស់ជាច្រើនបែបនេះ រួបរួមយ៉ាងសកម្មក្នុងអំពើរត់គយ និងក្នុងរបៀប “ជួញជំនួញដ៏លាក់កំបាំង ” ដទៃទៀត ដែលប្រព្រឹត្តទៅតាមរយៈពួកពាណិជ្ជករចិនក្នុងស្រុក ដែលជាពាណិជ្ជករមានបក្សពួក

របស់ខ្លួននៅតាមផ្សារងងឹតនានានៅទីក្រុងបាងកក ព្រៃនគរ សាំងកាពួរ និងហុងកុង។ ការរីកចម្រើននៃ“ជំនួញដ៏លាក់កំបាំង” តាមរបៀបផ្សេងៗ (មានការរត់គយទំនិញ ការគែប្រវិញ្ញដូរ រូបិយប័ណ្ណបរទេស។ល។) បានបង្កើតឱ្យមានអំពើពុករលួយ កាន់តែខ្លាំងឡើង ដែលរាលដាលដល់ក្រសួងនានានៃរដ្ឋការ និងអង្គការនយោបាយរបស់រដ្ឋ។ ប្រាក់ចំណូលរបស់រដ្ឋ ដែល បានមក ដោយសារការនាំចេញទំនិញចូលតាមរយៈក្រុមហ៊ុន សូណិចស៊ីម ក៏កាន់តែអន់ថយទៅ។ ការលួតលាស់នៃនិន្នាការ ដ៏អាក្រក់បែបនេះ បានប្រព្រឹត្តទៅនៅក្នុងពេលដែលមានការ កម្រិតកាន់តែខ្លាំង នូវប្រភពចំណូលហិរញ្ញវត្ថុក្រៅប្រទេស ដែល បានមកពីជំនួយសេដ្ឋកិច្ចរបស់ប្រទេសមូលធននិយម ជាពិសេស របស់សហរដ្ឋអាមេរិក។ ជានិន្នាការអាក្រក់ ដែលបានបណ្តាល ឱ្យមានឱនភាពថវិការដ្ឋ ហើយនៅឆ្នាំ១៩៦៦ ឱនភាពនេះបាន ឡើងដល់៣០% នៃការចំណាយ។ ដើម្បីទប់ទល់នឹងការចំណាយ រដ្ឋមួយភាគធំ គេបានអនុវត្តជាពិសេស លើស្ថានភាពនៃវិបត្តិ ខាងហិរញ្ញវត្ថុ ដែលជាហេតុបណ្តាលឱ្យមានការចុះតម្លៃប្រាក់ ហើយដែលទៅជាទម្ងន់ដ៏ធ្ងន់ធ្ងរ ដែលធ្លាក់មកលើស្មារបស់ ស្រទាប់ប្រជាពលករដ៏ក្រីក្រ។

ការលំបាក និងវិបត្តិខាងហិរញ្ញវត្ថុបានទាក់ទាញឱ្យ រដ្ឋាភិបាលកម្រិតជាអតិបរមាដល់ការចំណាយទុន នៅក្នុងវិស័យ ផលិតកម្មដ៏សំខាន់ៗ នៃសេដ្ឋកិច្ចជាតិ។

នៅឆ្នាំ១៩៦៨ អង្គការដឹកនាំ “ សង្គម ” បានចាប់ផ្តើម អនុវត្តមាគ៌ានយោបាយ ដើម្បីទាក់ទាញមូលធនបរទេសឱ្យចូល

មកធ្វើសហការក្នុងប្រទេស ហើយបានបង្កើតការទាក់ទងជាមួយធនាគារអន្តរជាតិផ្តាច់មុខនានា។

នៅសម័យកាលនៃឆ្នាំ១៩៦០ គេសង្កេតឃើញសភាពការណ៍ នៃការកកើតវណ្ណៈនៅស្រុកស្រែ និងភាពក្រីក្រតោកយ៉ាករបស់កសិករក្រីក្រកាន់តែខ្លាំងឡើង។

នៅក្នុងអំឡុងឆ្នាំ១៩៦៤ - ១៩៦៧ រដ្ឋាភិបាលបានរំលាយសហករណ៍លក់ទិញទំនិញរាប់រយ ដែលមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការសងប្រាក់ដល់រដ្ឋវិញ។ម្យ៉ាងវិញទៀត សកម្មភាពបែបនេះ មិនបានបង្កើតឱ្យមានកិច្ចត្រួតត្រាដ៏មធ្យ័តលើសកម្មភាពរបស់គ្រឹះស្ថានអូរ៉ុក ទេ។ នៅឆ្នាំ១៩៦៧ - ១៩៦៨ តាមរយៈនៃអង្គការនេះ រដ្ឋបានផ្តល់ប្រាក់ឥណទានសម្រាប់ឱ្យសហករណ៍កសិកម្មខ្ចី ដែលមានចំនួនទាំងអស់ដល់ ៤០០លានរៀល។ ក៏ប៉ុន្តែ ដូចគ្នានឹងឆ្នាំមុនៗ ប្រាក់ឥណទាននេះមួយចំនួនធំបានធ្លាក់ទៅក្នុងកណ្តាប់ដៃ នៃស្រទាប់មនុស្សជិះជាន់ដែលយកប្រាក់នេះទៅប្រើប្រាស់ដើម្បីកៀបសង្កត់ លើកសិករទាំងឡាយតាមរបៀបដែលមានលក្ខណៈដូចមុនសម័យមូលធន។ សហករណ៍ជាច្រើននៅតែមានការបង់ខាតតទៅមុខទៀត។ គ្រាន់តែចាប់ពីឆ្នាំ១៩៦៧ - ១៩៦៨ ប្រាក់ឥណទានដែលសហករណ៍មិនបានសងដល់រដ្ឋវិញ មានចំនួនឡើងដល់ ៧០លានរៀល។

នៅចុងអំឡុងឆ្នាំទី៦០ គេឃើញច្បាស់ថា ប្រព័ន្ធនៃគ្រឹះស្ថានអូរ៉ុក គ្មានសមត្ថភាពដោះស្រាយភារកិច្ចនានាទាក់ទងទៅនឹងការបំបាត់ឥទ្ធិពលរបស់មូលធននៃអ្នកចងការប្រាក់ និងពួកឈ្មួញកណ្តាលឡើយ។ គឺក្រោមឥទ្ធិពលដ៏អាក្រក់នេះហើយ

ដែលកសិដ្ឋានកសិករមួយចំនួនធំបានបន្តបំពេញសកម្មភាពរបស់ខ្លួននៅក្នុងប្រទេស។

ភាពក្រីក្រតោកយ៉ាក និងស្ថានភាពជំពាក់បំណុលបានបង្ខិតបង្ខំឱ្យកសិករក្រីក្រ និងកសិករគ្មានដីធ្លីប្រែខ្លួនទៅជាប្រជាពលករ “ អ្នកកៀសខ្លួន ” ពីស្រុកស្រែចូលមកបំពេញជួរនៃវណ្ណៈអធននៅទីក្រុងនានា។

នៅសម័យពាក់កណ្ដាលទី២ នៃអំឡុងឆ្នាំទី៥០ និងនៅអំឡុងឆ្នាំទី៦០ វណ្ណៈកម្មករនៃប្រទេសកម្ពុជា បានកើនចំនួនរបស់ខ្លួន។ ចំនួននេះមានទំហំមិនធំប៉ុន្មាន ក៏ប៉ុន្តែ ជាភស្តុតាងបញ្ជាក់ឱ្យឃើញ នូវទម្រង់នៃផលិតកម្មរបៀបមូលធននិយមដែលមានកម្រិតច្បាស់លាស់។ ទោះបីយ៉ាងនេះក្ដី ក៏នៅឆ្នាំ ១៩៥៥ - ១៩៥៨ តាមស្ថិតិនានា ចំនួនកម្មករដែលធ្វើការនៅក្នុងរោងឧស្សាហកម្ម និងនៅក្នុង គមនាគមន៍មានដល់ ៤០ - ៥០ ពាន់នាក់។ នៅឆ្នាំ១៩៦៨ ចំនួនទូទៅនៃកម្មកររោងចក្រ គមនាគមន៍ សំណង់ការដ្ឋាន និងនៅចម្ការដំណាំនានា បានឡើងដល់ ៧៥ - ៨០ពាន់នាក់ ហើយនះមិនបូករួមទាំងពួកសិប្បករ និងអ្នកប្រកបអាជីវកម្មតូចតាចដែលមានចំនួនដល់ ៩០ - ១០០ពាន់នាក់។

ទីប្រមូលផ្ដុំដ៏សំខាន់របស់វណ្ណៈកម្មករ នៃប្រទេសកម្ពុជា គឺចម្ការកៅស៊ូ ដែលនៅទីនេះមានកម្មករ ២៤ - ២៥ពាន់នាក់ តមក គឺរោងចក្រ និងរោងផលិតនានា ដែលប្រើប្រាស់កម្មករចំនួន ៧ - ៨ពាន់នាក់។

មជ្ឈដ្ឋានមណ្ឌលប្រមូលផ្តុំវណ្ណៈអធនដ៏សំខាន់ គឺទីក្រុងភ្នំពេញ ហើយនៅទីនេះ មានកម្មកររោងចក្រ សំណង់ និងគមនាគមន៍ចំនួនរាប់ម៉ឺននាក់។

# ចំពូកទី៤
## ទិបត្តិរបស់របបត្រប់គ្រងសង្គមរាស្ត្រនិយម

ការតស៊ូ ដើម្បីការពារនយោបាយអព្យាក្រឹតភាព និងការពង្រឹងអធិបតេយ្យភាពរដ្ឋនៃប្រទេសកម្ពុជា បានជំរុញឱ្យមានចោទជាភារកិច្ចនូវការពង្រឹងបណ្តាកម្លាំងប្រជាធិបតេយ្យ និងស្នេហាមាតុភូមិនៅក្នុងប្រទេស។ ក៏ប៉ុន្តែ ការដោះស្រាយភារកិច្ចនេះបានជួបប្រទះនឹងសេចក្តីលំបាកជាច្រើន ដែលទាក់ទងជាពិសេសទៅនឹងលក្ខណៈនានា នៃនយោបាយផ្ទៃក្នុងរបស់អង្គការដឹកនាំ " សង្គម " ដែលមិនបានបញ្ឈប់នូវបំណងរបស់ខ្លួនក្នុងការបង្ក្រាបកម្លាំងប្រជាធិបតេយ្យនានា នៅក្នុងប្រទេស។ ចរន្តបដិបក្ខមុខពីរ និងនិន្នាការផ្ទុយគ្នានៅក្នុងនយោបាយបែបនេះរបស់អង្គការដឹកនាំ " សង្គម " ត្រូវបានអនុវត្តកាន់ខ្លាំងតទៅទៀត ចាប់តាំងពីពេលចុងអំឡុងឆ្នាំទី៥០ រហូតដល់ដើមអំឡុងឆ្នាំទី៦០ គឺជាពេលវេលាដែលបង្កបង្កើតឱ្យមានស្ថានភាពដ៏ស្មុគស្មាញសម្រាប់បំពេញសកម្មភាព របស់បក្សប្រជាជនបដិវត្តន៍កម្ពុជា និងរបស់កម្លាំងចម្រើននិយមនានានៅក្នុងប្រទេសដែលបានគាំទ្រដល់បក្សនេះ។

នៅខែកញ្ញា ឆ្នាំ១៩៦០ មានការបើកសម័យប្រជុំមហាសន្និបាតលើកទីពីរនៃបក្សប្រជាជនបដិវត្តន៍កម្ពុជា ហើយដែលនៅក្នុងពេលនោះ សមមិត្ត ទូ - សាមុត ជាជនកុម្មុយនិស្តអន្តរជាតិនិយម ត្រូវបានជ្រើសរើសជាអ្នកដឹកនាំបក្ស។ មហាសន្និបាតបានទាំងឱ្យឈ្មោះថ្មីដល់បក្សថា ជាបក្សកុម្មុយនិស្ត ហើយបាន

អនុម័តកម្មវិធីថ្មី ដែលសម្របសម្រួលទៅតាមស្ថានភាពដែលបានកើតមានឡើងនៅក្នុងប្រទេស បន្ទាប់ពីការរៀបចំអធិបតេយ្យភាពរដ្ឋឡើងវិញ។ ក៏ប៉ុន្តែ ជនកុម្មុយនិស្តកម្ពុជាទាំងឡាយ ពុំទាន់បានអនុវត្តកម្មវិធីនេះជាធរមាន ដោយហេតុថា នៅដើមអំឡុងឆ្នាំទី៦០ បក្សពួករបស់ប៉ុល ពត អៀង សារី បានចាប់ផ្តើមធ្វើវិទ្ធង្សនានៅក្នុងជួររបស់បក្ស។

បន្ទាប់ពីបានត្រឡប់មកពីស្រុកបារាំង វិញ នៅឆ្នាំ១៩៥៣ ប៉ុល ពត និងបក្សពួករបស់ខ្លួនបានចូលជាសមាជិកក្នុងជួររបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា។ ក្នុងការបំបិទបំបាំងនូវបំណងដ៏ខ្មៅងងឹតរបស់ខ្លួនអស់រយៈពេលជាច្រើនឆ្នាំ ប៉ុល ពត បានចូលរួមក្នុងការងាររបស់អង្គការបក្សនៅភ្នំពេញ។ ដោយការប្រកាន់តាមពាក្យស្លោកឆ្វេងនិយមហួសហេតុ ប៉ុល ពត និងបក្សពួករបស់វាបានដណ្តើមយកតំណែងដឹកនាំ ក្នុងអង្គការបក្សនៅទីក្រុងបន្តិចម្តងៗ។ នៅពេលជាមួយគ្នានោះ ប៉ុល ពត បានទៅជាលេខាផ្ទាល់របស់សមមិត្ត ទូ - សាមុត។ ក្នុងការប្រើប្រាស់ស្ថានភាពរបស់ខ្លួន ប៉ុល ពត បានចាប់ផ្តើមប្រមែប្រមូលបង្កើតក្រុមពួករបស់ខ្លួន ដែលប្រឆាំងនឹងបក្ស។ នៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៦២ ក្រុមពួកនេះធ្វើឃាតដ៏ព្រៃផ្សៃ ដោយសម្លាប់លើរូបសមមិត្ត ទូ - សាមុត និងសមាជិកដឹកនាំដទៃរបស់បក្សខ្លះទៀត។

បន្ទាប់ពីបានធ្វើជាអ្នកដឹកនាំបក្ស ប៉ុល ពត បានចាប់ផ្តើមរៀបចំសកម្មភាពរបស់បក្ស ឱ្យស្របទៅតាមទស្សនៈឆ្វេងនិយមហួសហេតុ ហើយសកម្មភាពបែបនេះបានផ្តល់ផលវិបាកដ៏ធ្ងន់ធ្ងរដល់ចលនាបដិវត្តន៍ប្រជាធិបតេយ្យ ប្រឆាំងចក្រពត្តិនិយមនៅប្រទេសកម្ពុជា នាសម័យកាលអំឡុងឆ្នាំទី៦០។

នៅដើមអំឡុងឆ្នាំទី៦០ សកម្មភាពប្រឆាំងបក្ស និងអំពើវិទ្ធង្សនានៅក្នុងបក្សអនុវត្តដោយប៉ុល ពត មានលក្ខណៈកាន់តែខ្លាំងក្លាឡើងនៅក្នុងស្ថានភាពដែលនៅពេលនោះ អង្គការដឹកនាំ " សង្គម " ក៏បានចាប់ផ្តើមធ្វើការបង្ក្រាបយ៉ាងធ្ងន់ធ្ងរប្រឆាំងនឹងអ្នកតំណាងកម្លាំងចម្រើននិយមទាំងឡាយ ជាពិសេសប្រឆាំងនឹងក្រុម " ប្រជាជន " ដែលជាអង្គការត្រឹមត្រូវតាមច្បាប់របស់បក្សប្រជាជនបដិវត្តន៍កម្ពុជា ។

នៅរដូវវស្សានៃឆ្នាំ១៩៦០ តាមបញ្ជារបស់អាជ្ញាធរកម្ពុជា កាសែត " ប្រជាជន " និងសារព័ត៌មានដទៃ ពីរ - បីទៀត ដែលជាសារព័ត៌មានតែងបានលាតត្រដាងដ៏ច្បាស់លាស់ នូវស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេស និងប្រឆាំងនឹងអំពើពុករលួយ ព្រមទាំងអំពើរំលោភដទៃទៀតរបស់រដ្ឋការនៅក្រសួងនានា សារព័ត៌មានទាំងនេះ ត្រូវបានគេបញ្ឈប់ មិនឱ្យចេញផ្សាយតទៅទៀត ។ នៅខែសីហា ឆ្នាំ១៩៦១ មានការកោះហៅសមាជជាតិពិសេស ដើម្បីធ្វើជាកលល្បិចបង្កើត " តុលាការសាធារណៈ " ប្រឆាំងនឹងក្រុម " ប្រជាជន "។ ក្នុងលេសនៃការបង្កើត " តុលាការ " បែបនេះ គឺសំណើរបស់ក្រុម " ប្រជាជន " សុំឱ្យដោះស្រាយបញ្ហាមួយចំនួន ដែលទាក់ទងនឹងស្ថានភាពសេដ្ឋកិច្ចរបស់ប្រទេស ហើយនៅក្នុងបណ្តាបញ្ហាទាំងនេះ មានទាំងបញ្ហាស្តីអំពីការផឹកការធ្វើក្នុងបណ្តាយុវជន។ ពេលនោះ ការថ្លែងសុន្ទរកថារបស់នរោត្តម សីហនុ នៅសម័យសមាជជាតិពិសេស ប្រកបដោយការគំរាមកំហែងដ៏ចំហ ដល់អ្នកតំណាងកម្លាំងប្រជាធិបតេយ្យ និងដល់អ្នកតំណាងចម្រើននិយមទាំងអស់។ ការគំរាមកំហែងទាំងនេះ បានទៅជាសញ្ញាដ៏សំខាន់សម្រាប់ធ្វើឃោសនាបង្ក្រាប

ដល់បណ្ដា " ជនកុម្មុយនិស្ដ " ក្នុងស្រុក។ តាំងពីនោះមក នៅលើទំព័រនៃសារព័ត៌មានជាផ្លូវការមានទុកកន្លែងពិសេស ដែលមានចុះផ្សាយនាមឈ្មោះ និងអាសយដ្ឋានរបស់ជន "ប្រកបដោយមន្ទិលសង្ស័យ" ព្រមទាំងហេតុការណ៍ដែលបញ្ជាក់អំពីការទាក់ទងរបស់ខ្លួនជាមួយអ្នកតំណាងចម្រើននិយម។ នៅខែមករា ឆ្នាំ ១៩៦២ អ្នកដឹកនាំ "ប្រជាជន" គឺសមមិត្ត នង - សួន និងជូ - ជេត ត្រូវបានឃុំឃាំងក្នុងពន្ធនាគារ ហើយនៅពេលជាមួយគ្នា មានការចាប់ឃុំឃាំង ដល់អ្នកតំណាងចម្រើននិយមដទៃ ដែលនៅក្នុងនេះមានទាំងចាងហ្វាងកាសែត " បញ្ញសីលា "។

នៅខែមករា ឆ្នាំ១៩៦២ មានការប្រឌិតឯកសារមួយដែលធ្វើឡើង ហើយដែលចោទប្រកាន់ថា ក្រុម "ប្រជាជន" មានការទាក់ទងខាងនយោបាយជាមួយភ្នាក់ងារបរទេស។ ក្រុមប៉ូលិសបានចាប់ឃុំឃាំងមនុស្សមិនស្គាល់ឈ្មោះ ១៣នាក់ នៅជាយក្រុងភ្នំពេញ ហើយបានចោទប្រកាន់ថា ពួកនេះបានចូលរួបរួមក្នុងអំពើឃុបឃិតដើម្បីប្រព្រឹត្តអំពើក្បត់។ នៅពេលនោះ រដ្ឋការបានប្រកាសយ៉ាងឆាប់រហ័សថា មនុស្សទាំងនោះជាភ្នាក់ងារបរទេស ហើយមានការទាក់ទងនឹងក្រុម " ប្រជាជន "។ ការចោទប្រកាន់ដោយអំពើបង្កបង្កើតហតុបែបនេះ មិនបានបង្កើតជាភស្តុតាងអ្វីច្បាស់លាស់ឡើយ ក៏ប៉ុន្តែ ទោះបីដូចម្ដេចក្ដី ក៏រដ្ឋាភិបាលបានកោះហៅតុលាការសឹក ឱ្យកាត់ទោសដល់សមមិត្ត នង - សួន ដែលជាអ្នកដឹកនាំម្នាក់របស់ក្រុម " ប្រជាជន "។ តាមបញ្ជាពីខាងលើ តុលាការសឹកបានកាត់ទោសឱ្យប្រហារជីវិតសមមិត្ត នង - សួន នៅខែឧសភា ឆ្នាំ១៩៦២។

នយោបាយក្នុងប្រទេសរបស់ ន. សីហនុ យោងទៅលើគោលការណ៍ជាមូលដ្ឋាន នៃការថ្លឹងឱ្យស្មើរវាងចរន្តបដិបក្ខទាំងពីរ ដែលម្ខាងតំណាងដោយកម្លាំងប្រជាធិបតេយ្យបដិវត្តន៍ ហើយម្ខាងទៀតតំណាងដោយមជ្ឈដ្ឋានខាងស្តាំបំផុត។ យុទ្ធសាស្ត្រនៃការថ្លឹងឱ្យស្មើ និងការប្រយុទ្ធលើ " រណសិរ្សពីរបែប " បានប្រព្រឹត្តទៅនៅក្នុងស្ថានភាព នៃការកម្រិតសេរីភាពនយោបាយ និងការដកហូតអំណាចពីមុខងារ របស់អង្គការតំណាងនីតិប្បញ្ញត្តិ ក្នុងគោលបំណងនឹងពង្រឹង របបគ្រប់គ្រងផ្ទាល់ខ្លួនរបស់នរោត្តម សីហនុ។

ព្រឹត្តិការណ៍នានានៃនយោបាយបែបនេះ នៅពេលនោះ គឺទាក់ទងទៅនឹងការសាកល្បងបង្កើតសភាខេត្ត ដែលត្រូវបានចាត់ថា ជាអង្គការនីតិប្រតិបត្តិស្វ័យភាពនៅក្នុងខេត្តនីមួយៗ។

សូមរំលឹកថា ជាយូរមកហើយ នៅប្រទេសកម្ពុជា ចៅហ្វាយខេត្ត និងចៅហ្វាយស្រុកជាអ្នកកាន់កាប់អំណាចទាំងអស់នៅក្នុងកណ្តាប់ដៃរបស់ខ្លួន នៅតាមខេត្ត តាមស្រុក និងឃុំ។ នៅខែមករា ឆ្នាំ១៩៥៦ មានការបោះឆ្នោតជ្រើសរើសសភាខេត្ត។ក៏ប៉ុន្តែ នៅពេលនោះ សភាខេត្តបានចាប់ផ្តើមបំពេញការងាររបស់ខ្លួនបន្ទាប់ពីពេលបោះឆ្នោតពីរឆ្នាំ គឺនៅខែធ្នូ ឆ្នាំ១៩៥៧។ ការនេះបញ្ជាក់ឱ្យឃើញថា តាំងពីដើមទីមក នៅសភាខេត្តមានការធ្វើការទិតៀន ជាខ្លាំងដល់អំពីពុករលួយនៅក្រសួងរដ្ឋបាលនានា និងដល់ការយឺតយ៉ាវក្នុងការអនុវត្តកម្មវិធីនយោបាយ"សង្គម"។នៅក្នុងអំឡុងពេលនៃឆ្នាំ១៩៥៦-១៩៥៧ ពួកមន្ត្រីនៃការិយាល័យនិយមជាន់ខ្ពស់ បានធ្វើការសម្អាតដល់អ្នកតំណាងសភាខេត្តនានា។

សកម្មភាពរបស់សភាខេត្តនាឆ្នាំ១៩៥៨ - ១៩៥៩ បាន បញ្ជាក់ឱ្យឃើញនូវទំនាស់ និងការប៉ះទង្គិចជានិច្ចរបស់សភានេះ ជាមួយអំណាចរបស់រដ្ឋបាលកណ្តាល។ នៅឆ្នាំ១៩៥៩ ដោយ ការប្រទេ្បាតខឹងនឹងពាក្យទិតៀនគ្រប់បែបយ៉ាង ន. សីហនុ បាន ដាក់បញ្ហាអំពីការបំបិទសភាខេត្ត ឱ្យអ្នកស្រុកធ្វើប្រជាមតិ ពិសេស។ ក្នុងការបំភ័យប្រជាជនចំពោះអំពើវិទ្ធង្សនាបំបែក បំបាក់សាមគ្គីជាតិ អង្គការដឹកនាំ "សង្គម" បានសម្រេចគោលដៅ របស់ខ្លួន គឺថាប្រជាមតិបានយល់ស្របតាមសេចក្តីសម្រេចស្តី អំពីការបំបិទស្ថាប័ននៃសភាខេត្ត។

ចលនាសហជីពដែលកំពុងលូតលាស់ នៅក្នុងប្រទេស ត្រូវបានអនុញ្ញាតឱ្យបង្កើតឡើង នៅក្នុងលក្ខខណ្ឌដ៏តានតឹង បំផុត។ នៅឆ្នាំ១៩៥៦ មានការបង្កើតសហជីព៣ គឺសហជីព កម្មករកម្ពុជា សហជីពកម្មករកំពង់ផែ និងសហជីពអ្នក អយស្ម័យយាន។ នៅក្នុងលក្ខន្តិកៈ នៃអង្គការសហជីពទាំងនេះ មានសរសេរបញ្ជាក់ថា ភារកិច្ចដ៏ចំបងរបស់គេស្ថិតនៅលើការ បង្រួបបង្រួមកម្មករ ក្នុងគោលបំណងការពារផលប្រយោជន៍ អាជីវកម្មរបស់គេទាំងឡាយ។ នរោត្តម សីហនុ ត្រូវបានតែងតាំង ជាប្រធានសហជីព ដែលធំជាងគេ គឺសហជីពកម្មករកម្ពុជា រីឯ អ្នកដឹកនាំដទៃរបស់អង្គការ " សង្គម " ត្រូវបានតែងតាំងឱ្យធ្វើជា ប្រធានសហជីពកម្មករកំពង់ផែ និងសហជីពអ្នកអយស្ម័យយាន។ ដោយមានគោលបំណង ត្រួតត្រាលើចលនាសហជីពនៅក្នុង ក្របខ័ណ្ឌនៃការទាមទារខាងសេដ្ឋកិច្ចរបស់គេ អង្គការដឹកនាំ " សង្គម " បានបញ្ចូល " ខ " មួយ នៅក្នុងលក្ខន្តិកៈសហជីព ដែលបញ្ជាក់ អំពីការហាមឃាត់ការពិភាក្សាបញ្ហានយោបាយ

នៅក្នុងសម័យប្រជុំកម្មករនានា។ នៅរដូវក្ដៅឆ្នាំ១៩៥៩ ក្រឹត្យចេញពីទីស្ដីការរដ្ឋមន្ត្រីក្រសួងការងារ បានបញ្ជាក់អំពីការហាមឃាត់ មិនឱ្យធ្វើកូដកម្ម។ នៅទីបំផុត សកម្មភាពរបស់ចលនាសហជីព បានប្រែទៅជាសកម្មភាពស្ថិតក្នុងការហាមឃាត់ ហើយសហជីព បានក្លាយទៅជាខឿននយោបាយឧបត្ថម្ភដល់រដ្ឋាភិបាលអង្គការ " សង្គម " ទៅវិញ។

សមាជជាតិ គឺជាស្ថាប័ន និងជាសម្ភារៈដ៏សំខាន់សម្រាប់បម្រើរបបអំណាចផ្ទាល់ខ្លួនរបស់នរោត្ដម សីហនុ។ នៅពេលដំបូង សមាជទាំងនេះ គឺជាមហាសន្និបាតជាតិទូទៅរបស់អង្គការ " សង្គម " ហើយដែលស្របទៅតាមលក្ខន្តិកៈ ត្រូវបើកសម័យប្រជុំពីរដង ក្នុងមួយឆ្នាំ។ តាមពិត ការដឹកនាំសកម្មភាពរបស់សមាជជាតិទាំងនេះ ស្ថិតនៅទាំងមូលក្នុងកណ្ដាប់ដៃរបស់នរោត្ដម សីហនុ និងអ្នកហែហមរបស់ខ្លួន។ នៅខែធ្នូ ឆ្នាំ១៩៥៧ អង្គការដឹកនាំ " សង្គម " បានសម្រេចបញ្ចូល " ខ " ពិសេសមួយក្នុងរដ្ឋធម្មនុញ្ញ ដែលស្ដីអំពីការបង្កើតសមាជជាតិថា ជាស្ថាប័ននយោបាយរដ្ឋ។ រដ្ឋធម្មនុញ្ញបានចុះបញ្ជាក់ថា សេចក្ដីសម្រេចនានា របស់សមាជជាតិត្រូវទទួលទុកដូចជា សេចក្ដីទូន្មានដល់រដ្ឋាភិបាល និងរដ្ឋសភា។

អង្គការដឹកនាំ " សង្គម " បានប្រើប្រាស់វេទិកាសមាជជាតិ ដើម្បីពង្រឹងឥរិយាបថនយោបាយរបស់ខ្លួន។ សេចក្ដីសម្រេចនានា របស់សមាជជាតិ ដើម្បីការពារនយោបាយអព្យាក្រឹតនៅសម័យកាលនៃឆ្នាំ៥០ បានជួយដល់អង្គការ " សង្គម " ឱ្យវាយបំបាត់សកម្មភាពប្រឆាំងពីសំណាក់មជ្ឈដ្ឋាននិយមនយោបាយចក្រពត្តិ ហើយនៅឆ្នាំ១៩៥៨ បានជួយឱ្យអង្គការ " សង្គម "

អាចរំលាយរដ្ឋសភា ដែលនៅក្នុងនោះ មានអ្នកតំណាងរាស្ត្រភាគច្រើន ជាតំណាងក្រុមប្រឆាំងខាងស្តាំ។ នៅពេលជាមួយគ្នា ព្រឹត្តិការណ៍នានាបានផ្តល់ឱកាសល្អឱ្យ នរោត្តម សីហនុ អាចប្រមូលផ្តុំនូវអំណាចនយោបាយទាំងអស់ នៅក្នុងកណ្តាប់ដៃរបស់ខ្លួន។ នៅក្នុងការរំលំរដ្ឋសភាមុននីតិកាលនៅឆ្នាំ១៩៥៨ នរោត្តម សីហនុ បានសម្រេចលើការត្រួតពិនិត្យរបស់ខ្លួនលើការរៀបចំសម័យឃោសនាបោះឆ្នោតរបស់អង្គការ “ សង្គម ”។ ចាប់តាំងពីឆ្នាំ ១៩៥៨ រហូតដល់ឆ្នាំ១៩៦៦ នរោត្តម សីហនុ ផ្ទាល់ បានជ្រើសរើសបញ្ជីបេក្ខជនអង្គការ “ សង្គម ” មុនពេលឈរឈ្មោះក្នុងសម័យបោះឆ្នោត។ សកម្មភាពបែបនេះ បានផ្តល់លទ្ធភាពដល់ នរោត្តម សីហនុ ឱ្យបង្កើតបាននូវសមាសភាពនៃបក្សពួករបស់ខ្លួនក្នុងរដ្ឋសភា។

ការប្រមូលផ្តុំអំណាចដាន់ខ្ពស់ផ្តាច់មុខ ផ្ទាល់ខ្លួនរបស់ នរោត្តម សីហនុ មានកម្រិតខ្ពស់បំផុតនៅឆ្នាំ១៩៦០ គឺនៅពេលដែលរដ្ឋសភាជាតិបានធ្វើសេចក្តីសម្រេចតែងតាំងគាត់ឱ្យធ្វើជាប្រមុខរដ្ឋ ដែលប្រកបដោយការប្រមូលផ្តុំអំណាចនៅក្នុងកណ្តាប់ដៃរបស់គាត់ ហើយដែលមានការកម្រិតអំណាចទាំងនេះតែនៅក្នុងអត្ថបទនៃរដ្ឋធម្មនុញ្ញប៉ុណ្ណោះ។

ការតែងតាំងរបបគ្រប់គ្រងនៃអំណាចផ្តាច់មុខផ្ទាល់ខ្លួនរបស់ប្រមុខរដ្ឋ នៅប្រទេសកម្ពុជា បានបង្កើតឱ្យមានលក្ខណៈដ៏ស្មុគស្មាញប្រកបដោយបដិបក្ខកម្ម នៅក្នុងការវិវត្តខាងនយោបាយសេដ្ឋកិច្ច និងសង្គមកិច្ចនៅក្នុងបរិយាកាសនៃការបង្កើនកម្រិតនយោបាយវាតទីនិយម របស់ចក្រពត្តិនិយម

អាមេរិក នៅឥណ្ឌូចិន នៅក្នុងចុងអំឡុងឆ្នាំទី៥០ - ដើមអំឡុងឆ្នាំទី៦០។

លុះកណា សហរដ្ឋអាមេរិក កាន់តែលង់ខ្លួនចូលក្នុង“សង្គ្រាមដ៏កខ្វក់” នៅវៀតណាម លុះកនោះ ចក្រពត្តិនិយមកាន់តែខិតខំប្រើការសាកល្បងគ្រប់បែបយ៉ាង ដើម្បីធ្វើឱ្យប្រទេសកម្ពុជា នេះប្រែទៅជាមូលដ្ឋាន នៃអំពើឈ្លានពានរបស់ខ្លួននៅឥណ្ឌូចិនទាំងមូល។

នៅក្នុងការប្រើប្រាស់មជ្ឈដ្ឋានប្រតិកិរិយានៅវៀតណាមខាងត្បូង និងថៃឡង់ដ៍ សហរដ្ឋអាមេរិក បានបន្តបង្កើតវិបត្តិខាងនយោបាយ និងយោធាប្រឆាំងប្រទេសកម្ពុជា តទៅទៀត។ នៅទីក្រុងព្រៃនគរ និងទីក្រុងបាងកក ពួកប្រតិកិរិយាបានធ្វើការឃោសនាយ៉ាងខ្លាំងប្រឆាំងប្រទេសកម្ពុជា ហើយនៅក្នុងនេះមានការទាមទារឱ្យពិនិត្យសាជាថ្មី នូវព្រំប្រទល់របស់ប្រទេសកម្ពុជា ក្នុងគោលបំណងដើម្បីឈ្លានពានកាន់កាប់លើទឹកដីដែលស្ថិតនៅតំបន់ព្រំប្រទល់ខ្លះ។ ពួកប្រតិកិរិយាថៃឡង់ដ៍ និងព្រៃនគរ បានប៉ុនប៉ងបញ្ឆេះទំនាស់ស្តីអំពីបញ្ហាទឹកដី ដោយការបង្កបង្កើតហេតុតាមយោធា នៅតាមព្រំប្រទល់ប្រទេសនៅសម័យភាគខាងចុងឆ្នាំ១៩៦២។ នយោបាយបំភ័យថា៖ “ សង្គ្រាមនឹងកើតមានឡើង ” អនុវត្តដោយបន ង៉ូ ឌិញយៀម និងដោយមជ្ឈដ្ឋានយោធានិយមថៃឡង់ដ៍ ប្រឆាំងប្រទេសកម្ពុជា មានកម្រិតកាន់តែខ្លាំងកាន់តែធ្ងន់ធ្ងរ។ សកម្មភាពជាសត្រូវទាំងនេះ បានជំរុញឱ្យរដ្ឋាភិបាលប្រទេសកម្ពុជា ធ្វើសេចក្តីសម្រេចស្តីអំពីការផ្តាច់ចំណងទូតជាមួយទីក្រុងព្រៃនគរ នៅខែសីហា ឆ្នាំ១៩៦៣។ ការផ្តាច់ចំណងទូតជាមួយទីក្រុងព្រៃនគរ បានធ្វើឡើងនៅក្នុង

ស្ថានភាពនៃការបង្កើនសកម្មភាពវិទ្ធង្សនា របស់អង្គការកៀស ខ្លួន " ខ្មែរសេរី " ដែលតែងបញ្ជូនក្រុមអ្នកធ្វើវិទ្ធង្សនារបស់ខ្លួន មកលើទឹកដីប្រទេសកម្ពុជា។ អ្នកធ្វើវិទ្ធង្សនាបែបនេះមួយក្រុម ត្រូវបានចាប់បាននៅរដូវវស្សាឆ្នាំ១៩៦៣។ ឯកសារនានារបស់ ក្រុមនេះ បានបញ្ជាក់ឱ្យឃើញនូវភស្តុតាងថ្មីៗស្តីអំពីការទាក់ទង ដ៏ជិតស្និទ្ធរបស់អង្គការនេះ ជាមួយអង្គការចារកិច្ចអាមេរិក។

នៅរដូវក្តៅឆ្នាំ១៩៦៣ អង្គការ " ខ្មែរសេរី " បានបង្កើត ស្ថានីយផ្សាយវិទ្យុមួយយ៉ាងខ្លាំង នៅតាមព្រំប្រទល់ប្រទេស កម្ពុជា ហើយដោយមានការគាំទ្រពីសហរដ្ឋអាមេរិក ពួកនេះ បានធ្វើការផ្សាយដោយសេចក្តីអំពាវនាវដ៏ចំហ ដើម្បីរំលំរដ្ឋាភិបាល ប្រទេសកម្ពុជា។

ការកៀបសង្កត់ពីខាងក្រៅ និងសកម្មភាពប្រតិកិរិយានៅ ខាងក្នុងប្រទេស ដែលមានកម្រិតកាន់តែខ្លាំងឡើង បានជំរុញ ឱ្យប្រទេសកម្ពុជា ចាប់ផ្តើមពិនិត្យសាជាថ្មីយ៉ាងជ្រាលជ្រៅនូវ ទំនាក់ទំនងរបស់ខ្លួនជាមួយទីក្រុងវ៉ាស៊ីនតោន។ ជាពិសេស ការពិនិត្យ និងការដោះស្រាយបញ្ហានេះ បានជំរុញឱ្យប្រទេស កម្ពុជា ឈប់ទទួលជំនួយសេដ្ឋកិច្ច និងយោធាអាមេរិក ដោយ ហេតុថា ជំនួយនេះ មួយចំនួនធំបានប្រែទៅជាអាវុធសម្រាប់ សកម្មភាពវិទ្ធង្សនាទៅវិញ។ ក្នុងការផ្តល់ជំនួយយោធារបស់ខ្លួន សហរដ្ឋអាមេរិក បានដាក់លក្ខខណ្ឌ ដែលបានធ្វើឱ្យមានការ កម្រិតដល់សិទ្ធិរស់នៅក្នុងអធិបតេយ្យភាព របស់ប្រទេសកម្ពុជា។ ហេតុនេះហើយ បានជានៅឆ្នាំ១៩៥៨ អគ្គរដ្ឋទូតអាមេរិក ប្រចាំ ទីក្រុងភ្នំពេញ បានប្រកាសដោយត្រង់ដល់រដ្ឋាភិបាលកម្ពុជា ថា សហរដ្ឋអាមេរិក ហាមប្រាម មិនឱ្យប្រើគ្រឿងសព្វាវុធអាមេរិក

ប្រឆាំងពួក “សម្ពន្ធមិត្តសហរដ្ឋអាមេរិក ”ឡើយ ដែលនៅក្នុងនេះ មានរបបព្រៃនគរ និងរដ្ឋាភិបាលថៃឡង់ដ៍។ អ្នកតំណាងមជ្ឈដ្ឋានទូតនៅវ៉ាស៊ីនតោន បានគូសបញ្ជាក់ថា គ្រឿងអាវុធផ្តល់ ដោយសហរដ្ឋអាមេរិក ដល់ប្រទេសកម្ពុជា ត្រូវតែប្រើប្រាស់សម្រាប់តែតស៊ូប្រឆាំងនឹង “កម្លាំងកុម្មុយនិស្តនិយម ” តែម៉្យាង។ សហរដ្ឋអាមេរិក បានធ្វើការឃោសនាគំរាមកំហែងដល់ប្រទេសកម្ពុជា ថាខ្លួននឹងបញ្ឈប់ការផ្តល់ជំនួយគ្រឿងប្រដាប់ប្រដារយោធា និងគ្រឿងឧបភោគបរិភោគ ប្រសិនបើប្រទេសកម្ពុជា ខំសាកល្បងរកជំនួយយោធាពីសំណាក់ប្រទេសសង្គមនិយមនានា។ ទីក្រុងវ៉ាស៊ីនតោន បានឈប់ផ្តល់គ្រឿងអាវុធការពារខាងផ្លូវអាកាស។ ដូច្នេះ បានជានយោបាយសហរដ្ឋអាមេរិក ក្នុងការផ្តល់ជំនួយយោធាដល់ប្រទេសកម្ពុជា បានបន្ទាបជាអតិបរមានូវលទ្ធភាពរបស់ប្រទេសនេះ ក្នុងការបង្កើនសមត្ថភាពក្នុងកិច្ចការពាររបស់ប្រទេសកម្ពុជា។ ការសម្រេចនូវកម្មវិធីជំនួយសេដ្ឋកិច្ចសហរដ្ឋអាមេរិក បានបង្កើតជាផលវិបាកដ៏អាក្រក់ ដោយហេតុថា ជំនួយនេះបានជំរុញសកម្មភាពរបស់វណ្ណៈគហបតីកុំប្រាឌ័រ ដែលមានការទាក់ទងនឹងកម្លាំងប្រឆាំងជាតិ ឱ្យលូតលាស់កាន់តែខ្លាំងឡើងទៅវិញ។

ព្រឹត្តិការណ៍ឆ្នាំ១៩៥៥ - ១៩៦៣ បានបញ្ជាក់ឱ្យឃើញថាជំនួយយោធា និងសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក បានបង្កើតឱ្យមានការគំរាមកំហែងដល់សន្តិសុខជាតិ នៃប្រទេសកម្ពុជា កាន់តែខ្លាំងឡើង។ យោងទៅតាមកាលៈទេសៈបែបនេះ នាខែវិច្ឆិកាឆ្នាំ១៩៦៣ រដ្ឋាភិបាលប្រទេសកម្ពុជា បានអនុម័តលើសេចក្តីសម្រេចថា ឈប់ទទួលជំនួយអាមេរិក គ្រប់បែបយ៉ាង។

ការបញ្ឈប់ជំនួយសហរដ្ឋអាមេរិក មានការទាក់ទងនឹងការសោកល្បងរបស់រដ្ឋាភិបាលប្រទេសកម្ពុជា ដើម្បីធ្វើយ៉ាងណាឱ្យមានកិច្ចធានារ៉ាប់រងអន្តរជាតិ ស្តីអំពីបូរណភាពទឹកដី និងអព្យាក្រឹតភាពរបស់ប្រទេស។ នៅខែសីហា ឆ្នាំ១៩៦២ រដ្ឋាភិបាលប្រទេសកម្ពុជា បានធ្វើសេចក្តីអំពាវនាវដល់រដ្ឋាភិបាលនានាដែលជាសមាជិកចូលរួមក្នុងសន្និសញ្ញាហ្សឺណែវ នាឆ្នាំ១៩៦២ ស្តីអំពីប្រទេសឡាវ ដើម្បីសុំឱ្យកោះហៅសន្និសីទអន្តរជាតិមួយស្តីអំពីប្រទេសកម្ពុជា ដែលនៅក្នុងនេះ ត្រូវមានប្រទេសចំនួន១៤ចូលរួបរួម ដើម្បីដោះស្រាយអំពីកិច្ចធានារ៉ាប់រងអន្តរជាតិនៃបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិប្រទេសកម្ពុជា។ សេចក្តីអំពាវនាវនេះ បានទទួលការគាំទ្រពីសំណាក់សហភាពសូវៀត និងបណ្តាប្រទេសសង្គមនិយមដទៃ ក៏ប៉ុន្តែ នៅពេលជាមួយគ្នា សហរដ្ឋអាមេរិក បានប្រកាន់ឥរិយាបថផ្ទុយស្រឡះ។ នៅក្នុងសេចក្តីឆ្លើយតបជាផ្លូវការរបស់ខ្លួន ទីក្រុងវ៉ាស៊ីនតោន មិនបានយល់ព្រម តាមការកោះហៅប្រជុំសន្និសីទអន្តរជាតិបែបនេះទេ។ ក្នុងការកែតម្រូវនូវឥរិយាបថរបស់ខ្លួន រដ្ឋាភិបាលសហរដ្ឋអាមេរិក បានប្រកាសថា កិច្ចធានារ៉ាប់រងអន្តរជាតិនៃប្រទេសកម្ពុជា មិនអាចប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌសន្និសញ្ញារួមរបស់ប្រទេសទាំង១៤បានឡើយ ក៏ប៉ុន្តែ អាចប្រព្រឹត្តទៅបានតែតាមមាគ៌ា នៃសេចក្តីថ្លែងការណ៍ឯកតោភាគីរបស់ប្រទេសដែលទាក់ទងក្នុងរឿងនេះ។

ទីក្រុងព្រៃនគរ និងបាងកក ក៏មិនព្រមទទួលតាមសំណើស្តីអំពីការកោះសន្និសីទអន្តរជាតិនេះដែរ ហើយការមិនយល់ព្រមរបស់ប្រទេសទាំងពីរនេះ គ្មានបញ្ជាក់អ្វីដែលស្តីអំពីទម្រង់

ផ្សេងៗចំពោះការដោះស្រាយកិច្ចធានារ៉ាប់រងអន្តរជាតិ នៃប្រទេសកម្ពុជា បន្តិចបន្តួចសោះ។ នៅក្នុងលក្ខខណ្ឌបែបនេះ ការយល់ព្រមរបស់អាមេរិក ក្នុងការទទួលស្គាល់ជាឯកតោភាគីនូវអព្យាក្រឹតភាពប្រទេសកម្ពុជា បានប្រែក្លាយទៅជាសេចក្តីថ្លែងការណ៍តែខាងក្រៅ ឥតខ្លឹមសារ ដោយហេតុថា ទីក្រុងវ៉ាស៊ីនតោន នៅតែរក្សាលទ្ធភាពរបស់ខ្លួនក្នុងការបន្តសកម្មភាពវិទ្ធង្សនា ហើយដើម្បីសម្រេចគោលដៅនេះ សហរដ្ឋអាមេរិក បានប្រើប្រាស់រដ្ឋការព្រៃនគរ និងប្រទេសថៃឡង់ដ៍។

ការប្រឹងប្រែងរបស់ប្រទេសកម្ពុជា តម្រង់ទៅលើកិច្ចធានារ៉ាប់រងអន្តរជាតិនៃអធិបតេយ្យភាពរបស់ខ្លួន បានប្រព្រឹត្តទៅនៅក្នុងស្ថានភាពតានតឹងនៃទំនាស់រវាងបារាំង និងអាមេរិកនៅឥណ្ឌូចិន។ នៅឆ្នាំ១៩៦២ - ១៩៦៤ ប្រទេសបារាំង បានបង្កើនសកម្មភាពនយោបាយរបស់ខ្លួននៅឥណ្ឌូចិន។ ដោយឆ្លៀតឱកាសក្នុងភាពអន់ខ្សោយ នៃស្ថានភាពរបស់សហរដ្ឋអាមេរិក នៅតំបន់នេះ ដែលកើតមកពីការរីកចម្រើន នៃចលនាតស៊ូរដោះជាតិ រដ្ឋាភិបាលបារាំង ប៉ុនប៉ងពង្រឹងឥទ្ធិពលរបស់ខ្លួននៅប្រទេសនានា នៃឥណ្ឌូចិន។ នៅឆ្នាំ១៩៦២ រដ្ឋាភិបាលរបស់ឧត្តមសេនីយ៍ ដឺហ្គោល បានធ្វើសេចក្តីថ្លែងការណ៍ទិតៀនប្រឆាំងនយោបាយអាមេរិក នៅតំបន់នោះ ហើយបានធ្វើសំណើស្តីអំពីអព្យាក្រឹតូបនីយកម្ម នៃវៀតណាមខាងត្បូង។ នៅឆ្នាំដដែល រដ្ឋាភិបាលបារាំង បានគាំទ្រដល់គំរោង នៃកិច្ចធានារ៉ាប់រងអន្តរជាតិដល់ប្រទេសកម្ពុជា។ នៅរដូវរងា និងរដូវក្តៅឆ្នាំ១៩៦៤ ប្រទេសកម្ពុជា និងប្រទេសបារាំង បានធ្វើការចរចាអំពីបញ្ហានៃការពង្រីកទំនាក់ទំនងខាងនយោបាយ សេដ្ឋកិច្ច និង

វប្បធម៌ រវាងប្រទេសទាំងពីរ។ ជាលទ្ធផល នៃការចរចានេះ នៅរដូវក្តៅឆ្នាំ១៩៦៤ នៅទីក្រុងប៉ារីស មានពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីអំពីការផ្តល់ជំនួយយោធា និងសេដ្ឋកិច្ច ដោយប្រទេសបារាំង ដល់ប្រទេសកម្ពុជា។

នៅសម័យកាលនោះ ការគាំទ្រខាងនយោបាយសេដ្ឋកិច្ច និងខាងផ្លូវចិត្តរបស់សហភាពសូវៀត និងបណ្តាប្រទេសសង្គមនិយមដទៃ បានផ្តល់អត្ថន័យដ៏ធំធេងដល់ប្រទេសកម្ពុជា។ ក្នុងឋានៈជាប្រទេសមួយដែលជាសមាជិកប្រធាន នៃសន្និសញ្ញាហ្សឺណែវ ឆ្នាំ១៩៥៤ ស្តីអំពីឥណ្ឌូចិន សហភាពសូវៀត តែងដឹកនាំមាគ៌ានយោបាយឥតល្អៀង ក្នុងកិច្ចការពារអធិបតេយ្យភាពប្រទេសកម្ពុជា ហើយបានគាំទ្រយ៉ាងសកម្មដល់សំណើនានាស្តីអំពីការកសាងប្រព័ន្ធដ៏ស័ក្តិសិទ្ធិ នៃកិច្ចធានាប៉ាប់រងអន្តរជាតិដល់អព្យាក្រឹតភាព និងបូរណភាពទឹកដីនៃប្រទេសកម្ពុជា។

នៅខែវិច្ឆិកា ឆ្នាំ១៩៦៣ រដ្ឋាភិបាលប្រទេសកម្ពុជា បានធ្វើសេចក្តីថ្លែងបញ្ជាក់ នូវការផ្តើមគំនិតជាថ្មីក្នុងការកោះហៅប្រជុំសន្និសីទអន្តរជាតិមួយ ស្តីអំពីប្រទេសកម្ពុជា ដោយការរួបរួមរបស់សហរដ្ឋអាមេរិក និងរបស់ប្រទេសជាសាមីខ្លួនដទៃ។ ក៏ប៉ុន្តែ ដូចពេលមុនៗ សេចក្តីផ្តើមគំនិតនេះបានជួបប្រទះនឹងសកម្មភាពទំនាស់របស់សហរដ្ឋអាមេរិក។ យោងទៅតាមឥរិយាបថអវិជ្ជមានរបស់សហរដ្ឋអាមេរិក នាខែកុម្ភៈ ឆ្នាំ១៩៦៤ ប្រទេសកម្ពុជា បានធ្វើសំណើសម្របសម្រួលមួយ ស្តីអំពីការកោះហៅប្រជុំសន្និសីទចតុភាគីមួយ ដែលនៅក្នុងនេះ មានការចូលរួមនៃសហរដ្ឋអាមេរិក ប្រទេសថៃឡង់ វៀតណាមខាងត្បូង និងកម្ពុជា។ តាមទម្រង់ខាងក្រៅ សហរដ្ឋអាមេរិក មិនបានថ្លែង

ប្រឆាំងនឹងសំណើនេះទេ ក៏ប៉ុន្តែ ប្រទេសនេះ បានចោទលក្ខខណ្ឌជាដំបូង ក្នុងការកោះហៅប្រជុំសន្និសីទចតុភាគី ដោយសេចក្តីទាមទារឱ្យបង្កើតគណៈកម្មការចម្រុះមួយ ដែលមានការចូលរួមរបស់ប្រទេសថៃឡង់ដ៍ និងវៀតណាមខាងត្បូង ដើម្បី " បញ្ជាក់ " ព្រំប្រទល់រដ្ឋ នៃប្រទេសកម្ពុជា ជាមុនសិន។ លក្ខខណ្ឌបែបនេះត្រូវបានទាត់ចោលដោយប្រទេសកម្ពុជា ព្រោះថាលក្ខខណ្ឌនេះអាចបង្កើតឱ្យមានសេចក្តីសង្ស័យ ដល់ភាពត្រឹមត្រូវតាមច្បាប់នៃព្រំប្រទល់ប្រទេសកម្ពុជា ដែលទទួលស្គាល់ដោយសន្ធិសញ្ញាអន្តរជាតិនានា ហើយការទទួលស្គាល់ទាំងនេះ មានសេចក្តីបញ្ជាក់នៅក្នុងសន្ធិសញ្ញាទីក្រុងវ៉ាស៊ីនតោន នាឆ្នាំ១៩៤៦។

ការសំដែងនូវបំណងដ៏រឹងរូសរបស់សហរដ្ឋអាមេរិក ក្នុងការមិនព្រមទទួលស្គាល់ភាពត្រឹមត្រូវ តាមច្បាប់នៃព្រំប្រទល់បច្ចុប្បន្នរបស់ប្រទេសកម្ពុជា បានផ្តល់ឥទ្ធិពលខ្លះៗនៅលើនយោបាយប្រទេសនេះ ទាក់ទងទៅនឹងកងកម្លាំងស្នេហាមាតុភូមិនៅវៀតណាម។ នៅឆ្នាំ១៩៦៤ មានការចរចាជាផ្លូវការរវាងប្រទេសកម្ពុជា និងសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម រវាងប្រទេសកម្ពុជា និងរណសិរ្សសេរីកាជាតិវៀតណាមខាងត្បូង ស្តីអំពីការរៀបចំ និងការពង្រីកទំនាក់ទំនងរវាងគ្នានឹងគ្នា នៅលើមូលដ្ឋាននៃសន្ធិសញ្ញាហ្សឺណែវ នាឆ្នាំ១៩៥៤។ នៅខែវិច្ឆិកាឆ្នាំ១៩៦៤ អង្គការដឹកនាំ " សង្គម " បានស្នើឡើងឱ្យធ្វើការកោះហៅប្រជុំសន្និសីទ នៃអង្គការស្នេហាមាតុភូមិ របស់ប្រជាជនទាំងបីប្រទេស វៀតណាម កម្ពុជា និងឡាវ។ សន្និសីទនេះ ត្រូវបានគេឱ្យឈ្មោះថា ជាសន្និសីទប្រជាជននានានៅឥណ្ឌូចិន ហើយបានប្រព្រឹត្តទៅនៅខែមីនា ឆ្នាំ១៩៦៥ នៅទីក្រុងភ្នំពេញ។ នៅ

សម័យប្រជុំសន្និសីទនេះ មានការចូលរួមនៃអ្នកតំណាងអង្គការស្នេហាមាតុភូមិ នៃប្រទេសនានានៅឥណ្ឌូចិន ចំនួន៣៩ ដែលនៅក្នុងនេះមានអ្នកតំណាងរណសិរ្សមាតុភូមិ នៃសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម អ្នកតំណាងរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង អ្នកតំណាងរណសិរ្សស្នេហាមាតុភូមិប្រទេសឡាវ ព្រមទាំងអ្នកតំណាង “ សង្គមរាស្ត្រនិយម ” និងអ្នកតំណាងនៃអង្គការនយោបាយដទៃទៀត។

ភារកិច្ចដ៏សំខាន់របស់សន្និសីទនៅពេលនោះ គឺការដោះស្រាយបញ្ហារៀបចំសន្តិភាពឡើងវិញនៅឥណ្ឌូចិន និងការធានារ៉ាប់រងដល់ឯករាជ្យភាពជាតិរបស់ប្រជាជននានានៅឥណ្ឌូចិន។ នៅសម័យនៃការប្រជុំសន្និសីទ សមាជិកនានាមានរបៀប និងមាគ៌ាដោះស្រាយបញ្ហាដ៏ស្មុគស្មាញនេះខុសៗគ្នា។ ក៏ប៉ុន្តែ កាលៈទេសៈបែបនេះ មិនបានរំខានដល់គេទាំងឡាយឱ្យសំដែងនូវឯកភាពចំពោះទស្សនៈ និងការវាយតម្លៃដល់ធាតុពិតនៃនយោបាយឈ្លានពានអាមេរិក នៅឥណ្ឌូចិន។ នៅក្នុងសេចក្តីសម្រេចចិត្តរួម អនុម័តជាឯកច្ឆ័ន្ទនាថ្ងៃទី៨ មីនា ឆ្នាំ១៩៦៥ សមាជិកនៃសន្និសីទទាំងអស់បានផ្តន្ទាទោសយ៉ាងម៉ឺងម៉ាត់ ដល់អំពើជ្រៀតជ្រែករបស់សហរដ្ឋអាមេរិក មកលើកិច្ចការផ្ទៃក្នុង នៃប្រទេសនានានៅឥណ្ឌូចិន ហើយបានទទួលស្គាល់កិច្ចការចាំបាច់ ដើម្បីពង្រឹងរណសិរ្សនៃការតស៊ូប្រឆាំងចក្រពត្តិនិយម និងអាណានិគមនិយមថ្មី។ នៅសម័យប្រជុំសន្និសីទ គណៈប្រតិភូប្រទេសកម្ពុជាបានធ្វើសេចក្តីថ្លែងការណ៍ ស្តីអំពីការគាំទ្ររបស់ខ្លួនដល់កងកម្លាំងប្រឆាំងចក្រពត្តិនិយមនៅប្រទេសវៀតណាម និងប្រទេស

ឡាវ ដែលកំពុងធ្វើយុទ្ធនាការប្រឆាំងអំពើឈ្លានពានអាមេរិក នៅឥណ្ឌូចិន។

ប្រតិកម្មជាចម្លើយរបស់ទីក្រុងវ៉ាស៊ីនតោន ចំពោះនយោបាយសាមគ្គីនៃប្រទេសកម្ពុជា ជាមួយកងកម្លាំងសេរីកានៅឥណ្ឌូចិន គឺការចូលរួមដោយប្រយោលនៃកងកម្លាំងប្រដាប់អាវុធសហរដ្ឋអាមេរិក ក្នុងការបង្កបង្កើតវិបត្តិនៅតាមព្រំប្រទល់នៃប្រទេសកម្ពុជា។ ចាប់តាំងពីឆ្នាំ១៩៦៥ កងអាកាសចរណ៍អាមេរិក បានហោះទម្លាក់គ្រាប់បែកជារឿយៗមកលើតំបន់ព្រំប្រទល់នៃប្រទេសកម្ពុជា ហើយអំពើរំលោភនេះបានទៅជាមូលហេតុដ៏ធំនាំឱ្យរដ្ឋាភិបាលប្រទេសកម្ពុជា ផ្ដាច់ការទាក់ទងខាងផ្លូវទូតជាមួយសហរដ្ឋអាមេរិក នាខែឧសភា ឆ្នាំ១៩៦៥។

នៅឆ្នាំ១៩៦៧ ទីបញ្ជាការយោធារដ្ឋអាមេរិក នៅឥណ្ឌូចិន បានប្រកាសជាផ្លូវការនូវ “ សិទ្ធិក្នុងការដេញតាមបច្ចាមិត្ត ” របស់ខ្លួននៅលើទឹកដីប្រទេសកម្ពុជា។ អំពើបែបនេះ គឺជាអំពើឈ្លានពានដ៏គ្រោតគ្រាតទៅលើច្បាប់អន្តរជាតិជាធរមាន និងជាលេសថ្មីនៅក្នុងនយោបាយ នៃការគំរាមកំហែងខាងយោធាមកលើប្រទេសកម្ពុជា។ ការតស៊ូដើម្បីការពារអធិបតេយ្យភាពជាតិនៃប្រទេសកម្ពុជា បានឆ្លងចូលមកក្នុងដំណាក់កាលដ៏តានតឹងថ្មីមួយទៀត។

នយោបាយកៀបសង្កត់កាន់តែខ្លាំង របស់សហរដ្ឋអាមេរិក បានទៅជាប្រភពមួយ នៃភាពតានតឹងខាងនយោបាយនៅក្នុងប្រទេស។ គឺនៅក្នុងទិសដៅនេះហើយ ដែលកត្តាដទៃនៃនយោបាយខាងក្នុងបានកើតឡើង ជាកត្តាដែលទាក់ទងនឹង

ភាពតានតឹងនៃបដិបក្ខកម្មខាងសង្គមកិច្ច និងស្ថានភាពអាក្រក់ខាងសេដ្ឋកិច្ចទូទៅ ដែលកើតមានឡើងនៅប្រទេសកម្ពុជា។

ព្រឹត្តិការណ៍នានា នៃសម័យកាលភាគខាងចុងអំឡុងឆ្នាំទី៦០ បានបញ្ជាក់ឱ្យឃើញនូវបរាជ័យ នៃនយោបាយខាងសេដ្ឋកិច្ច និងសង្គមកិច្ចរបស់មជ្ឈដ្ឋានដឹកនាំ “ សង្គម ”។ កាលៈទេសៈបែបនេះ បានជំរុញឱ្យមាន “វិបត្តិក្នុងការទុកចិត្ត” ដល់ពាក្យស្លោក និងកម្មវិធីរបស់សង្គម ហើយការណ៍នេះបានបណ្ដាលឱ្យមានការកកើតនូវកម្លាំងនយោបាយនានា នៅក្នុងប្រទេស។

ទឹកចិត្តប្រឆាំងរបស់មជ្ឈដ្ឋាន អភិរក្សនិយមមួយភាគ នៅក្នុងសមាសភាពនៃទីបញ្ជាការកងទ័ពកម្ពុជា ដែលរួបរួមគ្នានៅជុំវិញឧត្តមសេនីយ លន់ - ណុល និងបក្សពួកជិតដិតរបស់គាត់ បានទៅជាកត្តាមួយថ្មីដ៏សំខាន់នៅក្នុងការរីកចម្រើននៃនិន្នាការនយោបាយបែបនេះ។ ជាយូរពេលមកហើយ មជ្ឈដ្ឋាននាយទាហានរបស់កងទ័ពបានបំពេញមុខងារជាអ្នកស្ដាប់បង្គាប់តាមបញ្ជារបស់រាជរដ្ឋាភិបាល។ នៅសម័យនៃឆ្នាំ១៩៥០ នាយទាហានជាន់ខ្ពស់នៃកងទ័ព ស្ដាប់តាមបញ្ជាការរបស់នរោត្តម សីហនុ បានធ្វើប្រតិបត្តិការយោធាដ៏ឃោរឃៅបណ្ដេញបណ្ដាកសិករមិនឱ្យនៅតំបន់ខ្លះ ដែលស្ថិតនៅក្រោមការត្រួតត្រារបស់ខ្មែរឥស្សរៈ។ នៅឆ្នាំ១៩៥៩ អង្គភាពកងទ័ពមួយកងបានធ្វើការបង្ក្រាបលើការសាកល្បងធ្វើរដ្ឋប្រហារយោធា នៅខេត្តសៀមរាប ដែលបានរៀបចំឡើងដោយភ្នាក់ងាររបស់បក្សសម្ព័ន្ធយោធាសេអាតូ នៅក្នុងប្រទេសកម្ពុជា។ ក៏ប៉ុន្តែ សហប្រតិបត្តិការរបស់នាយទាហានជាន់ខ្ពស់ជាមួយអង្គការដឹកនាំ “ សង្គម ”

បានទៅជាខ្សោយចាប់តាំងពីឆ្នាំ១៩៦០ គឺនៅពេលនោះហើយ ដែលមាននាយទាហានខ្លះ បានសំដែងនូវកំហឹងរបស់ខ្លួនចំពោះ នយោបាយក្នុងប្រទេស និងក្រៅប្រទេសរបស់អង្គការ "សង្គម"។ កំហឹងដ៏ខ្លាំងក្លារបស់ នាយទាហានជាន់ខ្ពស់បានកើតឡើងដោយ សារសេចក្ដីសម្រេចចិត្តរបស់រដ្ឋាភិបាល ក្នុងការបញ្ឈប់កម្មវិធី ជំនួយអាមេរិក ដោយហេតុថា ការបញ្ឈប់កម្មវិធីជំនួយខាង យោធានេះ បានកម្រិតប្រភពនៃការផ្ដល់ថវិកាខាងហិរញ្ញវត្ថុជា ខ្លាំងដល់កងទ័ព។ ពីសម័យពាក់កណ្ដាលនៃអំឡុងឆ្នាំទី៦០ មជ្ឈដ្ឋាននាយទាហានជាន់ខ្ពស់ នៃកងទ័ពបានទៅជាកម្លាំង មួយដ៏សកម្ម របស់ក្រុមប្រឆាំងខាងស្ដាំ នៅក្នុងជីវភាពនយោបាយ ផ្ទៃក្នុងប្រទេស។

ចាប់ផ្ដើមពីឆ្នាំ១៩៦៦ នរោត្ដម សីហនុ ឈប់ប្រើ " សិទ្ធិ ជាប្រពៃណី " របស់ខ្លួនក្នុងការជ្រើសរើសបេក្ខជន " សង្គម " ដើម្បីការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ សម្រាប់រដ្ឋសភា។ វិធីថ្មីនៃការជ្រើសរើសបេក្ខជនរបស់អង្គការ " សង្គម " ដោយសេរី បានផ្ដល់ជ័យជម្នះដល់កម្លាំង ខាងស្ដាំនៅសម័យបោះឆ្នោតនា ឆ្នាំ១៩៦៦ គឺជាសម័យដែលពួកនេះបានទទួលតំណែងភាគច្រើន នៅរដ្ឋសភា ហើយបានបង្កើតរដ្ឋាភិបាល " របស់ខ្លួន " ដែល មានឧត្ដមសេនីយ លន់ - ណុល ជាប្រធាន។

លទ្ធផលនៃសម័យបោះឆ្នោតនាឆ្នាំ១៩៦៦ បានបញ្ជាក់ ឱ្យឃើញនូវភាពប្រេះឆាដ៏ខ្លាំងក្លា ជាលើកទី១នៃរបបគ្រប់គ្រង របស់អំណាចផ្ដាច់ការផ្ទាល់ខ្លួននៃនរោត្ដម សីហនុ ដែលឥឡូវនេះ ត្រូវតែសម្របសម្រួល ការដោះស្រាយបញ្ហានយោមួយចំនួន

តាមទស្សនៈនយោបាយ របស់តំណាងរាស្ត្រខាងស្តាំភាគច្រើន នៅរដ្ឋសភា ដែលមាននាយទាហានជាន់ខ្ពស់ស្ថិតនៅពីក្រោយខ្នង។

រង្វង់នៃឥទ្ធិពលនយោបាយ ងាករេចុះឡើងរបស់នរោត្តម សីហនុ និងបក្សពួករបស់ខ្លួនត្រូវបានកម្រិតបន្តិចម្តងៗទៅតាម ភាពតានតឹងក្នុងទំនាស់ខាងនយោបាយ និងសង្គមកិច្ចនៅក្នុង ប្រទេស។ និន្នាការបែបនេះកាន់តែមានល្បឿនខ្លាំងទៅមុខ ដោយសារព្រឹត្តិការណ៍ដែលកើតមានឡើង ក្នុងចលនារំដើប រំជួលរបស់កសិករនៅតំបន់សំឡូត ក្នុងខេត្តបាត់ដំបង នាខែមីនា ឆ្នាំ១៩៦៧។ ប្រភពនៃចលនារំដើបរំជួលនេះ បានកើតមកអំពី អំពើរំលោភរបស់រដ្ឋការស្រុក និងអំពីអំពើជិះជាន់ដល់កសិករពី សំណាក់ពួកពាណិជ្ជករចងការប្រាក់។

តាមបញ្ជារបស់លន់ - ណុល អង្គភាពកងទ័ពមួយកងត្រូវ បានបញ្ជូនទៅទីនោះ។ ប្រតិបត្តិការបង្ក្រាបដ៏ឃោរឃៅបាន បណ្តាលឱ្យអ្នកស្រុកស្លាប់ពីរបីរយនាក់។ អ្នកស្រុកចំនួន ប្រហែល៤ពាន់នាក់ បានរត់ភៀសខ្លួនចូលទៅក្នុងព្រៃ ហើយពី ពេលនោះមក ការជួបប្រយុទ្ធគ្នាដោយគ្រឿងអាវុធរវាងអ្នកស្រុក ជាមួយកងទ័ព និងក្រុមនគរបាល ក៏ចាប់ផ្តើមមានឡើងជាបន្ត បន្ទាប់។

នៅខែមេសា ឆ្នាំ១៩៦៧ អង្គការ “ ដឹកនាំសង្គម ” បាន ធ្វើការសាកល្បងដើម្បីជម្នះលើវិបត្តិនយោបាយ។ នៅខែឧសភា ឆ្នាំ១៩៦៧ លន់ - ណុល ត្រូវបានចាកចេញពីតំណែង។ នៅ ពេលជាមួយគ្នា មានការចាត់វិធានការណ៍ដើម្បីសម្រួលស្ថានភាព ឡើងវិញនៅខេត្តបាត់ដំបង។ កងទ័ពបានទទួលបញ្ជាឱ្យឡោម ព័ទ្ធ “ តំបន់រំដើបរំជួល ” ក៏ប៉ុន្តែ កងទ័ពបានទទួលការហាមឃាត់

មិនឱ្យបន្តអំពើបង្ក្រាបដ៏ព្រៃផ្សៃរបស់ខ្លួនប្រឆាំងនឹងអ្នកស្រុក។ អង្គការដឹកនាំ " សង្គម " បានថ្លែងបញ្ជាក់ថា ប្រភពនៃ " ភាពរំជើបរំជួល " នៅក្នុងខេត្តនេះ មានសភាពជាកិច្ចការនយោបាយផ្ទៃក្នុង ហើយការទទួលខុសត្រូវ ត្រូវធ្លាក់ទៅលើរដ្ឋបាលស្រុកទាំងអស់។ នៅខែមិថុនា ឆ្នាំ១៩៦៧ មានសេចក្ដីប្រកាសអំពីការលើកលែងទោស ដល់បណ្ដាកសិករដែលបានចូលរួមរួមក្នុងកុបកម្មនេះ ហើយតមក អ្នកស្រុកមួយភាគនៅតំបន់សំឡូត ក៏បានវិលត្រឡប់មករកផ្ទះសំបែងរបស់ខ្លួនវិញ។

នៅរដូវវស្សានាឆ្នាំ១៩៦៧ នរោត្តម សីហនុ បានបំបិទអង្គការសារព័ត៌មានប្រឆាំងទាំងអស់ ហើយបានថ្លែងសន្ធរកថាកំណត់កំហុសទៅលើក្រុម " ក្រហម " ដែលនៅក្នុងនេះ គាត់បានចោទប្រកាន់ទាំងអ្នកតំណាងប្រជាធិបតេយ្យ និងអ្នកតំណាងចលនាសេរីនិយមនៅប្រទេសកម្ពុជា។ ព្រឹត្តិការណ៍នានានៅចុងឆ្នាំ១៩៦៧ និងដើមឆ្នាំ១៩៦៨ បានបង្កើតជាភស្តុតាងបញ្ជាក់ថា នៅក្នុងស្ថានភាពវិបត្តិនយោបាយ ដែលកើតមានឡើងកាន់តែខ្លាំង នរោត្តម សីហនុ បានផ្អៀងខ្លួនទៅតាមកម្លាំងខាងស្ដាំបំផុតដ៏សុទ្ធសាធ ហើយបានប្រើប្រាស់អំណាចផ្ដាច់ការរបស់ខ្លួនក្នុងឋានៈជាប្រមុខរដ្ឋ ដើម្បីវាយបំបាក់ចលនាប្រជាធិបតេយ្យ។ នារដូវវស្សានាឆ្នាំ១៩៦៨ នៅទីក្រុងភ្នំពេញ និងទីក្រុងដទៃទៀត មានការចាប់ឃុំឃាំងបុគ្គលមួយចំនួន ដែលត្រូវមានសេចក្ដីមន្ទិលសង្ស័យថា ជាអ្នកធ្វើការឃោសនាប្រឆាំងរដ្ឋាភិបាល។ នៅពេលជាមួយគ្នា កងទ័ពបានចាប់ផ្ដើមធ្វើការបោសសម្អាតភូមិនានានៅស្រុកស្រែ ក្នុងគោលបំណងបំភិតបំភ័យដល់អ្នកស្រុក។

ការអនុវត្តនយោបាយ បង្ក្រាបចលនាប្រជាធិបតេយ្យតាមការប្រើប្រាស់កម្លាំងយោធាត្រង់ៗ ដោយមជ្ឈដ្ឋានដឹកនាំខាងស្តាំបានផ្តល់សន្ទុះថ្មីនៃការរីកចម្រើន ក្នុងចលនាប្រយុទ្ធរំដោះជាតិតាមរបៀបផ្សេងៗ ហើយសន្ទុះនៃចលនាកុបកម្មទាំងនេះ មានមូលដ្ឋានរបស់ខ្លួន នៅក្នុងស្រទាប់វណ្ណៈកសិករក្រីក្រតោកយ៉ាក។ គ្រាន់តែនៅសម័យភាគខាងដើមនៃឆ្នាំ១៩៦៨ នៅខេត្តផ្សេងៗនៃប្រទេសមានការប៉ះទង្គិចខាងយោធា និងប៉ូលិសជាមួយនឹងកម្លាំងរបស់បណ្តាកុបករ។

ស្ថានភាពនៃបដិបក្ខភាពខាងនយោបាយ និងសង្គមកិច្ចនៅក្នុងប្រទេសមានកម្រិតកាន់តែខ្ពស់ឡើង។ ចាប់ផ្តើមពីឆ្នាំ១៩៦៨ទៅ សឹងរាល់ថ្ងៃ សារព័ត៌មានជាផ្លូវការបានចុះផ្សាយអំពីការប្រយុទ្ធគ្នាដោយអាវុធជាមួយក្រុមកុបករ ដែលនៅពេលនោះបានធ្វើសកម្មភាពរបស់ខ្លួននៅលើទឹកដីនៃខេត្ត ចំនួន១២។

នៅឆ្នាំ១៩៦៩ គេសង្កេតឃើញច្បាស់នូវភាពមិនត្រឹមត្រូវនៃការគន់គូររបស់នរោត្តម សីហនុ ទាក់ទងនឹងនយោបាយ “ បើកទ្វារចំហ ” ដល់មូលធនបរទេស។ បណ្តាធនាគារផ្តាច់មុខអន្តរជាតិធំៗ ពុំបានឆ្លើយតបស្របតាមសំណើខ្ញុំប្រាក់ពីសំណាក់ប្រទេសកម្ពុជា។ នៅពាក់កណ្តាលនៃឆ្នាំ១៩៦៩ វិបត្តិថវិកាជាតិនៃប្រទេសបានឡើងដល់កម្រិតខ្ពស់បំផុត គឺឡើងដល់ ១.៥០០ លានរៀល ជាវិបត្តិដែលបានធ្វើឱ្យរដ្ឋាភិបាលស្ថិតនៅចំពោះមុខនៃស្ថានភាពរលំថវិការបស់ប្រទេស។

វិបត្តិហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរ បានបណ្តាលឱ្យមជ្ឈដ្ឋានប្រតិកិរិយាក្នុងប្រទេសរើកំរើកឡើងយ៉ាងខ្លាំង ដោយការទាមទារ

ឱ្យចាប់ផ្តើមរៀបចំកម្មវិធីទទួលជំនួយអាមេរិក ឡើងវិញ ព្រមទាំងឱ្យធ្វើនយោបាយជិតដិតជាមួយសហរដ្ឋអាមេរិក។

ក្នុងគោលបំណងរក្សាអំណាចផ្ទាល់ខ្លួនទៅទៀត នរោត្តម សីហនុ បានធ្វើការអំពាវនាវដល់មតិសាធារណៈនៃប្រទេស ដោយប្រើប្រាស់វេទិកា នៃសមាជជាតិដែលជាវេទិកាធ្លាប់បានបម្រើដល់នយោបាយនៃមជ្ឈដ្ឋានដឹកនាំ របស់អង្គការសង្គមជំស្មោះត្រង់អស់រយៈពេល ១៤ឆ្នាំមកហើយ។ ក៏ប៉ុន្តែ សមាជជាតិដែលធ្វើឡើងនៅខែកក្កដា - សីហា ឆ្នាំ១៩៦៩ បានបង្ហាញឱ្យឃើញថា នរោត្តម សីហនុ បានបាត់បង់អំណាចរបស់ខ្លួនក្នុងការត្រួតត្រាលើសកម្មភាពរបស់អង្គការដឹកនាំ “ សង្គម ” ដែលនៅក្នុងពេលនោះ មានក្រុមប្រឆាំងខាងស្តាំនិយមអាមេរិក បានកកើតឡើង។ នៅក្នុងសម័យនៃការប្រជុំសមាជពេលនោះ អង្គប្រជុំបានអនុម័តលើសេចក្តីសម្រេចចិត្តផ្តល់សេចក្តីទុកចិត្តឱ្យ នរោត្តម សីហនុ តែក្នុងលក្ខខណ្ឌនៃការបង្កើតរដ្ឋាភិបាលថ្មីមួយជាបន្ទាន់ ដែលអាចមានលទ្ធភាពធានាដល់ការជម្នះលើវិបត្តិសេដ្ឋកិច្ច និងនយោបាយក្នុងពេលវេលាយ៉ាងខ្លី។ សេចក្តីសម្រេចដោយរបៀបសម្របសម្រួលបែបនេះ បានត្រួសត្រាយផ្លូវសម្រាប់ពួកតំណាងប្រតិកិរិយាខាងក្នុងប្រទេស។

នៅខែសីហា ឆ្នាំ១៩៦៩ នរោត្តម សីហនុ បានទទួលយល់ព្រមបង្កើតរដ្ឋាភិបាលថ្មី ដែលមានអ្នកតំណាងនិន្នាការខាងស្តាំបំផុត ជាអ្នកកាន់កាប់រដ្ឋាភិបាលនេះ គឺ លន់ - ណុល និងស៊ីសុវត្ថិ សិរិមតៈ។

ជំហានជាដំបូងមួយរបស់រដ្ឋាភិបាលនេះ គឺបញ្ឈប់ធ្វើជាតូបនីយកម្ម និងការកែប្រែវិស័យសេដ្ឋកិច្ចរបស់ប្រទេសឱ្យទៅ

ជាកម្មសិទ្ធិរបស់ឯកជន។ ការបញ្ឈប់សកម្មភាពជាតូបនីយកម្ម នៅក្នុងវិស័យសេដ្ឋកិច្ច និងការបង្កើតសកម្មភាពក្នុងប្រតិបត្តិការយោធាប្រឆាំងចលនាកុបកម្មនៅក្នុងប្រទេស ទាំងអស់នេះ បានបញ្ជាក់ឱ្យឃើញថា កម្លាំងខាងស្តាំបានកាន់កាប់កិច្ចការដឹកនាំដ៏សំខាន់នៅក្នុងផ្នែកនយោបាយខាងក្នុងប្រទេស។

នៅសម័យភាគខាងចុងនៃឆ្នាំ១៩៦៩ ទម្ងន់ដ៏ធ្ងន់នៅក្នុងការប្រយុទ្ធរបស់មជ្ឈដ្ឋានដឹកនាំ នៃប្រទេសបានទាក់ទាញទៅលើវង្វង់នយោបាយអន្តរជាតិ។ បញ្ហាមួយជាគ្រឹះនៅក្នុងការប្រយុទ្ធនេះ គឺទំនាក់ទំនងរបស់ប្រទេសកម្ពុជា និងកងកម្លាំងស្នេហាមាតុភូមិនៃប្រទេសវៀតណាម។

ស្ថានភាពដ៏តានតឹងកើតមានឡើងនៅឆ្នាំ១៩៦៨ បានបញ្ជាក់ឱ្យឃើញ នូវការផ្លាស់ប្តូរដ៏ច្បាស់លាស់ ក្នុងនយោបាយរបស់រដ្ឋាភិបាលកម្ពុជា ចំពោះការទាក់ទងជាមួយរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង និងសាធារណរដ្ឋប្រជាធិតេយ្យវៀតណាម។ នៅចុងឆ្នាំ១៩៦៨ និងដើមឆ្នាំ១៩៦៩ នរោត្តម សីហនុ បានធ្វើសេចក្តីថ្លែងការណ៍នានា ដែលគាត់បានប្រឌិតអំពីរឿងដែលថា កម្លាំងខាងឆ្វេងនៃប្រទេសកម្ពុជា ធ្វើសកម្មភាព " តាមបញ្ជាបរទេស " ហើយថា រណសិរ្សរំដោះជាតិវៀតណាមខាងត្បូង ហាក់ដូចជាផ្តល់ជំនួយយោធាដល់អ្នកតំណាងនៃចលនាប្រឆាំងខាងឆ្វេង។

ក្នុងសេចក្តីថ្លែងចោទ ប្រកាន់ដល់កងកម្លាំងស្នេហាមាតុភូមិវៀតណាម នរោត្តម សីហនុ បានចាប់ផ្តើមដុតភ្លើងបញ្ឆេះ ដោយហេតុថា ការចោទប្រកាន់ដល់រណសិរ្សរំដោះជាតិវៀតណាមខាងត្បូង និងដល់សាធារណរដ្ឋប្រជាធិតេយ្យវៀតណាម ត្រូវបាន

ប្រើប្រាស់ដោយមជ្ឈដ្ឋានខាងស្តាំ សម្រាប់បង្កើតការឃោសនាប្រឆាំងកុម្មុយនិស្តដ៏ខ្លាំងក្លានៅក្នុងប្រទេសទាំងមូល។ ហើយនៅពេលនោះ សកម្មភាពទូតអាមេរិក ក៏បានបំពេញសកម្មភាពរបស់ខ្លួនទៅតាមទិសដៅបែបនេះដែរ។

ក្នុងគោលបំណងដើម្បី បញ្ឈប់ការទាក់ទងរវាងប្រទេសកម្ពុជា និងរណសិរ្សរំដោះជាតិវៀតណាមខាងត្បូង និងរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិតេយ្យវៀតណាម ក្នុងគោលបំណងបង្ក្រាបចលនាប្រឆាំងចក្រពត្តិនិយម សហរដ្ឋអាមេរិក បានចាប់ផ្តើមរៀបចំការទាក់ទង របស់ខ្លួនឡើងវិញជាមួយប្រទេសកម្ពុជា។ នៅខែមេសា ឆ្នាំ១៩៦៩ ទីក្រុងវ៉ាស៊ីនតោន បានធ្វើសេចក្តីប្រកាសជាផ្លូវការ ស្តីអំពី “ការទទួលស្គាល់ និងការគោរពអធិបតេយ្យភាព ឯករាជភាព និងបូរណភាពទឹកដីនៃប្រទេសកម្ពុជា ”។ ក្នុងអំឡុង ៣ខែក្រោយមក ការទាក់ទងខាងផ្លូវទូតរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក ក៏ត្រូវបានរៀបចំឡើងវិញ។

បន្ទាប់ពីពេលនោះមក មជ្ឈដ្ឋានប្រតិកិរិយាខាងក្នុងប្រទេសក្នុងការធ្វើឃោសនាប្រឆាំងប្រទេសវៀតណាម ក៏បានផ្ទុះឡើងក្លាមយ៉ាងខ្លាំងបំផុត។ ការឃោសនាបែបនេះ ពុំជួបប្រទះនឹងការហាមឃាត់ពីសំណាក់នរោត្តម សីហនុ សោះឡើយ។ ការឈប់មានការទាក់ទងជាមួយចលនាខាងឆ្វេង និងជាមួយកម្លាំងប្រជាធិបតេយ្យក្នុងប្រទេស បានធ្វើឱ្យនរោត្តម សីហនុ ស្ថិតនៅក្នុងស្ថានភាពទាល់ច្រក ឯកោខាងនយោបាយ។ នៅក្នុងលក្ខខណ្ឌបែបនេះ សកម្មភាពរបស់ពួកប្រតិកិរិយាក្នុងប្រទេស បានកើនឡើងយ៉ាងខ្លាំងក្លា បន្ទាប់ពីពេលតែងតាំងលន់ - ណុល ជាប្រមុខរដ្ឋាភិបាល (នៅខែសីហា ឆ្នាំ១៩៦៩) ពួកប្រតិកិរិយា

បានឆ្លងដល់ដំណាក់កាលមួយ  នៅក្នុងការដណ្ដើមអំណាចឱ្យស្ថិតនៅក្នុងកណ្ដាប់ដៃទាំងស្រុង របស់មជ្ឈដ្ឋានអ្នកដឹកនាំខាងស្ដាំបំផុត។

# វគ្គទី៤

# ប្រទេសកម្ពុជា នាឆ្នាំ១៩៧០-១៩៨០

## ចំពូកទី១

## ការតស៊ូនៃប្រជាជនកម្ពុជា ប្រឆាំងចក្រពត្តិនិយមអាមេរិក និងរបបត្រប់ត្រងរបស់លន់ - ណុល

នៅឆ្នាំ១៩៧០ ចលនាតស៊ូរំដោះជាតិនៃប្រទេសកម្ពុជា បានចូលមកដល់ដំណាក់កាលថ្មីមួយទៀត។ មជ្ឈដ្ឋានតំណាងកម្លាំងខាងស្តាំ បានពឹងផ្អែកទៅលើចក្រពត្តិនិយមអាមេរិក ហើយបានពង្រឹងស្ថានភាពរបស់ខ្លួន ដែលនៅទីបំផុត អាចឱ្យពួកនេះចូលប្រឡូកក្នុងការដណ្តើមអំណាចដោយចេញមុខ។ ការដណ្តើមអំណាចនេះ បានលេចឡើងច្បាស់នៅពេលដែលនរោត្តម សីហនុ មិនស្ថិតនៅប្រទេសកម្ពុជា ដោយបានចេញទៅសម្រាក និងព្យាបាលជំងឺនៅប្រទេសបារាំង នៅដើមឆ្នាំ១៩៧០។

ការធ្វើឃោសនាប្រឆាំងវៀតណាម បានចាប់ផ្តើមឡើងដោយពួកប្រតិកិរិយា នៅពេលជាមួយគ្នានឹងការរៀបចំធ្វើរដ្ឋប្រហារ។ នៅថ្ងៃទី១១ មីនា ឆ្នាំ១៩៧០ ពួកប្រតិកិរិយាបានធ្វើបាតុកម្មនៅទីក្រុងភ្នំពេញ ដែលនៅពេលនោះ ពួកបាតុករបានសម្រុក ចូលស្ថានទូតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និងស្ថានទូតសាធារណរដ្ឋវៀតណាមខាងត្បូង ហើយបាន

ប្រព្រឹត្តអំពើបំផ្លិចបំផ្លាញដល់ស្ថានទូតទាំងនោះ។ នៅក្នុងទីក្រុងកុបកម្មប្រឆាំងវៀតណាម ក៏បានចាប់ផ្តើមមានឡើង។

ពួកអ្នករៀបចំអំពើឃុបឃិតគំនិតក្បត់ បានបង្កបង្កើតបាតុកម្ម និងចលនាសម្រាប់ជាមធ្យោបាយ ដើម្បីកោះហៅកងទ័ពដែលស្មោះស្ម័គ្រនឹងខ្លួនឱ្យចូលមកក្នុងរដ្ឋធានី " ដើម្បីរៀបចំរបៀបរៀបរយ និងសន្តិសុខនៅទីក្រុង "។ គ្រឹះស្ថានក្រសួងនានានៃរដ្ឋាភិបាលត្រូវបានយាមល្បាតដោយកងយោធា និងកងប៉ូលិស។ ទីព្រលានយន្តហោះពោធិ៍ចិនតុងនៅរដ្ឋធានី ត្រូវបានបិទ។ បុគ្គលិកនានាប្រកបដោយទស្សនៈចម្រើននិយមត្រូវបានបញ្ចេញពីទីស្តីការរដ្ឋមន្ត្រី និងពីក្រសួងនៃរដ្ឋាភិបាលនានា។ ទាំងអស់នេះ គឺជាប្រតិបត្តិការដែលបានរៀបចំទុកជាមុនយ៉ាងល្អិតល្អន់។

នៅថ្ងៃទី១៨ មីនា ឆ្នាំ១៩៧០ ក្រុមប្រឹក្សារាជាណាចក្រ និងរដ្ឋសភាជាតិ ក្រោមការបង្ខិតបង្ខំរបស់អ្នកដឹកនាំនៃមជ្ឈដ្ឋានយោធា និងខាងស្តាំ ដែលមានជាអាទិ៍ គឺឧត្តមសេនីយលន់ - ណុល និងអង្គម្ចាស់សិរិមតៈ បានធ្វើសេចក្តីប្រកាសស្តីអំពីការរំលំនរោត្តម សីហនុ ពីអំណាច។

អង្គការសារព័ត៌មានជាច្រើននៃប្រទេស បានគូសបញ្ជាក់ការចូលរួមរបស់អង្គការចារកិច្ចរបស់អាមេរិក នៅក្នុងព្រឹត្តិការណ៍ទាំងនេះនៅទីក្រុងភ្នំពេញ។

បន្ទាប់ពីរដ្ឋប្រហារមួយថ្ងៃកន្លងមក ក្រសួងការបរទេសអាមេរិក បានធ្វើសេចក្តីថ្លែងការណ៍ស្តីអំពីការទទួលស្គាល់រដ្ឋអំណាចថ្មីនៅទីក្រុងភ្នំពេញ ដែលមានលន់-ណុល និងសិរិមតៈ ជាអ្នកដឹកនាំ។ នៅថ្ងៃទី៣០ មីនា ឆ្នាំ១៩៧០ អ្នកតំណាងនៃ

សេតវិមាន ទាក់ទងនឹងបញ្ហាសារព័ត៌មាន នាម រ.ហ្ស៊ីគ្លែរ បាន ថ្លែងថា ទីបញ្ជាការអាមេរិក នៅវៀតណាមខាងត្បូង ត្រូវបាន ទទួលសិទ្ធិ " បញ្ជាទ័ពអាមេរិកាំង ឱ្យវាយលុកចូលក្នុងទឹកដីប្រទេសឡាវ ឬប្រទេសកម្ពុជា ក្នុងករណីនៃការចាំបាច់ខាងយោធា "។ នៅថ្ងៃ១៦ មេសា ១៩៧០ លន់ - ណុល បានស្នើសុំឱ្យសហរដ្ឋអាមេរិក ផ្តល់ " ជំនួយយោធា " ជាគ្រឿងអាវុធយុទ្ធភ័ណ្ឌ និងគ្រាប់រំសេវនានា។ ពីរថ្ងៃកន្លងមក យន្តហោះអាមេរិកកាំង ផ្ទុកដោយគ្រឿងអាវុធ និងគ្រាប់រំសេវ បានចាកចេញពីវៀតណាមខាងត្បូង ហើយមកចុះចតនៅប្រទេសកម្ពុជា។ ទាល់តែនៅថ្ងៃទី៦ ឧសភា នៅទីក្រុងវ៉ាស៊ីនតោន គេបានប្រកាសជាផ្លូវការអំពីការផ្តល់គ្រឿងសព្វាវុធនេះ។ ចាប់តាំងពីចុងខែមីនា ១៩៧០ កងទ័ពព្រៃនគរ បានវាយលុកចូលមកទឹកដីប្រទេសកម្ពុជា ដើម្បីបង្ក្រាបភាពចលាចល របស់បណ្តាជនដែលបានក្រោកឈរដើម្បីការពារនយោបាយអព្យាក្រឹតភាព ឯករាជភាព និងបូរណភាពទឹកដីប្រទេស។ នៅខែមេសា ការវាយលុករបស់កងទ័ពព្រៃនគរមានសភាពកាន់តែញឹកញាប់។

បក្សសម្ពន្ធយោធាសេអាតូ ក៏មិនបានស្ថិតនៅស្ងៀមដែរនៅពេលនោះ។ នៅដើមខែមេសា ១៩៧០ នៅទីក្រុងបាហ្គីយោ ប្រទេសហ្វីលីពីន មានការបើកសម័យប្រជុំពិសេសនៃទីប្រឹក្សាយោធារបស់បក្សសម្ពន្ធនេះ ដែលនៅពេលនោះ មានការពិភាក្សាជាពិសេស អំពីស្ថានភាពដែលកើតមានឡើងនៅប្រទេសកម្ពុជា។ អគ្គលេខាបក្សសម្ពន្ធយោធាសេអាតូ នាម ហេស៊ូស-បានហ្គាស បានថ្លែងថា ក្រុមប្រឹក្សារដ្ឋមន្ត្រីរបស់បក្សសម្ពន្ធ

យោធាសេអាតូ នឹងពិនិត្យពិច័យសំណូមពរគ្រប់បែបយ៉ាងរបស់រដ្ឋាភិបាលថ្មី នៃប្រទេសកម្ពុជា ស្ដីអំពីការផ្ដល់ជំនួយ។

លើសកលលោកទាំងមូល គេបានវាយតម្លៃដល់សកម្មភាពទាំងនេះថា ជាកិច្ចការរៀបចំអន្ដរាគមន៍ខាងយោធាដ៏ត្រង់របស់សហរដ្ឋអាមេរិក នៅក្នុងប្រទេសកម្ពុជា។ នៅថ្ងៃទី៣០ មេសា ១៩៧០ កងទ័ពអាមេរិក - ព្រៃនគរ បានចាប់ផ្ដើមវាយសម្រុកចូលក្នុងទឹកដីប្រទេសកម្ពុជា។ ដល់ចុងខែឧសភា ចំនួនទាហានអន្ដរាគមន៍បានឡើងដល់ ៨០ពាន់នាក់ ហើយប្រតិបត្តិការពាតត្បាតព្រៃផ្សៃបានរីកសាយទៅលើខេត្តចំនួន១០ នៅក្នុងប្រទេស។ នៅពេលជាមួយគ្នា កងនាវាចរណ៍អាមេរិក បានបិទចរាចរតាមឆ្នេរសមុទ្រប្រទេសកម្ពុជា។

ក្នុងការសម្រេចបញ្ជូនកងទ័ពអាមេរិក ឱ្យចូលវាយសម្រុកទឹកដីកម្ពុជា ទីក្រុងវ៉ាស៊ីនតោន មិនបានទាំងយកចិត្តទុកដាក់ផ្ដល់ព័ត៌មាននេះជាមុនដល់ លន់ - ណុល ដែលជាប្រមុខរបបគ្រប់គ្រងនៅទីក្រុងភ្នំពេញ ឱ្យបានជ្រាបជាមុនផង។ គាត់បានជ្រាបអំពីរឿងនេះ តែតាមទីភ្នាក់ងារសារព័ត៌មានបរទេស គឺនៅពេលដែលកងទ័ពអាមេរិក - ព្រៃនគរ បានស្ថិតនៅលើទឹកដីប្រទេសកម្ពុជា រួចទៅហើយ។

នៅក្នុងសេចក្ដីថ្លែងការណ៍ចុះផ្សាយថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧០ រដ្ឋាភិបាលសហភាពសូវៀត បានគូសបញ្ជាក់ថា៖ “ បន្ទាប់ពីវាយលុកចូលប្រទេសកម្ពុជា ដោយកងទ័ពអាមេរិក គេបានឃើញច្បាស់ នូវការទាក់ទងរវាងសកម្មភាពវិទ្ធង្សនានៃអង្គការចារកិច្ចនៃសហរដ្ឋអាមេរិក និងរដ្ឋប្រហារនៅទីក្រុងភ្នំពេញ ”។

នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៧០ ប្រធានាធិបតីអាមេរិក រ.និចសុន បានឡើងថ្លែងតាមវិទ្យុ និងទូរទស្សន៍ បញ្ជាក់អំពីមូលហេតុ នៃសេចក្តីសម្រេចក្នុងការបញ្ជាដល់កងទ័ពឱ្យវាយលុកចូលប្រទេសកម្ពុជា លើហេតុថា ហាក់ដូចជាមានការចាំបាច់ដើម្បីស្រោចស្រង់ជីវិតទាហានអាមេរិក ដែលស្ថិតនៅវៀតណាមខាងត្បូង ហើយមិនតែប៉ុណ្ណោះ ហាក់ដូចជាបញ្ជាក់នូវគោលបំណងទីក្រុងវ៉ាស៊ីនតោន ដើម្បី " បញ្ចប់សង្គ្រាមឱ្យបានឆាប់នៅឥណ្ឌូចិន "។

យោបល់ទាំងនេះរបស់ រ.និចសុន ត្រូវបានបើកអាក្រាតយ៉ាងច្បាស់នៅក្នុងសេចក្តីថ្លែងការណ៍ របស់រដ្ឋាភិបាលសូវៀតចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ១៩៧០។ សេចក្តីថ្លែងការណ៍បានបញ្ជាក់ថា៖ " នេះគឺជាវិចារញ្ញាណដ៏ប្លែកបំផុត ពួកឈ្លានពានបានវាយលុកចូលទឹកដីរបស់ប្រទេសមួយជាមុនសិន រួចក៏បានប្រកាសថា ជីវិតទាហានរបស់ខ្លួន គឺជាជីវិតរបស់ពួកអ្នកធ្វើអន្តរាគមន៍បរទេសទទួលការគំរាមកំហែងទៅវិញ ហើយការនេះតាមយោបល់របស់ពួកឈ្លានពាន គឺជាកលល្បិចគ្រប់គ្រាន់ដើម្បីចូលលុកលុយលើទឹកដីប្រទេសមួយទៀត ដែលជាប្រទេសជិតខាងនឹងប្រទេសទីមួយ។ នៅក្នុងរឿងនេះ សម្រាប់សហរដ្ឋអាមេរិក ព្រំប្រទល់ និងអធិបតេយ្យរបស់ប្រទេស អភ័យឯកសិទ្ធិនៃព្រំប្រទល់ប្រទេស ទៅជាគ្មានអត្ថន័យអ្វីឡើយ។ ក៏ប៉ុន្តែនយោបាយបែបនេះ គឺជាអំពើរំលោភដ៏គ្រោតគ្រាតនៅក្នុងកិច្ចការអន្តរជាតិ ហើយត្រូវតែទទួលការផ្តន្ទាទោសដ៏ម៉ឺងម៉ាត់។

សេចក្តីថ្លែងការណ៍បានបញ្ជាក់តទៅទៀតថា៖ " កាន់តែឆ្ងាយពីការពិត គឺការប្រកាសថា ការបង្កបង្កើតសមរភូមិនៅលើ

ទឹកដីប្រទេសកម្ពុជា ទៅជាការបញ្ចប់សង្គ្រាមនៅវៀតណាម ឱ្យបានឆាប់ទៅវិញ បានសេចក្ដីថា ការពង្រីកយុទ្ធនាការនៅឥណ្ឌូចិន បែរជាមិនពង្រីកទំហំភ្លើងសង្គ្រាមទេ ហើយទៅជាបង្រួមទីសមរភូមិឱ្យតូចទៅវិញ ”។

ហេតុដូច្នេះហើយ បានជាប្រទេសកម្ពុជា ក៏ដូចជាប្រទេសវៀតណាម និងឡាវ រួចមកហើយ បានប្រែទៅជាសមរភូមិនៃយុទ្ធនាការដ៏កាចសាហាវបំផុត។ ប្រភពនៃសង្គ្រាមនេះកើតមកអំពីបំណងរបស់មជ្ឈដ្ឋានចក្រពត្តិនិយមសហរដ្ឋអាមេរិក និងបរិវាររបស់ខ្លួននៅទីក្រុងភ្នំពេញ ដើម្បីជំរុញប្រទេសកម្ពុជា ឱ្យចាកចេញពីមាគ៌ាឯករាជ្យ និងអព្យាក្រឹត ហើយប្រែបង្វិលប្រទេសនេះឱ្យទៅជាប្រទេសរណបអាមេរិក ហើយប្រើប្រាស់ប្រទេសនេះ ដូចជាមូលដ្ឋានសម្រាប់ការប្រយុទ្ធប្រឆាំងចលនាតស៊ូរំដោះជាតិនៅឥណ្ឌូចិន។

ការពង្រីកអំពើឈ្លានពានអាមេរិក នៅកម្ពុជា បានបង្កើតឱ្យមានចលនាប្រឆាំង ដ៏ខ្លាំងក្លាលើពិភពលោកទាំងមូល។ សម័យប្រជុំមីទ្ទីង និងបាតុកម្មនានាប្រឆាំងការលុកលុយទឹកដីប្រទេសកម្ពុជា ដោយកងទ័ពអាមេរិក - ព្រៃនគរ បានប្រព្រឹត្តទៅនៅក្នុងប្រទេសជាច្រើន។ ទោះបីប្រទេសជាសម្ពន្ធមិត្តអាមេរិកខ្លះ ក៏បានស្ថិតនៅឆ្ងាយពីសកម្មភាពទីក្រុងវ៉ាស៊ីនតោន។ ចលនាប្រឆាំងក៏បានចាប់ផ្ដើមមានឡើង នៅសហរដ្ឋអាមេរិកផ្ទាល់។

ក្រោមឥទ្ធិពលនៃមតិមហាជនពិភពលោក ដែលនៅក្នុងនេះ មានទាំងមតិមហាជននៅសហរដ្ឋអាមេរិក រដ្ឋាភិបាលអាមេរិកបានបង្ខំចិត្តដកទ័ពរបស់ខ្លួនចេញពីប្រទេសកម្ពុជា នៅថ្ងៃទី១

ខែកក្កដា ឆ្នាំ១៩៧០។ ក៏ប៉ុន្តែ ពួកទាហានរបស់របបគ្រប់គ្រង អាយ៉ងព្រៃនគរ បានស្ថិតនៅប្រទេសនេះយ៉ាងយូរតទៅទៀត ហើយកងអាកាសចរណ៍អាមេរិក បានបន្តការទម្លាក់គ្រាប់បែក យ៉ាងឃោរឃៅទៅលើទីក្រុង និងស្រុកស្រែដ៏សុខសាន្តទាំងឡាយ នៅកម្ពុជា រហូតដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ១៩៧៣។ គ្រាន់តែ នៅក្នុងអំឡុងពេលនេះ តាមស្ថិតិអាមេរិក យន្តហោះសហរដ្ឋ អាមេរិក បានទម្លាក់គ្រាប់បែកចំនួន ៥០០ពាន់តោនគ្រាប់ទៅ លើទឹកដីកម្ពុជា។ រដ្ឋាភិបាលអាមេរិក បានទទួលបីបាច់រក្សា របបគ្រប់គ្រង លន់ - ណុល។ ជំនួយអាមេរិក បានផ្តល់លទ្ធភាព ឱ្យពង្រីកកងទ័ព ដែលកាលមុនមានចំនួនតែ ៣០ពាន់នាក់ រហូតដល់ចំនួន ២០០ពាន់នាក់ ហើយប្រដាប់ដល់កងទ័ពនេះ ដោយគ្រឿងអាវុធ និងយុទ្ធភ័ណ្ឌអាមេរិក ដ៏ទំនើបៗ។

ក្នុងគោលបំណងពង្រឹងគោលជំហររបស់ខ្លួន របបគ្រប់គ្រង លន់ - ណុល បានចាប់ផ្តើមចាត់វិធានការមួយចំនួន។ នៅទីក្រុងភ្នំពេញ គេបានបង្កើតបក្សនយោបាយ៣ គឺបក្សសង្គម សាធារណរដ្ឋ បក្សប្រជាធិបតេយ្យ និងបក្សសាធារណរដ្ឋ ហើយ លន់ - ណុល បានធ្វើជាអ្នកដឹកនាំបក្សទី១។ នៅថ្ងៃទី៩ ខែតុលា ឆ្នាំ១៩៧០ គេបានប្រកាសការបង្កើត “ សាធារណរដ្ឋ ”។ នៅ ខែមីនា ឆ្នាំ១៩៧២ លន់ - ណុល បានរំលំរដ្ឋសភា និងរដ្ឋាភិបាល ហើយបានប្រកាសខ្លួនថា ជាប្រធានាធិបតីនៃសាធារណរដ្ឋ។ នៅថ្ងៃទី៣០ មេសា ឆ្នាំ១៩៧២ នៅទីក្រុងភ្នំពេញ គេបានធ្វើ ជាប្រជាមតិ ដើម្បីអនុម័តលើរដ្ឋធម្មនុញ្ញថ្មី។ នៅថ្ងៃទី៣០ កក្កដា មានការបោះឆ្នោតជ្រើសរើសប្រធានាធិបតី។ នៅថ្ងៃទី៣ កញ្ញា មានការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ សម្រាប់រដ្ឋសភា ហើយ

នៅថ្ងៃទី១៧ កញ្ញា មានការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា។ លន់ - ណុល ត្រូវបានជ្រើសរើសជាប្រធានាធិបតី បក្សសង្គមសាធារណរដ្ឋ បានទទួលកន្លែងទាំងអស់នៅរដ្ឋសភាជាតិ និងនៅព្រឹទ្ធសភា។ នៅខែមេសា ឆ្នាំ១៩៧៣ នៅទីក្រុងភ្នំពេញ មានការបង្កើតក្រុមប្រឹក្សានយោបាយជាន់ខ្ពស់ ដែលមាន លន់ - ណុល ជាប្រធាន ហើយនៅខែឧសភា “រដ្ឋាភិបាលវិសាមញ្ញមួយ” បានកើតមានឡើង។ នៅចុងខែមីនា ឆ្នាំ១៩៧៤ ក្រុមប្រឹក្សានយោបាយជាន់ខ្ពស់ត្រូវបានរំលំ ហើយគេបានបង្កើតក្រុមប្រឹក្សានីតិប្រតិបត្តិមួយជំនួស ដែលមាន លន់ - ណុល ជាប្រធាន។

ក៏ប៉ុន្តែកលល្បិច និងរបៀបរបបកែប្រែចុះឡើងទាំងនេះ ពុំបានផ្លាស់ប្តូរអ្វីដល់លក្ខណៈប្រជាប្រិយ នៃរបបគ្រប់គ្រងយោធាផ្តាច់ការឡើយ។ របបគ្រប់គ្រងនេះ បានរស់រានមានជីវិតក៏ដោយសារតែឆន្ទៈរបស់រដ្ឋាភិបាលអាមេរិក ប៉ុណ្ណោះ។ នៅទីក្រុងភ្នំពេញ ទីប្រឹក្សា និងអ្នកឯកទេសអាមេរិកទាំងឡាយ បានចាត់ចែងកិច្ចការទាំងអស់។ ពួកនេះមិនគ្រាន់តែបំពាក់អាវុធ និងបង្វឹកបង្វឹន និងដឹកនាំប្រតិបត្តិការយោធាកងទ័ពភ្នំពេញប៉ុណ្ណោះទេ ក៏ប៉ុន្តែ បានទាំងបញ្ជាក់នូវមាគ៌ានយោបាយខាងក្នុង និងខាងក្រៅប្រទេសទាំងអស់ទៀតផង។ កិច្ចការមានដំណើរហូតដល់មានកាលៈទេសៈខ្លះ ទីក្រុងវ៉ាស៊ីនតោន បានរៀបចំតាក់តែងអត្តបទសារលិខិតរបស់លន់ - ណុល ផ្ញើដល់ប្រមុខរដ្ឋាភិបាលនៃប្រទេសដទៃ ដើម្បីស្នើសុំជំនួយខាងហិរញ្ញវត្ថុសម្រាប់របបគ្រប់គ្រងនៅទីក្រុងភ្នំពេញ។

រដ្ឋប្រហារនៅទីក្រុងភ្នំពេញ ធ្វើឡើងដោយពួកប្រតិកិរិយា មិនបានបំពេញមុខងារស្រេបតាមឆន្ទៈ របស់អ្នកផ្តើមគំនិតធ្វើរដ្ឋ

ប្រហារនេះទេ ប៉ុន្តែ បែរទៅជាបង្កើតបាននូវផលវិបាកជាអវិជ្ជមានផ្សេងៗ។ រដ្ឋប្រហារបានផ្តល់លទ្ធភាពឱ្យមជ្ឈដ្ឋាននានា ដែលប្រឆាំងចក្រពត្តិអាមេរិក និងបរិវាររបស់ខ្លួននៅប្រទេសកម្ពុជាអាចរួបរួមគ្នាឱ្យមានការពង្រឹង នូវតួនាទីរបស់បក្សកុម្មុយនិស្តឱ្យមានសន្ទុះដ៏ខ្លាំងក្លានៃកម្លាំងថ្មីៗ នៅក្នុងចលនាបដិវត្តន៍ប្រទេសកម្ពុជា។

នៅថ្ងៃទី២៣ មីនា ឆ្នាំ១៩៧០ ក្នុងសេចក្តីថ្លែងការណ៍ធ្វើនៅទីក្រុងប៉េកាំង នរោត្តម សីហនុ បានបញ្ជាក់ថា រដ្ឋប្រហារធ្វើឡើងដោយពួកប្រតិកិរិយា មានលក្ខណៈខុសច្បាប់ ខុសរដ្ឋធម្មនុញ្ញ ហើយបានថ្លែងប្រកាសរំលំរដ្ឋាភិបាល និងរដ្ឋសភាដែលមាននៅទីក្រុងភ្នំពេញ។ នៅពេលជាមួយគ្នា គាត់បានថ្លែងប្រកាសអំពីបំណងរបស់គាត់ ដើម្បីបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងកងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា។

នៅថ្ងៃទី២៣ មេសា ក្រុម “ ប្រជាជន ” ក៏បានថ្លែងគាំទ្រដល់សេចក្តីថ្លែងការណ៍របស់នរោត្តម សីហនុ។ ពីថ្ងៃទី៣ ដល់ថ្ងៃទី៤ ឧសភា ឆ្នាំ១៩៧០ មានការបើកសម័យប្រជុំសន្និបាតជាតិកម្ពុជាមួយ ដែលបានធ្វើសេចក្តីអនុម័តលើការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា។ សន្និបាតបានជ្រើសរើសគណៈកម្មាធិការមជ្ឈិម និងការិយាល័យនយោបាយនៃគណៈកម្មាធិការមជ្ឈិមរបស់រណសិរ្សរួបរួមជាតិកម្ពុជា ហើយបានបង្កើតរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។

នៅក្នុងកម្មវិធី នយោបាយរបស់រណសិរ្សរួបរួមជាតិកម្ពុជាអនុម័តយល់ព្រមដោយសម័យប្រជុំសន្និបាតនេះ មានសេចក្តីប្រកាសអំពីគោលដៅ ដើម្បីបង្រួបបង្រួមឯកភាពជាតិសម្រាប់

ការតស៊ូប្រឆាំងអំពើឈ្លានពាន នៃពួកចក្រពត្តិអាមេរិក ដើម្បីរំលំរបបគ្រប់គ្រងផ្តាច់ការទីក្រុងភ្នំពេញ ដើម្បីការពារឯករាជភាព សន្តិភាព អព្យាក្រឹតភាព អធិបតេយ្យភាព និងបូរណភាពទឹកដីនៃប្រទេស តាមព្រំប្រទល់បច្ចុប្បន្ន ដើម្បីការបង្កើតនូវរដ្ឋអំណាចប្រជាជន ប្រកបដោយលក្ខណៈប្រជាធិបតេយ្យ និងសេរីភាព ដើម្បីកសាងប្រទេសកម្ពុជា ដ៏សម្បូររុងរឿងស្របតាមឆន្ទៈដ៏ពិសិដ្ឋរបស់ប្រជាជនកម្ពុជា ។

កងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា កសាងឡើងដោយរណសិរ្សរួបរួមជាតិកម្ពុជា បានធ្វើការប្រយុទ្ធយ៉ាងខ្លាំងក្លា ក្នុងការវាយប្រហារលើកងទ័ពទីក្រុងភ្នំពេញ ។ កងកម្លាំងប្រដាប់អាវុធរំដោះជាតិកម្ពុជា មានកងទ័ពរៀបរយ កងអាសាស្ម័គ្រប្រជាជន និងកងឆ្មក់ ។

ដូចជានៅពេលមុនៗ នៅសម័យកាលនៃការតស៊ូប្រឆាំងពួកអាណានិគមនិយមបារាំង ប្រជាជនវៀតណាម បានមកជួយយកអាសារដល់បណ្តាអ្នកស្នេហាមាតុភូមិកម្ពុជា ។ ហេតុនេះហើយ បានជាក្នុងរយៈពេលដ៏ខ្លី កងកម្លាំងប្រដាប់អាវុធប្រជាជនកម្ពុជា បានទទួលគ្រឿងបច្ចេកទេសយោធា និងឯកសណ្ឋាននានា ផ្ញើមកពីសាធារណរដ្ឋប្រជាធិតេយ្យវៀតណាម តាមសេចក្តីសុំរបស់អ្នកស្នេហាមាតុភូមិកម្ពុជា ។ នៅឆ្នាំ១៩៧១ ដោយឆ្លើយតបតាមសេចក្តីអំពាវនាវពីភាគីកម្ពុជា កងទ័ពវៀតណាម បានចូលមកលើទឹកដីប្រទេសកម្ពុជា បានជួយយកអាសារដល់អ្នកស្នេហាមាតុភូមិកម្ពុជា ហើយព្រមទាំងបានទទួលជ័យជម្នះលើប្រតិបត្តិការសឹកឈ្មោះ “ ចេនឡាទី២ ” ចាប់ផ្តើមដោយកងទ័ពរបស់លន់ - ណុល ។ នៅពេលជាបន្ទាប់មក កងទ័ពប្រជា

ជនវៀតណាម បានរំដោះទាំងស្រុងដល់ខេត្តជាច្រើននៃប្រទេសកម្ពុជា ហើយខេត្តទាំងនេះ បានប្រគល់ឱ្យស្ថិតនៅក្រោមកិច្ចត្រួតត្រារបស់រណសិរ្សរួបរួមជាតិកម្ពុជា ដែលជាមូលហេតុអាចឱ្យរណសិរ្សពង្រឹងអំណាច និងពង្រីកកម្លាំងប្រដាប់អាវុធរបស់ខ្លួន។

ដល់ឆ្នាំ១៩៧៥ កងកម្លាំងប្រដាប់អាវុធរណសិរ្សរួបរួមជាតិកម្ពុជា ដោយមានការគាំទ្រពីកងទ័ពប្រជាជនវៀតណាមមួយភាគផង បានរំដោះ៩០% នៃទឹកដីប្រទេសកម្ពុជា។

ពួកអាមេរិក បានខំសាកល្បងស្រោចស្រង់របបគ្រប់គ្រងលន់ - ណុល តាមការបង្កើតផ្លូវដែលហៅថា “ ស្ពានអាកាស ” ដែលភ្ជាប់អាកាសយានដ្ឋានពោធិ៍ចិនតុង នៅជាយទីក្រុងភ្នំពេញទៅនឹងមូលដ្ឋានសឹកអាមេរិក នៅវៀតណាមខាងត្បូង និងនៅថៃឡង់ដ៍។ គឺតាម “ ស្ពានអាកាស ” នេះហើយ ដែលពួកអាមេរិកបានផ្តល់ជំនួយស្បៀង គ្រាប់រំសេវ ប្រេងឥន្ធនៈ អង្ករ មកដល់ទីក្រុងភ្នំពេញ។ ក៏ប៉ុន្តែ ការរលំរលើងនៃរបបគ្រប់គ្រងនេះមិនអាចចៀសផុតបានឡើយ។ ទោះបីមានការចងស្ពានអាកាសក្តី ទោះបីមានសេចក្តីថ្លែងការណ៍ លាក់ពុតរបស់រដ្ឋការភ្នំពេញ ស្តីអំពីបំណងចំពោះការបញ្ឈប់សង្គ្រាម និងការបង្រួបបង្រួមជាតិក្តី ក៏កិច្ចការទាំងនេះ មិនអាចជួយស្រោចស្រង់ដល់របបគ្រប់គ្រងលន់ - ណុល បានឡើយ។

នៅថ្ងៃទី១ មេសា ( ១៩៧៥ ) លន់ - ណុល បានចាកចេញពីទីក្រុងភ្នំពេញ។ ជាមួយនឹងលន់ - ណុល មានទាំងនាយទាហានជាន់ខ្ពស់ និងឧត្តមសេនីយ៍ជាង ៣០នាក់ ដែលបានភៀសខ្លួនទៅមូលដ្ឋានសឹកអាមេរិក ឈ្មោះ អ៊ូតាប៉ាវ នៅប្រទេសថៃឡង់ដ៍។ បន្ទាប់មក តាមរយៈប្រទេសឥណ្ឌូនេស៊ី ពួកទាំងនេះបានធ្វើដំណើរ

មកដល់កោះហាវ៉ៃ។ នៅថ្ងៃដាមួយគ្នា នៅពេលល្ងាច កងកម្លាំងអ្នកស្នេហាមាតុភូមិ បានវាយដណ្តើមយកបានចំណុចយុទ្ធសាស្ត្រដ៏សំខាន់មួយ គឺទីក្រុងអ្នកលឿង ដែលស្ថិតនៅចំងាយ ៥០គ.ម.ពីភ្នំពេញ។ ទីក្រុងនេះជាចំណុចការពារចុងក្រោយបំផុតរបស់របបគ្រប់គ្រងក្រុងភ្នំពេញ តាមទន្លេមេកុង និងជាសេចក្តីសង្ឃឹមចុងក្រោយ ក្នុងការទទួលជំនួយពីខាងក្រៅ តាមផ្លូវទឹក។

នៅថ្ងៃទី១១ - ១២ ខែមេសា តាមបញ្ជារបស់ឯកអគ្គរដ្ឋទូតអាមេរិក ឈ្មោះ ឌីន ពលរដ្ឋអាមេរិក ដែលនៅសេសសល់ចំនួន ៨២នាក់ ត្រូវបានចាកចេញពីទីក្រុងភ្នំពេញ តាមឧទ្ធម្ភាគចក្រ ៣៦គ្រឿង ក្រោមកិច្ចការពាររបស់ទាហានជើងទឹកអាមេរិក ចំនួន ៣៥០នាក់។ ការរៀបចំដំណើរចាកចេញរបស់ពលរដ្ឋអាមេរិក នេះមានឈ្មោះជាសំងាត់ថា “អ៊ីគ្ល ពូល”។ អ្នកឆ្លើយឆ្លងសារព័ត៌មាន “ ញូវយ៉កថៃម ” នាម ស៊ីដណី - សេនប៊ែក បានសរសេរអំពីដំណើរចាកចេញនេះថា៖ “ បន្ទាប់ពីពេលដែលសហរដ្ឋអាមេរិកបានជួយដល់រដ្ឋាភិបាលសក្តិភូមិ អស់រយៈពេលចំនួន៥ឆ្នាំ ហើយដែលសហរដ្ឋអាមេរិក បានមើលងាយ បានដឹកនាំសង្គ្រាមដែលគេទាំងអស់គ្នាដឹងច្បាស់ថា ជាសង្គ្រាមគ្មានទីសង្ឃឹម នៅទីបំផុតសហរដ្ឋអាមេរិក គ្មានអ្វីបង្ហាញដល់ពិភពលោក ក្រៅពីទិដ្ឋភាពដ៏ក្រៀមក្រំនៃដំណើរចាកចេញរបស់ពលរដ្ឋអាមេរិក ដែលនៅពេលនោះ អគ្គរដ្ឋទូត ដៃម្ខាងបានកាន់ទង់ជាតិអាមេរិក ហើយដៃម្ខាងទៀត បានខំអូសទាញហិបរបស់ខ្លួនមួយយ៉ាងធំសម្បើម។

ក៏ប៉ុន្តែ ផលវិបាកនៃសង្គ្រាមនេះ គឺមានជនជាតិកម្ពុជារបួស និងស្លាប់ចំនួន១លាននាក់ ចំនួន១/៧ នៃប្រជាជន មាន

មនុស្សភៀសខ្លួនរាប់សែននាក់ ដែលរស់នៅក្នុងរោងប្រក់ស្លឹកដ៏រហែមរហាម ប្រទេសទៅជាទីរហោដ្ឋាន កុមារស្លាប់បាត់បង់ជីវិតដោយក្តីអត់ឃ្លាន ហើយដាងឈើបានធ្វើមឈូសខ្មោចពីបន្ទះឡាំង ដែលដាក់គ្រាប់រំសេវ។

អំពើជ្រៀតជ្រែកដ៏គ្រោតគ្រាតមកក្នុងកិច្ចការផ្ទៃក្នុង និងអំពើឈ្លានពានរបស់សហរដ្ឋអាមេរិក មកក្នុងប្រទេសកម្ពុជា អស់រយៈពេលចំនួន៥ឆ្នាំ បានចប់សព្វគ្រប់ យ៉ាងជូរចត់បែបនេះ។

កាសែតវៀតណាមឈ្មោះ“ញ៉ាន សាន”បានធ្វើអត្ថាធិប្បាយអំពីដំណើរចាកចេញរបស់បុគ្គលិកអាមេរិក ពីទីក្រុងភ្នំពេញ ថា ៖ “ ដំណើរចាកចេញរបស់បុគ្គលិកទូត និងយោធាសហរដ្ឋអាមេរិក ពីទីក្រុងភ្នំពេញ មានន័យថា ទីក្រុងវ៉ាស៊ីនតោន បានទទួលស្គាល់នូវបរាជ័យពេញទី របស់ខ្លួនក្នុងនយោបាយឈ្លានពាន និងក្នុងអំពើជ្រៀតជ្រែកខាងយោធា និងខាងផ្លូវទូតមកក្នុងកិច្ចការប្រទេសកម្ពុជា អស់រយៈពេលចំនួន៥ឆ្នាំ ”។ កាសែតបានសរសេរបន្តថា ៖ “ ធាតុពិតនៃនយោបាយនេះ គឺរដ្ឋប្រហារប្រតិកិរិយា ប្រឆាំងរដ្ឋាភិបាលត្រឹមត្រូវតាមច្បាប់។ ការបញ្ជូនកងទ័ពអាមេរិក ឱ្យមកឈ្លានពានទឹកដីកម្ពុជា ការប្រើប្រាស់កម្លាំងប្រតិបដិវត្តន៍ប្រឆាំងអ្នកស្នេហាមាតុភូមិ ”។ បន្ទាប់ពីពេលដែលពួកអាមេរិក បានចេញផុតពីទីក្រុងភ្នំពេញ ស្ថានភាពប្រកបដោយអនាធិបតេយ្យ ច្របូកច្របល់ភ័យចលាចល បានគ្រប់ដណ្តប់លើសំណល់នៃរបបគ្រប់គ្រង លន់ - ណុល។ ពួកអាមេរិក បានចាកចោលទីក្រុងភ្នំពេញ ដោយការឈប់ផ្តល់ជំនួយអង្ករ ប្រេងឥន្ធនៈ និងគ្រាប់រំសេវ ដល់ទីក្រុងភ្នំពេញ។ ដោយហេតុថា គ្មានកិច្ចធានាដល់សន្តិសុខ នៃចរាចរណ៍តាម

អាកាស។ រដ្ឋសភានៅទីក្រុងភ្នំពេញ និងបក្សនយោបាយទាំងឡាយបានបញ្ឈប់សកម្មភាពរបស់ខ្លួន។ ប្រធានាធិបតីស្ដីទីឈ្មោះ សូ ខាំខូយ គាត់បានបំពេញមុខងារជាប្រធានាធិបតីតែក្នុងអំឡុងពីថ្ងៃទី១ ដល់ថ្ងៃទី១២ មេសា ឆ្នាំ១៩៧៥ ត្រូវបានចោទប្រកាន់ថា ជាអ្នកប្រព្រឹត្តអំពើឧក្រិដ្ឋរដ្ឋ ដោយហេតុថា គាត់បានសាកល្បងបញ្ឈប់ការតស៊ូដោយអាវុធ ហើយសុខចិត្តឱ្យទីក្រុងភ្នំពេញ ចុះចាញ់ចំពោះអ្នកស្នេហាមាតុភូមិ។ នៅថ្ងៃ១៤ មេសា យន្តហោះទម្លាក់គ្រាប់បែកធុនតេ - ២៨ ជាជំនួយអាមេរិក ដល់របបគ្រប់គ្រងភ្នំពេញ បានហោះហើរទៅទម្លាក់គ្រាប់បែកលើទីអគ្គមេបញ្ជាការកងទ័ពរបស់របបគ្រប់គ្រងនេះ។

នៅថ្ងៃទី១៤ មេសា កងកម្លាំងអ្នកស្នេហាមាតុភូមិ វាយដណ្ដើមយកបានអាកាសយានដ្ឋានរដ្ឋធានី ហើយនៅថ្ងៃទី១៧ មេសា អង្គភាពនៃកងទ័ពរំដោះបានចូលដល់ទីក្រុងភ្នំពេញ។ បន្ទាប់ពីការរំដោះរដ្ឋធានី ទីក្រុងដទៃទៀតនៃប្រទេសកម្ពុជា ក៏ត្រូវបានរំដោះជាបន្តបន្ទាប់។ សំណល់នៃរបបគ្រប់គ្រងមុនបានរលំរលើង ហើយបានប្រកាសសារភាពការចុះចាញ់របស់ខ្លួន។ ការប្រយុទ្ធរបស់កងកម្លាំងអ្នកស្នេហាមាតុភូមិ ដែលបានប្រព្រឹត្តទៅអស់រយៈពេលចំនួន៥ឆ្នាំ និង១ខែ បានបញ្ចប់ដោយជ័យជម្នះពេញលេញរបស់កងកម្លាំងស្នេហាមាតុភូមិ និងដោយបរាជ័យដ៏អាក្រក់អាក្រីនៃរបបគ្រប់គ្រងលន់ - ណុល គាំទ្រដោយកម្លាំងចក្រពត្តិនិយមអាមេរិក។ ជាលទ្ធផលនៃការប្រយុទ្ធដោយអាវុធ និងការទម្លាក់គ្រាប់បែកអាមេរិក ជនជាតិកម្ពុជា ជាង១លាននាក់ បានបាត់បង់ជីវិត បានរងរបួស និងទៅជាមនុស្សពិការ។ នៅក្នុងប្រទេស រោងឧស្សាហកម្ម ៤/៥ ត្រូវបានបំផ្លិច

បំផ្លាញចម្ការដំណាំកៅស៊ូ ២/៣ ត្រូវបានបាត់បង់ ផ្លូវថ្នល់និងផ្លូវដែក ពី៧០ - ៨០% ត្រូវបានខូចខាត ហើយកំពង់ផែ និងកំពង់ចម្លងក៏បានទទួលខូចខាតជាទម្ងន់។

នៅក្នុងជ័យជម្នះ របស់ខ្លួនលើពួកឈ្លានពានអាមេរិកព្រៃនគរ និងលើរបបគ្រប់គ្រងប្រតិកិរិយាអាមេរិកនិយមរបស់លន់ - ណុល ប្រជាជនកម្ពុជា ទទួលការឧបត្ថម្ភជាអាទិពីសំណាក់នៃការចូលរួមរបស់ជនកុម្មុយនិស្ត និងអ្នកស្នេហាមាតុភូមិដ៏ស្មោះស្ម័គ្រនៃប្រទេសកម្ពុជា នៅក្នុងការតស៊ូរំដោះជាតិនេះ។ គេទាំងឡាយរាប់ពាន់នាក់ បានបាត់បង់ជីវិតនៅក្នុងការតស៊ូដើម្បីសេរីភាព និងឯករាជភាពនៃមាតុភូមិ។ ជាពិសេស គឺដោយសារសកម្មភាពប្រឹងប្រែង របស់ជនកុម្មុយនិស្តទាំងឡាយនេះហើយ បានជារណសិរ្សរួបរួមជាតិបានទៅជាអង្គការមហាជនមួយដ៏ធំទូលាយ។

ក្រុម “ ប្រជាជន ” បានចូលរួមនៅក្នុងរណសិរ្សរួបរួមជាតិកម្ពុជា ហើយអង្គការមហាជន សមាគមកម្មករ កសិករ នារី យុវជន អ្នកនិពន្ធ បញ្ញវន្ត និងអង្គការដទៃទៀត ក៏បានចូលរួមក្នុងជួររណសិរ្សដែរ។ មិនតែប៉ុណ្ណោះ នៅក្នុងជួររណសិរ្ស មានទាំងការចូលរួមពីសំណាក់គណៈសង្ឃនៃពុទ្ធសាសនា និងសមាជិកនៃរាជវង្សានុវង្សជាច្រើនទៀតផង។ លក្ខណៈនៃសមាសភាពដ៏ទូលំទូលាយរបស់រណសិរ្សរួបរួមជាតិកម្ពុជា បានធានារ៉ាប់រងឱ្យមានការគាំទ្រពីស្រទាប់នានានៃប្រជាជនកម្ពុជា។ គេទាំងឡាយបានរួបរួមកម្លាំងគ្នា ក្នុងគោលបំណងនឹងរៀបចំនូវអធិបតេយ្យភាពឯករាជភាព និងបូរណភាពទឹកដីនៃប្រទេស។

នៅខែកក្កដា ឆ្នាំ១៩៧៣ មានបើកសម័យប្រជុំសន្និបាតជាតិទី១ នៃកងកម្លាំងស្នេហាមាតុភូមិកម្ពុជា ហើយចាប់ពីថ្ងៃទី២៤ - ២៥ ខែកុម្ភៈ ឆ្នាំ១៩៧៥ មានបើកសន្និបាតជាតិបែបនេះជាលើកទី២។ សមាជិកចូលរួមក្នុងសន្និបាតទាំងនេះ បានកំណត់គោលដៅនានា ដ៏ច្បាស់លាស់នៃការតស៊ូដើម្បីការកសាងជាតិឡើងវិញ ដើម្បីឯករាជ្យភាពដ៏ពិតប្រាកដ ដើម្បីសន្តិភាព និងអព្យាក្រឹតភាពនៃប្រទេស។

ចំណែកឯរបបគ្រប់គ្រងភ្នំពេញ វិញ នៅក្នុងរបបនេះមានអ្នកនយោបាយខាងស្តាំ បានចូលរួបរួមនៅខែមេសា ឆ្នាំ១៩៧០ ពួកអ្នកទាំងនេះ បានពួតដៃគ្នាសំដែងនូវសំអប់របស់ខ្លួនចំពោះរបបគ្រប់គ្រងដែលមានមកហើយនៅពេលនោះ នៅក្នុងប្រទេសកម្ពុជា។ ក៏ប៉ុន្តែ បន្ទាប់ពីការដណ្តើមអំណាចគ្នាក្នុងបណ្តាអ្នកដឹកនាំរបបគ្រប់គ្រងទីក្រុងភ្នំពេញ ក៏មានការចាប់ផ្តើមបែកបាក់គ្នា ដែលមានស្ថានភាពកាន់តែតានតឹងនៅពេលខាងចុងនៃរបបគ្រប់គ្រងនេះ។ អ្នកដឹកនាំមួយចំនួនបានសុំលាចេញពីរដ្ឋាភិបាល ដោយបានធ្វើការទិតៀនជាខ្លាំងដល់ លន់ - ណុល និងមនុស្សជាដៃជើងជិតដិតរបស់គាត់ដទៃទៀត។

នៅសម័យកាលនៃរបបគ្រប់គ្រងលន់ ណុល និងនៅសម័យកាលនៃសង្គ្រាមនៅប្រទេសកម្ពុជា ប្រទេសដ៏សម្បូរសប្បាយបានប្រែទៅជាទីអន្តរាយដ៏រហោស្ថាន។ នៅក្នុងតំបន់ខ្លះ ដែលស្ថិតនៅក្រោមការត្រួតត្រារបស់របបលន់ ណុល ផលិតកម្មខាងកសិកម្មបានចុះដល់ ១/៤ ខាងឧស្សាហកម្មបានចុះដល់១/៨ បើប្រៀបធៀបទៅនឹងស្ថិតិនៃសម័យកាលមុនសង្គ្រាម។ កាលមុនប្រទេសកម្ពុជា ជាប្រទេសដែលនាំអង្ករទៅលក់នៅប្រទេសក្រៅ

តមក ក៏បានប្រែទៅជាប្រទេសដែលបានទិញអង្ករពីប្រទេសក្រៅទៅវិញ។ ទំនិញជាចាំបាច់សម្រាប់ជីវភាពបានឡើងថ្លៃហួសកម្រិតអតិផរណា ប្រាក់ចុះថ្លៃ ភាពឥតការធ្វើ អំពើពុករលួយ ក៏មានកម្រិតខ្ពស់ឥតឧបមា។ កងទ័ពបានបាត់បង់វិន័យ ទាហាន និងនាយទាហានបានរត់ចេញពីកងទ័ព ហើយចូលមកខាងកងកម្លាំងនៃអ្នកស្នេហាមាតុភូមិ។

របបគ្រប់គ្រងលន់ ណុល គ្មានឥទ្ធិពលរបស់ខ្លួន មិនមែនតែនៅប្រទេសកម្ពុជា ទេ ប៉ុន្តែ នៅប្រទេសដទៃជាច្រើន ដែលនៅក្នុងនេះមានទាំងប្រទេសមូលធននិយម ជាអាទិ សហរដ្ឋអាមេរិកទៀតផង។ សកម្មភាពខ្លះៗរបស់រដ្ឋសភាអាមេរិក បានបញ្ជាក់ឱ្យឃើញនូវកំហឹងនៃសាធារណជនអាមេរិក ចំពោះរបបគ្រប់គ្រងនេះ។ រដ្ឋសភាអាមេរិក បានហាមឃាត់ និងបញ្ឈប់ការផ្តល់ជំនួយដល់ប្រតិបត្តិការយោធាសហរដ្ឋអាមេរិក នៅប្រទេសកម្ពុជា បន្ទាប់ពីថ្ងៃទី១៥ សីហា ឆ្នាំ១៩៧៣ទៅ រដ្ឋសភានេះបានបន្ថយជំនួយយោធាសម្រាប់ឆ្នាំ១៩៧៤-១៩៧៥ ដល់របបគ្រប់គ្រងលន់ ណុល ហើយមិនព្រមបន្ថែមជំនួយសម្រាប់ឆ្នាំ១៩៧៥។ នៅក្នុងលក្ខខណ្ឌបែបនេះ អ្នកនយោបាយសហរដ្ឋអាមេរិក ជាច្រើនបានយល់ច្បាស់ថា គ្មានជំនួយណាមួយអាចជួយស្រោចស្រង់ដល់របបគ្រប់គ្រងដ៏ពុករលួយ ឱ្យមានជីវិតតទៅទៀតបានឡើយ។

ជំនួយ និងការគាំទ្ររបស់ប្រជាជនវៀតណាម ព្រមទាំងឯកភាព និងយុទ្ធសាមគ្គីភាពរវាងប្រជាជនទាំងបីប្រទេសនៅឥណ្ឌូចិន គឺវៀតណាម ឡាវ និងកម្ពុជា មានអត្ថន័យដ៏សំខាន់សម្រាប់ជ័យជម្នះរបស់ប្រជាជនកម្ពុជា។

កាលពីថ្ងៃទី២៥ មេសា ឆ្នាំ១៩៧០ រដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម បានធ្វើសេចក្តីថ្លែងការណ៍ពិសេសមួយដែលនៅក្នុងនេះមានការគូសបញ្ជាក់ថា នៅក្នុងការសាកល្បងបន្តសង្គ្រាមនៅវៀតណាមខាងត្បូង តាមមធ្យោបាយ " វៀតណាមូបនីយកម្ម " សង្គ្រាមនេះ និងក្នុងការបង្កើតភ្លើងសង្គ្រាមនៅប្រទេសឡាវ នៅពេលជាមួយគ្នា មជ្ឈដ្ឋានអ្នកដឹកនាំសហរដ្ឋអាមេរិក បានពង្រីកអំពើឈ្លានពានរបស់ខ្លួនមកក្នុងកិច្ចការនៃប្រទេសកម្ពុជា ដោយមានបំណងកែប្រែប្រទេសនេះឱ្យទៅជាប្រទេសអាណានិគមតាមបែបថ្មី ហើយដើម្បីបង្កើតប្រព័ន្ធមូលដ្ឋានយោធានានា ដែលស្ថិតនៅតាំងពីវៀតណាមខាងត្បូង ដល់ប្រទេសថៃឡង់ដ៍ ដោយបូកបញ្ចូលទាំងប្រទេសកម្ពុជា និងឡាវ ទៀតផង។

នៅក្នុងសេចក្តីថ្លែងការណ៍នេះ មានការគូសបញ្ជាក់ជាពិសេសថា រាជរដ្ឋាភិបាលសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាមនឹងផ្តល់ការគាំទ្រឥតល្អៀងរបស់ខ្លួនដល់ប្រទេសកម្ពុជា និងដល់ប្រជាជនដទៃនៅឥណ្ឌូចិន ដែលធ្វើការតស៊ូប្រឆាំងពួកឈ្លានពានចក្រពត្តិអាមេរិក។

រដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្ន នៃសាធារណរដ្ឋវៀតណាមខាងត្បូង និងគណៈកម្មាធិការមជ្ឈិមនៃរណសិរ្សស្នេហាមាតុភូមិប្រទេសឡាវ ក៏បានធ្វើសេចក្តីថ្លែងការណ៍ដូចៗគ្នាដែរ។

សន្និសីទកំពូលប្រជាជនឥណ្ឌូចិន បានប្រព្រឹត្តទៅនៅថ្ងៃទី២៤-២៥ មេសា ឆ្នាំ១៩៧០។ សមាជិកចូលរួមក្នុងសន្និសីទបានធ្វើសេចក្តីអំពាវនាវដល់ប្រជាជនទាំងបីប្រទេស នៅឥណ្ឌូចិនឱ្យពង្រឹងសាមគ្គីភាព ហើយធ្វើការតស៊ូប្រឆាំងពួកចក្រពត្តិនិយមអាមេរិក និងបរិវាររបស់វា ដើម្បីការពារសិទ្ធិជាតិនានា ដើម្បី

ឱ្យឥណ្ឌូចិន ទៅជាតំបន់នៃឯករាជភាព និងសន្តិភាពពិតប្រាកដ ស្របតាមសុឆន្ទៈរបស់ប្រជាជនទាំងបីប្រទេស និងស្របតាមផលប្រយោជន៍នៃសន្តិភាពនៅអាស៊ីអាគ្នេយ៍ និងលើពិភពលោកទាំងមូល។

ក្នុងសេចក្តីអំពាវនាវមានការបញ្ជាក់ថា ការតស៊ូរំដោះជាតិ និងកិច្ចការពារប្រទេសនីមួយៗ គឺជាកិច្ចការផ្ទាល់របស់ប្រជាជនជាសាមីនៃប្រទេសនោះ។ សមាជិកចូលរួមក្នុងសន្និសីទទាំងអស់ត្រូវមានកាតព្វកិច្ច ផ្តល់ការគាំទ្រគ្រប់បែបយ៉ាងទៅវិញទៅមក ស្របទៅតាមសំណូមពរនៃប្រទេសនីមួយៗនៅលើមូលដ្ឋាននៃការគោរពគ្នាទៅវិញទៅមក។ នៅពេលសន្និសីទ សមាជិកទាំងឡាយបានយកចិត្តទុកដាក់ ជាពិសេសដល់ស្ថានភាពប្រទេសកម្ពុជា។ សមាជិកចូលរួមក្នុងសន្និសីទទាំងអស់បានគាំទ្រយ៉ាងម៉ឺងម៉ាត់ដល់ការតស៊ូដ៏អង់អាចរបស់ប្រជាជនកម្ពុជា។ សេចក្តីសម្រេចនានា របស់សម័យប្រជុំសន្និសីទបានទៅជាមូលដ្ឋានដ៏រឹងមាំសម្រាប់យុទ្ធសាមគ្គីភាពនៃប្រជាជននានា នៅឥណ្ឌូចិននៅក្នុងការតស៊ូរបស់ខ្លួនដើម្បីសេរីភាព និងឯករាជភាព។ គេទាំងឡាយបានបង្កើតមូលដ្ឋាន តាមផ្លូវច្បាប់មួយសម្រាប់សម្របសម្រួលការប្រឹងប្រែងនៃប្រទេសទាំងបីនៅឥណ្ឌូចិន នៅក្នុងការធ្វើសង្គ្រាមប្រឆាំងពួកឈ្លានពានអាមេរិក។

ដូចគេបានដឹងច្បាស់មកហើយថា ការរំដោះដ៏ពេញលេញនៃប្រទេសកម្ពុជា មានលក្ខណៈស្របគ្នាទៅនឹងពេលវេលានៃការបញ្ចប់ការតស៊ូរំដោះជាតិនៅវៀតណាមខាងត្បូង ទៅនឹងជ័យជម្នះនៃកម្លាំងចម្រើននិយមលើពួកប្រតិកិរិយា នៅប្រទេសឡាវ។ ហើយកិច្ចការនេះមិនមែនជាចៃដន្យទេ។ ប្រជាជននានា

នៅប្រទេសវៀតណាម កម្ពុជា ឡាវ ធ្លាប់មានការទាក់ទងគ្នាដ៏ជិតស្និទ្ធពីយូរយាមកហើយ ក្នុងការតស៊ូដើម្បីសេរីភាព ឯករាជភាព និងវឌ្ឍនភាពសង្គម។ ក្នុងការទទួលផ្លែផ្កានៃការតស៊ូនេះ ប្រជាជនវៀតណាម កម្ពុជា និងឡាវ អាចជួយគ្នាទៅវិញទៅមក អាចប្តូរបទពិសោធន៍រវាងគ្នានឹងគ្នា ដោយសារជោគជ័យនិងសមិទ្ធិនានារបស់គេ។

ជាដរាប សហភាពសូវៀត បានគាំទ្រដល់ការតស៊ូរបស់ប្រជាជនកម្ពុជា ដើម្បីសេរីភាព បូរណភាពទឹកដី និងវឌ្ឍនភាពខាងសង្គមកិច្ចរបស់ប្រទេសនេះ។ នៅក្នុងការទាក់ទងរបស់ខ្លួនជាមួយប្រទេសកម្ពុជា សហភាពសូវៀត បានសង្កត់ទៅលើមូលដ្ឋាននៃគោលការណ៍សហវិជ្ជមានដ៏សុខសាន្ត នៃសមភាពនៃការយោគយល់គ្នាទៅវិញទៅមក និងការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជា។

នៅក្នុងសេចក្តីថ្លែងការណ៍ របស់ទីភ្នាក់ងារសារព័ត៌មានតាស្សសហភាពសូវៀត ចុះផ្សាយនាថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៧០ មានការផ្តន្ទាទោសដ៏ម៉ឺងម៉ាត់ ដល់សកម្មភាពដ៏ឧក្រិដ្ឋរបស់រដ្ឋអំណាចយោធាទីក្រុងភ្នំពេញ ប្រឆាំងអាណិកជនវៀតណាម ដែលរស់នៅលើទឹកដីប្រទេសនេះ។

សេចក្តីថ្លែងការណ៍ របស់ទីភ្នាក់ងារសារព័ត៌មានតាស្ស ចុះថ្ងៃទី១ ខែឧសភា ឆ្នាំ១៩៧០ បានបញ្ជាក់ថា ការលុកលុយនៃកងទ័ពអាមេរិក មកលើប្រទេសកម្ពុជា ទុកដូចជាអំពើឈ្លានពានមួយ ដើម្បីពង្រីកសមរភូមិនៃយុទ្ធនាការនៅលើទឹកដីឥណ្ឌូចិនទាំងមូល គឺជាការសាកល្បងបន្ទាក់បន្ទាញប្រទេសកម្ពុជា ឱ្យឃ្លាតចេញពីមាគ៌ាសន្តិភាព និងអព្យាក្រឹតភាព។ សេចក្តីថ្លែងការណ៍

បានគូសបញ្ជាក់តទៅទៀតថា អំពើឈ្លានពានរបស់សហរដ្ឋអាមេរិក បានធ្វើឱ្យស្ថានភាពនៅឥណ្ឌូចិន និងនៅអាស៊ីភាគអាគ្នេយ៍ទាំងមូលកាន់តែធ្ងន់ធ្ងរ ហើយបានបង្កើតឱ្យមានសេចក្តីភ័យបារម្ភដ៏ត្រឹមត្រូវតាមច្បាប់។

សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលសូវៀត ចុះផ្សាយនៅថ្ងៃទី៤ ឧសភា បានផ្តន្ទាទោសយ៉ាងម៉ឺងម៉ាត់ដល់អំពើឈ្លានពានខាងយោធារបស់សហរដ្ឋអាមេរិក ប្រឆាំងប្រទេសកម្ពុជា។ សេចក្តីថ្លែងការណ៍នេះបានបញ្ជាក់ថា៖ “ គ្មានសេចក្តីសង្ស័យអ្វីទេថា ការពង្រីកអំពើឈ្លានពានអាមេរិក នៅអាស៊ីភាគអាគ្នេយ៍នឹងជួបប្រទះការតស៊ូប្រឆាំងកាន់តែអង់អាច កាន់តែសក្តិសិទ្ធិពីសំណាក់ប្រជាជននានា ដែលទទួលការកៀបសង្កត់របស់ពួកចក្រពត្តិ ពីសំណាក់របស់ប្រជាជនទាំងឡាយលើពិភពលោក ដែលស្នេហាសន្តិភាព សេរីភាព ប្រជាជន ”។

សហភាពសូវៀត បានធ្វើគារវកិច្ចដល់ការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា ដល់ការពង្រឹងរណសិរ្សរួមប្រឆាំងចក្រពត្តិនិយមរវាងប្រជាជននានានៅឥណ្ឌូចិន ព្រមទាំងដល់វិធានការនានាដែលចាត់ចែងឡើង ដើម្បីរៀបចំការតស៊ូរបស់កងកម្លាំងអ្នកស្នេហាមាតុភូមិ នៃប្រទេសកម្ពុជា ប្រឆាំងអំពើឈ្លានពានអាមេរិក។

នៅថ្ងៃទី២៤ ឧសភា ឆ្នាំ១៩៧០ តាមបញ្ជារបស់រដ្ឋាភិបាលសូវៀត អគ្គរដ្ឋទូតសហភាពសូវៀត ប្រចាំប្រទេសកម្ពុជា បានធ្វើសេចក្តីថ្លែងការណ៍ដល់រដ្ឋអំណាចនៅភ្នំពេញ ថា អំពើឈ្លានពានលុកលុយទឹកដីប្រទេសកម្ពុជា ដោយកងយោធាអាមេរិក និងព្រៃនគរ គឺជាការឈ្លានពានដ៏គ្រោតគ្រាតដល់សន្ធិសញ្ញាហ្សឺណែវ នាឆ្នាំ១៩៥៤ ស្តីអំពីឥណ្ឌូចិន និងដល់ច្បាប់អន្តរជាតិ

ដែលបានអនុវត្តជាធរមានទូទៅ។ នៅក្នុងសេចក្តីថ្លែងការណ៍ មានការបញ្ជាក់ថា នយោបាយសន្តិភាពនិយម នយោបាយអព្យាក្រឹត ការតស៊ូរបស់ប្រទេសកម្ពុជា ដើម្បីសន្តិភាពប្រឆាំងអំពើឈ្លានពានរបស់ចក្រពត្តិនិយម អនុវត្តមករហូតដល់ថ្ងៃទី ១៨ មីនា ឆ្នាំ១៩៧០ ជានយោបាយដែលបម្រើផលប្រយោជន៍ពិតប្រាកដក្នុងរយៈកាលដ៏យូរសម្រាប់ប្រទេសកម្ពុជា។ នៅពេលក្រោយមក អគ្គរដ្ឋទូតសូវៀត បានធ្វើដំណើរចាកចេញពីក្រុងភ្នំពេញ។

នៅក្នុងសេចក្តីថ្លែងការណ៍ របស់ក្រុមប្រឹក្សាជាន់ខ្ពស់នៃសហភាពសូវៀត ចុះផ្សាយថ្ងៃទី១៥ កក្កដា ឆ្នាំ១៩៧០ មានការផ្តន្ទាទោសដ៏មុឺងម៉ាត់ ដល់ការពង្រីកយុទ្ធនាការរបស់សហរដ្ឋអាមេរិក មកលើទឹកដីកម្ពុជា។

សម័យប្រជុំនៃមហាសន្និបាតទី២៤ របស់បក្សកុម្មុយនិស្តសហភាពសូវៀត បានថ្លែងគាំទ្រដល់អ្នកស្នេហាមាតុភូមិប្រទេសកម្ពុជា។ នៅក្នុងសេចក្តីអំពាវនាវអនុម័តនាថ្ងៃទី៨ ខែមេសា ឆ្នាំ ១៩៧១ “ សេរីភាព និងសន្តិភាព ត្រូវមានដល់ប្រជាជននានានៅតឥណ្ឌូចិន! ” មានសេចក្តីដូចតទៅ៖ “ យើងសូមថ្លែងនូវសមានចិត្ត និងការគាំទ្ររបស់យើងដល់កម្លាំងអ្នកស្នេហាមាតុភូមិនៅប្រទេសឡាវ និងកម្ពុជា ដែលកំពុងដឹកនាំការតស៊ូដ៏អង់អាចប្រឆាំងអន្តរាគមន៍ចក្រពត្តិនៃសហរដ្ឋអាមេរិក ដើម្បីការពារបុព្វហេតុដ៏ត្រឹមត្រូវរបស់គេ ”។ នៅក្នុងសេចក្តីអំពាវនាវនេះ មានការគូសបញ្ជាក់ថា មូលដ្ឋានដ៏សមហេតុសមផលសម្រាប់ការដោះស្រាយបញ្ហាកម្ពុជា គឺជាសេចក្តីស្នើនានារបស់រណសិរ្សរួបរួមជាតិកម្ពុជា ហើយតទៅអនាគត ក៏ដូចជានៅក្នុងអតីតកាល សហភាពសូវៀត គាំទ្រដល់ចលនារំដោះជាតិនៅប្រទេសកម្ពុជា។

ឯកសារនានាអនុម័តដោយ បក្សកុម្មុយនិស្តសហភាពសូវៀត ដោយក្រុមប្រឹក្សាជាន់ខ្ពស់ និងដោយរដ្ឋាភិបាលសូវៀត ព្រមទាំងសេចក្តីថ្លែងដទៃនៃអ្នកដឹកនាំសូវៀត បានថ្លែងនូវការគាំទ្រដល់ការតស៊ូរបស់អ្នកស្នេហាមាតុភូមិកម្ពុជា។

សារព័ត៌មានសូវៀត នានា បានចុះផ្សាយដ៏ក្បោះក្បាយនូវកម្មវិធីរបស់រណសិរ្សរួបរួមជាតិ ព្រមទាំងអត្ថបទនានាស្តីអំពីការគាំទ្រដល់រណសិរ្សនេះ។ សហភាពសូវៀត ចាត់ទុករណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា បង្កើតឡើងដោយរណសិរ្សនេះថា ជាអង្គការដឹកនាំដ៏ពិតប្រាកដរបស់ប្រជាជនកម្ពុជា ដែលដឹកនាំការតស៊ូ ដើម្បីសេរីភាព និងឯករាជ្យភាពរបស់ប្រទេសកម្ពុជា។ នៅអង្គការសហប្រជាជាតិ គណៈប្រតិភូសូវៀត បានថ្លែងជានិច្ច ដើម្បីការទទួលស្គាល់ដល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលត្រូវទុកដូចជាអ្នកតំណាងត្រឹមត្រូវពេញច្បាប់តែមួយគត់របស់ប្រទេសកម្ពុជា។ អង្គការរដ្ឋ និងអង្គការមហាជនសូវៀត ទទួលអបអរសាទរដល់បណ្តាអ្នកដឹកនាំនៃរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ដែលបានមកធ្វើទស្សនកិច្ចនៅសហភាពសូវៀត។ ហើយទោះបីបន្ទាប់ពីមានរដ្ឋប្រហារនៅទីក្រុងភ្នំពេញ ក៏ដោយ ក៏ស្ថានទូតរាជរដ្ឋាភិបាលកម្ពុជា ដឹកនាំដោយរណសិរ្សរួបរួមជាតិកម្ពុជា នៅតែបន្តកិច្ចការរបស់ខ្លួនប្រចាំទីក្រុងម៉ូស្គូ។

ប្រជាជនសូវៀត យល់ថា ការតស៊ូរបស់អ្នកស្នេហាមាតុភូមិកម្ពុជា ប្រឆាំងពួកឈ្លានពានអាមេរិក-ព្រៃនគរ ប្រឆាំងរបបគ្រប់គ្រងអាយ៉ងអាមេរិកនិយមរបស់ លន់ - ណុល ជាការតស៊ូមួយដែលស្ថិតនៅក្នុងសមាសភាពដ៏សំខាន់ នៃការតស៊ូទូទៅរបស់ប្រជាជន

នានានៅឥណ្ឌូចិន ប្រឆាំងអំពើឈ្លានពាន និងអំពើជ្រៀតជ្រែករបស់ចក្រពត្តិនិយម មកក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសទាំងនេះ ដើម្បីការពារសិទ្ធិ ក្នុងការដោះស្រាយជោគវាសនារបស់ខ្លួនដោយខ្លួនឯង ។

អង្គការមហាជន សារព័ត៌មាន វិទ្យុ និងទូរទស្សន៍សូវៀត បានថ្លែងគាំទ្រដ៏សកម្ម ដល់ការតស៊ូដ៏ត្រឹមត្រូវរបស់អ្នកស្នេហាមាតុភូមិកម្ពុជា ។ សប្តាហ៍នៃសាមគ្គីភាពជាមួយការតស៊ូរបស់អ្នកស្នេហាមាតុភូមិកម្ពុជា បានប្រព្រឹត្តទៅនៅទីក្រុងម៉ូស្គូ នៅទីក្រុងឡេនីនក្រាដ នៅរដ្ឋធានីនៃសាធារណរដ្ឋសង្គមនិយមសូវៀតនានា និងនៅទីក្រុងដទៃទៀត នៃសហភាពសូវៀត ។

នៅក្នុងសារលិខិតសំដែងគារវកិច្ច របស់អ្នកដឹកនាំសូវៀត ចុះថ្ងៃទី១៨ មេសា ឆ្នាំ១៩៧៥ ទាក់ទងនឹងការរំដោះទីក្រុងភ្នំពេញ មានសេចក្តីដូចតទៅ៖ “ស្មោះស្ម័គ្រនឹងគោលការណ៍នានា នៃអន្តរជាតិនិយម និងសាមគ្គីភាពជាមួយប្រទេសទាំងឡាយ ដែលតស៊ូដើម្បីការរំដោះជាតិខ្លួន សហភាពសូវៀត ជានិច្ចកាល គាំទ្រដល់អ្នកស្នេហាមាតុភូមិកម្ពុជា ដល់រណសិរ្សរួបរួមជាតិ និងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ”។ សហភាពសូវៀត នឹងពង្រីកតទៅអនាគតនូវទំនាក់ទំនងជាប្រពៃណីនៃមិត្តភាព និងសហប្រតិបត្តិការដ៏ប្រសើររវាងប្រទេសយើងទាំងពីរ ។ សហភាពសូវៀត នឹងផ្តល់ការគាំទ្រដល់ប្រជាជនកម្ពុជា នៅក្នុងការសាកល្បងរបស់ខ្លួន ដើម្បីកសាងប្រទេសកម្ពុជា ដ៏សម្បូររុងរឿង ដែលមានសន្តិភាព ឯករាជភាព អព្យាក្រឹត្យភាព និងអធិបតេយ្យភាពដល់ប្រទេសកម្ពុជា ។

ក្នុងនយោបាយគាំទ្រដ៏ទៀងទាត់ ដល់រណសិរ្សរួបរួមជាតិ និងរដ្ឋាភិបាលរួបរួមជាតិកម្ពុជា នៅខែមេសា ឆ្នាំ១៩៧៥ រដ្ឋាភិបាល

សហភាពសូវៀត បានធ្វើសេចក្តីសម្រេច ដើម្បីផ្តល់ជំនួយសម្ភារៈដល់អ្នកស្នេហាមាតុភូមិកម្ពុជា។

បណ្តាប្រទេសដទៃនៃសហគមន៍សង្គមនិយម ក៏បានសំដែងការគាំទ្រដ៏ទៀងទាត់ របស់ខ្លួនដល់អ្នកស្នេហាមាតុភូមិកម្ពុជា ដែរ។ នៅក្នុងសេចក្តីថ្លែងការណ៍របស់ប្រមុខរដ្ឋាភិបាលនៃប្រទេសសង្គមនិយមទាំង៨ ចុះថ្ងៃទី១៤ ឧសភា ឆ្នាំ១៩៧០ មានការផ្តន្ទាទោសដ៏មុឹងម៉ាត់ ដល់អំពើឈ្លានពានរបស់សហរដ្ឋអាមេរិក ប្រឆាំងប្រទេសកម្ពុជា។ នៅក្នុងសេចក្តីថ្លែងការណ៍នេះមានការគូសបញ្ជាក់ថា មូលដ្ឋានដ៏សមហេតុសមផលក្នុងការដោះស្រាយបញ្ហាកម្ពុជា គឺជាកម្មវិធីនៃការតស៊ូរបស់រណសិរ្សរួបរួមជាតិកម្ពុជា ប្រឆាំងអំពើឈ្លានពានអាមេរិក ដើម្បីការពារអព្យាក្រឹតភាព និងឯករាជភាពនៃប្រទេសកម្ពុជា។

នៅក្នុងសម័យប្រជុំនៃគណៈកម្មាធិការពិគ្រោះពិភាក្សានយោបាយរបស់ប្រទេសចូលរួមក្នុងកតិកាសញ្ញាទីក្រុងវ៉ាសូវី ដែលបានប្រព្រឹត្តទៅនៅទីក្រុងប្រាគ នាថ្ងៃទី២៦ មករា ឆ្នាំ១៩៧២ មានការអនុម័ត "សេចក្តីថ្លែងការណ៍ស្តីអំពីការបន្តអំពើឈ្លានពានរបស់សហរដ្ឋអាមេរិក" ដែលនៅក្នុងនោះ មានការបញ្ជាក់អំពីការគាំទ្ររបស់ប្រទេសទាំងនេះ ដល់កម្លាំងអ្នកស្នេហាមាតុភូមិនៃប្រទេសកម្ពុជា។

អ្នកតំណាងរបស់បក្សកុម្មុយនិស្តនានា តែងតែធ្វើសេចក្តីថ្លែងការណ៍ បញ្ជាក់អំពីការគាំទ្រ របស់ខ្លួនដល់ការតស៊ូប្រកបដោយយុត្តិធម៌របស់ប្រជាជនកម្ពុជា។ ហេតុនេះហើយ បានជានៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ១៩៧០ នៅក្នុងសន្និបាតនៃអ្នកតំណាងបក្សកុម្មុយនិស្តនៅប្រទេសមូលធននានា នៅទ្វីបអឺរ៉ុប ដែលបាន

ប្រព្រឹត្តទៅនៅទីក្រុងប៉ារីស សមាជិករួបរួមក្នុងសន្និបាតបានធ្វើការអនុម័ត លើសេចក្តីអំពាវនាវមួយ ដល់ប្រជាជនទាំងឡាយនៅប្រទេសអឺរ៉ុបខាងលិច ដែលនៅក្នុងនេះ គេបានសំដែងនូវសាមគ្គីភាពរបស់គេជាមួយប្រជាជនប្រទេសកម្ពុជា ។

សមាជិករួបរួមក្នុងចលនាប្រទេសមិនចូលបក្សសម្ពន្ធ ក៏បានគាំទ្រយ៉ាងសកម្មដល់រណសិរ្សរួបរួមជាតិ និងរាជរដ្ឋាភិបាលរួបរួមកម្ពុជា ។ អង្គប្រជុំសន្និសីទទី៤ នៃប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលប្រទេសមិនចូលបក្សសម្ពន្ធទាំងឡាយ ដែលបានប្រព្រឹត្តទៅនៅទីក្រុងអាល់ហ្សេ នាខែកញ្ញា ឆ្នាំ១៩៧៣ បានធ្វើសេចក្តីថ្លែងការណ៍ថា៖ រដ្ឋាភិបាលត្រឹមត្រូវតាមច្បាប់តែមួយរបស់ប្រទេសកម្ពុជា គឺជារាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា ហើយអង្គប្រជុំនៃសន្និសីទនេះបានអំពាវនាវឱ្យប្រទេសទាំងអស់ទទួលស្គាល់រដ្ឋាភិបាលនេះ ។

អង្គប្រជុំសន្និសីទទី៥ នៃប្រមុខរដ្ឋ និងប្រមុខរដ្ឋាភិបាលប្រទេសមិនចូលបក្សសម្ពន្ធ ដែលបានប្រព្រឹត្តទៅនៅទីក្រុងកូឡុមបូ នាខែសីហា ឆ្នាំ១៩៧៦ បានធ្វើគារវកិច្ចដល់ជ័យជម្នះរបស់ប្រជាជនកម្ពុជា នាថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ក្នុងការតស៊ូប្រឆាំងអំពើឈ្លានពានរបស់ពួកចក្រពត្តិអាមេរិក ។

អង្គការមហាជនអន្តរជាតិជាច្រើន បានធ្វើសេចក្តីថ្លែងការណ៍គាំទ្រដល់ការតស៊ូរបស់ប្រជាជនកម្ពុជា ប្រឆាំងអំពើជ្រៀតជ្រែក និងឈ្លានពានរបស់ពួកអាមេរិក មកក្នុងប្រទេសកម្ពុជា ។ នៅសម័យប្រជុំក្រុមប្រឹក្សាពិភពលោក នៃសន្តិភាពនៅទីក្រុងម៉ូស្គូ នាថ្ងៃទី៤ - ៦ មេសា ឆ្នាំ១៩៧០ ដើម្បីរំលឹកដល់ខួបកំណើតលើកទី១០០ របស់ វ.ឥ.ឡេនីន សមាជិករួបរួមក្នុង

សម័យប្រជុំទាំងឡាយ បានធ្វើសេចក្ដីសម្រេចចិត្តស្ដីអំពីប្រទេសវៀតណាម និងប្រទេសដទៃទៀតនៅឥណ្ឌូចិន ដែលនៅក្នុងនេះ គេបានសំដែងសមានចិត្តដ៏ជ្រាលជ្រៅ និងការគាំទ្រដល់ប្រជាជននៃប្រទេសវៀតណាម ឡាវ និងកម្ពុជា ដែលទទួលការរងគ្រោះដោយអំពើឈ្លានពានរបស់សហរដ្ឋអាមេរិក។ នៅក្នុងសេចក្ដីសម្រេចនេះ មានការទាមទារឱ្យបញ្ឈប់អំពើឈ្លានពានអាមេរិកនៅប្រទេសកម្ពុជា និងនៅឥណ្ឌូចិន ដែលសហរដ្ឋអាមេរិក បានបង្កបង្កើតឱ្យមានភ្លើងសង្គ្រាម។

សក្ខីភាពដ៏ត្រចះត្រចង់ នៅក្នុងការគាំទ្រដល់ការតស៊ូដ៏ត្រឹមត្រូវរបស់អ្នកស្នេហាមាតុភូមិកម្ពុជា ដោយអង្គការមហាជនប្រជាធិបតេយ្យនៅក្នុងពិភពលោកទាំងមូល គឺសន្និសីទអន្តរជាតិស្ដីអំពីសាមគ្គីភាពជាមួយប្រជាជនកម្ពុជា ដែលបានបើកសម័យប្រជុំរបស់ខ្លួន ពីថ្ងៃទី៨ - ៩ ធ្នូ ឆ្នាំ១៩៧៣ នៅទីក្រុងប៉ារីស។ នៅក្នុងសន្និសីទនេះ មានប្រតិភូចំនួន៣០០រូប ដែលជាអ្នកតំណាងអង្គការមហាជន និងអន្តរជាតិ ពី៥៣ប្រទេស ដែលបានចូលរួមក្នុងសម័យប្រជុំការងារ។

នៅក្នុងអង្គប្រជុំ នៃសន្និបាតសកលលោក របស់កម្លាំងសន្តិភាពនិយមដែលបានប្រព្រឹត្តទៅនៅទីក្រុងម៉ូស្គូ ពីថ្ងៃ២៥-៣១ ខែតុលា ឆ្នាំ១៩៧៣ ដែលនៅក្នុងនេះ មានការចូលរួមរបស់គណៈប្រតិភូនៃរណសិរ្សរួបរួមជាតិ និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាផង។ សមាជិកសម័យប្រជុំបានធ្វើការផ្ដន្ទាទោសដល់សកម្មភាពរបស់សហរដ្ឋអាមេរិក និងបរិវាររបស់ខ្លួននៅភ្នំពេញ ហើយបានសំដែងការគាំទ្រដល់អ្នកស្នេហាមាតុភូមិកម្ពុជា។

ទោះបីយ៉ាងនេះក្តី ក៏មជ្ឈដ្ឋានប្រតិកិរិយាចក្រពត្តិនិយម មិនព្រមស្រុះស្រួលនឹងការ “ បាត់បង់ប្រទេសកម្ពុជា ” ឡើយ។ នៅថ្ងៃទី១២ ឧសភា ឆ្នាំ១៩៧៥ កប៉ាល់អាមេរិក ឈ្មោះ “ ម៉ាយ៉ាហ្គេស ” ដែលចូលទៅធ្វើចារកិច្ចនៅក្នុងតំបន់សមុទ្រកម្ពុជា ត្រូវបានឃាត់ឃាំង។ ហើយពីរថ្ងៃកន្លងមក គឺនៅថ្ងៃទី១៤ ឧសភា កប៉ាល់នេះ ព្រមទាំងសមាជិករបស់កប៉ាលត្រូវបានដោះលែង។ ដោយមិនរវល់អំពីរឿងនេះ យន្តហោះអាមេរិក បានហោះទៅទម្លាក់គ្រាប់បែកយ៉ាងឃោរឃៅលើកប៉ាល់កម្ពុជា ដែលស្ថិតនៅតាមមាត់សមុទ្រប្រទេសកម្ពុជា។ មិនតែប៉ុណ្ណោះ យន្តហោះអាមេរិកកាំង បានហោះទម្លាក់គ្រាប់បែកលើចំណតយន្តហោះ លើរោងចក្រចម្រាញ់ប្រេងកាត និងសំណង់ដទៃទៀតនៅកំពង់ផែកំពង់សោម ហើយកងនាវាអាមេរិក មួយក្រុម ក៏បានចុះមកលើកោះតាង។

សកម្មភាពបែបនេះរបស់កងយោធាអាមេរិក ដែលបានបំពេញឡើងដោយកិច្ចបញ្ជា របស់ប្រធានាធិបតីសហរដ្ឋអាមេរិក ឈ្មោះ ហ្វ៊ត គឺជាអំពើឈ្លានពានដ៏គ្រោតគ្រាត ដោយការប្រើកម្លាំងអាវុធនៅក្នុងការទាក់ទងអន្តរជាតិ ដែលត្រូវហាមឃាត់ដោយច្បាប់អន្តរជាតិបច្ចុប្បន្ន។

អំពើឈ្លានពានរបស់កងយោធាអាមេរិក ប្រឆាំងប្រទេសកម្ពុជា បានបន្តទៅទៀត។ នៅថ្ងៃទី២៥ កុម្ភៈ ឆ្នាំ១៩៧៦ យន្តហោះអាមេរិក ៣គ្រឿង បានហោះទម្លាក់គ្រាប់បែកលើទីក្រុងសៀមរាប ហើយបានហោះវិលត្រឡប់ទៅប្រទេសថៃឡង់ដ៍វិញ។ ក្នុងការទម្លាក់គ្រាប់បែកនេះ មនុស្ស១៥នាក់បានស្លាប់ ហើយ ៣០នាក់បានរបួស។

មជ្ឈដ្ឋានចក្រពត្តិនិយមសហរដ្ឋអាមេរិក និងសម្ពន្ធមិត្តរបស់ខ្លួនខ្លះ ក៏បានបន្តផ្តល់ជំនួយ និងគាំទ្រដល់ពួកប្រតិបដិវត្តន៍ខាងស្តាំ ហើយបានបញ្ជូនពួកបំពេញចារកិច្ចផ្សេងៗ មកក្នុងទឹកដីប្រទេសកម្ពុជា

# ចំពូកទី ២

## ប្រជាជនប្រទេសកម្ពុជា តស៊ូប្រឆាំងរបប
## គ្រប់គ្រងប៉ុល ពត - អៀងសារី - ខៀវ សំផន

ពីថ្ងៃទី២៥ដល់២៧ខែមេសាឆ្នាំ១៩៧៥នៅទីក្រុងភ្នំពេញ មានបើកសម័យប្រជុំមហាសន្និបាតជាតិវិសាមញ្ញមួយ ។ ស្រប តាមសេចក្ដីសម្រេចរបស់មហាសន្និបាត គេបានរៀបចំរដ្ឋធម្មនុញ្ញ ថ្មី នៃប្រទេស ដែលត្រូវអនុវត្តជាធរមាននៅថ្ងៃទី៥ មករា ឆ្នាំ ១៩៧៦ ។ រដ្ឋធម្មនុញ្ញបានរំលំរាជានិយម ប្រទេសត្រូវបានឱ្យ ឈ្មោះថា “ កម្ពុជាប្រជាធិបតេយ្យ ”។

នៅថ្ងៃទី២០មីនាឆ្នាំ១៩៧៦មានការបោះឆ្នោតជ្រើសរើស តំណាងប្រជាជនសម្រាប់សភាតំណាងប្រជាជន។ នៅខែមេសា សម័យប្រជុំទីមួយ នៃសភាតំណាងប្រជាជនបានប្រព្រឹត្តទៅ ហើយនៅពេលនោះ នរោត្តម សីហនុ បានសុំលាលែងពីតំណែង។ គណៈប្រធានរដ្ឋមួយ ត្រូវបានបង្កើតឡើងស្របតាមរដ្ឋធម្មនុញ្ញ ថ្មី។ នៅពេលនេះ ប៉ែន នុត ជាប្រធានរាជរដ្ឋាភិបាលរួបរួមជាតិ ក៏បានសុំលាលែងពីតំណែងដែរ។ រដ្ឋាភិបាលមួយរបស់ “ កម្ពុជា ប្រជាធិបតេយ្យ ” ក៏ត្រូវបានបង្កើតឡើង ។

ក្រុមពួកដែលមាន ប៉ុល ពត, អៀង សារី, និងខៀវ សំផន ជាអ្នកដឹកនាំក៏បានឡើងកាន់កាប់អំណាច។ក្រុមនេះមានសមាជិក របស់ខ្លួន ដែលទាក់ទងគ្នាយ៉ាងជិតស្និទ្ធជាបងប្អូន ជាអ្នកនៅ ស្រុកជាមួយគ្នា ឬជាអ្នកមានផលប្រយោជន៍រួមគ្នា។ ក្រុមនេះ

បានសាកល្បងទាញយកផ្លែផ្កានៃជ័យជម្នះនាថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ពីប្រជាជនកម្ពុជា។

ភារកិច្ចដ៏ស្មុគស្មាញនានា បានចោទឡើងនៅចំពោះមុខប្រទេសជាតិ គឺបំបាត់ផលវិបាកសង្គ្រាម រៀបចំសេដ្ឋកិច្ចជាតិឡើងវិញ ធានារ៉ាប់រងបណ្តាជនដោយការផ្តល់ស្បៀងអាហារ។ ក៏ប៉ុន្តែ កិច្ចការដែលមានសារៈសំខាន់សម្រាប់ពួកអ្នកដឹកនាំថ្មីទាំងនេះ គឺជារឿងផ្សេងទៅវិញ។ បនប៉ុល ពត ដែលបានឡើងកាន់កាប់អំណាច ស្ថិតនៅឆ្ងាយពីផ្លូវដែលត្រូវដឹកនាំប្រជាកសិករដែលចូលរួមក្នុងបដិវត្តន៍ ឱ្យប្រកបដោយស្មារតីភ្ញាក់រលឹកនៃវណ្ណៈអធន។ ដូចគេបានដឹង បានយល់មកហើយថា នៅប្រទេសកម្ពុជា បក្ស និងកងទ័ពដែលបានបំពេញតួនាទីជួរមុខក្នុងការសម្រេចចលនាបដិវត្តន៍ ក៏ប៉ុន្តែ បក្ស កងទ័ព និងប្រទេសទាំងមូលស្ថិតនៅក្នុងស្ថានភាពជាបក្ស កងទ័ព និងប្រទេសរបស់វណ្ណៈកសិករសឹងទាំងអស់។

បនប៉ុល ពត, អៀង សារី, ខៀវ សំផន ជឿស៊ប់ទៅតាមលទ្ធិឆ្វេងនិយមហួសហេតុ ឈប់ទាក់ទងនឹងចលនាកម្មករ និងកម្មុយនិស្តនិយមអន្តរជាតិ។ ពួកនេះប៉ុនប៉ងរកទម្រង់នៃការកសាងសង្គមដោយពឹងផ្អែកទៅលើរូបមន្ត ដែលមិនយោងទៅតាមលក្ខណៈពិសេសនៃការលូតលាស់នៃប្រពៃណី និងសមត្ថភាពរបស់ប្រទេស។ កាលមុន គំនិតបែបនេះស្ថិតនៅក្នុងទស្សនៈជាទ្រឹស្តីរបស់ក្រុមអ្នកប្រកាន់ទស្សនៈឆ្វេងនិយមហួសហេតុ។ ក្នុងការវិនិច្ឆ័យដល់ស្ថានភាពនៅប្រទេស ពួកទាំងនេះមានយោបល់ថា៖ ដំណើរវិវត្តនៃកម្លាំងទៅមុខរបស់បដិវត្តន៍ គឺវណ្ណៈកសិករក្រីក្របំផុត និងស្រទាប់ខ្លះនៃវណ្ណៈកសិករមធ្យម។ នៅក្នុង

បញ្ហានេះ ពួកទាំងនេះបញ្ជាក់ថា នៅប្រទេសកម្ពុជា ពុំដែលមានការខ្វះខាតដីសម្រាប់ធ្វើស្រែចម្ការណាឡើយ ហើយតាមទស្សនៈបែបនេះ គេចង់ទាញយោបល់ថា នៅក្នុងប្រទេស ពុំដែលមានបដិបក្ខភាពរវាងវណ្ណៈកសិករ និងវណ្ណៈសក្តិភូមិនៅក្នុងវិស័យនេះទេ។ បដិបក្ខភាពដែលបានលេចជារូបរាងច្បាស់លាស់ គឺបដិបក្ខភាពរវាងប្រជាកសិករ និងវណ្ណៈពាណិជ្ជករចងការប្រាក់ដែលនៅស្រុកស្រែតំណាងដោយជនជាតិចិន មួយភាគយ៉ាងធំ។ ទីក្រុង - គឺជាប្រភពនៃមូលធននិយម ជាមធ្យោបាយបង្កើតអំពើជិះជាន់វណ្ណៈកសិករ ដោយពួកអ្នកចងការប្រាក់។ ដើម្បីជាមធ្យោបាយបំបាត់អំពើជិះជាន់តាមរបៀបចងការប្រាក់ ពួកទាំងនេះយល់ថា ត្រូវតែបំបាត់ការប្រើប្រាស់ប្រាក់កាស ហើយបង្កើតជាទូទៅនូវសហករណ៍កសិករ។

ចំពោះបញ្ហាឧស្សាហូបនីយកម្ម ពួកទាំងនេះយល់ថា បញ្ហានេះនឹងអាចដោះស្រាយបានតែតាមមធ្យោបាយ “ ពឹងផ្អែកលើកម្លាំងផ្ទាល់ខ្លួន ”។ តាមពិត គំនិតនៃសេដ្ឋកិច្ចបិទទ្វារបែបនេះ គឺជានយោបាយផ្តាច់ការ ទាក់ទងជាមួយពិភពលោកខាងក្រៅ ដូចជា នៅក្នុងវិស័យពាណិជ្ជកម្ម ក៏ដូចជានៅក្នុងវិស័យនៃសហប្រតិបត្តិការខាងសេដ្ឋកិច្ច ដោយពួកនេះមានមតិយល់ថា ការទាក់ទងនឹងប្រទេសលូតលាស់ ធ្វើឱ្យអន្តរាយដល់ប្រទេសកម្ពុជា ដែលតាមពិត បានស្ថិតនៅស្ថានភាពខ្លះនៃ “ បុរេមូលធននិយម ” នៅឡើយ។

ក្នុងការដោះស្រាយបញ្ហាឧស្សាហូបនីយកម្ម ដោយការប្រើមធ្យោបាយពឹងផ្អែកលើកម្លាំងផ្ទាល់ខ្លួនហួសហេតុ បានបញ្ជាក់ឱ្យឃើញ នូវការមិនព្រមយល់ដល់ទំនាក់ទំនង នៃបដិវត្តន៍ខ្មែរ

ទៅនឹងចលនាកុម្មុយនិស្តនិយមពិភពលោក ទៅនឹងបណ្តាប្រទេសសង្គមនិយម។ តាមពិត មនោគមវិជ្ជារបស់វណ្ណៈអនុជនបណ្តាលឱ្យមានកំហុសដ៏ធំខាងទ្រឹស្តី ហើយកំហុសនេះនឹងអាចតម្រែតម្រង់ហើយជម្នះវិញបាន ក៏លុះត្រាតែមានទំនាក់ទំនងដ៏ជិតស្និទ្ធជាមួយចលនាកុម្មុយនិស្តនិយមអន្តរជាតិ ជាមួយសហភាពសូវៀត និងប្រទេសសង្គមនិយមដទៃទៀត។ ទំនាក់ទំនងបែបនេះនឹងអាចឆ្លើយតបដល់ផលប្រយោជន៍ជាតិនៃប្រទេសកម្ពុជា។ ក៏ប៉ុន្តែក្នុងស្ថានភាពឯកោដាច់ចេញស្រឡះ ពីចលនាកុម្មុយនិស្តអន្តរជាតិ និងរំដោះជាតិ គឺមានអំពើក្បត់ដល់ប្រយោជន៍បដិវត្តន៍ដល់សមិទ្ធិជ័យបដិវត្តន៍នៃប្រជាជនកម្ពុជា ហើយជាការបណ្តាលឱ្យបំផ្លាញលទ្ធផលនៃជ័យជម្នះនាថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥។ គំនិនានាស្តីអំពីសមភាព មានសមភាពក្នុងការប្រើប្រាស់គ្រឿងឧបភោគ ការប្រឆាំងនឹងជីវភាពនៅទីក្រុង ការវិលត្រឡប់មកកាន់ស្រុកស្រែចម្ការវិញ។ល។ ត្រូវបានអនុវត្ត ដើម្បីបង្កើនអំណាចផ្តាច់ការ ការិយាល័យនិយម យោជាមួយនៅក្នុងប្រទេសដោយមានការពឹងផ្អែក ទៅលើវណ្ណៈកសិករកម្ពុជាមួយភាគដែលមានស្ថានភាពសង្គម - សេដ្ឋកិច្ចអន់ថយបំផុត និងទៅលើបណ្តាជនជាតិភាគតិចខ្លះៗនៅប្រទេសកម្ពុជា។

នៅក្នុងស្ថានភាពនៃប្រទេសកម្ពុជា ដែលជារដ្ឋរបស់កសិករបែបនេះ ការត្រួតត្រារបស់ក្រុមពួកប៉ុល ពត, អៀង សារី, ខៀវ សំផន បានអនុវត្តវិធានការដ៏ព្រៃផ្សៃបំផុត។ បនប៉ុល ពត ដែលបានឡើងកាន់អំណាចដោយកម្លាំង ស្ថិតនៅក្នុងស្ថានភាពឯកោ។

លក្ខណៈពិសេសក្នុងជីវភាពនៃប្រទេសកម្ពុជា បណ្តាលឱ្យបទពិសោធន៍បែបនេះ កើតមានឡើង។ ប្រទេសកម្ពុជា ជា

ប្រទេសដែលមានវណ្ណៈកសិករក្រីក្រ និងមធ្យមរស់នៅប្រកប ដោយចិត្តសាស្ត្រ និងជំនឿ ដែលជឿថា អំណាចរដ្ឋ គឺជាអង្គការ ដ៏មហិមា ដែលអណ្តែតនៅខ្ពស់ពីលើសង្គមមនុស្ស។ បនប៉ុល ពត នៅពេលដែលដណ្តើមបានអំណាច បានឆ្លៀតអនុវត្តនូវចិត្ត សាស្ត្រ និងប្រពៃណីបែបនេះ។ របបអំណាចផ្តាច់ការប៉ុល ពត បានក្លាយទៅជាកម្លាំងដ៏ឃោរឃៅ ដែលជ្រាបចូលដ៏ជ្រាលជ្រៅ ទៅក្នុងជីវភាពសង្គមនៅគ្រប់វិស័យ។

ពួកប៉ុល ពត បានជ្រាបចូលទៅក្នុងអង្គការដឹកនាំនានា របស់បក្ស បានពឹងពាក់លើបណ្តាយុវជនក្មេងខ្ចីក្នុងគោលបំណង ផ្តាច់ប្រពៃណី នៃតំណជំនាន់មនុស្សនៅក្នុងចលនាបដិវត្តន៍ខ្មែរ ហើយបានផ្លាស់លទ្ធិម៉ាក្ស - ឡេនីននិយម ដោយមនោគមវិជ្ជា ជាតិនិយមចង្អៀតចង្អល់ហួសហេតុ។ មនុស្សមានវ័យចំណាស់ ត្រូវបានពួកវា " មន្ទិលសង្ស័យ " ដោយចាត់ទុកអ្នកទាំងនេះថា ជាមនុស្ស " ប្រឡាក់ប្រឡូសដោយមនោគមន៍វិជ្ជានៃរបបចាស់ "។ កាលណា ប៉ុល ពត បានឡើងជាប្រមុខបក្ស ពួកវាបានទទួល ឱ្យចូលជាបក្ខជន តែពីសំណាក់ជនជាតិកម្ពុជា ណា ដែលមាន អាយុពី១៦ ដល់២៤ឆ្នាំ។ នរណាដែលមានអាយុតិចជាង១៨ឆ្នាំ ពួកប៉ុល ពត បានផ្តាច់ខ្លួនគេពីគ្រួសារ ដោយសេចក្តីភ័យខ្លាច ថា យុវជនជ្រួតជ្រាបតាម "មនោគមវិជ្ជារបស់ឪពុកម្តាយចាស់ៗ "។ តាមការនិទានរបស់ជនកុម្មុយនិស្តកម្ពុជាខ្លះ ដែលបានចៀសផុត អំពីការសម្អាតជួរបក្សដ៏ឃោរឃៅបែបនេះ ប៉ុល ពត និងក្រុមពួក របស់វាប្រើមធ្យោបាយកម្ទេចយុទ្ធជនដើងចាស់នៃចលនារំដោះ ជាតិ តាំងពីពេលយូរមកហើយ មុនឆ្នាំ១៩៧៥។

ប៉ុល ពត តាមឈ្មោះដើមគេហៅថា សាឡុត - ស។ កើតនៅឆ្នាំ ១៩២៥ នៅក្នុងគ្រួសារកសិករមានសម្បត្តិមួយនៅខេត្តកំពង់ធំ បានរៀនជាដំបូងនៅសាលាវត្ត។ តមក បានរៀនចប់អនុវិទ្យាល័យបច្ចេកទេសនៅភ្នំពេញ ហើយបានទៅរៀននៅប្រទេសបារាំង ពីឆ្នាំ១៩៤៥ ដល់១៩៥៣។ នៅទីក្រុងប៉ារីស ប៉ុល ពត ដោយរៀនសូត្រមិនកើតការ បានចាប់ផ្តើមប្រឫកប្រឫបល់នឹងកិច្ចការនយោបាយ បានចូលរួមក្នុងក្រុមត្រុតស្គីស្តនិយមរបស់និស្សិត ហើយបានដឹកនាំក្រុមនេះ គឺជាក្រុមដែលបានបញ្ចូលគំនិតអំពីសង្គមនិយមក្លែងក្លាយគ្រប់បែបថា ជាទស្សនៈម៉ាក្សនិយម។

នៅខែធ្នូ ឆ្នាំ១៩៥៣ ប៉ុល ពត បានត្រឡប់មកទីក្រុងភ្នំពេញវិញ ហើយបានចូលរួមក្នុងសកម្មភាពរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា។ បន្ទាប់ពីប្រទេសកម្ពុជា បានទទួលឯករាជ្យ បក្សត្រូវបានបន្តសកម្មភាពរបស់ខ្លួនក្នុងលក្ខខណ្ឌលាក់កំបាំង។ ប៉ុល ពត ដែលប៉ិនប្រសប់គ្រាន់ បើក្នុងការបំពេញសកម្មភាពបែបនេះនៅទីក្រុង ជាងបណ្តាបក្ខជនជើងចាស់ ដែលធ្វើការតស៊ូដោយយុទ្ធនាការនៅក្នុងព្រៃ បានអនុវត្តពាក្យស្លោកបដិវត្តន៍ឆ្វេងនិយមហួសហេតុ ហើយបានដណ្តើមយកអំណាចដឹកនាំបន្តិចម្តងៗនៅក្នុងអង្គការបក្សនៅទីក្រុង។

នៅសម័យនោះ សមមិត្ត ទូ - សាមុត ដែលជាយុទ្ធជនជើងចាស់ នៃចលនាកុម្មុយនិស្តនៅឥណ្ឌូចិន បានធ្វើជាអ្នកដឹកនាំក្រុមម៉ាក្សនិយម និងអន្តរជាតិនិយមរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា។ នៅថ្ងៃទី២៧ ឧសភា ឆ្នាំ១៩៦២ សមមិត្ត ទូ - សាមុត ត្រូវបានគេធ្វើឃាតនៅក្នុងលក្ខខណ្ឌដ៏លាក់កំបាំងបំផុត។ នៅពេលបច្ចុប្បន្ន ទើបគេបានដឹងច្បាស់ថា ឃាតកម្មដ៏ព្រៃផ្សៃនេះ បាន

ប្រព្រឹត្តទៅនៅក្រោមការទទួលខុសត្រូវរបស់ ប៉ុល ពត និងក្រុមពួករបស់ខ្លួន។ នៅពេលក្រោយមក ប៉ុល ពត បានឡើងកាន់កាប់តំណែងជំនួសសមមិត្ត ទូ - សាមុត ហើយបានចាប់ផ្តើមទាក់ទាញបក្សឱ្យស្ថិតនៅលើទស្សនៈឆ្វេងនិយមហួសហេតុ។

នៅពេលពាក់កណ្តាលឆ្នាំ១៩៦៥ប៉ុល ពត បានទៅស្រុកចិន ដែលនៅពេលនោះ " បដិវត្តន៍វប្បធម៌ដ៏មហិមា នៃវណ្ណៈអធន " ទើបបានចាប់ផ្តើមឆាបឆេះឡើងនៅប្រទេសនេះ។ នៅក្នុង " បដិវត្តន៍វប្បធម៌ " ប៉ុល ពត បានឈ្លក់នឹងគំនិតដែលខ្លួនបាននឹកមមៃជាយូរមកហើយ។ ក្រោមការកាប់សម្លាប់ជីវិតមនុស្សរាប់ម៉ឺនរាប់សែននាក់ និងក្នុងការធ្វើទុក្ខទោសខាងផ្លូវចិត្តដល់មនុស្សរាប់សែននាក់ទៀត ប៉ុល ពត យល់ថាជា " ការសម្អាតខ្លួនប្រាណពីមេរោគឆ្លង "។ ប៉ុល ពត បានវិលត្រឡប់មកប្រទេសកម្ពុជា វិញ ដោយមានអារម្មណ៍ផ្ចិតជាប់នឹងផ្សាយគំនិត និងរបៀបនៃ " បដិវត្តន៍វប្បធម៌ " នៅប្រទេសកម្ពុជា។

នៅក្រោមការត្រួតត្រារបស់ក្រុមពួក ប៉ុល ពត, អៀង សារី, ខៀវ សំផន ប្រទេសបានប្រែក្លាយទៅជាជំរំឃុំឃាំងដ៏ធំធេង ដែលសឹងបិទជិតទាំងអស់ពីពិភពលោកខាងក្រៅ។ សកម្មភាពដ៏ " ឆៅ " ទីមួយ អនុវត្តដោយបនប៉ុល ពត នៅលើទឹកដីនៃប្រទេសកម្ពុជា បានជំរុញឱ្យប្រជាជនកម្ពុជា ធ្លាក់ចុះទៅក្នុងរណ្តៅនៃទុក្ខវេទនា និងមហាវិនាសកម្មដ៏ទារុណ។ ក្រោមកលល្បិចនៃការ " បោសប្រាស់សម្អាតសង្គម " ពួកប៉ុល ពត បានជន្លៀសបណ្តេញបណ្តាជនចំនួន៣លានកន្លះ ពីទីក្រុងភ្នំពេញ និងពីទីក្រុងដទៃទៀត ឱ្យទៅតំបន់នានានៅស្រុកស្រែ តែក្នុងរយៈពេល៧២ម៉ោងប៉ុណ្ណោះ។ ពួកវាបានហាមឃាត់ មិនឱ្យអ្នកស្រុកយករបស់របរ

ជាចាំបាច់ទៅតាមខ្លួនឡើយ ហើយនៅក្រោមកំដៅថ្ងៃចែងចាំង នៃខែចេត្រ ដែលមានកម្រិតដល់សែសិបអង្សាលើសូន្យ ដោយគ្មានម្ហូបអាហារ គ្មានទឹកសម្រាប់ទប់ទល់នឹងសេចក្ដីស្រេចឃ្លាន ពួកវាបាន បណ្ដេញបណ្ដាអ្នកស្រុកឱ្យដើរជើងទទេនៅតាមផ្លូវថ្នល់នានានៃប្រទេស។ ជនានុជនរាប់ម៉ឺននាក់បានបាត់បង់ជីវិត ដោយអត់បាយ អត់ទឹក ដោយកំដៅហួតហែងនៃព្រះអាទិត្យ ដោយការឈឺចាប់នឹងជំងឺឆ្លង។ គេហដ្ឋានចំនួន៣០០ពាន់ខ្នង នៅទីក្រុងភ្នំពេញ បានស្ថិតនៅទទេស្ងាត់ឈឹង ប្រៀបដូចជាពេលបន្ទាប់ពីការផ្ទុះគ្រាប់បែកណឺត្រុង។

ប្រជាជនទាំងអស់នៅក្នុងប្រទេសត្រូវបានបែងចែកជាបីប្រភេទគឺ៖ “ប្រជាជនចាស់” “ប្រជាជនថ្មី” និងបណ្ដាបុគ្គលដែលបានសហការជាមួយរបបគ្រប់គ្រងចាស់។ នៅក្នុងប្រភេទនៃ “ ប្រជាជនចាស់ ” បនប៉ុល ពត បានបូកបញ្ចូលទាំងជនជាតិភាគតិចនៅតំបន់ព្រៃ និងតំបន់ភ្នំ ដែលជាតំបន់មូលដ្ឋាននៃកុបកម្មនានាឆ្នាំ១៩៧០ - ១៩៧៥។ នៅទីនេះ ជនជាតិ និងអ្នកស្រុកតែងយល់ថា រាជវង្សានុវង្សខ្មែរ គឺជាតំណាងនៃវណ្ណៈអ្នកជិះជាន់។ បើប្រៀបធៀបទៅនឹងអ្នកស្រុកនៅតំបន់ដទៃទៀត អ្នកស្រុកនៅតំបន់ព្រៃភ្នំទាំងនេះ មានជីវភាពក្រីក្រលំបាកបំផុត ដោយហេតុថា នៅទីនេះ ធាតុអាកាសត្រជាក់ ផលដំណាំស្រូវមិនគ្រប់គ្រាន់ ហើយដើម្បីរស់នៅ អ្នកស្រុកបានបំពេញការខ្វះខាតរបស់ខ្លួនដោយបរបរបាញ់សត្វ នេសាទត្រី និងការបេះផលផ្លែឈើក្នុងព្រៃ។

តាមប្រពៃណី អ្នកស្រុកនៅតំបន់ទាំងនេះ តែងចងកំហឹងប្រឆាំងនឹងអ្នកស្រុកដែលរស់នៅតាមទីទំនាប។ អ្នកស្រុកនៅ

តំបន់រុក្ខាទាំងនេះបានទទួលការឃោសនា និងការអប់រំ តិចជាងអ្នកស្រុកនៅតំបន់ដទៃទៀត។ គឺក្នុងបណ្ដាកូនចៅជនជាតិទាំងឡាយនេះហើយ ដែលពួកប៉ុល ពត បានជ្រើសរើស “ក្របខ័ណ្ឌ” ជាមូលដ្ឋានសម្រាប់អង្គការ និងកងទ័ពរបស់ខ្លួន។

នៅក្នុងប្រភេទ “ប្រជាជនថ្មី” គឺពួកវាបានបញ្ចូលបណ្ដាជននៃតំបន់នានា ដែលកាលពីមុន ស្ថិតនៅក្រោមរបបគ្រប់គ្រងលន់ ណុល។ នៅក្នុងប្រភេទទីបី គឺមាននាយទាហាន និងទាហានកងទ័ពលន់ ណុល មាននាហ្មឺនមុខមន្ត្រី មានព្រះសង្ឃ និងពុទ្ធបរិស័ទ មានបញ្ញាវន្ត។

បន ប៉ុល ពត, អៀង សារី, ខៀវ សំផន បានដាក់ផែនការកម្ទេចប្រជាជនប្រភេទទីបី ហើយបោសប្រាស់សម្អាតដល់ប្រភេទទីពីរ។ មុនដំបូង ពួកវាពុំបានធ្វើទុក្ខបុកម្នេញអ្វីដល់ប្រភេទទីមួយ គឺ “ប្រជាជនចាស់” ទេ ។ ក៏ប៉ុន្តែ បន្ទាប់ពីឆ្នាំ១៩៧៧ មកអ្នកទាំងនេះ ក៏ទទួលរងមហាទុក្ខទោស ដូចបណ្ដាជនក្នុងប្រភេទដទៃ។

នរណាដែលមិនត្រូវបានពួកវា យកទៅកាប់សម្លាប់ភ្លាមទេ ត្រូវទទួលការអប់រំដ៏ធ្ងន់ធ្ងរនៅក្នុងភូមិពិសេសៗ។ របបជិះជាន់កៀបសង្កត់ធ្វើទុក្ខទោសមនុស្សឱ្យឈឺចាប់ និងការកាប់សម្លាប់បណ្ដាជន សកម្មភាពទាំងអស់នេះបានបញ្ជាក់ឱ្យឃើញនូវរបបបង្កើតជំរំឃុំឃាំងបណ្ដាជន ដែលពួកវាខំបំបិទបំបាំង។

ជាមួយនឹងការបំបាត់ទ្រព្យសម្បត្តិឯកជន មានទាំងការបំបាត់ទ្រព្យផ្ទាល់ខ្លួន តាំងពីចានឆ្នាំងឡើងទៅ។ មនុស្សម្នាគ្មានសិទ្ធអ្វីបន្តិចបន្តួចសោះ ហើយគ្រាន់តែមានកំហុសប៉ុនសរសៃសក់ប៉ុណ្ណោះ នោះពួកវាបានវាយធ្វើបាបឱ្យឈឺចាប់ដល់គេទាំងឡាយ

ហេតុដល់មានការកាប់សម្លាប់នៅទីកន្លែង។ គ្រឹះស្ថានសិក្សាទាំងឡាយត្រូវបានពួកវាបិទ ហើយកែប្រែឱ្យទៅជាពន្ធនាគារ ឬជាបន្ទាយ។ រោងកុន ព្រមទាំងទូរទស្សន៍ត្រូវបានពួកវាបិទទ្វារ បោកបំបាក់សឹងទាំងអស់ ហើយប្រជាជនត្រូវបានរស់នៅដាច់ស្រឡះពីពិភពលោកខាងក្រៅ។

ការបាញ់សម្លាប់ជាទូទៅ សេចក្តីអត់ឃ្លាន និងសេចក្តីខ្វះខាតគ្រប់បែបយ៉ាងក្នុងការជំនួយដល់អ្នកជំងឺ (ដោយហេតុថាគ្រូពេទ្យ និងមន្ទីរពេទ្យនានាត្រូវបានពួកវាសម្លាប់ និងបំបាត់ចោល)។ ទាំងអស់នេះបណ្តាលឱ្យបណ្តាជនស្លាប់បាត់បង់ជីវិតច្រើនឥតគណនា។ គ្រាន់តែចាប់ពីខែមេសា ឆ្នាំ១៩៧៥ ដល់ខែធ្នូ ឆ្នាំ១៩៧៦ នៅប្រទេសកម្ពុជា ពួកវាបានសម្លាប់មនុស្សដល់ចំនួន១លានពីរសែននាក់ ដែលនៅក្នុងនោះ មានទាំងមនុស្សចាស់ ព្រឹទ្ធាចារ្យ នារី និងកុមារ។ នៅខែកក្កដា ឆ្នាំ១៩៧៦ ប៉ុល ពត បានប្រកាសទាំងគឃ្លើនថា “ ពលករជាង ៨០ភាគរយមានជំងឺគ្រុនចាញ់ ហើយបាត់បង់សមត្ថភាពក្នុងការបំពេញពលកម្ម ”។

ទន្ទឹមនឹងការបែងចែកប្រជាជនជាប្រភេទផ្សេងៗ មានការបែងចែកទឹកដីប្រទេស ជាភូមិភាគ ជាតំបន់ ជាស្រុក ជាភូមិនានា។ ភូមិនីមួយៗបានប្រែទៅជាសហករណ៍ ដែលបង្រួបបង្រួមពី១០០ ដល់ មួយពាន់គ្រួសារ ហើយផលវិបាកនៃការបែងចែកនេះ បានបង្កើតឱ្យមានជាទីបំផុតនូវ “ ឃុំប្រជាជន ” តាមរបៀបចិន នាសម័យ “ បដិវត្តន៍វប្បធម៌ ”។ នៅក្នុងឃុំបែបនេះ គឺគ្មានទ្រព្យសម្បត្តិឯកជន និងផ្ទាល់ខ្លួន ហើយគ្រួសារនីមួយៗមានតែសិទ្ធិហូបបាយដាច់ឡែកពីគេ។ ក៏ប៉ុន្តែ ចាប់តាំង

ពីខែមីនា ឆ្នាំ១៩៧៦ ទៅ "ការបន្ធូរបន្ថយបន្តិចបន្តួច" នេះ ត្រូវបានបដិសេធចោល ហើយបែបនេះ ពួកវាក៏បានអនុវត្តភាពស្មើគ្នាដ៏លួង់ខ្លៅនៃ "លទ្ធិកុម្មុយនិស្តនិយមក្លែងក្លាយ" ស្អីគេនោះ។

ទោះបីមានភេរវកម្ម បង្កើតឡើងក្នុងអំពើឃោរឃៅនៅក្នុងកិច្ចចាត់វិធានការដើម្បីអប់រំ "ពាក់ព័ន្ធ" មនុស្សតាមវិធីនានា ដែលពួកវាបានប្រើដើម្បី ធ្វើឱ្យសម្រេចនូវផែនការបង្ហូរទឹកបញ្ចូលដីស្រែចម្ការ ទំហំ១លានប្រាំសែនហិកតា ដើម្បីបង្កើនផលិតកម្មដំណាំស្រូវក្តី ក៏ផែនការសេដ្ឋកិច្ចនេះត្រូវទទួលបរាជ័យ ហើយសេដ្ឋកិច្ចជាតិនៃប្រទេស ក៏មានស្ថានភាពកាន់តែដុនដាប។

នៅប្រទេសកម្ពុជា មានជនជាតិភាគតិចចំនួនប្រហែល ២០ ក៏ប៉ុន្តែ រដ្ឋធម្មនុញ្ញប៉ុល ពត បានចែងថា នៅប្រទេសកម្ពុជា មានប្រជាជាតិតែមួយ គឺប្រជាជាតិខ្មែរ។ នៅក្នុងសារាចរពិសេសរបស់រដ្ឋាភិបាល មានសរសេរបញ្ជាក់ថា នៅប្រទេសកម្ពុជា មានភាសាតែមួយ គឺភាសាខ្មែរ ជនជាតិតែមួយ គឺជនជាតិខ្មែរ។ ហេតុនេះហើយ បានជាបណ្តាជនទាំងអស់នៅក្នុងប្រទេស ត្រូវមាននាមឈ្មោះជាខ្មែរ ហើយភាសាជនជាតិ និងលក្ខណៈពិសេសនៃជនជាតិនានា ដែលមានមកពីមុន ត្រូវតែបំបាត់ចោលយ៉ាងម៉ឺងម៉ាត់។ មនុស្សទាំងឡាយណាដែលពុំព្រមព្រៀងតាមនយោបាយបញ្ចូលពូជសាសន៍ដោយបង្ខំនេះ ត្រូវបានពួកវាសម្លាប់ចោល។

របបត្រួតត្រាប៉ុល ពត មិនបានទាំងទទួលស្គាល់នូវសិទ្ធិដ៏ធម្មតាបំផុតរបស់មនុស្ស ដោយការបំបាត់សេរីភាពខាងជំនឿ។ នៅក្នុងរដ្ឋធម្មនុញ្ញមានចែងសេចក្តីថា៖ " មិនអនុញ្ញាតឱ្យមានសាសនាប្រតិកិរិយាណា ដែលបំផ្លិចបំផ្លាញកម្ពុជាប្រជាធិបតេយ្យ

និងប្រជាជនកម្ពុជា ដាច់ខាត ”។ ស្របតាមការអនុវត្តនូវសេចក្តីបែបនេះ ក្នុងរដ្ឋធម្មនុញ្ញពួកប៉ុល ពត បានប្រព្រឹត្តអំពើឃាតកម្មដល់ព្រះសង្ឃ និងពុទ្ធបរិស័ទទាំងឡាយ ទោះបីនៅប្រទេសកម្ពុជា ប្រជាជន៨៥ភាគរយជាអ្នកកាន់ពុទ្ធសាសនាក្តី។ ពួកប៉ុល ពត បានវាយកម្ទេចរូបពុទ្ធបដិមាករ បានដុតកម្ទេចគម្ពីពុទ្ធសាសនា បានយកវត្តអារាមធ្វើជាពន្ធនាគារ ជាឃ្លាំងផ្ទុកឥវ៉ាន់ ហើយក្នុងបណ្តាវត្តទាំង២.៨០០ ដែលមានក្នុងប្រទេសនៅសម័យមុន គឺគ្មានវត្តអារាមណាមួយ ដែលធ្វើសកម្មភាពរបស់ខ្លួន នៅក្រោមរបបគ្រប់គ្រងរបស់ពួកវា។ ព្រះសង្ឃមួយចំនួនតូចបំផុត ក្នុងបណ្តាព្រះសង្ឃចំនួន៨ម៉ឺន២ពាន់រូប បានចៀសផុតអំពីអំពើឃាតកម្មបែបនេះ។ សាសនាអ៊ីស្លាម ក៏ត្រូវបានហាមឃាត់ដូចជាពុទ្ធសាសនាដែរ។ អគ្គនាយកសាសនាអ៊ីស្លាម នាមហារី - រូស្លូស និងអគ្គនាយករង នាមហាជហ្ស៊ី - ស៊ូឡឺម័ន - សូគ្រូ ក៏ត្រូវបានពួកប៉ុល ពត ធ្វើឃាតកម្ម។

ដើម្បីជម្រះសម្អាតផ្លូវ ទៅកាន់អំណាចផ្តាច់ការផ្តាច់មុខនៃ “ អង្គការ ” ប៉ុល ពត និងក្រុមពួករបស់ខ្លួនបានវាយប្រហារយ៉ាងឃោរឃៅ ទៅលើសមាជិកនៅក្នុងជួរបក្សកុម្មុយនិស្ត ដោយហេតុថា សមាជិកចំនួន ៩០% របស់បក្ស ដែលស្ថិតនៅស្មោះស្ម័គ្រនឹងទ្រឹស្តីម៉ាក្ស - ឡេនីននិយម និងឧត្តមគតិសង្គមនិយមស្អាតស្អំត្រូវពួកប៉ុល ពត សម្លាប់ចោល។ ប្រសិនបើសមមិត្ត ទូ - សាមុតត្រូវបានពួកវាសម្លាប់ដោយស្ងាត់កំបាំងនោះបន្ទាប់ពីថ្ងៃ១៧ មេសាឆ្នាំ១៩៧៥ ទៅ អ្នកស្នេហាមាតុភូមិពិតប្រាកដ អ្នកតំណាងកម្លាំងល្អបរិសុទ្ធរបស់បក្សកុម្មុយនិស្តកម្ពុជា ត្រូវបានពួកវាប្រហារជីវិតដោយចេញមុខ។ នៅទីក្រុងភ្នំពេញ នាថ្ងៃទី៣ កក្កដា ឆ្នាំ

១៩៧៨ បនប៉ុល ពត បានផ្សាយសេចក្ដីប្រកាសយ៉ាងខ្ទរខ្ទារស្ដី អំពីការប្រហារជីវិត បណ្ដាក្របខ័ណ្ឌជាន់ខ្ពស់របស់បក្ស ចំនួន ១៨រូប ប្រៀបហាក់ដូចជាជោគជ័យមួយដ៏មហិមា។ ក្នុងបណ្ដា ក្របខ័ណ្ឌទាំងនេះ មានសមមិត្ត កែវ - មុនី ជាអនុប្រធានគណៈ កម្មាធិការមជ្ឈិមបក្សកុម្មុយនិស្ដកម្ពុជា និងជាយុទ្ធជនជើង ចាស់មួយរូបនៃចលនាតស៊ូរំដោះជាតិរបស់ប្រជាជនកម្ពុជា។

តាំងពីពេលដំបូងនៃការឡើងកាន់អំណាចដោយប៉ុល ពត សមមិត្ត កែវ - មុនី បានថ្លែងបើកមុខអំពីសកម្មភាពប្រឆាំង ប្រជាជនរបស់បនប៉ុល ពត ដោយបានព្រមានអំពីគ្រោះថ្នាក់ ដែលនឹងកើតមានឡើងចំពោះប្រជាជន និងបក្សកុម្មុយនិស្ដ កម្ពុជា។ ប្រជាជនបានស្គាល់ បានស្រឡាញ់សមមិត្ត កែវ - មុនី ដោយបានចាត់ទុកថា ជាយុទ្ធជនដ៏អង់អាចមួយរូប ដែលបាន តស៊ូដើម្បីសេរីភាព និងឯករាជភាពរបស់ប្រទេស។ សមមិត្ត កែវ - មុនី ត្រូវបានពួកពេជ្ឈឃាដ ប៉ុល ពត ប្រហារជីវិតនៅ អតីតវិទ្យាល័យទួលស្លែង នៅទីក្រុងភ្នំពេញ ដែលបនប៉ុល ពត បានកែប្រែឱ្យទៅជាពន្ធនាគារ។ គឺនៅពន្ធនាគារនេះហើយ ដែល ពេជ្ឈឃាដរបស់បនប៉ុល ពត បានប្រហារជីវិតបណ្ដាអ្នកស្នេហា មាតុភូមិ ចំនួន២០ពាន់រូបនៅក្នុងសម័យនៃការត្រួតត្រារបស់ បននេះ។

ក្នុងបណ្ដាអ្នកស្នេហាមាតុភូមិ ដែលត្រូវបានពួកវាប្រហារ ជីវិត គឺមានទាំងសមមិត្តសឹង ផ៉ុកមិញ ដែលជាអតីតប្រធាន រណសិរ្សខ្មែរឥស្សរៈ និងជាយុទ្ធជនជើងចាស់បំផុតនៃចលនា តស៊ូរំដោះជាតិ មានសមមិត្ត ហ៊ូ - នឹម ជាសមាជិកគណៈកម្មាធិការ មជ្ឈិមបក្សកុម្មុយនិស្ដកម្ពុជា និងជារដ្ឋមន្ត្រីឃោសនាការ មាន

សមមិត្ត តូច - ភឿន ជារដ្ឋមន្ត្រីសង្គមកិច្ច មានសមមិត្ត កុយ ធួន ជាមេបញ្ជាការសឹកតំបន់ទី៣០៤។

នៅខែឧសភា ឆ្នាំ១៩៧៨ ពួកវាបានប្រហារជីវិតដល់សមមិត្ត សោ - យ៉ាន់ ហៅ ភឹម ដែលធ្វើជាលេខាគណៈកម្មាធិការបក្សនៅតំបន់បូព៌ា នៃប្រទេសកម្ពុជា ហើយដែលបានដឹកនាំកុបកម្មអ្នកស្រុកតំបន់នេះ ប្រឆាំងរបបត្រួតត្រាប៉ុល ពត ។

នៅក្នុងបញ្ជីមួយ រកឃើញបន្ទាប់ពីការរំលំរបបប្រល័យពូជសាសន៍នេះ គេឃើញមាននាមឈ្មោះបណ្ដាក្រុបខ័ណ្ឌជាន់ខ្ពស់របស់បក្សចំនួន២៦២រូប ដែលត្រូវបានចាប់ឃុំឃាំង ហើយត្រូវបានប្រហារជីវិត ដោយបនប៉ុល ពត ក្នុងអំឡុងពេលពីឆ្នាំ១៩៧៦ ដល់ថ្ងៃទី៩ មេសា ឆ្នាំ១៩៧៨។ ក្នុងបណ្ដាក្របខ័ណ្ឌជាន់ខ្ពស់ទាំងនេះ មានសមាជិកគណៈកម្មាធិការមជ្ឈិមបក្សពីររូប លេខាគណៈកម្មាធិការបក្សនៃភូមិភាគ ៤រូប លេខា និងសមាជិកគណៈកម្មាធិការបក្សនៃតំបន់ ២៤រូប រដ្ឋមន្ត្រីរដ្ឋាភិបាល ៤រូប ស្នងការនយោបាយ និងអនុស្នងការនយោបាយនៃកងពល ៨រូប ។

ពាក្យស្លោកមួយរបស់មនោគមវិជ្ជា របស់វណ្ណៈគហបតីតូចតាចគឺ “ ស្រុកស្រែឡោមព័ទ្ធទីក្រុង ” ត្រូវបានអនុវត្តយ៉ាងត្រចះត្រចង់នៅប្រទេសកម្ពុជា។ ក្នុងការជន្លៀសបណ្ដាជនទាំងអស់ពីទីក្រុងនានា បនប៉ុល ពត ចង់ដើរទៅឆ្ងាយជាងគ្រូបាធ្យាយរបស់ខ្លួន ដោយបានបង្កើតពាក្យស្លោកមួយថ្មីថា៖ “ ស្រុកស្រែលេបទីក្រុងនានា ”។

របៀបឃោឃូបនីយកម្មទូទាំងប្រទេស និងការបង្កើតរបប ជំរំឃុំឃាំងឃោជានិយមនៅក្នុងប្រទេស បានទៅជាសកម្មភាព នយោបាយក្នុងប្រទេសដ៏ខ្លាំងក្លាជាងគេរបស់បនប៉ុល ពត។

ការអនុវត្តរបៀប " បដិវត្តន៍វប្បធម៌ " នៅកម្ពុជា បាន ប្រព្រឹត្តទៅតាមទំហំដ៏ធំធេង នៃអំពើឃោរឃៅព្រៃផ្សៃគ្រោងទុក ជាមុន។ មានការបំបាត់ជីវិតជនដែលមានមតិខុសពីបនប៉ុល ពត មានការបំពាក់ផ្លាកថាជា " សត្រូវ " តាមគំនិតមមើមមាយដល់ បណ្តាជនមួយចំនួនធំ ដែលជាជនចេះដឹងជួរមុខ មានការលុប ចោលនូវប្រព័ន្ធសិក្សាធិការ មានការលុបបំបាត់ដាននូវ " កេរមរតក ពីអតីតកាល " ដោយការបំផ្លាញប្រាសាទបូរាណនៃវប្បធម៌ និង ការដុតបំផ្លាញគម្ពីសៀវភៅ។ ទាំងអស់នេះគឺជាវិធានការនានា ដែលបនប៉ុល ពត បានប្រើប្រាស់នៅប្រទេសកម្ពុជា ដោយបាន សាកល្បងវិធានការបែបនេះនៅសម័យនៃ " បដិវត្តន៍វប្បធម៌ "។

នៅប្រទេសកម្ពុជា ពួកវាបានបង្កើត " ឃុំនានា " បានបង្កើត " កងទ័ពពលករ " និង" ការលោតផ្លោះដ៏មហិមា " ដែលបាន ប្រព្រឹត្តទៅនៅក្រោមពាក្យស្លោកថា " កាលណាមានស្រូវអង្ករ គឺ នឹងមានអ្វីៗទាំងអស់! "។

នៅក្នុងនយោបាយក្រៅប្រទេស បនប៉ុល ពត,អៀង សារី, ខៀវ សំផន បានធ្វើឱ្យប្រទេសស្ថិតនៅលើស្ថានភាពឯកោ ដាច់ ចេញស្រឡះពីពិភពលោកខាងក្រៅ។ ការទាក់ទងអន្តរជាតិទាំង អស់ត្រូវបានផ្តាច់ដោយបននេះ ហើយប្រទេសកម្ពុជា មិនព្រម ធ្វើសហប្រតិបត្តិការជាមួយប្រទេសនានានៅអាស៊ីអាគ្នេយ៍។

ប្រទេសកម្ពុជា បានប្រែក្លាយទៅជាមូលដ្ឋាននៃការបង្ក បង្កើតហេតុខាងយោធាប្រឆាំងប្រទេសជិតខាង គឺប្រទេស

វៀតណាម ឡាវ និងថៃឡង់ ហើយបានបង្កើតឱ្យមានអស្ថិរភាព នៅក្នុងប្រព័ន្ធនៃការទាក់ទងរវាងប្រទេសនានា មិនមែនគ្រាន់តែនៅឥណ្ឌូចិន ទេ តែនៅអាស៊ីអាគ្នេយ៍ទាំងមូល។ បនប៉ុល ពត បានប្រកាន់នយោបាយ ផ្តាច់ចំណងសាមគ្គីភាពជាប្រពៃណីរវាងប្រទេសឥណ្ឌូចិន ជាសាមគ្គីភាពដែលបានកើតឡើងដោយសារការតស៊ូរួមគ្នាអស់ពេលដ៏យូរប្រឆាំងនឹងសត្រូវរួម។

ការរៀបចំទំនាក់ទំនងទៅវិញទៅមក សហប្រតិបត្តិការក្នុងតំបន់នេះរវាងប្រទេសនានានៅអាស៊ីភាគអាគ្នេយ៍ ការផ្តើមគំនិតរបស់ប្រទេសវៀតណាម នៅក្នុងវិស័យនេះ ដែលមានបញ្ជាក់ជាពិសេសនៅក្នុងគោលការណ៍ ៤ " ខ " នៃនយោបាយក្រៅប្រទេសរបស់សាធារណរដ្ឋសង្គមនិយមវៀតណាម ដែលត្រូវបានប្រកាស នៅពេលបន្ទាប់ពីការបង្រួបបង្រួមប្រទេស។ កិច្ចការទាំងអស់នេះ បានរំខានដល់ផែនការអនុត្តរភាពរបស់ទីក្រុងប៉េកាំង នៅអាស៊ីអាគ្នេយ៍។

នៅថ្ងៃទី១ ឧសភា ឆ្នាំ១៩៧៥ បន្ទាប់ពីជ័យជម្នះរបស់អ្នកស្នេហាមាតុភូមិវៀតណាម ដែលទើបនឹងបានដោតទង់រំដោះរបស់ខ្លួននៅទីក្រុងព្រៃនគរ កងកម្លាំងប្រដាប់អាវុធបនប៉ុល ពត បានវាយចូលលើទឹកដីវៀតណាម។ នៅថ្ងៃទី ៤ ឧសភា កងកម្លាំងនេះបានវាយឡើងលើកោះវៀតណាម ឈ្មោះ ហ្វូកុក (កោះត្រល់) ហើយនៅថ្ងៃទី១០ ឧសភា កងកម្លាំងប៉ុល ពត បានវាយឡើងលើកោះថូចៀវ។ ការវាយលុករបស់កងកម្លាំងប្រដាប់អាវុធប៉ុល ពត ទៅក្នុងខេត្តខាងត្បូងនានា នៃសាធារណរដ្ឋសង្គមនិយមវៀតណាម បានធ្វើឱ្យអ្នកស្រុកដ៏សុខសាន្តរាប់ពាន់នាក់ទទួលរងគ្រោះ។ ហើយចាប់ពីពេលនោះមក កងកម្លាំងប៉ុល ពត

បានចាប់ផ្ដើមធ្វើការវាយលុកជាញឹកញាប់ ទៅលើទឹកដីវៀតណាម នៅតាមព្រំប្រទល់វៀតណាម - កម្ពុជា ទាំងអស់ ដែលមានចម្ងាយ រហូតដល់១.១០០ គ.ម.។ នៅខែ មេសា ឆ្នាំ១៩៧៧ កងកម្លាំងប្រដាប់អាវុធ ប៉ុល ពត ប្រកបដោយកងពលនានារបស់ “ កម្ពុជាប្រជាធិបតេយ្យ ” បានវាយលុកលើទឹកដីប្រទេសវៀតណាម ហើយចម្បាំងព្រំប្រទល់ ក៏បានផ្ទុះឡើង។

នៅពេលមួយគ្នា បនប៉ុល ពត បានចាប់ផ្ដើមធ្វើការឃោសនាប្រឆាំងវៀតណាម នៅក្នុងប្រទេស ដោយបញ្ជេះនូវការសំអប់ជាតិចំពោះប្រទេសវៀតណាម ចំពោះប្រជាជនវៀតណាម ទាំងមូល។ នៅឆ្នាំ១៩៧៧ - ១៩៧៨ ការផ្សាយវិទ្យុទីក្រុងភ្នំពេញ ការផ្សាយសារព័ត៌មាន និងឯកសារនានាដែលចែកចាយទៅតាមអង្គភាពកងទ័ព និងទៅតាមភូមិស្រុករបស់អ្នកស្រុក មានដាក់នូវពាក្យស្លោកប្រឆាំងវៀតណាម ដែលមានសេចក្ដីដូចតទៅ៖ “ ប្រទេសវៀតណាម ជាសត្រូវទី១ របស់កម្ពុជា ”, “ យើងរៀបចំខ្លួនធ្វើការប្រយុទ្ធនឹងប្រទេសវៀតណាម អស់រយៈពេលចំនួន៧០០ឆ្នាំ! ”, “ នៅពីក្រោយយើង មានប្រជាជនចិន ចំនួន៨០០ លាននាក់ ”។ ប៉ុល ពត បានចាប់ផ្ដើមធ្វើការទាមទារទឹកដីមួយចំនួនពីប្រទេសវៀតណាម។

រដ្ឋាភិបាលសាធារណរដ្ឋសង្គមនិយមវៀតណាម បានធ្វើសំណើជាច្រើនដងដល់ភាគីកម្ពុជា ឱ្យដោះស្រាយបញ្ហាទំនាស់នានា ដែលមានរវាងគ្នាតាមមាគ៌ានៃការចរចា ដើម្បីពិភាក្សាគ្នា ស្ដីអំពីការរៀបចំការទាក់ទងរវាងគ្នានឹងគ្នា ជាអ្នកជិតខាងឡើងវិញ។ ក៏ប៉ុន្តែ បន ប៉ុល ពត , អៀង សារី, ខៀវ សំផន បានទាត់ចោលនូវសំណើដ៏សមហេតុសមផលទាំងនេះ។

លក្ខណៈប្រឆាំងប្រជាជន ដ៏ខ្លាំងក្លានៃនយោបាយផ្ទៃក្នុង និងក្រៅប្រទេសរបស់របបប៉ុល ពត បានបង្កើតឱ្យមានសេចក្តីសំអប់ជាខ្លាំងពីសំណាក់ប្រជាជនកម្ពុជា។ ចលនាប្រឆាំងពួកប៉ុល ពតរបស់ប្រជាជនបានកើតមានឡើងក្រោមការដឹកនាំរបស់កម្លាំងស្មោះត្រង់នៃបក្សកុម្មុយនិស្តកម្ពុជា ដែលជាអ្នកស្នេហាមាតុភូមិពិតប្រាកដ។ រនាំងនេះ បានកើតមានឡើងជាលើកដំបូងបន្ទាប់ពីបនប៉ុល ពត , អៀង សារី, ខៀវ សំផន បានឡើងកាន់កាប់អំណាច។ គឺជាបដិវត្តន៍ប្រជាជនប្រជាធិបតេយ្យដែលនៅក្នុងប្រទេសកម្ពុជា កើតមានឡើងនៅក្នុងលក្ខខណ្ឌ នៃការតស៊ូរំដោះជាតិ។

នៅខែកញ្ញា ឆ្នាំ១៩៧៥ អ្នកស្រុកនៅខេត្តសៀមរាបបានក្រោកឈរឡើងប្រឆាំងនឹងរបបប៉ុល ពត ហើយនៅខែកុម្ភៈ ឆ្នាំ១៩៧៧ ទាហាន៦០០នាក់នៃកងពលតូចទី១៧០ ដែលត្រូវបានគេចាត់ឱ្យមករក្សាទីក្រុងភ្នំពេញ ក៏បានក្រោកឡើងប្រឆាំងនឹងរបបដ៏ឃោរឃៅនេះ ក៏ប៉ុន្តែ នៅពេលនោះ ការប្រយុទ្ធបែបនេះត្រូវបានបង្ក្រាប។ ពួកប៉ុល ពត បានបាញ់ប្រហារជីវិតដល់មេបញ្ជាការកងពលនេះ នាម ចក្រី ហើយពួកវាបានដុតសម្លាប់អ្នកដឹកនាំចលនានៃការប្រយុទ្ធ ៣នាក់ទៀត នៅកីឡដ្ឋានទីក្រុង។ ចលនានៃការប្រយុទ្ធប្រឆាំងពួកប៉ុល ពត ដ៏ខ្លាំង បានកើតមានឡើងនៅខែវិច្ឆិកា ឆ្នាំ១៩៧៧ និងខែឧសភា ឆ្នាំ១៩៧៨ នៅតំបន់ខាងបូព៌ា និងខាងពាយ័ព្យនៃប្រទេសកម្ពុជា។ ទោះបីកុបកម្មទាំងនេះ ត្រូវបានបង្ក្រាបដ៏ព្រៃផ្សៃបំផុតក៏ដោយ ក៏ការតស៊ូរបស់កុបករទាំងឡាយនៅតែមានបន្ត តមកទៀត។

បន្ទាប់ពីមានកុបកម្មទាំងនេះ នៅតំបន់ស្រុកស្រែនានា នៃប្រទេសកម្ពុជា តំបន់រំដោះក៏កើតមានឡើងជាលើកទី១។ ជនទាំងឡាយណា ដែលបានគេចផុតពីពេជ្ឈឃាដប៉ុល ពត ហើយដែលមានចិត្តឈឺចាប់នឹងអំពើឃោរឃៅ ព្រៃផ្សៃទាំងនេះ ក៏បានរត់ចូលមកតំបន់រំដោះទាំងនេះ ដើម្បីកាន់អាវុធនៅដៃ ហើយធ្វើការតស៊ូរំដោះប្រទេសជាតិ។ ចាប់ពីពេលពាក់កណ្តាលនៃឆ្នាំ ១៩៧៨មក យុទ្ធជនជើងចាស់នៃការតស៊ូរំដោះជាតិជាច្រើន ដែលបានរត់ភៀសខ្លួនដោយភេរវកម្មរបស់បន ប៉ុល ពត ទៅប្រទេសវៀតណាម និងថៃឡង់ដ៍ ក៏បានវិលត្រឡប់មកកាន់មាតុភូមិវិញ តាមមធ្យោបាយផ្សេងៗ ដើម្បីទាក់ទងនឹងកម្លាំងបដិវត្តន៍ ហើយបញ្ចូលខ្លួនក្នុងការតស៊ូដ៏អង់អាច ដើម្បីរំដោះប្រទេសកម្ពុជា ពីអំពើដ៏ព្រៃផ្សៃរបស់ពួកបរិវារទីក្រុងប៉េកាំង។ នៅលើទឹកដីកម្ពុជា ពោរពេញដោយការបង្ហូរឈាម កម្លាំងនានាបានប្រមូលផ្តុំឡើង បង្កើតជាកម្លាំងតស៊ូប្រឆាំង នឹងរបបផ្តាច់ការដ៏ព្រៃផ្សៃនេះ។ នៅរដូវវស្សាឆ្នាំ១៩៧៨ ក្នុងបណ្តាខេត្តទាំង១៨ មានខេត្តចំនួន១៦ ដែលមានតំបន់នានា ស្ថិតនៅក្រោមការត្រួតត្រាពេញលេញ របស់កម្លាំងបដិវត្តន៍ នៃអ្នកស្នេហាមាតុភូមិកម្ពុជា។

នៅថ្ងៃទី២ ធ្នូ ឆ្នាំ១៩៧៨ សន្និបាតនៃអ្នកតំណាងប្រជាជន បានបើកសម័យប្រជុំនៅក្នុងតំបន់រំដោះមួយ។ សម័យប្រជុំនៃសន្និបាតបានធ្វើសេចក្តីប្រកាស ស្តីអំពីការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ អ្នកស្នេហាមាតុភូមិពិតប្រាកដ ដែលជាអ្នកតំណាងកម្លាំងដ៏ស្មោះត្រង់ របស់បក្សកុម្មុយនិស្តកម្ពុជា ហើយដែលបានគេចខ្លួនផុតពីភេរវកម្មរបស់របបប៉ុល ពត បានធ្វើជាអ្នកដឹកនាំនៃរណសិរ្សនេះ។ សម័យប្រជុំនៃសន្និបាត

បានអនុម័តលើសេចក្តីថ្លែងការណ៍ របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលបានអំពាវនាវដល់ប្រជាជនទាំងមូលឱ្យក្រោកឈរឡើង ហើយធ្វើការតស៊ូដ៏អង់អាច ដើម្បីផ្តួលរំលំរបបគ្រប់គ្រងផ្តាច់ការប្រតិកិរិយានេះចេញ ដើម្បីបង្កើតការគ្រប់គ្រងមួយថ្មីនៅប្រទេសកម្ពុជា ដែលមានលក្ខណៈប្រជាជន ប្រជាធិបតេយ្យ ដើម្បីស្ថាបនាប្រទេសកម្ពុជា សេរីភាព ឯករាជ្យ ប្រជាធិបតេយ្យ ហើយដែលដើរតាមមាគ៌ានៃលទ្ធិសង្គមនិយម ។

កម្មវិធីរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានទទួលការគាំទ្រទូទៅពីសំណាក់ប្រជាជន ដោយហេតុថា នៅក្នុងកម្មវិធីនេះ មានការដាក់ជាភារកិច្ចជាតិទូទៅនូវផលប្រយោជន៍របស់ប្រជាជនកម្ពុជា រាប់លាននាក់ ដែលទទួលរងទុក្ខទោសពីអំពើព្រៃផ្សៃរបស់ពួកប៉ុល ពត ។ កម្មវិធីរណសិរ្ស បានប្រកាសឱ្យបំបាត់ពលកម្មដោយបង្ខំ ឱ្យបំបាត់ការ “ ឃុំប្រជាជន ” អាពាហ៍ពិពាហ៍ដោយបង្ខំ ហើយកម្មវិធីបានបញ្ជាក់អំពីការធានារ៉ាប់រងដល់សេរីភាព ប្រជាធិបតេយ្យ ដល់សេរីភាពក្នុងជំនឿសាសនា ដល់សមភាពរវាងពលរដ្ឋទាំងអស់ និងការគោរពដល់បុគ្គលភាព និងអត្តភាពរបស់មនុស្ស ។

រណសិរ្សបានធ្វើសេក្តីថ្លែងការណ៍ ទាមទារឱ្យបញ្ឈប់ការបង្កបង្កើតហេតុដោយយោធា នៅតាមព្រំប្រទល់ប្រទេសកម្ពុជា និងប្រទេសវៀតណាម ថៃឡង់ ឡាវ ។ ផ្ទុយពីនយោបាយក្រៅប្រទេសរបស់បនប៉ុល ពត, អៀង សារី, ខៀវ សំផន ដែលជានយោបាយយោធានិយមប្រឆាំងជាតិ រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា បានថ្លែងបញ្ជាក់អំពីការអនុវត្តនយោបាយសន្តិភាព និងសហប្រតិបត្តិការ នៅលើឆាកអន្តរជាតិជាមួយប្រទេសទាំង

អស់ ហើយបានបញ្ជាក់នូវការប្រុងប្រៀបខ្លួន ដើម្បីរៀបចំការទាក់ទងដ៏ស្និទ្ធស្នាលជាអ្នកជិតខាងនឹងគ្នា ជាមួយប្រទេសនៅអាស៊ីអាគ្នេយ៍ ឡើងវិញ។

កាលពីថ្ងៃទី៥ - ៧ មករា ឆ្នាំ១៩៧៩ យុទ្ធកុម្មុយនិស្តដ៏ស្មោះត្រង់ទាំងឡាយ ដែលបានគេចផុតពីអំពើភេរវកម្មប៉ុល ពត បានបើកសម័យប្រជុំមហាសន្និបាតទី៣ នៃបក្សកុម្មុយនិស្តកម្ពុជា។ គឺជាមហាសន្និបាត ដែលមានគោលដៅនឹងរៀបចំជួរបក្សឡើងវិញ។ អ្នកចូលរួបរួមក្នុងសម័យប្រជុំបានផ្តន្ទាទោសដល់នយោបាយប្រតិកិរិយារបស់របបប៉ុល ពត ហើយបានអនុម័តលើកម្មវិធី នៃការតស៊ូ ដើម្បីបំបាត់របបនេះ និងដើម្បីការកសាងជាតិឡើងវិញ។ សម័យប្រជុំបានអនុម័តលើសេចក្តីសម្រេចស្តីអំពីការរៀបចំបក្សឡើងវិញ ឱ្យស្ថិតនៅលើមូលដ្ឋាននៃលទ្ធិម៉ាក្ស - ឡេនីននិយម ពិតប្រាកដ។

សេចក្តីអំពាវនាវ របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដើម្បីរំលំបនប៉ុល ពត ត្រូវបានប្រជាជនកម្ពុជា គ្រប់ស្រទាប់ទទួលអបអរសាទរ ដោយគេយល់ច្បាស់ថា ជាការតស៊ូដើម្បីរំដោះប្រជាជនពីអំណាចផ្តាច់ការដ៏ព្រៃផ្សៃនាសម័យមធ្យមភូមិ និងពីនយោបាយប្រល័យពូជសាសន៍ អនុវត្តដោយបននេះ។ អត្ថន័យដ៏សំខាន់នៅក្នុងជោគជ័យនៃការពង្រីកចលនាបដិវត្តន៍បែបនេះ ស្ថិតនៅលើហេតុថា កងកម្លាំងអ្នកស្នេហាជាតិកម្ពុជា បានធ្វើការទាក់ទងនឹងប្រទេសវៀតណាម ជាបងប្អូន ហើយទទួលបានការគាំទ្រពីកម្លាំងចម្រើននិយមនានា នៅលើពិភពលោក។ អ្នកស្នេហាមាតុភូមិកម្ពុជា ចេះប្រែក្រឡៃធ្វើឱ្យចម្បាំងឈ្លានពានប្រឆាំងប្រទេសវៀតណាម បញ្ឆេះដោយបនប៉ុល ពត

ប្រែជាចម្បាំងបដិវត្តន៍ក្នុងស្រុកទៅវិញ។ នៅចុងខែធ្នូ ឆ្នាំ១៩៧៨ កងកម្លាំងប្រដាប់អាវុធបដិវត្តន៍ ដែលបានកសាងឡើងដោយរណសិរ្ស ក្រោមការគាំទ្ររបស់អ្នកស្ម័គ្រចិត្តនៃកងទ័ពប្រជាជនវៀតណាម បានចាប់ផ្ដើមធ្វើការវាយលុកទូទៅ ដើម្បីរំលំរបបប្រល័យពូជសាសន៍។ នៅថ្ងៃទី៧ មករា ឆ្នាំ១៩៧៩ កងកម្លាំងប្រដាប់អាវុធរបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា វាយចូលដណ្ដើមបានទីក្រុងភ្នំពេញ ហើយបានដោតទង់ជាតិក្រហមដ៏រុងរឿង ប្រកបដោយកំពូលប្រាសាទ៥ ដែលជានិមិត្តរូបនៃបូរាណប្រាសាទខ្មែរ គឺប្រាសាទអង្គរវត្ត។ របបប្រតិកិរិយាប៉ុល ពត, អៀង សារី, ខៀវ សំផន ត្រូវបានផ្ដួលរំលំ។ នៅថ្ងៃទី៨ មករា ឆ្នាំ១៩៧៩ មានការប្រកាសចាត់តាំងក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ដែលជារដ្ឋាភិបាលបដិវត្តន៍នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និងនៅថ្ងៃទី១១ មករា សមមិត្ត ហេង សំរិន ជាប្រធានគណៈកម្មាធិការមជ្ឈិម របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ត្រូវបានតែងតាំងជាប្រធាន នៃក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា។ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា បានអនុម័តនូវគោលការណ៍ទូទៅក្នុងមាគ៌ានយោបាយ ដែលបញ្ជាក់អំពីគោលដៅនៃជ័យជម្នះបដិវត្តន៍ខែមករា គឺការកសាងប្រទេសកម្ពុជាប្រកបដោយសន្តិភាព ឯករាជ្យ ប្រជាធិបតេយ្យ អព្យាក្រឹត មិនចូលបក្សសម្ពន្ធ ធ្វើដំណើរទៅមុខតាមមាគ៌ានៃការកសាងសង្គមនិយម។

នៅក្នុងប្រទេស មានការរៀបចំស្ថាប័ននានានៃរដ្ឋអំណាចប្រជាជនដ៏ត្រឹមត្រូវ។ គេបានចាប់ផ្ដើមកសាងឡើងវិញនូវវិស័យនានានៃផលិតកម្ម គេបានរៀបចំឡើងវិញនូវក្រសួងសុខាភិបាល នូវប្រព័ន្ធអប់រំជាតិ នូវវប្បធម៌ប្រជាជន គេបានចាប់ផ្ដើមកសាង

ក្រសួងនគរបាលប្រជាជន និងកងទ័ពប្រជាជនបដិវត្តន៍កម្ពុជា។ នៅពេលជាមួយគ្នា អង្គការសហជីព ប្រជាករ កសិករ អង្គការនារី អង្គការយុវជន និងអង្គការមហាជនដទៃទៀត ក៏បានកកើតឡើងជាលំដាប់លំដោយ។

ក្នុងការផ្តួលរំលំរបបរបស់បនប្រឆាំងប្រជាជន ប្រជាជនកម្ពុជាទាំងមូលបានធ្វើវិភាគទាន ដ៏សំខាន់នៅក្នុងការសម្អាតបរិយាកាសនយោបាយនៅតំបន់អាស៊ីអាគ្នេយ៍ ប្រជានជនកម្ពុជាបានធ្វើវិភាគទានយ៉ាងសំខាន់ដល់កិច្ចការកសាងសន្តិភាព និងសន្តិសុខនៅផ្នែកនៃទ្វីបអាស៊ីដ៏សំខាន់នេះ។ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍បានធ្វើសេចក្តីថ្លែងថា ប្រទេសកម្ពុជាថ្មី នឹងរៀបចំការទាក់ទង របស់ខ្លួនជាមួយប្រទេសទាំងអស់នៅលើគោលការណ៍នៃការរួមរស់ដោយសន្តិភាព។ ប្រទេសកម្ពុជាថ្មី នឹងពង្រឹងសាមគ្គីភាពរបស់ខ្លួន ជាមួយបណ្តាប្រទេសសង្គមនិយម ជាមួយរដ្ឋទាំងឡាយដែលតស៊ូដើម្បីឯករាជ្យជាតិ ជាមួយបណ្តាចលនារំដោះជាតិទាំងអស់។ ប្រទេសកម្ពុជាថ្មី នឹងធ្វើសកម្មភាពគ្រប់បែបយ៉ាងដើម្បីពង្រឹងចលនានៃប្រទេសមិនចូលបក្សសម្ពន្ធ។

នៅក្នុងសេចក្តីថ្លែងការណ៍ចុះថ្ងៃទី១០ មករា ឆ្នាំ១៩៧៩ មានសេចក្តីបញ្ជាក់ថា ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ គឺជាអង្គការគ្រប់គ្រងរដ្ឋដ៏ត្រឹមត្រូវតាមច្បាប់តែមួយរបស់ប្រទេស នៅក្នុងការទាក់ទងអន្តរជាតិនៅអង្គការសហប្រជាជាតិ នៅក្នុងចលនាមិនចូលបក្សសម្ពន្ធ និងនៅក្នុងអង្គការអន្តរជាតិនានា ដែលប្រទេសកម្ពុជា ជាសមាជិក។

# ចំពូកទី ៣
## សាធារណរដ្ឋប្រជាមានិតកម្ពុជា

បន្ទាប់ពីពេលទទួលជ័យជម្នះដោយបដិវត្តន៍ភ្លាម គេបានចាប់ផ្ដើមបំពេញការងារបន្ទុះនូវដំបៅដ៏ធ្ងន់ធ្ងរ ដែលកើតមានឡើងចំពោះប្រទេសកម្ពុជា ដោយសារការប្រល័យពូជសាសន៍របស់បនប៉ុល ពត, អៀង សារី, ខៀវ សំផន។ គេបានធ្វើសេចក្ដីប្រកាស ស្ដីអំពីការបដិសេធចោលនូវច្បាប់ប្រឆាំងប្រជាជននានារបស់បនប៉ុល ពត ជាសេចក្ដីប្រកាសស្ដីអំពីការធានាដល់សេរីភាពប្រជាធិបតេយ្យ ដល់សេរីភាពក្នុងជំនឿសាសនា ដល់សិទ្ធិចំពោះការងារ ការឈប់សម្រាក ការសិក្សា ដល់សមភាពសម្រាប់ពលរដ្ឋទាំងអស់ ដល់ការគោរពចំពោះបុគ្គលិកលក្ខណៈ និងអត្តភាពរបស់មនុស្ស។ នៅគ្រប់ទិសទី នៅទីក្រុង ក៏ដូចជានៅស្រុកស្រែ គេបានបង្កើត គណៈកម្មាធិការប្រជាជនបដិវត្តន៍ស្វយ័តនានា ដែលទទួលភារកិច្ចអនុវត្ត ការរៀបចំសង្គមតាមរបៀបបដិវត្តន៍សង្គមនិយម ទទួលភារកិច្ចក្នុងការផ្ដល់ជំនួយដល់ជនជាតិកម្ពុជាទាំងអស់ណា ដែលទទួលការអនុញ្ញាតឱ្យត្រឡប់មកកាន់ទីក្រុង និងភូមិកំណើតរបស់ខ្លួន ឬមកជួបជុំគ្រួសាររបស់ខ្លួន។

កិច្ចការស្ដារស្ថានភាពប្រទេសឡើងវិញ បានចាប់ផ្ដើមប្រព្រឹត្តទៅ នៅក្នុងស្ថានភាពដ៏លំបាកលំបិនយ៉ាងក្រៃលែង។ របបប៉ុល ពត បានបំផ្លិចបំផ្លាញខ្ទេចខ្ទីដល់មូលដ្ឋាននូវរបៀបគ្រប់គ្រងខាងសង្គមទាំងអស់របស់ប្រទេស ពួកវាបានបំផ្លិចបំផ្លាញទម្រង់នៃជីវភាពធម្មតារបស់ប្រជាជន ហើយមិនតែ

ប៉ុណ្ណោះ ពួកវាបានធ្វើឱ្យមានមហាវិនាសកម្ម និងអនាធិបតេយ្យដ៏ខ្លាំងក្លាដល់សេដ្ឋកិច្ចជាតិ ដែលពុំទាន់មានការលូតលាស់នៅឡើយ។ ពួកវាបានធ្វើឱ្យអន្តរាយដ៏ធ្ងន់ ជាពិសេសដល់ប្រព័ន្ធឧស្សាហកម្ម គមនាគមន៍ និងទូរគមនាគមន៍របស់ប្រទេសទាំងមូល។

វិស័យកសិកម្ម បានស្ថិតនៅក្នុងស្ថានភាពដ៏ធ្ងន់ធ្ងរបំផុត។ ការប្រហារជីវិត ជនានុជនរាប់លាននាក់បណ្តាលឱ្យមានផលវិបាកដ៏ខ្លាំង ដោយហេតុថា បណ្តាជននៅស្រុកស្រែបានថយចំនួនដ៏សម្បើម។ ការបង្កើតទូទៅនៅក្នុងប្រទេសនូវរបបរស់នៅរួមគ្នាក្នុង "ឃុំ" ដោយគ្មានការប្រើប្រាស់ និងការលក់ដូរទំនិញដោយគ្មានសិទ្ធិ ក្នុងការប្រើប្រាស់ភោគផលនៃពលកម្មរបស់ខ្លួនបានបង្កើតឱ្យមានស្ថានភាពក្រីក្រតោកយ៉ាក ទូទៅនៅក្នុងប្រទេស។ នៅតំបន់ស្រុកស្រែនានា មានការខ្វះខាតខាងពូជដំណាំ ខាងសត្វពាហណៈ ខាងគ្រឿងសម្ភារៈកសិកម្ម។

កិច្ចការស្តារស្ថានភាព ឱ្យមានជីវភាពសេដ្ឋកិច្ចធម្មតាឡើងវិញ បានប្រព្រឹត្តទៅដោយសេចក្តីលំបាកលំបិនបំផុត ដោយកង្វះខាតដ៏ខ្លាំង ខាងក្របខ័ណ្ឌដែលមានគុណសម្បត្តិ។ នៅក្រោមសម័យនៃការត្រួតត្រារបស់បន ប៉ុល ពត បននេះបានប្រហារជីវិតក្របខ័ណ្ឌ និងអ្នករដ្ឋការរបស់ប្រទេសអស់ ៨០% ដែលនៅក្នុងនេះ មានអ្នករដ្ឋការនៅក្រសួងនានា វិស្វករ ក្របខ័ណ្ឌបច្ចេកទេស អ្នកឯកទេសនៅក្នុងវិស័យកសិកម្ម និងសេដ្ឋកិច្ចជាតិ គ្រូពេទ្យនានា និងអ្នកបម្រើក្រសួងអប់រំ និងវប្បធម៌។ ស្របតាមឯកសារបោះពុម្ពផ្សាយនៅទីក្រុងភ្នំពេញ ក្នុងបណ្តាសាស្ត្រាចារ្យឧត្តមសិក្សាចំនួន ៧២០នាក់ នៅសល់តែសាស្ត្រាចារ្យ ៥០នាក់

ដែលនៅរស់ ក្នុងបណ្តាគ្រូចំនួន ៤៨៧នាក់ - នៅរស់តែ ៥៤នាក់ ក្នុងបណ្តាឱសថការីចំនួន ១៩៦នាក់ - នៅរស់តែ ១៥នាក់ ក្នុងបណ្តាបញ្ញវន្ត ដែលបានធ្វើការសិក្សានៅបរទេសចំនួន ១.០០០ នាក់ - នៅរស់តែ ៨៥នាក់ ក្នុងបណ្តាសាស្ត្រាចារ្យអនុវិទ្យាល័យ និងវិទ្យាល័យចំនួន ២.៣០០នាក់ នៅរស់តែ ២០៧នាក់ ក្នុងបណ្តាគ្រូបង្រៀនបឋមសិក្សាចំនួន ២១.៣១១នាក់ - នៅរស់តែ ២,៧១៧ នាក់ ក្នុងបណ្តានិស្សិតនៅឧត្តមសិក្សាចំនួន ១១ពាន់នាក់ - នៅរស់តែ ៤៥០នាក់ ក្នុងបណ្តាសិល្បករចំនួន ១.២៤១នាក់ - នៅរស់តែ ១២១នាក់។

នៅថ្ងៃទី១៤ មីនា ឆ្នាំ១៩៧៩ នៅទីក្រុងភ្នំពេញ មានការបើកសម័យប្រជុំសន្និបាត កម្មាភិបាលដឹកនាំទូទាំងប្រទេសកម្ពុជា ដែលបានទទួលភារកិច្ចស្តារស្ថានភាពសេដ្ឋកិច្ច ដែលបានធ្លាក់ក្នុងវិនាសកម្មដ៏ធ្ងន់ធ្ងរ ដើម្បីជម្នះលើផលវិបាកនានា ដែលកើតមានឡើងដោយអំពើផ្តាច់ការឧក្រិដ្ឋព្រៃផ្សៃរបស់បនប៉ុល ពត។ ជាចាំបាច់ត្រូវតែពន្លឿនសង្វាក់ នៃស្ថិរភាពក្នុងជីវភាពប្រជាជន ដោយការផ្តល់ជំនួយគ្រប់បែបយ៉ាងដល់អ្នកស្រុក ដែលបានវិលត្រឡប់មកស្រុកកំណើតវិញ ដោយការបង្កើតឱ្យមានលក្ខខណ្ឌដ៏ប្រសើរក្នុងការរៀបចំសេដ្ឋកិច្ចជាតិឡើងវិញ។

នៅពេលជាមួយគ្នា ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា ត្រូវបានបង្ខំចិត្តធ្វើការប្រយុទ្ធប្រឆាំងនឹងសំណល់បនបាក់ទ័ព ប៉ុល ពត។ ពួកសំណល់បន ប៉ុល ពត បានចាប់ផ្តើមធ្វើការប្រយុទ្ធលបធ្មក់ប្រឆាំងរដ្ឋាភិបាលបដិវត្តន៍ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ស្ថានីយផ្សាយវិទ្យុ “ សំឡេងកម្ពុជាប្រជាធិបតេយ្យ ” ដែលស្ថិតនៅលើខេត្តខាងត្បូង នៃប្រទេសចិន ឈ្មោះ

យូណាន់ បានចាប់ផ្តើមធ្វើសកម្មភាពរបស់ខ្លួនតាងនាមនៃរបប ប៉ុល ពត។ នៅតំបន់ព្រំប្រទល់នានា នៃប្រទេសកម្ពុជា ជាប់នឹងប្រទេសថៃឡងដ៍ កងប្រដាប់អាវុធរបស់ចលនា “ សេរីកា ” ដែលតំណាងឱ្យកម្លាំងខាងស្តាំបំផុត បានចាប់ផ្តើមធ្វើសកម្មភាពនៅទីទាំងនោះ។ ក៏ប៉ុន្តែ ផែនការរបស់ពួកប្រតិកិរិយាដើម្បីរៀបចំរបប ដែលរលំហើយឡើងវិញ ត្រូវបានទទួលបរាជ័យ។ នៅខែមីនា - មេសា ឆ្នាំ ១៩៧៩ កងកម្លាំងប្រដាប់អាវុធរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើការវាយប្រហារយ៉ាងខ្លាំងក្លាទៅលើមូលដ្ឋានសឹកដ៏សំខាន់របស់បនប៉ុល ពត នៅតំបន់តាសាញ់ (ខេត្តបាត់ដំបង) ដែលត្រូវបានកសាងឡើងមុនពេលរលំនៃរបបប៉ុល ពត, អៀង សារី, ខៀវ សំផន។ នៅមូលដ្ឋាននេះមានការកសាងប្រព័ន្ធដ៏ស្មុគស្មាញ សម្រាប់កិច្ចការពារខាងយោធាក្នុងពេលដ៏យូរអង្វែង ប្រកបដោយជម្រកជារូងក្នុងដីខ្វាត់ខ្វែង ព្រមទាំងកន្លែងដាក់ស្បៀងអាហារ គ្រឿងអាវុធ និងគ្រាប់រំសេវ។

ទោះបី ប៉ុល ពត និងក្រុមពួករបស់ខ្លួនបានរត់គេចផុតពីការវាយប្រហារយកមូលដ្ឋាននេះក្តី ក៏ប្រតិបដិវត្តន៍ត្រូវបានទ្រុឌទ្រោមជាទម្ងន់ ហើយមិនអាចងើបមុខតទល់ទៀតកើតឡើយ។ ដោយគ្មានការគាំទ្រពីបណ្តាជន ហើយត្រូវបាក់បែក បែកខ្ញែកដ៏ខ្លាំង ក្រុមប្រតិបដិវត្តន៍ជាច្រើនបានចូលមកសារភាពដល់រដ្ឋអំណាចនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ជាមួយនឹងការកម្ទេចមូលដ្ឋាននៅតាសាញ់ មានការកម្ទេចនូវអគ្គទីបញ្ជាការកងទ័ពប៉ុល ពត នៅអមលាំង (ខេត្តកំពង់ស្ពឺ) នូវសំណល់កងនាវាចរណ៍ប៉ុល ពត ដែលពួនលាក់ខ្លួននៅតាមព្រៃកនានានៅ

ខេត្តកោះកុង នូវមូលដ្ឋានខាងក្រោយជាចុងក្រោយនានារបស់ពួកវានៅខេត្តពោធិ៍សាត់។

អត្ថន័យដ៏សំខាន់បំផុតក្នុងការបើកមុខអាក្រាត និងផ្ដន្ទាទោសដល់អំពើឧក្រិដ្ឋដ៏ឃោរឃៅព្រៃផ្សៃរបស់បនប៉ុល ពត និងដល់របបប្រឆាំងប្រជាជនរបស់បននេះ គឺការបើកសម័យប្រជុំកាត់ទោសនៃតុលាការប្រជាជន ដែលបានប្រព្រឹត្តទៅនៅទីក្រុងភ្នំពេញ ពីថ្ងៃទី១៥ - ២០ សីហា ឆ្នាំ១៩៧៩។ តុលាការបដិវត្តន៍ប្រជាជនពិសេសនេះ ត្រូវបានបង្កើតឡើងដោយក្រឹត្យរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍នៃប្រទេសកម្ពុជា។ នៅក្នុងលិខិតចោទប្រកាន់ ដែលរៀបចំឡើងដោយការប្រមូលឯកសារដ៏ច្រើនលើសលប់ មានភស្តុតាងរបស់សាក្សីនានា មានសក្ខីភាពជាក់ស្ដែង មានការពិនិត្យគុក និងជំរំឃុំឃាំង ព្រមទាំងកន្លែងនានា ដែលពួកវាបានប្រហារជីវិតមនុស្ស។

នៅសម័យប្រជុំកាត់ក្ដី របស់តុលាការប្រជាជនបដិវត្តន៍មានការប្រមូលផ្ដុំ នូវឯកសារនានាដែលបញ្ជាក់អំពីភាពជាប់ពិរុទ្ធក្នុងអំពើឧក្រិដ្ឋរបស់អតីតរដ្ឋមន្ត្រីទី១នៃ “កម្ពុជាប្រជាធិបតេយ្យ” នាម ប៉ុល ពត និងអនុរដ្ឋមន្ត្រីទី១ នាម អៀង សារី គឺជាអំពើឧក្រិដ្ឋដ៏ធ្ងន់ធ្ងរក្រៃលែង គឺជាការប្រហារជីវិតគិតទុកជាមុនចំពោះជនានុជនស្លូតត្រង់ គឺការបណ្ដេញបណ្ដាជនពីទីក្រុង និងស្រុកស្រែនានា ការបង្កើតជំរំឃុំឃាំងទាំងឡាយសម្រាប់ពលកម្មដោយបង្ខំ ការបំផ្លិចបំផ្លាញប្រព័ន្ធសេដ្ឋកិច្ច និងវប្បធម៌របស់ប្រទេស ការបំបាត់ប្រពៃណីក្នុងចំណោមគ្រួសារ និងការទាក់ទងរបស់សាធារណជន។ ដូចមានសេចក្ដីបញ្ជាក់ក្នុងលិខិតចោទប្រកាន់នៅក្រោមរបបត្រួតត្រារបស់បនប៉ុល ពត, អៀង សារី,

ខៀវ សំផន នយោបាយប្រល័យពូជសាសន៍បានប្រព្រឹត្តទៅនៅលើទឹកដីកម្ពុជា ទាំងមូល ហើយជាហេតុបណ្តាលឱ្យមានការបាត់បង់ជីវិតរបស់ប្រជាជនជិតដល់ ៣លាននាក់។ ប្រជាជនជាង ៤លាននាក់ ដែលនៅរស់រានមានជីវិត ត្រូវបានទ្រុឌទ្រោមខាងផ្លូវកាយ និងផ្លូវចិត្តជាខ្លាំង។ នយោបាយនៃឃាតកម្មប្រជាជនទូទៅត្រូវបានធ្វើឡើងដើម្បីសម្លាប់ប្រជាជនកម្ពុជា ទាំងខាងផ្លូវកាយ និងផ្លូវចិត្ត។

តុលាការប្រជាជនបដិវត្តន៍បានទទួលស្គាល់ថា ប៉ុល ពត, អៀង សារី និងខៀវ សំផន ជាមេកើយនៃរបបគ្រប់គ្រងដែលរលំទៅហើយ ជាមនុស្សជាប់ពិរុទ្ធក្នុងការប្រព្រឹត្តអំពើមហាឧក្រិដ្ឋកម្មនៃការប្រល័យពូជសាសន៍ ហើយបានកាត់ទោសប្រហារជីវិតតាមវិធានការដ៏តឹងតែងបំផុតដល់ពួកប៉ុល ពត , អៀង សារី។ នៅក្នុងសាលក្រម នៃសេចក្តីកាត់ទោសនេះមានការបញ្ជាក់ថាមនុស្សជាប់ចោទ នៅតែបន្តសកម្មភាពក្បត់ របស់ខ្លួនចំពោះប្រទេសជាតិ ហើយធ្វើសកម្មភាពនេះជាមួយពួកប្រតិកិរិយាបរទេសប្រឆាំងប្រជាជនកម្ពុជា។ តុលាការប្រជាជនបដិវត្តន៍បានអនុម័តលើសេចក្តីសម្រេច ស្តីអំពីការស្វែងរកចាប់ឃុំឃាំងជនឧក្រិដ្ឋទាំងពីរនេះ ដែលកំពុងលាក់ខ្លួនបំពួនអាត្មា។

ពីថ្ងៃទី២៩ - ៣០ ខែកញ្ញា ឆ្នាំ១៩៧៩ នៅទីក្រុងភ្នំពេញមានការបើកសម័យ ប្រជុំនៃមហាសន្និបាតទី២ របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា ដែលនៅក្នុងនេះ មានការចូលរួមពីសំណាក់ប្រតិភូចំនួន ៥០០រូប ដែលជាតំណាងខេត្តទាំងអស់របស់ប្រទេស។ អង្គប្រជុំនៃមហាសន្និបាតបានធ្វើសេចក្តីរាយការណ៍បូកសរុបអំពីសកម្មភាពរបស់រណសិរ្ស និងក្រុមប្រឹក្សា

ប្រជាជនបដិវត្តន៍កម្ពុជា នៅក្នុងវិស័យនៃការតស៊ូបំបាត់ផលវិបាកដ៏ធ្ងន់ធ្ងរ នៃរបបត្រួតត្រាដ៏ឃោរឃៅផ្តាច់ការ របស់ប៉ុល ពត ហើយបានអនុម័តលើសេចក្តីសម្រេច ដែលទាក់ទងទៅនឹងកិច្ចការស្តារស្ថានភាពនៃជីវភាពធម្មតានៃសាធារណរដ្ឋ ព្រមទាំងបានបញ្ជាក់អំពីគោលដៅដ៏សំខាន់ៗ នៅក្នុងការស្ថាបនាមូលដ្ឋានសង្គមសេដ្ឋកិច្ច និងនៅក្នុងវិស័យនយោបាយ។

ប្រតិភូទាំងឡាយរបស់មហាសន្និបាត បានអនុម័តលើលក្ខន្តិកៈបណ្តោះអាសន្ន របស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ នៅក្នុងលក្ខន្តិកៈនេះ មានសេចក្តីបញ្ជាក់ថា៖ “រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា គឺជាអង្គការមហាជនប្រជាជនកម្ពុជា ដែលបានធ្វើការប្រយុទ្ធប្រឆាំងរបបប៉ុល ពត ប្រឆាំងពួកចក្រពត្តិ និងពួកប្រតិកិរិយាទាំងអស់។ អង្គការនេះធ្វើការតស៊ូដើម្បីឯករាជភាព ការសង្គ្រោះជាតិ ការស្ថាបនាប្រទេសកម្ពុជា ឯករាជ្យប្រជាមានិត អព្យាក្រឹត មិនចូលបក្សសម្ពន្ធ និយមសន្តិភាព ធ្វើដំហានទៅមុខតាមមាគ៌ាឆ្ពោះទៅកាន់សង្គមនិយម បំពេញវិភាគទានរបស់ខ្លួនក្នុងការពង្រឹងសន្តិភាព និងស្ថិរភាពនៅតំបន់អាស៊ីអាគ្នេយ៍ និងលើពិភពលោកទាំងមូល។

នៅក្នុងដំណោះស្រាយភារកិច្ចខាងសេដ្ឋកិច្ច ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា បានយកចិត្តទុកដាក់ជាពិសេសទៅលើបញ្ហានានា ទាក់ទងទៅនឹងកិច្ចការស្តារស្ថានភាពខាងផលិតកម្មកសិកម្មឡើងវិញ។ នៅសម័យកាលក្រោមរបបប៉ុល ពត ដីសម្រាប់ដាំដំណាំ ២/៣ ត្រូវបានបោះបង់ចោល សត្វពាហនៈគោក្របី ដែលពីមុនមានចំនួនដល់ ៣លានក្បាល ហើយឥលូវនៅសល់តែ ៧០០ពាន់ក្បាល។ ក្នុងការដេកខ្លួនថយក្រោមការវាយលុក

របស់កម្លាំងប្រដាប់អាវុធបដិវត្តន៍ កងទ័ពបនប៉ុល ពត បានដុត បំផ្លាញជង្រុកស្រូវធំៗ ដើម្បីបង្កើតឱ្យមានទុរ្ភិក្សនៅក្នុងប្រទេស។ នៅក្នុងតំបន់ជាច្រើន ប្រព័ន្ធបង្ហូរទឹកត្រូវបានបំផ្លាញចោល។

ភារកិច្ចជាបន្ទាន់បំផុត បានចោទឡើងចំពោះក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា - គឺតស៊ូជម្នះលើសេចក្តីអត់ឃ្លាន ធានាដល់ប្រជាជនដោយការផ្តល់ស្បៀងអាហារ បង្កើនលទ្ធភាពនានា ដើម្បីធ្វើឱ្យរោងឧស្សាហកម្មមានដំណើរការធម្មតា។ នៅឆ្នាំ១៩៧៩ កិច្ចការសាបព្រោះបានប្រព្រឹត្តទៅដ៏ប្រសើរ នៅក្នុងតំបន់នានា នៅតំបន់កណ្តាល ខាងកើត និងខាងត្បូងនៃប្រទេស។ ដំណាំស្រូវបានគ្របដណ្តប់លើដីទំហំ ៨៥៣.០០០ហិកតា ហើយដំណាំស្បៀងឯទៀតៗ បានគ្របដណ្តប់លើដីចំនួន ១៩០.០០០ហិកតា។ នៅឆ្នាំ១៩៨០ គេបានធ្វើដំណាំស្រូវលើដីទំហំ ១.២០០.០០០ហិកតា ហើយដំណាំស្បៀង និងដំណាំឧស្សាហកម្មនៅលើដីទំហំជាង ២០០.០០០ ហិកតា។

ក្នុងកិច្ចការធ្វើស្រែចម្ការ កសិករបានទទួលការឧបត្ថម្ភ និងជំនួយជាគ្រឿងឧបករណ៍ពីរដ្ឋអំណាចប្រជាជន។

រោងចក្រធ្វើជីហ្វូស្វាត បានដំណើរការ គេបានរៀបចំប្រឡាយបង្ហូរទឹក អាងរក្សាទឹក និងប្រព័ន្ធបង្ហូរទឹកដទៃទៀតជាថ្មីឡើងវិញ។ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍បានធ្វើការអំពាវនាវដល់បណ្តាកសិករឱ្យបង្កើត “ ក្រុមសាមគ្គីបង្កបង្កើនផល ” ដើម្បីធានាដល់ការដោះស្រាយភារកិច្ចដ៏ស្មុគស្មាញទាំងឡាយ ដែលបានចោទឡើងចំពោះរបរកសិកម្ម។ គ្រាន់តែពីឆ្នាំ១៩៧៩ - ១៩៨០ នៅប្រទេសកម្ពុជា គេបង្កើនបាន “ ក្រុមសាមគ្គីបង្កបង្កើនផល ”

ចំនួន ៧០ពាន់ក្រុម ហើយមួយក្រុមៗ មានគ្រួសារចំនួន ពី ១៥ - ២០។

ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ បានអនុម័តលើសេចក្តីទូន្មានជាពិសេស ស្តីអំពីទម្រង់នៃអង្គការចាត់តាំង និងសិទ្ធិនានារបស់ក្រុមសាមគ្គីបង្កបង្កើនផល នៅស្រុកស្រែចម្ការនានា។ នៅក្នុងសេចក្តីទូន្មាននេះ មានចែងបញ្ជាក់ថា៖ ដោយយោងទៅលើស្ថានភាពលំបាកខ្វះខាតរបស់កសិករ រដ្ឋបានបដិសេធ និងបន្ធូរបន្ថយមិនយកពន្ធកសិកម្ម នៅក្នុងដំណាក់កាលដ៏ចាំបាច់នេះ។ ក្រុមសាមគ្គីបង្កបង្កើនផលអនុវត្តការចែករំលែកផលដំណាំ ឬប្រាក់ចំណេញដល់សមាជិកនីមួយៗរបស់ក្រុម ដោយយោងទៅតាមប្រភេទនៃការងារដែលបានបំពេញ ឬទៅតាមចំនួនថ្ងៃនៃការបំពេញការងារ។ ក្រុមសាមគ្គីបង្កបង្កើនផលធានារ៉ាប់រងផ្តល់ប្រាក់ចំណូល សម្រាប់ការធានាដល់ការចិញ្ចឹមជីវិតរបស់គ្រួសារនីមួយៗ។ នៅក្នុងសេចក្តីទូន្មានរបស់ក្រុមប្រឹក្សាមានការបញ្ជាក់ថា៖ រដ្ឋធានារ៉ាប់រងជាអាទិដល់ក្រុមសាមគ្គីបង្កបង្កើនផល ដោយការផ្តល់ស្បៀង និងពូជដំណាំ។ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ បានអំពាវនាវដល់បណ្តាកសិករឱ្យធ្វើដំណាំលើដីទំនេរជាមួយគ្នានឹងបំពេញការងារលើដី ដែលស្ថិតនៅជាកម្មសិទ្ធិរបស់ក្រុមសាមគ្គីបង្កបង្កើនផល។ ក្នុងគោលបំណងពង្រីកទូទៅនូវកម្លាំងផលិតកម្មនៅក្នុងវិស័យកសិកម្មជាមួយគ្នា និងការបង្កើតសិទ្ធិនៃកម្មសិទ្ធិជាសមូហភាពនៅលើដី មានការបន្ធូរបន្ថយឱ្យមានកម្មសិទ្ធិផ្ទាល់ខ្លួននៅលើដីទៀតផង។

នៅឆ្នាំ១៩៧៩ - ១៩៨០ សេចក្តីភិតភ័យចំពោះគ្រោះទុរ្ភិក្សប្រជាជន ដែលបានកើតមានឡើងដោយផលវិបាកអាក្រក់នៃ

របបប៉ុល ពត ដោយសារការអន្តរាយខាងសេដ្ឋកិច្ច ត្រូវបាន ទប់ទល់ទាន់ដោយការផ្តល់ជំនួយអង្ករជាបន្ទាន់ និងស្បៀង អាហារដទៃទៀត ពីសហភាពសូវៀត ពីប្រទេសវៀតណាម ព្រមទាំងដោយសារជំនួយ របស់អង្គការមនុស្សធម៌អន្តរជាតិនានា អង្គការយូនីសេហ្វ អង្គការមូលនិធិកុមារនៃអង្គការសហប្រជាជាតិ គណៈកម្មាធិការអន្តរជាតិនៃកាកបាទក្រហម អង្គការអុក្សហ្វាំម និងដទៃទៀត។ ក្នុងអំឡុងពីរឆ្នាំនោះ នៅតំបន់ស្រុកស្រែនានា លក្ខខណ្ឌដ៏ប្រសើរ បានកើតមានឡើងសម្រាប់ការបង្កើនផលិតកម្មក្នុងវិស័យកសិកម្ម។ កសិករចំនួនជាង ៩០% បានបង្រួបបង្រួមគ្នាជាក្រុមសាមគ្គីបង្កបង្កើនផល ចំនួនត្រាក់ទ័រក៏បានកើតចំនួន សត្វពាហនៈសម្រាប់របកសិកម្មក៏បានកើនឡើងច្រើន ហើយកសិដ្ឋានកសិក របានទទួលគ្រឿងឧបករណ៍កសិកម្ម កាន់តែប្រសើរ។ គ្រាន់តែនៅរដូវវស្សាឆ្នាំ១៩៨០ - ១៩៨១ ផលដំណាំស្រូវទទួលបានចំនួន ១.៥០០.០០០តោន ជាចំនួនដែលអាចធានាដល់សេចក្តីត្រូវការ ខាងស្បៀងអាហារសម្រាប់បណ្តាជនប្រទេសមួយភាគធំ។

នៅពេលពាក់កណ្តាលនៃឆ្នាំ១៩៨០ គេបានសម្រេចជោគជ័យដ៏សំខាន់ៗ នៅក្នុងកិច្ចការរៀបចំខឿនឧស្សាហកម្មឡើងវិញ។ រោងជាង និងរោងចក្រចំនួន ៨០% បានចាប់ផ្តើមដំណើរការរបស់ខ្លួន។ យានជំនិះក៏បានចាប់ផ្តើមមានសកម្មភាពជាថ្មី។ ផ្លូវរទេះភ្លើងដែលភ្ជាប់រដ្ឋធានី និងទីក្រុងបាត់ដំបង ព្រមទាំងផែសមុទ្រកំពង់សោម ក៏ត្រូវបានរៀបចំឱ្យបំពេញសកម្មភាពឡើងវិញ។ ជាថ្មី ចរាចរណ៍តាមផ្លូវថ្នល់ និងតាមផ្លូវទឹកក៏បានចាប់ផ្តើមមានឡើងយ៉ាងសកម្មរស់រវើក។ អាកាសចរណ៍បាន

ចាប់ផ្តើមធ្វើសកម្មភាពរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ព្រមទាំងប្រទេសឡាវ។ តាំងពីខែធ្នូ ឆ្នាំ១៩៨០ មានការបើកចរាចរខាងអាកាសចរណ៍រវាងទីក្រុងភ្នំពេញ និងទីក្រុងម៉ូស្គូ។ ប្រព័ន្ធនៃការទាក់ទងខាងប្រៃសណីយ៍នៅក្នុងប្រទេស និងក្រៅប្រទេស ដែលត្រូវបានបញ្ឈប់ក្នុងសម័យរបបប៉ុល ពត ត្រូវបានរៀបចំឱ្យមានដំណើរការឡើងវិញ។

នៅខែមីនា - មេសា ឆ្នាំ១៩៨០ នៅក្នុងប្រទេស ដែលបានរស់នៅអស់រយៈពេលប្រាំឆ្នាំ ដោយគ្មានការប្រើប្រាក់កាសបានចាប់ផ្តើមប្រើប្រាក់រៀល របស់សាធារណរដ្ឋប្រជាមានិតកម្ពុជាឡើងវិញ។ ការរៀបចំប្រព័ន្ធប្រាក់នៅក្នុងប្រទេសបានបង្កើនចលនារីកចម្រើនខាងសេដ្ឋកិច្ច បានសម្រួលស្ថានភាពផ្សារក្នុងប្រទេស បានបង្កើនកម្រិតជីវភាពប្រជាជនគ្រប់ស្រទាប់នៅក្នុងប្រទេស។ ប្រព័ន្ធអប់រំប្រជាជន និងក្រសួងសុខាភិបាល ក៏បានចាប់ផ្តើមរីកចម្រើនឡើងវិញតាមទំហំដ៏ធំធេង។ សិស្សានុសិស្សជិត ១.៥០០.០០០នាក់ បានទៅរៀនសូត្រនៅសាលារៀន។

ការបោះឆ្នោតទូទៅ ដែលបានប្រព្រឹត្តទៅនៅខែមីនា-ឧសភា ឆ្នាំ១៩៨១ បានបង្ហាញឱ្យឃើញនូវការលូតលាស់ជាទូទៅនូវការពង្រឹងមូលដ្ឋាននៃរដ្ឋអំណាចប្រជាជន។ នៅក្នុងប្រវត្តិប្រទេសកម្ពុជា គឺជាការបោះឆ្នោតប្រកបដោយលក្ខណៈប្រជាធិបតេយ្យ និងសេរីភាព ជាលើកទីមួយ ដើម្បីជ្រើសរើសតំណាងប្រជាជនទាំងឡាយ សម្រាប់អង្គការរដ្ឋអំណាចនៅមូលដ្ឋាន និងនៅសភា។ បណ្តាជនគ្រប់ប្រភេទ និងគ្រប់អាយុបោះឆ្នោតទាំងអស់នៅសាធារណរដ្ឋ បានធ្វើការបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួន។ គេទាំងឡាយបានជ្រើសរើសតំណាងប្រជាជនចំនួន

១១៧រូប សម្រាប់រដ្ឋសភា ដែលជាអង្គការកំពូលនៃរដ្ឋអំណាច។ លទ្ធផលទូទៅ នៃការបោះឆ្នោតទូទាំងប្រទេស ជាសក្ខីភាពដ៏ត្រចះត្រចង់បញ្ជាក់ ឱ្យឃើញប្រចក្សនូវសាមគ្គីភាពល្អិតរមួតនៃប្រជាជនកម្ពុជា នូវការគាំទ្រប្រជាជនដល់អង្គការដឹកនាំរបស់ប្រទេសនូវភាពមិនត្រឡប់ក្រោយនូវការផ្លាស់ប្តូរបដិវត្តន៍ ដែលបានប្រព្រឹត្តទៅនៅសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ការបើកសម័យប្រជុំមហាសន្និបាតទី៤ របស់បក្សកុម្មុយនិស្តកម្ពុជា ដែលបានប្រព្រឹត្តទៅពីថ្ងៃទី២៦ ដល់ថ្ងៃទី២៩ ឧសភា ឆ្នាំ១៩៨១ គឺជាការវិវត្តជាប្រវត្តិសាស្ត្រមួយធំនៅក្នុងជីវភាពលូតលាស់ខាងសង្គម និងនយោបាយរបស់ប្រទេស។ មហាសន្និបាតបានធ្វើតុល្យការ ស្តីអំពីដំណាក់ការជាប្រវត្តិសាស្ត្រដ៏សំខាន់នៅក្នុងជីវភាពប្រទេស បានកំណត់ទិសដៅជាមូលដ្ឋាននៃការលូតលាស់របស់បក្ស និងរបស់ប្រទេសនៅសម័យបច្ចុប្បន្ន។

អង្គប្រជុំនៃមហាសន្និបាត បានអនុម័តលើសេចក្តីសម្រេចដ៏សំខាន់ៗជាប្រវត្តិសាស្ត្រ។ មានការប្រកាសជាឱឡារិកនូវមាគ៌ានៃការស្ថាបនាមូលដ្ឋានសង្គមនិយមនៅប្រទេសកម្ពុជា និងដំណើរឈានឡើងបន្តិចម្តងៗ ឆ្ពោះទៅកាន់សង្គមនិយមនៅក្នុងសហប្រតិបត្តិការដ៏ជិតស្និទ្ធជាមួយបណ្តាប្រទេសសង្គមនិយមជាបងប្អូន។ មានសេចក្តីថ្លែងការណ៍ដ៏មុឺងម៉ាត់ស្តីអំពីការចាំបាច់ការពង្រឹងតទៅអនាគត នូវយុទ្ធសាមគ្គីភាពបដិវត្តន៍រវាងប្រទេសទាំងបីជាបងប្អូននៅឥណ្ឌូចិន - គឺវៀតណាម ឡាវ កម្ពុជា។ ប្រតិភូនៃមហាសន្និបាតបានវាយតម្លៃយ៉ាងខ្ពស់ដល់បេសកកម្មរំដោះរបស់កងយោធាវៀតណាម ដែលបានជួយស្រោចស្រង់ប្រជាជនកម្ពុជា ឱ្យចៀសផុតពីក្រញាំរបស់របបប្រល័យពូជ

សាសន៍ ហើយបានជួយឧបត្ថម្ភក្នុងកិច្ចការពារមាតុភូមិ ប្រឆាំងអំពើជ្រៀតជ្រែកពីសំណាក់ពួកសត្រូវក្រៅប្រទេស និងក្នុងការកសាងជីវភាពថ្មី។

ភារកិច្ចដ៏ចម្បងមួយ នៅក្នុងសម័យប្រជុំមហាសន្និបាត គឺការពិភាក្សាលើកម្មវិធីស្តីអំពីកិច្ចការស្តារស្ថានភាព និងការពង្រីកសេដ្ឋកិច្ចជាតិ។ មហាសន្និបាតបានអនុម័តលើកម្មវិធីនៃផែនការប្រាំឆ្នាំ ក្នុងការពន្លឿននៃការបង្កើនសេដ្ឋកិច្ចជាតិឱ្យបានសម្រេចលទ្ធផល ប្រហាក់ប្រហែលនឹងស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា នាសម័យខាងចុងឆ្នាំ១៩៦០។ ដោយយោងទៅតាមលក្ខណៈធម្មជាតិនៃប្រទេស មហាសន្និបាតបានទាញយោបល់រួម ដូចតទៅ - កសិកម្ម គឺជាស្នូលដើម្បីដោះស្រាយភារកិច្ចនានានៅក្នុងការពង្រីកសេដ្ឋកិច្ចជាទូទៅ។ មហាសន្និបាតបានកំណត់ប្រមូលផលដំណាំស្បៀងប្រចាំឆ្នាំ ឱ្យបានដល់ ២,៥ - ២,៨លានតោន នៅក្នុងផែនការប្រាំឆ្នាំ បច្ចុប្បន្ន ១៩៨១ - ១៩៨៥។

ស្របតាមកម្មវិធីសង្គម - សេដ្ឋកិច្ច អនុម័តដោយអង្គប្រជុំរបស់មហាសន្និបាត នៅក្នុងសម័យនៃដំណើរចម្លងឈានឡើងទៅកាន់សង្គមនិយម សេដ្ឋកិច្ចប្រទេសកម្ពុជា នឹងបង្រួមវិស័យសេដ្ឋកិច្ចបីប្រភេទ គឺ៖ សេដ្ឋកិច្ចរដ្ឋ ដែលនៅក្នុងនេះ មានរោងឧស្សាហកម្មទាំងអស់ គមនាគមន៍ សហគ្រាសសេដ្ឋកិច្ច និងពាណិជ្ជកម្មមួយចំនួនធំ។ សេដ្ឋកិច្ចសមូហភាព ដែលនៅក្នុងនេះ មានក្រុមសាមគ្គីបង្កបង្កើនផលកសិករទាំងឡាយ។ សេដ្ឋកិច្ចឯកជន ដែលនៅក្នុងនេះមានកសិករឯកជន អ្នកលក់ដូរតូចតាចសិប្បករឯកជន។

ឯកសារអនុម័ត ដោយមហាសន្និបាតបានគូសបញ្ជាក់ថា រដ្ឋយកចិត្តទុកដាក់ជាពិសេសដល់ការពង្រីកសេដ្ឋកិច្ចរដ្ឋ និងសេដ្ឋកិច្ចសមូហភាព ហើយនៅពេលជាមួយគ្នា រដ្ឋនឹងតម្លើងទឹកចិត្តដល់ការផ្ដើមគំនិតឯកជន ជាពិសេសក្នុងផ្នែកពាណិជ្ជកម្ម ដែលនៅក្នុងដំណាក់ការបច្ចុប្បន្ន និងជំរុញឱ្យសេដ្ឋកិច្ចមានសកម្មភាពរស់រវើក និងជួយលើកស្ទួយឱ្យបណ្ដាជនមានជីវភាពខាងសម្ភារៈកាន់តែប្រសើរឡើង។

មហាសន្និបាតបានអនុម័ត លើសេចក្ដីសម្រេចដាក់ឈ្មោះបក្សឱ្យដូចកាលពីពេលមុន គឺ បក្សប្រជាជនបដិវត្តន៍កម្ពុជា។

នៅចុងខែមិថុនា ឆ្នាំ១៩៨១ នៅទីក្រុងភ្នំពេញ មានការបើកសម័យប្រជុំនីតិកាលទី១របស់រដ្ឋសភា។ សមាជិករួបរួមក្នុងសម័យប្រជុំ បានធ្វើសេចក្ដីអនុម័តជាឯកច្ឆ័ន្ទលើរដ្ឋធម្មនុញ្ញនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។ មាត្រាច្បាប់ជាគ្រឹះ ដែលពង្រឹងនូវរបបគ្រប់គ្រងប្រជាធិបតេយ្យពិតប្រាកដ ប្រកាសជាឱឡារិកថា ប្រជាជនជាម្ចាស់ពិតប្រាកដលើទឹកដីប្រទេសកម្ពុជា ព្រមទាំងចែងបញ្ជាក់នូវជោគជ័យនានា ទទួលបានដោយប្រជាពលករទាំងឡាយ នៅក្នុងកិច្ចការស្តារស្ថានភាពមាតុភូមិរបស់ខ្លួនឡើងវិញ។

នៅក្នុងរដ្ឋធម្មនុញ្ញ ដែលរៀបចំឡើងដោយការប្រើប្រាស់ឯកសារពិសោធរបស់ប្រទេសនៃសហគមន៍សង្គមនិយម មានចែងច្បាស់អំពីគោលការណ៍ជាចម្បងនានា នៃរបបគ្រប់គ្រងរដ្ឋ និងទម្រង់នានាខាងនយោបាយ និងសង្គមកិច្ចច្បាស់លាស់សម្រាប់រដ្ឋប្រជាមានិតប្រជាធិបតេយ្យ។ រដ្ឋធម្មនុញ្ញបានគូសបញ្ជាក់ថា បក្សប្រជាជនបដិវត្តន៍កម្ពុជា គឺជាកម្លាំងដឹកនាំ

គ្រប់គ្រងសង្គមប្រទេសកម្ពុជា។ រណសិរ្សសាមគ្គីកសាងការពារមាតុភូមិនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា គឺជាអង្គការមហាជនដ៏សំខាន់បំផុត នៅក្នុងកិច្ចការប្រមែប្រមូលកម្លាំង របស់សង្គមដើម្បីបំពេញសេចក្តីសម្រេចនានារបស់បក្ស និងរដ្ឋាភិបាល នៅក្នុងការស្ថាបនាមូលដ្ឋាននៃសង្គមនិយម។

នៅក្នុងសម័យប្រជុំនៃនីតិកាលទីមួយរបស់រដ្ឋសភាជាតិ មានការអនុម័ត លើកម្មវិធីនៃការពង្រីកសេដ្ឋកិច្ចសាធារណរដ្ឋប្រជាមានិតកម្ពុជា សម្រាប់ឆ្នាំ១៩៨១ សម្រាប់ពេលដ៏យូរអង្វែង និងលើការបង្កើតស្ថាប័នរដ្ឋជាកំពូល។ អង្គការអចិន្ត្រៃយ៍របស់រដ្ឋសភា គឺជាក្រុមប្រឹក្សារដ្ឋប្រកបដោយគណៈប្រធាននៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។

នៅខែធ្នូ ឆ្នាំ១៩៨១ នៅទីក្រុងភ្នំពេញ មានការបើកសម័យប្រជុំនៃមហាសន្និបាតទី៣ របស់រណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា។ សម័យប្រជុំបានធ្វើរបាយការណ៍អំពីសកម្មភាពនៃអង្គការមហាជនដ៏ធំជាងគេនេះ ក្នុងការប្រមែប្រមូលកម្លាំងសង្គមនារយៈពេលបីឆ្នាំកន្លងទៅ។ តមកសម័យប្រជុំបានកំណត់កម្មវិធីនៃសកម្មភាពរបស់ខ្លួននៅពេលអនាគត។

ជោគជ័យក្នុងការបោះឆ្នោតទូទាំងប្រទេស ការអនុវត្តជាធរមាននូវរដ្ឋធម្មនុញ្ញ និងការបង្កើតស្ថាប័នរដ្ឋអំណាចនានាខាងនីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិទាំងអស់ស្របតាមរដ្ឋធម្មនុញ្ញ។ ទាំងអស់នេះបានបញ្ជាក់ ឱ្យឃើញការរីកចម្រើនថ្មីនៅក្នុងការបង្កើតស្ថាប័ននយោបាយ និងសង្គមនៅលើមូលដ្ឋានថ្មីដ៏ប្រសើរ។ អត្ថន័យដ៏ធំធេងស្ថិតនៅលើកត្តាដែលបញ្ជាក់ថា បក្សប្រជាជនបដិវត្តន៍បានបំពេញតួនាទីដ៏សំខាន់ នៅក្នុងជីវភាពនយោបាយ

និងសង្គមរបស់ប្រទេស ដូចជាកម្លាំងដឹកនាំគ្រប់គ្រងសង្គមកម្ពុជា។

តាំងពីដើមទី សាធារណរដ្ឋប្រជាមានិតកម្ពុជា បានប្រឹងប្រែងបញ្ជាក់នូវសិទ្ធិ នៃអត្ថិភាពរបស់ខ្លួនដោយឈមមុខប្រឆាំងនឹងការឃោសនារបស់សត្រូវ ដែលធ្វើឡើងដោយកម្លាំងចក្រពត្តិ និងប្រតិកិរិយាអន្តរជាតិប្រឆាំងប្រទេសកម្ពុជា។ នៅពេលជាមួយគ្នា ពួកវាបានខិតខំសាកល្បងប្រោះព្រំរបបរលំនៅកម្ពុជា ដោយការអនុវត្តផែនការបង្កើត អង្គការប្រតិបដិវត្តន៍រួមមួយដែលបញ្ចូលទាំងពួកខ្មាំងនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលរស់នៅភៀសខ្លួននៅបរទេស។ នៅខែកញ្ញា ឆ្នាំ១៩៧៩ នៅទីក្រុងប៉េកាំង អ្នកតំណាងប៉ុល ពត បានធ្វើសន្និសីទសារព័ត៌មានមួយ ដែលនៅពេលនោះ ពួកនេះបានប្រកាសអំពីការបង្កើតរបស់ដែលហៅថា “ រណសិរ្សរួបរួមជាតិកម្ពុជា ”។ នៅក្នុងគម្រោងការនៃ “ កម្មវិធីនយោបាយរណសិរ្ស ” បានបញ្ជាក់គោលដៅច្បាស់លាស់ក្នុងការប្រមែប្រមូលកម្លាំងប្រតិបដិវត្តន៍កម្ពុជាទាំងអស់ ទាំងនៅក្រៅប្រទេស ក៏ដូចជានៅក្នុងប្រទេស ដើម្បីធ្វើការប្រយុទ្ធប្រឆាំងរដ្ឋាភិបាលដ៏ត្រឹមត្រូវរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ព្រមទាំងដើម្បីគាំទ្រដល់កងកម្លាំងប្រតិបដិវត្តន៍កម្ពុជា នៅក្នុងប្រទេស និងក្រៅប្រទេស។

នៅខែធ្នូ ឆ្នាំ១៩៧៩ ពួកនេះបានសំដែងរឿងកំប្លែង “ ប្រោះព្រំ ” ឡើងវិញ នូវរបបរលំរបស់បនប៉ុល ពត ដោយខិតខំធ្វើឱ្យមាន “ ទិដ្ឋភាពជាទីគាប់ចិត្ត ” ជាពិសេស សម្រាប់មជ្ឈដ្ឋាននយោបាយនៅប្រទេសខាងលិច។ ជំនួសមុខបិសាចរបស់

ប៉ុល ពត, ខៀវ សំផន ត្រូវបានប្រកាសឱ្យធ្វើជារដ្ឋមន្ត្រីទីមួយរបស់ " កម្ពុជាប្រជាធិបតេយ្យ "។

បន្ទាប់ពីជ័យជម្នះ របស់កងកម្លាំងអ្នកស្នេហាមាតុភូមិបដិវត្តន៍នៅប្រទេសកម្ពុជា ពួកចក្រពត្តិអាមេរិក និងពួកអនុត្តរភាពបានចេញដើរតួស្របគ្នា ខំធ្វើនយោបាយឱ្យសាធារណរដ្ឋប្រជាមានិតកម្ពុជា ស្ថិតនៅឯកោនៅលើឆាកអន្តរជាតិ ក្នុងគោលបំណងរំខានដល់ការទទួលស្គាល់អន្តរជាតិ ដល់សាធារណរដ្ឋប្រជាមានិតកម្ពុជា។ នៅថ្ងៃទី១២ មករា ឆ្នាំ១៩៧៩ នៅក្រុមប្រឹក្សាសន្តិសុខ នៃអង្គការសហប្រជាជាតិ មាន " ការប្ដឹងផ្ដល់ " ពីមេកើយរបស់បនប្រល័យពូជសាសន៍ ដែលរលំនៅកម្ពុជា។ កាលនោះ គណៈប្រតិភូសូវៀត បានឡើងថ្លែងប្រឆាំងយ៉ាងម៉ឺងម៉ាត់ ហើយបានចោទប្រកាន់ដល់ការសាកល្បងមិនសមរម្យដើម្បីទាក់ទាញឱ្យអង្គការសហប្រជាជាតិ ធ្វើការវិនិច្ឆ័យអំពីកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជា។ ក៏ប៉ុន្តែ គេបានផ្ដល់វេទិកាឱ្យអ្នកតំណាងរបបដែលរលំនេះ ហើយគណៈប្រតិភូរបស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ដែលជាតំណាងត្រឹមត្រូវតាមច្បាប់តែមួយរបស់ប្រជាជនកម្ពុជា ទៅជាមិនបានទទួលការអនុញ្ញាតឱ្យចូលរួមក្នុងសម័យប្រជុំទៅវិញ។ នៅក្នុងលក្ខខណ្ឌបែបនេះ តាមពិតក្រុមប្រឹក្សាមុខជាមិនអាចមានលទ្ធភាព ធ្វើសេចក្ដីសម្រេចណាមួយបាន ដែលបញ្ជាក់ឱ្យឃើញភាពពិតសត្យានុម័តនៅប្រទេសកម្ពុជា។ ហេតុដូច្នេះហើយ បានជាសហភាពសូវៀត ដែលជាសមាជិកអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាសន្តិសុខ បានបោះឆ្នោតប្រឆាំងនឹងគម្រោងការ នៃសេចក្ដីសម្រេចចិត្តគ្រោងឡើងដោយគណៈប្រតិភូពីរបីប្រទេស។ ការបោះឆ្នោតប្រឆាំងបានរាំងរាប្រទេស

កម្ពុជា ឱ្យចៀសផុតពីអំពើជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជា ពីសំណាក់ចក្រពត្តិនិយម និងអនុត្តរភាពនិយម។

ទោះបីយ៉ាងនេះក្តី ក៏កម្លាំងសត្រូវនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា នៅតែបន្តសកម្មភាពរបស់ខ្លួននៅក្នុងក្របខ័ណ្ឌនៃអង្គការសហប្រជាជាតិ។ នៅខែមីនា ឆ្នាំ១៩៧៩ នៅអគ្គលេខាធិការដ្ឋាននៃអង្គការសហប្រជាជាតិ មានការទទួលសារតាំងពីតំណាងរបបប្រល័យពូជសាសន៍ប៉ុល ពត, អៀង សារី, ខៀវ សំផន។ ចំពោះរឿងនេះ រដ្ឋមន្ត្រីក្រសួងការបរទេស នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានផ្ញើសារលិខិតមួយច្បាប់ជូនដល់អគ្គលេខាធិការនៃអង្គការសហប្រជាជាតិ ដែលនៅក្នុងនេះមានសេចក្តីគូសបញ្ជាក់ថា អ្នកតំណាងដ៏ត្រឹមត្រូវស្របតាមច្បាប់តែមួយរបស់ប្រជាជនកម្ពុជា គឺក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ដែលត្រួតត្រាលើទឹកដីប្រទេសកម្ពុជា ទាំងមូល។ ហេតុដូច្នេះ ការរក្សាតំណាងរបបប្រល័យពូជសាសន៍ នៅអង្គការសហប្រជាជាតិ មានលក្ខណៈផ្ទុយនឹងស្ថានភាពពិតនៅក្នុងប្រទេស ហើយជាសកម្មភាពជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេស និងជាការរំលោភលើធម្មនុញ្ញនៃអង្គការសហប្រជាជាតិ។

ក្នុងសេចក្តីបន្ថែម ដល់វគ្គនៃកម្មវិធីនយោបាយក្រៅប្រទេសរបស់កម្មវិធីរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា និងដល់គោលការណ៍នយោបាយ របស់ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍ ក្រសួងការបរទេសនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើសេចក្តីថ្លែងការណ៍នាថ្ងៃទី១៨ មករា ឆ្នាំ១៩៧៩ ដែលក្នុងនេះមានសេចក្តីបញ្ជាក់ថា សាធារណរដ្ឋប្រជាមានិតកម្ពុជា អនុវត្តមាគ៌ានយោបាយសន្តិភាព ឯករាជភាព ប្រជាធិបតេយ្យ អព្យាក្រឹតភាព

មិនចូលបក្សសម្ពន្ធ ហើយធ្វើដំណើរតាមមាគ៌ាទៅកាន់សង្គមនិយម។ សាធារណរដ្ឋប្រជាមានិតកម្ពុជា បានប្រុងប្រៀបខ្លួនរៀបចំការទាក់ទងជាមិត្តភាពជាមួយប្រទេសទាំងអស់ មានជាអាទិ ជាមួយប្រទេសជិតខាងនៅអាស៊ីអាគ្នេយ៍ ដោយយោងទៅលើគោលការណ៍នៃការគោរពឯករាជភាព អធិបតេយ្យភាពបូរណភាពទឹកដីនៃប្រទេស ការមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងទៅវិញទៅមកនៃភាពស្មើគ្នា និងចំណេញទៅវិញទៅមក។

ក្នុងការពុំព្រមទទួលស្គាល់ សាធារណរដ្ឋប្រជាមានិតកម្ពុជា សត្រូវនៃប្រទេសកម្ពុជា តែងបានប្រើលេសលើហេតុថា នៅលើទឹកដីកម្ពុជា មានកងទ័ពវៀតណាម។ ចំពោះរឿងនេះ ក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា បានធ្វើសេចក្ដីបញ្ជាក់ជាពិសេសថា តាមសំណូមពររបស់រណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា កងទ័ពប្រជាជនវៀតណាម បានផ្តល់ជំនួយដល់កងកម្លាំងប្រដាប់អាវុធប្រទេសកម្ពុជា ក្នុងការរំលំរបបប្រឆាំងប្រជាជន ហើយក៏ស្ថិតនៅលើទឹកដីកម្ពុជា ស្របតាមសន្ធិសញ្ញាស្ដីអំពីសន្តិភាព មិត្តភាព និងសហប្រតិបត្តិការរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម។ សេចក្តីថ្លែងការណ៍នៃក្រសួងការបរទេស របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា បានបញ្ជាក់តទៅទៀតថា នៅពេលណាកងកម្លាំងសំណល់របស់បនប៉ុល ពត និងកងកម្លាំងពួកប្រតិកិរិយាចក្រពត្តិនិយមដទៃឈប់បំពារបំពានលើជីវភាពសុខសាន្តរបស់ប្រជាជនកម្ពុជា ភ្លាមនោះអង្គភាពនៃកងទ័ពវៀតណាមនឹងត្រឡប់ទៅប្រទេសវៀតណាមវិញ។

នៅខែកញ្ញា ឆ្នាំ១៩៧៩ នៅក្នុងក្របខ័ណ្ឌនៃអង្គការសហប្រជាជាតិ មានការប្រកាន់អំពីជាអមិត្តភាពចំពោះសាធារណរដ្ឋ

ប្រជាមានិតកម្ពុជា។ តាមសេចក្តីស្នើរបស់ប្រទេសនានានៃអង្គការអាស៊ាន នៅក្នុងរបៀបវារៈប្រចាំថ្ងៃនៃមហាសន្និបាតលើកទី២៦ នៃអង្គការសហប្រជាជាតិ មានចុះ “ បញ្ហាស្តីអំពីស្ថានភាពនៅប្រទេសកម្ពុជា ”។ សម័យនៃការពិភាក្សាបានបញ្ជាក់ឱ្យដឹងថា បញ្ហានេះត្រូវបានចោទឡើង មិនមែនដើម្បីវិនិច្ឆ័យអំពីលទ្ធភាពនៃការផ្តល់ការគាំទ្រដល់ប្រជាជនកម្ពុជា ទេ ប៉ុន្តែ ដើម្បីបម្រើគោលដៅផ្សេងទៀត គឺទាក់ទាញសមាជិកចូលរួមក្នុងមហាសន្និបាតឱ្យធ្វើការពិភាក្សាអំពី “ ស្ថានតំណាង ” ប្រទេសកម្ពុជានៅអង្គការសហប្រជាតិ ដោយមិនព្រមទទួលស្គាល់អ្នកតំណាងត្រឹមត្រូវតាមច្បាប់របស់ប្រជាជនកម្ពុជា។ ពួកខ្មាំងនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានប៉ុនប៉ងសងសឹកដល់សេចក្តីសម្រេចរបស់សន្និសីទទី៦ នៃប្រមុខរដ្ឋ និងរដ្ឋាភិបាលបណ្តាប្រទេសមិនចូលបក្សសម្ពន្ធ នៅទីក្រុងឡាហាវ៉ាន នាឆ្នាំ១៩៧៩ ដែលមិនព្រមទទួលអ្នកតំណាងរបបប្រល័យពូជសាសន៍ប៉ុល ពត, អៀង សារី, ខៀវ សំផន ដែលបានប៉ុនប៉ងធ្វើជាតំណាងប្រទេសកម្ពុជា នៅក្នុងចលនាមិនចូលបក្សសម្ពន្ធ។

អ្នកតំណាងនៅក្នុងសម័យមហាសន្និបាតទី៣៤ នៃអង្គការសហប្រជាជាតិ របស់ប្រទេសនានា នៃសហគមន៍សង្គមនិយម និងរបស់ប្រទេសនានានៅទ្វីបអាហ្វ្រិក នៅទ្វីបអាស៊ី នៅមជ្ឈិមបូព៌ាអារ៉ាប់ បានឡើងថ្លែងផ្តន្ទាទោសជាបន្តបន្ទាប់គ្នា ដល់អំពើឧក្រិដ្ឋដ៏ឃោរឃៅរបស់បនប្រល័យពូជសាសន៍ប៉ុល ពត ហើយបានពន្យល់ឱ្យយល់ច្បាស់ នូវភាពមិនសមហេតុផលក្នុង “ យោបល់អំពីអាណត្តិ ” របស់របបដែលគ្មាននៅក្នុងប្រទេស។ ក៏ប៉ុន្តែបច្ចាមិត្តរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើឱ្យមាន

ការរក្សាអាសនៈប្រទេសកម្ពុជា នៅអង្គការសហប្រជាជាតិ ដោយអ្នកតំណាងរបស់បនប្រល័យពូជសាសន៍ប៉ុល ពត។ នៅសម័យប្រជុំមហាសន្និបាត ពី៣៥ ដល់៣៦ នៃអង្គការសហប្រជាតិ អានុភាពចក្រពត្តិនិយម និងប្រតិកិរិយា ដែលបានធ្វើការឃោសនាមូលបង្កាច់ស្ថានភាពពិតសត្យានុម័តនៅប្រទេសកម្ពុជា បានធ្វើឱ្យអង្គការនេះព្រមបន្តអាណត្តិអ្នកតំណាងបនប៉ុល ពត តទៅទៀត។

នៅខែកក្កដា ឆ្នាំ១៩៨១ នៅទីក្រុងញូវយ៉ក ពួកតំណាងអានុភាពជាខ្មាំងនឹងសាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើឱ្យគេកោះហៅប្រជុំរបស់ដែលហៅថា " សន្និសីទអន្តរជាតិស្តីអំពីប្រទេសកម្ពុជា "។ បណ្តាប្រទេសនៃសហគមន៍សង្គមនិយមប្រទេសនានានៅឥណ្ឌូចិន ព្រមទាំងប្រទេសមិនចូលបក្សសម្ពន្ធមួយចំនួនធំ មិនព្រមចូលរួមក្នុង " សន្និសីទ " ដោយយល់ថា នេះគឺជាមធ្យោបាយសាកល្បងជ្រៀតជ្រែកដ៏គ្រោតគ្រាតចូលកិច្ចការផ្ទៃក្នុងរបស់ប្រទេសឯករាជ្យមួយ ក្រោមរបាំងនៃអង្គការសហប្រជាជាតិ។ កិច្ចការរបស់ " សន្និសីទ " បានបង្ហាញឱ្យឃើញថា៖ បណ្តាអ្នកផ្តើមគំនិត គ្មានបំណងអ្វីដើម្បីសម្រួលស្ថានភាពនៅជុំវិញប្រទេសកម្ពុជា ទេ តែផ្ទុយទៅវិញ ពួកទាំងនេះមានគោលដៅដើម្បីទទួលការធានា " ខាងផ្លូវច្បាប់ " សម្រាប់ការរំលំរដ្ឋអំណាចប្រជាជននៅប្រទេសកម្ពុជា។ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើសេចក្តីថ្លែងការណ៍បញ្ជាក់ថា ការកោះហៅសន្និសីទដោយគ្មានសេចក្តីយល់ព្រមពីសំណាក់ នៃរដ្ឋាភិបាលត្រឹមត្រូវតាមច្បាប់ ជ្រើសរើសដោយប្រជាជន គឺជាសកម្មភាពជ្រៀតជ្រែកដ៏គ្រោតគ្រាត ពុំអនុញ្ញាតបានមកក្នុងកិច្ចការផ្ទៃក្នុងរបស់ប្រទេសកម្ពុជា គឺជាការរំលោភលើគោលការណ៍នៃធម្មនុញ្ញ

សហប្រជាជាតិ និងលើច្បាប់អន្តរជាតិ។ ហេតុដូច្នេះ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ចាត់ទុកថា សេចក្ដីសម្រេចទាំងអស់របស់សន្និសីទនេះ មិនត្រឹមត្រូវតាមច្បាប់ ហើយគ្មានប្រសិទ្ធិភាពអ្វីឡើយ។

ក្នុងគោលបំណងទាក់ទាញអារម្មណ៍ ប្រជាជនកម្ពុជា និង " ការដោះស្រាយនយោបាយ " ស្អីគេនោះ កម្លាំងប្រតិកិរិយាអន្តរជាតិ បានខិតខំសាកល្បងបង្កើតរបស់ដែលហៅថា " រដ្ឋាភិបាលចម្រុះត្រីភាគី " ដែលមានការចូលរួមពីអ្នកតំណាងពួកប្រតិបដិវត្តន៍កម្ពុជា បីក្រុម ដែលរស់នៅកៀសខ្លួន ហើយដឹកនាំដោយ ខៀវ សំផន សីហនុ និងសឺន សាន ដែលជាអតីតរដ្ឋមន្ត្រីទី១កម្ពុជា។ មានការជួបគ្នារវាងពួកអ្នកដឹកនាំទាំងបីរូបនេះនៅទីក្រុងសិង្ហបុរី ម្តង នៅទីក្រុងប៉េកាំង ម្តង។ គោលដៅធំរបស់ពួកអ្នកផ្តើមគំនិតប្រឌិតរបស់ដែលហៅថា " រដ្ឋាភិបាលចម្រុះត្រីភាគី " គឺធ្វើឱ្យមតិសាធារណៈពិភពលោកមានអារម្មណ៍ជាប់ចំពោះការដោះស្រាយមិនដាច់ស្រឡះអំពី " បញ្ហាកម្ពុជា " ព្រមទាំងបង្កើតបដិបក្ខភាព រវាងរដ្ឋាភិបាលត្រឹមត្រូវតាមច្បាប់ ជ្រើសរើសដោយប្រជាជននៃសាធារណរដ្ឋប្រជាមានិតកម្ពុជា និងពួកបរិវារ។

នៅលើទឹកដីប្រទេសថៃឡង់ដ៍ មានជម្រកសម្រាប់ទទួលពួកសំណល់បនបាក់ទ័ពប៉ុល ពត ដែលតែងចេញទៅប្រព្រឹត្តភេរវកម្មលួចប្លន់ នៅតាមព្រំប្រទល់នានានៃប្រទេសកម្ពុជា។ នៅតាមមូលដ្ឋាននានា កសាងឡើងតាមព្រំប្រទល់ថៃឡង់ដ៍-កម្ពុជា " មានទីប្រឹក្សាបរទេសរាប់រយនាក់ ដែលបង្ហាត់បង្រៀនចម្បាំងចិត្តសាស្ត្រ " និងចម្បាំងលបធ្មក់ដល់ពួកឧទ្ទាមប៉ុល ពត

ទាំងនេះ ដែលត្រូវបានបញ្ចូលមកយ៉ាងជ្រៅក្នុងទឹកដីប្រទេស កម្ពុជា។ ពីថ្ងៃទី២២ - ២៣ កក្កដា ឆ្នាំ១៩៨០ នៅតាមព្រំប្រទល់ ថៃឡង់ - កម្ពុជា មានការបង្កបង្កើតហេតុខាងយោធា ដែលពួកវា បានប្រើមធ្យោបាយដែលហៅថា "មាតុភូមិនិវត្តន៍" ដោយស្ម័គ្រ ចិត្តនូវជនភៀសខ្លួន ដែលនៅពេលនោះ ពួកប៉ុល ពត មួយ ចំនួនធំ ក្រោមកិច្ចការពាររបស់កងទាហានថៃឡង់ បានសាក ល្បងលុកចូលមកលើទឹកដី នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ដោយសារការបង្កបង្កើត ពីសំណាក់ពួកប្រតិកិរិយាអន្តរជាតិ ព្រំ ប្រទល់ថៃឡង់ - កម្ពុជា បានប្រែទៅជាទីសមរភូមិចម្បាំងមិន ចេញមុខ ប្រឆាំងសាធារណរដ្ឋប្រជាមានិតកម្ពុជា។

ក្នុងការតស៊ូប្រឆាំងនឹងការបង្កបង្កើតហេតុ របស់អានុភាព ចក្រពត្តិនិយម និងអនុត្តរភាពនិយម សាធារណរដ្ឋប្រជាមានិត កម្ពុជា អនុវត្តយ៉ាងម៉ឺងម៉ាត់ក្នុងនយោបាយក្រៅប្រទេសរបស់ ខ្លួននូវមាគ៌ាសន្តិភាព សហប្រតិបត្តិការអន្តរជាតិ ការរស់នៅជា អ្នកជិតខាងនឹងគ្នា សាមគ្គីភាពជាមួយប្រជាជនទាំងអស់ ដែល ស្រឡាញ់សន្តិភាព និងសេរីភាព។ នៅក្នុងរដ្ឋធម្មនុញ្ញនៃ សាធារណរដ្ឋប្រជាមានិតកម្ពុជា មានសេចក្តីបញ្ជាក់ថា នៅលើ ឆាកអន្តរជាតិ "ប្រទេសកម្ពុជា ប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវនយោបាយ ឯករាជភាព សន្តិភាព និងការមិនចូលបក្សសម្ពន្ធ"។ សាធារណរដ្ឋ ប្រជាមានិតកម្ពុជា ប្រកាន់នយោបាយសន្តិសហវិជ្ជាមានជាមួយ ប្រទេសទាំងអស់ ដែលមានសភាពខុសគ្នាខាងនយោបាយ និង របបគ្រប់គ្រងខាងសង្គម នៅលើមូលដ្ឋាននៃការគោរពឯករាជភាព អធិបតេយ្យភាព បូរណភាពទឹកដី និងការមិនជ្រៀតជ្រែកចូល កិច្ចការផ្ទៃក្នុងទៅវិញទៅមក សមភាព និងការគោរពគ្នាទៅវិញ

ទៅមក ដើម្បីផលប្រយោជន៍សន្តិភាព ស្ថិរភាព និងសន្តិសុខ នៅអាស៊ីអាគ្នេយ៍ និងលើពិភពលោកទាំងមូល។

ការអនុវត្តឥតល្អៀងនូវនយោបាយសន្តិភាព និងសហប្រតិបត្តិការអន្តរជាតិ ដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា បានទទួលការគាំទ្រដ៏ទូលំទូលាយ ពីសំណាក់នៃមតិមហាជនពិភពលោក ហើយកិត្យានុភាពអន្តរជាតិរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា កាន់តែកើនឡើងជាលំដាប់។ នៅចុងឆ្នាំ១៩៨៤ ប្រទេស និងចលនារំដោះជាតិចំនួន៤០ បានទទួលស្គាល់សាធារណរដ្ឋប្រជាមានិតកម្ពុជា ជាផ្លូវការ។

ភារកិច្ចចំបងនៅក្នុងនយោបាយ ក្រៅប្រទេសរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ស្ថិតនៅលើការពង្រឹងទំនាក់ទំនងដ៏ស្និទ្ធស្នាល ពិសេសរវាងប្រទេសបងប្អូនទាំងបីនៅឥណ្ឌូចិន គឺវៀតណាម ឡាវ និងកម្ពុជា។ ភាពចាំបាច់នៅក្នុងទំនាក់ទំនងនេះ កើតមានឡើងដោយសារការគំរាមកំហែងបច្ចុប្បន្ន នៃនយោបាយអនុត្តរភាពនិយម ចក្រពត្តិនិយម លើឥណ្ឌូចិនទាំងមូល និងដោយសារផលប្រយោជន៍នៃការកសាងខាងសេដ្ឋកិច្ច និងសង្គមកិច្ចនៅក្នុងសាធារណរដ្ឋទាំងបី។

អត្ថន័យដ៏សំខាន់ សម្រាប់ការពង្រីកទំនាក់ទំនងនៃសាមគ្គីភាពជាបងប្អូន និងសហប្រតិបត្តិការដ៏ស្និទ្ធស្នាលរវាងប្រទេសកម្ពុជា និងប្រទេសវៀតណាម ស្ថិតនៅក្នុងទស្សនកិច្ចដ៏ស្និទ្ធស្នាលជាផ្លូវការ របស់គណៈប្រតិភូរដ្ឋាភិបាលវៀតណាម ដឹកនាំដោយសមមិត្ត ផាម វ៉ាន់ដុង ជារដ្ឋមន្ត្រីទី១ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម នៅសាធារណរដ្ឋប្រជាមានិតកម្ពុជា នាខែកុម្ភៈ ឆ្នាំ១៩៧៩។ តុល្យការដ៏សំខាន់នៃទស្សនកិច្ចនេះ គឺ

ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីអំពីសន្តិភាព មិត្តភាព និងសហប្រតិបត្តិការរវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា និង សាធារណរដ្ឋសង្គមនិយមវៀតណាម។ គឺជាកិច្ចព្រមព្រៀងដែល បានបើកដំណាក់កាលមួយថ្មី នៅក្នុងការពង្រីកទំនាក់ទំនង រវាងប្រជាជនជិតខាងទាំងពីរ។

នៅក្នុងកិច្ចព្រមព្រៀងដែលបានធ្វើឡើង សម្រាប់រយៈ ពេល២៥ឆ្នាំ ភាគីទាំងសងខាងបានព្រមព្រៀងគ្នា “ ធ្វើការប្រឹង ប្រែងគ្រប់បែបយ៉ាងសម្រាប់ការពង្រីក និងកិច្ចការពារយុទ្ធសាមគ្គី ភាពជាប្រពៃណី មិត្តភាព និងសហប្រតិបត្តិការរវាងកម្ពុជា និង វៀតណាម ”។ ប្រទេសជាបងប្អូនទាំងពីរបានបញ្ជាក់នូវការប្រុង ប្រៀបរបស់ខ្លួន ដើម្បីកសាងទំនាក់ទំនងរបស់ខ្លួននៅលើ គោលការណ៍នៃការគោរពឯករាជភាព អធិបតេយ្យភាព ការមិន ជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងនៃប្រទេសនីមួយៗ ការគោរព សមភាព និងផលប្រយោជន៍ទៅវិញទៅមក ដើម្បីផ្តល់ជំនួយ គ្រប់បែបយ៉ាងទៅវិញទៅមកសម្រាប់ការពង្រឹង និងកិច្ចការពារ ឯករាជភាព អធិបតេយ្យភាព បូរណភាពទឹកដី និងការងារដើ សុខសាន្តរបស់ប្រជាជននៃប្រទេសនីមួយៗ ប្រឆាំងនឹងអំពើរ វិទ្ធង្សនានានារបស់អានុភាពចក្រពត្តិនិយម និងប្រតិកិរិយាអន្តរ ជាតិ។

ទស្សនកិច្ចដ៏ស្និទ្ធស្នាល ជាផ្លូវការរបស់គណៈប្រតិភូ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវដឹកនាំដោយសមមិត្ត សុផាន់នុវង្ស ជាប្រធានាធិបតីនៃសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ ដែលបានប្រព្រឹត្តទៅនាខែមីនា ឆ្នាំ១៩៧៩ ក៏ បានទទួលជោគជ័យដ៏ធំដូចគ្នា។ នៅឱកាសនៃទស្សនកិច្ចនេះ

មានពិធីចុះហត្ថលេខា លើកិច្ចព្រមព្រៀង ស្តីអំពីសហប្រតិបត្តិការកម្ពុជា - ឡាវ គ្រប់បែបយ៉ាង។ នៅក្នុងសេចក្តីថ្លែងការណ៍រួមភាគីទាំងពីរបានគូសបញ្ជាក់ថា “ សាមគ្គីរវាងប្រជាជនកម្ពុជា ឡាវ វៀតណាម ដែលកំពុងលូតលាស់លើគោលការណ៍នៃលទ្ធិម៉ាក្ស-ឡេនីននិយម នៃលទ្ធិអន្តរជាតិនិយមរបស់វណ្ណៈប្រជាពលករអធន នៃការគោរពឯករាជភាព អធិបតេយ្យភាពទៅវិញទៅមក គឺជាកត្តាមួយដ៏សំខាន់បំផុត ដែលធានារ៉ាប់រងដល់ជ័យជម្នះរបស់បដិវត្តន៍នៅក្នុងប្រទេសនីមួយៗ ” ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា បានប្រកាសមាគ៌ានៃស្ថាបនកម្មមូលដ្ឋានសង្គមនិយម ហើយកំពុងពង្រីកទំនាក់ទំនងមិត្តភាពជាបងប្អូន និងសហប្រតិបត្តិការគ្រប់បែបយ៉ាងជាមួយប្រទេសនានា នៃសហគមន៍សង្គមនិយម។ នៅឆ្នាំ ១៩៧៩ និង១៩៨០ គណៈប្រតិភូជាន់ខ្ពស់របស់សាធារណរដ្ឋប្រជាមានិតកម្ពុជា បានបំពេញទស្សនកិច្ចជាមិត្តភាពជាផ្លូវការនៅសហភាពសូវៀត វៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ សាធារណរដ្ឋគុយបា សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ សាធារណរដ្ឋសង្គមនិយមឆេកូស្លូវ៉ាគី សាធារណរដ្ឋប្រជាមានិតហុងគ្រី សាធារណរដ្ឋប្រជាមានិតប៊ុលហ្គារី។ ប្រតិភូទាំងឡាយរបស់ប្រទេសកម្ពុជាថ្មី បានឃើញប្រចក្សនូវសាមគ្គីភាពដ៏ជ្រាលជ្រៅនៃប្រទេសសង្គមនិយមនានា ជាមួយការតស៊ូដ៏អង់អាចរបស់ប្រជាជនកម្ពុជា។ លទ្ធផលបានមកពីការចរចានានាដែលបានធ្វើឡើង គឺពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងនានាស្តីពីជំនួយដល់ប្រទេសកម្ពុជា និងសហប្រតិបត្តិការជាមួយប្រទេសកម្ពុជា នៅក្នុងវិស័យផ្សេងៗ។ ការពង្រឹង

សហប្រតិបត្តិការខាងនយោបាយ និងសេដ្ឋកិច្ចជាមួយប្រទេសនានានៃសហគមន៍សង្គមនិយម បានផ្តល់លទ្ធភាពដ៏ប្រសើរដល់ប្រទេសកម្ពុជា ក្នុងការដោះស្រាយភារកិច្ចនានាក្នុងវិស័យនៃការកសាងប្រទេស ក្នុងកិច្ចការស្តារស្ថានភាពសេដ្ឋកិច្ចប្រជាជន ក្នុងការដោះស្រាយភារកិច្ចដ៏ស្មុគស្មាញនានា ដែលបានចោទឡើងចំពោះយុវសាធារណរដ្ឋប្រជាមានិត។

ទំនាក់ទំនងនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាមួយបណ្តាប្រទេសកំពុងលូតលាស់ ក៏បានទទួលលទ្ធផលដ៏ប្រសើរ។ នៅឆ្នាំ១៩៨០ - ១៩៨១ គណៈប្រតិភូរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យយ៉េមេន ប្រទេសនីការាហ្គ័យា ប្រទេសអង់ហ្គោឡា ប្រទេសកុងហ្គោ ប្រទេសស៊ីរី ប្រទេសឥណ្ឌា និងប្រទេសដទៃទៀត។

នៅថ្ងៃទី២០ ឧសភា ឆ្នាំ១៩៨០ នៅទីក្រុងភ្នំពេញ តាមសេចក្តីផ្តើមគំនិតរបស់ក្រុមប្រឹក្សាទូទាំងពិភពលោក នៃសន្តិភាព មានការបើកសម័យប្រជុំសន្និសីទអន្តរជាតិមួយ ស្តីអំពីសាមគ្គីភាពជាមួយប្រជាជនកម្ពុជា ដែលនៅក្នុងពេលនោះ មានការចូលរួមពីសំណាក់គណៈប្រតិភូចំនួន៥០ មកពីប្រទេសផ្សេងៗនៃពិភពលោក។ សមាជិកចូលរួមក្នុងសម័យប្រជុំដ៏ឱឡារិកនេះ បានធ្វើការអនុម័តលើសេចក្តីប្រកាសស្តីអំពីសាមគ្គីភាពជាមួយប្រជាជនប្រទេសកម្ពុជា។

សាធារណរដ្ឋប្រជាមានិតកម្ពុជា យកចិត្តទុកដាក់ដល់បញ្ហាសន្តិភាព និងដល់ការរៀបចំទំនាក់ទំនងដ៏ប្រសើរជាមួយបណ្តាប្រទេសជិតខាង ហើយបានធ្វើសេចក្តីថ្លែងការណ៍រួមគ្នា

ជាមួយសាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដោយមានសេចក្តីផ្តើមគំនិតដ៏សមហេតុផលនានា តម្រង់ទៅរកដំណោះស្រាយស្ថានភាពនៅអាស៊ីអាគ្នេយ៍ ដើម្បីប្រែត្រឡប់ភូមិភាគនេះឱ្យទៅជាតំបន់ប្រកបដោយសន្តិភាព និងស្ថិរភាព។ ចាប់ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៨២ សន្និសីទថ្នាក់រដ្ឋមន្ត្រីក្រសួងការបរទេស នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានប្រព្រឹត្តទៅចំនួនប្រាំដង ហើយលទ្ធផលនៃសន្និសីទទាំងនេះ ស្ថិតនៅលើសំណើថ្មីៗ ស្តីអំពីដំណោះស្រាយសន្តិភាព។ ជាពិសេស ប្រទេសកម្ពុជា ប្រទេសវៀតណាម ប្រទេសឡាវ បានស្នើឱ្យកោះហៅសន្និសីទតំបន់មួយរវាងប្រទេសឥណ្ឌូចិន និងប្រទេសអាស៊ាន។ នៅក្នុងដំណាក់កាលជាដំបូង គេអាចអនុវត្តការពិភាក្សាពហុភាគី ឬទ្វេភាគី ស្តីអំពីបញ្ហាមួយចំនួន ដែលប្រជាជនទាំងឡាយនៅតំបន់នេះទាមទារឱ្យមានការដោះស្រាយជាបន្ទាន់ គេអាចបង្កើតអង្គការអចិន្ត្រៃយ៍មួយ សម្រាប់ការចរចាពិភាក្សារវាងប្រទេសនានានៅឥណ្ឌូចិន និងរបស់អង្គការអាស៊ាន ហើយកិច្ចការទាំងនេះ នឹងអាចជំរុញឱ្យមានការរៀបចំ និងការពង្រីកទំនាក់ទំនងនៃសហវិជ្ជមានដ៏សុខសាន្ត រវាងប្រទេសទាំងអស់នៅក្នុងតំបន់នេះ។ ប្រទេសទាំងបីនៅក្នុងឥណ្ឌូចិន បានប្រុងប្រៀបខ្លួនចុះហត្ថលេខា លើកិច្ចព្រមព្រៀងទ្វេភាគីជាមួយប្រទេសចិន ស្តីអំពីការមិនឈ្លានពានទឹកដីគ្នាទៅវិញទៅមក។ ប្រទេសទាំងបីបានធ្វើសំណើដល់ប្រទេសថៃឡង់ ឱ្យធ្វើការចរចាផ្ទាល់ ឬប្រយោល ដើម្បីវិនិច្ឆ័យ និងដោះស្រាយគ្រប់បញ្ហាទាំងអស់

ដែលនៅក្នុងនេះ មានបញ្ហាព្រំប្រទល់ជាមួយប្រទេសកម្ពុជា ហើយការដោះស្រាយបញ្ហានេះ នឹងអាចផ្តល់ផលប្រយោជន៍ទៅវិញទៅមក។

ក៏ប៉ុន្តែ សេចក្តីផ្តើមគំនិតសន្តិភាពនានារបស់ប្រទេសកម្ពុជា វៀតណាម ឡាវ ពុំបានទទួលការតបឆ្លើយពីរដ្ឋាភិបាលនៃប្រទេសអង្គការអាស៊ាន និងប្រទេសចិន ឡើយ។ ផលវិបាកបែបនេះ បានបណ្តាលឱ្យសភាពការណ៍នៅតំបន់នេះកាន់តែតានតឹងឡើង។

ដំណាក់កាលថ្មី នៅក្នុងការពង្រីកទំនាក់ទំនងជាប្រពៃណីខាងមិត្តភាព និងសហប្រតិបត្តិការរវាងប្រជាជនសូវៀត និងប្រជាជនកម្ពុជា បានចាប់ផ្តើមមានជំហានទៅមុខ ជាមួយនឹងជ័យជម្នះនៃបដិវត្តន៍នៅប្រទេសកម្ពុជា។ សហភាពសូវៀតជាមួយនឹងកម្លាំងចម្រើននិយមទាំងអស់លើពិភពលោកតែងតែគាំទ្រដល់អ្នកស្នេហាមាតុភូមិកម្ពុជាទាំងឡាយ បានស្វាគមន៍ដ៏កក់ក្តៅដល់ជ័យជម្នះនៃបដិវត្តន៍ប្រជាជន នៅប្រទេសកម្ពុជា។ សហភាពសូវៀត ជាមហាប្រទេសទី១ ដែលបានទទួលស្គាល់ជាផ្លូវការនូវសាធារណរដ្ឋប្រជាមានិតកម្ពុជា។ នៅសហភាពសូវៀត ប្រជាជនបានយល់ថា ការវិត្តនៃបដិវត្តន៍នៅសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាជ័យជម្នះនៃកម្លាំងលទ្ធិសង្គមនិយម និងប្រជាធិបតេយ្យ។ នៅខែមេសា ឆ្នាំ១៩៧៩ បន្ទាប់ពីពេលអាក់ខានដ៏យូរ ស្ថានទូតសូវៀត បានចាប់ផ្តើមបំពេញសកម្មភាពរបស់ខ្លួនតទៅអនាគត។

ដោយយល់ច្បាស់នូវសេចក្តីលំបាកដ៏ធ្ងន់ធ្ងរ ខាងសេដ្ឋកិច្ចជួបប្រទះដោយសាធារណរដ្ឋប្រជាមានិតកម្ពុជា សហភាពសូវៀត

បានចាប់ផ្តើមផ្តល់ជំនួយខាងសម្ភារៈគ្រប់បែបយ៉ាង ដល់ប្រទេសកម្ពុជា។ នៅឆ្នាំ១៩៧៩ មានការចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយចំនួន ស្តីអំពីការផ្តល់ជំនួយឥតចំណងដោយសហភាពសូវៀតដល់សាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលមានជាអាទិ៍គឺ៖ ស្បៀងម្ហូបអាហារ ដឹកជញ្ជូន គ្រឿងឥន្ធនៈ ប្រេងកាត ក្រណាត់សំពត់ គ្រឿងឱសថ និងឥវ៉ាន់ផ្សេងៗ សម្រាប់ជាគ្រឿងឧបភោគប្រជាជន។

ទស្សនកិច្ចជាមិត្តភាពតាមផ្លូវការទីមួយ របស់គណៈប្រតិភូរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា នៅសហភាពសូវៀត នៅថ្ងៃទី៤ កុម្ភៈ ឆ្នាំ១៩៨០ ជាសក្ខីភាពដ៏ច្បាស់លាស់ ក្នុងការពង្រឹងមិត្តភាពសូវៀត - កម្ពុជា។ នៅឱកាសនៃកិច្ចពិភាក្សាសូវៀត - កម្ពុជា នានា មានការចុះហត្ថលេខាលើសន្ធិសញ្ញាដ៏សំខាន់ៗមួយចំនួន ដែលកំណត់ការចាប់ផ្តើមដំណាក់កាលថ្មី នៅក្នុងការពង្រីកចំណងជាមិត្តភាពរវាងសហភាពសូវៀត និងសាធារណរដ្ឋប្រជាមានិតកម្ពុជា។ លទ្ធផលជាគុល្យការ នៃការចរចានានាស្ថិតនៅលើការចុះហត្ថលេខាលើកិច្ចព្រមព្រៀងនានា ស្តីអំពីសហប្រតិបត្តិការខាងសេដ្ឋកិច្ច និងបច្ចេកទេស អំពីសហប្រតិបត្តិការខាងវប្បធម៌ និងវិទ្យាសាស្ត្រ អំពីកិច្ចព្រមព្រៀងខាងពាណិជ្ជកម្ម ព្រមទាំងកិច្ចព្រមព្រៀងដទៃទៀត នៅក្នុងវិស័យនៃទំនាក់ទំនងខាងពាណិជ្ជកម្ម-សេដ្ឋកិច្ច។

គ្រាន់តែនៅឆ្នាំ១៩៧៩ សហភាពសូវៀត បានផ្តល់ជំនួយឥតចំណងខាងសម្ភារៈ គិតជាប្រាក់ចំនួន ៨៥លានដុល្លារ។ សហភាពសូវៀត បានផ្តល់ដល់សាធារណរដ្ឋប្រជាមានិតកម្ពុជា នូវស្បៀងចំនួន ១៥៩ពាន់តោន គ្រឿងឥន្ធនៈប្រេងកាតចំនួន

៥០ពាន់តោន ក្រណាត់សំពត់ចំនួន ៤,៦លានម៉ែត្រ រថយន្តចំនួន ៦៦០គ្រឿង និងឥវ៉ាន់ដទៃទៀតជាច្រើនមុខ។ នៅឆ្នាំ ១៩៨០ ជំនួយផ្តល់ដោយសហភាពសូវៀត ដល់ប្រទេសកម្ពុជា មានទំហំកាន់តែទូលំទូលាយ ដែលនៅក្នុងនេះ មានទាំងគ្រឿងបរិភោគចំនួន ១៦៤ពាន់តោនផង។ តាមអត្ថន័យនៃសេចក្តីថ្លែងការណ៍របស់អ្នកដឹកនាំនានា នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ជំនួយសូវៀត ខាងគ្រឿងបរិភោគនាឆ្នាំ១៩៧៩ - ១៩៨០ បានបំពេញតួនាទីដ៏សំខាន់ ក្នុងការសង្គ្រោះប្រជាជនកម្ពុជា ឱ្យចៀសផុតពីគ្រោះអត់ឃ្លាន។

នៅសម័យបច្ចុប្បន្ន ដោយឆ្លើយតបតាមសូមណូមពរ នៃភាគីកម្ពុជា និងស្របតាមអត្ថន័យនៃកិច្ចព្រមព្រៀង សហភាពសូវៀត កំពុងជួយឧបត្ថម្ភដល់សាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងសហការខាងសេដ្ឋកិច្ច និងបច្ចេកទេស មានការកសាងឡើងវិញ និងការស្ដាបនាមន្ទីរពេទ្យនានា គ្រឹះស្ថានសិក្សានានា រោងចក្រឧស្សាហកម្ម និងទីតាំងខាងកសិកម្មនានា មធ្យោបាយដឹកជញ្ជូន និងគមនាគមន៍ សហភាពសូវៀត នៅតែបន្តផ្តល់គ្រឿងបរិភោគ គ្រឿងឥន្ធនៈប្រេងកាត មធ្យោបាយជញ្ជូន និងឥវ៉ាន់មួយចំនួនធំសម្រាប់ជាគ្រឿងឧបភោគប្រជាជន។

នៅខែមករា ឆ្នាំ១៩៨២ អ្នកដឹកនាំថ្នាក់កំពូលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានថ្លែងបញ្ជាក់ថា ៖ “ បក្សប្រជាជនបដិវត្តន៍ រដ្ឋាភិបាល និងប្រជាជនកម្ពុជា សូមឱ្យតម្លៃដ៏ខ្ពង់ខ្ពស់ដល់ជំនួយសប្បុរសដ៏សក្តិសិទ្ធិទាន់ពេលវេលា និងដល់ការគាំទ្រពីសំណាក់នៃមហាប្រជាជនសូវៀត ជាបងប្អូន ដែលបានផ្តល់លទ្ធភាពដ៏ពិសិដ្ឋក្នុងកិច្ចការអនុវត្ត និងការកសាងវិស័យសេដ្ឋកិច្ច

និងសង្គមកិច្ច ព្រមទាំងក្នុងការពង្រឹងកិច្ចការពារជាតិនៃប្រទេស។ ប្រជាជនកម្ពុជា សូមរក្សាជានិរន្តន៍នូវកតញ្ញូតាដ៏ស្មោះត្រង់ចំពោះជំនួយ និងការគាំទ្រដ៏បវរនេះ ” ។

នៅខែវិច្ឆិកា ឆ្នាំ១៩៨៤ គណៈប្រតិភូនៃក្រុមប្រឹក្សាជាន់ខ្ពស់ ស.ស.ស.ស. បានអញ្ជើញទៅធ្វើទស្សនកិច្ចជាផ្លូវការនៅសាធារណរដ្ឋប្រជាមានិតកម្ពុជា។ នៅក្នុងឱកាសនៃទស្សនកិច្ចនេះ មានធ្វើការចរចានានា ជាមួយឥស្សរជនថ្នាក់កំពូលបក្សប្រជាជនបដិវត្តន៍កម្ពុជា និងរដ្ឋសភា នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ការចរចាទាំងនេះបានប្រព្រឹត្តទៅក្នុងបរិយាកាសប្រកប ដោយភាតរភាពដ៏ស្និទ្ធស្នាល និងដោយទស្សនៈនយោបាយស្រប គ្នាទាំងអស់។ ការចរចាទាំងនេះ បានទៅជាសក្ខីភាពដ៏ប្រចក្សបញ្ជាក់នូវមិត្តភាព ជាបងប្អូនរវាងប្រជាជនសហភាពសូវៀត និងប្រជាជនកម្ពុជា។ ប្រធានគណៈប្រតិភូសូវៀត បានគូសបញ្ជាក់ថា រដ្ឋាភិបាលសូវៀត គាំទ្រ និងគាំទ្រតទៅអនាគតនូវការតស៊ូរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ដើម្បីវឌ្ឍនកម្មខាងសង្គមកិច្ច ដើម្បីកិច្ចការពារអធិបតេយ្យភាពជាតិ ដើម្បីសន្តិភាព និងសន្តិសុខនៅអាស៊ីអាគ្នេយ៍។

# យោបល់រួម

ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ប្រកបដោយព្រឹត្តិការណ៍ពោរពេញដោយនាដភាពដ៏ទារុណ។ គឺមានសម័យកាលប្រកបដោយការរីកចម្រើនដ៏គគ្រឹកគគ្រេង ដែលនៅពេលនោះ កម្លាំងផលិតភាព និងវប្បធម៌របស់ប្រទេសបានឡើងដល់កម្រិតខ្ពង់ខ្ពស់ ហើយដែលមនុស្សយើងក្នុងបច្ចុប្បន្នកាលទទួលស្ញប់ស្ញែង ហើយពិបាកទាំងគិតយល់ដល់ការរីកចម្រើនទាំងនេះទៀតផង។ ក៏ប៉ុន្តែ មានសម័យកាលនៃស្ថានភាពចុះដុនដាប គឺជាពេលដែលប្រជាជនខ្មែរបានទទួលអំពើជិះជាន់ មិនគ្រាន់តែពីសំណាក់របស់ពួកអ្នកជិះជាន់កៀបសង្កត់នៅក្នុងប្រទេសប៉ុណ្ណោះទេ ក៏ប៉ុន្តែ ពីសំណាក់របស់ពួកអាណានិគមនិយម និងចក្រពត្តិនិយមឯនាយសមុទ្រទៀតផង។ ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា មានដំណើរការឆ្លងតាមសម័យកាល នៃការបង្កើតចក្រភពមួយដ៏រុងរឿងធំធេង ហៅថា ចក្រភពកម្ពុជទេស រហូតមកដល់សម័យកាល នៃអាណាព្យាបាលបារាំង បានឆ្លងពីសម័យកាលនៃស្ថាបនកម្មមហាបុរាណប្រាសាទអង្គរ ដ៏ឧត្តុងឧត្តម រហូតដល់សម័យកាលនៃវិនាសកម្មដោយការបំផ្លាញសារមន្ទីរ បណ្ណាល័យ រោងល្ខោន និងសាលារៀនទាំងឡាយ។ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា បានឆ្លងតាមសម័យកាលនៃរបបសក្តិភូមិដ៏ងងឹតសូន្យសុង មកដល់សម័យកាលនៃការស្ថាបនាជីវភាពប្រកបដោយដោយសេរីភាព បានឆ្លងពីសម័យកាលនៃរាជានិយម មកកាន់រដ្ឋអំណាចប្រជាជន ពីសម័យកាលនៃជំរំឃុំឃាំងរបស់បនប្រល័យពូជសាសន៍ប៉ុល ពត មកកាន់ឧត្តមគតិដ៏ភ្លឺស្វាងនៃសង្គមនិយម។ ទាំងអស់នេះ គឺជា

ព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែលកើតមានឡើងនៅតាមមាគ៌ាដ៏លំបាកលំបិនរបស់ប្រជាពលករខ្មែរដ៏អង់អាច និងព្យាយាម ។ ក៏ប៉ុន្តែ នៅគ្រប់សម័យកាលទាំងអស់លក្ខណៈពិសេស ដែលគេតែងសង្កេតឃើញមក គឺសេចក្ដីប្រាថ្នារបស់ប្រជាជនខ្មែរ ដើម្បីសេរីភាព ឯករាជភាព និងវឌ្ឍនភាពខាងសង្គម។ គឺដើម្បីសម្រេចសេចក្ដីប្រាថ្នាទាំងនេះហើយ ដែលអ្នកស្នេហាជាតិកម្ពុជាពិតប្រាកដទាំងអស់គ្នា កំពុងតែបន្តការតស៊ូរបស់ខ្លួនជានិច្ចកាល ទោះនៅក្នុងសម័យបច្ចុប្បន្នក្ដី នៅក្រោមការដឹកនាំដ៏ភ្លឺស្វាងរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា ។

ឥទ្ធិពលដ៏មហិមា នៅក្នុងសន្ទុះរីកចម្រើននៃការតស៊ូនេះ បានមកដោយជ័យជម្នះនៃមហាបដិវត្តន៍សង្គមនិយម ខែតុលា នៅប្រទេសរុស្ស៊ី និងការស្ថាបនារដ្ឋទី១របស់វណ្ណៈកម្មករ និងកសិករលើពិភពលោក គឺសហភាពសូវៀត ។ គេទាំងឡាយបានបំផុសបណ្ដាប្រជាពលករ និងប្រជាជនទទួលអំពើជិះជាន់នានា នៅចុងបូព៌ា ដែលនៅក្នុងនេះ មានទាំងប្រជាជនកម្ពុជា ឱ្យក្រោកឈរឡើងធ្វើការតស៊ូប្រឆាំងអំពើជិះជាន់ និងវិសមភាព ដើម្បីសម្រេចនូវសិទ្ធិដ៏ពិសិដ្ឋរបស់គេ ។

ព្រឹត្តិការណ៍ទាំងពីរនេះបានផ្ដល់សន្ទុះដ៏ខ្លាំងក្លា ដែលបានផុសផុលឡើងលើពិភពលោកទាំងមូល គឺជាសន្ទុះនៃមនោគមវិជ្ជាម៉ាក្ស - ឡេនីន ដែលបានទាំងរីកសាយទៅលើ “ តំបន់ដាច់ស្រយាល ” ដែលបានស្ថិតនៅក្រោមអាណានិគមនិយម ។ ក្នុងការសិក្សាប្រវត្តិសាស្ត្រប្រទេសកម្ពុជា គេបានឃើញច្បាស់ថា គឺមានតែយុទ្ធជនកុម្មុយនិស្តទេ ដែលបានត្រួសត្រាយមាគ៌ាដ៏ត្រឹមត្រូវតែមួយ ដើម្បីការរំដោះជាតិដល់ប្រជាជនខ្មែរ ។ ដំណាក់កាល

ដ៏សំខាន់មួយនៅក្នុងការតស៊ូនេះ គឺការបង្កើតបក្សកុម្មុយនិស្ត ឥណ្ឌូចិន នាឆ្នាំ១៩៣០។

នៅប្រទេសកម្ពុជា មនោគមវិជ្ជាម៉ាក្ស - ឡេនីន បានត្រួសត្រាយមាគ៌ា និងបានពង្រឹងស្ថានភាពខ្លួននៅក្នុងបដិបក្ខភាព មិនគ្រាន់តែជាមួយទ្រឹស្តីផ្សេងៗ ដែលបានបញ្ជាក់ឱ្យឃើញការចាំបាច់ក្នុងការរីកចម្រើននៅក្នុងប្រទេស ប្រកបដោយវិស័យមូលធននិយមប៉ុណ្ណោះទេ ក៏ប៉ុន្តែ ទ្រឹស្តីនេះបានទង្គិចនឹងលក្ខណៈពិសេសម្យ៉ាងនៃសង្គមនិយម " ជាតិ " និង" សាសនា " ដែលជាមនោគមវិជ្ជា "រាជសង្គមនិយមពុទ្ធសាសនា "។ ក្រោមពាក្យស្លោកថា " សង្គមនិយម " មនោគមវិជ្ជានេះ បានបំបិទបំបាំងនូវកម្មវិធីកែប្រែរបស់វណ្ណៈគហបតីតូចតាច ដែលមានគោលបំណងពង្រីកមូលដ្ឋាននិយមនៅប្រទេសកម្ពុជា តាមទិសដៅ ដែលហៅថា " ទិសដៅជាគំរូជាតិ "។

បនប៉ុល ពត ក៏បានថ្លែងប្រឆាំងនឹងលទ្ធិម៉ាក្ស - ឡេនីននិយមដែរ ដោយហេតុថា ក្រុមពួកនេះបានសាកល្បងអនុវត្ត " ការពិសោធខាងសង្គម " នៅលើទឹកដីខ្មែរ ដោយការបណ្តេញប្រជាជនពីទីក្រុងនានា ដោយការបញ្ឈប់មិនឱ្យប្រើប្រាស់ប្រាក់កាស ដោយការបញ្ឈប់ទំនាក់ទំនងខាងពាណិជ្ជកម្ម ដោយការបំបាត់កម្មសិទ្ធិផ្ទាល់ខ្លួន ដោយការហាមឃាត់មិនឱ្យមានទំនាក់ទំនងជាបងប្អូន ដោយការបង្ខំឱ្យប្រជាពលករទាំងអស់បំពេញពលកម្មឥតរើសប្រភេទ ដោយការបំបាត់បណ្តាបញ្ញវន្ត និងបុគ្គលទាំងអស់ណា ដែលបននេះមានសំអប់។ នៅទីបំផុតរបបប៉ុល ពត បានចាប់ផ្តើមអនុវត្តនយោបាយប្រល័យពូជសាសន៍ដល់ប្រជាជនកម្ពុជា។ សម័យកាលនៃរបបគ្រប់គ្រងប៉ុល ពត

បានទៅជា “ បាតុភូត ” ដ៏ងងឹតងងុលមួយមិនមែនសម្រាប់តែប្រទេសកម្ពុជា ទេ ប៉ុន្តែ សម្រាប់មនុស្សជាតិទាំងមូល ។ ហេតុដូច្នេះហើយ បានជាអ្នកស្នេហាមាតុភូមិពិតប្រាកដនៃប្រទេសកម្ពុជាទាំងអស់គ្នា បានតស៊ូប្រឆាំងនឹងគំនិតសំអប់មនុស្សជាតិបែបនេះរបស់ប៉ុល ពត ។

ការតស៊ូរបស់ប្រជាជននៃប្រជាជនកម្ពុជា ដើម្បីសេរីភាព ឯករាជភាព និងវឌ្ឍនភាពខាងសង្គម គឺជាភាគមួយនៅក្នុងទំនាក់ទំនងអចិន្ត្រៃយ៍នៃការតស៊ូបដិវត្តន៍នៅឥណ្ឌូចិន និងលើពិភពលោកទាំងមូល ដើម្បីវឌ្ឍនភាព ហើយបើរបបរបស់បនប៉ុល ពត បានកើតមកហើយ អន្តរធានទៅវិញភ្លាម គឺថាចំណងទាក់ទងអចិន្ត្រៃយ៍នេះ បានដាច់មួយដងមួយកាលប៉ុណ្ណោះ រវាងអ្នកបដិវត្តន៍ខ្មែរ ជាមួយនឹងចលនាកុម្មុយនិស្តនិយមអន្តរជាតិ និងចលនារំដោះជាតិលើសកលលោកទាំងមូល ។

ប្រវិត្តសាស្ត្រប្រទេសកម្ពុជា បានផ្តល់នូវឧទាហរណ៍ដ៏ជាក់ស្តែង ដែលបញ្ជាក់ថា នៅក្នុងការតស៊ូប្រឆាំងនឹងពួកឈ្លានពានបរទេស ដើម្បីសេរីភាព ឯករាជភាព និងវឌ្ឍនភាពខាងសង្គម ប្រជាជនខ្មែរបានទទួលជំនួយ និងការគាំទ្រដ៏ស្មោះស្ម័គ្រពីសំណាក់ប្រជាជនសហភាពសូវៀត ប្រទេសវៀតណាម ប្រទេសឡាវ ប្រទេសសង្គមនិយមដទៃ និងពីសំណាក់នៃបក្សកុម្មុយនិស្ត និងកម្មករនៅក្នុងប្រទេសកំពុងលូតលាស់ និងប្រទេសមូលធននិយម និងពីកម្លាំងចម្រើនជឿនលឿនទាំងអស់លើពិភពលោក ។

អត្ថន័យដ៏ពិសេស សម្រាប់ជោគវាសនាអនាគតនៃប្រទេសកម្ពុជា តែងស្ថិតជានិច្ចនៅក្នុងទំនាក់ទំនងជាមួយនឹងប្រទេសជិតខាងពីររបស់ខ្លួន គឺវៀតណាម ឡាវ ព្រមទាំងនៅក្នុងសាមគ្គី

ជាតិដ៏ស្អិតរមួត ជាបងប្អូនរវាងប្រជាជនទាំងបីប្រទេសនេះ។ សម្ពន្ធភាពដ៏រឹងមាំ នាសម័យបច្ចុប្បន្ន រវាងប្រជាជនទាំងបីប្រទេស គឺជាមូលដ្ឋានដ៏សំខាន់ សម្រាប់ធានារ៉ាប់រងដល់សន្តិភាព សេរីភាព ឯករាជភាព និងវឌ្ឍនភាព មិនគ្រាន់តែនៅឥណ្ឌូចិន ប៉ុណ្ណោះទេ ប៉ុន្តែ នៅអាស៊ីអាគ្នេយ៍ទាំងមូល។ នៅពេលមុនៗនេះ មានសេចក្តីផ្តើមគំនិតដ៏ច្បាស់លាស់ខាងនយោបាយ ស្នើដោយ សាធារណរដ្ឋប្រជាមានិតកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដើម្បីកែប្រែភូមិភាគនេះឱ្យទៅជាតំបន់នៃសន្តិភាព នៃសន្តិសហវិជ្ជមាន នៃសហប្រតិបត្តិការទៅវិញទៅមក ។

ប្រទេសទាំងបីនៅឥណ្ឌូចិន បានធ្វើសេចក្តីថ្លែងការណ៍ស្នើឱ្យមានការរៀបចំការ ជួបគ្នាជាមួយតំណាងរដ្ឋាភិបាលជាសមាជិកនៃអង្គការអាស៊ាន ដើម្បីធ្វើការពិភាក្សា និងដោះស្រាយបញ្ហានានានៃតំបន់នេះ នៅលើមូលដ្ឋាននៃសមភាពនៃការគោរពគ្នាទៅវិញទៅមក និងការមិនបង្ខិតបង្ខំគ្នាឱ្យទៅតាមទស្សនៈណាមួយរបស់ខ្លួន។ គឺនៅក្នុងគោលដៅនេះហើយ ដែលប្រទេសទាំងបីបានធ្វើសំណើ ឱ្យកោះហៅសន្និសីទអន្តរជាតិមួយស្តីអំពីបញ្ហានៅអាស៊ីអាគ្នេយ៍។

ជាច្រើនដងមកហើយ សាធារណរដ្ឋប្រជាមានិតកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ បានធ្វើសេក្តីស្នើដល់ប្រទេសថៃឡង់ឱ្យព្រមព្រៀងចុះហត្ថលេខា លើកិច្ចសន្យាស្តីអំពីការមិនឈ្លានពាន និងមិនជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងទៅវិញទៅមក។ ប្រទេសទាំងបីបានបញ្ជាក់នូវសេក្តីប្រុងប្រៀបខ្លួន ដើម្បីពិភាក្សាអំពី

វិធានការដ៏ចាំបាច់បំផុតទាំងអស់ សម្រាប់ការធានារ៉ាប់រងដល់សន្តិសុខ ឯករាជភាព អធិបតេយ្យភាព និងបូរណភាពទឹកដីនៃប្រទេសនីមួយៗ ជាមួយប្រទេសថៃឡង់ដ៍។

សាធារណរដ្ឋប្រជាមានិតកម្ពុជា បានស្នើឱ្យបង្កើតតំបន់អយោធាមួយ ដែលស្ថិតនៅតាមដងព្រំប្រទល់ប្រទេសកម្ពុជា-ថៃឡង់ដ៍។ នៅថ្ងៃទី៧ កក្កដា ឆ្នាំ១៩៨២ ប្រទេសកម្ពុជា បានធ្វើសេចក្តីស្នើឱ្យរៀបចំតាមបណ្តោយព្រំដែន រវាងប្រទេសទាំងពីរនូវតំបន់សន្តិសុខមួយ ដែលនៅទីខាងព្រំប្រទល់កម្ពុជា នៃតំបន់នេះ ត្រូវមានតែកងទ័ពរបស់សាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយនៅទីខាងព្រំប្រទល់ថៃឡង់ដ៍ ត្រូវមានតែកងទ័ពថៃឡង់ដ៍ នៅទីនេះ។ សាធារណរដ្ឋប្រជាមានិតកម្ពុជា បានទាំងបញ្ជាក់នូវការប្រុងប្រៀបខ្លួន ដើម្បីពិភាក្សាអំពីវិធានការចាំបាច់នានាទាំងអស់ សម្រាប់ធានាដល់ការគោរពដល់ព្រំប្រទល់ប្រទេសទាំងពីរ ដោយហាមឃាត់មិនឱ្យប្រើប្រាស់ទឹកដីប្រទេសមួយសម្រាប់ការបង្កើតសកម្មភាពជាសត្រូវចំពោះប្រទេសមួយទៀតជាមួយប្រទេសថៃឡង់ដ៍។ កិច្ចព្រមព្រៀងបែបនេះ នឹងអាចប្រព្រឹត្តទៅនៅក្រោមកិច្ចត្រួតត្រាអន្តរជាតិ។

សាធារណរដ្ឋប្រជាមានិតកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ តែងធ្វើសេចក្តីថ្លែងថា មានតែសាធារណរដ្ឋប្រជាមានិតកម្ពុជា មួយទេ ដែលជាអ្នកតំណាង ត្រឹមត្រូវពេញលេញតាមច្បាប់តែមួយរបស់ប្រជាជនកម្ពុជា នៅលើឆាកអន្តរជាតិ។ មិនតែប៉ុណ្ណោះ នៅថ្ងៃទី៧ កក្កដា ឆ្នាំ១៩៨២ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើសេចក្តីថ្លែងថា ប្រសិនបើបនប៉ុល ពត ត្រូវបាន

បណ្តេញចេញពីអង្គការសហប្រជាជាតិ ហើយអាសនៈប្រទេសកម្ពុជា ត្រូវស្ថិតនៅទំនេរនោះក្នុងពេលអនាគតដ៏ខ្លីនេះ សាធារណរដ្ឋប្រជាមានិតកម្ពុជា នឹងមិនទាមទារសិទ្ធិនៃស្ថានតំណាងរបស់ខ្លួននៅក្នុងអង្គការនេះភ្លាមៗទេ។

ដើម្បីជាកត្តាច្បាស់លាស់ នៃកាយវិការប្រកបដោយសុធន្ទៈរបស់ សាធារណរដ្ឋប្រជាមានិតកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម នាខែកក្កដា ឆ្នាំ១៩៨២ , ខែឧសភា ឆ្នាំ១៩៨៣ , ខែមិថុនា ឆ្នាំ១៩៨៤ មានការអនុវត្តដកកងទ័ពវៀតណាមមួយភាគ ចេញពីប្រទេសកម្ពុជា។

ប្រជាជននៃប្រទេសកម្ពុជា បានចារដ៏ច្បាស់លាស់នូវទំព័រប្រវត្តិសាស្ត្រដ៏មានជ័យរបស់ខ្លួននៅក្នុងប្រទេស និងនៅក្នុងពិភពលោកទាំងមូល។ ពិតមែនហើយ ប្រជាជនកម្ពុជា ត្រូវតែមានមោទនភាពនឹងប្រវត្តិសាស្ត្រ នៅក្នុងអតីតកាលរបស់ខ្លួន។ បំណងរបស់បនប៉ុល ពត ដើម្បីធ្វើឱ្យ “ ប្រឡាក់ប្រឡូស ” ដល់ប្រវត្តិសាស្ត្រដ៏បូរាណនៅអនាគតកាល ហើយបានចាប់ផ្តើមសរសេរប្រវត្តិសាស្ត្រកម្ពុជា ពីលើ “ សន្លឹកក្រដាសទទេ ” គឺជាអំពើក្បត់ដ៏ធ្ងន់ធ្ងរ ដល់ប្រជាជននៃប្រទេសកម្ពុជា។

ទោះបីមានសេចក្តីលំបាកលំបិនយ៉ាងណាក្តី ក៏ដំណាក់កាលបច្ចុប្បន្ន បានក្លាយទៅជាការចាប់ផ្តើមសករាជថ្មីមួយនៅក្នុងប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា។ ជាលើកទីមួយនៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួន នៅក្រោមកិច្ចដឹកនាំរបស់បក្សប្រជាជនបដិវត្តន៍កម្ពុជា ប្រជាជនកម្ពុជា បានទៅជាម្ចាស់ពិតប្រាកដនៃវាសនារបស់ខ្លួន ហើយកំពុងតែកសាងមូលដ្ឋាននៃសង្គមសង្គមនិយមនៅក្នុងប្រទេសដោយជោគជ័យ។

ការផ្លាស់ប្តូរទាំងឡាយ ដែលកើតមានឡើងនៅប្រទេសកម្ពុជា គឺជាភាពពិតសត្យានុម័ត ហើយគ្មានអនុភាពប្រតិកិរិយាប្រតិកម្ម ណាមួយអាចប្រែក្រឡាស់ដល់សមិទ្ធិស្ថាបនកម្ម ក្នុងវិស័យសង្គម-សេដ្ឋកិច្ច និងវប្បធម៌ដែលកំពុងសម្រេចឡើងនៅលើទឹកដីខ្មែរដ៏បូរាណបានឡើយ។

# កាលប្បវត្តិ

| | |
|---|---|
| ៤០.០០០ - ១៥.០០០ ឆ្នាំ មុន គ្រឹស្តសករាជ (គ.ស.) | -យុគបុរាណសិលានៅលើទឹកដីប្រទេសកម្ពុជា។ |
| ១៤.០០០ - ៧.០០០ ឆ្នាំ មុន គ.ស. | -យុគមជ្ឈមសិលានៅលើទឹកដីប្រទេសកម្ពុជា។ |
| ៧.០០០ - ៦.០០០ ឆ្នាំ មុន គ.ស. | -យុគនវសិលា នៃវប្បធម៌ ប្រកបដោយរបរបេះផ្លែឈើ និង ដាំដំណាំ។ |
| ៦.០០០ - ៥.០០០ ឆ្នាំ មុន គ.ស. | -យុគនវសិលាខាងចុង នៅលើ ទឹកដីប្រទេសកម្ពុជា។ |
| ៤.០០០ - ឆ្នាំមុន គ.ស. (ភាគពាក់កណ្ដាល) | -កំណកំណើតមជ្ឈមណ្ឌលនៃ លោហធាតុស្ពាន់។ |
| ៣.០០០ - ឆ្នាំមុន គ.ស. (ទីបញ្ចប់) | -ការចាប់ផ្ដើមសម័យកាល នៃវប្បធម៌លង្ហិន។ |
| ១.០០០ - ឆ្នាំមុន គ.ស. (ភាគខាងដើម) | -ចុងសម័យកាល នៃវប្បធម៌លង្ហិន។ |
| សតវត្សរ៍ទី២ មុន គ.ស. | -ការផ្សព្វផ្សាយទូទៅ នៃរបៀប ប្រើប្រាស់ដែក។ |
| សតវត្សរ៍ទី១ - ទី២ គ.ស. | -កំណកំណើតសង្គមប្រកបដោយ វណ្ណៈនៅលើទឹកដីប្រទេសកម្ពុជា។ |

| | |
|---|---|
| សតវត្សរ៍ទី២ - ទី៤ | -សម័យកាលនៃរដ្ឋបាភ្នំ ការផ្សព្វផ្សាយវិធីប្រើប្រាស់អក្សរ, សាសនា, ប្រព័ន្ធប្រាក់កាស, ការរៀបចំទំនាក់ទំនងនឹងប្រទេសឥណ្ឌា។ |
| ចុងសតវត្សរ៍ទី២ - ដើមសតវត្សរ៍ទី៣ | -ការបញ្ចូលបណ្ដារដ្ឋមន និងម៉ាឡាយូមួយចំនួនឱ្យស្ថិតនៅក្រោមអំណាចចក្រភពបាភ្នំ។ |
| ដើមសតវត្សរ៍ទី៣ | -ការពង្រឹងទំនាក់ទំនងអន្តរជាតិ និងខាងពាណិជ្ជកម្ម នៃចក្រភពបាភ្នំ ជាមួយប្រទេសឥណ្ឌា និងប្រទេសចិនខាងត្បូង (ក្នុងរជ្ជកាលរាជវង្ស អ៊ូ)។ |
| ដើមសតវត្សរ៍ទី៥ | -ការពង្រឹង និងពង្រីកឥទ្ធិពលព្រហ្មញ្ញសាសនា, ការរៀបចំទំនាក់ទំនងនឹងរដ្ឋបល្លាវៈ នៅឧបទ្វីបឥណ្ឌូស្ថាន។ |
| សតវត្សរ៍ទី៦ (ភាគពាក់កណ្ដាល) | -សម័យចុះអន់ថយនៃចក្រភពបាភ្នំ សម័យចាប់ផ្ដើមកំណកំណើត និងការពង្រឹងរដ្ឋកម្ពុជា (ចេនឡា)។ |
| សតវត្សរ៍ទី៧ | -កំណកំណើតទំនាក់ទំនងនៃរបបសក្តិភូមិ ការប្រតិស្ឋានពិធីសក្ការៈ |

| | |
|---|---|
| | បូជាទេវ-រាជា, ការពង្រឹងឯកភាពអំណាចខាងសាសនា និងរដ្ឋអំណាច។ |
| សតវត្សរ៍ទី៧ (ភាគពាក់កណ្ដាលទី១) | -ការបង្រួបបង្រួមដែនដីទាំងឡាយ ដែលស្ថិតនៅតាមទីវាលទំនាបនៃទន្លេមេកុង និងនៅតាមឆ្នេរឈូងសមុទ្រសៀម ភាគខាងឦសាន។ ការស្ថាបនារដ្ឋធានីថ្មី គឺឦសានបូរៈ។ |
| សតវត្សរ៍ទី៧ (ភាគពាក់កណ្ដាលទី២) | -ការពង្រីកទឹកដីប្រទេសទៅទិសឧត្តរ។ ការផ្សព្វផ្សាយសាសនាសិវៈ។ |
| ដើមសតវត្សរ៍ទី៨ | -ការបង្កើតរដ្ឋសហភាពពីរ - គឺរដ្ឋកម្ពុជា (ចេនឡា) ដីគោក និងរដ្ឋកម្ពុជា (ចេនឡា) ដីទឹក។ ការរីកចម្រើននៃរបបសក្តិភូមិ។ |
| សតវត្សរ៍ទី៩ - ទី១១ | -សម័យកាលខាងដើម នៃចក្រភពកម្ពុជទេស។ |
| សតវត្សរ៍ទី៩ (ភាគពាក់កណ្ដាលទី១) | -ការចាប់ផ្ដើមបង្រួបបង្រួមដែនដីខ្មែរ។ |
| ចុងសតវត្សរ៍ទី៩ - ដើមសតវត្សរ៍ទី១០ | -ការកសាងពង្រឹងចក្រភពកម្ពុជទេស។ |
| គ.ស.៩៤៥ - គ.ស.៩៤៦ | -ចម្បាំងជាមួយប្រទេសចម្ប៉ា។ |

| | |
|---|---|
| ចុងសតវត្សរ៍ទី៩ | -ការរៀបចំទម្រង់ខាងសង្គមកិច្ច នៃចក្រភពកម្ពុជទេស។ |
| ដើមសតវត្សរ៍ទី១១ - ដើមសតវត្សរ៍ទី១៣ | -សម័យកាលដ៏រុងរឿង នៃចក្រភពកម្ពុជទេស។ |
| គ.ស.១០១១ - គ.ស.១០៥០ | -ចម្បាំងបង្ក្រាបរដ្ឋល្វោ រដ្ឋមន។ |
| សតវត្សរ៍ទី១២ (ភាគពាក់កណ្តាលទី១) | -យុទ្ធនាការ នៃចម្បាំងរបស់ចក្រភពកម្ពុជទេស ប្រឆាំងប្រទេសចម្ប៉ា ប្រទេសដាយវៀតនិងរដ្ឋបុណ្យជ័យ។ ស្ថាបនកម្ម ព្រះវិហារ ប្រាសាទអង្គរវត្ត។ |
| គ.ស.១១៨១ | -ចម្បាំងជាមួយប្រទេសចម្ប៉ា។ ពីការពង្រីកព្រំប្រទល់ នៃចក្រភពកម្ពុជទេស តទៅមុខទៀត។ |
| សតវត្សរ៍ទី១៣ (ភាគកណ្តាល) | -វិបត្តិសេដ្ឋកិច្ចនៅតំបន់កណ្តាល និងនិន្នាការរីកចម្រើននៅតំបន់ដាច់ស្រយាលនៃចក្រភព។ |
| ចុងសតវត្សរ៍ទី១៣ | -ការផ្សព្វផ្សាយពុទ្ធសាសនាថេរវាទ។ វិវត្តនាការមកកាន់ស្ថានភាពជាចក្រភពកម្ពុជទេស ឯកជាតិ។ |
| ទសវត្សរ៍ទី២ - ទី៣ នៃសតវត្សរ៍ទី១៤ | -សម័យកាលខាងចុង នៃចក្រភពកម្ពុជទេស។ |

| | |
|---|---|
| គ.ស.១៣៩៨ | -ចម្បាំងវាយលុក នៃរដ្ឋអយុធ្យា (ប្រទេសសៀម) មកលើប្រទេសកម្ពុជា និងការវាយចូលរដ្ឋធានី។ |
| គ.ស.១៤៣៤ | -ការកសាងរដ្ឋធានីនៅតំបន់ចតុមុខ (រដ្ឋធានីភ្នំពេញ សព្វថ្ងៃ)។ |
| គ.ស.១៤៩៤ - គ.ស.១៥១៥ | -ចលនាកុបកម្មបះបោរកសិករក្រោមកិច្ចដឹកនាំរបស់នាយកន។ |
| នៅដើមសតវត្សរ៍ទី១៦ | -ការចាប់ផ្តើមជ្រៀតចូលនៃពួកអឺរ៉ុប មកក្នុងប្រទេសកម្ពុជា។ |
| គ.ស.១៥៥៦ - គ.ស.១៥៦៧ | -ចម្បាំងជាមួយរដ្ឋអយុធ្យា។ |
| គ.ស.១៦០០ | -ចលនាកុបកម្មបះបោរ ក្រោមកិច្ចដឹកនាំរបស់នាយកែវ |
| ចុងសតវត្សរ៍ទី១៦ - ដើមសតវត្សរ៍ទី១៧ | -ចម្បាំងហែកហួរផ្ទៃក្នុង រវាងពួកសក្តិភូមិនៅប្រទេសកម្ពុជា។ ការបង្កើនឥទ្ធិពលនៃរដ្ឋអយុធ្យា លើប្រទេសកម្ពុជា។ |
| គ.ស.១៦៤០ - គ.ស.១៦៤២ | -ការបង្កើនសកម្មភាពជំនួយ នៃក្រុមហ៊ុនពាណិជ្ជកម្មហុល្លង់ ឈ្មោះអុសអិន្ត នៅប្រទេសកម្ពុជា។ |
| ជិតគ.ស.១៦៩០ | -ការភ្ជាប់ដីខ្មែរ ដែលស្ថិតនៅត្រើយខាងឆ្វេង នៃទីវាលទំនាប |

| | |
|---|---|
| | នៃទន្លេមេកុង ទៅនឹងប្រទេសវៀតណាម (ដាន់ធ្លុង)។ |
| សតវត្សរ៍ទី១៨ (ភាគកណ្តាល) | -វិបត្តិដ៏ខ្លាំងក្លានៅក្នុងសង្គមសក្តិភូមិខ្មែរ។ ការព្រមទទួលរបបអាណាព្យាបាលទ្វេភាគីលើប្រទេសកម្ពុជា។ |
| គ.ស.១៨៦១ | -ចលនាកុបកម្មបោះបោរក្រោមកិច្ចដឹកនាំរបស់ស៊ី វត្ថា។ |
| គ.ស.១៨៦៣ - (ថ្ងៃទី១១ សីហា) | -ពិធីចុះហត្ថលេខាលើសេចក្តីព្រមព្រៀងបារាំង-ខ្មែរ ស្តីអំពីរបបអាណាព្យាបាលបារាំង ដែលបានទទួលសច្ចាប័ន នាថ្ងៃទី៨ មេសា ឆ្នាំ១៩៦៥។ |
| គ.ស.១៨៦៤ - គ.ស.១៨៦៦ | -ចលនាកុបកម្មបះបោរក្រោមកិច្ចដឹកនាំរបស់អាចារ្យស្វា។ |
| គ.ស.១៨៦៥ - គ.ស.១៨៦៧ | -ចលនាកុបកម្មបះបោរក្រោមកិច្ចដឹកនាំរបស់ ពោធិ៍ - កំបោរ។ |
| គ.ស.១៨៦៦ | -ការផ្លាស់រដ្ឋធានីនៃកម្ពុជា ពីឧត្តុង្គមកតាំងនៅភ្នំពេញ។ |
| គ.ស.១៨៧៦ - គ.ស.១៨៧៧ | -ចលនាកុបកម្មបះបោរទីពីរដឹកនាំដោយស៊ី - វត្ថា។ |

| | |
|---|---|
| គ.ស.១៨៨៤ (ថ្ងៃទី១៧ មិថុនា) | -កិច្ចព្រមព្រៀងបារាំង - កម្ពុជាស្តីអំពីការរៀបចំរបបគ្រប់គ្រងអាណានិគមបារាំង នៅក្នុងប្រទេស។ |
| គ.ស.១៨៨៤ - គ.ស.១៨៨៦ | -ចលនា " ការពារមហាក្សត្រ "។ |
| គ.ស.១៨៨៥ - គ.ស.១៨៨៦ | -ចលនាកុបកម្មបះបោរទីបី ក្រោមកិច្ចដឹកនាំដោយស៊ី - វត្ថា។ |
| គ.ស.១៨៨៧ | -ការបង្កើតសហភាពឥណ្ឌូចិន ដែលមានបញ្ចូលទាំងប្រទេសកម្ពុជា។ |
| គ.ស.១៩០៧ | -ចលនាកុបកម្មកសិករ ក្រោមកិច្ចដឹកនាំរបស់ វិសេស-ញៀវ។ |
| គ.ស.១៩១៤ | -ការបើកសាលាបាលីនៅភ្នំពេញ (ចាប់ពីឆ្នាំ១៩២៣ សាលានេះបានក្លាយទៅជាសាលាបាលីជាន់ខ្ពស់)។ |
| គ.ស.១៩១៦ (ខែមករា - ខែកុម្ភៈ) | -ចលនាបះបោរកសិករប្រឆាំងរដ្ឋបាលបារាំង។ |
| គ.ស.១៩២៥ (ថ្ងៃទី១៦ មេសា) | -កុបកម្មបោះបោរកសិករនៅខេត្តកំពង់ឆ្នាំង។ |
| គ.ស.១៩២៩ (នៅថ្ងៃទី២១ មិថុនា) | -បាតុកម្មកម្មករនៅក្រុមហ៊ុនបារាំងឈ្មោះ " ក្រុមហ៊ុនដឹកនាំនិងគមនាគមន៍ នៃឥណ្ឌូចិន " នៅភ្នំពេញ។ |

| | |
|---|---|
| គ.ស.១៩២៩ (ថ្ងៃទី៣ តុលា) | -បាតុកម្មកម្មកររោងចក្រនានា នៅភ្នំពេញ។ |
| គ.ស.១៩៣០ (ខែសីហា) | -ចលនារំដើបរំជួលនៅមជ្ឍដ្ឋានកម្មករនៅចម្ការកៅស៊ូ។ |
| គ.ស.១៩៣០ | -ការបង្កើតបក្សកុម្មុយនិស្តឥណ្ឌូចិន។ |
| គ.ស.១៩៣១ (ថ្ងៃទី២៦ ឧសភា) | -ការបះបោរជនជាតិខ្មែរនៅស្រុកព្រៃ ប្រឆាំងរដ្ឋបាលអាណានិគមបារាំង។ |
| គ.ស.១៩៤២ | -ការបង្កើតរណសិរ្សខ្មែរឥស្សរៈ។ |
| គ.ស.១៩៤៥ (ថ្ងៃទី៩ មីនា) | -អំណាចយោធានិយមជប៉ុន បានមកកាន់កាប់អំណាចនៅឥណ្ឌូចិនជំនួសរដ្ឋបាលបារាំង។ |
| គ.ស.១៩៤៥ (ខែតុលា) | -ការវាយលុករបស់អង្គភាពកងទ័ពអាណានិគមបារាំង ចូលមកប្រទេសកម្ពុជា។ |
| គ.ស.១៩៤៦ - ១៩៤៧ | -ការបង្កើតមូលដ្ឋាននៃរណសិរ្សខាងក្រោយរបស់ខ្មែរឥស្សរៈ។ |
| គ.ស.១៩៤៩ (ខែវិច្ឆិកា) | -ការទទួលស្គាល់ “ ឯករាជភាព ” នៃប្រទេសកម្ពុជា ក្នុងក្របខ័ណ្ឌនៃសហភាពបារាំង។ |
| គ.ស.១៩៥១ (ខែកុម្ភៈ) | -មហាសន្និបាតទីពីរ នៃបក្សកុម្មុយនិស្តឥណ្ឌូចិន។ |

| | |
|---|---|
| គ.ស.១៩៥១ (ថ្ងៃទី២៨ មិថុនា) | -ការបង្កើតបក្សប្រជាជនបដិវត្តន៍កម្ពុជា។ |
| គ.ស.១៩៥១ (ខែមីនា) | -ការបង្កើតរណសិរ្សរួម នៃចលនាតស៊ូប្រជាជននានានៅឥណ្ឌូចិន។ |
| គ.ស.១៩៥១ (ខែមិថុនា) | -ការបង្កើតរណសិរ្សឯកភាពជាតិ នៃខ្មែរឥស្សរៈ (សមាគមខ្មែរឥស្សរៈ)។ |
| គ.ស.១៩៥១ (ថ្ងៃទី១៩ មិថុនា) | -សេចក្តីថ្លែងការណ៍របស់រណសិរ្សខ្មែរឥស្សរៈ ស្តីអំពីឯករាជភាពនៃប្រទេសកម្ពុជា។ |
| គ.ស.១៩៥២ (ខែ វិច្ឆិកា) | -កូដកម្មបណ្តាពលករ និងបាតុកម្មសិស្សានុសិស្សនៅភ្នំពេញ។ |
| គ.ស.១៩៥៣ (ថ្ងៃទី៩ វិច្ឆិកា) | -ការដកអង្គភាពកងទ័ពបារាំង ពីភ្នំពេញ និងការបញ្ឈប់សកម្មភាពរបស់រដ្ឋបាលបារាំង នៅភ្នំពេញ។ |
| គ.ស.១៩៥៤ (ខែឧសភា-មិថុនា) | -សន្និសីទអន្តរជាតិនៅទីក្រុងហ្សឺណែវ ស្តីអំពីឥណ្ឌូចិន។ |
| គ.ស.១៩៥៤ (នៅរដូវវស្សា) | -ការបង្កើតក្រុម “ ប្រជាជន ”។ |
| គ.ស.១៩៥៥ (ខែមីនា) | -ការបង្កើតអង្គការនយោបាយ “ សង្គមរាស្ត្រនិយម ”។ |
| គ.ស.១៩៥៥ (ខែកញ្ញា) | -ការដកខ្លួនថយ នៃប្រទេសកម្ពុជា ពីសហភាពបារាំង។ |

| | |
|---|---|
| គ.ស.១៩៥៥ (ខែធ្នូ) | -ការទទួលស្គាល់ប្រទេសកម្ពុជា ជាសមាជិកនៅក្នុងអង្គការសហប្រជាជាតិ។ |
| គ.ស.១៩៥៦ (ខែកុម្ភៈ) | -ការមិនយល់ព្រម នៃប្រទេសកម្ពុជា ចូលក្នុងបក្សសម្ព័ន្ធយោធាសេ.អា.តូ។ |
| គ.ស.១៩៥៦ (ខែឧសភា) | -ការរៀបចំទំនាក់ទំនងខាងទូតរវាងប្រទេសកម្ពុជា និងសហភាពសូវៀត។ |
| គ.ស.១៩៥៧ (ខែកញ្ញា) | -សេចក្តីអនុម័តលើឯកសារស្តីអំពីអព្យាក្រឹត្យភាព នៃប្រទេសកម្ពុជា។ |
| គ.ស.១៩៥៨ (ខែមករា) | -អំពើក្បត់របស់ សម - សារី។ |
| គ.ស.១៩៦០ (ខែកញ្ញា) | -មហាសន្និបាតទីពីរ នៃបក្សប្រជាជនបដិវត្តន៍កម្ពុជា។ សេចក្តីសម្រេចដាក់ឈ្មោះបក្សជាថ្មីថា ជាបក្សកុម្មុយនិស្តកម្ពុជា។ |
| .ស.១៩៦២ (ខែមករា) | -វិធានការបង្ក្រាបរបស់អង្គការសង្គមរាស្ត្រនិយម ប្រឆាំងបណ្តាកម្លាំងប្រជាធិបតេយ្យ។ ការចាប់ឃុំឃាំងអ្នកដឹកនាំក្រុម “ ប្រជាជន ”។ |
| គ.ស.១៩៦២<br>(ថ្ងៃទី២៧ ឧសភា) | -ឃាតកម្មលើរូបសមមិត្ត ទូ - សាមុត ជាអ្នកដឹកនាំបក្សកុម្មុយនិស្ត |

| | |
|---|---|
| | កម្ពុជា ប្រព្រឹត្តទៅដោយក្រុមពួកប្រឆាំងបក្សដឹកនាំដោយប៉ុល ពត។ |
| គ.ស.១៩៦៣ (ខែសីហា) | -ការផ្តាច់ទំនាក់ទំនងទូតរវាងប្រទេសកម្ពុជា និងរបបគ្រប់គ្រងព្រៃនគរ។ |
| គ.ស.១៩៦៣ (ខែវិច្ឆិកា) | -ការប្រកែកនៃប្រទេសកម្ពុជា មិនព្រមទទួលជំនួយយោធា និងសេដ្ឋកិច្ចរបស់សហរដ្ឋអាមេរិក។ |
| គ.ស.១៩៦៥ ( ខែមីនា) | -ការផ្តាច់ចំណងទាក់ទងទូតរវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក។ |
| គ.ស.១៩៦៥ | -ការកោះហៅប្រជុំសន្និសីទអន្តរជាតិនៃប្រជាជននានា នៃឥណ្ឌូចិននៅទីក្រុងភ្នំពេញ។ |
| គ.ស.១៩៦៧ (ខែមីនា) | -កុបកម្មបះបោរកសិករនៅស្រុកសំឡូត ខេត្តបាត់ដំបង។ |
| គ.ស.១៩៦៨ | -ការចាប់ផ្តើមអនុវត្តនយោបាយរបស់ពួកខាងស្តាំក្នុងការប្រើកម្លាំងយោធា ដើម្បីបង្ក្រាបដោយត្រង់លើបណ្តាចលនាប្រជាធិបតេយ្យនៅក្នុងប្រទេស។ |
| គ.ស.១៩៦៩ (ខែមេសា) | -ការរៀបចំទំនាក់ទំនងទូតសារជាថ្មី រវាងប្រទេសកម្ពុជា និងសហរដ្ឋអាមេរិក។ |

| | |
|---|---|
| គ.ស.១៩៧០ (ថ្ងៃទី១៨ មីនា) | -រដ្ឋប្រហារ និងការកាន់កាប់អំណាចនៃរបបគ្រប់គ្រងអាមេរិកនិយម របស់លន់ - ណុល។ |
| គ.ស.១៩៧០ (ថ្ងៃទី២៤-ទី២៥ មេសា) | -សន្និសីទនៃប្រជាជននានា នៅឥណ្ឌូចិន។ |
| គ.ស.១៩៧០ (ថ្ងៃទី៣០ មេសា) | -ការវាយលុកនៃកងទ័ពអាមេរិក-ព្រៃនគរ មកលើប្រទេសកម្ពុជា។ |
| គ.ស.១៩៧០ (ថ្ងៃទី៤ ឧសភា) | -ការបង្កើតរណសិរ្សរួបរួមជាតិកម្ពុជា និងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា។ |
| គ.ស.១៩៧៥ (ថ្ងៃទី១៧ មេសា) | -ការរំដោះទីក្រុងភ្នំពេញ និងការរលំនៃរបបគ្រប់គ្រងលន់ - ណុល។ |
| គ.ស.១៩៧៨ (ថ្ងៃទី២ ធ្នូ) | -ការបង្កើតរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ |
| គ.ស.១៩៧៩ (ថ្ងៃទី៧ មករា) | -ការរំដោះប្រទេសកម្ពុជា ពីក្រញ៉ាំនៃរបបប្រល័យពូជសាសន៍ប៉ុលពត, អៀង សារី, ខៀវ សំផន។ |
| គ.ស.១៩៧៩ (ថ្ងៃទី១០ មករា) | -សេចក្តីប្រកាសស្តីអំពីសាធារណរដ្ឋប្រជាមានិតកម្ពុជា។ |
| គ.ស.១៩៧៩ (ថ្ងៃទី១៨ កុម្ភៈ) | -ពិធីចុះហត្ថលេខាលើកិច្ចព្រមព្រៀងស្តីអំពីសន្តិភាព មិត្តភាព និងសហប្រតិបត្តិការ រវាងសាធារណរដ្ឋប្រជាមានិតកម្ពុជា |

| | |
|---|---|
| | និងសាធារណរដ្ឋសង្គមនិយមវៀតណាម។ |
| គ.ស.១៩៧៩ (ថ្ងៃទី១៥ -ទី២០ សីហា) | -ពិធីបើកការងារតុលាការប្រជាជនដើម្បីកាត់ទោសបន ប៉ុល ពត។ |
| គ.ស.១៩៧៩ (ថ្ងៃទី២៩-ទី៣០ កញ្ញា) | -មហាសន្និបាតទីពីរនៃរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា។ |
| គ.ស.១៩៨០ (ខែកុម្ភៈ) | -ទស្សនកិច្ចមិត្តភាពជាផ្លូវការនៃគណៈប្រតិភូរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងក្រុមប្រឹក្សាប្រជាជនបដិវត្តន៍កម្ពុជា នៅសហភាពសូវៀត។ |
| គ.ស.១៩៨១ (ថ្ងៃទី១ ឧសភា) | -សម័យបោះឆ្នោតទូទៅ ដើម្បីជ្រើសរើសតំណាងរាស្ត្រសម្រាប់រដ្ឋសភា។ |
| គ.ស.១៩៨១ (ថ្ងៃទី២៦-ទី២៩ ឧសភា) | -មហាសន្និបាតទី៤ នៃបក្សកុម្មុយនិស្តកម្ពុជា។ សេចក្ដីសម្រេចហៅឈ្មោះបក្សដូចមុនវិញ គឺបក្សប្រជាជនបដិវត្តន៍កម្ពុជា។ |
| គ.ស.១៩៨១ (ថ្ងៃទី២៥-ទី២៧ មិថុនា) | -សម័យប្រជុំនីតិកាលទី១ នៃរដ្ឋសភា ដែលនៅពេលនោះមានសេចក្ដីអនុម័តឱ្យប្រើប្រាស់រដ្ឋធម្មនុញ្ញ និងបង្កើតរដ្ឋាភិបាល។ |

| | |
|---|---|
| គ.ស.១៩៨១ (ថ្ងៃទី២២ ធ្នូ) | -មហាសន្និបាតទី៣ នៃរណសិរ្សសាមគ្គីកសាងការពារមាតុភូមិកម្ពុជា។ |
| គ.ស.១៩៨២ (ខែធ្នូ) | -កាចូលរួមរបស់គណៈប្រតិភូបក្សនិងរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ក្នុងពិធីប្រារព្ធខួបឆ្នាំទី៦០ នៃការបង្កើត ស.ស.ស.ស.។ |
| គ.ស.១៩៨៣ (ខែកុម្ភៈ ទីក្រុងវៀងច័ន្ទ) | -សន្និសីទអន្តរជាតិទីមួយ រវាងថ្នាក់ដឹកនាំនៃប្រទេសទាំងបីនៅឥណ្ឌូចិន គឺសាធារណរដ្ឋប្រជាមានិតកម្ពុជា សាធារណរដ្ឋសង្គមនិយមវៀតណាម និងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ |
| គ.ស.១៩៨៤ (ខែវិច្ឆិកា) | -ទស្សនកិច្ចជាផ្លូវការ និងមិត្តភាពរបស់គណៈប្រតិភូជាន់ខ្ពស់ ស.ស.ស.ស. នៅសាធារណរដ្ឋប្រជាមានិតកម្ពុជា។ |

# មាតិកាអត្ថបទ

អារម្ភកថា ........................................................ III
វគ្គទី១: ប្រទេសកម្ពុជា ពីសម័យកាលដ៏បុរមបុរាណ
ដល់សម័យកាលភាគទី១ នៃសតវត្សរ៍ទី១៩ ............... ០១
ចំពូកទី១: ប្រទេសកម្ពុជា ពីសម័យកាលក្នុងពេលដ៏បុរាណ
ព្រេងនាយ រហូតដល់ភាគខាងដើមនៃមធ្យមសម័យ ..... ០១
ចំពូកទី២: ចក្រភពកម្ពុជទេស (ចក្រភពអង្គរ) ........... ៤៣
ចំពូកទី៣: ប្រទេសកម្ពុជា នៅភាគកណ្តាលនៃសតវត្សរ៍
ទី១៤ - ទី១៥ ........................................................ ១១២
ចំពូកទី៤: ប្រទេសកម្ពុជា នៅសតវត្សរ៍ទី១៧ - ១៨ ..... ១៤៧
ចំពូកទី៥: ប្រទេសកម្ពុជា នាសម័យពាក់កណ្តាល
ភាគទី១នៃសតវត្សរ៍ទី ១៩ ...................................... ១៩៦
វគ្គទី២: ប្រទេសកម្ពុជា នាសម័យនៃអាណានិគមនិយម ....២១១
ចំពូកទី១: អំពើជ្រៀតជ្រែកចូលប្រទេសកម្ពុជា ដោយ
ប្រទេសបារាំង ........................................................ ២១១
ចំពូកទី២: រាជានិយមខ្មែរ និងរបបគ្រប់គ្រងអាណា
និគមនិយមបារាំង .................................................. ២២៧
ចំពូកទី៣: ចលនាប្រឆាំងនៅប្រទេសកម្ពុជា និង
ការចាប់ផ្តើមនៃការតស៊ូរបស់ប្រជាជនខ្មែរ ដើម្បី
ឯករាជភាពប្រទេស ................................................ ២៤៧
ចំពូកទី៤: ប្រទេសកម្ពុជា នៅក្នុងសម័យកាល
នៃរបបអាណាព្យាបាលរបស់ប្រទេសបារាំង ................ ២៦៤
ចំពូកទី៥: ចលនាតស៊ូរំដោះជាតិនៅសម័យ
អាណាព្យាបាលបារាំង ........................................... ២៨៨

វគ្គទី៣: ប្រទេសកម្ពុជា នាឆ្នាំ១៩៤៥-១៩៧០ ........... ៣០១
ចំពូកទី១: យុទ្ធនាការដើម្បីរំដោះជាតិ ........................ ៣០១
ចំពូកទី២: ការបង្កើតសង្គមរាស្ត្រនិយម និង
ការរៀបចំនយោបាយអព្យាក្រឹត ...................................... ៣៣២
ចំពូកទី៣: លក្ខណៈពិសេសនៃការលូតលាស់
ខាងសេដ្ឋកិច្ច និងសង្គមកិច្ចនៃប្រទេសកម្ពុជា ............. ៣៦០
ចំពូកទី៤: វិបត្តិរបស់របបគ្រប់គ្រងសង្គមរាស្ត្រនិយម ... ៣៨០
វគ្គទី៤: ប្រទេសកម្ពុជា នាឆ្នាំ១៩៧០-១៩៨០ ............ ៤០៦
ចំពូកទី១: ការតស៊ូ នៃប្រជាជនកម្ពុជា ប្រឆាំងចក្រពត្តិ
និយមអាមេរិក និងរបបគ្រប់គ្រងរបស់លន់-ណុល ....... ៤០៦
ចំពូកទី២: ប្រជាជនប្រទេសកម្ពុជា តស៊ូប្រឆាំងរបប
គ្រប់គ្រងប៉ុល ពត, អៀង សារី, ខៀវ សំផន ................ ៤៣៥
ចំពូកទី៣: សាធារណរដ្ឋប្រជាមានិតកម្ពុជា ................ ៤៥៨
យោបល់រួម ............................................................ ៤៩០
កាលប្បវត្តិ .............................................................. ៤៩៨

គោរពជូនមិត្តអ្នកអានជាទីមេត្រី!

អង្គការបោះពុម្ពផ្សាយ " ប្រូហ្គ្រេស្ស " សូមថ្លែងអំណរគុណជាមុន ប្រសិនបើមិត្តអ្នកអានផ្ញើមកឱ្យយើងខ្ញុំនូវសេចក្តីសង្កេតរបស់មិត្ត ស្តីអំពីគុណភាពនៃការបកប្រែសៀវភៅ ស្តីអំពីការរៀបចំទម្រង់សិល្បៈ និងការបោះពុម្ពអក្សរ ព្រមទាំងបំណងដទៃទៀតរបស់មិត្ត។

អាសយដ្ឋានរបស់យើង: I7, Zoubovski boulevard, Moscou , U.R.S.S

អង្គការបោះពុម្ពផ្សាយ “ ប្រូហ្គ្រេស្ស ”
កំពុងរៀបចំធ្វើការបោះពុម្ពផ្សាយៈ

យេ. ឆេវេរិក , យូ. ស្វីរកូវ
ចំណោះដាន់ដំបូង នៃផែនការូបនីយកម្ម

បញ្ហាសំខាន់ៗនៃទ្រឹស្តី និងកិច្ចប្រតិបត្តិការនៃផែនការូបនីយកម្ម ត្រូវបានឧទ្ទេសនាមឡើងយ៉ាងសាមញ្ញ និងងាយយល់នៅក្នុងវណ្ណកម្មនេះ។ បណ្តាអ្នកនិពន្ធបានគិតគូរដល់បញ្ហាទាំងឡាយ ស្តីអំពីការចាត់ចែងដំណើរការសង្គម និងសេដ្ឋកិច្ចទៅតាមផែនការ ដែលសម្រាប់ប្រទេសកំពុងលូតលាស់ទាំងឡាយ គឺជាបញ្ហាដ៏មានសារៈសំខាន់បំផុត សម្រាប់បច្ចុប្បន្នកាល។ គេបានបង្ហាញខ្លឹមសារ ល័ក្ខការណ៍ វិធីសាស្ត្រ និងការរៀបចំចាត់តាំងផែនការូបនីយកម្ម។ គេធ្វើការសិក្សាអំពីមូលដ្ឋាននានា នៃផែនការូបនីយកម្មធ្វើដោយរដ្ឋនៅកម្រិតអប្បសេដ្ឋកិច្ចអំពីលក្ខណៈពិសេស នៃផែនការរូបនីយកម្មសាខាសេដ្ឋកិច្ចនានា។ គេផ្តល់ចរិតលក្ខណៈពិស្តារ នៃផែនការូបនីយកម្ម។ ឯកសារផ្សេងៗសម្រាប់ផ្សំជាវណ្ណកម្មនេះ ត្រូវបានបញ្ជាក់អះអាងដោយឧទាហរណ៍ នៃកិច្ចប្រតិបត្តិការក្នុងការធ្វើផែនការនៅ ស.ស.ស.ស. នៅបណ្តាប្រទេសសង្គមនិយមឯទៀតៗ និងបណ្តាប្រទេសកំពុងលូតលាស់។

អង្គការបោះពុម្ពផ្សាយ “ ប្រូហ្គ្រេស្ស ”

កំពុងរៀបចំធ្វើការបោះពុម្ពផ្សាយៈ
គ្រូពស្កាយ៉ា ន.ក., អំពីការអប់រំ និងការ
សិក្សាពលកម្ម

នៅក្នុងសៀវភៅនេះ មានប្រជុំស្នាដៃដែលជ្រើសរើស របស់ ន.ក. គ្រូពស្កាយ៉ា។ ស្នាដៃទាំងនេះ ពន្យល់អំពីប្រព័ន្ធនៃការអប់រំ និងការសិក្សាក្នុងសាលាសូវៀត តាក់តែងឡើងដោយ គ្រូពស្កាយ៉ា ព្រមទាំងអំពីមាគ៌ាអនុវត្តនៃប្រព័ន្ធនេះនៅក្នុងការជាក់ស្តែង។ សៀវភៅនេះ ប្រមូលផ្តុំអត្ថបទនានា ដែលក្នុងនោះមានបញ្ជាក់នូវមូលដ្ឋាន និងល័ក្ខការទាំងឡាយ នៃកិច្ចការដ៏មានប្រយោជន៍សម្រាប់សង្គម។ ឯកសារទាំងឡាយដែលបាន ប្រមូលផ្តុំនៅក្នុងសៀវភៅនេះ នៅតែមានប្រយោជន៍សម្រាប់ បច្ចុប្បន្នកាលផងដែរ ពីព្រោះសាលាសូវៀត សព្វថ្ងៃដំណើរការ និងរីកចម្រើនសមស្របតាមប្រព័ន្ធនៃការសិក្សា និងការអប់រំ កុមារ ដែលតាក់តែងឡើងដោយ ន.ក.គ្រូពស្កាយ៉ា។

# ឧបសម្ពន្ធ

## ពាក្យមួយចំនួនដែលគួរកែសម្រួលនៅក្នុងសៀវភៅនេះ

១. បន្ទាប់ពីមាន**ព្រះរាជអាពាហ៍ពិពាហ៍**នេះហើយ (ទំព័រ១៥) គួរកែសម្រួលថា បន្ទាប់ពីមាន**ព្រះរាជអភិសេក**...។

២. បន្ទាប់ពី**មរណភាព**របស់ព្រះបាទជ័យវរ្ម័ន (ទំព័រ២៣) គួរកែសម្រួលថា បន្ទាប់ពី**ការសោយទិវង្គត**...។

៣. បន្ទាប់ពី**មរណភាព**របស់រាជបុត្រច្បងនៃរាជវង្សានុវង្សសូរ្យវង្ស មក... (ទំព័រ២៧) គួរកែសម្រួលថា បន្ទាប់ពី**ការសោយទិវង្គត...**។

៤. រាជវង្សានុវង្ស នាមកវរ្ម័ន **បានរៀបអាពាហ៍ពិពាហ៍**... (ទំព័រ២៧) គួរកែសម្រួលថា បានរៀប**ព្រះរាជអភិសេក**...។

៥. តាបសឥសី កម្ពុ - ស្វ័យយម្ភូ បានរៀប**អាពាហ៍ពិពាហ៍**នឹងព្រះនាងទេវីមេរៈ...(ទំព័រ២៧) គួរកែសម្រួលថា បានរៀប**អភិសេក**...។

៦. ដោយមានការបង្រួបបង្រួមគ្នា ជាមួយដែនដីកម្ពុជា (សម័យចេនឡា)**ដីទឹក**...(ទំព័រ៤០) គួរកែសម្រួលថា (សម័យចេនឡា)**លិចទឹក**...។

៧. នៅក្នុងរជ្ជកាលព្រះបាទឥន្ទ្រវរ្ម័នទី១ **របៀបរៀបអាពាហ៍ពិពាហ៍**រវាងរាជវង្សានុវង្សនានា(ទំព័រ៥៣)គួរកែសម្រួលថា **របៀបរៀបអភិសេក**...។

៨. បន្ទាប់ពី**មរណភាព**របស់ព្រះបាទជ័យវរ្ម័នទី៤ (ទំព័រ៦២) គួរកែសម្រួលថា បន្ទាប់ពីការសោយ**ទិវង្គត**...។

៩. ដែនដីត្រួសត្រាយថ្មីនោះ ស្ថិតនៅភាគខាងក្រោមនៃ**ទន្លេថៅ - ប្រៃ** (ទំព័រ៦៦) គួរកែសម្រួលថា **ទន្លេថៅផ្រះយ៉ា**។

១០. ដែលស្ថិតនៅតាមទីវាលទំនាបនៃ**ទន្លេថៅ - ប្រៃន** (ទំព័រ៦៩) គួរកែសម្រួលថា **ទន្លេថៅផ្រះយ៉ា**។

១១. ប្រទេសមន ដែលស្ថិតនៅតាមទីវាលទំនាបនៃ**ទន្លេថៅ - ប្រៃន** (ទំព័រ៧១) គួរកែសម្រួលថា **ទន្លេថៅផ្រះយ៉ា**។

១២. និយាយរួម ពាក្យថា **ទន្លេថៅ - ប្រៃន** និង **ទន្លេថៅ - ប្រៃ** គួរកែសម្រួលថា **ទន្លេថៅផ្រះយ៉ា**។

១៣. គឺការតស៊ូដើម្បីភ្ជាប់ដែនដីព្រៃនគរ **បារីយ៉ា, កំពាំង, ស្រកាត្រី** (ទំព័រ១៥៧) គួរកែសម្រួលថា ខេត្ត**ព្រះសួគ៌ (បារីយ៉ា=Ba Ria), ព្រះត្រពាំង, ចង្វាត្រពាំង ( Bien Hoa)**។

១៤. នៅឆ្នាំ១៩៥៣ ប៉ុល ពត និងបក្សពួករបស់ខ្លួនបានចូលជាសមាជិកក្នុងជួរ របស់**បក្សប្រជាជនបដិវត្តន៍កម្ពុជា** (ទំព័រ៣៨១) គួរកែសម្រួលថា **បក្សប្រជាជនបដិវត្តន៍ខ្មែរ**។

១៥. ក្នុងឋានៈជាប្រទេសមួយ ដែលជា**សមាជិកប្រធាន**នៃសន្និសញ្ញាហ្សឺណែវ ឆ្នាំ១៩៥៤ (ទំព័រ៣៩) គួរកែសម្រួលថា **សហប្រធាន**...។

១៦. ពួកបាតុករបានសម្រុកចូលស្ថានទូតសាធារណរដ្ឋប្រជាធិបតេយ្យវៀតណាម និង**ស្ថានទូតសាធារណរដ្ឋវៀតណាមខាងត្បូង**(ទំព័រ៤០៦) គួរកែតម្រូវថា **ស្ថានទូតរដ្ឋាភិបាលបដិវត្តន៍បណ្តោះអាសន្នវៀតណាមខាងត្បូង (វៀតកុង)**។

១៧. គឺទីក្រុងអ្នកលឿង ដែលស្ថិតនៅចំងាយ **៥០គ.ម.**ពីភ្នំពេញ (ទំព័រ៤១៧) គួរកែតម្រូវថា ស្ថិតនៅចំងាយ **៦០គ.ម.** ពីភ្នំពេញ។

១៨. **នៅថ្ងៃទី១១ - ១២ ខែមេសា** តាមបញ្ជារបស់ឯកអគ្គរដ្ឋទូតអាមេរិក ឈ្មោះ ឌីន (ទំព័រ៤១៧) គួរកែតម្រូវថា **នៅថ្ងៃទី ១២ ខែមេសា** (លុបថ្ងៃទី១១ ចោល)។

១៩. កាសែតវៀតណាមឈ្មោះ " **ញ៉ាន សាន** " (ទំព័រ៤១៨) គួរកែតម្រូវថា " **ញិន ហ្សិន** " គឺ កាសែតប្រជាជន (Nhân Dân) ជាកាសែតផ្លូវការរបស់បក្សកុម្មុយនិស្តវៀតណាម។

២០. តមក ប៉ុល ពត បានរៀនចប់អនុវិទ្យាល័យបច្ចេកទេសនៅភ្នំពេញ ហើយបានទៅរៀននៅប្រទេសបារាំង **ពីឆ្នាំ១៩៤៥ ដល់១៩៥៣។** (ទំព័រ៤៤០) គួរកែតម្រូវថា **ពីឆ្នាំ១៩៤៩ ដល់១៩៥៣។**

២១. ក្នុងបណ្តា**ព្រះសង្ឃចំនួន៨ម៉ឺន២ពាន់រូប**... (ទំព័រ៤៤៦) គួរកែតម្រូវថា **ព្រះសង្ឃចំនួន៨ម៉ឺន២ពាន់អង្គ**... ។

២២. សមមិត្ត តូច កឿន **ជារដ្ឋមន្ត្រីសង្គមកិច្ច** (ទំព័រ៤៤៨) គួរកែតម្រូវថា តូច កឿន **ជារដ្ឋមន្ត្រីក្រសួង សាធារណការ** ។

២៣. សមមិត្ត កុយ ធួន **ជាមេបញ្ជាការសឹកតំបន់ទី៣០៤** (ទំព័រ ៤៤៨) គួរកែតម្រូវថា សមមិត្ត កុយ ធួន ជា**លេខាគណៈកម្មាធិការបក្សភូមិភាគ៣០៤**។

២៤. សមមិត្ត សោ - យ៉ាន់ ហៅ ភឹម ដែលធ្វើជាលេខាគណៈកម្មាធិការបក្សនៅ**តំបន់បូព៌ា** នៃប្រទេសកម្ពុជា (ទំព័រ៤៤៨) គួរកែតម្រូវថា នៅ**ភូមិភាគបូព៌ា**...។

២៥. បានប្រព្រឹត្តទៅនៅក្រោមពាក្យស្លោកថា “ **កាលណាមានស្រូវអង្ករ គឺនឹងមានអ្វីៗទាំងអស់!** ” ( ទំព័រ៤៤៩ ) គួរកែតម្រូវថា “ **មានស្រូវ គឺមានអ្វីៗទាំងអស់!** ” ។

២៦. នៅថ្ងៃទី១០ ឧសភា កងកម្លាំងប៉ុល ពត បានវាយឡើងលើ**កោះថូជៀវ** ( ទំព័រ៤៥០ ) គួរកែតម្រូវថា **កោះថូ ចូវ** ( Thổ Châu ) ខ្មែរហៅថា **កោះក្រចកសេះ** ។

២៧. ការបោះឆ្នោតទូទៅ ដែលបានប្រព្រឹត្តទៅ**នៅខែមីនា - ឧសភា** ឆ្នាំ១៩៨១ ( ទំព័រ៤៦៨ ) គួរកែតម្រូវថា **នៅថ្ងៃទី១ ខែឧសភា** ឆ្នាំ១៩៨១។

២៨. ការតស៊ូរបស់ប្រជាជននៃ**ប្រជាជនកម្ពុជា** ដើម្បីសេរីភាព ( ទំព័រ៤៩៣ ) គួរកែតម្រូវថា ការតស៊ូរបស់ប្រជាជន**នៃប្រជាជាតិកម្ពុជា** ។

**សូមអរគុណ!**

